គ្រប់គ្រងដោយគណៈកម្មាការ
COMMISSION DES LIVRES & COUTUMES

ព្រះធម្មសុន្ទរិយា


ទស្សនាវដ្តី ផ្សាយចំណាំងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ៣៤ លេខ ១ ខែមករា

ព.ស. ២៥០៤ គ.ស. ១៩៦២

- ភ្នំពេញ -



ភ្នំពេញសិក្ខា

ទស្សនាវដ្តី ផ្សាយខាងសាសនា ទំនៀមអក្សរសាស្ត្រ
ចេញរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
–	វិសាខបូជា	១
–	លោកុត្តរកិរិយាមួយ (ត) អ្នកឧកញ៉ា ទា-សាន អតីតរដ្ឋមន្ត្រីរៀបរៀង	៦
–	ព្រះអភិធម្មបិដក (គម្ពីរព្រះយមកៈ) (ត) លោកឃ្មួ-ប៊ុំ ប្រែរៀបរៀង	១៤
–	មធុរសៈវាហិណី(ត)សម្តេចព្រះធម្មលិទ្ធិតស្ងី-ឯម ប្រែ ព្រះញាណកោសលញ-ឈឺនតិន្ត	២៤
–	មហោសធជាតក(ត)លោក អឹម-កន ជម្នះពីសាស្ត្រាស្ងឹកនឹងព្រះពុទ្ធវង្ស កឹម-ឆ្លុះ តិន្ត	៣០
–	អំពីទង់ពុទ្ធសាសនា លោក ជឹង-វង រៀបរៀង	៣៤
	ផ្នែកអក្សរសាស្ត្រ	
–	វប្បធម៌ខ្មែរ (ត) លោក លី-ធាមតេង រៀបរៀង	៤២
–	ពាក្យខ្មែរប្រែចេញពីបរទេស (ត) ដោយគណៈកម្មការវប្បធម៌	៤៧
–	វចនានុក្រមសំស្ក្រឹតខ្មែរ (ត) ព្រះមហា ជាំង-ខាត់ រៀបរៀង	៤៨
–	រឿងសាមកុក (ត) ឧកញ៉ា ន ហន ប្រែ	៤៩
–	រឿងត្រែងចិន (ត) លោក ក័យ ប៊ុក ប្រែរៀបរៀង	៦២
–	ភ្នំមិសាស្ត្រសេដ្ឋកិច្ចអាហ្វ្រិកខាងត្បូង លោក ញ៉ែម-ទឹម ប្រែ	៧៣
	ផ្នែកកំណត់ទំនឹងប្រវត្តិការណ៍	
–	អនុស្សាវរីយ៍មហាសន្និបាតនៃមន្ត្រីសង្ឃលើកទី ១៨ លោក ជឹង-វង រៀបរៀង	៨៦

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជា ២៣០រ០០

34è Année — N° 1 — Janvier 1962

KAMBUJASURIYA

Revue mensuelle de culture religieuse et littéraire publiée par l'Institut-Bouddhique de Phnom-Penh

SOMMAIRE

Partie religieuse page

— Editorial 1
— Lokkuttara Bhisamaya par l'Oknha TEA-SAN (suite). 6
— Prah Abhidhamma pitaka (Kampi prah Yamaka) (suite) par M. BOU-PO. 14
— Madhurasavahini (suite) traduit par Samdech Prah Dhammalikhita LOUIS-EM, revu et corrigé par Vén NHEAN-CHHOEUN. 24
— Mahosatha Jataka (suite) relevé du manuscrit sur feuilles de latanier par M. IM-PHON, revu et corrigé par Vén. KEM-TO 30
— Le drapeau bouddhique par M. THANG-VONG 38

Partie Littéraire

— La culture khmère (suite) par M. LY-THEAM-TENG . . 42
— Activités de la Commission culturelle (suite) 47
— Dictionnaire Sanscrit-Khmèr (suite) par Vén. PANG-KHAT 48
— Histoire de Sam-Kok (suite) traduite par l'Oknha NOU-KAN 49
— Légendes populaires de la Chine par M. RAY-BUC . . 62
— Géographie économique de l'Afrique du Sud traduite par M. NHEM-KHEM 77

Notes et Chroniques

— 18ème Réunion annuelle des Dignitaires religieux par M. THANG-VONG 86

Abonnement annuel (comprenant 12 numéros) : 230 ſ 00

. . . . . .
. ពាក្យយោគមិនឲ្យ ធ្វើការអាក្រក់ .
. ជាការលាមក ឲ្យធ្វើល្អទៅ ។ .
. ឲ្យដុំសខាត់ចិត្ត កុំឲ្យហ្មងសៅ .
. នេះឯងលោកហៅ ពុទ្ធសាសនា ។ .
. . . . . ច.ព. . . . . .

វិចារណកថា

ពួកពុទ្ធបរិស័ទ សូមរួបរួមសាមគ្គីគ្នា
ដើម្បីញុំាងព្រះពុទ្ធសាសនា ឲ្យល្អតលាស់ចំរើន

ព្រះពុទ្ធបរមគ្រូ មុនទីឆ្នាំបរិនិព្វានទៅ ព្រះអង្គទ្រង់បានផ្តែផ្តាំពុទ្ធបរិស័ទចាំង ៤ ពួកគឺ ភិក្ខុ - ភិក្ខុនី - ឧបាសក - ឧបាសិកាថា ព្រះពុទ្ធសាសនាដែលទីឆ្ងាំចំរើនរុងរឿងបាន ឬ វិនាសសាបសូន្យទៅវិញនោះ អាស្រ័យមកអំពីពុទ្ធបរិស័ទចេះរួបរួមគ្នា ឬមិនចេះរួបរួមគ្នាគោរពប្រតិបត្តិតាមព្រះបរមភុំក្នាក់ដែលព្រះអង្គបានត្រាស់សំដែងទុក ដែលចែកចេញជាធម្មក្ខន្ធមាន ៨ ម៉ឺន ៤ ពាន់ព្រះធម្មក្ខន្ធ ដូចពុទ្ធបរិស័ទបានជ្រាបបានចេះដឹងមកគ្រប់សព្វអស់ហើយ ។

ទៅប្រទេសកម្ពុជាយើងនេះ ប្រជាពលរដ្ឋខ្មែរសុទ្ធតែកាន់ព្រះពុទ្ធ-

សាសនាស្ទើរតែតាំងអស់ តាំងច្បាប់រដ្ឋធម្មនុញ្ញ នៃព្រះរាជអាណាចក្រ
កំពុងគំរាមកំហែងព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ ហើយពុទ្ធបរិស័ទ
គ្រប់ជាន់ថ្នាក់ ជាន់តាំគ្នាគោរពប្រតិបត្តិមកអស់កាលជាច្រើនសតវត្សរ៍
ណាស់មកហើយផង ។ ពួកពុទ្ធបរិស័ទនាសម័យបច្ចុប្បន្ននេះ តាំងបព្វជិត-
តាំងគ្រហស្ថភាគច្រើនណាស់ ដែលបានខំប្រឹងប្រែងរៀនសូត្រតាមព្រះ
ពុទ្ធឧភនេះ ដើម្បីនឹងបានជាប្រទីបធ្វើរបំភ្លឺមើលច្បាប់ខុសត្រូវ ដែលខ្លួន
ត្រូវប្រតិបត្តិឲ្យបានហ្មត់ចត់ ។

តាមការសង្កេតរបស់ក្រសួងធម្មការយើញថា សព្វថ្ងៃនេះមានពួក
ពុទ្ធបរិស័ទខ្លះ មិនត្រមរួបរួមសាមគ្គីគ្នា ដើម្បីញុំាងព្រះពុទ្ធសាសនា
ឲ្យរីកចំរើនរុងរឿងឡើយ ។ ច្រើនតែនាំគ្នាប្រតិបត្តិដោយកាន់ច្រឡំ
ប្រកាន់អស្មិមានៈ ឆក់ហេតុបន្តិចបន្តួចមកជាសេស នាំបង្កឲ្យគេជា
អធិករណ៍ធំដុំឡើង នាំប្រកាន់ថា ពួកគេ ពួកយើង ហើយរកវិនិច្ឆ័យ
ផ្តល់តីគ្នាឯង ដែលជាពុទ្ធបរិស័ទដើរវាក្តាជាមួយគ្នា រកតិះដៀលមិន
យើញ ។ គោរះបីកដកាមុខក្រសួងសម្រុះសម្រួលឲ្យរួបរួមគ្នាយ៉ាងណា
ក៏ដោយ នៅតែមិនត្រមទួលរួបរួមគ្នាជាដាច់ខាត ប្រកាន់យកត្រូវ
តែតាមចំណុចក្បួនរៀង ។ ខ្លួន ។ ការមិនរួបរួមសាមគ្គីគ្នាបែបនេះ នាំឲ្យ

ពុទ្ធបរិស័ទចំណុះដើងវត្តនោះ ខ្ញុំលផលអាក្រក់ច្រើនប្រការដោអាទិ៍តី:

- នាំឲ្យថោកគាបសាបសាប បើផ្ទឹមទៅនឹងភិក្ខុបរិស័ទចំណុះដើងវត្តឯទៀត ដែលគេមានសាមគ្គីធម៌រួបរួមគ្នា ។

- ធ្វើបុណ្យទានម្តង ។ មិនបានពុងរឿងល្អ ឬអាក់ខានធ្វើមិនកើតផងក៏មាន ដោយបណ្តាលមកតែបក្សពួកដំទាស់គ្នាទៅវិញទៅមក ។

- នាំឲ្យបង់ទាក្រចាក់ការ ទាកពេលធ្វើបវេកស៊ីដោយសារតែទាស់ខែនឹងខ្វែងគំនិតមិនស្របយោបល់គ្នា ប្តឹងផ្តល់តីគ្នា ។

- កុដិ . វិហារ . សាលា ដែលមានហើយចេះតែចាក់បែក ចាស់ទ្រុឌទ្រោមគ្រាំគ្រា ដែលមិនទាន់មាន ក៏ចេះតែគ្មានហួតទៅជាលំដាប់ ព្រោះទុកាសមិនបើកឲ្យជួសជុល-ឲ្យស្ថាបនាឡើងកើត ។

- គ្រហស្ថ-បព្វជិត ដែលត្រូវគោរសេក្សាព្រះបរិយត្តិធម៌ ព្រះពុទ្ធ-វចនៈរបស់ព្រះពុទ្ធបរមគ្រូ ដើម្បីឲ្យបានចេះដឹងជ្រៅជ្រះនោះ ក៏អាក់ខានពេលរៀនសូត្រមិនកើត ព្រោះខ្វះការសប្បាយទាំង៤យ៉ាងគឺ: សេនា-សនសប្បាយ, ធម្មសប្បាយ, បុគ្គលសប្បាយ ឧទ្ធ័អាហារសប្បាយ ។ ម្ល៉ោះហើយបព្វជិត-គ្រហស្ថ អ្នកសិក្សារៀនសូត្រ ក៏រវាតយ៉ាតចាកការរៀនសូត្រអស់ មកទំប្រឹងរៀនឯការចាក់រុកបុកម្នាក់គ្នា . ទំប្រឹងប្តឹងផ្តល់

ព័ន្ធយកឈ្នះ-ចាញ់ ដែលជាអំពើឥតប្រយោជន៍ឯណោះវិញ ។

- កាលបើកុដិ . សាលា . វិហារ . សាលារៀនមិនគ្រប់គ្រាន់ហើយ តម្រូវដើម្បី . ក្សួនខ្ចាតខាងព្រះពុទ្ធសាសនា នឹងអ្នកចេះដឹងនូវព្រះពុទ្ធវចនៈ ជ្រៅជ្រះក៏មិនមានជាច្រើនដ ។ កាលបើគ្មានអ្នកចេះដឹងព្រះពុទ្ធវចនៈ គឺព្រះពុទ្ធសាសនាដែលជាទំនៀមរបស់ព្រះពុទ្ធបរមគ្រូហើយ . ព្រះពុទ្ធ-សាសនានឹងវិនាសសាបសូន្យទៅឯង មិនអាចបិតរវៀរកាលដកជជង់ ៥០០០ ព្រះវស្សាបានឡើយ ហើយគេអាចចាត់ពុទ្ធពុទ្ធបរិស័ទពួកក្រុមនោះថា ជាអ្នកញ៉ាំងព្រះពុទ្ធសាសនាឲ្យចូលកន្លងផុតវិនាសសាបសោចមិនឲ្យសូតសាស់ចំរើនឡើងបាន ។

ពុទ្ធបរិស័ទនាំងឆ្ងាយ !

ផលអាក្រក់ដែលបណ្តាលមកពីការបែកសាមគ្គី ដូចបានរៀបរាប់សង្ខេបមកខាងលើនេះ យើងជាអ្នកកាន់ព្រះពុទ្ធសាសនាគួរត្រិះរិះពិចារ . ណាឲ្យហ្មត់ចត់ គួរកុំប្រកាន់គ្នា កុំឈ្លោះពាស់ពែងគ្នារវាងពុទ្ធបរិស័ទគ្នាឯង ព្រោះសេចក្តីប្រតិបត្តិយ៉ាងគ្នាបន្តិចបន្តួច តប្បីតែអត់សង្កត់សង្កោសគ្នា យោគយល់គ្នាទៅវិញទៅមកជាដរាប ដើម្បីបណ្តុះសាមគ្គីធម៌ឲ្យកើតមានឡើង ។ កាលបើសេចក្តីសាមគ្គី គឺការត្រមេត្រៀងគ្នាកើតមាន

ហើយ កិច្ចការគ្រប់ដំណើរក្នុងវត្តអារាម ក៏ចេះតែមានសកម្មភាពប្រព្រឹត្តទៅជាំ.ជាប់ ។ កាលបើកិច្ចគ្រប់ដំណើរក្នុងវត្តអារាមបានចំរើនហើយ ព្រះពុទ្ធសាសនាក៏នឹងបានចំរើនលូតលាស់ជាំ.ជាប់ទៅដែរ ។ អាយុកាលនៃព្រះពុទ្ធសាសនា ក៏មានដំណើរបើតថែរចើរកាលរហូតដល់ទ្រាំ.ពាន់ព្រះវស្សា ឬច្រើនលើសពីនេះទៅទៀតក៏បានឡើយ ។

ក្រសួងធម្មការ មានសេចក្តីសង្ឃឹមយ៉ាងម៉ាំ.ថា ពុទ្ធបរិស័ទនឹងចេះពិចារណាកែការខុសត្រូវ ហើយចេះរួបរួមគ្រួតជៃគ្នាថែរក្សាព្រះពុទ្ធសាសនា ឲ្យបានធំធីតែតែចំរើនរុងរឿង លែងមានអធិករណ៍រវាងព្រះសង្ឃនឹងព្រះសង្ឃ, ព្រះសង្ឃនឹង ឧបាសក.សិកា ឬឧបាសក.សិកា នឹង ឧបាសក.សិកាជូចគ្នាតទៅទៀតមិនបាន ។

ភាគទី ៤

អ្នកឧកញ៉ា ធា-សាន អតីតរដ្ឋមន្ត្រី រៀបរៀង

(តពីលេខ ១១ ឆ្នាំ ១៩៦១)

ការត្រាស់ដឹងមគ្គ ៤ ផល ៤ និងនិព្វាន

ព្រះអនាគាមីអង្គនោះ កាលបើបានដឹងច្បាស់នូវអរូបភពនោះហើយ ក៏រំពឹងពិចារណាគិតឃើញថា អរូបភពនេះ ក៏មិនមែនជាភពប្រកបដោយបរមសុខ គួរឲ្យមានចិត្តច្រណែនតិចតួចនោះទេ បើដូច្នេះឃើញថាមានតែអរហត្តមគ្គ និងអរហត្តផលនោះទេ ដែលអាចនាំមកនូវបរមសុខ គឺសុខយ៉ាងសុខុមក្រៃលែងគ្មានទោសគ្មានទុក្ខ ។

កាលបើព្រះអនាគាមី រំពឹងគិតឃើញយ៉ាងដូច្នេះហើយ លោកក៏ដំកល់ចិត្តឲ្យតាំងនៅជាកណ្តាលធ្វើព្រងើយកន្តើយ មិនអើពើចំពោះអរូបភព: មានន័យដូច្នេះ ឲ្យច្បាស់រឿយ ។ លុះត្រាតែខន្ធសន្តានរលឹងហួតស្ងួតចាកខន្ធភ្លាតិយតាំង ៣ នោះអស់ទៅ ដែលជាហេតុនឹងនាំព្រះអនាគាមីឲ្យលះសំយោជនៈបាន ៩ នៅសល់តែអវិជ្ជា ១ ទៀតទេ ។

អាស្រ័យហេតុនេះ ទើបព្រះអនាគាមីចាំរើនអាកិញ្ចញ្ញាយតនជ្ឈានដែលមានវត្ថុយ៉ាងល្អិតក្រៃលែង ស្ទើរតែមិនមានវត្ថុជាអារម្មណ៍រឿងកប

ដកហ លុះត្រាតែបានសម្រេចនូវអរូបជ្ឈានចិត្តទី ៣ ដូចមានលក្ខណៈតទៅនេះ ។

៣ រីឯអរូបជ្ឈានចិត្តទី ៣ ដែលសម្រេចកើតមានឡើងនេះ ជាអរូបជ្ឈានចិត្តប្រព្រឹត្តទៅកន្លងនូវនិមិត្ត គឺនិមិត្តជាគ្រឿងសំគាល់នូវសភាពដែលគ្មានអ្វីបន្តិចបន្តួចសោះ ពោលគឺកន្លងសភាពដែលគ្មានអ្វីសំគាល់ថាជាសំយោជនៈ ដែលជាហេតុនឹងញាំងព្រះអនាគាមីឲ្យលះអវិជ្ជាគឺសេចក្តីល្ងង់ដែលជាសមុដ្ឋាននៃសំយោជនៈ ៩ ខាងដើមនោះ ជាចំស្រឡះដោយសមុច្ឆេទប្បហានៅខណៈនោះៗ ។

ដោយអានុភាពនៃការលះអវិជ្ជាជាចំស្រឡះ ដោយសមុច្ឆេទប្បហាន, ព្រះអនាគាមីកំបានសម្រេចនូវបញ្ញាវិសុទ្ធិ គឺសេចក្តីបរិសុទ្ធិនៃបញ្ញានៅខណៈនោះជាលំដាប់ខ្មៅត ។

បន្ទាប់អំពីនោះ ព្រះអនាគាមីត្រូវចំរើននូវសញ្ញាសញ្ញាយតនជ្ឈានដែលមានសញ្ញាយ៉ាងល្អិតក្រៃលែង ស្ទើរតែមិនមានសញ្ញាជាអារម្មណ៍ឲ្យបានរឿយ ។ ដកហលុះត្រាតែបានសម្រេចនូវអរូបជ្ឈានចិត្តទី ៤ ដូចមានលក្ខណៈតទៅនេះ ។

៤ – រីឯអរូបជ្ឈានចិត្តទី ៤ ដែលសម្រេចកើតមានឡើងនេះ ជាអរូបជ្ឈានចិត្តប្រព្រឹត្តទៅកន្លងសុញ្ញានិមិត្ត គឺនិមិត្តជាគ្រឿងសំគាល់នូវ

សភាពដែលសូន្យទទេគ្មានអ្វីសោះ គេហៅថាសូន្យគ្មានសំយោជនៈ ដែលជាហេតុទាំឲ្យព្រះអនាគាមីបានសម្រេចនូវវិមុត្តិវិសុទ្ធិ គឺសេចក្តីចរិសុទ្ធិនៃការរួចចាកសំយោជនៈដោយទិស្សរណវិមុត្តិ គឺរួចចាកដោយការលាស់ចេញផុតទៅអស់ហើយ ។

ដោយអានុភាពនៃការសម្រេចនូវបញ្ញាវិសុទ្ធិ ទើបវិមុត្តិវិសុទ្ធិ ព្រះអនាគាមីក៏បានត្រាស់ដឹងនូវអរហត្តមគ្គ គឺមគ្គចិត្តទី ៤ ដែលលះសំយោជនៈ ១០ ដាច់ស្រឡះដោយសមុច្ឆេទប្បហាន ទើបបានសម្រេចនូវអរហត្តផល គឺផលចិត្តទី ៤ ដែលរួចចាកសំយោជនៈ ១០ ដោយទិស្សរណវិមុត្តិ, បានឈ្មោះថាជាព្រះអរហន្ត គឺជាអរិយបុគ្គលដែលផ្ងាយចាកកិលេសទើបជាអរិយបុគ្គល ដែលបានទៅដល់ដំណាក់ចុងបំផុតនៃផ្លូវ ដែលនាំដំណើរឆ្ពោះទៅកាន់និព្វាន គឺបរមសុខនោះ ។

ឯមគ្គចិត្តទី ៤ ទើបផលចិត្តទី ៤ នេះ គឺជាចិត្តតាំងនៅក្នុងសុខុមាលសុខរួចផុតស្រឡះចាកកំដៅក្តៅក្រហល់ក្រហាយ, សេចក្តីអន្ទះអន្ទែងទើបសេចក្តីស្រេកឃ្លានចង់ស្រើបស្រាលត្រេកត្រអាល ក្នុងវិជ្ជមង្សរទៀតហើយដែលជាហេតុទាំឲ្យព្រះអរហន្តអាចដោះខ្លួនឲ្យរួចផុតពីតណ្ហា ៣ ប្រការ ។

សរុបសេចក្តីទៅយើញថា ព្រះអរហន្តអង្គនេះ ទំពាំងបានត្រាស់

ដឹងអរហត្តមគ្គ នឹងអរហត្តផល ត្រូវចំពោះយោមបំពេញតបធម៌ផ្សេង។ រៀនតាមលំដាប់ដូចតទៅនេះ៖

១- ជានចំរើនបឋមជ្ឈានកុសល ដែលជាហេតុនាំឲ្យលោកជានសម្រេច អប្បនាសមាធិ ។

២- ជានចំរើនវិបស្សនាភាវនា ដែលជាហេតុនាំឲ្យលោកលះសំយោជន: ៣ គឺសក្កាយទិដ្ឋិ, វិចិកិច្ឆា, សីលព្វតបរាមាស នឹងនាំឲ្យជានសម្រេចសុទ្ធិ គឺសេចក្តីបរិសុទ្ធិ ៩ ប្រការ មានទិដ្ឋិវិសុទ្ធិជាដើម ដើម្បីត្រាស់ដឹងសោតាបត្តិមគ្គ នឹងសោតាបត្តិផល ។

៣- ជានចំរើនឧបរិមជ្ឈាន នឹងទុតិយជ្ឈាន ដែលជាហេតុនាំឲ្យលោកលះអង្គវិតក្ក: នឹងវិចារ: នឹងនាំឲ្យចិត្តសង្ហរនៃពេជ គឺសេត់អស់ទៅ ដើម្បីត្រាស់ដឹងសកទាគាមិមគ្គ នឹងសកទាគាមិផល ។

៤- ជានចំរើនតតិយជ្ឈាន នឹងចតុត្ថជ្ឈាន ដែលជាហេតុនាំឲ្យលោកលះកាមរាគ: បដិឃ: នឹងនាំឲ្យជានសម្រេចចិត្តវិសុទ្ធិ គឺសេចក្តីបរិសុទ្ធិនៃចិត្ត ដើម្បីត្រាស់ដឹងអនាគាមិមគ្គ នឹង អនាគាមិផល ។

៥ - ជានចំរើនរូបជ្ឈាន ៤ ដែលជាហេតុនាំឲ្យលោកលះទុក្ខម្ចាតិយ-សំយោជន: ៥ នឹងនាំឲ្យលោកជានសម្រេចបញ្ញាវិសុទ្ធិ នឹងវិមុត្តិវិសុទ្ធិ ដើម្បីត្រាស់ដឹងអរហត្តមគ្គ នឹងអរហត្តផល ។

ម្យ៉ាងទៀតទៀត ដោយកម្លាំងអានុភាពនៃការសម្រេចនូវរូបជ្ឈាន ៤ នឹងអរូបជ្ឈាន ៤ នោះ ព្រះអរហន្តត្រូវបានសម្រេចនូវអភិញ្ញា ៦ ទៀត គឺ ឥទ្ធិវិធៈ ចេះសម្តែងឫទ្ធិផ្សេង ។ មានចេះទៅមកតាមផ្លូវអាកាសជាដើម ១, ទិព្វសោតៈ គឺមានត្រចៀកទិព្វ ១, ចេតោបរិយញ្ញាណ ចេះកំណត់ដឹងចិត្តអ្នកដទៃ ១, បុព្វេនិវាសានុស្សតិ ចេះរលឹកនឹកឃើញជាតិពីអតីតកាល ១, ទិព្វចក្ខុ គឺមានភ្នែកទិព្វ ១, ឧដ្ឋាសវក្ខយញ្ញាណ ចេះធ្វើអាសវៈឲ្យអស់ ១ ។

រីឯអភិញ្ញា ៦ នេះ គឺជាវិជ្ជា ៦ ដែលមានកើតឡើងក្នុងបណ្តាវិជ្ជា ៨ នោះឯង ។

៥- ការត្រាស់ដឹងលោកុត្តរធម៌ ៩ គឺឯកាទ

ឯកាទ គឺបរមសុខមាន ២ ប្រការគឺ៖

ឧបាធិសេសនិព្វាន គឺបរមសុខរួចផុតចាកភ្លើងកិលេស ១,

អនុបាធិសេសនិព្វាន គឺបរមសុខរួចផុតចាកភ្លើងទុក្ខ ១ ។

មានតែព្រះអរហន្តដែលបានសម្រេចមគ្គ ៤ នឹងផល ៤ រួចស្រេចហើយនោះទេ ដែលអាចនឹងត្រាស់ដឹងនូវនិព្វានទាំង ២ ប្រការនោះបាន ក៏ប៉ុន្តែទុបាទិសេសនិព្វាន ជាសច្ចិកតធម៌ គឺធម៌ដែលត្រូវអរហន្តគប្បីធ្វើឲ្យជាក់ច្បាស់ប្រាកដឡើង ទើបអាចនឹងត្រាស់ដឹង នូវទុបាទិសេស-

ទិព្វាន គឺបរមេសុខរួចផុតចាកកំដៅភ្លើងកិលេសទោះបាន ។

ដើម្បីនឹងបំភ្លេចការណ៍ឃើញកន្លងនេះ ព្រះអរហន្តអគ្គនោះ ក៏ស្ទង់ស្មារ
ចំពោះនូវអនុបស្សនា៣ប្រការគឺ សុញ្ញតានុបស្សនា, អនិមិត្តានុបស្សនា, នឹង
អប្បណិហិតានុបស្សនា ដើម្បីតាំចាណាបញ្ចាក់ឲ្យដឹង តើអរហត្តផល
គឺផលចិត្ត ដែលខើបនឹងរួចចាកសំយោជន: ១០ នោះ បានតាំងស្ថិតនៅ
ក្នុងវិមោក្ខ គឺកង្វល់រួចចាកកិលេស ៣ ប្រការហើយឬនៅ ? ។

កាលបើព្រះអរហន្តអគ្គនោះបានតិចាណា សង្កេតដឹងច្បាស់ដោយ
ចិត្តញាណទស្សនៈថា អរហត្តផលនោះ បានតាំងនៅស្ថិតក្នុងវិមោក្ខ ៣
ប្រការគឺ:

- សុញ្ញតវិមោក្ខ គឺការរួចផុតចាកកិលេស ព្រោះសូន្យគ្មាន
កិលេសសោះ ១ ,

- អនិមិត្តវិមោក្ខ គឺការរួចផុតចាកកិលេស ព្រោះគ្មានអ្វីជា
គ្រឿងសំគាល់ថាកិលេសសោះ ១ ,

- អប្បណិហិតវិមោក្ខ គឺការរួចចាកកិលេស ព្រោះគ្មានអ្វី
ជាទីតាំងនៅនៃកិលេសសោះ ១ ,

តិតិ្តកជាកាលណាហើយ គឺនៅខណៈនោះហើយដែលគប្បីសន្និ-
ដ្ឋានថា ព្រះអរហន្តអគ្គនោះបានធ្វើទិព្វានសច្ចកិរិយា ពោលគឺបានធ្វើ

កិរិយាជាក់ព្សាស់នៃនិព្វានឲ្យកើតមានច្រើនដងឡើងហើយ ពីព្រោះវិមោក្ខ ៣ ប្រការនោះ ជាគ្រឿងសំគាល់ថា ក្លើងកិលេសលេត់អស់ពីខន្ធសន្តានទៅហើយ ។ គឺនៅខណៈជាមួយគ្នានោះហើយ ដែលព្រះអរហន្តអង្គនោះបានត្រាស់ដឹងទុជាទិសេសនិព្វាន គឺបរមសុខ រួចពាក់ក្លើងកិលេសនោះឯង ។

ចាប់តាំងពីពេលដែលព្រះអរហន្តអង្គនោះ បានសម្រេចនិព្វានគឺបរមសុខក្នុងបច្ចុប្បន្នកាលណាហើយ ព្រះអរហន្តអង្គនោះ ត្រូវបានខួលនាមថ្មី២ទៀតគឺ នាមជាព្រះខីណាស្រព គឺជាអ្នកអស់អាសវៈហើយ ទំនងនាមជាព្រះអរសក្ខៈ គឺជាអ្នកអស់ការសិក្សា ពោលគឺគ្មានអ្វីត្រូវលះ ឬត្រូវបំពេញតទៅទៀតឡើយ ។

តែប៉ុន្តែ ព្រះខីណាស្រពពុំបានតង់សម្រាកនៅស្ងៀមទំនេរជាដរាបដែរ ដូនកាលគេឃើញព្រះខីណាស្រពអង្គនោះ តង់ក្បែនសម្ងំនៅស្ងៀមត្រងើយហាក់ដូចតំពុងស្មឹងស្មាធិ៍មិនដឹងខ្លួនអ្វីសោះ ។

ក្រែងតំរិយាបថនេះ គេអាចសំគាល់ដឹងថា ព្រះខីណាស្រពតំពុងបណ្តែតអារម្មណ៍ ពោលគឺបណ្តែតអរហត្តផលឡើងកាន់តែខ្ពស់ទៅកន្លងវិមោក្ខ ៣ ប្រការដែលជាហេតុនាំឲ្យព្រះអង្គអាចតាំងនៅក្នុងចិត្តសង្ខារ ទំនងកាយសង្ខារនិរោធ គឺកន្លងកិរិយារលត់នៃសញ្ញាទំនងវេទនា ព្រមទាំងរួលដកដង្ហើមចេញចូលអស់រយៈពេលជាច្រើនថ្ងៃទើបភ្ញាក់ដឹងខ្លួនឡើងវិញ ។

ចំពោះអរិយាបថដ៏ចម្រូងនេះ គប្បីសំគាល់ថា ព្រះអរហន្តអង្គនោះ កំពុងចូលកាន់និរោធសមាបត្តិ ។

បទានុក្រម ត្រង់ភាក្យនិរោធសមាបត្តិថ្លាប់ថា ព្រះអរហន្តអាចស្ថិតនៅក្នុងនិរោធសមាបត្តិ យ៉ាងយូរបានត្រឹមតែ ៧ ថ្ងៃទេ ។

បើសង្កេតតាមដំណើរហេតុដូចមានខាងលើនេះ គេអាចដឹងថាតិរៀមក្ខ ៣ ដែលព្រះអរហន្តបន្សាត់អរហត្តផល គឺផលចិត្តទី ៤ ឲ្យជ្រុតធ្វើជាវិហារសមាបត្តិ សម្ងំនៅជាបរមសុខនោះហើយ ដែលហៅថានិរោធសមាបត្តិ ពីព្រោះក្រៅពីតិរៀមក្ខ ៣ ប្រការនោះ ពុំមានអារម្មណ៍ឯណាដទៃទៀត ដែលអាចឲ្យអរហត្តផលចិត្តប្រកបដោយបរមសុខធ្វើជាវិហារសមាបត្តិជ្រុតសម្ងំនៅបានឡើយ ។

ព្រះអរហន្តអង្គនោះ រមែងតែចូលកាន់និរោធសមាបត្តិដូច្នេះ ជារឿយ ។ នៅក្នុងចន្លោះពេលខំនេរៀងពីបដល់អាយុក្សយមកដល់វេលាណា ទើបលោកលំសត់អាយុសង្ខារចូលកាន់អនុបាទិសេសនិព្វាន គឺបរមសុខដែលរួចផុតស្រឡះចាកភាំងកើងកំលេសនិងកើងខន្ធ ហើយដែលជាហេតុនាំឲ្យព្រះអរហន្តអង្គនោះ បានសម្រេចនូវអាសាទជាតិ គឺជាតិជាទីបុងក្រោយបំផុត ធ្វងចេញរួចផុតចាកវ័ត្តសង្សារ រមែងត្រឡប់មកអន្លង់លិលកើតស្លាប់ក្នុងវ័ត្តកពេទៀតហើយ ។

(នៅមានត)

ព្រះអភិធម្មបិដក

គម្ពីរព្រះយេមកា:

លោក ប៊ូ - ប៊ូ ប្រែរៀបរៀង

(តពីលេខ ១១ ឆ្នាំ ១៩៦១)

ខន្ធយមកា:

ឥធាធិ ម្ហូលយមកេ ទេសិតនយេនេវ កុសលា-ធិធម្មោ ខន្ធវសេន សង្គហ្ហិតត្តា ម្ហូលយមកានន្តរំ ទេសិតត្តា ខន្ធយមកស្ស វណ្ណនា ហោតិ ។

ភាវៈនេះ សូមវិសជ្ជនាកថាខន្ធយមកៈតទៅ ដំណើរសេចក្តីថា *វណ្ណនា* ការពណ៌នាកែខន្ធខ្លួនយមកៈ ដែលសម្តេចព្រះមហាមុនីទ្រង់សង្គ្រោះខ្លួនជាមិត្តដ៏ឆ្ងាយ មានកុសលធម៌ជាអាទិ៍ ដោយអំណាចជាភ្លុកជាកង់គ្នា តាមន័យដែលព្រះមានព្រះភាគជាម្ចាស់ត្រាស់ទេសនាក្នុងម្ហូលយមកៈ ហើយត្រាស់សំដែងក្នុងម្ហូលយមកៈជាលំដាប់នោះ រមែងមានប្រាកដក្នុងកាលឥឡូវនេះ ។

ឥមស្មិំ ខន្ធយមកេ ក្នុងខន្ធយមកៈនេះ មានភាវៈ ៣ គឺ បញ្ញត្តិភាវៈ ១ បវត្តិភាវៈ ១ បរិញ្ញាភាវៈ ១ ។ បណ្ណាភាវៈទាំង ៣ ប្រការនោះ ភាវៈណាប្រព្រឹត្តទៅដោយអំណាចនៃការជម្រះ ខ្លួវឈ្មោះនៃខន្ធ

ពាំងឡាយ ក៏រនោះឈ្មោះថា បញ្ចក្ខន្ធក៏រ ។ ឯបវត្តិក៏រ ជាឧដ្ឋល់
ការដែលត្រាស់ទេសនាប្រត្រឹត្តទៅ ដោយអំណាចកើតនឹងលេត់ខន្ធ
ពាំងឡាយ នូវបរិញ្ញាខន្ធពាំងឡាយដ៏ប្រត្រឹត្តទៅដោយលំដាប់ដូច្នេះ ។

ក្នុងខន្ធយមកនេះ ព្រះភ្នំឧដ្ឋគ្រែងត្រាស់ទេសនានូវខន្ធពាំងឡាយច្រាំ
ប៉ុន្តែគ្រែងត្រាស់ទេសនាបុព្វជាគួ ។ ត្រាស់វិសជ្ជនាជាគួ ។ គ្នា គឺត្រាស់
ទេសនានូវរូបក្ខន្ធ, វេទនាខន្ធ, សញ្ញាខន្ធ, សង្ខារក្ខន្ធ, វិញ្ញាណក្ខន្ធ ។

ខន្ធពាំងច្រាំនោះ គ្រែងត្រាស់បុព្វជក្នុងរូបក្ខន្ធជាមុនថា យំកិញ្ចិ
រូបំ រូបក្ខន្ធ តើកន្លងនៃរូបនោះ ឬ ឈ្មោះថា រូបក្ខន្ធ ?

មានភាក្យអធិប្បាយថា បើយរូបំ សាតរូបំ រូបដែលបុគ្គល
គប្បីស្រឡាញ់ ជាទីស្រឡាញ់ ជាទីត្រេកអរនោះ ឈ្មោះថារូបក្ខន្ធមែន
ឬទេ ? រូបក្ខន្ធពាំងពួងនោះឈ្មោះថា រូបក្ខន្ធ មែនឬទេ ?

ព្រះគ្រែងត្រាស់បុព្វជដូច្នេះហើយ ទើបគ្រែងត្រាស់វិសជ្ជនាថា បើយ.
រូបំ ក៏ រូបជាទីស្រឡាញ់ ទឹងជាទីត្រេកអរក្តី ចូរលើកទុកចុះ មហាភូត.
រូបបួន ទឹងទុកជាយរូបម្ភៃបួនក្តី កំសង្គ្រែងចូលក្នុងរូបក្ខន្ធ ។ នោះឯង
ឈ្មោះថា រូប ។ នោះឯងឈ្មោះថា រូបក្ខន្ធ ។

ក្នុងវេទនាខន្ធនោះ គ្រែងត្រាស់បុព្វជថា វេទនាតើការសោយ
អារម្មណ៍នោះ ឈ្មោះថាវេទនាខន្ធមែនឬទេ ? គ្រែងត្រាស់វិសជ្ជនាថា

អាមន្តា អើ! តើវេទនានោះឯង ឈ្មោះថា វេទនាខន្ធ ។ នោះឯង ឈ្មោះថា វេទនា ។

កាលសញ្ញាខន្ធទ្រង់ត្រាស់ប្តូរថា សញ្ញានោះឬឈ្មោះថា សញ្ញាខន្ធ? សញ្ញាខន្ធនោះឬឈ្មោះថា សញ្ញា? ទើបទ្រង់ត្រាស់វិសជ្ជនាថា អាមន្តា អើ! សញ្ញានោះឯងឈ្មោះថា សញ្ញាខន្ធ ។ នោះឯងឈ្មោះថា សញ្ញា ។

កាលសង្ខារក្ខន្ធ នឹងវិញ្ញាណក្ខន្ធ ព្រះពុទ្ធអង្គទ្រង់ត្រាស់ប្តូរនឹងវិសជ្ជនាជាគូ ។ ត្រា ដូចន័យដែលសំដែងហើយក្នុងរូបក្ខន្ធ ។

ខន្ធទាំង ៥ ប្រុំមានរូបក្ខន្ធជាដើម អ្នកប្រាជ្ញតម្រិះពិចារណាឲ្យឃើញដោយឧបមាថា ខន្ធទាំង ៥ ប្រៀបដូចជាសឹកសត្រូវដែលមានជាវគ្គ ៥ លើកជាខ្មៅង នឹងប្រៀបដូចជាវត្ថុសម្រាប់ចំពាមបរិភោគ ។ ម្យ៉ាងទៀត តម្រិះពិចារណាឲ្យឃើញថា បញ្ចក្ខន្ធមិនទៀង, ជាទុក្ខ, មិនមែនជារបស់ខ្លួន ព្រោះហេតុបច្ច័យ គឺកុសលនឹងអកុសលតាក់តែងឡើង ខេះរោលដោយសង្ខេបលុះតម្រិះពិចារណាឃើញដោយ ៣ ។ ឥន្ទ្រាវតោ បនេត្ថ បើនឹងរោលដោយពិស្តារ ក្នុងបញ្ចក្ខន្ធនោះគឺ

រូប ប្រៀបដូចដុំខែតភុះទឹក,

វេទនា ប្រៀបដូចក្រពេញទឹកដែលផុសច្រួច ។ ឡើងពីខ្សែទឹក,

សញ្ញា ប្រៀបដូចត្រីភ្លាថ្ងៃ ឬហៅថា ថ្ងៃបណ្តើរកូន,

សង្ខារ ប្រៀបដូចដើមចេក ,

វិញ្ញាណ ប្រៀបដូចល្បែមាយា ឬមានតុតត្បុត ។

មិណ្ហោ មាំ ធិសប្បាកេ ឯវំ មែនតែ រាងកាយនេះ ឥតខ្វល់សោះសោះ ព្រោះមិនខ្មៅងាត់ មិនមាំមួន ។ ឯរាងកាយនេះ បុគ្គលនឹងយកមកធ្វើជាការងារសម្រាប់ដាក់ត្បូងពួន គឺធ្វើជាចាន, ជាឆ្នាំង, ជាថូ, ជាការមិនកើត ។ ន សោភេតិ រាងកាយនេះ មិនបានសម្រស់ប្រយោជន៍អ្វីសោះ រមែងបែកខ្ចាត់ខ្ចាយទៅ យ៉ាងណា ។ ន សក្កា តហេតុំ បុគ្គលណាមួយមិនអាចនឹងកាន់យកថាជារបស់ខ្មៅងាត់, ថាជារបស់មាំមួន នឹងសំគាល់ថាជារបស់ខ្លួនក៏មិនបាន ។ តស្មាតិហ សម្បីបុគ្គលនឹងចាប់កាន់រាងកាយនេះ ក៏ចាប់មិនបាន មិនតស់ទៅកន្លែងដៃ តែងបែកខ្ចាយសាបសូន្យអស់ទៅយ៉ាងណា ។

រូបំ សត្តាំ រូបកាយរបស់មនុស្សសត្វទាំងឡាយនេះ មិនខ្មៅ, ជាទុក្ខ. មិនមែនជារបស់ខ្លួន ក៏មានទុបមេយ្យយ៉ាងនោះ ។

ម្យ៉ាងទៀត រាងកាយនេះ ជាចំណែកតូចៗ ធំៗ ជាប់គ្នា ។ គ្នាច្រើនដំណាលឡើង ទៅជាលំនៅរបស់សត្វតិតទាំងឡាយមានត្រីជាដើម យ៉ាងណា ។ ឯរូបំ រូបកាយនៃមនុស្សសត្វទាំងឡាយក៏ជាចំណែកតូចៗ ធំៗ ជាប់គ្នា ។ គ្នាជាច្រើនដំណាល ក៏ជាទីអាស្រ័យនៅនៃសត្វទាំងឡាយមានជង្ឃវាជាដើម មានទុបមេយ្យយ៉ាងនោះដែរ ។ អសីតិកិមិ-

ក្បាលដំ ត្រកួលនៃដងខ្លួនវាតាំងពីឆ្អាយ ៨០ ត្រកួល រមែងមកអាស្រ័យនៅក្នុងរូបកាយនេះ ។ រូបកាយនេះ ជាទីកើត ចាស់ ឈឺ ស្លាប់ ជាទីជាំធាតុកន្ទុងដុតដងខ្លួនវាតាំងអស់នោះ ។ អញ្ញត្ត អាកង្ខា ហូរដងខ្លួនវាតាំងអស់នោះ មិនមែនមកអំពីទីឯណាទេ ប្រាកដជាកើតមាននៅក្នុងរូបកាយនេះឯង ។

ដេណាុបិណ្ឌោ ច ប្រការមួយទៀត ដុំពពុះទឹកនោះមុនដំបូងប៉ុនស្លឹកពុទ្រា លុះយូរទៅប៉ុនកំពូលភ្នំ ចេះតែចំរើនធំឡើង ។ តាមលំដាប់ដូចម្តេច ។ អាធិតោ កាលសមត្តំ រូបនេះចាប់ផ្តើមមុនដំបូងប៉ុនដំណក់ប្រេងល្ងាកលល: លុះយូរទៅក៏ចំរើនធំឡើង ។ តាមលំដាប់មានឧបមេយ្យដូច្នោះ ។

ប្រការមួយទៀត ដុំនៃពពុះទឹកនោះ តាំងជាំធំឡើងហើយអណ្តែតទៅជល់ផ្ទៃនៃមហាសាគរ ក៏រមែងបែកធ្លាយទៅជាប្រាកដដូចម្តេច ។ កាលលុកភ្លេច សូម្បីរូបនេះចាប់ផ្តើមមុនដំបូងជាកលលៈ ហើយប្រែក្លាយទៅជាអម្ពុ: ជាជេសិ (ដុំសាច់) ទៅតាមលំដាប់ បើមិនបានរលត់រលាយរូបនេះទេ ចេះតែចំរើនធំឡើងរហូតដល់ប្រសូតចាកផ្ទៃមាតាហើយរស់នៅយូរឆ្នាំទៅទៀត ។ បើពុកជារូបនេះរស់នៅយូរឆ្នាំ ក៏មិនលើសពីមួយរយឆ្នាំដែរ តនឹងរលត់រលាយទៅតាមរូបនេះទៅវិញជាមិនខាន ហេតុនេះ បានជារោគប្រៀបរូបកាយទៅនឹងដុំពពុះទឹក ។

វេទនាខន្ធ ប្រៀបដូចក្រពេញទឹក(១) ។ ជម្មតាក្រពេញទឹកនោះ បុគ្គលចាប់ជាក់ក្តីបាតដៃមិនបានទេ សូម្បីយកកាជនៈអ្វី ។ ទៅដួសក៏មិនបានដែរ គ្រាន់តែបះតាល់ភ្លាមរលត់រលាយបាត់ទៅ ដូចម្តេច ។ វេទនាខន្ធ កដ៏នៃវេទនា គឺការសោយអារម្មណ៍នេះ មានឧបមេយ្យដូចក្រពេញទឹកនោះដែរ ។

ពិតណាស់វេទនាខន្ធនោះ ទោះបីកើតជាទិច្ចឥតអាក់មានវិលាណាក៏ជាការមិនទៀងទាត់ តែងប្រែប្រួលផ្លាស់ប្តូរជាធម្មតា គឺថា បុគ្គលបានសោយអារម្មណ៍ជាសុខហើយ មិនមែនចេះតែបានសុខនោះជាប់បិតរហូតមិនកាលទៅទេ តង់មានពេលខ្លះឬថ្ងៃខ្លះផ្លាស់ទៅសោយទុក្ខវិញ កាលបានទុក្ខហើយ មិនមែនចេះតែបានទុក្ខរហូតទៅទេ តង់មានវិលាបានសុខវិញ ។ សុខនឹងទុក្ខតែងផ្លាស់ប្តូរគ្នាជាវេនដូច្នេះ បានជាលោកប្រាប់ថាវេទនាមិនទៀងទេ ។ នេះនិយាយចំពោះតែមនុស្សម្នាក់ ។ បួនកាលបានសុខ, ដួនកាលបានទុក្ខ ។ សោមនស្សក្តី ទោមនស្សក្តី ឧបេក្ខាក្តី កំតែងប្រែប្រួលផ្លាស់ប្តូរគ្នា ដូចជាសុខទុក្ខនេះដែរ ។

ឧប្បជ្ជន្តិ ចេវ ឯវុប្បជ្ជន្តិ ច វេទនានោះរមែងកើតឡើងហើយរលត់ទៅវិញ រលត់ទៅហើយត្រឡប់កើតឡើងវិញ ចេះតែកើតហើយរលត់ ។ ហើយកើតដកបះទៅ កើតជាសុខខ្លះ ជាទុក្ខខ្លះផ្លាស់ប្តូរ

១- សំដៅយកទឹកដែលផុំព្រួចរា ពីក្រោមឡើងលើ ហៅក្រពេញទឹក, ដូចទឹកដែលគេដាំក្នុងឆ្នាំង ហើយផុំព្រួចរាឡើងលើមុនដំបូង ទើបកើតទៅជាពពុះបោងអណ្តែតខាងក្រោយ ។

ត្តា ដូចន័យខាងដើម ។ ឯវេទនាខន្ធតើតឡើងបានដោយអាស្រ័យ
ហេតុ ๔ ប្រការ គឺ៖

๑- វត្ថុជាទីតើត ,

๒- អារម្មណ៍ជាទីគោចរក្បាញ ,

๓- កិលេស ,

๔- ការខ្ជាំងខ្លប់ ឬបិះពាល់ ។

សញ្ញាខន្ធ ប្រៀបដូចត្រីញាថ្ម ព្រោះប្រាសចាកខ្លឹមសារ ។
ត្រីញាថ្មនោះ បើតើតឡើងហើយ គេក្រឡេកមើលពីចម្ងាយឃើញ
ហាក់ដូចជាមានរូបកាន់តួរនីនចាប់កាន់បាន សំឡឹងមើលដូចសណ្ឋាននៃ
ផ្ទះជាដើម លុះចូលទៅជិតហើយ ស្រាប់តែបាត់អស់ទៅ នីនចាប់កាន់
មិនបាន ដូចម្តេច សញ្ញាមានឧបមេយ្យដូច្នោះ ។

អបិច បរិវជ្ជនតិ ប្រការមួយទៀត ត្រីញាថ្មនោះតែងប្រែ
ប្រួលទៅផ្សេងៗ យ៉ាងណា សញ្ញាក៏ប្រែប្រួលយ៉ាងនោះដែរ ។ សញ្ញា
ខន្ធំ សោ ភិក្ខវេ សញ្ញាប្រៀបដូចរលកតើតឡើងក្នុងមហាសមុទ្រ តែង
ប្រែប្រួលទៅជាធម្មតា ។ រលកមិនដែលនីនទៅមួយកន្លែងយ៉ាងណា
សញ្ញាក៏តែងប្រែប្រួលយ៉ាងនោះដែរ ។

សង្ខារក្ខន្ធ ប្រៀបដូចដើមចេក ។ កក្ខឌលិខន្ធសទិសា
សង្ខារា សង្ខារទាំងឡាយ ប្រៀបដូចដើមចេក ព្រោះថាជាធម្មជាតិឥត

ខ្វឹមសារ ។ ឯ សត្ថោតិ បុគ្គលណាក៏មិនអាចយកខ្វឹមដើមចេក ទៅឈួសចាំធ្វើជារបស់អ្វីៗ បានដែរ ព្រោះដើមចេកនោះគ្មានខ្វឹមសោះ មានតែបណ្តូលខាងក្នុងប៉ុណ្ណោះ ។

សង្ខារក្ខន្ធខ្លាយនោះ បុគ្គលមិនអាចនឹងពោលថាជារបស់ខ្លឿងពាត់បានឡើយ ព្រោះថាសង្ខារធម៌ខ្លះ កុសលប្រគល់ឲ្យ, បច្ច័យតឹកុសលតាក់តែង ជួនកាលអកុសលប្រគល់ឲ្យ, បច្ច័យតឹអកុសលតាក់តែង ។ កាលបើកុសលតាក់តែង កំប្រកបដោយរូបកន្ធ ទ្រង់ទ្រាយឥណិសម្បុរដ៏ល្អស្រស់ គួរឲ្យចាប់ចិត្តស្រឡាញ់ ប្រកបដោយសីរសម្បត្តិបរិបូណ៌ដោយសរីរាណកទ្រព្យ ទីឆ៍អរីរាណកទ្រព្យ ជាច្រើនពាប់មិនអស់ ។

សង្ខារ បើអកុសលប្រគល់ឲ្យ តឹអកុសលជាបច្ច័យប្រជុំតាក់តែង កំមានរូបកន្ធអាក្រក់គួរឲ្យគេស្អប់ខ្ពើម ច្រាសចាតសីរៈនឹងឥណិសម្បុរ មានសរីរកវយៈជាទោស ទីឆ៍ជាមនុស្សកំសត់ទុគ្គត ជាមនុស្សអភ័ព្វទុព្វលភាព មិនជាទីស្រឡាញ់តេញចិត្តរបស់អ្នកណាម្នាក់ឡើយ ។ ហេតុនោះ ចានជាពោលថា សង្ខារក្ខន្ធខ្លាយមិនខ្លឿងពាត់ ឥតខ្វឹមសារ ឧបមាដូចជាដើមចេក ។

ឥមាវុដ្ឋបដ្ឋសមោជាតោ ដើមចេកជាទីប្រជុំនៃស្រទាបដ៏ច្រើនយ៉ាងណា ឥមាឆម្មសមោជាតោ សង្ខារធម៌នេះជាទីប្រជុំនៃធម៌តាំងខ្លាយដ៏ច្រើន យ៉ាងនោះ ។ ជាជាលក្ខណោ ដើមចេក

មានលក្ខណៈផ្សេង ។ គឺពណ៌ស្វាយ ខ្មៅពណ៌ស្រែខបខាងក្រៅបែបម្យ៉ាង, ពណ៌ខាងក្នុងបែបម្យ៉ាង មិនស្របគ្នាឡើយ ដេះមានឧបមាដូចម្តេច ។ សង្ខារក្ខន្ធមានលក្ខណៈផ្សេង។ គឺលក្ខណៈនៃផស្សៈផ្សេងពៅម្យ៉ាង, លក្ខណៈនៃចេតនាផ្សេងពៅម្យ៉ាង មិនត្រូវត្រង់គ្នា មានឧបមេយ្យដូច្នោះ ។

វិញ្ញាណំបិ មាយាសទិសំ ឯវិញ្ញាណក្ខន្ធ ប្រៀបដូចជាស្ត្រីមានមាយា ប្រកបដោយអាកប្បកិរិយាលួងលោមបញ្ឆោតបុរសឲ្យវង្វេងវិលវល់លះកាត់មិនដាច់ ។ អាកតោ វិយ កតោ ធ្វើអាការមកខ្មីងពៅ ហាក់ដូចជាពៅស្ថិតនៅជាប់ក្នុងចិត្តរបស់បុរស ។ ខ្មីងដេកដើរឈរអង្គុយក្តី ។ បើបុរសនោះបានជួបប្រទះខ្មីងស្ត្រីមាយា គឺពោលវាខ្មីងធ្វើអាកប្បកិរិយាជាហេតុញុំងចិត្តឲ្យកើតជម្រេកក្នុងស្ត្រីមាយានោះ ឲ្យវង្វេងស្មារតីពៅក្នុងស្ត្រីមាយានោះ ។

ទេយម្យ៉ាងទៀត វិញ្ញាណក្ខន្ធ នេះ ប្រៀបដូចនាយពាណិជប្រកបដោយមាយាច្រើនធ្វើពាណិជ្ជកម្ម មហាជំ វាណ្ជុតិ នាយពាណិជដែលមានមាយានោះ តែងនិយាយលួងលួនលោមបញ្ឆោតមហាជនឲ្យកាន់ច្រឡំដោយសំដីរបស់ខ្លួនថា ឥទំ វត្ថុំ អនឃ្ឃំ វត្ថុនេះ ខ្ញុំមិនលក់ឲ្យថ្លៃច្រើនគេកទេ តាលតាំដើមរកខ្ញុំញុំបានដាយ។ ឥឡូវនេះ បើពុកជាអ្នកមានជ្រាក់ច្រើន ក៏រកខ្ញុំញុំមិនបានដែរ ជារបស់ក្រមានហើយកាត់ថ្លៃមិនកើតផង គឺថាជារបស់ថ្លៃណាស់ ប៉ុន្តែ បើអ្នក

ចង់បានស៊ុតវិញខ្ញុំហើយ ខ្ញុំក៏គិតថាអ្វីដែរ ការត់ជិតលក់ដូនៗទៅចុះ ឱ្យមកខ្ញុំតែប៉ុណ្ណោះរៀល ឬប៉ុណ្ណោះរៀលល្មមហើយ តាមប្រាក់អ្នកមានគ្រោះជាអ្នកឆាប់លក់ដូរជួញគ្នា ។ អ្នកវិញឮសំដីដូច្នោះក៏ខឹងចិត្ត វង្វិនទៅទៅដោយយកពាមាយារបស់នាយតាណាំង ដៀតាមស្ទុះហើយ ក៏ចាប់កប់ប្រាក់ប្រគល់ទៅឱ្យនាយតាណាំង សេចក្តីនេះ មានឧបមាយ៉ាងណា ។ ឯវិញ្ញាណក្ខន្ធ ក៏ធ្វើអារម្មណ៍ឱ្យប្រាជ្ញដូចមកតាន់មនោគ្រាវៃថ្លៃ បះញ្ជោតចិត្តឱ្យមកខ្វល់អារម្មណ៍មានរូបជាដើមថា អារម្មណ៍នេះល្អ អារម្មណ៍នេះមិនល្អ មានឧបមេយ្យដូចនាយតាណាំងនោះដែរ ។

បណ្ឌិតចាំងឡាយ តប្បីយល់ឃើញថា អារម្មណ៍មានរូបជាដើមនេះមិនល្អទេ ។ ប៉ុន្តែ រូបចាំងពួងនោះល្អទៅតាមលោកសន្ទុតថាល្អយ៉ាំងណា ។ លុះដល់ជាតភាពចូលមកគ្រប់សង្កត់ហើយ ក៏លែងល្អ ។ បើគ្មានជាតភាពគ្រប់សង្កត់ទេ ក៏ឃើញហាក់ដូចជាល្អខ្លះដែរ ដោយសារគេទំនាក់តែងគ្រឿងអលង្ការ មានសំពត់អាវមេ្យវមៀតមាសពេជ្រជាដើម ។ តាមធម្មតា រូបគ្មានល្អត្រង់ណាសោះ ជារបស់ស្មោកគ្រោកគួរខ្ពើមអើម ព្រោះកើតមកអំពីជាតុដ៏ខឹកក្លិនឆ្អាប់ចាំងបួនប្រជុំគ្នា នេះពោលតាមបរមត្ថវេហារ ។ បើពោលតាមភាសាអ្នកស្រុកថា រូបមានល្អខ្លះ មានអាក្រក់ខ្លះ ។

(នៅមានត)

សម្តែបព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង

ព្រះញាណកោសល ញាណ-ឈ័ន ព័ន្ធ

(តព័លេ ១១ ឆ្នាំ ១៩៦៩)

១ - សហាយសប្ប បរិច្ចត្តដីវិតវត្ថុកថា

សំដែងរឿងទិជាន បុរសលះបង់ជីវិតដល់សំឡាញ់ ដោយភាវៈចាស់ថា: ភកវតិ បរិដិត្តេ ដូច្នេះជាដើម អធិប្បាយថា កាលព្រះមានព្រះភាគទ្រង់ចូលព្រះបរមនិព្វានរៀហើយ ក្រោយនោះមានព្រាហ្មណ៏តីរនាក់ មួយឈ្មោះសោមព្រាហ្មណ៏ មួយឈ្មោះសោមទត្តព្រាហ្មណ៏ នៅអាស្រ័យក្នុងនគរសាវត្ថីជាមួយគ្នា ។ ឯសោមព្រាហ្មណ៏ តែងលេងល្បែងចាស្ការស់ ជាមួយនឹងសោមទត្តព្រាហ្មណ៏ជាសំឡាញ់រឿយ ។ ។ អនេកាធិវាសំ មានវារមួយជាខាងក្រោយ សោមទត្តព្រាហ្មណ៏ចាន លេងឈ្នះសោមព្រាហ្មណ៏ ហើយដោះយកសំតត់បង់តអំតីស្មានឹងចិញ្ចៀន អំតីម្រាមដៃរបស់សោមព្រាហ្មណ៏នោះ កាលដែលនឹងត្រឡប់ទៅកាន់ផ្ទះវិញ គំនិយាយទៅនឹងសំឡាញ់ថា: ម្នាលសោមព្រាហ្មណ៏សំឡាញ់ អ្នកចូរមក យើងនឹងទៅកាន់ផ្ទះឥឡូវនេះឯង ។

លំដាប់នោះសោមព្រាហ្មណ៏ និយាយតបវិញថា អើ! សំឡាញ់

ខ្ញុំមានសំពត់សាដកតែមួយ ខ្ញុំពុំអាចនឹងចុះទៅកាន់ផ្លូវលំបានឡើយ, អំពើដែលខ្ញុំនៅក្នុងទីនេះ ប្រសើរជាងទៅដោយពិត ។

ឯសោមទត្តព្រាហ្មណ៍បានស្តាប់ហើយ ក៏និយាយថា អើ! សំឡាញ់ បើដូច្នោះត្រូវអ្នកកាន់យកសំពត់សាដកសំពប់ចង់កនេះ ដណ្តប់ហើយដើរទៅចុះ, លុះគោលយ៉ាំងនេះហើយក៏ឲ្យសំពត់សាដកនោះ ដល់សោមព្រាហ្មណ៍ជាសំឡាញ់នោះឯង ហើយនិយាយតឿនទៀតថា ម្នាលសំឡាញ់! អ្នកត្រូវមក យើងនឹងទៅកាន់ផ្ទះក្នុងកាលឥឡូវនេះឯង ។ ឯសោមព្រាហ្មណ៍ជាសំឡាញ់ក៏ពុំព្រមទៅសោះ, ខណៈនោះសោមទត្តព្រាហ្មណ៍បានសួរម្តងទៀតថា ព្រោះហេតុអ្វីបានអ្នកមិនទៅ? សោមព្រាហ្មណ៍ឆ្លើយថា ម្នាលសំឡាញ់! បានជាខ្ញុំមិនទៅ ដ្បិតមនុស្សជាបរិស័ទតាំងពាយមានកូនចៅនឹងប្រពន្ធជាដើម តែគេពុំយើញចិញ្ចៀនក្នុងដៃខ្ញុំហើយគេនឹងធ្វើជម្ងោះឈ្លោះទាស់ទែងនឹងខ្ញុំពុំលែងឡើយ ព្រោះហេតុដូច្នោះបានជាខ្ញុំមិនទៅ ។

កាលនោះ សោមទត្តព្រាហ្មណ៍ បាននិយាយនឹងសោមព្រាហ្មណ៍ថា ម្នាលសំឡាញ់អើយ! បើអ្នកមានប្រាថ្នាយ៉ាងណា ខ្ញុំនឹងឲ្យដល់អ្នកយ៉ាងនោះចុះ លុះនិយាយហើយ ក៏យកចិញ្ចៀននោះហុចឲ្យសោមព្រាហ្មណ៍ពាក់ញែកដូចដែល ហើយនាំគ្នាដើរទៅកាន់ផ្ទះរបស់ខ្លួនទីនៃ ។ ទៅ ។ ព្រាហ្មណ៍ពាំងពីរនាក់នោះ ក៏យកគ្នាជាមិត្តសំឡាញ់ដោយហេតុ

មានប្រមាណប៉ុណ្ណេះ កន្លងកាលនោះហោង ។

លុះកាលជាចំណែកខាងក្រោយ មនុស្សតាំងឡាយត្រូតគ្នាចាប់យកនូវសោមទត្តព្រាហ្មណ៍ថាន ព្រោះអំពើធ្វើបរទារកម្ម លួចប្រពន្ធគេ ហើយនាំយកទៅថ្វាយព្រះបរមក្សត្រិយ៍ ឲ្យទ្រង់កាត់សេចក្តីតាមច្បាប់សំរាប់បវេណីនគរ ។

ឯសម្តេចព្រះនរាធិបតីជាម្ចាស់ផែនដី លុះទ្រង់ជ្រាបនូវឃើញរូបសម្បត្តិនៃសោមទត្តព្រាហ្មណ៍ហើយ ព្រះអង្គពុំបានកាត់ទោសដល់ព្រាហ្មណ៍ឡើយ ព្រះអង្គគ្រាន់តែព្រះរាជទានដំបូន្មានថា ម្នាលព្រាហ្មណ៍ដ៏ចំរើន ! អ្នកកុំធ្វើអំពើយ៉ាងនេះទៀត ត្រូវអ្នកវៀរលែងឲ្យស្រឡះចេញ ហើយទ្រង់បញ្ជាឲ្យដោះលែងសោមទត្តព្រាហ្មណ៍នោះឲ្យត្រឡប់ទៅផ្ទះខ្លួនវិញ ។

ចំណែកសោមទត្តព្រាហ្មណ៍នោះ កំពុងបានវៀរលែងអំពើដែលខ្លួនធ្លាប់ធ្វើនោះឡើយ, នៅតែធ្វើជាដែល មនុស្សតាំងឡាយចាប់បានទាំងយកមកថ្វាយព្រះបរមក្សត្រិយ៍ជាគម្រប់ពីរដង បីដង ទ្រង់គ្រាន់តែបន្ទោសប្រដៅហើយដោះលែងទៅវិញដូចមុនទៀត លុះគេចាប់បានកន្លងវារៈជាគំរប់ ៤ ដងក៏នាំយកមកថ្វាយព្រះបរមក្សត្រិយ៍ទៀត ព្រះរាជាទ្រង់ក្រោធគំរោធខ្លាំងហើយ ត្រាស់បញ្ជាតួរពេជ្ឈឃាដថា អ្នកតាំងឡាយត្រូវចាប់ចងព្រាហ្មណ៍នោះទៅមាំ នាំយកទៅកាន់កន្លែងសំរាប់សំឡាប់មនុស្ស

ហើយសំឡាប់ក់ចោលឲ្យនាប់ទៅចុះ ។

ធម្មតាមនុស្សអ្នកត្រេកអរក៏តែងយកក្នុងចិត្តរកម្ម ដំណាមកយ៉ាងនេះ ពោះបើបុគ្គលខ្លួនប្រដៅដោយអាការច្រើនដូចម្តេចក្តី ក៏គង់តែពុំអាចនឹងហាមបុគ្គលដែលប្រព្រឹត្តណាមកនោះឲ្យកន្លងចាលបានឡើយ ។ ព្រោះហេតុដូច្នោះ បានជាព្រះគន្ធវេទាចារ្យលោកពោលជាបទព្រះគាថា ថា:

សោណា ចេវ សិង្គាលា ច កាយសា ឯលមត្តិកា
កុណបេ សន្តេ អច្ចន្តំ ន សន្តប្បន្តិ ឯសេធកំ
តថា ចាណាតិចារេសុ បរទារេ សុភយ ច
មុសាភណេសុ ថេយ្យេសុ តេ សត្តា ន ឯកវយា ។

អធិប្បាយថា: ពួកឆ្កែក្តី ពួកចចកក្តី ពួកឆ្កែកក្តី ពួករុយខៀវក្តី តែងត្រេកអរលង់ភ្លៅតែក្នុងសាកសព មានភ្នែចដំរីនឹងសេះជាដើម ដែលបុគ្គលមិនអាចនឹងឃាត់ហាមបាន មានឧបមាយ៉ាងណា, ជនអសប្បុរសពាលខ្លាយ ជាអ្នកត្រេកអរក្នុងអំពើសម្លាប់សត្វក្តី អំពើលួចប្លន់ទ្រព្យគេក្តី អំពើលួចប្រពន្ធគេក្តី អំពើពោលពាក្យកុហកបញ្ឆោតគេក្តី អំពើផឹកទឹកស្រវឹងគឺសុរានឹងមេរ័យក្តី ដែលបុគ្គលមិនអាចនឹងឃាត់ហាមបាន ក៏មានឧបមេយ្យយ៉ាងនោះឯង ។

ព្រោះហេតុដូច្នោះ សោមទត្តព្រាហ្មណ៍នេះ ជាអ្នកត្រេកអរតែក្នុងអំពើលួចប្រពន្ធគេ ព្រះបរមគ្រូយ៉ាងខ្ពង់ខ្ពស់ខ្លាំនឃាត់ហាមដោយពាក្យជាច

ច្រើនដង កំតង់ពុំព្រមរៀវលែងឡើយ នោះតែប្រព្រឹត្តទៅអំពើនោះដដែល ដោយតិត ។

លំដាប់នោះ ពួកបុរសតាំងឡាយចាប់ចងសោមទត្តព្រាហ្មណ៍យ៉ាងមាំ តាមព្រះពួកបញ្ជា ហើយនាំបណ្តើរយកទៅដើម្បីនឹងសំឡាប់ ។

គ្រានោះ សោមព្រាហ្មណ៍ជាសំឡាញ់ បានឃើញពួកបុរសតាំងឡាយ នាំយកសោមទត្តព្រាហ្មណ៍ទៅប្រុងនឹងសម្លាប់ដូច្នោះ ក៏មានដួងហឫទ័យញាប់ញ័រអាណិតគេពេកណាស់ បានចូលទៅកាន់សំណាក់ពួកបុរសមួយរំពេច ហើយអង្វរសូមឃាត់ថា បពិត្រលោកដ៏ចំរើន! សូមលោកតាំងឡាយកុំអាលសំឡាប់ព្រាហ្មណ៍នេះឡើយ រង់ចាំខ្ញុំក្រាបបង្គំទូលព្រះបរមក្សត្រិយ៍ សូមព្រះអង្គទ្រង់ជ្រាបសិន លុះសោមព្រាហ្មណ៍បានសូមអង្វរយ៉ាងនេះហើយ ក៏ចូលទៅគាល់ព្រះបរមក្សត្រិយ៍ ហើយស្ថិតនៅក្នុងទីសមគួរ ទើបលើកដៃប្រណម្យ ក្រាបបង្គំទូលសូមទោសថា បពិត្រព្រះសម្មតិទេព! សូមព្រះអង្គទ្រង់ព្រះមេត្តាប្រោសព្រះពួកជនដ៏វិតដល់សោមទត្តព្រាហ្មណ៍នេះផង, ប្រសិនបើព្រះអង្គមិនទ្រង់ព្រះមេត្តាប្រោសទេ ទ្រង់ច្រានចោលនឹងសំឡាប់ពិតមែន សូមព្រះអង្គសំឡាប់ខ្ញុំម្ចាស់ជំនួសវិញចុះ តាមសត្យវាចាព្រះពួកជហឫទ័យ ។

ព្រះភូមិន្ទ្រាធិបតីបរមក្សត្រិយ៍បានទ្រង់ព្រះសណ្តាប់ហើយ ស្តេចនោះស្ងៀមពុំមានព្រះបន្ទូលថាអ្វីសោះឡើយ ។

ឯកដបុរសគាំងឡាយ កំរោងលែងសោមទត្តព្រាហ្មណ៍ ហើយ
ចាប់ចងសោមព្រាហ្មណ៍ទាំងយកទៅសំឡាប់ក្នុងកាលនោះឯង ។

បពិត្រសប្បុរសគាំងឡាយដើម ! យើងគាំងឡាយគួរពិចារណាថា
សោមព្រាហ្មណ៍នោះ មានសន្ដានចិត្តកតញ្ញូកតវេទី អាចប្ដូរដើរតែបស់ខ្លួន
ដោះលែងសោមទត្តព្រាហ្មណ៍ ដែលមានគុណដល់ខ្លួនឲ្យច្រើនអំពីសេចក្ដី
ស្លាប់បាន ស្លាប់ដោយខ្លួនឯង នេះជាគុណអស្ចារ្យពន់ពេកណាស់ ។

ព្រោះហេតុដូច្នេះ ឋានជាមានភ្នំគាស៊ិតថា :

កតញ្ញុវេ ភាវមញ្ញាយ សន្ដោ ភោគេ មនុស្សកេ
ជីវិតំ ឧតវិ សោ ភោគេ សោមទត្តស្ស អត្ថជោ ។

អធិប្បាយថា មនុស្សណាមួយ កាលបើបានទឹកលើកន្លួ
ចបការគុណ ដែលអ្នកដទៃគេបានធ្វើដល់ខ្លួនហើយ ត្រូវតែធ្វើតបគុណ
វិញឲ្យដូចជាសោមព្រាហ្មណ៍ដែលបានលះបង់ដើរតែបស់ខ្លួន ឲ្យដល់
សោមទត្តព្រាហ្មណ៍ដែលមានគុណដល់ខ្លួនដូច្នោះឯង ។

ដោយអំណាចផលនៃសង្ឃដែលបានឲ្យដើរតែមានខោះ សោម-
ព្រាហ្មណ៍សោតកំបានអន្ទោលទៅកើតក្នុងស្ថានខ្វះលោកនាយ ស្ថិតនៅ
ក្នុងប្រាសាទមាសយ៉ាងធំដ៏ប្រសើរ មានស្រីទេពអប្សរមួយពាន់ ចោម
រោមជាយសបរិវារ សោយទុវែសម្បត្តិទិព្វដ៏មានសិរីសួស្ដី ក្នុងស្ថានសួគ៌
ខ្វះលោកនោះឯង ។

(នៅមានត)

មហោសធជាតក

លោក អ៊ឹម-កង បម្លែងពីសាស្ត្រាសូត្រតំ

ព្រះពុទ្ធវង្ស កឹម-ភ្ងរ តំខ្ញុំ

(តពីលេខ ១១ ឆ្នាំ ១៩៦-)

ទើបអាចារ្យតំង ៤ ទូលថា តិតក្រាកដណាស់ កុំបីអម្ចាស់
សន្ធិះសង្ឃ័យឡើយ, បើអម្ចាស់ពុំជឿ កំចូរអម្ចាស់ឲ្យហៅមហោសធ
ឡើងមក ហើយអម្ចាស់ដណ្តឹងខ្លួវអាថ៌កំបាំងថា តួរសំដែងថ្លែងក្រាបអ្នក
ឯណាប្រសើរ បើមហោសធពុំជាសត្រូវឡើយ កឹមហោសធក្រាបទូល
ថា តួរសំដែងក្រាបអ្នកនោះ ឈ្នះដូច្នោះ ។ ហោង, បើមហោសធ
ជាសត្រូវមែនតិតក្រាកដហើយ មហោសធនឹងក្រាបទូលថា ពុំតួរគប្បី
សំដែងក្រាបអ្នកដទៃ ក្រែងនឹងអាក្នាងឯងឡើយ អម្ចាស់នឹងជ្រាបថា
កាលគ្រាតឲ្យវាខេះក្រោកដពុំលែងឡើយ ហើយអម្ចាស់នឹងជឿយើងខ្ញុំថា
ក្រាបទូលតិតក្រាកដ ដោយដំណើរយើងខ្ញុំយល់នោះហោង ។ ព្រះបាទ
វិទេហរាជ ស្តេចស្តាប់ពាក្យអាចារ្យតំង ៤ ក្រាបទូលនូវប្រការអម្បាល
នោះហើយ កំដឿនទូលយកពាក្យនោះថា តាមដូច្នោះហោង, ឯកាធិ-
វាសំ មានកាលសម័យថ្ងៃមួយកូវ អ្នកប្រាជ្ញតំង ៤ នូវព្រះបរមពោធិសត្វ
មហាបុរសតែនវិសេស ឡើងទៅតាល់អង្គុយក្នុងដំហានមួយ សមគួរនឹង
អាក្នា, ទើបព្រះបាទវិទេហរាជបរមបពិត្រ មានព្រះបន្ទូលត្រាស់សួរថា

ទៃអាចារ្យតាំង ៤ អើយ! អញទើបចង់ដណ្តឹងខ្លួនអាចារ្យស្នាមួយមានឮដំ
បន្តបណ្តើតបញ្ចាសូត្រ ក្នុងវិសតិនិបាត ហើយស្តេចសូត្រខ្លួនគាថាខេះថា:
បត្តុបណ្ឌិតា សមាគតា បញ្ញោ មេ បដិភាតិ តំ សុណាថ
ឯតំ្ឌយមត្តំ បសំសិយំ ក កាសេ្តភិរិតរេយ្យ កុយ្ហមត្តិ ។

សេចក្តីថា: ម្នាលអ្នកប្រាជ្ញតាំង ៥ អើយ! ចូរអ្នកស្តាប់អញទើប
ដណ្តឹងខ្លួនប្រស្នាខេះ រឿងអ្នកជនតាំងពួយ គប្បីសំដែងខ្លួនអាចារ្យតួរតែះ
ដៀលក្តី ខ្លួនអាចារ្យសេរេសើរក្តី ខ្លួនអាចារ្យតាំងពួនក្តី តើគួរសំដែង
ថ្លែងប្រាប់អ្នកឯណា ? ។

សេដ្ឋគោ រឿងអាចារ្យសេនក: ស្តាប់ព្រះបន្ទូល សូវេណ្ឌឹង
អាចារ្យស្នាខ្លួនប្រកាអម្បាលនោះហើយ ត្រេកអរក្នុងចិត្តដ្បិតត្រូវទើនតំនិត
ហើយទើបទូលថា :

មហារាជ បពិត្រមហារាជអើយ! រឿយើងខ្ញុំតាំង ៥ ជាអ្នកប្រាជ្ញ
សឹងតិចារណាស្រេចប្រពៃដោយតួចិត្ត ។ ហើយ សូមអម្ចាស់ធ្វើយប្រ-
ស្នានោះជាមុនឲ្យច្បាស់ប្រាកដហើយ ដ្បិតព្រះអង្គជាអធិបតី ជាអម្ចាស់
នៃយើងខ្ញុំតាំងពួយ សឲ្យមើយើងខ្ញុំធ្វើយថ្វាយជាឯក្រោយព្រះអង្គវិញ ។

ព្រះបាទវិទេហរាជ ស្តាប់តាក្យអាចារ្យសេនក:ខ្លួនប្រកាអម្បាល
នោះហើយ ស្តេចខឹនធ្វើយប្រស្នា ហេតុស្តេចលោភក្តីកំលេសតណ្ហានៃ
អាត្មាហើយ មានព្រះបន្ទូលថា :

រីប្រពន្ធឯណា មានសីលប្រព្រឹត្តស្រគត់ស្រគំតន្ត្រីយ ស្រដាប់ប្រពៃ គឺអ្នកជាទៃលួចពុំបាន ដោយខ្លួសម្ចាស់លេស ដ៏លុះអំណាចចំណង់នៃប្តី សំឡាញ់តាប់ចិត្ត តាប់គួរថ្លែងសំដែងខ្លួវអាចដំនៀលក្តី ស្រដីសរសើរក្តីខ្លួសេចក្តីកំប៉ាំងពាំងពួនក្តី គួរតប្បីច្រាប់ប្រពន្ធនោះហោង ។ ស្តេចមានព្រះបន្ទូលដូច្នោះហើយ ស្តេចដណ្តើនទៅអាចារ្យសេនកៈថា តើព្រះស្តេងនឹងថ្លែងច្រាប់ខរណា ? ។

ទើបអាចារ្យសេនកៈទូលថា:

មហាភដអើយ! រីក្មេងឯណា តាប់ចិត្តជាពំនាក់សំណាក់បាន គួរតប្បីថ្លែងច្រាប់ក្មេងនោះហោង ។

លំដាប់នោះ, ព្រះមហាសត្រ មានព្រះបន្ទូលដណ្តើនអាចារ្យបុក្ខុសថា ព្រះស្តេងតើគួរថ្លែងច្រាប់ខរណា ? ។

ទើបអាចារ្យបុក្ខុសក្រាបទូលថា:

បពិត្រមហាភដអើយ! ជនប្តួន បើមានសីល ប្រព្រឹត្តស្រគត់ស្រគំតន្ត្រីយ គួរសំដែងច្រាប់ខ្លួវអាចដំនៀលក្តី អាចសេចក្តីកំប៉ាំងក្តី គួរតប្បីច្រាប់ប្តួនោះហោង ។

លំដាប់នោះ, ស្តេចដណ្តើនអាចារ្យកាមិទ្ធថា តើព្រះស្តេងគួរសំដែងច្រាប់ខរណា ? ។ ទើបអាចារ្យកាមិទ្ធក្រាបទូលថា:

បពិត្រមហាភដអើយ! បើក្មួនបានខន្ធិនចិត្ត ស្រគត់ស្រគំតន្ត្រីយ ពុំស្រដីឡេះឡោះ ពុំដែលមានមោះនឹងអាតុកឡើយ, គួរថ្លែងខ្លួវអាច

ដំណោះដំនៀលក្តី គួរសំដែងអំពើកំចាំងសេចក្តីគាំងឲ្យាយច្រាប់កូនខ្លោះ ហោង ។

លំដាប់នោះ, ព្រះមហាសត្វត្រដណ្តឹងអាចារ្យទៅខ្លួថា តើព្រះស្តេចគួរសំដែងច្រាប់នណា? ។ ទើបអាចារ្យទៅខ្លួក្រាបទូលថា:

បពិត្រមហាក សូត្រធំទុត្តមប្រសើរក្រៃលែងក្រស្តេចគាំង-ឲ្យាយអើយ! បើម្តាយនោះរក្សាព្យាបាលកូនខ្លោះហើយស្រឡាញ់តេញចិត្តវតអ្វីប្រៀបបាន តុំដែលស្រដីឲ្យរង្គើសចិត្តកូនខ្លោះឡើយ, បពិត្រអើយ! គួរគប្បីច្រាប់ម្តាយនោះហោង ។

កាលនោះ, ព្រះបាទវិទេហក សេ្តចដណ្តឹងអាចារ្យគាំង ៤ ឲ្យរើយដោយខ្លួនទីទៀ, សេ្តចជ្រាបសេចក្តីខ្លួប្រែការអម្បាលនោះហើយ សេ្តចដណ្តឹងពោធិសត្វថា ម្នៃមហាសថអើយ! បាយល់ដូចម្តេច? ទើបពោធិសត្វថ្លែងទូលដោយបទគាថា ដូចខ្លះថា:

កុយ្ហាស្ស ហិ កុយ្ហមេវ សាធុ
ន ហិ កុយ្ហស្ស បសជ្ជមាវិកម្មំ
អនិប្ផន្នាយ សហេយ្យ ឆវេ
និប្ផន្នត្ថោ យថាសុខំ កណោយ្យាតិ ។

ពោធិសត្វទូលថា: ទេវ បពិត្រព្រះកូមិន្ទខ្លួនខ្លួនទោ ព្រះបាទនាកយណ៌នវបតី ស្រីសម្តីទេវាសូត្រថ្លៃប្រសើរអើយ! រីក្តីតំចាំងឯណាប្រពៃ អ្នកច្រាប្តូរផងគាំងឲ្យាយ តុំដែលចែងចាយនិយាយច្រាប់អ្នកដទៃ

ក្រែនឯងអាត្មាឯងឡើយ បើអាចកុំជុំឯងនោះ ចានស៊ីខ្ញុំដូចគ្នាថ្ងៃ
ហើយ តប្បីស្រដីតាមដោយខ្លួនស្រណុកចិត្តហោង ។

ស្តេចស្តាប់ពាក្យតោធិសត្វខ្លួនខ្លួនប្រកាន់អម្បាលនោះហើយ ស្តេច
មានព្រះហឫទ័យនោះពុំសប្បាយ ស្ងប់សញ្ជប់ដាក់ព្រះខន្ធ្រា ពុំមាន
ព្រះបន្ទូលអ្វីតទៅទៀតឡើយ ។ សេនតេតា រអាចារ្យសេនកៈ កំ
រម៉ៃលម៉ើលព្រះកន្ត្រៃព្រះចុតវិទេហរាជ ។ ឯព្រះចុតវិទេហរាជ កំរម៉ៃល
ម៉ើលមុខអាចារ្យសេនកៈ ។

ព្រះបរមតោធិសត្វ ឃើញខ្លួនហេតុអ្នកតាំងអម្បាលនោះហើយ អ្នក
តតថា សមអាចារ្យតាំង ៤ ចានឡើងមកក្រាបទូលស្តេច រកចំបែកឲ្យជា
សត្រូវនឹងអញដូចអំពីមុនហើយ, ប្រស្នាអាចារ្យសេនកៈ កាលទៅសួរ
ជណ្តើងអញដោយខ្លួនសំមា ជាល្បិចលន់ខ្លួន ឥឡូវនេះនាំពាក្យនោះ
មកជាទោសវិញហើយ ។ បពិត្រអើយ ! រីព្រះចុតវិទេហរាជ ទើង
អាចារ្យតាំង ៤ ព្រមតាំងព្រះតោធិសត្វ លុះដណ្តើងប្រស្នាកំចុំងតាំង
អម្បាលនោះហើយ, ព្រះអាទិត្យកំអស្តង្គតងងឹតហើយ លោកឲ្យអុជប្រទីប
ភ្លើតាំងព្រះរាជមន្ទីរ, ទើបតោធិសត្វគិតក្នុងចិត្តថា នាំហៅកិច្ចព្រះមហា-
ក្សត្រ ទើងជាខុសខ្ញុំដូចម្តេច ។ គឺអញទើងដឹងតុំចានឡើយ, បើដូច្នោះ
ហើយ គួរអញចុះទៅឲ្យធាប់តាប់ហោង ។ តោធិសត្វគិតឃើញប្រកា
អម្បាលនោះហើយ ក្រាបថ្វាយបង្គំប្រណម្យលាព្រះមហាក្សត្រចុះចេញ

ទៅ ហើយគោធិសត្វអ្នកគិតថា អាចារ្យទាំង ៤ ស្រាយប្រស្នាព្រះមហា-
ក្សត្រ អ្នកខ្លះថាគួរច្រាប់ក្តើ, អ្នកខ្លះថាគួរច្រាប់ជួន, អ្នកខ្លះថា
គួរច្រាប់កូន, អ្នកខ្លះថាគួរច្រាប់ម្តាយ, រីឯចំពោះអាចារ្យទាំង ៤
នាក់នេះ គាត់ថាទស្រដីនិយាយគ្នាច្រាកដឯងមិនខេះឡើយ, រីឯខ្ញុំ
ខ្ញុំដឹងអំពើអ្នកទាំង ៤ នាថ្ងៃនេះឯងច្រាកដពុំលែងឡើយ ។ អ្នក
ច្រាជ្ញទាំង ៤ នោះ បើចុះអំពីតាល់ព្រះមហាក្សត្រអំពីមុនរៀងមក តែង
ទៅអង្គុយលើខ្នងអាងថាយ និយាយគ្នានៅខាងក្នុងព្រះពជ្រកំផង ហើយ
ទើបហួសទៅផ្ទះទើរៃ ។ ហោង, គោធិសត្វអ្នកគិតយល់ហេតុខ្លួនប្រកា-
អម្បាលនោះហើយ ទើបអ្នកប្រើប្រុសជាបរំពោរឱ្យយកកំពាលមកក្រាល
ក្រោមអាងថាយនោះ ហើយគោធិសត្វចូលទៅក្រោមអាងថាយ ហើយផ្តាំ
ខ្លួនប្រុសនោះថា បើអាចារ្យទាំង ៤ ហួសចុះទៅ ព្រះស្តេចមកបើក
យកអញចេញអំពីក្រោមអាងនោះ ប្រុសជាបរំពោរស្តាប់តាស្យគោធិសត្វ
ដូច្នោះហើយ ប្រុសនោះក៏ថយឆ្ងាយចេញទៅចាំឃ្លាំមើល ដូចបណ្តាំ
គោធិសត្វផ្តាំនោះហោង ។ សេចក្តោ រីអាចារ្យសេនកៈយល់គោធិ-
សត្វទៅហើយ ក្រាបទូលថា មហាភាគ បពិត្រមហាភជអើយ !
អម្ចាស់មិនដឿតាស្យយើងខ្ញុំ ឥឡូវនេះច្រាកដមែនដូចយើងខ្ញុំទូលឬទេ ?
ព្រះបាទវិទេហភជ ស្តាប់តាស្យអាចារ្យសេនកៈទូលបំបែកដូច្នោះហើយ
ស្តេចពុំបានតិចារណាឡើយ ក៏តិតតិយ ស្តេចជណ្តើរទៅអាចារ្យសេនកៈ

ថា អាចារ្យសេនកៈអើយ ! ឥឡូវនេះ យើងនឹងធ្វើម្តេច ? ។ អាចារ្យសេនកៈក្រាបទូលថា ម ហាក ជ តបត្រមហាកជអើយ ! តំនិតនេះ មិនគួរឲ្យអ្នកជខៃដ៏ឆ្លាតដល់តិចឡើយ កុំបង្អង់លង់ឡើយ, យើងខ្ញុំនឹងសម្លាប់កូនគហបតីឲ្យស្រឡះជ្រះមនុស្ស ដ្បិតវាជាសត្រូវនឹងព្រះអង្គ ។ ស្តេចស្តាប់ពាក្យអាចារ្យសេនកៈទូលដូច្នោះហើយ ស្តេចចាប់ព្រះទាន់ហូតហុចទៅអាចារ្យសេនកៈ ហើយមានព្រះបន្ទូលថា ម៉ៃអាចារ្យសេនកៈអើយ ! អ្នកឯណាជខៃ នាំហៅនឹងចងឲ្យប្រយោជន៍ដល់អញនេះ : ឥតអស្ចារ្យមានឡើយ, មានតែព្រះស្តេចឯង ចូរព្រះស្តេចយកទូរជាវរោះទៅ ហើយព្រះស្តេចប្រើបុរសឯណាស្ទុះទុកចិត្តស្មើនាក្នុងព្រះស្តេច ហើយព្រះស្តេចផ្តាំថា ឲ្យកាន់ជាវរោះទៅ ហើយព្រះស្តេចប្រើបុរសឯណាមួយឈរខាងលង្វែកមាត់ទ្វារ ហើយបើមហាសថបុត្រគហបតីចេញពីមាត់ទ្វារ ខ្ញុំនឹងមកបំរើអញត្រឹកនេះហើយ ចូរអ្នកចាំនឹងឲ្យឃាត់ឃាត ឃាតក្បាលមហាសថ នាំឲ្យមកថ្វាយអញនាត្រឹកនេះឯងហោង ។ (តេ ធម្មោ ភ ឧស្សិតា) រីអ្នកបណ្ឌិតចាំង ៤ ក្រាបថ្វាយបង្គំប្រណម្យទូលថា ឆេវ បតិត្រមហាកជអើយ ! កុំព្រះអង្គព្រួយព្រះកជហឫទ័យឡើយ យើងខ្ញុំចាំង ៤ នឹងសម្លាប់មហាសថថ្វាយព្រះអង្គ, ហើយអាចារ្យចាំង ៤ លាចុះទៅអំពីព្រះកជមន្ទីរ ទៅអង្គុយលើខ្នងអាសនៈថ្វាយនោះ ទើបអាចារ្យសេនកៈស្រែកថា ឥឡូវនេះ ខ្ញុំនៃខ្ញុំសត្រូវយើងយល់

ហើយ ម្នាលគ្រហបតីនែ៎ ! យើងសម្លាប់កូនគហបតីនេះឲ្យបាន លុះនៅដោយប៉ុណ្ណេះយើងហោង ។ អាចារ្យទាំង ៣ ធ្វើជាកោតខ្លាចអាចារ្យសេនកៈហើយស្រដីថា មានតែអម្ចាស់ឯងនែ៎ទើបតតែការឆ្ងន់នេះបាន ។ ឮដំណាលនោះ អាចារ្យសេនកៈដណ្តើងទៅអាចារ្យទាំង ៣ ថា ការអ្នកខ្លួលព្រះមហាក្សត្រថា អាថ៌កំបាំងសំដែងប្រាប់កូន, ប្រាប់ប្អូន, ប្រាប់ម្តាយ, តឡប្តីនេះ ហានស្មានតែអ្នកឯណាទើបបានឮដល់មួយរឡែយ, តែយើងទើងសំដែងប្រាប់គ្នាឲ្យបានដឹង, ទើបអាចារ្យទាំង ៣ ស្រដីថា ចូរអ្នកសំដែងមុនទើបអាចារ្យសេនកៈថា អាថ៌កំបាំងនេះ បើមហាសព៌ដើងហើយ សមនឹងពាក្យនេះទៅខ្លួលស្តេច ។ ជ្រាបហើយ រីដំរៃនៃខ្ញុំតតអង្គីមានឡែយ ។ អាចារ្យទាំង ៣ ថា ហៃអាចារ្យអើយ ! កុំបីខ្លាចឡែយ នាបីហៅថានឹងបែកនៃក្តីកំបាំងឮចេញភ័ហានេះតតអង្គីមានឡែយ, ចូរអ្នកថ្លែងប្រាប់មកហោង ។ អាចារ្យសេនកៈគោះខ្លួចាតអាងបាយនោះនឹងក្រចកថា ក្រែងកូនគហបតីមកលបតួននៅក្រោមបាតអាងបាយនេះ ។ រីអ្នកប្រាជ្ញទាំង ៣ ស្រដីថា ហៃអ្នកអាចារ្យអើយ ! កូនគហបតីនោះកំអួតតិចតួចអ្វី មិនគួរគប្បីនឹងមកចូលនៅក្រោមហានមានសភាតដូច្នេះឡើយ នៅលើតស្លាសេម្បត្តិនោះ តាត់នឹងមករកអ្វីនៅក្រោមនេះ ចូរអ្នកថ្លែងសំដែងខ្លួចាអាថ៌កំបាំងនោះកុំបារម្ភឡែយ ។

(នៅមានត)

អំពីធង់ពុទ្ធសាសនា

លោក ជង-ឯង រៀបរៀង

តាំងពីព្រះសម្មុខបរមគ្រូ ទ្រង់បរិនិព្វានទៅ ពុំទាន់មានប្រទេស
ជាពុទ្ធសាសនិកណាមួយ ឋានផ្តើមបង្កើតធង់ពុទ្ធសាសនាឲ្យមានរូបរាង
ឡើងជាពិតប្រាកដ ដូចកន្លែងប្រពៃណីឯទៀតៗ នោះទេ ។

លុះដល់ថ្ងៃអង្គារ ៦ កេីត ខែជេស្ឋ ឆ្នាំកាលទោស័ក ព.ស.២៤៨៦
ត្រូវនឹងថ្ងៃទី ៦ ខែមិថុនា គ.ស. ១៩៤០ ទេីបពុទ្ធិកប្រទេសចាំង ២៨
មានប្រទេសស្រីលង្កាជាដេីម ឋានបង្កើតពុទ្ធិកសមាគមពិភពលោក
ហេីយឋានធ្វេីសន្និសីទលេីកទី ១ នៅប្រទេសស្រីលង្កា ដែលគណៈ
ប្រតិភូខ្មែរយេីង មានសម្តេចព្រះមហាសុមេធាធិបតី (ជួន-ណាត)
ជាតញ្ញាណា សង្ឃមាយកគណៈមហានិកាយជាប្រធានទៅរួមប្រជុំផង
ឋានមូលមតិគ្នា បង្កើតធង់ពុទ្ធសាសនាឡេីង ហៅថា " ធង់ពុទ្ធិកសមាគម
ពិភពលោក " តាមលក្ខន្តិកៈនៃសមាគមៈនេះ ដែលមាន ២៧ មាត្រា,
ត្រង់មាត្រាទី ២៦ ចែងថា ៖

" ធង់របស់ពុទ្ធិកសមាគមពិភពលោក ជាធង់មានពណ៌ ៦ តម្រៀ

ទឹងទត្តិឈ្មោះថ្លៃ បេះសំព្រះសម្ពុទ្ធជាម្ចាស់ ទុកជាមូលដ្ឋានតាមគំរូដែលក្រុមប្រឹក្សាប្រតិបត្តិការបានធ្វើហើយ" ។

៧ ដូច្នេះ ពន់ភុទ្ធសាសនា កំពុងប្តូរឡើងជាស្ថាពរតាំងពីកាលនោះមក ។

ពន់ភុទ្ធសាសនា មាន ៦ ពណ៌នោះគឺ: ១- ខៀវ, ២- លឿង, ៣- ក្រហម, ៤- ស, ៥- ហាងឬទាង (ជម្ពូទីដូចដើងហង្ស), ៦- ផ្កែក (ពន្លឺពេជ្រ) = (គឺគេយកពណ៌ទាំង ៥ មានដើមមួយ ។ មកដាក់បញ្ចូលគ្នាក្នុងថ្នាំង ទី ៦ នេះ ជា ១ ពណ៌) ។

ព្រះបរមលោកនាថ ព្រះអង្គមានវស្សា ៦ ពណ៌ផ្សាយចេញពីព្រះវរកាយយ៉ាងនេះ ដោយលទ្ធផលនៃកានបរមត្ថបារមី ដែលព្រះអង្គបានសាងមកពីអតីតភពយ៉ាងមហាស្ចារ្យ ហើយដែលមិនអាចអ្នកណាមួយធ្វើដូចព្រះអង្គបាន ។

ឯវស្សីមួយ ។ ជាដំណាងព្រះជាតិមួយ ។ គឺ:

១- វស្សីពណ៌ខៀវ: ជាដំណាងព្រះអង្គ កាលទ្រង់សោយព្រះជាតិជាព្រះបាទស្រីតកស្តេ ។ កាលនោះ ព្រះអគ្គមហេសីបានឱនមុតទ្វួនជាព្រាហ្មណ៍ចាស់ម្នាក់ ចូលមកសូមព្រះនេត្រព្រះអង្គទាំងគូ ។ ព្រះអង្គទ្រង់ឆ្កៀលព្រះនេត្រទាំងពីរឲ្យទៅឥទ្ធព្រាហ្មណ៍ ។

២- វស្ស៊ីតណាវេស្សីន: ជាដំណាងព្រះអង្គ កាលទ្រង់សោយព្រះជាតិជាវិនីបណ្ឌិត ។ កាលនោះ ព្រះឥន្ទ្រាធិរាជបានទិម្ខិតខ្លួនជាយក្ស ធ្វើជាឆ័ត្រ ។ វិនីបណ្ឌិត បានអារសាច់ខ្លួនឲ្យជាឆ័ត្រ ដើម្បីដំណែ ធ្វើជាមាសចំពោះព្រះពុទ្ធរូប ។

៣- វស្ស៊ីតណាក្រហាម: ជាដំណាងព្រះអង្គ កាលទ្រង់សោយព្រះជាតិជាបទុមមាណព ។ គ្រានោះ មានតាសម្លាញ់ប្រកបដោយគតិសប្បុរសពីរនាក់ ចិតមានតាព្រះអង្គ ។ ទ្រង់យកតាំបិតមកពុះទ្រូង លួចយកពេះដួងមកផ្សំថ្នាំមើលមាតាឲ្យគង់ដីវិត ។

៤ វស្ស៊ីតណាស: ជាដំណាងព្រះអង្គ កាលទ្រង់សោយព្រះជាតិជាព្រះចាតុវេស្សន្តរ បានប្រទានដំរីមង្គលមួយ ជាសត្វសម្រាប់ឲ្យដល់ពួកព្រាហ្មណ៍ពលិង្គរដ្ឋ ពួកអ្នកខនតនាំគ្នាទីន បំបះបង់ព្រះអង្គឲ្យទៅនៅនាវង្គតបព៌ត ។

៥- វស្ស៊ីតណាហង្សចារ: ជាដំណាងព្រះអង្គ កាលទ្រង់សោយព្រះជាតិជាវិជ្ជាធរ ។ មាតាព្រះអង្គត្រូវយក្សចាប់យកបាន, ព្រះអង្គទ្រង់អារសាច់ឲ្យយក្សបរិភោគដំខ្លួនដីវិតមាតា ។

៦- វស្ស៊ីតណាផ្នែក: ជាដំណាងព្រះអង្គ កាលទ្រង់សោយព្រះជាតិជាខន្ធកឈ្មោះរោមបណ្ឌិត មានព្រះតម្ងាសត្វចង់បំភេញបាន ។

គ្រានោះ ព្រះឥន្ទ្រាធិរាជបានទទួលភ្លាម ជាព្រាហ្មណ៍ចាស់ម្នាក់អត់អាហារដើរហួលមក ។ ខន្ធកុមារសោមបណ្ឌិត បានលោតចូលកន្លង់ភ្លើងដើម្បីចំអិនសាច់ព្រះអង្គឲ្យដល់ឥន្ទ្រាហ្មណ៍បរិភោគ ។

ស្មើតាំង ៦ ពណ៌នេះ បានផ្សាយចេញអំពីព្រះរាយនៃព្រះអង្គកន្លះគ្រាស់ដឹងអនុត្តរសម្មាសម្ពោធិញ្ញាណ, កន្លះសំដែងថាដំហាវ ដើម្បីបំបាក់បង់នូវអស្មិមានៈនៃព្រះញាតិរបស់ព្រះអង្គ ដែលសំគាល់ថា ព្រះអង្គជាមនុស្សទៅក្នុងមិនគួរគោរព នឹងកន្លះគ្រាដែលព្រះអង្គទ្រង់ធ្វើយមកបាដំហាវផ្ទាំញាំពួកតិរ្ថិយ លើដើមគណ្ហាមព្រឹក្ស (ដើមស្វាយរបស់នាយគណ្ហៈ) ។

ដូចេ្នះហើយ បានជាពុទ្ធិកសមាគមភិតពលោក ដែលធ្វើនៅប្រទេសស្រីលង្កាលើកទី ១ នោះ ផ្តើមធ្វើទង់ពុទ្ធសាសនា មាន ៦ ពណ៌តម្រូវនឹងឆព្វណ្ណរង្សីរបស់ព្រះសម្មុទ្ធជាម្ចាស់ ។

ផ្នែកអក្សរសាស្ត្រ

អក្សរសាស្ត្រខ្មែរ	ខ្មែរគួរក្រើន
ឲ្យរីកចម្រើន	គង់វង្សតំណ ។
ព្រោះអក្សរជាតិ	ដោលជាតិប្រាកដ
អក្សរលត់	ជាតិក៏រលាយ ។

ប.ព.

វិធី ១: ក្នុងការកសាងវប្បធម៌

លោក លី-ជាមតេង រៀបរៀង

(តាំលេខ ១១ ឆ្នាំ ១៩៦១ ទំព័រ ៥)

កន្លងសម្បានាវដ្តយើងលេខមុន យើងបានចុះមួងហើយ អំពីវិធី ១: ក្នុងការកសាងវប្បធម៌ ដែលកាលនោះ យើងបានចែកជាពីរផ្នែកគឺ: ទី ១ ផ្នែកស្រាវជ្រាវវប្បធម៌ខាងដែលមានមកស្រាប់ ទំព័រ ២. ផ្នែកបង្កើតវប្បធម៌ថ្មីដែលមិនទាន់មាន ។ ផ្នែកទី ១ យើងបានពោលកំយកប់ក្បោះក្បាយរួចមកហើយ ឥឡូវយើងត្រូវពោលពីផ្នែកទី ២ ទៀត ។

ផ្នែកនេះ គឺមានសារៈសំខាន់ ហើយជាការចាំបាច់ណាស់ដែរ គឺយើងដឿសាងពីសេចក្តីខ្វះខាតក្នុងបច្ចុប្បន្ន សំរាប់ឲ្យដនជាតិយើងទាន់ការ:ទេស ជួបអារ្យប្រទេសនានា ។ ខ្លឹមសារជាកម្មវត្ថុ នៃផ្នែក

ទី ២ នេះគឺ មានមុខជាក៏រកតាមបែបវិទ្យាសាស្ត្រ (Etudes scientifigues) ដើម្បីប្រមូលក្រងនូវចំណេះវិជ្ជាសព្វសារពើ ដែលខ្មែរយើងមានមកស្រាប់តាំងពីបុរាណ ហើយផ្សំផ្សាំសំយោគវិធី ជាមួយនឹងវិជ្ជាចំនេះបច្ចុប្បន្ន ដែលអ្នកប្រាជ្ញបច្ចុប្បន្នបានរកឃើញជាលំដាប់ ។ ឧទាហរណ៍ដូចជា : អក្សសាស្ត្របុរាណ ផ្សំនឹងអក្សរសាស្ត្រចំនេះបច្ចុប្បន្ន, សិល្បបុរាណ ផ្សំនឹងសិល្បៈថ្មីៗ, ការផ្សាយតាមសាសនាតាមវិធីចាស់ នឹងការផ្សាយបែបថ្មី ផ្អែកទៅលើគោលវិទ្យាសាស្ត្រជាដើម ។

ហេតុបានជាយើងយល់ថា គប្បីឲ្យមានរកនូវវិធីបែបថ្មីៗ ដោយបញ្ចូលវប្បធម៌ចាស់នឹងវប្បធម៌ថ្មីតាមបែបសំយោគវិធី (Synthèse) នឹងផ្លាស់ប្តូរវិធីយោសនា ឲ្យមានភាពជាក់ស្តែង តាមវិទ្យាសាស្ត្រដូចនេះ ព្រោះយើងយល់ថា សន្ទានចិត្តយុវជនសម័យថ្មីនឹងយុវជនអ្នកសិក្សាពីដើម មានចរន្តប្លែកគ្នា ដ្បិតនៅសម័យបច្ចុប្បន្ន គុមារភាពតែងបានខ្លួនឆាប់ ភាវៈប៉ិនប្រសប់មជ្ឈដ្ឋានច្រើនជាងកាលពីសម័យព្រេងនាយ ។ ដូច្នេះ ក្មេងពាំងនោះតែងមានការគិតច្រើនជាងក្មេងពីដើម ជាន់សេចក្តីថា បើមុននឹងប្រគល់ចិត្តទៅកន្លងដំនឿអ្វីមួយ ។ ក៏តែងគិតពិចារណាកេះហេតុផលឲ្យឃើញភាពសមរម្យសក្តិសិទ្ធិជាមុនសិន ។ ប្រសិនណាជាដំនឿនោះ

ជាដំរៀតន្តីមានហេតុមានផលតិតមែន ទើបពាំនាំគ្នាដឿហើយនាំគ្នាអនុវត្ត
តាមទ្រឹស្តី តាមដំរៀនោះទៅ ដូចយោវិញ បើរកុំយើញមូលហេតុជា
សភាពពិតជាក់ស្តែងទេ ក៏តែងនាំគ្នាយោលចិត្តឆ្ងាយតាដំរឿ (Cro-
yances) ពាំនោះបន្តិចម្តង ។ រហូតដាច់ស្រឡះ ។ មានការគួរសង្កេត
១ ថែមទៀតគឺថា បើភ្លេះបីជាវប្បធម៌ពាសពេញយើងមានរូបភាពជាក់ច្បាស់ជា
ថែមបន្ថែមសិក្សាស្រាប់មកហើយក៏ដោយ បើយុវជនអ្នកសិក្សាពុំបានយល់ពី
លក្ខខ័ណ្ឌក្បួនខ្នាតនោះជាក់លាក់ទេ ក៏តែមុខជាយល់ច្រឡំថា «ជាតិយើង
ពុំមានក្បួនខ្នាតពាំនេះជាក់លាក់ទេ ដោយរកពុំឃើញអ្វីជាគោលចារឹក
សោះ» ។ បើមតិច្រឡំនេះកើតឡើងដូចបាណា ដូចបានោះច្បាស់ជា
មានការអនុវត្តន៍តាមន័យច្រឡំជាមិនខាន់ដែរ ទីធំនាំឲ្យអ្នកសិក្សាពាំនោះ
ដៀលត្មះបុព្វបុរសយើងថា មិនចេះគិតគូរពង្រឹងក្បួនខ្នាតអ្វីខ្លះមកសោះ
នាំឲ្យគេពិបាករកគោលចារឹកអ្វីរៀនសូត្រគ្មាន ។ មិនតែប៉ុណ្ណោះ ផល
អាក្រក់មួយទៀតកើតមកជាមួយនោះដែរ គឺអ្នកសិក្សានោះឯង បែរជា
ស្រពះចៅរកក្បួនខ្នាតរបស់ជាតិដទៃមកពាប់អាខ្លួន ជាតែឆ្ងោតឆាយគប្បី
នាំគ្នារៀនសូត្រតាមគេវិញជាមិនខាន ហើយថែមពាំនរំមែប្រមូលយក
ក្បួនខ្នាតបរទេសពាំនោះមកខ្លួនជាក់ថាជាលក្ខណៈគោល ដែលគេនាំគ្នា

និយមឲ្យតម្លៃដ៏លើសលុប ។

បើនិយាយតាមដំណើរហូរហែ ដូចបញ្ជាក់មកនេះ យើងយើញថា
ការៈយើងបច្ចុប្បន្នកន្លងដំណើរកេសាងជាតិ កំតប្បីនិយមខ្លះជាក់ថា បញ្ហា
កសាងវប្បធម៌ឲ្យមានក្បួនច្បាតត្រប់គ្រាន់សំរាប់សិក្សា, សំរាប់ផ្សាយខ្លះៗ
កន្លងស្រុកក្តី ក្រៅស្រុកក្តី, ជាបញ្ហាបន្ទាន់មួយដែរ ព្រោះដំណើរទៅរក
វប្បធម៌ តែងតែឲ្យបានស្របគ្នាត្រប់ចង្វាក់ទាំងអស់ ប៉ុះក្នុងចោលឲ្យ
ខ្វះចន្ទោះត្រង់ណាមួយ កំថាហេតុទាំងឲ្យទៅសល់តាយើតយ៉ាំតុំល្អមើល
ដែរ ។ សមបើ ផ្នែកវប្បធម៌នេះ ជាផ្នែកបណ្តុះសតិស្មារតីដែលជា
មូលដ្ឋានគំនិតបញ្ជាអ្នកស្រុកផងទោះ យើងយល់ថា តែតែជាការចាំបាច់
បន្ទាន់ណាស់ទៅទៀត ។ដើម្បីលើកតម្លៃមុខម៉ាត់ មុខវិជ្ជានេះទាំងខាង

កន្លងប្រទេសទាំងខាងក្រៅប្រទេស ។ ប្រហែលជាដោយផ្នែកទៅលើ
ការយល់ច្បាស់ពោរពេញចាំបាច់ដូច្នេះហើយ បានជាប្រទេសខ្លះដែលជា
ប្រទេសកសាងជាតិថ្មី ។ ដែរ គេបានលើលកឲ្យមានក្រសួងមួយទទួល
ការតាំសេសតែផ្នែកវប្បធម៌ (Ministère de la Culture) ដោយមានមុខ
ងារស្រាវជ្រាវពេញក្រង ទើងផ្សាយខ្លះៗដោយឡែកពីសេសពីផ្នែកសិក្សា
ធម្មតា (Enseignement) ព្រោះក្រសួងនេះ មានមុខងារបង្ហាត់បង្រៀន

យ៉ាងធ្ងន់ធ្ងរណាស់ទៅហើយ ដូចជាយើងឃើញក្រសួងសិក្សាធិការនៅ
ប្រទេសយើងជាអាទិ៍ ដែលសព្វថ្ងៃនេះ ការសិក្សានៅប្រទេសយើងតាម
ការចាប់ផ្តើមដំណើរការចំហើងនៃរដ្ឋាភិបាលសង្គមកម្ពុជានិយម ក្រោមព្រះពុទ-
ធិបដិការនាំយ៉ាងក្លឹស្វាង នៃសម្តេចសហជាតិនៃព្រះប្រមុខរដ្ឋ ជាទីគោរពនៃ
យើង, តំណាងតែរីកសាយភាយពាសពេញទិសទីក្នុងព្រះពុទ្ធអាណាចក្រ
គាំងពីបឋមសិក្សា, មធ្យមសិក្សា រហូតដល់ឧត្តមសិក្សាថែមទៀត ។

ក្នុងខណ្ឌនេះដែរ យើង - លេខរក្រយៗទៀត បើពុំមានអ្វីជាឧបសគ្គ
ទេ - យើងសូមលើកយកបញ្ហាដ៏ខ្លីខ្លួលយកក្នុងអាវុធមិនខ្លីទៅ មកធ្វើ
អត្ថាធិប្បាយបន្តិចបន្តួច ។ តទៅទៀត ដើម្បីពង្រីកស្មារតីអ្នកអានយើងឲ្យ
រឹតតែក្លឹស្វាងច្បាស់ឡើង ភាមលក្ខភាពស្តួចស្តើងរបស់យើង ។

ដោយគណៈកម្មការវិជ្ជាជីវៈ

(តពីលេខ ១១ ឆ្នាំ១៩៦១)

Dysenterie amibienne		ពេគមួល
Dysenterie bacillaire		ពេគមួលពក
Peste	*n.f.*	ពីលប៉េស្ត
Fièvre jaune	*n.f.*	ត្រុនលឿង
Infection puerpérale		ជម្ងឺក្រឡាភ្លើង
Ophtalme des nouveaux-nés		ជម្ងឺភ្នែកទារក
Rougeole	*n.f.*	កញ្ជ្រឹល
Fièvre de malte		ត្រុនម៉ល់ត៏
Lèpre	*n.f.*	ឃ្លង់
Fièvre récurrente		ត្រុនលស់
Respect	*n.m.*	គារវៈ
Vénération	*n.f.*	សក្ការកាព
Révérence	*n.f.*	គរុការកាព
Egard	*n.m.*	មានទកាព
Considération	*n.f.*	សេចក្តីគប់រក
Déférence	*n.f.*	សេចក្តីគប់មាន
Hommage	*n.m.*	សាទរកាព

(នៅមានត)

វចនានុក្រមសំស្ក្រឹត-ខ្មែរ

ព្រះមហា ថាំង . ខាត់ រៀបរៀង

(តពីលេខ ១១ ឆ្នាំ ១៩៦១)

អតិលុព្ធ គុ. ដែលលោភក្រៃលែង ។ *អតិលុព្ធា*, ស្រ. សេចក្តីលោភក្រៃលែង ។

អតិលោភ ប៉ុ. សេចក្តីលោភក្រៃលែង ។ *អតិលោភតា* ស្រ. ភាវនៃសេចក្តីលោភក្រៃលែង ។

អតិលោម គុ. ដែលមានរោមក្រៃលែង, ដែលមានរោមច្រើន ។

អតិលោល គុ. ដែលឡេះឡោះក្រៃពេក, ដែលប្រែតប្រែតក្រៃពេក ។

អតិលោលុប គុ. ដែលចង់ដានក្រៃពេក ។

អតិលោហិត អតិលោហិនី គុ. ដែលក្រហមក្រៃលែង, ដែលក្រហមឆ្អៅ ។

អតិលៅល្យ ន.ប៉ុ. សេចក្តីត្រាថ្នាក់ក្រៃលែង ។ *អតិលោលុវន្ត* គុ. ដែលមានសេចក្តីត្រាថ្នាក់ក្រៃលែង ។

អតិវង្ក ក. ន. អ្នកទំយោយក្រៃលែង. អ្នកទំយាយច្រើន, អ្នកមើលងាយ ។

អតិវិបិ ឆគុ. ទំយាយក្រៃលែង. តេះដៀល, ទំយាយរើម ។

អតិវិត្សល គុ. ដែលមានចិត្តដាប់ទន់ភ្លន់ខ្លៃ (ក្តា) គុ. ដែលមានចិត្តទន់ភ្លន់ ។

(នៅមានត)

ភាគ្លាទី ៤៦

ទុកញ៉ាវិបុលកជសេនា ខ្ជ-ក្ក ជ្រៃរៀបរៀង

(តតីលេខ ១១ ឆ្នាំ ១៩៦១)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកលឹងវៃឆ្លាសបើបានអាន
ទឹងរះខះជាយកលច់ណាន
តាំងមានសន្តានស្នេហាជាតិ
ឃ្ល - អ៊ុន

លុះថៃថ្ងៃបានឫក្សជោគដ៏យល្អ ខាងធំកុកថៃ កំឡុះរៀបតុតាំងលៀង អាហារអស់បណ្តាខាម៉ឺនសក្តិមុខមន្ត្រី ហើយទឹងរៀបវៃកាមង្គលទៀតទឹងខាងស៊ុនហ៊ុយនតាមប្រពៃណី លុះវេលាយប់បណ្តាខាម៉ឺនក៏លាត្រឡប់ទៅផ្ទះរៀងខ្លួន ខាងធំកុកថៃ ក៏អុចខៀនបំភ្លឺតាំងសងខាងមាគ៌ាតាំងពីទីលំនៅទៀតរហូតទៅដល់បន្ទប់ខាងស៊ុនហ៊ុយន ហើយឲ្យចាស់ទុំនាំទៀតចូលទៅរមដំណេកទឹងខាងស៊ុនហ៊ុយន លុះទៀតដើរដល់កន្លែងខាងស៊ុនហ៊ុយនទៅ ក៏ឃើញសុទ្ធតែភួកស្ត្រីតាំងភួងតែងខ្លួនសៀតក្រម៉ង ដូចភួកខាហានចូលច្បាំងក្នុងសង្គ្រាម ហើយឃើញគ្រឿងសាស្ត្រាវុធ

ផ្សេង ។ រៀបបញ្ជូនឲ្យខុកជាច្រើន ឡៅតីក៏យកគំស្ទុកឈរស្ងៀងកាំង ។

ស្រីចាស់ម្នាក់និយាយនឹងឡៅតីថា លោកកុំភ័យ ! នាងស៊ុនហ៊ូយិនេះ តាំងពីតូចមក ចូលចិត្តតែហាត់រៀនខាងកួនអាវុធបែបបួកពិដ្ឋយសង្គ្រាម ហើយចូលចិត្តមើលខាហានកំភ្លេងអាវុធ ចូលប្រយុទ្ធគ្នាបានជាវិសេសនេះ នាងក៏ហ្វឹកហាត់ពួកស្ត្រីឲ្យកំប្រមើ នឹងចូលតយុទ្ធគ្នាដោយភ្លេងអាវុធផ្សេង ។ ឲ្យលោកមើល ឡៅតីថា ឯការកំភ្លេងអាវុធច្បាំងគ្នានេះ មិនជាការគួរសមនឹងឲ្យនាងស៊ុនហ៊ូយិនមើលសោះ ព្រោះចិត្តខ្ញុំជាអ្នកញាក់ញ៉ីតខ្លាចណាស់ ឲ្យប្រមូលរៀបលាក់ខុកឲ្យអស់ទៅ ស្រីចាស់នោះក៏ចូលទៅប្រាប់នាងស៊ុនហ៊ូយិន ។ ឮដូច្នោះក៏អស់សំណើចហើយថា ធ្វើការសង្គ្រាមមកដល់អាយុប៉ុណ្ណេះហើយ ឃើញគ្រឿងសាស្ត្រាវុធត្រឡប់ជាខ្លាចវិញ ហើយនាងក៏បង្គាប់ពួកស្រីម៉ៅតាំងឲ្យប្រមូលគ្រឿងអាវុធតាំងអស់នោះយកទៅខុកជាក់អស់ ហើយក៏អញ្ជើញឡៅតីចូលទៅដល់ដំណេកនាងស៊ុនហ៊ូយិន អ្នកតាំង ២ ក៏បានរួមសុខទុក្ខនឹងគ្នាតាមប្រពៃណីធម្មតាជាតិសោមនស្សស្មោះសរទៅវិញទៅមក។ លុះទៅនឹងថ្ងៃរសៀលថ្ងៃ ឡៅតីក៏រៀបចំចំណាយរបស់ទ្រព្យសម្ភារៈគ្រាមាសប្រាក់ ឲ្យជាបំណាច់ផ្ទាំងពួកស្រីម៉ៅកន្លះរយនាក់ជាច្រើនគ្រប់ ។ គ្នា ប្រាថ្នាឲ្យនឹងចងចិត្តទុកនឹងតបស្នេហាញ៉ាំខ្លួន ហើយក៏ប្រើស៊ុនខៀនឲ្យនាំតតិមានតាំងពួនទៅដកបង្គន់បេនឯស្រុកគេនឹងវិត្រប់ប្រការ ។

ឯស៊ុនគួនសរសេរសំបុត្រឲ្យដំណឹងទៅដល់យើ នៅស្រុកឧសងគុន តាមហេតុទាំងពួងគ្រប់ប្រការ ជាយើដឹងហើយ កុំតូចចិត្តគិតបរិតែក្តៈពន់ប្រមាណ ខើបរិះគិតការទុច្ចរិតមួយទៀត កុំធ្វើតសរសេរសំបុត្រជើមកស៊ុនគួនសេចក្តីថា: ពីដើមខ្ញុំនឲ្យគិតធ្វើការនេះ ប្រាថ្នាធំធ្វើអន្តរាយខ្លួនឯង ដើម្បីធំនាយកស្រុកកេងដើមកវិញប៉ុណ្ណោះ ការដែលគិតធ្វើនោះកំត្រឡប់ជាខុសខាងយើង ឲ្យបានចំណេញទៅខាងខ្លួនឯងទៅវិញ ដូចេ្នះតម្រេះរបស់ខ្ញុំធំគិតរកទុច្ចរិតទៅទៀត តែថាខ្លួនឯងនេះ ជាមនុស្សមានតម្រេះប្រាជ្ញាណាស់ ធ្វើកិរិយាខាងក្រៅជាល្អពេះៈកយធំធំអាណាប្រជានុកស្តួតាំងខ្លាយខ្លួនទៅ សមបានខុងបេងមកជាប្រឹក្សាធំថែមទៀត មានតាំងគួនអ៊ូ, ខៀវហ៊ុយ, ជួឡុងជានាយគាហានឯក មុខជាមិនមែនទៅនៅក្រោមបង្គាប់អ្នកឯណា ការនេះសុំឲ្យលោកប្រើប្រាជ្ញាប្រលោមយកខ្លួនឲ្យតាំងវង្សធំនៅក្នុងស្រុកតងធំ ដំណតទៅ ខ្លួនធំធ្វើកេចបោះបង់ខុងបេង, គួនអ៊ូ, ខៀវហ៊ុយ, យើងធំធ្វើលើកទ័ពទៅវាយយកស្រុកកេងដែរ គង់ធំធ្វើសម្រេចបានដោយងាយ បើខ្លួនឯងត្រឡប់ទៅស្រុកវិញបាន កំដូចលែងត្រីទៅក្នុងសមុទ្រ គង់តែត្រឡប់ធ្វើជាសត្រូវទៅថ្ងៃមុខ ឲ្យលោកពិ គ្រោះមើលតាមគួរចុះ ហើយកំប្រើគាហានឲ្យកាន់សំបុត្រនោះទៅឲ្យស៊ុនគួនឯស្រុកឡាំស៊ុ ។

ស៊ុនគួនឧទ្ទូលសំបុត្រនោះរម៉ាលដឹងសេចក្តីហើយ កំឱ្យហៅខៀវលៀវមកប្រឹក្សា ខៀវលៀវកំនំយោយទំនឹងស៊ុនគួនថា សេចក្តីដែលដាវយើតតស្អណាស់ ត្រូវទឹងតំនិតខ្ញុំបាទដែរ សុំឱ្យលោកសាងគ្រឹះស្ថានមួយឱ្យឡៅតីខៅ ហើយដីកជាស្រះស្រង់ដាំត្រាំតសំបង់ស្បូន្ត ទំនិងឈូកសឈូកច្រាលគ្រប់ពណ៌ រួចធ្វើជាសួនច្បារដាំផ្កា ដែលមានកូនត្រអូបក្រអែបសព្វទិសា ជ្រើសរើសរកស្រីកញ្ញា ដែលមានរូបឆោមលោមពណ៌ល្អឱ្យបំរើបម្រុងឡៅតី ជាទីតម្រេកត្រេកត្រអាល ឯឡៅតីជាមនុស្សចិត្តស្រាលឆាប់ទំលែកក្រមកយូរហើយ មិនឆាប់មានទុក្ខរឿង បើយើងទំនុកបំរុងឱ្យឆ្អែងសព្វាយ ឱ្យមាសប្រាក់ចេញចាយមិនមានខ្វះខាត ក៏ទំនងត្រេកអរក្តៅខចិត្តក្តៅចិតដល់ខុនបេង, គួនអ៊ូ ទំនង ខៀវហ៊ុយ សួនឱ្យសោះ ឯ ខុនបេង, គួនអ៊ូ ទំនង ខៀវហ៊ុយ នោះក៏ទំនងក្តួចចិត្តលែងតិតស្រណោះឡៅតីជាទីពឹង យើងក៏តនង់ទំនងបានស្រុកគេងដ៏វែងដោយងាយ សុំលោកប្រញាប់រិះតិតធ្វើតាមតំនិតដាវយើចាំនោះចុះ ។

ស៊ុនគួនឮដូច្នោះ ក៏មានចិត្តត្រេកអរណាស់ ទើបចាត់មេការឱ្យកសាងគ្រឹះស្ថានមានដីតស្រះស្រង់ទំនងសួនឆ្ងាស់រួចហើយ កំឱ្យអញ្ជើញឡៅតី ខាងស៊ុនហ៊ូយិន ខៅខៅសំណាក់ ហើយចាត់ខ្ញុំស្រីប្រុសជាមនុស្សបំរើទំនងមាសប្រាក់ជាច្រើន ហើយឱ្យជ្រើសរើសរកស្រីកញ្ញា ដែលដែលមានរូបឆោមល្អចំនួន ១០ នាក់ ឱ្យច្រៀងកំបម្រើឡៅតី គ្រប់ទំន

ទំពាក្រឹ ។ នាឯដំកុងរៃ យើញប៊ុនគួនពាប់អានស្រាឮញ៉ាំខ្លៅតាដូច្នោះ
ក៏មិនជុនដំឯកលុចជាយ មានចិត្តសប្បាយសោមនស្សក្រៃពេកណាស់ ។

សម័យនោះ ខ្លៅតាំងៅជាមនុស្សមានគ្រឿងសម្បត្តិ បរិបូណ៌ដោយ
បរិវារ ក៏ធ្វើសំរែងមិនជុនតិតរៀបត្រឡប់ទៅស្រុកកេងដីវិសោះឡើយ
ម្ល៉ោះហើយ ដូច្នឹង ក៏គ្មានកិច្ចការអ្វីធ្វើ តែងនាំគាហានចាំង ៩០០ ដើរ
ចេញៅ ឲ្យគាហានចាំងនោះហាត់ដំរះសេះជុញគ្នាពក់ ។ ថ្ងៃ លុះយូរ
ទៅក៏កន្ធឹងចូលឆ្នាំថ្មី ដូច្នឹង ក៏ក្តុកស្មាតើនឹកយើញដល់តាក្យខុនចេង
ផ្តាំខុនថា បើទៅដល់ស្រុកឡាំស៊ុ ឲ្យហែកស្រោមសំបុត្រទី ១ បើកមើល
បើដល់ចូលឆ្នាំថ្មី ឲ្យហែកស្រោមសំបុត្រទី ២ បើកមើល ឯសំបុត្រទី ៣
ឲ្យហែកមើល ក្នុងគ្រាដែលមានអាសន្នក្រ គ្រានេះ ៗហ្មាយ
យើងមកនៅក៏យូរលង់ដល់ចូលឆ្នាំថ្មី យើញធ្វេសស្មាតើរង្វើនៅដោយ
សេចក្តីស្រឡាញ់កវ័យច្នៃភេកណាស់ មិនដែលដួបប្រទះនិយាយការ
អ្វីនឹងយើងដល់ម្តងសោះ គួរនឹងហែកស្រោមសំបុត្រទី ២ បើកមើលចុះ ។

ដូច្នឹងតិតដូច្នោះ ក៏ហែកស្រោមសំបុត្រទី ២ មើលយើញសេចក្តីថា
បើខ្លៅតាធ្វេសស្មាតើ ដោយសេចក្តីប្រតិតិ្តខ្ជិលភោះកវ័យថ្មី ដោយកល
ខុចាយស៊ុនគួន មិនជុនតិតរលឹកនឹកនឹងចង់ត្រឡប់ទៅស្រុកវិញទេ ឲ្យ
ដូច្នឹងទៅល្បួងបញ្ឆោតខ្លៅតាថា ចូរធ្វើលិកខិតមកកាយស្រុកកេងដីវិ

ហើយ ខុនបេងឲ្យគួនអ៊ូ ខៀវហ៊ុយ ចេញច្បាំងកំងកជាតន្ទឹកណាស់
កងទ័ពចូន កំនៅមិនទាន់រៀសត្រឡប់ បើនិយាយរៀបរាប់ដូច្នេះហើយ
ខ្លៅតីនៅតែអាខ្លោះអាល័យកវិយោ កំត្រូវឲ្យថា រំលឹកខ្លៅតីឲ្យនាំរឿង
ក៏វែ ដែលដីវិយើនឯងស៊ុនគួនធ្វើកលទុចាយនោះ ឲ្យនាងស៊ុនហ៊ួយិនស្លាប់
ឯនាងស៊ុនហ៊ួយិននោះ ជាមនុស្សប្រកបដោយសត្យាតត្រង់ តង់នឯងជាច់
ចិត្តដឹតដោយតាមខ្លៅតីនៅជាច្រាកដ ដូឲ្យនលុះដឹងតាមសេចក្តីសំបុត្រ
ដូច្នោះហើយ កំចូលទៅសុំដួចនឯងខ្លៅតី លុះទៅដល់ទ្វារផ្ទះកំឲ្យស្រីម្នាក់
ចូលទៅដំរាបខ្លៅតីថា ដូឲ្យនចូលមកចង់ជួប ព្រោះមានការអាសន្នប្លែក
ខ្លៅតីឮដូច្នោះ កំចេញទៅជួបនឯងដូឲ្យន ។ កំធ្វើជាតំយរលេះរលាំង
និយាយនឯងខ្លៅតីថា លោកមកនៅបាននសេចក្តីសុខសម្រាន្តក្នុងដែនស្រុក
នេះហើយ ប្រហែលជាគ្មេចស្រុកគេងដីវិសោះទេដឹង ខ្លៅតីក៏សួរថា
មេតុម្តេចបានជាតំយរតិតបែបដូចរត់ចូលមក ដូឲ្យនឆ្លើយថា តាមសេចក្តី
សំបុត្រខុនបេងសរសេរទុកមកនោះគ្រប់ប្រការ ខ្លៅតីឮដូច្នោះក៏ថា ចាំ
យើនទៅប្រឹក្សានឯងនាងស៊ុនហ៊ួយិនសិន ដូឲ្យនថាដែលលោកនឯងប្រឹក្សា
នោះមុខជានាងស៊ុនហ៊ួយិនមិនឲ្យលោកទៅទេ លោកកុំឲ្យនាងស៊ុនហ៊ួ-
យិនដឹងឯងឡើយ ពេលយប់នេះយើនឯងទាំគ្នារត់ទៅ ដើម្បីនឯងបានដួយ
ខុនបេងប្រឹងរៃតែតធ្វើការច្បាំងនឯងចូន ។

ខ្លៅតិនិយាយថា អ្នកវិលទៅស្រុកសិនចុះ ចាំយើងត្រៃរ៉ែរមើលសិន ដូឡុងក៏គិតទាប់ណាខ្លៅតិចេញទៅ ខ្លៅតិក៏ត្រឡប់ចូលមកកន្ទុងធ្វើជាយំសោក ប្រាប់ថានឹងឲ្យកន្ទុយសាកសួរ នាងស៊ុនហ៊ួយិនយើញហើយក៏សួរថា អ្នកមានទុក្ខរឿងអ្វីបានជាយំសោកដូច្នេះ ខ្លៅតិក៏ថ្លែងប្រាប់ថា បងគិតតែតគុណមាតាបិតា កាលលោកស់នៅក៏មិនបានតបគុណអ្វីឡើយ លុះលោកអនិច្ចកម្មទៅហើយក៏មិនបានទៅគោរពបូជាដូចមិនមានសេចក្តីកតញ្ញូសោះ បងមកនៅនឹងប្អូនគ្រានេះ កំយូរណាស់ហើយ គ្រានេះកំចូលឆ្នាំថែមទៅទៀត បងគិតនឹកដល់គុណបុការៈបិតាមាតាដូច្នេះ បានជាមិនមានសេចក្តីសប្បាយ នាងស៊ុនហ៊ួយិនថា អ្នកកុំនិយាយបញ្ឆោតខ្ញុំថ្លៃទៀត សេចក្តីដែលដូឡុងមកដាំពាបអ្នកនោះ ខ្ញុំក៏បានឮជាក់ហើយ អ្នកនឹងចង់ត្រឡប់ទៅស្រុកកេងដីវែងប្រញាប់ ហេតុអ្វីអ្នកមកសាសើតួច្រាប់ខ្ញុំដូច្នេះវិញ ។

ខ្លៅតិតបថា សេចក្តីទាំងអម្បាលនេះ បើប្អូនដឹងអស់ហើយនឹងបង្អន់នៅយូរ មិនវិលទៅស្រុកកេងដីវែងណាបាន បើកើតថ្លង់ការណ៍ខ្លើងមនុស្សទាំងភូងក៏នឹងនាំគ្នាសើចដំនៀលដៀលគ្នះថា បងធ្វេសវង្វេងដោយកិរិយា ពាល់តែអន្តរាយស្រុកដោយចួនធួ តែថាបើនឹងទៅឥឡូវនេះសោត បងក៏ជាប់ចិត្តអាល័យប្អូនដូចរបេងបង ហេតុនេះ បានជាបងខប់សំណាកពុំបាន នាងស៊ុនហ៊ួយិនឆ្លើយថា ខ្ញុំនឹងជាបាទបរិច្ចាគជាប់

ស្រេចជារបស់អ្នកហើយ បើអ្នកទំនិរិះគិតដោយប្រការយ៉ាងណា ខ្ញុំត្រូវតែស្តាប់តាមអធ្យាស្រ័យនៃអ្នកទាំងអស់ ។ ឡៅតាឆ្លើយថា ប្អូនឱយយេះត្រូវណាស់ តែបងនៅបារម្ភចិត្តមាតារបស់ប្អូនទំនឹងស៊ុនគួនជាបងក្រែងមិនព្រមឲ្យទៅ បើប្អូនមានមេត្តា មិនឲ្យទ្រនំបងរងគម្រាំពុក្តុកក្តុងរឿងនេះ កំបូរត្រិះរិះគិតឲ្យស្រួលទៅផងចុះ បងនឹងគិតស្រួតត្រួតត្រាប់ទៅស្រុកកេង-ដីវិញជាប្រញាប់ ទំនឹងបានរិះគិតច្បាំងតស៊ូនឹងចូរួ ហើយឡៅតាកំធ្វើថាយ៉ំសញ្ជប់ជ្រប់កក្រើ ។

នាងស៊ុនហ៊ួយិនកំលួងលោមថា កុំឲ្យអ្នកកើតទុក្ខអ្វីឡើយ ខ្ញុំនឹងទៅស្រដីអង្វរករអ្នកម្តាយ ប្រហែលជានឹងព្រមឲ្យយើងទៅស្រុកនាយទាំងពីរនាក់ទេ ឡៅតាថា បើប្រសិនមានាប្អូនព្រមឲ្យទៅហើយ តែបើស៊ុនគួនមិនព្រមឲ្យទៅវិញ ប្អូនទំនឹងគិតម្តេចនៅទៀត នាងស៊ុន-ហ៊ួយិនថា ខ្ញុំនឹងទៅលាមាតាថា ដល់ចូលឆ្នាំថ្មីជាថ្ងៃខែត្រូវឆ្លើតឱកាសនៃរំលឹកគុណបិតាមាតា អ្នកត្រូវការទៅធ្វើតាមទំនៀមទំនឹងខានទៅសឿមកំពុងបាន ខ្ញុំក៏ត្រូវទៅជាមួយបង បើមាតាព្រមអនុញ្ញាតហើយ ហើយទំនឹងទាំគ្នាលបរត់ទៅកុំឲ្យស៊ុនគួនដឹងខាន់ ។

ឡៅតាឮដូច្នោះ ក៏មានចិត្តសោមនស្សក្រែកអរគន់ប្រមាណ បានឱយាយទំនឹងនាងស៊ុនហ៊ួយិនថា បងមិនបង់ចិត្តដែលបានប្តូរដៃតស្រឡាញ់

ប្អូន បើប្អូនរៃគិតថាបានដូចក្រុងថ្មាំកូនគ្រានេះ នោះបើខ្ញុំស្ងាប់បងក៏មិនភ្លេច
គុណប្អូន ហើយឡៅតីក៏ឱ្យហៅដូរឡុងមកបង្គាប់ថា ដល់ថ្ងៃខ្ញុត្តឫក្សចូលឆ្នាំថ្មី ឲ្យលើកទាហានទាំងអស់ចេញទៅត្រួតគ្នារវាំងយើងទៅផ្លូវហួងខាងក្រៅស្រុក យើងនឹងនាងស៊ុនហ៊ីយនឹងធ្វើទុក្ខយកលទាំងគ្នាតែម្តង អ្នកចូរត្រៀមចំរុងគារខុកឱ្យត្រួម ដូរឡុងទទួលប្រសាសន៍ហើយ ក៏លាចេញទៅចាត់ការតាមឡៅតីបង្គាប់ ។ ខណៈនោះ ព្រះចៅហៀនតេសោយរាជសម្បត្តិបាន ១៦ ឆ្នាំ ជាថ្ងៃខ្ញុត្តឫក្សចូលឆ្នាំថ្មី ។ ស៊ុនគួនក៏ឱ្យរៀបតុតាំងលៀងសាហាវដល់ទាមុឺនតូចធំទាំងភួង ។

ឡៅតីនឹងនាងស៊ុនហ៊ីយនិង ក៏នាំគ្នាកួលទៅគាប់លានាងធំកុកថៃ ហើយនាងស៊ុនហ៊ីយនិងដំណមាតាថា ឡៅតីលើកទឹកដល់គុណបិតាមាតា គណាញាតិទាំងពួងដែលចាកហានទៅហើយនោះ បានបញ្ជូនសពខុកទៅស្រុកខ្ញុនគួន មកសូមប្រណាំបតន៍លាអ្នកម្តាយទៅសែនសពបិតាមាតា តែឲ្យមជាហេតុតាមទំនៀមទំលាប់ដូនតា ខ្ញុំក៏សុំលាអ្នកម្តាយទៅជាមួយផង ។

នាងធំកុកថៃធ្វើយថា ការនេះជាទំនៀមប្រពៃណី កូនចៅត្រូវដើរតុណបិតាមាតា មួយទៀតនាងឯងក៏នៅមិនទាន់បានទៅតាប់សពបិតាមាតាខាងប្តីសោះ បើចង់ទៅក៏ទៅចុះ នាងស៊ុនហ៊ីយនិងក៏មានអំណរ

ណាស់ ពាំងពីរនាក់ក៏គំនាប់លាមាតាមកទីលំនៅវិញ ហើយរៀបចាត់
ចែងគ្រឿងមាសច្រាក់ ទំនិរបស់ទ្រព្យសព្វវត្ថុពាំងពួង រើសយកតែរបស់
ណាដែលល្អមានតម្លៃដាក់ផ្ទុកលើរថ ឡៅតីក៏ឡើងជិះសេះ ឲ្យនាងស៊ុន
ហ៊ីយិនឡើងជិះរថជាមួយនឹងចាវស្រី ១ដែលស្ងួន ចេញចាកស្រុកឡាំស៊ី
ទៅតាមផ្លូវដែលសញ្ញាឲ្យដូឡុងនៅរង់ចាំនោះ លុះដូឡុងក្រឡេកឃើញ
ឡៅតីទឹងនាងស៊ុនហ៊ីយិនបររថមកដល់ មានអំណរណាស់ ក៏លើក
ពាហនពាំងពួងការពារតើក្រោយទៅ ។

ឯស៊ុនគួនទឹងនាម៉ឺនពាំងពួងសេពសុកបរិភោគអាហារ នៅពាល់ថៃ
រសៀលល្ងាច ពាហនពាំងពួងឃើញស៊ុនគួនស្រវឹងស្រាខ្លាំងណាស់ មិន
ដឹងស្មារតី ក៏បបួលគ្នាគ្រាប់ស៊ុនគួនចូលទៅកន្លែងផ្ទះ អស់បណ្តាខាម៉ឺនមុខ
មន្ត្រីពាំងពួងក៏នាំគ្នាវិលទៅទីលំនៅរៀងខ្លួន ខណៈនោះមានពាហនម្នាក់
ដឹងសេចក្តីថា ឡៅតីទឹងនាងស៊ុនហ៊ីយិន នាំគ្នារត់ទៅហើយ ក៏ស្រួតរួត
ចូលទៅទឹងដំពាបស៊ុនគួន ឃើញស៊ុនគួនស្រវឹងស្រា មិនដឹងខ្លួនពាល់តែក្តី
ឡើង ស៊ុនគួនក៏ស្តីឆ្នាស្រាក្បាត់ភ័ដក ពាហនក៏ដំពាបថា ឡៅតី ទឹង
នាងស៊ុនហ៊ីយិនរត់ទៅចាត់តាមរៀបមិញទៅហើយ ស៊ុនគួនឮដូច្នោះ ក៏
តក់ស្លុតស្មារតី ឲ្យហៅនាម៉ឺនមុខមន្ត្រីមកប្រជុំប្រឹក្សា ។

ខៀវដៀវឆ្លើយថា ខ្ញុំតែមានតម្រេះប្រាថ្នាប្រើណាស់ បើសិនទៅដល់ស្រុកហើយ យូរទៅនឹងជាសត្រូវដល់លោកវិញ សុំលោកស្រួតប្រញាប់ចាត់ការ ឲ្យលើកទៅតាមចាប់យកខ្លួនឡៅតីមកវិញ ស៊ុនគួនយល់ឃើញត្រូវដែរ ទើបឲ្យហៅតំនប៊ូនឹងកូនដៀង មកបង្គាប់ថា អ្នកឯងទាំងពីរនាក់ត្រូវលើកទាហាន ៥០០ តាមទៅចាប់ខ្លួនឡៅតី មកឲ្យបាន តំនប៊ូ, កូនដៀង ក៏លើកទាហានតាមទៅ ស៊ុនគួនមានសេចក្តីខឹងក្តៅខ្លាំងណាស់ ឃាត់ដបទឹកឡៅចោលសំដៅទៅត្រូវដណ្តើងផ្ទះ ពាល់តែដបនោះបែកល្អិតខ្ទេច ខៀវទៅថា លោកមកក្រោធខឹងយ៉ាងណាក៏មិនជាការមានប្រយោជន៍សោះ ខ្ញុំបានឃើញឃើញថា តំនប៊ូ, កូនដៀងដែលលោកប្រើឲ្យលើកទាហានតាមទៅនោះ មុខជាមិនបានខ្លួនឡៅតីមកទេ ព្រោះទាំងស៊ុនហ៊ូយិនជាស្រីមានតម្រេះប្រាជ្ញា ហើយមានលោកកំពង់ទាន់ស្រឡាញ់ស្មើដូចជីវិត នាងក៏ព្រមចិត្តទៅជាមួយនឹងឡៅតី មុខជាទាហានទាំងអស់នឹងក្រែងខ្លាចតាំងមិនជាប្រាកដ ។

ស៊ុនគួនឮដូច្នោះក៏យល់ត្រូវ ទើបយកក្រមាអាជ្ញាសិទ្ធិប្រគល់ឲ្យដើរ. យឹមនឹង ដើរថាយ ហើយបង្គាប់ថា អ្នកឯងចំស្រួតលើកទាហានទៅតាមតំនប៊ូ, កូនដៀង ទៅខៀត បើទាន់ហើយឲ្យយកក្រមាំនេះកាត់ក្បាលឡៅតី នឹងនាងស៊ុនហ៊ូយិនមកឲ្យយើងឲ្យខាងតែបាន ; បើមិនបានទេ

យើងនឹងកាត់ក្បាលអ្នកឯងដំបូង ។ ដាវយឺម, ដាវថាយ ក៏ខ្លួលប្រសាសន៍ស៊ុនគួន លើកទាហាន ១ ពាន់ តាមទៅ ។

ឯខ្លៅតី វគ់ទៅកងថ្ងៃនោះ លុះគេរយាម ៤ កំឈរចំសម្រាកទាហានមួយស្រចក់ ហើយក៏ស្រួតលើកទៅដល់ដែនស្រុកឧសងគុណ ចាត់ឲ្យសំឡេងទាហានស្រែកហ៊ោ ហើយលើកដំតដោយតាមតីក្រោយ ហុយធូលី ងងឹតគេញភ្លូវ ខ្លៅតីក៏ប្រកាន់ដូឡុងថា អញ្ជើទាហានលើកដំតតាមមកច្រើនណាស់ យើងនឹងរិតគិតប្រការម្តេច? ។ ដូឡុងឆ្លើយថា លោកទំស្រួតរួតឲ្យសឿនទៅមុខជុះ ខ្ញុំចាំនឹងទាហានតាំងពួងនឹងតំងកការតាមតីក្រោយ ខ្លៅតីក៏ទាំទាងស៊ុនហ៊ូយិន វគ់ឥងថ្ងូវទៅតាមដើងកុំក្រោយស្រុកឧសងគុណ ។

ខណៈនោះ ដាវយើដឹងថា ខ្លៅតីនឹងទាងស៊ុនហ៊ូយិន ទាំគ្នាវគ់មកតីស្រុកឡាំស៊ុ ក៏គិតរំពឹងថា ខ្លៅតីវគ់មកគ្រានេះ បើមកផ្លូវគោកមុខជាកងស្រុកយើងមកតាមដើងកុំជាប្រាកដ ទើបប្រើឈើសេង, តេងហង. ឲ្យលើកទាហាន ៣ ពាន់ ទៅចាំស្ទាក់ផ្លូវ ។ ឈើសេង, តេងហង ក៏ឡើងមើលលើកុំ ក្រឡេកទៅឃើញខ្លៅតីមកតិចម្ងាយក៏ចេញស្ទាក់ផ្លូវនៅតីមុខហើយស្រែកថា ដាវយើ ប្រើយើងឲ្យមកចាំទៅដីនេះយូរហើយ

ចូរអ្នកចុះតាំលើសេះ យើងនឹងចាប់ខ្លួនទៅឲ្យដាវីយ៉ ។

ខ្មៅតី ឮនឮដូច្នោះ ក៏គិយស្តុតស្មារតី មើលទៅឃើញថាហាន ស្លាក់ដួងដាច្រើន ទើបបំផាយសេះរត់ត្រឡប់មកកន្លែងដួងវិញ ហើយប្រាប់ថា ថាហានចាំស្លាក់ដួងតែមុខច្រើនណាស់ យើងនឹងរិះគិតប្រការម្តេច ។ ដួងវិញឆ្លើយថា លោកកុំរិតក្តីឡើយ កាលយើងនឹងមកនោះ ខ្លួនបងក៏ថាន ឲ្យសំបុត្រមក ៣ ច្បាប់ ថានមើល ៦ ច្បាប់ហើយ ក៏ថានធ្វើការរួចខ្លួន រហូតមកដល់គេលនេះ នៅសំបុត្រច្បាប់ទី ៣ ខ្លួនបងផ្តាំថា បើមានគ័យអាសន្នមកដល់ខ្លួនវេលាណា ត្រូវឲ្យហែកស្រោមមើល តែឥឡូវដល់គ័យអាសន្នមកហើយ ត្រូវតែហែកមើលសំបុត្រនោះឲ្យជាំង ខ្លឹងថានរិះគិតទៅខ្មៅ ហើយដួងវិញក៏ហែកស្រោមសំបុត្រច្បាប់ទី ៣ ហុចឲ្យទៅខ្មៅតីមើល ។

(នៅមានត)

រឿងព្រេងចិន

លោក កុយ-ប៊ុក ប្រែរៀបរៀង

(ឥណ្ឌូ ១១ ឆ្នាំ ១៩៦១)

ឆ្នាំនោះ កំហានដំណើរដោយឆាប់រហ័ស, រហូតដល់គេលប្រណាំងសេះម្ដងទៀត ។ មានបិតានឹងកូនប្រុសស្រី កំត្រូវទៅកាន់ពិធីបុណ្យនោះ ។ ជនពាំង ៣ នាក់នេះ កំច្រឡំរាំជាមួយនឹងអ្នកដែលទៅទស្សនាប្រណាំងសេះពាំងអស់ ហើយផឹកស្រាដែលធ្វើពីដើមសែក្វ៉ (Seigle) ។ តែដល់គេលអាសាន ទាំងជាកូនប្រុសស្រី កំពោលទៅកាន់មាតាក្មេកថា :

"ម៉ែ ! ខ្ញុំមិនសូវស្រួលខ្លួន, ឆ្ងល់ក្បាល, ចង់ត្រឡប់ទៅផ្ទះវិញ សូមម៉ែអនុញ្ញាតឲ្យខ្ញុំទៅផ្ទះវិញ ដើរសេះខុសគ្នានេះណាម៉ែ ! " ។

ដោយគាចាស់យាយចាស់ស្រឡាញ់កូនប្រុសស្រីតន់តេក, លោកកំបើកឲ្យទាំងត្រឡប់ទៅផ្ទះវិញ, ដើរសេះខុសគ្នានោះ ។ កាលណាទាំងពុះតើលើកំពូលទៅខាងម្ខាង, ដោយទាំងយល់ថា បិតាមាតាក្មេកមិនឃើញទាំង កំបង់ដាយសេះយ៉ាងលឿនទៅកាន់ផ្ទះវិញ ដល់ផ្ទះទាំងបានតែមើលតញ្ជាញ់ចេកនោះ មិនឃើញសោះឡើយ, ទាំងដើរកចុះឡើង សព្វច្រកល្អក, ស្រាប់តែឃើញសែ្បកតញ្ជាញ់ចេកស្ថិតនៅ

ដ៏តមាត់ត្រកាំង ។ សៀកនេះ មានទ្រនំទ្រាយដូចកញ្ចាញ់ចេកជាស្ងាមិ
នាង ។ នាងគាន់សំណាកនោះ ដោយចិត្តសោមនស្សពេនំតេក រហើយ
នាងនឹកក្នុងចិត្តថា "នេះជាស្ងាមីអញ ! ឧត្តមឱ្យសប្បាយចិត្តពេនំតេក !
ជ័យបុរសនោះ ប្រាកដជាស្ងាមីអញ។ ជាឧស្ងាមីមានរូបឆោមលោមភណ
ស្រស់ប្រិមប្រិយណាស់ ។

នាងក៏ដួតទឹកក្តែក, តែទឹកក្តែកនោះជាចេះតែហូរសស្រាក់ចេញមក ។
នាងក៏ប្រែប្រួលមើលសៀកកញ្ចាញ់ចេកនោះ ជាច្រើនលើកច្រើនសា
ហើយនាងមានសេចក្តីតូចចិត្តក៏តោលថា: "ឧស្ងាមី ! ម្តេចបងចូលចិត្តតួន
លាក់ខ្លួនបងនៅក្នុងសៀកកញ្ចាញ់ចេកដ៏អាក្រក់ដូច្នេះ ? ម្តេចក៏បងចូល
ចិត្តធ្វើខ្លួនបងឱ្យតូច ឱ្យអាក្រក់ដូច្នេះ ? ប្រហែលជាបងយល់ថា ខ្ញុំជាស្ត្រី
មិនសមជាគ្រួស្រករនឹងបងឬ ? " ។

ដល់នាងតិចារណាខ្លួវសៀកកញ្ចាញ់ចេកនោះ នាងកាន់តែមានចិត្ត
ទោមនស្សខ្លើង ហើយនាងតោលថា: "អញយកសៀកនេះ ទៅដុត
ដើម្បីកុំឱ្យស្ងាមីអញ ចូលទៅក្នុងសៀកនេះបានទៀត", នាងតោល
ដូច្នេះ, ក៏យកសៀកនោះទៅដុតឆេះអស់គ្មានសល់ ។

ក្នុងពេលនោះ, ព្រះសុរិយាទៀបនឹងអស្តង្គត . ស្ងាមីនាងក៏ដំរះសេះ
មកដល់គេហដ្ឋាន, បានឃើញសៀកកញ្ចាញ់ចេកឆេះក្នុងភ្លើង, ប៉ុសេ
ក៏មុខស្ងាយតិយតក់ស្លុតខ្លាចតអប្បមា, លោតពីលើខ្នងសេះ ស្ទុះមក

កន្ត្រាក់ដណ្តើមយកស្បែកតញ្ជាញ់ចេកពីដៃនាង តែជាការឥតអំពើ... ស្បែកនោះវានេះអស់ទៅហើយ ។ បុរសក៏ថ្មរងំ ដួលនៅដីតថ្មមួយដុំ ចំមុខផ្ទះ ។

នាងជាភរិយា ក៏ស្ទុះទៅគ្រាហ៍ស្វាមី នាំចូលទៅក្នុងផ្ទះ រោលដោយសេចក្តីខ្វល់ខ្វក្រៀមក្រំថា: "ស្វាមី! សំឡាញ់ប្អូនអើយ! បងជាអស្ចារ្យវិតដ៏វិសេសវិសាល, ម្តេចក៏បងចូលចិត្តប្តូនឯងជាតញ្ជាញ់ចេកស្ត្រីទាំងឡាយ មានស្វាមីសុទ្ធតែមនុស្សជាតិ, ហេតុម្តេចក៏ខ្ញុំមានស្វាមីតញ្ជាញ់ចេកដូច្នេះ, ខ្ញុំកើតទុក្ខលំបាកឥតឧបមា" ។

បុរសក៏តបទៅវិញថា: "អូនសំឡាញ់អើយ! អូនគ្មានចិត្តខ្ពើមរោះ, អូនធ្វើកិច្ចការនេះដោយឆាប់រហ័សពេក បើអូនរង់ចាំឧកាសបន្តិចទៀត, ពេលដែលកំឡាំងបង មានអានុភាពឡើងវិញ អូនខឹងបាននរណាជាមួយខឹងបង បានសេចក្តីសុខសប្បាយមិនខាន ។ តែឥឡូវនេះ, បងមានតែសេចក្តីស្វាម៉ាងំ, ហើយប្រជាពលរដ្ឋខឹងមិនបានឧស្សាហ៍ដួលនូវសុកមង្គលដែលបងព្រួចាំបំពេញយ៉ាងម៉ឺងម៉ាត់" ។

នាងជាភរិយាក៏តបថា: "នេះជាកំហុសរបស់ខ្ញុំ! តើមានមនុស្សបុយអ្នកមួយណាមកតែកំហុសនោះបានដែរឬ?" ។

ស្វាមីក៏តបទៅភរិយាវិញថា: "មិនមែនទាំងធ្វើកំហុសទេ ចំពោះរឿងនេះ, កំហុសមកពីបងប្រមាទទៅវិញ, បងចង់តិះដៀលមើល

តាលកាតបស់បង, ចុនជាបងចុនទៅដំរះសេះប្រណាំងនឹងគេ, ដូច្នេះ
យើងតាំងតែនាក់ មិនចុនខ្លួលខ្លួសុគមង្គល ដូចសេចក្តីប្រាថ្នាទេ
ហើយប្រជាពស្ត្រ ក៏មិនចុនខ្លួលខ្លួរសេចក្តីសុខកាយសប្បាយចិត្តដែរ ។
បងមិនមែនមនុស្សសាមញ្ញទេ បងជាតុរសនៃនាងតន្តីនព្រះធរណី ។
បងរំពឹងថាខ្លួនមានកំឡាំងកំហែងសមគួរ នឹងបំពេញការណ៍យកចិត្តទ្រុបយ៉ាង
ដើម្បីសុគមង្គលប្រជាពស្ត្រ ។ បើបងចុនសម្រេចដូចបំណង អ្នកនឹង
ចុនឃើញផ្លូវថ្នល់យ៉ាងស្អាតមួយ គាត់តម្រង់ចំទៅកាជធានីបំកាំងតែម្តង
អ្នកនឹងចុនឃើញមហាកដហង្ស (១) ធ្វើព្រះអំណោយខ្លួរាជគ្រាប់ស្រូវ
ដល់យើង ។ នឹងថ្វាយទៅរាំញខ្លួរគោនឹងចៀម, តែសព្វថ្ងៃ បងមិនទាន់
មានតាលកាតល្មមគួរដល់ការទៅឡើយ, បងមិនអាចនឹងដើកកងទោល
យប់ ក្រៅតែស្បែកកញ្ចាញ់ចេករបស់បងចុនទេ បើបងគ្មានស្បែកនេះ
ខ្លួនបងមុខជាដើរស្ងាប់មុនពេលព្រះអាទិត្យរះឡើងពុំមានឡើយ ក្រោយ
ដែលបងមានកំឡាំងល្មមហើយ, បងអាចតស៊ូនឹងសេចក្តីដើរចុន បងនឹង
ចុនបំពេញបេសកកម្មជាប្រយោជន៍ដល់ប្រជាពស្ត្រ, សូកាតអាកាសកំ
ត្រជាក់ត្រជុំ ហើយបងនឹងចុនឱ្យលាក់ស្បែកកញ្ចាញ់ចេកនេះចុន

១- ហង្សជា ព្រះរាជិសន្តតិវង្សចំនួន ៥ នៃលោយរាជ្យ ២សតវត្ស មុនគ្រិស្តសករាជ ។

តែឥឡូវនេះ ពេលវេលាបង់ដល់ហើយ បងនឹងត្រូវស្លាប់ជាតិតទ្រាក់ដ,
យប់នេះ បងនឹងត្រឡប់ទៅគាន់ព្រះខាងតង្គីនព្រះធរណី ដែលជាមាតា
បងវិញហើយ ។

បុត្រីទីបីនៃស្តេចត្រាញ់ ទ្រង់ឮសេចក្តីថាស្លាប់ហើយ ទ្រង់
ព្រះកន្សែងអាណិតអាសូរស្លាប់ពន់ពេកណាស់ ។ ព្រះនាងទ្រង់មាន
ព្រះបន្ទូលតាំងពីក្នុងត្រៃមក្រក្នុងទេវថា : "ទ្រព្រះស្លាប់ម្ចាស់ថ្លៃប្អូនអើយ!
សូមព្រះអង្គកុំទ្រង់ទុំវង្គតអី! សូមព្រះអង្គទ្រង់តន់ទៅជាមួយនឹងខ្ញុំម្ចាស់!
ខ្ញុំម្ចាស់យល់ថា ព្រះអង្គនឹងរស់ពនមានជីវិតតទៅទៀតពុំខានឡើយ" ។

អស្សកោវិទបានឮព្រះវាចាព្រះនាងទេតីហើយ ទឹកភ្នែកជក្រក្នុងទេវ
អាណិតអាសូរទេពីពន់ពេកក៏មានបន្ទូលថា :

"ទ្រព្រះនាង! កុំព្រួយបារម្ភអ្វី! បើព្រះនាងចង់ឲ្យបងរស់ពនមានជីវិត
តទៅ, ត្រូវមានសេចក្តីសន្ធឹមចុះ ប៉ុន្តែ លុះត្រាតែព្រះនាងបានបំពេញ
តវណីយកិច្ចគ្រប់គ្រាន់បរិបូណ៌ទៅតាមសំនាំ ដែលបងប្រាប់ព្រះនាងឲ្យ
បានពេញលក្ខណៈ" ។

ទ្រង់មានបន្ទូលដូច្នេះ ទ្រង់យកព្រះហស្ត ចង្អុលទៅទិសបស្ចិម
ហើយមានបន្ទូលថា :

-« ត្រូវយើងសូមឲ្យព្រះអាទិទេពលោកដួយយើង ហើយឲ្យលោក
មានធនូដួយយើងផង ទើបបងរស់នៅបាន, សូមព្រះនាងគង់លើភាជីបង,
ភាជីនេះ មានល្បឿនយ៉ាងអស្ចារ្យ អាចទាំទៅដល់ទិសបស្ចិមបាន
ព្រះនាងនឹងបានទៅដល់ពាន់ពេលវេលា ទៅទីនោះ មានប្រាសាទ
ព្រះអាទិទេពមួយ, ព្រះនាងចូលទៅក្នុងប្រាសាទនោះ ហើយអង្វរការ
ព្រះអាទិទេពក្នុងនាមនៃសុភមង្គលប្រជាពស្ត្រ, ហើយព្រះនាងធ្វើសំណូម
ពរយ៉ាងចំពោះព្រះអាទិទេព , ហើយសូមព្រះអង្គប្រទានសំណូមពរ
មុនថ្ងៃនេះ ៖

- សំណូមពរទីមួយ, សូមព្រះអង្គទ្រង់ព្រះកជាន្តុញ្ញាតរាជាប្រជា-
ពស្ត្រកុំឲ្យមាន អ្នកមាន ឬ អ្នកក្រ ។

- សំណូមពរទីពីរ, សូមព្រះអង្គសម្រេចថា ពួកអភិជនៃប្រទេស
យើង កុំឲ្យធ្វើបាប កំហែងគ្រាមប្រជាពស្ត្រ ។

- សំណូមពរទីបី, សូមព្រះអង្គទ្រង់សម្រេចឲ្យមានថ្នល់មួយទៅតីទី
នេះ ទៅដល់ភជាន « បេតាំង » ដើម្បីនឹងបានទទួលផលិតផលពី
មហាភជាផង្ស ព្រមទាំងថ្វាយទៅវិញនូវគោនឹងចៀម ។ បើព្រះអាទិ-
ទេពទ្រង់នឹងព្រះរាជាន្តុញ្ញាតនូវសំណូមពរទាំងបីនេះហើយ ប្រទេសនឹង
ទៅជាត្រជាក់ត្រជុំ, បងនឹងបានចេញពីស្បែកកញ្ចាញ់ចេក ដោយរស់
ពនមានជីវិតមិនស្លាប់ឡើយ » ។

ព្រះនាងជាកវិយោកំឡើងតន់លើអាជាទេយ្យ បំផាយយាំងលឿន ដូចជាគេហោះកណ្តាលពពក អណ្តែតត្រសែត លឿនលើនគាស់យ ឥតបង្អន់ ។ ព្រះនាងទ្រង់ស្តេចទៅដល់ព្រះមហាប្រាសាទក្តីសន្ធោសទៀត ត្រចះត្រចង់ប្រកបដោយសោភណភាពនឹងអច្ឆរិយវត្ថុយ៉ាងអស្ចារ្យ, ព្រះនាងទ្រង់យាងចូលទៅក្នុងព្រះមហាប្រាសាទនោះហើយ ទ្រង់អង្វរសូមព្រះអាទិទេពដោយព្រះមធុរសវាចាផ្អែមល្ហែម ពាល់តែព្រះអង្គទ្រង់មានព្រះរាជហឫទ័យទោរទន់អាណិតអាសូរព្រះនាងពន់ពេកណាស់ ។

ព្រះអាទិទេពទ្រង់មានព្រះរាជឧង្កាទៅព្រះបន្ទូលសួរសេីហទាទ ទៅកាន់ព្រះនាងថា: " ព្រះនាង! ដោយព្រះនាងមានព្រះទ័យស្មោះត្រង់ចំពោះស្វាមី, យេីងនឹងអនុញ្ញាតឲ្យព្រះនាងទូវសំណូមពរចំនួនបី សូមព្រះនាងទូលដោយចិត្តរីករាយចុះ តែដេីម្បីឲ្យសំណូមពរបានសម្រេចទៅតាមលទ្ធផលដ៏ប្រសេីរនោះ, ត្រូវព្រះនាងយកដំណឹងនេះ ទៅប្រាប់ប្រជាកស្ត្រេទៅក្នុងភូមិឲ្យបានមុនថ្ងៃរះ ។ បេីព្រះនាងធ្វេីបានមុនព្រះសុរិយោះ, នៅទីនោះ លែងវិលវាហើយ។ ស្វាមីនាងនឹងបានចេញពីសែ្បកកណ្តាញចេញពុំខាន ។ ។

ព្រះនាងទ្រង់ថ្វាយបង្គំព្រះអំណេរចំពោះព្រះអាទិទេពរហើយ ទ្រង់បំផាយតាដីវិលត្រឡប់ទៅកាន់គេហដ្ឋានវិញ, ព្រះនាងទ្រង់ប្រញាប់

ប្រញាស់ខ្លីយកដំណឹងនេះ ទៅប្រាប់ក្រុមគ្រួសារក្នុងកូមិឲ្យបានជ្រាបពាំងអស់គ្នា ។ តែក្នុងគ្រាលែងដែលព្រះនាងទ្រង់ស្តេចទៅដល់ជ្រោះភ្នំខាងបុរីទ្រង់បានជួបនឹងព្រះបិតាព្រះនាង ទ្រង់ក៏ភ្ញាក់ប្រថាប់ទៅមុខប្រាសាទ ។

បិតាព្រះនាង, លុះបានឃើញព្រះពរបុត្រីតន់លើតាដ៏ បំផាយយ៉ាងសៀន, ទ្រង់មានព្រះបន្ទូលសួរព្រះនាងថា :

"កូនស្រី ! តើនាងមានការអ្វី ? ម្តេចក៏នាងបំផាយអាជាះទេយ្យគេលយប់ងងឹតដូច្នេះ ? " ។

ព្រះនាងទ្រង់ឆ្លើយតបទៅព្រះបិតាវិញថា : ខ្ញុំម្ចាស់មានកិច្ចសំខាន់ណាស់, បិតា! ព្រះអាទិទេពបានសន្យានឹងកូនថា ព្រះអង្គនឹងឲ្យមកកូនខ្សែតមួយដ៏វិសេសវិសាល កូននឹងយកដំណឹងនេះ ទៅប្រាប់ក្រុមគ្រួសារពាំងឡាយក្នុងកូមិនេះ " ។

បិតាសួរបញ្ជាក់ព្រះនាងថា : "កូនឯង ម្តេចក៏ប្រញាប់ប្រញាល់ដូច្នេះ, ចូរកូនប្រាប់បិតាផង ព្រះអាទិទេពទ្រង់បានសន្យានឹងកូនដូចម្តេចខ្លះ ? " ។

ព្រះនាងទ្រង់តបទៅបិតាថា : "កូនគ្មានពេលវេលានឹងដំណាលបិតាទេ, កូននឹងដំណាលបិតាក្រោយពីត្រឡប់ទៀត " ។

បិតាព្រះនាងទ្រង់យាងចុះមកក្រោម ហើយចាប់បង្ហៀរតាដ៏មានព្រះបន្ទូលថា :

« បិតាជាស្តេចត្រាញ់កាន់តាប់ការនៅទីនេះ, នាងត្រូវប្រាប់បិតាជាមុនសិន » ។

ដើម្បីទទឹងទ្រង់ចេញទៅបានរហ័សធាប់. ព្រះនាងទ្រង់បានក្រាបបង្គំទូលព្រះបិតា នូវកិច្ចសន្យាសព្វគ្រប់នៃព្រះអាទិទេពថា: ព្រះអាទិទេពទ្រង់បានឲ្យតរកូនបីយ៉ាងគឺ :

- ទីមួយ ទ្រង់មិនឲ្យមាន អ្នកមាន ឬអ្នកក្រ នៅទីនេះ ។

ស្តេចត្រាញ់ បានបញ្ជាប់ព្រះវាចាព្រះនាង ហើយមានព្រះបន្ទូលដោយញញាក់ព្រះភ្លុមថា:

« បើគ្មានអ្នកមាន ឬអ្នកក្រ តើគេអាចសំគាល់បានភ្លូកអភិជន ន័ងភ្លូកហីនជនដូចម្តេចកើត ? » ។

ព្រះបិតាព្រះនាងក៏នៅតែចាប់បន្ទូលតាងដាប់យ៉ាងមាំ ។ ឯព្រះនាងក៏ទូលព្រះបិតាតទៅទៀតថា :

« សំណូមពរទីពីរគឺ កុំឲ្យអ្នកធំធ្វើទុក្ខបុកម្នេញកំហែងតំកមប្រជារាស្ត្រនៅទីនេះ » ។

ព្រះបិតាព្រះនាងបានត្រវីព្រះសិរហើយមានព្រះបន្ទូលយ៉ាងភ្ញាំងថា:

« បើដូច្នេះ តើអ្នកណាធ្វើការជាប្រយោជន៍យើង ? អ្នកណាឃ្វាលសត្វតាមនេះរបស់យើង អ្នកណាធ្វើស្រែតាប់ចម្ការរបស់យើង » ។

ស្តេចគ្រាញ់ ទ្រង់មិនបានលែងចង្រៃរោដ៏សោះឡើយ ។

ឯព្រះនាងទ្រង់មានបន្ទូលតទៅទៀតថា:

"សំណូមតទៅបី តើយើងត្រូវធ្វើថ្នល់មួយតិចនេះ ទៅកាន់ជ.
ជានីបំពាំង ទើបមហាជនជាឆ្ប្រជានផលានុផលដល់យើង ។ ត្រូវថ្ងៃ ទៅរៀបភ្នូរគោនឹងចៀម បើសំណូមតទៅនេះបានសម្រេចទៅតាម ប្រាថ្នាហើយ យើងលែងមានអ្វី ។

ស្តេចគ្រាញ់ក៏ត្រេះបន្ទូលព្រះនាងហើយមានព្រះបន្ទូលថា: "ទ្រង់ ជាល្ងង់មែន! គោ, ចៀមយើងមានគ្រប់គ្រាន់ហើយ តើយើងត្រូវការយក ផលានុផលនៃមហាជនជាឆ្ប្រ មកធ្វើអ្វីទៀត! នេះចំជាគំនិតខ្វៃ! ព្រះអាទិ. ទេតមិនមែនមានព្រះរាជឱង្ការដូចនាងថាទេ, បិតាមិនដឿកូនទេ បិតាមិន ឲ្យកូនទៅនិយាយប្រាប់ពាក្យទេ រឿងនេះ!" ។

ព្រះនាងក៏អង្វរព្រះបិតា សូមលែងបង្ហើរសេះឲ្យព្រះនាងទៅ ហើយ ទ្រង់មានបន្ទូលថា: "បិតា! សូមបិតាមេត្តាឲ្យកូនទៅប្រាប់ប្រជាពាក្យ, បិតា! កូនមិនអាចនៅតិចនេះបានទេ, កូនប្រញាប់ប្រញាល់ណាស់... ហើយព្រះនាងទ្រង់យកខ្សែតឹងយកដ៏ ស្រែកប់ផាយឲ្យចោលទៅ តែ បិតានោះកាន់បង្ហើរោដ៏ជាប់មាំ ។ ព្រះនាងក៏ទ្រង់មានព្រះទ័យគោ. មនស្សន៍ចំបិតា.. ។ កន្លះពេលនោះមានស្រាប់តែរោវ ។ ព្រះនាងទ្រង់

តែយណាស់ ទ្រង់ទំរើតតណ្ដាប់ព្រះហស្តព្រះបិតា តែមិនអាចរើរួចបាន ដោយព្រះបិតាកាន់បង្ខ្លឹរពាដ៏នោះមាំណាស់ ។ កូនពាញ៧ខាង៨នេះ បិតាពាញ៧ខាង៨នោះ, ពាញចុះពាញឡើង ។ បិតាព្រះនាងទ្រង់ព្រះតំរេង មានព្រះបន្ទូលទៅកាន់ព្រះនាងថា :

តើនាងគ្មានព្រួយបារម្ភអ្វីទេឬ ? បើបិតាគ្មានអ្នកបម្រើ ? តើនាងចង់កុំឲ្យមានបុគ្គលម្នាក់ ដើម្បីនឹងមើលថែរក្សាសត្វពាហនៈ នឹងភ្ជួរគរស់កាប់គាស់ស្រែចម្ការឬ ? នេះហៅពេញជាឆ្គួត . . . ។

កន្លះពេលដែលព្រះនាងទ្រង់ទំរើបម្រាស តាតណ្ដាប់ដៃបិតា . . . , មាន់ស្រាប់តែរងាវតើរដង ។ ព្រះនាងទ្រង់មានសេចក្ដីព្រួយជាខ្លាំង . . . ទ្រង់យកខ្សែតីរយពាដ៏ឃាំងខ្លាំង ស្រែកចំដាយពាដ៏ទៅមុខ ។ ពាដ៏លោតឡើង លើស្ដេចត្រាញ់ ។ ក៏ទ្រង់ដួលទៅលើផែនដី ។ ដល់ព្រះនាងទ្រង់យាងទៅដល់តេហដ្ឋានអ្នកស្រុកខាងដើមកូមិ, មាន់រងាវជាលើកទីបី ។ កាលបើព្រះសុរិយោរះឡើង, ព្រះនាងទ្រង់មានបន្ទូលប្រាប់អ្នកស្រុករដាយពាគតិចណាស់អំពីរឿងនេះ ។ ក្រោយមកទ្រង់ទតឃើញព្រះអរុណរះ, ទ្រង់ក៏ត្រាប់ថា ជាការហួសពេលវេលា ទឹងចំពេញកិច្ចនោះហើយ ។ ទ្រង់ញាក់ពាដ៏វិលត្រឡប់មកកាន់ព្រះដំណាក់វិញ ។

លុះយោធមកដល់ ព្រះនាងទ្រង់ចាប់ខ្លួនទៅយល់ឃើញមាតាក្មេក កំពុងសោកសង្រេង ចំពោះមុខសាកសពកូនដែលទើបនឹងខួលមរណៈភាព ។ មាតាលើកអង្វរសុំថ្វាយបង្គំព្រះអាទិទេព សូមដួយកូនឲ្យរស់ពនមានជីវិតឡើងវិញ ។ តែបើពុតជាធ្វើយ៉ាំងណា ក៏ជាការអស់សង្ឃឹមជាការឥតប្រយោជន៍ ។ ព្រះនាងទ្រង់ស្តុះទៅគ្រាលលើសាកសពព្រះស្វាមី ដែលជាទីស្នេហាស្មើជីវិតរបស់ព្រះនាង ហើយទ្រង់ព្រះកន្សែងរៀបរាប់ថា " បុព្វហេតុនៃការខ្វល់ខ្វាយសោកនេះ មកពីបិតារបស់អញ, ឥបិតាមិនគួរឡើយមកធ្វើបាបកូនសោះ . . . " ។

ចំពោះមាតាក្មេកព្រះនាង ក៏សែងសាកសពកូនទៅដល់តាក់កណ្តាលចន្លោះកុំ កប់ទៅជិតជ្រោះមួយ ។ កាលពេលល្ងាច ព្រះនាងតែងយាងទៅកាន់ទីនោះ ហើយទ្រង់សម្រក់ទឹកព្រះនេត្រានៅលើផ្នូរព្រះស្វាមីដោយសេចក្តីសោកស្តាយអាឡោះអាល័យឥតឧបមា ។ ថ្ងៃមួយព្រះនាងកំពុងទ្រង់ព្រះកន្សែង ក៏ស្រាប់តែក្លាយខ្លួនទៅជាថ្ម ។

ថ្មនោះ ស្ថិតនៅរហូតសព្វថ្ងៃ ហើយស្ថិតនៅមាំមួនឥតកម្រើកនៅមាត់ជ្រោះកុំនោះ ។ តាមព្រាយ, គេមើលថ្ម ទ្រង់ព្រាយដុំវិញដូចជាស្រីក្រមុំមានសក់វែងរំសាយចុះ, មានទ្រង់ព្រាយហាក់ដូចជាធ្វើសំណូមពរ សូមឲ្យស្វាមីព្រះនាងបានរស់ពនមានជីវិតឡើងវិញ ។

X X X

មានសេចក្តីដំណាលថា មានជាងឈើម្នាក់ ទើបជាងដែកម្នាក់ចាន ជាដែកគ្នាគាន់តែខ្លាំង។ ល្បើង ។

ជាងដែកគោលរាចាសៅគាន់ជាងឈើថា: "ខ្ញុំធ្វើការប្រសើរជាងលោក!" ។

ជាងឈើតបវិញថា: "ខ្ញុំចេះកិច្ចការខាំងឡាយវិសេសវិសាលជាងលោក" ។

ជាងខាំងតីរដែកគ្នាអស់កាលដំយូរមិនដាច់ស្រេច, ក៏ព្រមព្រៀងគ្នាថា ទើបទៅក្រាបបង្គំទូលព្រះមហាក្សត្រិយ៍ សូមទ្រង់ប្រោសព្រះពរជាន សម្រេចទៅតាមព្រះពរយោបល់តាមការគួរតទៅ ។

អ្នកខាំងតីរ លុះទៅដល់ព្រះបរមពរជាំង ក៏ចានចូលទៅគាល់ព្រះមហាក្សត្រិយ៍ ។ ព្រះអង្គទ្រង់មានព្រះពរជទន្លានត្រាស់សួរអ្នកខាំងតីរថា: "តើលោកអញ្ជើញមកមានការអ្វី?" ។

ជាងឈើក៏ក្រាបបង្គំទូលព្រះមហាក្សត្រថា: "ទូលព្រះបង្គំជាខ្ញុំជាជាងឈើ, ទូលព្រះបង្គំជាខ្ញុំយល់ថា គ្មានជាងឈើណាឲ្យដំនាក្បាការជាងខ្ញុំទូលព្រះបង្គំជាខ្ញុំសោះឡើយ, តែជាងដែកនេះចានអួតអាងខ្លួនថាចេះការយ៉ាងដំនាក្បាជាងខ្ញុំទូលព្រះបង្គំជាខ្ញុំទៅទៀត" ។

ជាងដែកក៏ក្រាបបង្គំទូលព្រះមហាក្សត្រថា: « តែដែលខ្ញុំទូលព្រះបង្គំជាខ្ញុំបានឆ្លើ ជាតែដែលអ្នកតាំងពួងតែងតែសរសើរគ្រប់គ្នា តែជាងឈើនេះមកចេញពាក្យថា ខ្លួនចេះការប្រសើរជាងខ្ញុំព្រះបង្គំជាខ្ញុំវិញ ។

អ្នកតាំងតីរក៏ក្រាបបង្គំទូលព្រះមហាក្សត្រតទៅទៀតថា: «សូមទ្រង់ព្រះមេត្តាប្រោស, សូមស្តាប់ទូលីព្រះបាទ ទ្រង់វិនិច្ឆ័យចំពោះរឿងនេះ តើខ្ញុំព្រះបង្គំជាខ្ញុំតាំងតីរនោក, អ្នកណាចេះការជំនាញជាងអ្នកណា!" ។

ព្រះកដាទ្រង់មានព្រះពាក្យតុង្ការថា : « ឲ្យយើងវិនិច្ឆ័យយ៉ាងណាបាន, បើយើងមិនដែលបានស្គាល់ខ្លួនសមត្ថភាព មិនដែលបានឃើញខ្លួនស្នាដៃរបស់លោកដល់ម្តងសោះ តែយើងអនុញ្ញាត ១០ ថ្ងៃ ឲ្យលោកតាំងតីរ ធ្វើតែអ្វីតាមចិត្តចុះ, រួចឲ្យលោកយកវត្ថុនោះមកឲ្យយើងពិនិត្យ » ។

ដប់ថ្ងៃក្រោយមក, អ្នកតាំងតីរកើចូលមកក្រាបបង្គំគាល់ ព្រះមហាក្សត្រិយ ឯព្រះបរមាជដ៏ង, ជាងដែកបានយកត្រីមួយធំធ្វើតាដែក ។

ព្រះមហាក្សត្រិយ៍ ទ្រង់មានព្រះបន្ទូលសួរសុខទុក្ខជាងដែកថា:

« តើត្រីនេះ មានប្រយោជន៍អ្វីខ្លះ ? ។

ជាន់ដែកក៏ក្រាបបង្គំទូលព្រះរាជាថា: "សូមទ្រង់ព្រះមេត្តាជ្រាស, ត្រីនេះ អាចផ្គុំគ្នូវគ្រាប់ឈើមួយពាន់ជាវ ហើយអាចហែលកណ្តាលមហាសាគរជាន់ដែរ" ។

ព្រះរាជាទ្រង់ព្រះសម្រួលយ៉ាងខ្លាំង ហើយទ្រង់មានព្រះរាជឱង្ការថា: "វត្ថុធ្ងន់ម៉្លេះ, បើគេយកទៅដាក់លើទឹក, មុខជាលិចមិនខាន, ហើយគេថាវាចេះហែលដូចត្រីមែនទែន" តែទ្រង់មានព្រះបន្ទូលសួរ. សិរីមានាគ ឲ្យយកគ្រាប់ឈើមួយពាន់ជាវមកផ្គុំ ក្នុងពេលត្រីដែកនោះ, ហើយយកត្រីនោះចុះទៅក្នុងទឹក ទ្រង់មានព្រះរាជឱង្ការថា: "ត្រូវតែតិរោធន៍មើល" ។

តែគួរឲ្យថ្លែកអស្ចារ្យ, ត្រីដែកនោះចេះហែលរហ័សទៅលើទឹកនោះដូចត្រីមែនទែន! អ្នកទស្សនាតាំងពាក្យយកក៏មានចិត្តរង្គើនឹងឮពាន់តេក។ ព្រះរាជាទ្រង់ជានសារសើរជាន់ដែកនោះ ជាអនេកបរិយាយ ។

ទ្រង់មានព្រះរាជឱង្ការថា: "យើងសប្បាយចិត្តនឹងលោកពាន់តេក, យើងនឹងឲ្យគោរមង្សារជាផ្លូវការនៅក្នុងសំណាក់យើង" ។ រួចទ្រង់តែងតាំងជាន់ដែកជាមេសង្កាត់នៃពលជាន ។

(នៅមានត)

ភូមិសាស្ត្រសេដ្ឋកិច្ចនៃសហភាពអាហ្វ្រិកខាងត្បូង

លោក រ៉ូមាឡូមបែរត៍ អតីតសាស្ត្រាចារ្យ
នៃមហាវិទ្យាល័យច្បាប់ប្រទេសកម្ពុជា ជានិពន្ធកន្លងមក
លោក ឡៀម-ទឹម ប្រែសម្រួល

សហភាពអាហ្វ្រិកខាងត្បូង ស្ថិតនៅចុងខាងត្បូងបង្អស់ នៃទ្វីប-អាហ្វ្រិក, ជាប្រទេសចំណុះចក្រភពអង់គ្លេស, កាត់ផ្តាច់ជាសហព័ន្ធ កាលពីឆ្នាំ ១៩១០ ។ សហភាពអាហ្វ្រិកខាងត្បូងបម្រុងនឹងចុះបង់ចោលចក្រភពអង់គ្លេស ពីឆ្នាំ ១៩៦១ ។ សហព័ន្ធនេះ មានផ្ទៃដីចំហំ ១១.២០០ ០០០គ.ម², ដោយឥតគិតបញ្ចូលផ្ទៃ នៃដែនអាហ្វ្រិក-ទិសនិរតីផង ដែលជាអតីតប្រទេសចំណុះអាល្លឺម៉ង់ ហើយមានផ្ទៃដីចំហំ ៨០០.០០០.គ.ម² ។

នៅខាងត្បូងនៃប្រទេស, មានដែនមួយហៅថាឡឺកាប ។ ដែនកាប់នេះ ប្រកបទៅដោយព្រៃភ្នំធំ-តូច មានកំពស់មធ្យមប្រហែល ៦០០ម. ហើយភ្នំទាំងនោះ ជាន់លើទៅខាងជើង កាត់តាមខ្ពង់រាបហៅថា ការូស ។

នៅទិសអាគ្នេយ៍នឹងនៅទិសខាងកើតនៃប្រទេស, មានជួរភ្នំដ៏ខ្ពស់មួយ

ដែលលាយចោតតម្រង់ទៅមហាសមុទ្រឥណ្ឌៀ ហៅថា ជ្រោកនៃសស្យរកមានកំពស់រហូតដល់ ៣.៧០០ម ។

ចំណែកឯនៅខាងកើតនៃប្រទេសវិញ, ត្រង់តំបន់ខាងកើត, គេឃើញមានខ្ពង់រាបយ៉ាងខ្ពស់មួយ មានកំពស់ពី ១០០០ ទៅ ១៥០០ម- ហៅថា វ៉ែលដ៍ (Veld) គឺវាលស្មៅធំ ។

សហភាពអាហ្វ្រិកមានផែនដីកងដូចជាធើង គឺខ្ពស់ជុំវិញ ខាងកណ្តាល ហើយទៅកណ្តាលនៃផ្នែប្រទេស, គេឃើញមានវាលទំាបមួយដ៏ធំហៅថា កាឡាហារី ។

អំពីឯកាតុអាកាស:

បែកខាងត្បូងនៃប្រទេសមានឯកាតុអាកាសនៃសមុទ្រ ម៉ែដ្ឋីនៃកំណែតីសិសិរវដ្តវិក្តៅ, រសៀរដ្តូវ ស្ងួត ។ ភ្លៀងច្រើនធ្លាក់នៅសិសិរវដ្តូវ ឯរុក្ខជាតិ គេសង្កេតឃើញមានតំតាំងជាយដូ, ដើមឈើមានផ្លែ, ដើមក្រូចនឹងដើមឈើឯទៀត ដែលមានផ្លែស្រដៀងគ្នាខ្លាំងក្រូចដែរ ។

ខេត្តណាតាល់ (១) មានឯកាតុអាកាសក្តៅ ព្រោះស្ថិតនៅក្រោមដ្តូវគោចរនៃព្រះអាទិត្យ ។ នៅក្នុងខេត្តនេះ គេសង្កេតឃើញផលដំណាំដូចតទៅ : ឧបក, អំពៅ ខ្លះដើមឈើល្អៗឯទៀត ដែលមានដុះតែនៅក្នុងប្រទេសក្តៅ ។

១- ជាខេត្តមួយនៃសហភាពអាហ្វ្រិកខាងត្បូង ។

ភូមិសាស្ត្រ (Hydrographie) :

ប្រទេសអាហ្វ្រិកតុំសូរសែម្បូរផ្លូវទឹកខ្លះ ។ គេសង្កេតឃើញមានតែទន្លេធំមួយហៅថា អូរ៉ង់ ទឹងដែនទន្លេដែលខ្លះឈ្មោះ ក៏ល់ ។

អំពីប្រជាជននឹងបញ្ហាមនុស្ស :

ប្រជាជនតំតក្រោកជ ដែលកើតកន្លងស្រុកមានចំនួនតែ ៩០ ឬ ៧០ តាន់ប៉ុណ្ណោះ ។ ប្រជាជនទាំងនេះ រស់នៅតាមរបៀបមនុស្សបុកណាទៅស្បែកលឿងខ្លាំ ក្នុងរួមតូច ។ ធ្វើតាមែកឈើស្លឹកឈើ ប៉ុន្តែសត្វថ្លៃជិតផ្តាត់អស់ហើយ ប្រកបរបរចាប់សត្វ ទឹងដើរសែតងសត្វ ។

ក្រៅពីនេះ មានពួកប្រជាជនស្បែកខ្មៅមកពីទ្វីបអាហ្វ្រិកណ្តាលបានចូលមកភាគច្រើនក្នុងប្រទេស ។ បណ្តាប្រជាជនទាំងនោះ, គេសំគាល់ឃើញ :

- ពួកហ្វូឡង់តូត, សុទ្ធតែជាអ្នកគង្វាលស្ថិតនៅតំបន់ខាងលិចនៃប្រទេស ។

- លុះមកដល់សតវត្សរ៍ទី ១៩ ឬ ១៦ មានជនស្បែកខ្មៅមួយពួកទៀតឈ្មោះ បងឺ ខ្លួ, មានអារ្យធមិគ្រាន់បើជាងពួកមុន, គឺចេះភ្ជួរកស់, ចេះដាំដំណាំ, បានចូលមកលុកលុយសហការអាហ្វ្រិកខាងត្បូង។ ពួកនេះ រស់នៅតំបន់ខាងកើតនៃប្រទេស ហើយបានតស៊ូយ៉ាងតឹងតែងទាំងប្រទាំងនឹងពួកស្បែកស ។

- បន្ទាប់មកនៅសតវត្សរ៍ទី ១៧, ប្រជាជនដែលនៅក្រោមចំណុះប្រទេសហុល្លង់ ចានចូលមកតាំងនៅក្នុងតំបន់ខាងត្បូងបង្អស់ នៃប្រទេសដែលគេហៅថា ខេត្តកាប់ ។ តមក លុះមកដល់ចុងសតវត្សរ៍ទី ១៧ ចាក់ឆ្ងាំដែលជាអ្នកកាន់សាសនាប្រូតែស្តង់ ចានចូលមកនៅជាមួយនឹងពួកអ្នកអាណានិគមហុល្លង់ ។ ពួកប្រជាជនចំណុះហុល្លង់នេះ សុទ្ធតែជាអ្នកកសិករ នឹងជាអ្នកចិញ្ចឹមគោដែលគេឲ្យឈ្មោះថា ប៊ួរ ។ ពួកកសិករក្នុងអាណានិគមតំបន់នោះ ចានប្រើប្រាស់ជនជាតិស្បែកខ្មៅឲ្យធ្វើជាកម្មករខ្លួន នឹងចានញុះញង់ពួកជនជាតិស្បែកខ្មៅឲ្យនៅជាទាសកម្មករ ។

- នៅឆ្នាំ ១៨១៥ ខេត្តកាប់ក៏ត្រូវប្រគល់ឲ្យទៅរាជការអង់គ្លេស ។ ពួកកសិករក្នុងអាណានិគមអង់គ្លេស ក៏ចូលមកតាំងទីលំនៅ ក្នុងខេត្តកាប់ ។ រួចនៅឆ្នាំ ១៨៣៣, អំពើទាសភាពក៏ត្រូវគេបំបាត់ចោលតាំងអស់ នៅក្នុងបណ្តាប្រទេសដែលជាអាណានិគមអង់គ្លេស ។ ដូច្នេះដោយគ្មានពួកទាសកម្មករ សម្រាប់ដួលធ្វើការតទៅទៀត, ពួកប៊ួរ ក៏សម្រេចចិត្តដើរចេញពីខេត្តកាប់, ទៅនៅក្នុងខេត្តណាតាល់វិញ ប៉ុន្តែមកដល់ឆ្នាំ ១៨៤៣, ពួកអង់គ្លេសចានចូលមកកាន់កាប់ខេត្តណាតាល់ទៀត, ពួកប៊ួរ[1] ក៏ចេញពីខេត្តណាតាល់ទៀត ទៅនៅលើខ្ពង់រាប

---

១. ប្រជាជនដែលរស់នៅក្នុងអនុទ្វីបស្ថិតនៅអាហ្វ្រិក ចានឈ្មោះថា ប៊ួរ (Boers) មានដើមកំណើតមកពីប្រទេសហុល្លង់ ។

កណ្តាលប្រទេស , រួចកំញាំងខេត្តត្រង់ស្វាល់ ទឹងអូរ៉ាំង(១) ទៅជា
សាធារណរដ្ឋ ។

នៅឆ្នាំ ១៨៧០ , គេបានរកឃើញអណ្តូងរ៉ែពេជ្រដ៏សំខាន់ភ័ន្តនៅ
ក្នុងរដ្ឋអូរ៉ាំង , ទឹងអណ្តូងរ៉ែមាសដ៏សម្បើមមួយនៅក្នុងរដ្ឋត្រង់ស្វាល់ ក្នុង
ឆ្នាំ ១៨៨៥ ។

ពួកអង់គ្លេសសំឡឹងឃើញសម្បត្តិ ដ៏សម្បើមតន់ពេកក្នុងលោកនេះ
ក៏ប្រើមធ្យោបាយចង់ដណ្តើមយកសាធារណរដ្ឋពីរនេះមកកាន់កាប់ ។ គា-
ស្រ័យហេតុនេះសង្គ្រាមក៏កើតឡើងនៅឆ្នាំ ១៨៩៩ ។ លុះដល់ឆ្នាំ ១៩០២
អង់គ្លេសបានប្តាំងឈ្នះ ហើយក៏បញ្ចូលរដ្ឋពីរនេះ ទៅក្រោមអាណា-
ព្យាបាលខ្លួន ។ នៅឆ្នាំ ១៩១០, ខេត្តចំនួនគឺ: កាប់, ណាតាល់,
ត្រង់ស្វាល់ ទឹងអូរ៉ាំង បានរួមគ្នាទៅជាសហរដ្ឋមួយ ហៅឈ្មោះថា
សហភាពអាហ្វ្រិកខាងត្បូង ។

សព្វថ្ងៃនេះ សហភាពអាហ្វ្រិកខាងត្បូងមានប្រជាជនចំនួនសរុប
ប្រមាណ ១៣.៩០០.០០០ នាក់ គឺមានជាតិស្បែកស ចំនួន ៣.០០០.០០០នាក់
(៣ លាន) ។ ក្នុងបណ្តាជនជាតិស្បែកសប៉ុន្មានលាននាក់នេះ ៦០% ជា
ជាតិប៊ួរ (កសិករ) ៤០% ជាប្រជាជាតិមានដើមកំណើតពីអឺរ៉ុបមក គឺ
ជាតិអង់គ្លេស តែជនជាតិខាងក្រោយនេះហើយ ដែលជាអ្នកត្រួតត្រា

១- រដ្ឋមួយនៃសហភាពអាហ្វ្រិកខាងត្បូង ។

សេដ្ឋកិច្ចក្នុងប្រទេស ។ ក្រៅពីពួកស្បែកស គេសង្កេតឃើញ ជន
ស្បែកខ្មៅចំនួន ៩ លាននាក់, កូនកាត់ ១ លាននាក់ ទឹង ៤ សែននាក់
ជាជាតិផ្សេងៗ ។

រឿងប្រជាជននេះ បានចាត់ជាបញ្ហាយ៉ាងធំក្រៃលែង ព្រោះពួក
ស្បែកស ប្រកាន់តណិសម្បុរហួសហេតុ ហើយចង់តែធ្វើធំត្រួតត្រាលើ
ប្រជាជាតិស្បែកខ្មៅ ។ បញ្ហានេះ កាន់តែស្មុគស្មាញទៅ ។ រកដោះ
ស្រាយពុំបាន ដោយពួកអង់គ្លេសចង់សម្រួលស្ថានការណ៍ឲ្យបានស្រួល
កុំឲ្យកើតទៅជាទាស់ខែងគ្នា, ឯជាតិប៊ួរដែលមានចំនួនមនុស្សកើតកង ១
ផ្នាំ ។ ច្រើនលើសលុបជាងជាតិស្បែកស, ចង់តែញុំាងស្ថានការណ៍ឲ្យកាន
តែធ្ងន់ធ្ងរឡើង ។ ដូច្នេះ នៅក្នុងប្រទេសនោះ គេសង្កេតឃើញមាន
ភាសាពីរគឺ: ភាសាអាហ្វ្រិកមួយ ទឹងភាសាប៊ួរមួយ ។

ពួកប៊ួរចង់ប្រកាសសាធារណរដ្ឋ, ត្រូវការឲ្យមានទឹងជាតិជាទឹមិត្តរួម
នៃប្រទេស, ទឹងសុំចេញពីសមាគមអង់គ្លេស ។

ជាយូរក្រៃលែងណាស់មកហើយ គេបានចែកដីដល់ជនជាតិស្បែក
ខ្មៅធ្វើរបរ, តែដីនោះជាដីអាក្រក់គ្មានជីជាតិធ្វើដំណាំពុំកើត ហើយប្រ.
ជាជនខ្មៅកាន់តែកើនច្រើនឡើងៗ លុះក្រាតែសព្វថ្ងៃចង្អៀតរកដីនៅពុំចង់
បាន ។ ដូច្នោះ ជនជាតិស្បែកខ្មៅពុំអាចបបួលគ្នារស់នៅលើដីនោះ

ខ្មែតបានឡើយ , ម្ល៉ោះហើយ ត្រូវតែដើរចេញតាំដាំដែលគេចែកឲ្យនោះ ដើម្បីទៅកសាងធ្វើនៅទីដាំដែរក្រៅខ្មែត , ដូចជាទៅធ្វើការ នៅកន្លែងណាណាមួយ, ក្នុងពេលចប្រ ។ ឯធ្វើការនេះ គឺធ្វើការដោយជាប់កិច្ចសន្យាជាមួយនឹងនាយខុនចំនួន ២ ឬ ៣ ឆ្នាំ ហើយពួកខ្មែត្រូវរស់នៅក្នុងស្ថានតំមួយដោយឡែក គ្មានសិទ្ធិចេញទៅលេងក្រៅតិតន្លែងដែលគេបានកំណត់ឲ្យនោះឡើយ ។ ពួកស្បែកខ្មៅទោះបីធ្វើការដូចគ្នានឹងជនស្បែកសក៏ដោយ, ក៏ត្រូវបានប្រាក់ប៉ែណាចំតិចជាងជនស្បែកសដែរ ។

គេសង្កេតឃើញជនជាតិស្បែកខ្មៅ ធ្វើការនៅក្នុងអណ្តូងរ៉ែចំនួន ៣០០.០០០ នាក់ នៅក្នុងពេលទស្សាហកម្មចំនួន ៩០០.០០០ នាក់ ។ ក្រៅតិនេះ, គេប្រកបរបរកសិកម្ម ហើយមានដីកាតគ្រាន់បើជាងអ្នកធ្វើការនៅក្នុងអណ្តូងរ៉ែ, នៅក្នុងពេលចប្រ ។ ពួកប្រជាជនស្បែកខ្មៅគ្មានសិទ្ធិធ្វើនយោបាយទេ, ហើយត្រូវធ្វើដំណើរទៅណាមកណាតាមយានជំនិះផ្សែងតាំពួកស្បែកស ទឹងរៀនក្នុងសាលាទុសតាំពួកស្បែកស ។ អាកប្បកិរិយានៃពាជការអង់គ្លេស ដែលប្រើនយោបាយប្រកាន់តណិសម្បារហួសហេតុនេះ អាចនឹងបណ្តាលឲ្យកើតទៅជារឿងកំរាំដ៏ធំតុំខាន ព្រោះចំនួន ២-៣ ឆ្នាំទៅខាងមុខខ្មែត ពួកជនជាតិស្បែកខ្មៅនឹងមានចំនួន ៤ ទៅ ៥ ដងលើសប្រជាជាតិស្បែកស ហើយមាំងខ្មែត, ដោយរដ្ឋឯខ្មែត។

នៅក្នុងខ្ទីបអាហ្វ្រិកបានខ្ចូលឯកភាជ្ឈយ៉ាងច្រើនមកហើយ សហភាព
អាហ្វ្រិកខាងត្បូងប្រាកដជាកើតសម្បជញ្ញៈ ចង់បានឯកភាជ្ឈនឹងគេដែរពុំ
ខាន (រឿងនេះ បានកើតមានជាស្រេចទៅហើយ កាលពីដើមឆ្នាំ
១៩៦១) ។ មិនតែប៉ុណ្ណោះ ពួកស្បែកសបានប្រើអាកប្បកិរិយាដូចគ្នា
នេះ ទៅលើពួកសេណ្ឌៀ ដែលរស់នៅក្នុងសហភាពអាហ្វ្រិកនេះ ប្រកប
របរជាអំណៅនៅក្នុងខេត្តណាតាល់ ហើយជារឿងរាល់ឆ្នាំ ប្រទេស
ឥណ្ឌៀតែងលើកបញ្ហានេះ ទៅដាក់ជូនអង្គការសហប្រជាជាតិនៃច្រើយ
ប៉ុន្តែ គ្មានបានលទ្ធផលអ្វីសោះ ។

ប្រជាជនពុំសូវស្តិតនៅក្នុងទីក្រុងទេ ប៉ុន្តែគេសង្កេតឃើញមានទីក្រុង
ធំៗខ្លះ ដូចជាឡីកាប់ (៧០០.០០០នាក់) ជាកំពង់ផែទី១ នៃប្រទេស ។
ទីតាំងស្ថិតលើមុខទៅកាមហាសមុទ្រ ។ ឡីកាបនេះជាកន្លែងនាពួយ
យ៉ាងសំខាន់ ហើយជាកន្លែងសំខាន់ជំនួតក្រៃលែង សំរាប់នាំយកប៉ែងក
ស្បៀង ទៅគេលើដែលក្រៃកដីតស៊ីឈ្នេះគ្រាះគេជំនួមិនឲ្យនាំចេញចូល។

- ហ្សូហាន់ណេសប៊ួរ ១.០០០.០០០នាក់ ។ កាលពីឆ្នាំ ១៨៨០
ទីក្រុងនេះជាភូមិតូចមួយ ។ ឥឡូវនេះ, ទីក្រុងហ្សូហាន់ណេសប៊ួរជាទី
ក្រុងតំរូវការមេរៀបមាមៅតាំង, កើតឡើងដោយសារសម្បត្តិមាស, ជាទី
ក្រុងសម្បូរទៅដោយមាសជាងគេបង្អស់ នៅក្នុងសាកលលោក ។

- ខៀវបៃដំ ៤០០.០០០ នាក់ , ជាកំពង់ផែដ៏ធំនៃរដ្ឋណាតាល់ ។

- ប្រេកូរីយ៉ា ជាភជធានី ដ៏ធំជាទីតាំងនៃរដ្ឋាភិបាល ដ៏ធំជាមជ្ឈដ្ឋានឧស្សាហកម្មមួយយ៉ាងសំខាន់ ។

អំពីកសិកម្ម .- បេរកសិកម្មមានសារៈសំខាន់តែល្មមខ្លះដែលអាចធ្វើដំណាំបាន មានតិចណាស់ គឺ ១/១៥ នៃផ្ទៃដីកន្លែងដែលបានធ្វើដំណាំ ។ នៅកន្លែងខ្ពង្គាប់, គេមានដាំស្រូវសាលីតាំងពីបាយដូ , ឈើមានផ្លែ ចំណែកឯនៅកន្លែងខ្ពណាតាល់វិញ ដែលមានជាតុអាសាស្តៅ គេដាំអំពៅ, ដាំកុជាតិនៃប្រទេសក្តៅ ។

ការចិញ្ចឹមសត្វ .- ការចិញ្ចឹមសត្វមានសារៈសំខាន់ជាងកសិកម្មទៅទៀត ដោយហេតុថា នៅកន្លែងលាក្រូសសម្បូរស្មៅណាស់, គេសង្កេតឃើញមានចៀមចំនួន ៣៥ លានក្បាល , កាត់ពូជមកពីចៀមអេស្ប៉ាញ់ហៅថា ម៉េរីណូស ។ ចៀមម៉េរីណូសនេះ ផ្តល់រោមល្អណាស់ ហើយសហគាតអាហ្សង់ទីនជាប្រទេសមួយក្នុងបណ្តាប្រទេសឯទៀតក្នុងសាកលលោក ដែលសម្បូរដោយរោមចៀម ។ នៅលើកលស្មៅហៅរ៉ែល , គេមានចិញ្ចឹមសត្វគោដើម្បីយកសាច់និងទឹកដោះ ។

(នៅមានត)

ផ្នែកកំណាត់ដ៏ឥតប្រវត្តិការណ៍

អនុសំវច្ឆរមហាសន្និបាតនៃមន្ត្រីសង្ឃលើកទី ១៨

លោក ជួន - ណាត រៀបរៀង

អនុសំវច្ឆរមហាសន្និបាតនៃមន្ត្រីសង្ឃលើកទី ១៨ បានធ្វើចាប់តាំងពីថ្ងៃសៅរ៍ ១៥ កើត ដល់ថ្ងៃព្រហស្បតិ៍ ៥ រោច ខែបុស្សឆ្នាំឆ្លូ ត្រីស័ក ព.ស. ២៥០៦ (២០-២៩ មករា ១៩៦២) ក្រោមអធិបតីភាពនៃសម្តេចព្រះសង្ឃនាយកតាំង ៦ គណៈ គឺនៅវត្តបទុមវតីរាជវរាភរមនិងវត្តទុណ្ណាលោម ។

ទិវាទី ១

ថ្ងៃសៅរ៍ ទី ២០ មករា ១៩៦២, ពីម៉ោង ១៤ ទៅម៉ោង ១៩ នៃថ្ងៃនោះ ជាពេលបើកនូវសន្និបាតនៃមន្ត្រីសង្ឃ, សហជីវនស៊ុន.ប្បដ្ឋាន រដ្ឋលេខាធិការក្រសួងធម្មការ ដោយមានសហការីរបស់លោកជូនដំណើរផង ចូលមកដល់វត្តបទុមវតី និងវត្តទុណ្ណាលោម ដើម្បីបើកសម័យនៃសន្និបាត ។

ទិវាទី ២

ថ្ងៃអាទិត្យទី ២១ មករា ១៩៦២, ពេលព្រឹក ម៉ោង ៧ និង ៣០ នាទី មានការនិមន្តន៍ព្រះសង្ឃតាំង ៦ គណៈ ចំនួន ៤០ អង្គ ស្មាធ្យាយ

ព្រះសត្តប្បការណាតិជម្ម ទុទ្ធិសព្រះពជកុសលថ្វាយចំពោះព្រះបិតរ ទៅ
ព្រះចេតិយចាំងគួ ខាងមុខព្រះវិហារព្រះកែវមរកត ។ លុះដល់
ម៉ោង ១០ នឹង ៣០ នាទី ព្រះសង្ឃចាំងពីរគណៈ ទទួលចង្ហាន់តាមវត្ត
គឺទៅវត្តបទុមវតី ទីវត្ត១ ណ្ណាលោម ចំពោះមុខរដ្ឋមន្ត្រីក្រសួងធម្មការ ។

ពេលរសៀលម៉ោង ១៦ ក្រសួងធម្មការ បានបើកធ្វើពិធីអនុស្ស-
វរីយមហាសន្និបាតនៃមន្ត្រីសង្ឃ លើកទី ១៨ នៅឃាំនៃតុទ្ធិតវិទ្យាល័យ
ព្រះសុពម្រិត ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ នៃសម្តេចព្រះមហា-
ក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង ។

នៅកន្លែងប្រារព្ធពិធីនោះ គេបានសង្កេតឃើញ សម្តេចព្រះមហា-
សុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ, សម្តេចព្រះសុធម្មាធិបតី
សង្ឃនាយកគណៈធម្មយុត្តិកនិកាយ, ព្រះពោធិវង្ស ហួត - តាត
ចាងហ្វាងខួងនៃតុទ្ធិកសិក្សា, ព្រះសង្ឃជាពជាគណៈ ហ៊ានានុក្រម
មេគណ អនុគណ គ្រប់វត្តគ្រប់ស្រុក ជៅអធិការគ្រប់វត្តកងពជជានី
ព្រមទាំងព្រះសង្ឃជាច្រើនពាន់អង្គទៀត ដែលបានមិមន្តមកអំពីវត្តនានា
កងពជជានីទីឆ្ងាយគ្រាក្រៅ ដើម្បីរួបរួមកងមហាសន្និបាតនេះ ដែលប្រកប
ដោយរបៀបរៀបរយ សមមម្យៅតាមសមណសារូប ។

ផ្នែកខាងឥស្សរជន គេបានសង្កេតឃើញ អ្នកអង្គម្ចាស់នរោត្តម-
កន្ទុល ប្រធានក្រុមប្រឹក្សាព្រះពជអាណាចក្រ ឯកឧត្តមខេត្ត - ជន ខេស-

រដ្ឋមន្ត្រីទទួលបន្ទុកទាំងក្រសួងផែនការនឹងសាលាក្រុងភ្នំពេញ ឯកឧត្តម
ស៊ន . សាន ទេសរដ្ឋមន្ត្រីទទួលបន្ទុកទាំងក្រសួងហិរញ្ញវត្ថុនឹង សេដ្ឋកិច្ច-
ជាតិ ព្រមទាំងសមាជិកព្រះរាជរដ្ឋាភិបាល សមាជិកនៃសភាទាំងពីរ,
ទាំងក្រសួងធម្មការ មានសហជីវិន សុំន . បុប្ផាកា រដ្ឋលេខាធិការក្រ-
សួងធម្មការ ជាអ្នកចាត់ចែងពិធី សហជីវិន ចន្ទ . សុន នាយកនៃការិយា-
ល័យ សហជីវិន លឹម.ឆ្លួន.សេង នាយខុទ្ទកាល័យ ព្រមទាំងមន្ត្រីដំណាង
ក្រសួងនានា ប្រធានពុទ្ធិកសមាគម ប្រធានសមាគមគំលាំនសង្គ្រោះ
សាស្ត្រាចារ្យ នៃមហាវិទ្យាល័យព្រះសីហនុរាជ នឹងពុទ្ធិកវិទ្យាល័យព្រះ
សុរាម្រិត ព្រមទាំងមន្ត្រីរាជការជាច្រើនរូបទៀត ជានស្តេចយាង អញ្ជើញ
មក ដើម្បីរួបរួមជាកិត្តិយសកន្លងពិធីនេះដែរ ។

នៅវេលាម៉ោង ១៦ នឹង ៣០ នាទី សម្តេចព្រះមហាក្សត្រិយានី
ព្រះមាតាជាតិ នឹងសម្តេចព្រះប្រមុខរដ្ឋ ជាទីគោរពនឹងជាទីស្នេហាស្មើ
ដោយជីវិតនៃយើង ដោយមានឯកឧត្តមផ្ទួ . ត្រឿង អនុប្រធានឧត្តមក្រុម
ប្រឹក្សាព្រះរាជបល្ល័ង្ក ឯកឧត្តមគួ . រុន សមាជិកឧត្តមក្រុមប្រឹក្សាព្រះរាជ-
បល្ល័ង្ក ព្រមទាំងព្រះរាជបរិពារផ្ទាល់ព្រះអង្គជាច្រើនទៀត អមព្រះរាជ
ដំណើរផង ជានស្តេចយាងមកដល់កន្លែងជ្រោះត្នោតិធី ដោយជានឧទ្ទេស
តាវតិង្សយាងនុង្គដ៏ខ្ពស់ប៉ិនផុត ដំឡើក្រុមតាហានរក្សាព្រះអង្គ ដែលជានលើក

អាវុធផ្ញើខ្លួនកិច្ច ទើបបន្ទូលបង្គំភ្លេចលើលា ថ្វាយជាព្រះពរជតិត្តិយស
ចំពោះព្រះអង្គផង ។

ក្រោយតោលដែលស្តេចយាងខ្លួលការក្រាបថ្វាយបង្គំ អំពីឥស្សរ-
ជនជាន់ខ្ពស់ ទើបមន្ត្រីអភក្ជការភាំងឡាយរួចហើយ ក្រុមតន្ត្រីព្រះ
ពជទ្រឥ កំបានបន្ទូលបង្គំភ្លេចជាតិ ថ្វាយជាព្រះពជតិត្តិយសចំពោះព្រះ
អង្គ ។ តមក ឥស្សរជនភាំងឡាយ ដែលនៅឆ្ងាំចាំក្រាបថ្វាយបង្គំខ្លួល
ទើបសំដែងសេចក្តីស្មោម័តក្តី ចំពោះព្រះអង្គ កំបានដង្ហែព្រះពជដំណើរ
ចូលថ្វាយបង្គំព្រះសង្ឃ ហើយស្តេចគង់ប្រថាប់ លើព្រះសុវណ្ណភោច្ច:
នៅក្នុងយ៉ាខែភុទ្ធវិតវិទ្យាល័យ ព្រះសុភម្រិត ដោយព្រះវរិយោបថយ៉ាង
សមរម្យ ។

លុះពីប្រជុំបានរៀបរយរួចហើយ, សហជាវិន សុខ.ប៊ុប្ផាកោ ផ្ទ-
លេខាធិការក្រសួងធម្មការ បានថ្លែងសុន្ទរកថាមួយ មានសេចក្តីដូច
តទៅនេះ ៖

សូមព្រះតេជៈដ៏តស់លើត្បូង,

សូមព្រះពជទានក្រាបបង្គំខ្លួល សាម្តេចព្រះមហាក្សត្រិយានី ជា
អម្ចាស់ជីវិត

សូមព្រះពជទានក្រាបបង្គំខ្លួល សាម្តេចព្រះឧបយុវពជព្រះប្រមុខរដ្ឋ

សូមទ្រង់ជ្រាបក្រាមលួងផ្ទាល់ព្រះបាទ ។

ក្នុងនាមនៃក្រសួងធម្មការ សាសនៈសិក្សាធិការ ទីស្នាក់ការ ទីស្នាក់ការ
នៃខ្ញុំព្រះបង្គំជាខ្ញុំ ខ្ញុំព្រះបង្គំជាខ្ញុំ សូមព្រះរាជទានព្រះបរមរាជវរោ-
កាស ថ្វាយនូវព្រះមហាករុណាគុណដ៏ថ្លៃថ្លា ដោយភតញ្ញាគុណដ៏ស្មោះ
ស្ម័គ្រ ទីស្នាក់ការ ភក្តី ស្មោះភក្តី ចំពោះសម្តេចព្រះមាតាជាតិ ទីស្នាក់
សម្តេចសហជាតិនី ដែលទ្រង់សព្វព្រះរាជហឫទ័យ ស្តេចយាងមកជាព្រះ
រាជាធិបតី ក្នុងគ្រាសព៌ោតពិធីអនុស្សាវរីយ៍ច្នៃរមហាសន្និបាតមន្ត្រីសង្ឃលើ ១៨
សម្រាប់ឆ្នាំឆ្លូវត្រីស័ក ដោយសោមនស្សរេចរាជាទីបំផុត ។

សូមទ្រង់ព្រះមេត្តាប្រោស ,

ក្នុងវារៈនៅនេះ ខ្ញុំព្រះបង្គំជាខ្ញុំ សូមព្រះរាជទានព្រះបរមរាជវរោ-
កាស ស្ងួនធួលព្រះបាទ ដើម្បីប្រគេនពរតិចនិចខ្លះ ចំពោះព្រះសង្ឃ មាន
សម្តេចតំណ ២ ព្រះអង្គជាប្រធាន ដែលបានមកពីតំណាងតំណក្នុងក្រុង
ទីនៃខេត្តក្រៅ ខ្លះនៅក្នុងព្រះរាជអាណាចក្រតំណមួល មករួមប្រជុំក្នុង
មហាសន្និបាតនេះ ដូចតទៅ៖

សូមថ្វាយបង្គំសម្តេចតំណ ២ ព្រះអង្គ ព្រមតំណព្រះថេរានុត្ថេរៈជាព្រះ
រាជាគណៈ ហិរញ្ញានុក្រម មេគណៈ អនុគណៈ ទេវអធិការ គ្រប់ព្រះអង្គ
ដោយគោរព ។

ខ្ញុំព្រះករុណាសូមថ្វាយនូវអំណរព្រះគុណ ជាអតិបរមាចំពោះសម្តេច
ទីស្នាក់ព្រះករុណាគ្រប់ព្រះអង្គ ដែលបានមកជួបជុំនេះ ព្រោះការជួបជុំ

នេះបង្កើតនូវបរិយាកាសមួយដ៏ល្អប្រសើរ ដែលអាចផ្តល់នូវសេចក្តីសុខចំរើន រុងរឿងដូចជាតំណាសាសនាព្រះពុទ្ធបល្ល័ង្ក ទីដ៏មានតុប្រទេសតៗជាអនេកប្ប-ការ ដោយហេតុត្រូវតាមគន្ថដ៏អបរិហានីយធម៌តុទ្ធសាសនាដែលសំដែងថា : ការរួបរួមគ្នាប្រជុំដោយមូលមតិគ្នាជាឯកច្ឆន្ទ រមែងបានសេចក្តីរុង-រឿងចំរើន ឈ្នះមារសេក្រូវគ្រប់ទិសទុទិស ឥតនរណាផ្ទាំភ្ញាំបានឡើយ ។

សម្តេច !

ព្រះករុណាគ្រប់ព្រះអង្គ !

ដូចសម្តេចទីដ៏ព្រះករុណាគ្រប់ព្រះអង្គបានជ្រាបស្រាប់ហើយ តាំងពីតុទ្ធសតវត្សទី ៣ ដែលព្រះពុទ្ធសាសនាបានមកប្រតិស្ឋានទៅប្រទេសខ្មែរយើងមក ព្រះពុទ្ធសាសនាចេះតែមានជាប់ដកបរឿងមក រហូតដល់សព្វថ្ងៃ ពុំដែលបាត់សូន្យក្នុងកាលណាមួយឡើយ ។ ខ្មែរជាំងប្រទេសសុទ្ធសឹងជាពុទ្ធសាសនិក មានសទ្ធាដ៏ស្មោះចំពោះព្រៃសរណគមន៍ ។ លទ្ធផលដ៏ប្រសើរ ការរីកសាយទូលំទូលាយ នៃព្រះពុទ្ធសាសនាក្នុងកម្ពុជាណាចក្រនេះ ក៏អាស្រ័យដោយបុព្វហេតុដ៏ាប្រើន តែជាតិសេសគឺដោយសារព្រះពុទ្ធបតិមាដ៏ម្ចាស់មុត នៃព្រះមហាក្សត្រយើងគ្រប់ព្រះអង្គ ព្រមទាំងព្រះពុទ្ធវង្សានុវង្ស ។

សព្វថ្ងៃនេះ ក៏ដូចជាកាលដ៏នានាព្រះបាទអសោកមហាពុទ្ធដែរ ព្រះពុទ្ធបល្ល័ង្កទីដ៏ព្រះពុទ្ធវង្សានុវង្ស ព្រមទាំងព្រះពុទ្ធដង្ហាតិបាល ដែលមាន

សម្តេចព្រះឧបយុវរាជ ជាព្រះអគ្គមគ្គុទេសក៍ដ៏ឆ្នើម ទ្រង់បានយកព្រះទ័យ
ទុកដាក់ខ្ពស់ខ្ពែងលើកស្ទួយពុទ្ធនិយម ឲ្យមានរបៀបរៀបរយល្អ ថ្លៃថ្នូរ
ឧត្តុង្គឧត្តម សមជាទីតាំងផ្នែកនៃសត្វលោក ទីដ៏ជាទីតាវៈកក្តីនៃជនាពុជន
គ្រប់ប្រភេទ គ្រប់ជាន់ថ្នាក់ ។ ទ្រង់បានធ្វើកិត្តិសព្ទកិត្តិគុណនៃព្រះពុទ្ធ-
សាសនាឲ្យសេចក្តីសុខសាយក្លឹងក្រឹងរេញពាសពាលលោក ។ ប្រទេសនានា
ជាពុទ្ធសាសនិកក្តី ពុំមែនជាពុទ្ធសាសនិកក្តី សឹងបានសំដែងនូវសេចក្តីគោរព-
សរសើរ ចានចួលស្គាល់ថាប្រទេសកម្ពុជា មានភ័ព្វសំណាងល្អណាស់
ព្រោះជារដ្ឋអត្តាត្រិតការពារព្រះពុទ្ធសាសនា មានការប្រតិបត្តិជាមជ្ឈិម-
បដិបទា តាមលំអាននៃព្រះពុទ្ធាភិប្បាយ ពីព្រោះព្រះសង្ឃខ្មែរទាំងប្រទេស
គោរពតឹកុក្តីសាមណេរក្តី ក្រោមការដឹកនាំដ៏ភ្លឺស្វាង នៃសម្តេចព្រះសង្ឃ-
នាយកទាំង ២ ព្រះអង្គ ទីដ៏ព្រះពុទ្ធជាគណៈ ហានានុក្រម មេគណ-អនុគណ
ចៅអធិការឧបជ្ឈាយាចារ្យ ព្រមទាំងភិក្ខុសាមណេរជាបរិស័ទ ពុំបាន
ភ្លេចនូវព្រះបណ្តាំនៃព្រះពុទ្ធជាបរមគ្រូ ដែលទ្រង់បានផ្តាំថា: ព្រះពុទ្ធ-
សាសនាទីដ៏ប្លុំថ្លៃដ៏រុងរឿងក្តី សាបសូន្យទៅក្តី ក៏ដោយសារតែកូនចៅ
តថាគត ។

ដើម្បីជាខសម្បទានខ្ញុំព្រះករុណាសូមបញ្ជាក់ថា ទោះបីជា-
មានមេឃាភ្លៀងដ៏ខ្លាំងខ្លាយយ៉ាំងណាក៏ដោយ ក្នុងក្របខ័ណ្ឌនៃលទ្ធ
សន្តិភាពស្ថិតនៅយ៉ាង ប្រទេសយើងបានឧបត្ថម្ភដោយគោលក្ខណៈ ដល់

ព្រះពុទ្ធសាសនាច្រើនលែងបង្ហើន ចាន់ភ្ញាយាមតាំងព្រះពុទ្ធសាសនា
ឲ្យរីកសាយទៅក្នុងសាកលលោក មានចំនួនកប់រុងសមណៈនិស្សិតដែល
ទៅបន្តវិជ្ជាខាងសាសនានៅនានាប្រទេសជាដើម ហើយជាតិសេសចាន
រៀបចំធ្វើតិធីបុណ្យធំ ។ តស្តុតាងដូចបុណ្យព្រះអរហន្តធាតុ បុណ្យ
ពុទ្ធសករាជ ២.៩១០ ដែលហៅថា បុណ្យតាក់កណ្តាលសាសនា ដ៏
មហាឡាកត្រមាំងចានចាត់គណៈប្រតិភូជាច្រើន ឲ្យទៅរួមប្រជុំក្នុង
ពិធីបុណ្យពុទ្ធសករាជ ២៩០០ ជាច្រើននគរ ឲ្យទៅរួមប្រជុំក្នុងមហា.
សន្និបាតដែលហៅថា សន្និសីទពុទ្ធិកសមាគមតាតាលោក ក្នុងប្រទេស
នានាមានប្រទេសស្រីលង្កាជាដើម ហើយជាតិសេសនៅគេលថ្មី ។ នេះ
ចានចាត់ចែងធ្វើក្នុងលើកទី ៦ នៅក្រុងកុំពេញយើង ពីថ្ងៃទី ១៤ ដល់ទី
២៣ ខែវិច្ឆិកា ពុទ្ធសករាជ ២៩០៦ គ្រិស្តសករាជ ១៩៦១ ក្រោមព្រះ
កដ្ឋបត្តម្ភដ៏ខ្ពង់ខ្ពស់នៃសម្តេចសហដ៏វិនៃ ព្រះប្រមុខរដ្ឋដ៏ឆ្នើម ជាទីស្នេហា
ស្មើដីវិតនៃយើង ដែលព្រះអង្គទំនុកទ្នៃងតេញាលក្ខណៈ គោរបីប្រទេស
កំពុងមានការគំរាមតាបរទេសយ៉ាងណា ក៏ដំនះធ្វើទាល់តែកើតរឿងចាន
ជាមហាសន្និសីទដ៏មហាឡាក មានរបៀបរៀបរយថ្លៃថ្នូរ ដែលនាំឲ្យ
សាកលលោកស្គាល់ខ្លួនគុណភាពនៃប្រទេសខ្មែរតែច្រើនឡើង ។ ហើយ
ដែលចានទទួលសេចក្តីសរសើរតើសំណាក់គណៈប្រតិភូចាំង ៦៦ ប្រទេស
ដែលចានមករួមប្រជុំក្នុងសន្និសីទនេះ ។

សន្និសីទលើ ៦ នៃពុទ្ធិកសមាគមពិភពលោក ដែលធ្វើនៅប្រទេសយើងនេះ ជានធ្វើសេចក្តីសម្រេចចិត្តចំនួន ៦១ ។ ដែលជានចុះផ្សាយក្នុងសារពត៌មានរួចមកហើយស្រាប់ ។

សូមទ្រង់ព្រះមេត្តាប្រោស,

ក្នុងនាមនៃពុទ្ធមាមកជនទាំងអស់ ខ្ញុំលព្រះបង្គំជាខ្ញុំ សូមទ្រង់ព្រះបរមករុណាខ្ញុំញ្ញាតឆ្នៀតយកឧកាសដ៏ប្រពៃនេះ ដើម្បីថ្លែងជាថ្នូរភក្តីភាពដ៏ជ្រាលជ្រៅចំពោះព្រះមហាករុណាធិគុណនៃសម្តេចព្រះចតាឯកពជ្ជរាជក្នុងព្រះហឫទ័យដែលព្រះអង្គមានព្រះពជ្ឈាឫទ័យជ្រះថ្លា ចំពោះព្រះពុទ្ធសាសនា ទ្រង់ព្រះពជ្ឈាញ្ញាឲ្យចាត់ការធ្វើសន្និសីទលើកទី ៦ នៃពុទ្ធិកសមាគមពិភពលោកនៅប្រទេសយើង ដូចជានតណានាមករហើយជោយសង្ខេបនេះ ។ សន្និសីទនេះផ្តល់នូវគុណធម៌ដ៏ប្រសើរដែលជាមូលដ្ឋាននៃព្រះពុទ្ធសាសនា គោលគឺ អហឹសា: ការមិនបៀតបៀនអ្នកដទៃ, មេត្តាធម៌ : ការផ្សាយសេចក្តីរាប់អានទៅកាសត្វសត្វ ករុណាធម៌ : ការផ្សាយសេចក្តីអាណិតអាសូរទៅកាសត្វលោក ចំពោះពេលដែលលោកសន្និវាសកំពុងតែបញ្ចេញសូរសំឡូសគ្រាមគ្រើជាត់ ប៉ុន្តែក្តៅក្រៃលែងក្តៅ ទើដួបប្រទះការតាសោធន៍អាវុធបរមាណូ ដែលជាវត្ថុធាតុស្ថិត តែអាចបណ្តាលឲ្យពិភពលោកមានសេចក្តីអន្តរាយយ៉ាងធំក្រៃលែងធំ ។ ខ្ញុំលព្រះបង្គំជាខ្ញុំយល់ថាមានតែព្រះពុទ្ធសាសនាមួយទេ ដែលប្រដៅឲ្យប្រតិបត្តិធម៌ខាងចេតា-

និយម ជាសន្តិវរបទ អាចទម្រុះទម្រោមទៅ លោកៈ ទោសៈ មោហៈ របស់សត្វលោក ឲ្យក្រុះក្រោមនាំឲ្យតិកតរលោកមានសន្តិភាពបាន ។

មុខនឹងបញ្ចប់

កន្ធហានៈជាផ្លែលេខាធិការក្រសួងធម្មការ នឹងសាសនៈសិក្សាធិការ ទូលព្រះបង្គំជាខ្ញុំ សូមព្រះពុទ្ធានុញ្ញាត ដើម្បីថ្លែងនូវការប្រព្រឹត្តិនៃតុក្កដបរិស័ទខ្លះដូចនេះ៖

តាមការសង្កេតយើញសត្វថ្ងៃនេះ តុក្កដបរិស័ទខ្មែរយើងមានសេចក្តីប្រឹងប្រែងណាស់ ក្នុងការធ្វើបុណ្យទាន បុណ្យអ្វីក៏ដោយឲ្យតែជាបុណ្យទាងព្រះពុទ្ធសាសនា តុក្កដបរិស័ទតាំងប្រទេស ទោះបីមានដីវភាពដុនដាបយ៉ាំងណា ក៏ស៊ូប្តូរបរិច្ចាគធនធានយកទៅធ្វើបុណ្យនោះជាដរាប ដើម្បីដំរេចិត្តរបស់ខ្លួនឲ្យបរិសុទ្ធផុតចាកលោកៈ ទោសៈ មោហៈ ឈោងយកសេចក្តីសុខកន្ធលោកនេះ នឹងលោកខាងមុខ ហើយនឹងព្រះនិព្វាន ។

ប៉ុន្តែនៅមានតុក្កដបរិស័ទខ្លះ ប្រកាន់ភ្លក្រមហួសហេតុពេក តុំពាណាឲ្យដិតដល់សោះ សូម្បីតែបញ្ជូនខ្លះជាស្រែបុណ្យ មានស្មៅប្តូរត្រាស្បាតដុះគ្របគ្រុល គោលតីមានមន្ទិលសៅហ្មង ដោយគុំកាបត្តិដែលមន្ត្រីសង្ឃស្រុកវៃត្រ ប្តូរថៅសេកាជាន់ខ្ពស់ ចាន់ដំទុំដំរះកេទោសកំហុសយើញតិតប្រាកដ ហើយតម្រូវឲ្យផ្ទាស់តេខាកបញ្ជូនតាពក៏ដោយ តុក្កដបរិស័ទខ្លះជាភ្លក្រមនោះ ធ្វើជាមិនដឹងមិនគោរពប្បាប់តុក្ក-

ចក្រ - អាណាចក្រសោះ នៅតែខ្ញុំលស្គាល់ថា បព្វជិតនោះបរិសុទ្ធឥត
ទោសតែវ៍ ថែមទាំងជួយកាន់ដើងតវ៉ាប្តឹងផ្តល់ ដោយអាងសាក្សីខ្ញុំឯវិត
ឬមានះរឹងក្តីងក្រៀតខ្ញុំងច្បាប់ ដើម្បីបន្សាបសេចក្តីសម្រេចរបស់ដំខ្ញុំសង្ឃ
ជាន់ខ្ពស់ឱ្យសាបរលាប តុំព្រមជួយដំរះស្មៅឬកាប់ឆ្ការព្រៃស្បាតក្នុងស្រែ
បុណ្យស្មោគគ្រោកនោះ ឱ្យស្អាតបាត ឱ្យមានដីជាតិល្អគុកសម្រាប់
សាបព្រួសតូដស្រូវ គឺការផ្តើមានឱ្យបានផលល្អវិសេសឡើងទៅសោះ ។
ការជួយបំខាំងទោសកំហុសបែបនេះ ឈ្មោះថាបង្អាប់ព្រះពុទ្ធសាសនា
ឱ្យអាប់ឧន ព្រោះព្រះពុទ្ធសាសនាដែលនឹងរុងរឿងឬសាបសូន្យ គឺព្រោះ
តែពុទ្ធបរិស័ទនោះផង ។

តែក្រសួងធម្មការសង្ឃឹមថា ក្នុងអនាគតដ៏ខ្លីនេះ ដោយអានុភាព
ព្រះពុទ្ធបូតុម្ភក៍នៃសម្តេចព្រះប្រមុខរដ្ឋ នឹងសម្តេចព្រះសង្ឃនាយកទាំង ២
ព្រះអង្គ ព្រមទាំងព្រះគុណាគ្រប់ព្រះអង្គ អប់រំពេញលក្ខណៈគំមុខជា
ពុទ្ធបរិស័ទខ្ញុំទៅក្នុងព្រះពុទ្ធអាណាចក្រ នឹងចេតិយរាណារកខ្ញុំសត្រូវ
ហើយខ្ញុំលគោរពច្បាប់ពុទ្ធចក្រ នឹងអាណាចក្រតុំទាន់ឡើយ ។

ក្នុងហានៈជាតិសង្គមខ្មែរ ១ រូប ដែលចង់ឱ្យជាតិ សាសនា ព្រះពុទ្ធ
បច្ចុប្បន្ន ជាខ្ញុំលខ្ញុំវ៉ាឱ្យគាត់ច្នៃនឹងរុងរឿងពេញលក្ខណៈ សមហានៈជា
អារ្យប្រទេស ខ្ញុំលព្រះបង្គំជាខ្ញុំមានសេចក្តីរីករាយជាអតិបរមា ដោយ
យើញថា ព្រះសង្ឃខ្មែរទាំងឡាយ ដែលបិតនៅក្នុងព្រះពុទ្ធអាណាចក្រក្តី

ប្តូដែលបានចេញទៅបន្តសាសនាវិញ្ញាឯបរទេសក្តី សឹងបានជ្រាបនឹងយល់ច្បាស់នូវគោលនៃហេតុទាំងឡាយ ដែលខ្ញុំសូមព្រះបង្គំជាខ្ញុំបានភាណិនាត្រួស ។ ខាងដើមនេះហើយ ព្រះសង្ឃដែលគ្រាប់តែជួយស្រោចស្រង់នូវជាតិនិយមខ្មែរគោលតឺ ជាតិ សាសនា ព្រះរាជបល្ល័ង្ក ដែលបានទ្រទ្រង់រឿងរាជដកបមកនូវអារ្យធម៌ នឹងវប្បធម៌ខ្មែរ កំបានជួយទ្រទ្រង់ដោយកាយវាចាចិត្តគេញសមត្ថភាពនូវ ព្រះរាជបេសកកម្ម នឹងព្រះរាជនយោបាយដ៏ធ្ងន់ នៃសម្តេចព្រះទបយុវរាជ មានឧយោបាយអត្ថាក្រិតជាដើម ព្រោះអត្ថាក្រិតជានយោបាយស្របនឹងមជ្ឈិមបដិបទា ដែលព្រះសម្ពុទ្ធបរមគ្រូបានត្រាយពុកមក នឹងព្រះនយោបាយលើកដំកើងដីវភាពលរដ្ឋ ព្រោះកាលបើតលរដ្ឋដែលជាតុន្ទសាសនិកមិនសម្បូណិសប្បាយខ្លះថ្លើងទេ ព្រះពុទ្ធសាសនាដែលមានព្រះសង្ឃជាតំណាង ក៏ពុំអាចលូតលាស់សមតាមបំណងយើងទាំងអស់គ្នាឡើយ ។ ព្រោះហេតុនេះ បានជាចក្រទាំងពីរគឺ : តុន្ទចក្រ នឹងអាណាចក្រដែលជាកងរបស់ប្រទេសខ្មែរយើង ត្រូវតែរួលទៅស្មើគ្នា គឺថាត្រូវមានការច្រកស្រ័យគ្នាកាន់តែជិតស្និទ្ធឡើង ទើបអាចជួយបំពេញមុខការ នឹងប្រយោជន៍ផ្សេង ។ ដល់គ្នានឹងគ្នាទៅវិញទៅមក ឲ្យរីកចំរើន សុខសន្តិភាពគេញលក្ខណៈទៅបាន ។

ខ្ញុំលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ដឿជាកំចំពោះពុទ្ធភាសិតថា :

ធម្មញ្ហវេ សុចរិតំ ន តំ ទុច្ចរិតំ ចរេ
ធម្មចារី សុខំ សេតិ អស្មឹ លោកេ បរម្ហិ ច

សេចក្តីថា: បុគ្គលគប្បីប្រព្រឹត្តធម៌ឱ្យសុចរិត កុំគប្បីប្រព្រឹត្តធម៌នោះឱ្យទុច្ចរិតឡើយ ព្រោះអ្នកប្រព្រឹត្តធម៌សុចរិត តែងបានសុខទាំងបច្ចុប្បន្ន ទាំងអនាគត ។

អាស្រ័យដោយអានិសង្សនៃធម៌សុចរិត ដែលពុទ្ធបរិស័ទជាតិខ្មែរបានប្រព្រឹត្តកាន់តាមព្រះពុទ្ធសាសនា ជាយូរអង្វែងមកហើយផង ដែលកំពុងប្រព្រឹត្តកាន់តាមក្នុងបច្ចុប្បន្ននេះផង ព្រមទាំងដោយព្រះតេជៈបារមីនៃសម្តេចព្រះមហាក្សត្រិយានី ព្រះមាតាជាតិ នឹងសម្តេចសហដាយនៃព្រះប្រមុខរដ្ឋ ទ្រង់បានឧបត្ថម្ភពេញលក្ខណៈផង នឹងទ្រង់ប្រព្រឹត្តកាន់តាមព្រះពុទ្ធសាសនាត្រឹមត្រូវផង ប្រទេសកម្ពុជា នឹងតាំងជួបប្រទះនូវឧបទ្រវន្តរាយអ្វីមួយឡើយ សត្រូវទាំងឡាយ មានពួកក្សត់ឧត្តមប្រយោជន៍នៃជាតិ សាសនា ព្រះរាជបល្ល័ង្កជាដើម មុខជានឹងវិនាសសាបសូន្យគ្មានសេសសល់ ។

ទីបំផុតនេះ ខ្ញុំលព្រះបង្គំជាខ្ញុំ ក្រាមល្អដងថ្វាយព្រះពរ សូមប្រសិទ្ធិពរជូនសួនចំពោះគុណព្រះតេនត្រ័យ ព្រមទាំងទេវតាទាំងមឺនលោក. ជាតុ សូមដួយអភិបាលរក្សាព្រះពុទ្ធសាសនាព្រមទាំងសម្តេចព្រះមហា. ក្សត្រិយានី ព្រះមាតាជាតិជាអម្ចាស់ដ៏វិសេសលើសួង នឹងសម្តេចសហដាយនៃ

ព្រះប្រមុខរដ្ឋ សូមព្រះអង្គគង់នៅជាបរមសុខក្នុងសិរីពោធិសម្បត្តិ ដើម្បីជាម្លប់ដ៏ត្រជាក់នៃប្រជារាស្ត្រគ្រប់ប្រភេទតទៅ ។

មួយទៀត សូមព្រះករុណាគ្រប់ព្រះអង្គ មានសម្តេចព្រះសង្ឃនាយក ទាំង ២ ព្រះអង្គជាប្រធាន ជានប្រកបដោយសេចក្តីសុខចំរើនគ្រប់ប្រការ ដើម្បីការពារព្រះពុទ្ធសាសនាឲ្យបានថ្កុំថ្កើងរុងរឿងរហូតដល់ ៥០០០ វស្សា កុំបីឃ្លៀងឃ្លាត ។

សូមឲ្យអនុសំវច្ឆរមហាសន្និបាតទី ១៨ នៃមន្ត្រីសង្ឃ ប្រកបដោយខ្លួរជោគជ័យកុំបីខានឡើយ ។

× × ×

បន្ទាប់មក ព្រះតេជព្រះគុណ ព្រះគ្រូសិរីសេត្ថា កែវ-សាន វត្តកំផែង អនុគណ ស្រុកបាត់ដំបង បានថ្លែងសុន្ទរកថាមួយ ក្នុងនាមនៃសម្តេចព្រះសង្ឃនាយកទាំងពីរគណៈ ទឹងព្រះសង្ឃក្នុងកម្ពុជរដ្ឋទាំងមូល មានសេចក្តីដូចតទៅនេះ៖

សូមថ្វាយព្រះពរ សម្តេចព្រះមហាក្សត្រិយានី ជាម្ចាស់ដីវិត

សូមថ្វាយព្រះពរ សម្តេចទេជយុវរាជព្រះប្រមុខរដ្ឋ

សូមទ្រង់ជ្រាប ។

ក្នុងនាមនៃមន្ត្រីសង្ឃគ្រប់ឋានៈ ក្នុងព្រះពុទ្ធចក្រក្តី ទឹងក្នុងនៃព្រះក្រៅ ដែលបិតនៅក្រោមឧត្តមនៃសម្តេចសង្ឃនាយកទាំងពីរគណៈ

ហើយដែលបានមកជួបជុំគ្នាមហាសន្និបាតនេះ អាត្មាភាព សូមថ្វាយ
នូវព្រះពរ ថ្វាយនូវអំណរព្រះមហាករុណាគុណដ៏ខ្ពង់ខ្ពស់បំផុត នៃអង្គ
សម្តេចព្រះប្រមុខរដ្ឋ ដែលទ្រង់សព្វព្រះរាជហឫទ័យស្តេចយាងមកជាអធិ-
បតី ក្នុងពិធីអនុស្សាវរីយ៍មហាសន្និបាតទី ១៨ នៃមន្ត្រីសង្ឃនេះ ។

សូមថ្វាយព្រះពរ

អម្បាញ់មិញនេះ លោកអ្នកទេសរដ្ឋមន្ត្រីទទួលបន្ទុកការក្រសួងធម្មការ
បានថ្លែងសេចក្តីថ្វាយពត៌មានអំពីវឌ្ឍនភាព នៃព្រះពុទ្ធសាសនា ក្នុង
ប្រទេសកម្ពុជារួចហើយ ។

ឥឡូវនេះ អាត្មាភាព ជាតំណាងមន្ត្រីសង្ឃទាំងអស់ សូមព្រះ
រាជទានព្រះរាជវិភាស ដើម្បីថ្វាយពត៌មានខ្លះ អំពីសេចក្តីពេញចិត្ត
សេចក្តីរីករាយរបស់សង្ឃ ចំពោះភាវនានៃប្រទេសកម្ពុជា ខ្ញុំព្រះ
ពុទ្ធសាសនាក្នុងកម្ពុជរដ្ឋទាំងមូល ដោយសង្ខេបដូចតទៅនេះ:

ព្រះសង្ឃទាំងអស់បានដឹងច្បាស់លាស់ណាស់ថា ប្រទេសកម្ពុជា
ដែលបានរួចផុតអំពីអំណាចនៃបរទេស ហើយបានទទួលឯករាជ្យ អត្ថាក្រិតគឺដោយសារព្រះរាជសកម្មដ៏អង់អាច ខ្ញុំព្រះរាជនរោ-
ចាយដ៏ឧត្តមនៃសម្តេចព្រះប្រមុខរដ្ឋ ។ លុះបានដឹងដូច្នេះ ហើយក៏កើត
មានចិត្តរីករាយយ៉ាងខ្លាំងក្លា ព្រមទាំងមានតាវតិង្សក្តីប្រកបដោយកតញ្ញូ-
ធម្មយ៉ាងវិក្រៃលែង ចំពោះអង្គសម្តេចព្រះប្រមុខរដ្ឋ ឥតមានអ្វីខ្ញុំងឹង

មកបំបាត់បំបែកបានឡើយ មិនត្រឹមតែប៉ុណ្ណោះ ព្រះសង្ឃតាំងអស់
សឹងមានសេចក្តីសង្ឃឹមកក់ក្តៅជាទីបំផុត ចំពោះព្រះពុទ្ធជាម្ចាស់តាំងបាលសង្គម
ពុទ្ធិយមបច្ចុប្បន្ន ដែលមានអង្គសម្តេចព្រះប្រមុខរដ្ឋជាអគ្គនាយកថា
អាចនឹងជួយទប្តម្ភព្រះពុទ្ធសាសនាឲ្យមានវឌ្ឍនភាពតទៅអនាគត យ៉ាង
ប្រសើរជាងបច្ចុប្បន្នកាលនេះទៅទៀតពុំខាន ព្រោះព្រះសង្ឃតាំងអស់
បានយល់ឃើញថា ព្រះពុទ្ធសាសនាដែលមានទៅក្នុងប្រទេសកម្ពុជា
តាំងពីក្នុងពុទ្ធសតវត្សទី ១៣ មកហូតដល់ពុទ្ធសតវត្សទី ២០ នេះប្រមាណ
ជាងពីរពាន់ឆ្នាំហើយ តែងបានទទួលនូវព្រះបារមីជូបត្តម្ភជាដរាបមក ។

ក៏ក្នុងបច្ចុប្បន្នកាលនេះ ព្រះពុទ្ធសាសនាក្នុងប្រទេសកម្ពុជា បាន
ទទួលហានិភ័យជាសាសនារបស់រដ្ឋ នេះជាសក្តានុពលនៃព្រះបារមីជូបត្តម្ភដ៏
ខ្ពង់ខ្ពស់បំផុត នាំឲ្យព្រះសង្ឃពុទ្ធសាសនិក មានចិត្តរីករាយជាទីបំផុត
តែមានអ្វីនឹងប្រៀបផ្ទឹមបាន ដោយមានជំនឿថា បើរដ្ឋបានចំរើនរុង-
រឿងព្រះពុទ្ធសាសនាក៏បានចំរើនរុងរឿងដែរ ព្រោះព្រះពុទ្ធសាសនាជា
សាសនារបស់រដ្ឋ ជាប់នៅជាមួយនឹងរដ្ឋ ។

ដោយហេតុដូច្នេះ បានជាព្រះសង្ឃតាំងអស់ដែលជានិមិត្តរូបនៃព្រះ-
ពុទ្ធសាសនា មិនព្រងើយកន្តើយនឹងកិច្ចការរបស់រដ្ឋឡើយ សឹងបានតាំង
ចិត្តគំនិតរួបរួមជាមួយនឹងព្រះពុទ្ធិបាលហើយជួយបំពេញកិច្ចការ
គ្រប់យ៉ាង ដែលនាំឲ្យរដ្ឋបានចំរើនរុងរឿងមានការសន្តិសាលានឹងការ

ដ៏តស្រះជាដើម រៀបរៀងនៃតំបូងការខ្លះដែលផ្តុយនឹងពុទ្ធវិន័យ ។

សូមថ្វាយព្រះពរ !

ម្យ៉ាងទៀត ព្រះសង្ឃគាំងអស់ មានចិត្តរីករាយយ៉ាងខ្លាំងចំពោះការសម្រេចនៃសមាជជាតិលើកទី ១២ អំពីបញ្ហាដែលត្រូវបញ្ចូលការសិក្សាទាំងព្រះពុទ្ធសាសនាទៅក្នុងការសិក្សាខ្លួនៗ ក្នុងព្រះពាណាចក្រដោយមានសង្ឃឹមថា យុវជនគំនិតយើងបានទទួលការសិក្សាទាំងព្រះពុទ្ធសាសនាខ្លះៗ ហើយការសិក្សានេះ នឹងក្លាយជាការអប់រំឲ្យយុវជនខ្មែរមានអនាគតរបស់ខ្លួន អាចស្ថិតនៅក្នុងរង្វង់នៃព្រះពុទ្ធសាសនាបានពោះយើងវជនគំនិតពោះ មិនបានទៅជាពុទ្ធសាសនិកកំណាយ តែគង់បានចេះដឹង បានស្គាល់តម្លៃព្រះពុទ្ធសាសនាខ្លះតុំពាន ។

នៅអវសានខេះ អាត្មាភាពក្នុងនាមនៃព្រះសង្ឃគាំងអស់សូមថ្វាយនូវព្រះពរជ័យសួស្តី ជោគជ័យមហាមង្គលវិបុលសុខគ្រប់ប្រការ ចំពោះសម្តេចមហាក្សត្រិយានី ចំពោះសម្តេចព្រះប្រមុខរដ្ឋ សូមទ្រង់បានប្រកបដោយព្រះជន្មាយុយឺនយូរ មានព្រះសុខភាពបរិបូណ៌ ឈ្នះអស់មារសត្រូវគ្រប់ទិសទី តុំបីឃ្លៀងឃ្លាតទៅជាបាវជនៃក្រៅតិះនេះឡើយ ។

សូមព្រះពុទ្ធសាសនា ខ្ពង់ប្រុងសុភមង្គលបានចំរើនរុងរឿង ។

X

X X

លុះចប់សុន្ទរកថានេះហើយ ព្រះសង្ឃកិច្ចនិស្ស័យធម៌ដយន្តោប្រសិទ្ធិតដ៏យ ថ្វាយចំពោះសម្តេចព្រះមាតុជាតិ ទីដ៏សម្តេចព្រះប្រមុខរដ្ឋ ដើម្បីជាសុភមង្គលដ៏ប្រសើរចំពោះព្រះអង្គ ។

តមក សម្តេចព្រះប្រមុខរដ្ឋ បានថ្លែងព្រះសង្ឃថាឥតត្រាន់តែមួយក្នុងព្រះបរមនាមនៃសម្តេចព្រះមាតាជាតិ ទីដ៏ព្រះបរមនាមភ្ជាប់ព្រះអង្គថ្លែងអំណរព្រះគុណចំពោះព្រះសង្ឃគ្រប់ជាន់អស់ ដែលបានខិតខំមកប្រជុំរួមធ្វើអនុស្សាវរីយ៍មហាសន្និបាត ដើម្បីផ្សព្វផ្សាយធម៌នៃយសម្រាប់ព្រះសង្ឃទីដ៏រំលឹកអំពីការប្រជុំសន្និសីទព្រះពុទ្ធសាសនាពិភពលោក នៅកម្ពុជរដ្ឋយើង ទីដ៏បញ្ជាក់អំពីការស្ថាបនាកិច្ចការនានា ជាប្រយោជន៍ជាតិទីដ៏ព្រះពុទ្ធសាសនា ដើម្បីស្វែងរកទុតមប្រយោជន៍ គុណភាពទីដ៏សេចក្តីថ្លៃថ្នូរទីដ៏តម្រឹកវប្បធម៌ជាតិ ឲ្យជ្រួតជ្រាបដល់ប្រជាពលរដ្ឋគ្រប់ហាន:ជាន់អស់ក្នុងកម្ពុជរដ្ឋយើង ។ ជាពិសេស ព្រះអង្គបានថ្លែងអំពីនយោបាយក្នុងប្រទេស ទីដ៏ក្រៅប្រទេស ត្រមជាន់អធិប្បាយអំពីសារពតិមានយប្រទេសនានា ដែលបានអធិប្បាយអំពីគុណភាពនៃប្រទេសកម្ពុជាយើង ។

លុះចប់ព្រះពជសង្ឃថា ដំមានទ្វីមសារនេះហើយ សម្តេចព្រះមហាក្សត្រិយានី ទីដ៏សម្តេចព្រះប្រមុខរដ្ឋ កំបានក្រាបថ្វាយបង្គំលាព្រះសង្ឃជាន់អស់ ដែលមានសម្តេចព្រះសង្ឃនាយកជាន់ពីគណៈ ជាប្រធានហើយដោយមានព្រះពជបរិពារដែលដង្ហែអមផង បានស្តេចយាងទៅគ្តន់

ចូលព្រះបរមកដាំង ដោយមានការធ្វើតាវៀតចូថ្វាយជាព្រះរាជកិត្តិយស ដូចកាលស្តេចយាងមកដល់ដែរ ។

ពិធីអនុស្សាវរីយ៍មហាសន្និបាតលើកទី ១៨ នៅតុង្គវិស្សាល័យព្រះសុភមង្គល បានចប់សព្វគ្រប់នៅវេលាម៉ោង ៩ ទំនឹង ៣០ នាទី ក្រោយពេលដែលព្រះសង្ឃ បានឧទ្ទិសកុសលរួច ។

ចាប់ពីថ្ងៃទី ២៦ រហូតដល់ថ្ងៃទី ២៩ មករា ១៩៦២ គឺ ព្រះសង្ឃ ចាំង ២ គណៈ ប្រជុំនៅវត្តឧណ្ណាលោម ទឹងវត្តបទុមវតីរាជវរារាម ក្រោមអធិបតីភាពនៃសម្តេចព្រះសង្ឃនាយកគាមគណៈ ខិតខំតាមកម្មវិធីដែលសម្តេចចាំងពីរគណៈចាត់ធ្វើ ។

នៅវេលារសៀលនៃថ្ងៃទី ២៤ មករា ១៩៦២, នៅមន្ទីរសង្ឃរដ្ឋកុសុមៈ ក្នុងសង្កាត់លេខ ៣ ក្រុងភ្នំពេញ មានធ្វើមហាសន្និបាតមួយក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ នៃសម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ដីវត្តលើត្បូង ។

ចាប់តាំងពីម៉ោង ៤ រសៀលៗ, នៅទីប្រជុំ គេបានសង្កេតឃើញជាអាទិ៍ សម្តេចព្រះសង្ឃនាយកចាំងពីរគណៈ ព្រះរាជាគណៈហាខាន់ក្រមមេគណ អនុគណគ្រប់ខែត្រ ព្រមទាំងអធិការក្នុងក្រុងខ័ណ្ឌខែត្រក្បែរខ្លះ ព្រមទាំងភិក្ខុសាមណេរជាច្រើនរយអង្គទៀត ។

ផ្នែកគ្រហស្ថ សហជាតិនៃ ខេត-ផន ព្រះរាជប្រតិភូប្រចាំក្រុងភ្នំពេញ

សហជីវិន សុិន-បុប្ផកោ រដ្ឋលេខាធិការក្រសួងធម្មការ សហជីវិន ម៉េ-
កេង-ហ៊ាន នាយខុទ្ទកាល័យជាដំណាងលោករដ្ឋមន្ត្រី ក្រសួងសាធារណ-
សុខាភិបាល សហជីវិន កុំយ-លុត អធិបតីវេន.សមាគម សហជីវិនតុង-គត
ចាងហ្វាងគយ សហជីវិន ខេត-យុត ហិរញ្ញិកនៃសមាគម នឹងសមាជិក
សមាជិកានៃសមាគមត្រមាំងចាសក ចាសិកាជាច្រើនរូបទៀត ។

នៅវេលាម៉ោង ៩ នឹង ១៥ នាទី សម្តេចព្រះមាតាជាតិ ដោយ
មានសម្តេចក្រុមព្រះ ស៊ីសុវត្ថិ- មុនីវេត ប្រធានខុទ្ទកក្រុមប្រឹក្សាព្រះរាជ
បល្ល័ង្ក ឯកឧត្តម ផូ-ត្រឿន ឯកឧត្តមតំណាងដ៏ម៉ឺងម៉ាត់ អនុប្រធានសមាជិក
ឧត្តមក្រុមប្រឹក្សាព្រះរាជបល្ល័ង្ក លោកឧកញ៉ា ធេង.ហាក់ ចាងហ្វាងវេជ្ជ-
បាល កងព្រះបរមរាជវាំង លោកវរសេនីយ៍ឯក សរ.ហោ ព្រះរាជឱង្ការ
ត្រមាំងព្រះរាជបរិវារផ្ទាល់ព្រះអង្គ ជាច្រើនទៀតដង្ហែព្រះអង្គផង ចាន
ស្តេចយាងដល់មន្ទីរសង្ឃភោគក្រុសុមៈ ដែលកងទ័ពណៈនោះ ក្រុមចាហាន
រក្សាព្រះអង្គ នឹងក្រុមចាហានកងទ័ព ចានថ្វាយគារវៈកិច្ចលើកទាំងពុទ្ធបូជា
កងទ័ពជាព្រះរាជកិត្តិយស ។ នៅគេលចុះតីព្រះទីនាំងវេយ្យាឧ្ត សម្តេចព្រះ
មាតាជាតិ ទ្រង់ចានខ្លួលការក្រាបថ្វាយបង្គំតីលោក ឃួន-វិណ អធិបតី
សមាគម សហជីវិន ខេត-ផន សហជីវិន សុិន.បុប្ផកោ នឹងសមាជិកសមា-
ជិកាសមាគមដទៃទៀត ហើយតាមធម្មតាគោរពកងទ័ពជាតិក៏ចាប់ផ្តើមឡើង ។
តមក សម្តេចព្រះមាតាជាតិ ស្តេចយាងចូលកងទ័ពបង្ហាន់សាលា ថ្វាយបង្គំ

ព្រះសង្ឃ ដែលមានសម្តេចព្រះសង្ឃនាយកតាំងតំណែងជាប្រធាន ។

ក្រោយដែលសម្តេចព្រះមាគាជាតិ ទ្រង់គង់ប្រថាប់លើព្រះសុវណ្ណ-កោច្ចៈរួចហើយ, លោកអធិបតីនៃសមាគមគំលាន់ឧបដ្ឋានព្រះមហាក្សត្រិ-យានីបានថ្វាយសុន្ទរកថាមួយ រៀបរាប់អំពីដំណើរការលូតលាស់នៃសមា-គមនេះ ដែលជាតំរុសគឺអំពីថ្ងៃទី៦ ខែកញ្ញា ឆ្នាំ ១៩៦១ ទំនឹងការគ្រោងទុកក្នុងឆ្នាំ ១៩៦២ តទៅទៀត ។

លុះចប់សុន្ទរកថា នៃលោកអធិបតីសមាគមហើយ សម្តេចព្រះមាគាជាតិ ព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យថ្លែងខ្លួនព្រះសង្ឃថាមួយដូច តទៅនេះ ៖

ខ្ញុំព្រះករុណា សូមនមស្សការសម្តេចព្រះសង្ឃនាយកតាំងតំណែងជាយគោរព !

ព្រមទាំងព្រះថេរានុត្ថេរគ្រប់ព្រះអង្គ !

មួយអន្លើនឹងតំណែងជាកូនចៅ ដែលមានគណៈកម្មាធិការជាដើម ។

ខ្ញុំព្រះករុណា ខ្ញុំ សូមសំដែងនូវសេចក្តីអំណរគុណយ៉ាងក្រៃលែង ចំពោះតំណែងស្នាគមន៍របស់អធិបតី នៃសមាគមគំលាន់ឧបដ្ឋាន ព្រះ-មហាក្សត្រិយានី ដែលបានថ្វាយចំពោះខ្ញុំ ។

ខ្ញុំព្រះករុណា ខ្ញុំ មានហឫទ័យសោមនស្សជាពន់ពេក ដោយមានកត្តិយសមកជាអធិបតី កម្មវិធីមហាសន្និបាតនេះ ។

ដោយបានជ្រាប ខ្ញុំសេចក្តីថ្លែងការគោរពសិលធម៌ទីឆ្នាំ ឆ្នាំវត្ត ដែលបានចំរើនលួតលាស់កន្លងទៅ ១៨៦១ កន្លងទៅ យើញថា មានលទ្ធផលប្រសើរជាងពីរភាគ ។ ខ្ញុំព្រះករុណា-ខ្ញុំ មានសេចក្តីសង្ឃឹមយ៉ាងមាំថា : តទៅអនាគត កិច្ចការដើម្បីតែលបំរុងទីឆ្នើតទៅនេះ ទីឆ្នាំចំរើនជាកំយ៉ាងភាព ដោយស្នាដៃយ៉ាងចំណាន របស់គណៈកម្មាធិការដែលមានឯកឧត្តម ឃួន-ឈៀ ជាប្រធាន ។

ជាអាសាន ខ្ញុំព្រះករុណា-ខ្ញុំ សូមប្រគេនដូនតាសិរីភ្លូសាធុការ សូមព្រះអង្គទីឆ្នាំកូនចៅ បានប្រកបដោយសេចក្តីសុខ-ចំរើនគ្រប់ប្រការកុំបីឃ្លាត ។

លុះចប់ព្រះសង្ឃថានេះហើយ ព្រះសង្ឃក៏ចាប់ស្មាធ្យាយធម៌ដយៗខ្លាំថ្វាយចំពោះព្រះអង្គ ។

នៅវេលាម៉ោង ៩ ទីឆ្នាំ ៤៩ នាទី បន្ទាប់តីគ្រង់បានថ្លែងនូវព្រះសង្ឃ-ថាចប់ហើយ សម្តេចព្រះមាតាជាតិ ដោយមានព្រះកដចតែាដែលតាមហែផង បានថ្វាយបង្គំសម្តេចព្រះសង្ឃនាយកភាំងតីព្រះអង្គ ព្រមភាំងព្រះសង្ឃ ទីឆ្នាំលាខុជាសក ខុជាសិកា ជាកូនចៅព្រះអង្គ យាងត្រឡប់មកព្រះបរមរាជវាំងវិញ ដោយមានក្រុមគាហានបានថ្វាយតារវតិច្ចដូចកាលស្តេចយាងមកដល់ដែរ ។

បន្ទាប់មក សមាជិកសមាជិកានៃសមាគម ភាំងព្រះសង្ឃ ភាំង

គ្រហស្ថ កំពុងបន្តកិច្ចធ្វើមហាសន្និបាតសាមញ្ញ ដូចដែលធ្លាប់បានធ្វើជារៀងរាល់ឆ្នាំមក ។

ម្យ៉ាងទៀត ក្នុងគោលប្រជុំធ្វើអនុស័ព្ទមហាសន្និបាតលើ ១៨ នៃមន្ត្រីសង្ឃ ពីថ្ងៃ ២០ ដល់ថ្ងៃទី ២៥ មករា ឆ្នាំ ១៩៦២ នេះ, នៅវត្តទណ្ឌាលោម មហាសន្និបាតនៃមន្ត្រីសង្ឃ បានធ្វើសេចក្តីសម្រេចចិត្តមួយ មាន ១៩ ខ ដូចតទៅនេះ ៖

១- សេចក្តីព្រាងកំណែរយកចិត្ត នៃលោកចៅអធិការ អនុគណ. មេគណ ។

បកតាមសេចក្តីព្រាងតាំងស្រុករបស់គណៈកម្មការ ដែលបានតែងតាំងឡើងតាមលិខិតបង្គាប់ការក្រសួងធម្មការលេខ ១៩ ក.ធ. ឧ.ន លេខ ៨៣ ក.ធ. ចុះថ្ងៃទី ១៦ កុម្ភៈ ឧ.ន ថ្ងៃទី ២៦ សីហា ១៩៦១ ។

២- លោកវរលេខាធិការ ក្រសួងធម្មការ ស្នើសុំកុំឲ្យតិក្ខសាមណេរ ដើរតើតនើតតាមផ្ទះផ្សារដូចគ្រហស្ថ ដោយធ្លាប់បានឃើញគោលមាំង ៩ ឬ ១០ ដង ។

រឿងនេះ ត្រូវធ្វើការអប់រំផង ត្រូវប្រគល់ការៈទៅសង្ឃាយកទាំងពីរគណៈ ឧ.ន រដ្ឋមន្ត្រីក្រសួងធម្មការ ចាត់ការធ្វើព្រះសង្ឃប្បញ្ញត្តិផង ។

៣- ព្រះភិក្ខុវង្ស កឹម.ភូរ វត្តទណ្ឌាលោម ស្នើសុំត្រង់បញ្ចប់

អនុមោទនាយថា ទានំ ពុទ្ធត្រង់ អាយុ វណ្ណោ សុខំ ពលំ ។

មហាសន្និបាតសម្រេចថា :

យកតាមរបៀបវត្ត ក្នុងក្រុងភ្នំពេញ ដែលព្រះសង្ឃនាយកគណៈ មហានិកាយ បានបង្ហាត់តាលពីពេលមុនបុណ្យ ២៥០០ វស្សា ។

៤- ព្រះឥន្ទមុនី សេរ-នាង វត្តទុណ្ណាលោម ស្នើសុំឲ្យវត្ត ន័មួយ។ ធ្វើវិចិត្រកុដិ ឲ្យសមរម្យតាមអនាម័យ ។

មហាសន្និបាតសម្រេចថា :

យល់ត្រមធ្វើវិចិត្រកុដិ តាមសេចក្តីស្នើពាំង៍ស្រុង របស់ព្រះឥន្ទមុនី សេរ - នាង ។

ក្នុងពេលតាកូរឿងនេះ មានលោកអ្នកមានសទ្ធា ២ រូប គឺ គហបតី បេ - យាន នឹង លី - ស៊ុន - ជួន បានខ្ចូលកំប៉ង់រង ជួយប្រ-គេនប្រដាប់បង្គន់ តាមសមត្ថិយនិយមខ្លះ ដែលអាចជួយបាន ។

៥- អនុគណស្រុកចាត់ដំបង ខែត្រចាត់ដំបង ស្នើសុំ ៤ ខ:

ក- អំពីតិក្ខុសាមណេរខ្លះ ធ្វើដំណើរតាមវេត្តភ្នំង៍ជាដើម មាន សណ្ឋាប់ធ្នាប់តុំសមរម្យ ។

ខ- អំពីតិក្ខុសាមណេរខ្លះ មានវិញ្ញស្ថាយបើកសំឡេង តាមភូមិ ឯកស្រុក ។

គ- អំពីលោកអាចារ្យបង្រៀនសាលាពុទ្ធិកបឋមសិក្សា ទីង៍លោក

ចៅអធិការវត្ត ចេះតែមានការខ្វែងរយោបល់គ្នា ។

ឃ- អំពីរឿងរៀនកម្មដ្ឋាន ដោយគ្រូទំនងគ្រូ សិស្សទំនងសិស្ស មិនត្រូវគ្នា ។

មហាសន្និបាតសម្រេចថា:

ត្រង់ក ទំនង ខ ត្រូវធ្វើការអប់រំ ព្រោះមានក្នុងករណីយកិច្ចនៃលោកចៅអធិការ អនុគណ មេគណស្រាប់ហើយ ។

ត្រង់គ ព្រះពោធិវង្សជាអគ្គាធិការនៃពុទ្ធិកសិក្សាបានតាំងឲ្យស្គាល់បានហើយ, ត្រូវអនុវត្តតាមបទបញ្ជាសម្រាប់សាលាពុទ្ធិកបឋមសិក្សា ។

ត្រង់ ឃ ត្រូវសុំឲ្យក្រសួងធម្មការ តាំងគណៈកម្មការមួយក្រុមពិនិត្យរៀបចំគ្រួបង្រៀនកម្មដ្ឋាន ឲ្យបានត្រឹមត្រូវតាមច្បាប់ព្រះពុទ្ធសាសនា ។

ង- មេគណខែត្រស្វាយរៀង សើសុំឲ្យពង្រីកវិបស្សនាធុរៈឲ្យមានក្នុងព្រះពុទ្ធអាណាចក្រ ។

មហាសន្និបាតសម្រេចថា:

មុនទំនងពង្រីកវិបស្សនាធុរៈ ត្រូវចាត់ការរៀបចំរបៀបបង្រៀនកម្មដ្ឋានឲ្យបានត្រឹមត្រូវសិន ចាំពង្រីកជាខាងក្រោយ ។ ចំពោះទីតំណែងរៀនកម្មដ្ឋាន ឬ វិបស្សនាធុរៈ ត្រូវរៀបចំតំណែងរៀនក្នុងវត្តមួយ ។ ប្រសិនបើត្រូវការ មិនចាំបាច់រៀបចំតំណែងដាច់ខាត ។

ច- ព្រះវិន័យធរ អ៊ុម . សុម វត្តសាកេតសើសុំ ៤ ។:

ក- សុំបំបាត់ភាពថា គេស្គាល់មេគណគ្រូ,

ខ- សុំឲ្យដាំផ្តើមកិច្ចការវត្តចំពោះសង្ឃ,

គ- សុំឲ្យធ្វើសាលាសម្រាប់វត្ត,

ឃ- ស្តាបនកម្មចាំងអស់ មុខនឹងធ្វើសុំឲ្យសង្ឃសំដែងទីឲ្យសិន ។

មហាសន្និបាតសម្រេចថា:

ត្រង់ ក.ខ នឹង ឃ មានកន្លែងព្រះវិន័យស្រាប់ ហើយជាតារាណីយកិច្ច របស់ក្រសួងព្រះសង្ឃនាយក ត្រូវរៀបចំធ្វើព្រះសង្ឃប្រកាស ។

ត្រង់ គ សាលាវត្ត ត្រូវតែធ្វើទុកសម្រាប់វត្ត ។

៨- ព្រះអាចារ្យ ខៀវ-ជុំ វត្តលង្កា ស្នើពីការបញ្ជូលតុន្ធសាសនាទៅកន្លែងសាលាសិក្សាយុវជនកុមារ ។

មហាសន្និបាតសម្រេចថា:

បញ្ហានេះ ពាក់ព័ន្ធនឹងកជង្កៀកបាល ហើយជង្កៀកបាលបានសម្រេចរួចហើយ តាំងពីកន្លែងកាលនៃសមាជទី ១២, ដូច្នេះ មហាសន្និបាតនៃមន្ត្រីសង្ឃនេះ មិនចាំបាច់យកមកពិចារណាទៀតទេ ។

៩- ព្រះវិន័យតែ មេគណខៃត្រូបាត់ដំបង ស្នើសុំឲ្យបន្ថែមការអប់រំពួកតុន្ធិកជន ចាំងបព្វជិតចាំងគ្រហស្ថ ។

មហាសន្និបាតសម្រេចថា:

ត្រូវអនុវត្តតាមការណីយកិច្ចនៃចៅអធិការ អនុគណ មេគណ ។

១០- មេគណខែត្រតាកែវ ស្នើសុំឲ្យពាជការមានសមត្ថកិច្ចជួយរកមធ្យោបាយ បង្កើតពុទ្ធិកវិទ្យាល័យឲ្យបានគ្រប់ខែត្រ ។

មហាសន្និបាតសម្រេចថា:

បញ្ហានេះ ត្រូវសូមឲ្យពាជរដ្ឋាភិបាល បង្កើតពុទ្ធិកវិទ្យាល័យនៅខែត្រណា ដែលអាចបង្កើតបានមុនគេ ហើយចេះតែបង្កើត តទៅទៀតឲ្យបានគ្រប់ខែត្រ ប្រសិនបើអាច ។

១១- មេគណខែត្រកោះកុងស្នើសុំ ២ ខ:

ក- សុំឲ្យពាជរដ្ឋាភិបាល ទំនងសាសនាមពុទ្ធសាសនា ជួយបង្កើតសាលាពុទ្ធិកបឋមសិក្សា ជួយផ្តល់សិក្ខាបករណ៍ផ្សេងៗ ជួយចាត់អាចារ្យបង្រៀនធម្មវិន័យទំនងបង្រៀនបាលី តៅខែត្រកោះកុងតាមផ្លូវការ ។

ខ- សុំឲ្យព្រះសង្ឃខែត្រកោះកុង មានសិទ្ធិចូលមករៀនតៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិតបាន ដ៏ទាច់ប្រឡងប្រជែង បើមានវិញ្ញាបនបត្រពុទ្ធិកសិក្សាហើយ ហើយឲ្យសម្តេច ព្រះពាជាគណៈហានានុក្រម មេគ្គាជួយខ្វល់ព្រះសង្ឃខែត្រកោះកុងឲ្យសំណាក់អាស្រ័យដោយអនុគ្រោះ ។

១២- មេគណខែត្រកំពង់ឆ្នាំងស្នើ ៤ ខ:

ក- អំពីបញ្ហាពាកមធ្យោបាយបំបាត់អធិកវណ៌

ខ- សុំឲ្យក្រសួងធម្មការ បង្កើតការអប់រំជ្ឈានវុគ្គសល្យ ដល់អាចារ្យបង្រៀនក្នុងសាលាធម្មវិន័យកាល់ៗ,

គ- សុំឲ្យដាក់ចូល ជូយរកមធ្យោបាយឲ្យយុវជនអនាគតបានចូលបួសមុនទីឯចូលកាន់មុខដំណែងរាជការ,

ឃ- សុំឲ្យក្រសួងធម្មការ ជូយរកមធ្យោបាយឲ្យលោកអាចារ្យដែលបង្ហាត់បង្រៀនក្នុងសាលាពុទ្ធិកបឋមសិក្សាទីមួយ ។ ឲ្យបានយ៉ាងតិចបំផុតត្រឹម ៦ ខ្នាំ ។

មហាសន្និបាតសម្រេចថា :

ត្រង់ក. បានសម្រេចតាមក្នុងអនុសំវច្ឆរមហាសន្និបាតទី ១៧រួចហើយ,

ត្រង់ ខ. ត្រូវតាំងគណៈកម្មការមួយក្រុម សម្រាប់ត្រួតត្រាសាលាធម្មវិន័យសិន ។

ត្រង់ គ. ស្រេចទៅលើចិត្តរបស់យុវជន ព្រោះព្រះពុទ្ធសាសនាគ្មានបង្ខំទេ,

ត្រង់ ឃ. ត្រូវបង្កើតសមាគមគ្រប់ទ្វីបត្រ ដែលមានមូលដ្ឋានតែមួយនៅក្រុងភ្នំពេញ ដើម្បីជួយទុបត្ថម្ភលោកអាចារ្យបង្រៀនសាលាពុទ្ធិកបឋមសិក្សា ហើយសុំដាក់ចូលជួយទុបត្ថម្ភសមាគមនេះផង ។

១៣- ព្រះវិន័យធរជាអនុគណស្តីទីទ្វៃត្រកំពតស្នើសុំ ៣ ។:

ក- បញ្ហាលំបាកចំពោះសិស្សពុទ្ធិកបឋមសិក្សារៀនមិនចប់ខ្នាំ ,

ខ- បញ្ហាតិបាករកអាចារ្យ,

គ- បញ្ហាកែវិញ្ញាសា ប្រឡងចេញពីពុទ្ធិកបឋមសិក្សា ។

មហាសន្និបាតសម្រេចថា :

ត្រង់ក. ជាការរបស់មេគណ អនុគណ ដែលជាអធិការនៃគ្រឹះអធិការស្រុក ពិនិត្យត្រួតត្រាឲ្យមានរបៀបរៀបរយ,

ត្រង់ខ. ស្រេចលើលោកចៅអធិការជាម្ចាស់សាលា ត្រួតគ្រប់គ្រងដោយខ្លួនឯង

ត្រង់គ. ជាការក្រសួងធម្មការ ទទួលអគ្គាធិការផ្នែកនៃពុទ្ធិកសិក្សាបាត់ការ ។

១៨- មេគណនៃគ្រឹះក្រុង ស្នើសុំឲ្យសង្ឃមហាសន្និបាតរិះរកមធ្យោបាយបញ្ឈប់ឲ្យតឹងរឹងចៅលើចៅអធិការវត្តខ្លះ ដែលមិនត្រមប្រតិបត្តិតាមព្រះវិន័យបិដក តាមព្រះសង្ឃប្រកាសទំនៀមតាមសាកលរបៀង ។ ។

មហាសន្និបាតសម្រេចថា :

រឿងនេះ មិនត្រូវធ្វើសង្ឃប្រកាសបញ្ឈប់ឲ្យតឹងរឹងចៅទៀតទេ ព្រោះមានព្រះសង្ឃប្រកាសទំនៀមព្រះរាជក្រមៈនៅជាធរមាននៅឡើយ គ្រាន់តែអនុវត្តន៍ឲ្យសមគួរ តាមកាលៈទេសៈប៉ុណ្ណោះបានហើយ ។

១៩- មេគណនៃគ្រឹះតំពន់ស្ពឺស្នើសុំ ២ ខ:

ក- សុំគ្រប់សាលាជម្នាំទើយ ធ្វើលិខិតបកនៃគ្រឹះ បញ្ជូនទៅសាលាអនុគណ មេគណ ។

១- អង្គការដែលមន្ត្រីសង្ឃ បានសម្រេចជាឯកច្ឆន្ទ តឹងអនុសំវច្ឆរ-

មហាសន្និបាតហើយ បើភិក្ខុដែលរូបណាមិនប្រតិបត្តិតាម សុំឲ្យលោកគ្រូ អនុគណធ្វើសេចក្តីពិភាក្សាណែនាំ អំពីភិក្ខុដែលរូបនោះ ប្រគេនទៅក្រសួងព្រះសង្ឃនាយក ដើម្បីនិទ្ទិដ្ឋតាមដំណើរការណ៍ ។

មហាសន្និបាតសម្រេចថា:

ត្រង់ក- ត្រូវតែធ្វើ ប៉ុន្តែនេះជាការណែនាំយកចិត្តទុកដាក់របស់មេគណ អនុគណ ចាត់ការ,

ត្រង់ខ- ជាការលើមេគណ អនុគណ ធ្វើសេចក្តីពិភាក្សាណែនាំជូនទៅក្រសួងព្រះសង្ឃនាយក តាមរយៈក្រសួងធម្មការដើម្បីចាត់ការតទៅ។

១៦- ព្រះមុនីកោសល សូរ-ហាយ ស្នើសុំឲ្យបំបាត់ ពាក្យថា "ប្រាក់សង្គ្រតត្រៃ"

មហាសន្និបាតសម្រេចថា:

ត្រូវបំបាត់ពាក្យថា "ប្រាក់សង្គ្រតត្រៃ" ដោយយកពាក្យថា "បច្ចុយលទ្ធផលកម៌ន" ប្រើជំនួសវិញ ហើយកុំឲ្យលោកចៅអធិការខុកប្រាក់កម៌ននោះដោយខ្លួនឯង គឺត្រូវប្រគល់ឲ្យគណៈកម្មការវត្តខុកជាក់ ។

១៧- មេគណវិទ្រត្រស្ងួនត្រែងនិងតេនគិរី ស្នើសុំឲ្យបញ្ឈប់ផ្ទះលោក មានគណិតសាស្ត្រជាដើម ទៅកន្លែងសាលាធម្មវិន័យ ។

មហាសន្និបាតសម្រេចថា :

អាចបញ្ឈប់បានតាមសេចក្តីត្រូវការ ប៉ុន្តែ មិនត្រូវតែប្រែកម្មវិធីប្រឡងឡើយ ។

១៨- អនុគណស្រុកមុខកំពូល ស្នើសុំកុំឲ្យមេគណ អនុគណ ទីដ៏ចៅអធិការគ្រប់វត្ត ខ្លួលស្គាល់គូវ៉ៃក្នុងដែលមានវិន័យយ៉ាត្រចះ-ចាសម្រេចជ្រះស្រឡះហើយ ។

មហាសន្និបាតសម្រេចថា:

មិនអាចសម្រេចបានទេ, ក្នុងកាលៈទេសៈនេះ ។

១៩- អនុគណស្រុកកំពង់សៀមស្នើសុំ ៣ ខ:

ក- សុំឲ្យដាក់បទបញ្ជាត្តិឲ្យបានតឹងរឹងទៅលើរូបចៅអធិការដែលពុំព្រមចូលទៅតាន់ពីប្រដុំអនុសំវច្ឆរមហាសន្និបាតតាមសាលាអនុគណ ។

ខ- បើចៅអធិការណាមានគាំពាធ ឬចាស់ជរាពុំអាចចូលទៅតាន់ពីប្រដុំបានទេ ដោយមានសេចក្តីបញ្ជាក់គ្រប់គ្រាន់ហើយ ចៅអធិការនោះត្រូវចាត់ឲ្យគ្រួសូត្រស្តាំ ឬលោកដែលមានសមត្ថភាពទៅប្រដុំជំនួសខ្លួន ។

គ- បើលោកចៅអធិការរូបណា មានចូលតាន់ប្រដុំអនុសំវច្ឆរ-មហាសន្និបាត នៅសាលាអនុគណគ្រប់កំណត់ ៣ ដង ត្រូវឲ្យចៅអធិ-ការនោះលាចេញពីដំណែង ។

មហាសន្និបាតសម្រេចថា:

សេចក្តីស្នើសុំតាំង ៣ ខ នេះ សូមទុកជាការៈលើសម្តេចព្រះសង្ឃ-នាយកសម្រេចក្នុងពេលខាងមុខ ។

ព្រឹត្តិបត្រសាសនា


ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ៣៤ លេខ ២ ខែ កុម្ភៈ
ព.ស. ២៥០៤ គ.ស. ១៩៦២

- ភ្ជុំ ៣ -





អង្គុលិសន្ទេសរ

ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

បេញ្ចាវល់ខែពិធីសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
–	អំពីអវិជ្ជា លោក -ដេងជ្រើរ រៀបរៀង	១២១
–	លោកភិក្ខុភទ្រកិសម័យ (ត១ប៉ប់) អ្នកឧកញ៉ា ទា-សាន អតីតរដ្ឋមន្ត្រីរៀបរៀង	១៤១
–	ព្រះអភិធម្មបិដក (គម្ពីរព្រះយមកៈ) (ត)៖លោកប៉ូ-ប៉ូ ប្រែរៀបរៀង	១៤៨
–	មធុរសរាហ៍ណ៍(ត)សម្តេចព្រះធម្មលិខិតស្ងួ-ឯម ប្រៃ ព្រះញាណកោសលវង្ស-ឈឺនតាំងត្យ	១៥៤
–	មរហោសថជាតក(ត)លោក អឹម-ភន បម្លងពីសាស្ត្រាស្ងឹកតែព្រះពុទ្ធវង្ស កឹម-គួរ តាំនត្យ	១៦៦
–	រឿងនារទកស្សប កាព្យគាថា ៩ លោក ឃួ-អ៊ុន នំពន្ធ	១៧១
ផ្នែកអក្សរសាស្ត្រ		
–	ការអានភាសាវប្បធម៌ លោក គួច-តឹងឡេង រៀបរៀង	១៧៦
–	ភាសាខ្មែរប្រែចេញពីបរទេស (ត) ដោយគណៈកម្មការវប្បធម៌	២០៣
–	វចនានុក្រមសំស្ក្រឹត-ខ្មែរ (ត) ព្រះមហា ជាំង-ខាត់ រៀបរៀង	២០៤
–	រឿងសាមកុក (ត) ឧកញ៉ា ទូ-កន ប្រែ	២០៥
–	រឿងត្រែងចិន (ត) លោក ភ័យ ប៊ុក ប្រែរៀបរៀង	២០៨
–	ភ្ងមិសាស្ត្រសេដ្ឋកិច្ចអាហ្វ្រិកខាងត្បូង (ត១ប៉ប់) លោក ភ្ជើម-ទឹម ប្រែ	២១១
–	រឿងត្រែងជ្រោះក្ងុសភាសិត៤បទថា ឃ្លានទំអត់,ខ្សត់ទំរក,ឆេទ្យប្រើនកុំយក,ទ្វាបទ្យច្ចុលដិត	២១៦
ផ្នែកកំណត់ទំនីប្រវត្តិការណ៍		
-	មហាសន្និបាតនៃសមាគមមិត្តពុទ្ធិកវិទ្យាល័យ លោក ភ័យ-ប៊ុក រៀបរៀង	២២២
–	ព័ណ៌នាដ្ឋាន ចំរើនសុខភាព	២៣៧

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃដាវ ២៣០រ០០

34è Année — N° 2 — Février 1962

KAMBUJASURIYA

Revue mensuelle de culture religieuse et littéraire publiée par l'Institut-Bouddhique de Phnom-Penh

SOMMAIRE

Partie religieuse page

—L'Ignorance par M. PHENG-CHRIV 121
—Lokkottarabhisamaya par l'Oknha TEA-SAN (suite et fin) 141
—Prah Abhidhamma pitaka (Kampi prah Yamaka) (suite) par M. BOU-PO. 148
—Madhurasavahini (suite) traduit par Samdech Prah Dhammalikhita LOUIS-EM, revu et corrigé par Vén. NHEAN-CHHOEUN. 158
—Mahosotha Jataka (suite) relevé du manuscrit sur feuilles de latanier par M. IM-PHON, revu et corrigé par Vén. KEM-TO 166
—Histoire de Naradakassapa en vers par M. YOU-OUN . . 171

Partie littéraire

—Manière de lire des mots culturels par M. KUOCH-KY-LENG 196
—Activités de la Commission culturelle (suite) 203
—Dictionnaire Sanscrit-Khmèr (suite) par Vén. PANG-KHAT. 204
—Histoire de Sam-Kok (suite) traduite par l'Oknha NOU-KAN 205
—Contes et Légendes populaires de la Chine par M. RAY-BUC 208
—Géographie économique de l'Afrique du Sud (suite et fin) traduite par M. NHEM-KHEM 211
—Commentaires des proverbes cambodgiens par la Commission des Mœurs et Coutumes 216

Notes et Chroniques

—La réunion de l'Association des Amis du Lycée Bouddique par M. RAY-BUC. 222
—Infirmerie de Chamrœun SOKHA-PHEAP. 237

Abonnement annuel (comprenant 12 numéros) : 230 f 00

អំពីអវិជ្ជា

លោក ដេង - ទ្រីវ រៀបរៀង

មុនខ្ញុំពោលថា អវិជ្ជា មានន័យដូចម្តេច ? ជាតត្តៈនាំឲ្យ កើតអ្វី ? សូមពណ៌នាខ្លះតាមសិន ។

តណ្ហាគឺអ្វី ?

តណ្ហា គឺជាទីសំណាក់របស់សត្វ ក្នុងដំណើរត្រាច់ឆ្លាត់ក្នុងវដ្ដសង្សារ ។ តណ្ហាមាន ៣ គឺ កាមតណ្ហា ១ រូបតណ្ហា ១ អរូបតណ្ហា ១ ។

ហេតុដូចម្តេច បានជាហៅថា កាមតណ្ហា ?

បានជាហៅដូច្នេះព្រោះតណ្ហានេះ តោរតេញាដោយកាម (សេចក្តីត្រេក ចំណង់) ប្លែដោយកាមគុណ ៥ គឺ រូប សំឡេង ក្លិន រស សម្ផស្ស ។ សត្វក្នុងកាមតណ្ហាមែនត្រេបជញ្ជក់ តោះប៉ិតិច ប្លែច្រើនខ្លួ កាមគុណ ៥ នេះ មិនដែលអាក់ខានមួយវេលាណាឡើយ ។

ឯកាមតណ្ហាមាន ១១ ភូមិ ដោយកប់ស្ថានមនុស្សប្រកាលជាមួយផង ។

ហេតុម្តេចបានជាហៅថា រូបតណ្ហា ?

បានជាហៅដូច្នេះព្រោះតណ្ហានេះ ប្រាសចាកកាមគុណ ៥ គឺ

ថា បើសត្វណាមានបំណងនឹងទៅកើតជាទោះ ត្រូវឲ្យប្រាសចាកកាម-គុណទាំង ៥ ជាមុនសន្តាន បើពុំដូច្នោះទេ ខ្លួននឹងពុំអាចទៅអាស្រ័យនៅក្នុងភពនោះបានឡើយ ។

សូមបញ្ជាក់ថា ក្នុងរូបភព សត្វទៅត្រូវការប្រើប្រាស់រូបជាប្រយោជន៍ចិត្ត តែមិនមានការប្រកាន់មាំ នឹងការតម្រេកក្នុងរូបដូចជាសត្វក្នុងកាមភពឡើយ ។

ហេតុម្តេចបានជាហៅ អរូបភព ?

បានជាហៅដូច្នេះព្រោះភពនេះ មិនត្រឹមតែប្រាសចាកកាមគុណទាំង ៥ ប៉ុណ្ណោះទេ តែថែមទាំងមិនត្រូវការប្រើរូបទៀតផង ។ ហាំងនេះ បានជាមានសត្វខ្លះដោយយល់ភាន់ស្មានថា ភពនេះជាព្រះនិព្វាន ។ ភពទាំងបីនេះរួមគ្នា ហៅថាសង្សារវដ្ត ឬ សង្សារចក្រ ។

តើមនោគតិនៃសត្វក្នុងព្រហ្មភព មានសភាពដូចម្តេច ?

សត្វក្នុងព្រហ្មភពតែងមានមនោគតិរបស់ខ្លួនមិនខ្វះឡើយ មនោ-គតិនេះ លោតទូងទៅទូងមករវាងភពទាំងបី តាមទំហំនៃកំភ្លាំងផលកម្មរបស់ខ្លួន ។ ព្រោះណាសត្វប្រៀបដូចស្មារដែលមានខ្សែជាប់ក ហើយដែលគេចងទុកក្នុងកន្លែងមួយមានចុះបង្គោលបី ប្រកបដោយឈើខ្នងខាងបុង សម្រាប់ឲ្យសត្វនេះអាចលោតផ្លោះទៅមកបាន ។ ស្មារមិនអាចលោតផុតពីបង្គោលបីបានយ៉ាងណា ព្រោះណាសត្វក៏មិនអាចនឹងស្ទុះ

ផុតចេញពីភពប៉ុនយ៉ាងនោះ រៀវលែងតែវិញ្ញាណនៃព្រះវិណាស្រុតចេញ ។

មានបញ្ហាចោទឡើងថា ចុះសុគតិស្ថាននោះដូចម្តេច ? ទុគ្គតិស្ថាននោះដូចម្តេច ?

សុគតិស្ថានប្រែថា ស្ថានមានដំណើរស្រួល ទុគ្គតិស្ថានប្រែថាស្ថានមានដំណើតែងតីជាក ដោយអំណាចការផ្សងគ្នានៃផលកម្ម តែនោះជាយ៉ាងណា ក៏សត្វមិនអាចសុះរួចពីភពបីបានឡើយ ប្រៀបដូចជាខ្វែងដែលបុគ្គលបង្ហើរឡដំអាកាស ខ្វែងនោះនឹងត្រូវតែធ្លាក់មកលើផែនដីវិញជាប្រាកដ កាលណាអស់មានខ្យល់ច្រ ហើយត្រូវតែហោះឡើងទៅទៀត កាលណាត្រឡប់មានខ្យល់មកវិញ ។

ព្រះពុទ្ធទេសនាថា តែមានជាតិ ត្រូវមានជរា ត្រូវមានព្យាធិ ត្រូវមានមរណៈ ។ វត្តចាំងបួននេះ មានជាធម្មតាក្នុងភពបី ។

គេឧបមាទុកភពចាំងបី ដូចជាផ្ទះបីខ្នង មានសភាពផ្សងពីគ្នាគឺផ្ទះទី ១ ធ្វើអំពីស្មឹក ផ្ទះទី ២ ធ្វើអំពីឈើប្រក់ក្បឿង ផ្ទះទី ៣ ធ្វើអំពីឥដ្ឋ ប្តូបេតុងអារម៉ៃ ហើយក្នុងផ្ទះទីមួយ ។ សឹងមានមនុស្សម្នាក់អាស្រ័យទៅ ។

គេសួរថា តើមនុស្សទៅចាំងបីនាក់ខាងលើនេះ មានការថ្លៃថ្លារិះសេសជាងគ្នាបែបណាខ្លះ ? បើម្នាក់ ។ សុទ្ធតែមានជារយ៉ាងមុតព្យុះទៅនឹងជញ្ជាំង រង់ចាំឲ្យតែជល់តែលនឹងកាត់កម្ចាស់ផ្ទះរៀងខ្លួន ។ ត្រង់ចំណុច

នេះ ព្រះពុទ្ធឱសថ៍ មានដំណើរស្រួលនឹងដំណើរតំបាកប្លែកគ្នាខ្លះតិចតួចមែន តែគោះបីខ្លួនបាត់សុខស្រួលមួយគ្រា តែនឹងគ្រាក្រោយខ្លួននឹងត្រូវទៅជួបនឹងទុក្ខវិញជាមិនខាន ព្រោះវិញ្ញាណសត្វមិនមែនតាំងនៅជាស្ថាពរតែងតតន័មួយ ។ ឡើយ តែថាសត្វដែលទៅសំចតនៅអបាយតតិ្ត រូបភព ឬ កាមភពតិ្ត តែងតែត្រូវមរណៈសង្រ្គាមមកផ្តាច់ជីវិតន្ទ្រើយដូច ។ គ្នាជាធម្មតា ។

ដូច្នេះ សម្រេចសេចតិ្តថា តតាំងបី ឬ សង្ខារវដ្តជាកន្លែងទុក្ខ ព្រោះមានធម៌បីតី អនិច្ចំ ទុក្ខំ អនត្តា ស្ថិតនៅជានិច្ច ។

មានបញ្ហាចោទឡើងថា ម៉េតពីជាកន្លែងទុក្ខ ហេតុអ្វីក៏មានសត្វតេញចិត្តមកកើតច្រើនម្ល៉ះ ? ហើយមុននឹងបាត់ខ្លួនមកកន្លែងត្រៃភព តើវិញ្ញាណថ្នសត្វតាំងនោះ សំចត ឬ អាស្រ័យនៅស្ថានណា? តតណា ឬ ភូមិណា ? សូមទុកដោះស្រាយចំណុចនេះដែលជាចំណុចធំទៅខាងមុខ។

សួរថា វិញ្ញាណសត្វកាលបើមានហើយ នឹងគាចសាបសូន្យទៅវិញទេ ដោយស្វ័យប្រវត្តិ ឬទេ ?

វិញ្ញាណនេះតែមានហើយ មិនងាយនឹងសាបសូន្យទៅវិញដោយឯកឯងឡើយ សូម្បីវិញ្ញាណសត្វយ៉ាងតូចតាច ដូចជាស្រមើលភ្នែដោយ។ បើគេយកបូបសត្វទៅសន្ធប់កន្លែងគុហាភ្នំក្តី កន្លែងដីជំរៅប៉ុន្មានក្តី កន្លែងដែលឆ្ងាយយ៉ាងដូចម្តេចប្រសប់ត្រៃក្តី ទេវតាដុតភ្លើងសម្លាប់វិញ្ញាណសត្វនឹង

វិនាសសាបសូន្យជាមួយឬទេ? ។ ឆ្លើយថា វិនាសតែរូប ចំណែកវិញ្ញាណ
មិនវិនាសសោះ ។ បើមិនវិនាសតើអាស្រ័យនៅទីណា ស្ទុះចេញទៅតាម
ណា ហេតុអ្វីក៏មិនឃើញ? ។ ឆ្លើយថា កាលបើរូបវិនាសហើយ វិញ្ញាណ
ត្រូវស្ទុះទៅកើរូបថ្មីទៀតជាធម្មតា តាមសមគួរដល់កំឡាំងផលកម្ម ដោយ
ឥតមានទុរណាអាចដឹងឮបានឡើយ ព្រោះវិញ្ញាណជាអរូបធម៌ ។

ចុះបើយ៉ាំងដូច្នេះ គឺថាបើវិញ្ញាណមានហើយ។ នៅតែគ្រាប់ផ្តាំត
កន់កលវដ្តសង្សារ ដូចជាសត្វស្វាដែលប្តូរលចង់ទុកកន់ពេងមានបង្គើល
ប៉ ហេតុម្តេចវិញ្ញាណថ្នាំនោះ ដែលមិនទាន់ចូលមក កំពេញចិត្តនាំគ្នា
ពាំនែនពាំនែកោដិម្តង។ មកចូលឲ្យជាប់កន់លោកដូចជាត្រីជាប់ដុំចង្ហើ
អ្វី? តាមធម្មតា តែកន្លែងណាមានទុក្ខ មានគ្រោះថ្នាក់ មានសោក
ពេគភ័យ ទុបមាថា នៅស្រុកណាមានកើតអាសន្នពេគជាអាទិ៍ តែតែង
តែដៀសវាងមិនទៅស្រុកនោះជាដាច់ខាត ព្រោះគេត្រូវការតែសេចក្តី
សុខ ។ ដំណើរហេតុយ៉ាំងណា ចានជាវិញ្ញាណថ្នាំនេះតែងនាំគ្នាសម្រុក
ចូលមក តើមុនទីដ៏ចូលមកភ្លាំចានដឹងថា ត្រៃគភជាកន្លែងទុក្ខឬទេ? ជា
កន្លែងដែលសត្វចូលហើយ ត្រូវប្រថុយចេញចានដោយលំបាកឬទេ? ។

មនុស្សទៅតែត្រី ។ ទំស្ទុះត្រូវស្ទើរចាក់អង្រែត ដើម្បីដៀសឲ្យផុត
ពីការវិនាស ដែលជាការណ៍ដួយនឹងភាក្យចចាមអារាមតាំបូកណាដែលថា
ត្រីសុខចិត្តជាទាក្ខួនទីដ៏ចិញ្ចឹមមនុស្ស ព្រោះតាំងកូនម្តាយមួយបីដ៏ ។ កុំថា

ឡើយដល់ពៅត្រី សូម្បីតែមូស ឬសង្កើច ជាសត្វតូចល្អិត ក៏ភ័យនឹង
សេចក្តីស្លាប់ណាស់ដែរ ចូរយើងក្រឡេកមើល ! ក៏រំហើរនឹងរំវាត់
ការណាក៏ឃើញមនុស្សដេញនេះ ឬដេញតាមចាប់ ។ ចុះសត្វមាច
ដែលនាំគ្នាតាំងរយៈតាំងពាន់ មកក្រមក្តើងចង្រឹង ហើយបាននូវសូ
សេចក្តីអន្តរាយ តើបាណកសត្វនេះ ដឹងថាក្តើងជាសត្រូវនឹងគាត្មាឬទេ?
ត្រីស៊ីនូយដែលអ្នកនេសាទចិទនៅនឹងសន្ទូច ហើយឆ្លាក់ខ្លួនដល់សេចក្តី
ស្លាប់ តើវាដឹងថា មានសន្ទូចពួននៅខាងក្នុងនូយឬទេ? ពពែបរិភោគ
លាមកខ្លួនឯង តើវាដឹងថា លាមកជាវត្ថុស្មោកគ្រោកឬទេ?

ឧទាហរណ៍ប៉ុណ្ណេះ បញ្ជាក់ឲ្យឃើញថា សេចក្តីអន្តរាយឬសេចក្តី
ទុក្ខវេទនាដូចគ្រោលមកខាងលើ បណ្តាលមកតែពីការមិនដឹងជាហេតុ ។
សារុបសេចក្តីថាឃើញថា សេចក្តីទុក្ខទាំងពួងកើតមានឡើងដោយមាន
ការមិនដឹងជាមេ ។

ចើដូច្នេះ វិញ្ញាណថ្នាំនៃសត្វ ដែលច្រោលសម្រុកមកក្នុងកាយ ក៏
មានការមិនដឹងជាហេតុដែរឬ ? នេះគឺជាការណ៍ពិតឥតកម្រើក ។ អ្វីជា
ការមិនដឹងដែលទុកជាមេក្នុងធំ ដែលជម្រុលវិញ្ញាណថ្នាំនៃសត្វឲ្យមក
ចូលកន្លង់ដុះគឺត្រែកគ ? ការមិនដឹងនេះហៅថា អវិជ្ជា ។

ហេតុម្តេច ទ្រាន់ជាហ៊ានចាត់ទុក អវិជ្ជា ជាមេបង្កវិញ្ញាណថ្នាំ
នៃសត្វក្នុងត្រែកគ តើមានអ្វីនឹងបញ្ជាក់ទុកជាភស្តុតាង ?

ដើម្បីទិទ្ធន៍យោបល់នេះ សូមលើកយកបដិច្ចសមុប្បាទធម៌មកថ្លែងបញ្ជាក់ជាកស្តុតាងដូចតទៅ តែសូមថ្លែងបដិច្ចសមុប្បាទធម៌បដិលោមជាមុន ៖

"ការអស់សង្ឃឹម ការតូចចិត្ត ការខ្វល់ខ្វាយ ការកន្ទក់កន្ទេញ សេចក្តីសោយសោក សេចក្តីស្ងប់ ការចាស់ជរា ការមានជម្ងឺដំណាត់ ពាំងនេះមកតែពីមានជាតិ គឺការកើត, បានជាមានជាតិ មកពីមានភព, បានជាមានភព មកពីមានឧបាទានគឺសេចក្តីប្រកាន់ជាប់ចិត្ត, បានជាមានឧបាទាន មកពីមានតណ្ហាគឺសេចក្តីត្រូវការ, បានជាមានតណ្ហា មកពីមានវេទនាគឺសេចក្តីដឹងអារម្មណ៍, បានជាមានវេទនា មកពីមានផស្សៈគឺការប៉ះពាល់, បានជាមានផស្សៈ មកពីមានអាយតនៈ គឺកន្លែងកើតអារម្មណ៍, បានជាមានអាយតនៈ មកពីមាននាមរូប, បានជាមាននាមរូប មកពីមានវិញ្ញាណ, បានជាមានវិញ្ញាណ មកពីមានសង្ខារ គឺការផ្សំផ្គុំជាតុជាការប៉ាច់ប៉ាច់ ដើម្បីឲ្យកើតបានជាសរីរៈ, បានជាមានសង្ខារ មកពីមានអវិជ្ជា គឺជាការមិនដឹង" ។

បើថ្លែងបដិច្ចសមុប្បាទធម៌ ដោយអនុលោមវិញ គឺត្រូវកប់យកអវិជ្ជាជាដើមអាទិ៍ ដោយសង្ខេបដូចតទៅ :

"អវិជ្ជាជាបច្ច័យឲ្យមានសង្ខារ ។ ជាបច្ច័យឲ្យមានវិញ្ញាណ ។ ជា

បច្ច័យឲ្យមាននាមរូប ។ ល ។ តពជាបច្ច័យឲ្យមានជាតិ ។ ជាបច្ច័យឲ្យ
មានជរា ព្យាធិ មរណៈ" ។

បើគេសួរថា តពីអវិជ្ជាទៅ ឬ ខាន់ដើមអវិជ្ជាមានអ្វីទៀត ?

ត្រង់ចំណុចនេះ អ្នកណាក៏មិនអាចធ្វើយប្រាប់ថាខានឡើយ ។ ចំ-
ពោះការដោះស្រាយបញ្ហាវិញ្ញាណសន្តតិនៃត្រកូល ព្រះសក្យមុនីគោតម
បានទ្រង់លើកយកមកពិចារណាជាអនុលោមទន្ទឹមជាមួយលើតន្តបច្ចុប្ប-
ន្នក្រោមដើមពោធិព្រឹក្ស ខ្ញុំបាទដូចសម្តុំបញ្ហាខាងមុខ គឺធម៌ប្រែស្រ័យជាក់ខាង
គ្នាដូចច្រវាក់ ដើម្បីស្រាវជ្រាវឲ្យឃើញពិតថា អ្វីជាបច្ច័យបណ្តាលមកពី
ហេតុអ្វី រួចទ្រង់ពិចារណាបណ្តាយទៅវិញថា អ្វីជាហេតុនាំឲ្យមានអ្វី ។
ជាអាសាទ្រង់សម្រេចព្រះទ័យថា ធម៌ដែលប្រែស្រ័យគ្នា ដូចច្រវាក់នេះ
គឺមានអវិជ្ជាជាមេគឺចប់ត្រឹមអវិជ្ជានេះឯង គ្មានអ្វីតទៅទៀត ពោះព្រះអង្គ
ទ្រង់ពិចារណាឈ្វេចឈ្វើយ៉ាំងណា ក៏ទ្រង់យើញច្បាស់ថា អស់តែត្រឹម
អវិជ្ជា គឺអវិជ្ជានេះហើយដែលជាមេដើមអាទិភូតស់ ។ ចំណែកវិញ្ញាណ
មុខន្ទឹងចូលមកកន្លែងក ស្ថិតនៅជាធាតុ ។

ដើម្បីឲ្យងាយយល់ថា ធម៌ច្រវាក់នេះ មានការប្រែក្លាក់គ្នាបែបណា
ហើយពាល់អស់ត្រឹមអវិជ្ជានោះដូចម្តេច សូមលើកឧទាហរណ៍ជាសេចក្តី
ឧបមាដូនជាដំណឹងដូចតទៅ :

ដំណាលថា មានមួយថ្ងៃ សត្វកុកស៊ុះត្រីជាន់កូនក្រួចស្លាប់ ។ មេក្រួចក្តៅក្រហាយមិនសុខចិត្ត គំរៅប្តឹងតិដ្ឋក់ឲ្យដំទុំដំរះរឿងស្លាប់កូនខ្លួន ។ តុលាការសម័យនោះ មិនដឹងជាសត្វណាតាំងតិដ្ឋក់ឲ្យធ្វើជាចៅក្រមទេ ស្រាប់តែសត្វតម្រាតនេះមានអំណាចគោះហៅឲ្យកុកចូលមក ហើយសួរថា :

- ហេតុម្តេចបានជាកុកឯង ស៊ុះត្រីជាន់កូនក្រួចស្លាប់ ?

កុកឆ្លើយថា :

- បានជាខ្ញុំបាទស៊ុះត្រីជាន់ ព្រោះភ័យនឹងអាអួតស្រែករកខ្លួក ។

តិដ្ឋក់ឲ្យគោះហៅអាអួតមកសួរទៀតថា :

- អាអួតឯង ហេតុអ្វីក៏ស្រែករកខ្លួក ទាល់តែកុកភ័យស៊ុះត្រីជាន់កូនក្រួចស្លាប់ ?

- បានជាខ្ញុំបាទស្រែករកខ្លួក ព្រោះតួមានន់ទឹកស្រែករកច្រក ។

តិដ្ឋក់ឲ្យគោះហៅមានន់ទឹកមកសួរទៀតថា :

- មានន់ទឹកឯង ហេតុអ្វីក៏ស្រែករកច្រក នាំឲ្យអាអួតស្រែករកខ្លួក ?

- បានជាខ្ញុំបាទស្រែករកច្រក ព្រោះយើញក្រសារហូតជាវ ។

- ក្រសារឯង ហេតុអ្វីក៏ហូតជាវ នាំឲ្យមានន់ទឹកភ័យស្រែករកច្រក ?

- បានជាខ្ញុំបាទហូតជាវ ព្រោះយើញខ្ទុលយសំពៅ ។

– ពុទ្ធឯង ហេតុអ្វីក៏លះយសសំពៅ ទាំងក្រសារហូតដាវ ?

– ចានជាខ្ញុំចាលះយសសំពៅ ព្រោះឃើញត្រជក់ស្តាយយាម ។

– ត្រជក់ឯង ហេតុអ្វីក៏ទៅស្តាយយាម ទាំងពុទ្ធលះយសសំពៅ ?

លុះព្រះតម្កល់សួរដើចប់ ត្រជក់នៅស្ងៀម ធ្វើក្បាលងឺងើ ។ មិនដឹងឆ្លើយដូចម្តេច ព្រោះយាមនេះ វាស្តាយជាកូនតតាមក គ្មានមកពីហេតុអ្វី ដែលទាំងវាស្តាយឡើយ ។ កាលបើសួរម្តងជាពីរដងជាបីដង ត្រជក់នៅតែស្ងៀម ទើបតម្កល់ប្រកាសកាត់ទោសចំពោះត្រជក់ ថាជាមេដើមចមនៃការស្លាប់កូនក្រួច រួចតម្កល់លោតថង់ក្បាលត្រជក់ជ្រុះពេមអស់គ្មានសល់ ចានជាក្បាលត្រជក់ចំពែតរហូតមកដល់សព្វថ្ងៃ ។

ឧទាហរណ៍គួរអស់សំណើច ដែលខ្ញុំតាញមកថ្លែងជាសេចក្តីឧបមានេះ បង្ហាញឲ្យដឹងយល់ថា វិញ្ញាណច្ចុរបស់សត្វមានអវិជ្ជាជាមេ មិនមានអ្វីជាហេតុតទៅទៀតទេ ដូចជាសេចក្តីស្លាប់នៃកូនក្រួច មានត្រជក់ជាហេតុដំបូងដូច្នោះ ។ ចំណែកការតិចារណាបដិច្ចសមុប្បាទធម៌ នៃព្រះសម្មុទ្ធកំយ៉ាំងនោះដែរ ព្រះអង្គទ្រង់ដញ្ជឹងដោយព្រះបញ្ញាញាណដ៏ភ្លឺស្វាងទៅ ទ្រង់យល់ច្បាស់ថា គ្មានអ្វីជាហេតុតតាមអវិជ្ជាទៅទៀតទេ ទើបព្រះបរមគ្រូទ្រង់សម្រេចព្រះទ័យថា ធម៌ប្រភេទគ្នាដូចត្រជក់នេះ មានអវិជ្ជា ជាមេដើមចម គឺថាការមិនដឹងនេះឯងហើយ ដែលជាហេតុបណ្តាលឲ្យកើតវិញ្ញាណសត្វក្នុងវដ្តកាលខ្លួនខ្លួន ។

សារុបសេចក្តីថា ឃើញថា អវិជ្ជា មានន័យថាមិនដឹង អវិជ្ជា ជាកត្តុបដិវិញ្ញាណថ្នីនៃសត្វកន្លងវិត្រតត ។ តែមានសត្វហើយត្រូវតែមានទុក្ខ ព្រោះសត្វជាទុក្ខ ។ ជាសត្វ ហើយកន្លែងដែលសម្រាប់សត្វសំចតតំណាទុក្ខខ្លែត ដូចបានតណាំនាមកពីខាងលើរួចមកហើយ ។

ដើម្បីបញ្ជាក់ឲ្យកាន់តែច្បាស់ថា តើសត្វពិតជាទុក្ខមែនឬ ? សូមលើកយកសច្ចៈទាំងបួនមកអធិប្បាយ ជាគ្រឿងនិទស្សន៍ដូចតទៅ :

សច្ចៈ ប្រែថា សេចក្តីពិតដែលមានកន្លងលោក ហើយដែលមិនប្រែក្លាយទៅជាប្រការដទៃ ។ សច្ចៈនេះ ព្រះសម្មុទ្ធទ្រង់ជ្រាបច្បាស់មុនគេបង្អស់ ។ ឯសច្ចៈទាំងបួនគឺ ๑- ទុក្ខសច្ចៈ ប្រែថា ទុក្ខជាសេចក្តីពិត, ๒- សមុទយសច្ចៈ ប្រែថា ហេតុបណ្តាលឲ្យកើតទុក្ខ (តណ្ហា) ជាសេចក្តីពិត, ๓- និរោធសច្ចៈ ប្រែថា ស្ថានលត់ទុក្ខ (ព្រះនិព្វាន) ជាសេចក្តីពិត, ๔- មគ្គសច្ចៈ ប្រែថា ផ្លូវប្រតិបត្តិ ដើម្បីលត់ទុក្ខជាសេចក្តីពិត ។

ទុក្ខជាសេចក្តីពិតកន្លងលោកនោះដូចម្តេច ?

តាំងពីថ្ងៃដែលសត្វមកចាប់បដិសន្ធិ រហូតដល់ថ្ងៃប្រសូត សត្វខ្លួលទុក្ខវេទនាជាដរាប ។ សូមគិតមើល! តារាអស្រ័យនៅកន្លែងដ៏ចង្អៀតយ៉ាងក្រៃលែងគឺផ្ទៃមាតានេះ ជាសុខស្រួល ឬជាការលំបាក ? បើគេសួរឈើ ឬឆ្លើយឲ្យសួរមនុស្សម្នាក់ ហើយៈគប្រាកដ

មនុស្សនៅក្នុងនោះ គេអាចស្មានបានថា មិនមានការសុខស្រួលឡើយ ឯសត្វនៅក្នុងផ្ទៃម្តាយក៏មានសភាពដូច្នោះដែរ ។

គេអាចពោលបានថា ការអាស្រ័យនៅនៃសត្វក្នុងផ្ទៃម្តាយ ជាការធម្មតា ។ ចម្លើយនេះ ជាការសមរម្យម្យ៉ាងដែរ ព្រោះបើមិនមែនជាការធម្មតា ធ្វើដូចម្តេចនឹងមានសត្វរស់ពេញលោក ។ តែដែលយល់ថាជាការធម្មតានេះ កើតមានចំពោះតែសត្វដែលប្រាសចាកបញ្ញាទេ ចំណែកព្រះអរិយបុគ្គលវិញ លោកតិយខ្លាចនឹងខ្លឹមរអើម រកអ្វីបមាគ្មាន ។ រឿងនេះ មិនខុសគ្នាពីដង្កូវនៅក្នុងបង្គន់ទេ ត្រង់ដង្កូវខ្លួនឯងចូលចិត្តនឹងពេញចិត្តថា ការអាស្រ័យនៅក្នុងបង្គន់ ហើយបរិភោគលាមកពលរំថ្ងៃជាអាហារ ជាការគាប់ប្រសើរនៃអាត្មា តែបើឲ្យមនុស្សឬភេញ្ញាយោបល់ចំពោះបញ្ហានេះវិញ គេអាចតាយតុកមុនជាស្រេចថា ១០០/១០០ តិតជាថាមិនស្រួល មិនប្រពៃ ជាការស្មោកគ្រោករកអ្វីធ្វើមពុំបាន គួរតែដកខ្លួនថយចេញឲ្យឆ្ងាយយ៉ាំងតាប់រហ័សជាទីបំផុត ។

ចាប់តាំងថ្ងៃសម្រាលចេញពីផ្ទៃម្តាយ សត្វតែងរងទុក្ខវេទនាហួតដល់ទៅនឹងស្លាប់ ។ តើរងទុក្ខរបៀបណា ? ។ គេអាចដំណាស់បានថា បើថាសត្វទទួលតែទុក្ខយ៉ាំងនេះ ក៏មកក្នុងលោកគ្មានសត្វឡើយ នេះជាការផ្ទុយទៅវិញ គេឃើញសត្វមានចំនួនកាន់តែច្រើនឡើង ។ ហើយសើច

ញ្ញាភ្ញីមនឹងសម្លាយកែកយចំពោះការសេរៀនទៅកន្លះលោក ។ ចំណែកខ្ញុំសំ-
ណាក់អស្រ័យកំប្រែទម្រង់ស្ទើរពេលថ្ងៃ គឺប្រែតិអាក្រក់ទៅល្អ តិមិន
ស្រួលទៅជាស្រួល តិមិនសមមេ្យទៅសមមេ្យ តិតូចទៅធំ តិខាបទៅ
ខ្ពស់ តិចង្អៀតទៅខួលាយ តិក្រខ្វក់ទៅស្អាត ។ល។ មធ្យោបាយដឹក
នាំខ្មែរកំប្រែសើរបែបក ដែលតាំដើមយើងគួរបង្កាប់ភ្នែកឲ្យរឿងត្រង់ តាំង
អាហារសម្រាប់បរិភោគត្រូវតាំងសំលៀកបំពាក់ ទីលំនៅសំអាងកាយ
មិនឃ្លាតឡាយតិខេតនិម្មិតឡើយ ដើយ៉ាងនេះ តើត្រង់កន្លែងណាដែល
ទីលំនៅទេសន៍ឲ្យយើញច្បាស់ថា សត្វទៅជាវង្វេងខ្លួនវេទាជានិច្ចនោះ ? ។

ត្រង់ចំណុចនេះ យើញថាហាក់ដូចជាអីចឹងមែន ប៉ុន្តែការមែននេះ
កើតមានដល់តែតួតសមញ្ញាប្បុថុជ្ជន ដែលគ្រាសចាកការតិចារណាឲ្យដិត
ដល់ខេ ។ ហេតុអ្វីក៏ថាដូច្នេះ ? ថារឿងខាងលើនេះជាការវង្វេងត្រង
នៃសត្វខេតើ ព្រោះថាខ្លួនតែក ជាការមិនបណ្តាយ ជាការមិនអស់
សង្ឃឹម ដ្បិតខ្លួនសច្ចៈពុំដែលកើតជាក់ច្បាស់ដល់ចិតចិត្តនៃសត្វសាមញ្ញ
ខេ មានកើតខ្លះដែរ តែដោយតេលដោយខណៈ ដូចជាផ្លេកបន្ទោរ
ប៉ុណ្ណោះ ហើយសត្វក៏ចិតស្មានថា មិនមែនជាខ្លួនសច្ចៈផង ម្ល៉ោះហើយ
សេចក្តីត្រូវការកេសុខ រុញច្រានដោយជម្រុលចិតចិត្តសត្វកុំឲ្យនៅស្ងៀម
កុំឲ្យឈឺល កុំឲ្យធ្វើព្រងើយ ដ្បិតការពាំងនេះ តាមលោកសាស្តាថា
ត្រូវប្រាជាឲ្យខ្លួនដល់អាត្មាវិញ ហើយបើមិនតិចារណាឲ្យត្រង់ កំហាក់

ដូចជាការតិតអីចំណីមែនដែរ ព្រោះចលនានៃកាយនឹងចិត្ត នាំឲ្យ
ក្ខេចតិតដល់សេចក្តីទុក្ខមែន ដោយចិត្តអាល័យតែជាប់ជំពាក់កង់ការងារ
តែបើពិចារណាបន្តិចទៅទៀត ឃើញថា ចលនានៃកាយនឹងចិត្តនេះ
ក៏ជាទុក្ខ ព្រោះដូចពាក្យខ្មែរមែថា "មួយដងនឹងបួន" ដែរ ។ ទុក្ខ
ខាងក្រៅមិនមកបៈពាល់មែន តែការធ្វើបែកញើស ការអង្គុយតិតកប់
មៅង ការនិយាយស្តីអស់រយៈពេលដ៏យូរ ការខំប្រឹងអត់ធន់ងុយ ។ល។
តើទុក្ខជាអ្វីទៅវិញ ? ។

ម្យ៉ាងទៀត ចំពោះបញ្ហាខាងលើនេះ មានអ្នកច្រើនក្នុងលោក ពោះជាខាងពុទ្ធសាសនាក្តី ខាងវិទ្យាសាស្ត្រក្តី ខាងច្បាប់ជនិយមក្តី តែងដួយដោះស្រាយបញ្ហាទុក្ខឲ្យសូន្យ ដោយប្រើមធ្យោបាយខាងការពោលលួងលោមនឹងកម្ចាត់ចិត្តជាការថ្លៃ ការភ្លេចភ្លែត ការកន្ទក់កន្ទេញ ការយំសោកសង្រេងសង្រៃ ការអស់សង្ឃឹម ការត្រួយចិត្ត ការអាឡោះអាល័យ ទាំងនេះជាអំពើឥតប្រយោជន៍ ជាអំពើកំសាក ដែលជាហេតុគ្រាន់តែធ្វើឲ្យអាត់ដំណើរអាត្មាប៉ុណ្ណោះ រកលទ្ធផលល្អគ្មាន ប្រៀបដូចនឹងអ្នកដំណើរ ដែលកំពុងគ្រាច់ជើរកណ្តាលកន្លែង ឬ កុំពុងកណ្តាលទន្លេ ហើយពោលគួញតែរអំពីការស្រេកឃ្លាន ការក្តៅក្រហាយ ការឃេយស្រេកទន់ ការអស់កំឡាំង ទឹងការឿយហត់ ឯការពោលដូច្នេះ តើ

ទំនងដូចសត្វផ្សេងទៀតដែរ ។ ហើយចំពោះសេចក្តីខ្វៃខិលរបស់សត្វតាំងនេះ តើអ្នកណាអាចកំណត់បានថា ខ្លាំងក្លៅតែណាមួយឬទេ? មែនពិត បើយកក្តីដោយសន្តតិ នោះទំនងអាចមានបានខ្លះ តែបើយកក្តីតាមការពិត យើញថាវាតអង្គើមានទេរឿយ ព្រោះធម៌អនិច្ច វតប្រែក្លាយទៅជាប្រការដទៃទេ ។

ក្នុងលោកដ៏វែងជាខ្លួកវែងមួង ។ ព្រះពុទ្ធសំដែងថា: "តិដ្ឋិ មច្ចាន ជីវិតំ ប្រែថា ការរស់នៅនៃសត្វតាំងឡាយជាការលំបាក" ។ តាមទស្សនៈអ្នកប្រាជ្ញខាងលោកនិយម កំមានន័យស្រដៀងគ្នាទំនងតាមទស្សនៈដែរ : គេពោលថា: (La vie est une lutte) ប្រែថា ជីវិតជាការប្រយុទ្ធ ។ ក្នុងពាក្យ "ប្រយុទ្ធ" គឺមានការតស៊ូ មានបាតជ័យ ទំនង អបរាជ័យជាធម្មតា ។ ចុះបើយ៉ាងនេះ តើទំនងអាចកំណត់ខុសជីវិត ជាការសប្បាយជាការស្រួលឬជាទុក្ខ? ចម្លាំងធម្មតា តែងមានពេលក្តី តែងមានពេលចប់ ចំណែកចម្លាំងគឺជីវិតសត្វ ជាចម្លាំងដ៏ធំក្រៃលែងលើសចម្លាំងទាំងជាចម្លាំងមិនមានពេលសម្រាកទំនងរកទីបំផុតគ្មាន ។

លោកបែរណាដាំងដឺសាំងវែរ (Bernadain de Saint Pierre) អ្នកនិពន្ធជាតិបារាំងនៃសៀវភៅប្រលោមលោកឈ្មោះ "ប៉ូលអេវីរហ្ស៊ីនី" (Paul et Virginie) ពោលថា: "សេចក្តីស្លាប់ជាការរំដោះទុក្ខ" សំដី

ខេះបញ្ជាក់បន្ថែមលើយោបល់ខាងលើដែលថា ជីវិតជាសេចក្តីទុក្ខ ព្រោះ
បើមរណៈជាការរំដោះទុក្ខ ជីវិតពិតជាទុក្ខពិតប្រាកដដោយស្វ័យប្រវត្តិ ។

តើជីវិតជាទុក្ខមែបណា ?

ព្រះពុទ្ធទេសនាថា: "ជិឃ ទ្ធា បរមា រោគា ប្រែថា ការ
ស្រេកឃ្លានជារោគដ៏ធំក្រៃលែងជាងរោគទាំងឡាយ" ។

តាំងពីប្រសូតចេញមក សត្វត្រូវទទួលទានដោយអាសាដជីវិត ។
តាមសាកលប្រក្រតី អាហារជាគ្រឿងទប់ត្រួមទុំបានដល់ជីវិត ម្ល៉ះដែរ
ទុក្ខជាគ្រឿងបន្ទាប់បន្សំពីអាហារទាំងអស់ ។ ដូច្នេះហើយ ទើបតែតែង
ឮបន្តិចពីខ្លះ បន្តិចពីខ្លោះ ក្នុងសាកលលោក នូវការធ្វើបាបកម្ម
កុដកម្ម រដ្ឋប្រហារ បម្លាំង ទាំងនេះមិនមែនមានហេតុអ្វីក្រៅពីដណ្តើមគ្នា
រស់ឲ្យបានស្រួល បន្តិចតែចុំណ្ណោះ ព្រោះមានជនពួកខ្លះ ដោយអាងមាន
ឫទ្ធិអំណាចជាងគេដណ្តើមយកវត្ថុរស់តែម្នាក់ឯង ។ ឯអ្នកខ្លះទៀតពុំបាន
ធ្វើអ្វីទាំងគេ មកពីខ្លះមធ្យោបាយ ឬមកពីខាល់តំនិត ហើយក៏បណ្តាយ
ដំណើរជីវិតឲ្យប្រព្រឹត្តទៅតាមយថាកម្ម ។

ចំណែក ជរា ព្យាធិ ត្រមាំងការណ៍អ្វីផ្សេង គឺជាសេចក្តីទុក្ខបន្ទាប់
ពីជីវិត ។

សេចក្តីដូចគោលរៀបរាប់មកនេះ បញ្ជាក់ឲ្យឃើញច្បាស់ នូវទុក្ខ-
សច្ចៈ ថាវាជាមានច្រើនជាងគេក្នុងលោក ហើយមិនមានកន្លែងណាស្រួលក្នុង
លោកឡើយ ។

សមុទយសច្ចៈ សេចក្តីតាំងចេះហេតុដែលបណ្តាលឲ្យមានទុក្ខនោះដូចម្តេច ?

ត្រង់ទំនេះ គឺសំដៅយក តណ្ហា ជា សមុទយសច្ចៈ ។ អ្វីហៅតណ្ហា មានន័យដូចម្តេច ?

តណ្ហា ប្រែថា សេចក្តីត្រេកអរ ។ គឺសេចក្តីត្រេកអរចង់រស់នេះហើយដែលបណ្តាលឲ្យមានទុក្ខ ។

សួរថា បុះបើគេមិនត្រេកអរ គេមានគ្រប់គ្រាន់អស់ហើយ តើនឹងមានអ្វីនាំឲ្យគេមានទុក្ខ ?

បើតាមដូច្នេះ សមុទយសច្ចៈហាក់ដូចជាមិនមានកន្លែងលោក បើសច្ចៈ ទាំង ៤ នេះគ្មានហើយ សច្ចៈទីមួយ ត្រូវតែស្ថិតនៅជាអហោសិកម្ម ចំពោះអ្នកនោះ ។

សូមពិនិត្យមើលសិន តើមនុស្សណា ឬសត្វណាដែលមិនត្រេកអរចង់រស់ ដែលតោលថា អាត្មាអញគ្រប់គ្រាន់ហើយ ?

តាមការសង្កេតយ៉ាងហ្មត់ចត់ យើញថាគ្មានសត្វណាមួយដែលមិន

ចង់រស់ ដែលឆ្អែតឯង ព្រោះចាប់ប៉ើកក្អែកឡើងទៅគ្រប់ផ្ទះ ឃើញតែផ្សែងហុយគ្រលោម បើមានផ្ទះខ្លួមឥតហុយផ្សែង នោះអ្នកម្ចាស់គាង តែតេះទៅរកផ្ទះដែលមានផ្សែងហុយជាពុំខាន ដែលថានឹងស៊ូដេកគ្រំអត់ គឺពិតជាមិនមាន កុំថាឡើយអ្នកជាត្រឹមត្រូវ សូម្បីអ្នកវិកលវិការ ក៏គាង តែស្ទុះស្ទាវទៅរកស្រង់នឹងគេដែរ ដោយមធ្យោបាយផ្សែង ។ មានការដើរ សុំខាន់ជាដើម ។ បើការចង់រស់មានហើយ _ សេចក្តីត្រូវការផ្សែងដទៃ រមែងរត់មករកមកឯង ។ ជាធម្មតា ដូចជាលោហជាតិ រត់ទៅចាមរកមកមែដែរដូច្នោះ ។

គេអាចដណ្តឹងសួរថា: មានមនុស្សខ្លះសម្លាប់ខ្លួនឯង ដោយមធ្យោបាយផ្សែង ។ មានការចង់ក៏ជាដើម តើនឹងថាតុក្កមនុស្សនោះជាអ្នកចង់រស់ដែរឬឬ ?

ចំពោះចំណោទនេះ គួរឲ្យគិតបានណាដែរ បើគ្រប់សត្វតែងមានតណ្ហាគឺសេចក្តីត្រូវការ មានការចង់រស់ជាអាទិ៍ តើដោយប្រការម្តេចអ្នកនោះត្រឡប់ជាសម្លាប់អាត្មាទៅវិញ ហាក់ដូចជាផ្ទុយស្រឡះនឹងគោលសច្ចៈ ។

ចំពោះរឿងដែលបានមកនេះគឺងាយសោះ ។ អ្នកធ្វើអត្តនិធិបាតកម្មមានតណ្ហាយ៉ាងខ្លាំងក្លា គឺត្រូវការចង់រស់ជាងអ្នកដទៃដ៏លើសលុបតែដោយ

ការចង់រស់នោះមិនបានសម្រេចដូចចិត្តប៉ុនប៉ង ក៏គិតការទំមហិមាថា ការទៅរស់ក្នុងអនាគតជាតិប្រហែលប្រសើរជាងជីវិតបច្ចុប្បន្នរបស់ខ្លួន ម្ល៉ោះហើយក៏ដាច់ចិត្តធ្វើអត្តឃាតនិងភាតកម្ម ដោយមកតិត្រូវការចង់រស់ទៀតបានឆ្ងាស្រាលទេតើ ព្រោះការរស់ក្នុងជាតិនេះជាការតឹងតែក ។ រឿងនេះមិនខុសគ្នាប៉ុន្មានពីមនុស្សដែលដាច់ចិត្តដកខ្លួនចេញពីស្រុកកំណើតអាស្រ័យជាប្រទេសដែលអ្នកណាក៏តែងតែចង់នៅរួមសុខទុក្ខជាមួយមាតាបិតា ឪឬញាតិសាច់សាលោហិត ឧរណាក៏តែងរលឹកនឹងស្រឡាញ់រកអ្វីប្រៀបគ្មានតែដែលបានជាដាច់ចិត្តដើរចោល មកពីមានការគាន់តឹងត្រាំពុំបានហើយសង្ឃឹមថា សេចក្តីត្រូវការរបស់ខ្លួនឪឬបានសម្រេចដូចបំណង បើការណាអាស្រ័យដកខ្លួនទៅបាត់ដែរ ។

ដូច្នេះតណ្ហាគឺសេចក្តីត្រូវការ តែងមានក្នុងសន្តានសត្វគ្រប់គ្នា ហើយសេចក្តីទុក្ខធ្ងន់ស្រាលដែលកើតមានដល់សត្វ ក៏អាស្រ័យតែតិតណ្ហាធំឬតូចប៉ុណ្ណោះឯង ។ បើសត្វណាមានតណ្ហាធំ ទុក្ខក៏ធ្ងន់ បើសត្វណាមានតណ្ហាតូច ទុក្ខក៏ស្រាល តែថាឲ្យប្រាសចាកផុតពីតណ្ហាគឺរាគៈឡើយហើយតណ្ហានេះ អាចកាត់ទំរកត្រាំដែនគ្មាន បើបណ្តោយឲ្យវាប្រព្រឹត្តទៅតាមអំពើចិត្ត ។

សុភាសិតចែងថា : "តណ្ហាយ ជាយតេ សោតោ តណ្ហាយ ជាយតេ ភយំ តណ្ហាយ វិប្បមុត្តស្ស នត្ថិ សោតោ កុតោ ភយំ ប្រែថា ការសោកសង្រេងសង្រែ កើតមកតែពីសេចក្តីត្រេកអរ ការភ័យខ្លាច កំកើតមកតែពីសេចក្តីត្រេកអរ បើសេចក្តីត្រេកអរសូន្យហើយ ការសោកក្តី ការភ័យខ្លាចក្តី នឹងមានមកពីណា" ។

តុំនុ៎ះសុភាសិតនេះចង្អុលឲ្យឃើញថា តណ្ហានឹងទុក្ខ ពិតជាមានក្នុងលោកនឹងពិតជាមាននៅក្នុងសន្តានសត្វគ្រប់ប្រាណ តែសត្វនោះឥតបានយល់ បានស្គាល់ដ៏ជាក់ច្បាស់ទេ មានតែពួកព្រះអរិយៈទើបលោកជ្រាបច្បាស់ដោយបញ្ញាចក្ខុរបស់លោក ឯសត្វវិញដឹងតែតិចនិតរស់ ថ្លង់ភ្លឺភ្នែរ ស្រែកយំ . . . ប៉ុណ្ណោះ ។

ជាអវសាន សូមសាធុជនបញ្ជាក់ខ្ចីសច្ចៈពាំនឹងពីរម្តងទៀត ។ ឯសច្ចៈទី ៣ គឺនិរោធសច្ចៈ នឹងសច្ចៈទី ៤ គឺមគ្គសច្ចៈ តុំបានលើកយកមកអធិប្បាយក្នុងទីនេះទេ ព្រោះមិនមានការសំខាន់ដល់អត្ថបទនេះ ។

ដោយទុក្ខសច្ចៈនឹងសមុទយសច្ចៈជាសេចក្តីពិតដែលមានក្នុងលោក ទើបត្រូវទុកលោកឬតជាភពនៃទុក្ខ ។ ឯការមិនដឹងគឺ អវិជ្ជា ពិតជាមេដើមចមនៃសេចក្តីទុក្ខរបស់សត្វ ព្រោះ អវិជ្ជា មេបង្កើតវិញ្ញាណច្ចៃនៃសត្វបញ្ចូលមកកើតវិត្រកត ដូចដែលបានពណ៌នាមកហើយនោះ ។

ភាគទី ៥

អ្នកឧកញ៉ា ឆា-សាង អតីតរដ្ឋមន្ត្រីរៀបរៀង

(តចប់)

ត្រៃលោក ធំឯ ត្រៃភព

តើត្រៃលោក ដែលព្រះអរហន្តលោកធ្វើចេញរួចផុតស្រឡះនោះ ជាហានដខែផ្សេងពីត្រៃភព គឺភព ៣ ដែលព្រះអរហន្តអង្គនោះ លែងត្រឡប់មក រំលេចរំលែកស្នាប់ខៀតឬដូចម្តេច ?

ចំពោះសំនួរនេះ ខ្ញុំសូមដកថា ឯហានំពាំងឡាយដែលបណ្ឌិតលោកសន្មតហៅថា ត្រៃលោកក្តី ឬហៅថាត្រៃភពក្តី គឺជាហានដដែលមិនមែនជាហានផ្សេងជាច់ដោយឡែកពីគ្នាឡើយ ដោយបណ្ឌិតលោកគ្រាន់តែរួមហានខនេះទៅខាងក្រោមមនុស្សលោក ខឹងហានសួគ៌ក្នុងខនេះលោក ហើយសន្មតហៅថា កាមភព ខឹងបែងចែកព្រហ្មលោកធ្វើជា ភព ៦ ខៀត គឺយកហានព្រហ្មដែលមានរូបធ្វើជារូបភព ហើយយកហានព្រហ្មដែលគ្មានរូប ធ្វើជាអរូបភពតែប៉ុណ្ណោះខ ។

រីឯហានពាំងឡាយនោះឬនជាមួងហៅថាត្រៃលោក, ហើយមួងត្រូវហៅថា ត្រៃភពវិញនោះ ពីព្រោះកាលបើលោកនោលថា ត្រៃលោក

តែគ្រាន់តែសំគាល់ហានតាំងឡាយនោះ ថាជាលោកតែជាទីអាស្រ័យនៅនៃសត្វលោក ដូចជាមនុស្សលោក តែជាទីសំណាក់អាស្រ័យនៅនៃមនុស្ស ។ល។ ហើយកាលបើលោកពោលថា ត្រៃភពវិញ តែគ្រាន់តែសំគាល់ហានតាំងឡាយនោះថាជាភព តែជាទីសម្រាប់ឲ្យសត្វអន្ទោលវិលកើតវិលស្លាប់ តាមយថាកម្មរបស់ខ្លួនតែប៉ុណ្ណោះទេ ។

បើភពមានតែ ៣ ហៅថាត្រៃភព តើខុទ្ទកនិកាយនិងសុត្តន្តិកភពនោះជាភពដោយឡែកផ្សេងពីត្រៃភពនោះទៀត ឬដូចម្តេច ?

ចំពោះសំនួរនេះ ខ្ញុំសូមឆ្លើយថា ខុទ្ទកនិកាយនិងសុត្តន្តិកភពនោះតែកាមភពនោះឯង មិនមែនជាភពដទៃផ្សេងពីកាមភពនោះឡើយ ពីព្រោះខុទ្ទកនិកាយតែសំដៅអប្បាយភូមិ ៤ មានហានរកជាដើម ហើយសុត្តន្តិកភពតែសំដៅហានសួគ៌ ជាន់នោះ ។

ម្យ៉ាងវិញទៀត. បើលោកមានតែ ៣ ហៅថា ត្រៃលោកនោះ តើបរលោកនោះជាលោកផ្សេងពីត្រៃលោកទៀត ឬដូចម្តេច ?

ចំពោះសំនួរនេះ ខ្ញុំសូមឆ្លើយថា បរលោកនោះមិនមែនលោកឯណាក្រៅផ្សេងពីត្រៃលោកនោះទេ, ពីព្រោះបរលោកដែលប្រែថា លោកខាងមុខ ជាគូនឹងឥធលោកដែលប្រែថា លោកនេះ តែប៉ុណ្ណោះឯង ។

ឯបរលោកតែលោកខាងមុខនោះ តែសំដៅខុទ្ទកនិកាយ ដែលតាំងនៅខាងក្រោមមនុស្សលោក ខុទ្ទកនិកាយ ដែលតាំងនៅលើទេវលោកនោះ

ឯង តែព្រោះសត្វដែលស្លាប់តាំងពីកណ្តាល រមែងទៅចាប់បដិសន្ធិកើតក្នុងសុគតិភព ប្តូរគ្គតិភពតាមកម្មាំងបុណ្យឬបាបដែលសត្វនោះបានធ្វើដោយកាយវាចាចិត្តនោះ ។

រីឯទុគ្គតិភព ទំនងសុគតិភពដូចបានអធិប្បាយខាងលើនេះមានស្មានភាពដូចម្តេចខ្លះនោះ ខ្ញុំនឹងបរិយាយរៀបរាប់តាមដែលខ្ញុំបានជំនាញដូចតទៅនេះ :

១- អំពីទុគ្គតិភព

ឯទុគ្គតិភព គឺភពដែលជាទីកើតនៃសត្វដែលមានគតិអាក្រក់ គឺសត្វដែលបានធ្វើនូវអំពើបាបផ្សេង ។ ។

ឯទុគ្គតិភពនេះ គឺសំដៅអបាយភូមិ ៤ គឺនរក, ប្រេត, អសុរកាយ ទីដ៏តិរច្ឆាន ។ ឯនរកជាហាន ១ ស្ថិតនៅឯបាតាល គឺលោកខាងក្រោមមាននរណ្តៅជាទីលំនៅនៃសត្វនរក នៅទទួលឆេទុក្ខវេទនាតាមផលបាបកម្មធ្ងន់ ឬស្រាលដែលខ្លួនបានធ្វើ ដោយហេតុនេះ ទើបនរណ្តៅនរកមាន ៨ គឺ: ១- សញ្ជីវៈ ២- កាលសុត: ៣- សង្ឃាដ: ៤- រោរៈ: ៥- មហារោរៈ: ៦- តាប: ៧- មហាតាប: ៨- អវីចិ ។

ឯហានរកនោះមានន័យថា មានទាយន័យថាលាំង្ហើលណាកម្មផ្សេង ។ មានចាប់ពេលក្តៅធំជាដើម ដើម្បីឲ្យសត្វនរកបានសេចក្តីលំបាកវេទនាស្តែក្រហាយខ្លោចផ្សាស្លាប់តើត ។ ស្លាប់ក្នុងនរណ្តៅនរកនោះឯង ។

រីឯតូមីនៃប្រេត, អសុរកាយនឹងតវ្ចានវិញ្ញាខ្មោះ ឃើញមាននៅ
លាយឡំតែជាមួយនឹងមនុស្សក្នុងហានកណ្តាល ។

ឯប្រេតនោះ គឺសំដៅខ្មោចដែលតាំងដើមឡើយកើតជាមនុស្សបានធ្វើ
អំពើបាបដែលវិបាកមិនតម្រូវឲ្យធ្លាក់ទៅសោយទុក្ខក្នុងឯរណ្ណាននរកនោះ ។
ឯប្រេតនោះមាននិយាយថា មានរូបកាយអាក្រក់, មានដីវភាពរហម
រហាមយ៉ាងក្រៃលែង, តែមិនចេះលង់មនុស្សដូចខ្មោចឯទៀត ។

រីឯពួកអសុរកាយ, មានព្រាយអាកាស, ឧដ្ឋិតខ្មោចអាស្រ័យជាដើម
ក៏មានដីវភាពរហមរហាម ហើយមានខ្មោចព្រាយខ្លះដើរក្នុងពេលយប់
ស្វែងរកអសុចិវត្ថុ មានគំនរធំជាដើម លិទ្ធដញ្ជក់យកនូវសជាតិគំនរធំជា
អាហារ ។

ចំណែកឯសត្វតិរច្ឆាន ទោះបីកើតជាសត្វអ្វីក៏ដោយ សុទ្ធតែត្រូវ
ទទួលទុក្ខវេទនាខ្លាំងអស់, ខ្ញុំមិនចាំថាចំនួនណានោះទៀតឡើយ ។

ឯអបាយភូមិទាំង ៤ ដូចបានរៀបរាប់ដោយសង្ខេបខាងលើនេះ
ឃើញសុទ្ធតែជាទីប្រាសចាកសេចក្តីសុខ ទីនោះសេចក្តីចំរើនតិចណាស់ ។

ឯសត្វដែលទើងធ្លាក់ខ្លួនទៅកើតក្នុងអបាយភូមិណាមួយ ។ ក៏មកតែ
ពីផលបាបកម្មដែលសត្វនោះបានធ្វើតាក់តែងឲ្យទៅកើត ដើម្បីទទួល
ខុសត្រូវនឹងទុក្ខវេទនាតាមកម្លាំងបាបកម្មដែលខ្លួនបានធ្វើនោះ ។

រីឯបាបកម្ម គឺអំពើអាក្រក់ដែលធ្វើដោយកាយ, វាចា ចិត្ត, មាន១០

ហៅថា អកុសលកម្មបថ ១០ ចែកចេញជាកាយទុច្ចរិត ៣, វចីទុច្ចរិត ៤ នឹង
មនោទុច្ចរិត ៣ ។

២- អំពីសុគតិភព

ឯសុគតិភព គឺភពដែលជាទីកើតនៃសត្វដែលមានគតិល្អ គឺសំដៅ
យកសត្វដែលបានធ្វើនូវអំពើបុណ្យនោះឯង ។

ឯសុគតិភពគឺសំដៅហានសួគ៌ ៦ ជាន់គឺ :

ជាន់ទី ១ ហៅថា ចាតុមហារាជិកា, ជាន់ទី ២ ហៅថា
តាវតឹង្ស, ជាន់ទី ៣ ហៅថា យាមា, ជាន់ទី ៤ ហៅថា
តុសិតា, ជាន់ទី ៥ ហៅថា ឥម្មានរតី, ជាន់ទី ៦ ហៅថា
បរនិម្មិតវសវត្តី ។

ឯហានសួគ៌ ៦ ជាន់នេះជាទេវស្ថាន គឺជាហានៃពួកទេវតា នឹងស្រី
ទេពអប្សរមានព្រះឥន្ទ្រាធិរាជជាស្តេចគ្រប់គ្រង ។

ឯដីកែវនៃពួកទេវតា នឹងស្រីទេពអប្សរមានដំណើរខ្ពង់ខ្ពស់ប្រ-
សើរដូចម្តេចនោះ ខ្ញុំពុំបានដឹងឲ្យច្បាស់សព្វគ្រប់ទេ តែខ្ញុំបានដឹងថា
ទេវតាក្តី ស្រីទេពអប្សរក្តី រមែងបានជួបប្រទះនូវសុភមង្គលគ្រប់បែបយ៉ាង
ពីព្រោះនៅលើហានសួគ៌នោះមានតែមានតិ្ត, មានសម្បត្តិតិ្ត នឹងមាន
អាហារតិ្តឥតមានការព្រួយលំបាកនឹងអ្វីឡើយ ។

មួយវិញទៀតដោយហេតុថា កំណើតទេវតាក្តី កំណើតស្រីទេព អប្សរក្តីមិនមែនជាចុបជាតិកំណើតទេនោះ ខ្ញុំអាចសន្និដ្ឋានបានថា ទេវតាទីឆស្រីទេពអប្សរតែងទីទីឆទៅរួមសង្វាសជាមួយគ្នាជាស្វាមីភរិយា ដើម្បីសត្វដែលត្រូវទៅចាប់កំណើតឯហានសួគ៌នោះ អាចទៅចាប់បដិសន្ធិកើតឡើងបានដែរ ។

កាលបើហានសួគ៌មានខ្ចប់ជាន់តើទេវតាក្នុងហានទីមួយ។ បានបំពេញបុញ្ញកម្មផ្សេងពីគ្នាដូចម្តេច ទើបបានមកចាប់កំណើតលើហានសួគ៌ផ្សេង ។ ដូច្នេះ ?

ចំពោះបញ្ហានេះយើញថាតិបាកទីឆធ្វើយដោះស្រាយ ឲ្យសមហេតុផលណាស់ ព្រោះការកសាងសន្សំកុសល ទីឆបុណ្យរមែងមានលក្ខណៈទីឆដំណើរផ្សេង ។ ខុសពីគ្នាជាច្រើនអនេកប្បការ ។ ត្រង់នេះយើញមានតែបុញ្ញាភិសង្ខារនោះទេ ដែលអាចទីឆតាក់តែងកំណើតល្អក្នុងហានសួគ៌ទីមួយ ។ ឲ្យទៅតាមកម្លាំងបុញ្ញកម្មនោះ ។ បាន ។

រីឯបុញ្ញកម្ម ដែលជាមូលហេតុនៃកំណើតល្អក្នុងហានសួគ៌នោះ គឺសំដៅកុសលកម្មបថ ១០ ទីឆបុញ្ញកិរិយាវត្ថុ ១០ នោះឯង ។

ឯកុសលកម្មបថ ១០ គឺអំពើជាកុសល ដែលកើតឡើងដោយចេតនាវៀរមិនធ្វើទូវអំពើជាអកុសល ១០ គឺកាយទុច្ចរិត ៣ វចីទុច្ចរិត ៤ មនោទុច្ចរិត ៣ ។

ដើម្បីដូច្នេះ យើញថាកុសលកម្មបថ ១០ នេះគ្រាន់តែជាកុសលកម្មអាចញុំាងសត្វឲ្យដោះខ្លួនរួចពីអបាយភូមិ ៤ តែប៉ុណ្ណោះ ។ លុះណាតែសត្វនោះបានបំពេញបុញ្ញកិរិយាវត្ថុ ១០ មានទានមីលការនាជាដើមថែមទៀត ទើបបុញ្ញកម្មនេះតាក់តែងបដិសន្ធិឲ្យទៅកើតក្នុងសុគតិភពបាន ។

សរុបសេចក្តីទៅយើញថា ខុទ្ទកនិកាយ ទីឆសុគតិភពជាទីសម្រាប់ឲ្យសត្វលោកអន្ទោលវិលកើតវិលស្លាប់តាមយថាកម្មរបស់ខ្លួន រកទីបំផុតគ្មានឡើយ ។

អាស្រ័យហេតុនេះ ទើបបណ្ឌិតដែលបានដឹងច្បាស់នូវដ្ឋសង្ខារ គឺដំណើរវិលកើតវិលស្លាប់ក្នុងវិត្រកភពដូច្នេះ រមែងមានចិត្តខ្សឹយណាយ ហើយស្វែងរកទុាយសម្រាប់ដោះខ្លួនឲ្យរួចចាកវដ្តភ័យ គឺភ័យក្នុងការអន្ទោលវិលកើតវិលស្លាប់ក្នុងភពទួចកពពំនោះឯង ។

រីឯទុាយនោះ បណ្ឌិតតែងដឹងច្បាស់ថា គ្មានទុាយណាក្រៅពីការត្រាស់ដឹងមគ្គ ៤ ផល ៤ នីឆនិព្វានទេ, ពីព្រោះមគ្គផលនិព្វាននោះ ពិតជាលោកុត្តរធម៌ គឺធម៌អាចបម្លងសត្វឲ្យឆ្លងចេញរួចផុតពី វិត្រលោកបានពិតមែន ។

លោកុត្តរកិសម័យចប់ដោយសង្ខេបតែប៉ុណ្ណោះ ឯ។

ព្រះអភិធម្មបិដក

គម្ពីរព្រះយមកៈ

លោក ប៊ុ - ប៊ុ ប្រែរៀបរៀង

(តមក)

ព្រះយោគាវចរកុលបុត្រដែលប្រកបដោយវិរិយភាព កាលបើបានតិចារណាឃើញខន្ធទាំង ៥ ដោយសង្ខេប ឬដោយតស្ការដូច្នេះហើយ ក៏តិចារណាឃើញនូវអដ្ឋត្តិកវូប គឺរូបទាំងក្នុងជាដើមដោយអសុភសម្មាណ គឺនិយមថា រូបនេះមិនល្អ ខន្ធជាទីទាំមកន្ទូរសេចក្តីខ្ពើមរអើម ។ លំដាប់អំពីនោះ ខន្ធកំណត់ដឹងនូវកវឡិង្ការាហារ គឺកោដនាហារដែលខ្លួនធ្វើឲ្យជាតំនូតវិបល្លាសំ បដហាតិ ខន្ធលះបង់នូវវិបល្លាស គឺអារម្មណ៍មិនល្អ សំគាល់ថាល្អ លុះយល់ឃើញដូច្នោះហើយ កំនត់ដឹងខន្ធទាំងបួនតាមគុណបាន មិនប្រកបដោយសំយោជនៈ មានកាមសំយោជនៈជាដើម ខន្ធញុំាងខ្លួនឲ្យជាបុគ្គលប្រសើរ គឺជាព្រះខីណាស្រពក្នុងព្រះបវរពុទ្ធសាសនាខន្ធចំណាយបង់ផ្លាញនូវអតិដ្ឋអស់លោក មិនជាប់ជាពាក់ដោយទុជាតទាំង ៥ ខន្ធឃើញវេទនាថាជាទីទាំមកន្ទូរទុក្ខ ហើយកំណត់ដឹងនូវផស្សៈ លះបង់នូវការយល់ឃើញថាជាសុខក្នុងធម៌ទាំងពួងដែលទាំមកន្ទូរទុក្ខ ខន្ធទាំងបួនតាកកកេរយៈបាន ខន្ធជាព្រះខីណាស្រពក្នុង

ពុទ្ធសាសនា គ្មានឥស្សាថា ។ សូម្បីតែថាវេទនា សញ្ញា, សង្ខារ ធម៌ដទៃណាដោយព្រះអនត្តា ក៏កំណត់តែថាវេទនាទូទៅមានសភាពតែ ហាវលះបង់នូវបែល្វាស គឺយល់ឃើញថា ខ្លួនជារបស់ខ្លួនក្នុងបញ្ចក្ខន្ធ ដ៏ មិនមែនជារបស់ខ្លួន ធម៌ធ្វើនូវនេះ:គឺមិច្ចាទិដ្ឋិបាន ធម៌មិនប្រកាន់មាំ ក្នុងអត្តភាពពុំបានទេ ។ កាលតែថាវេទនាឃើញនូវវិញ្ញាណដោយអនិច្ច-លក្ខណៈ ក៏ធម៌កំណត់ដឹងនូវវិញ្ញាណហារ ធម៌លះបង់នូវបែល្វាសនៃ ចិត្ត គឺថាខ្មៀងក្នុងធម៌ដែលមិនខ្មៀង ធម៌ធ្វើនូវនេះ: គឺអវិជ្ជាបាន ធម៌បានជាព្រះអរិយបុគ្គលដ៏ប្រសើរគ្មានអាសវៈ ។

ព្រះយោគាវចរ ឃើញនូវអាទិសង្ខ្យក្នុងការតែថាវេទនាឃើញបញ្ចក្ខន្ធ គឺរូប, វេទនា, សញ្ញា, សង្ខារ, វិញ្ញាណ ប្រកបដោយអាទិសង្ខ្យដោ-ច្រើនដូច្នេះហើយ តម្បីតែថាវេទនាដោយសង្ខេបប៉ុដោយតាស្ពារដូចពោល មកហើយនោះ ក៏ធ្វើបានសម្រេចមគ្គញ្ញាណ ផលញ្ញាណ សូម្បី អកិរិយាវនៅមិនទាន់ចាស់ក្លា ក៏ជាបច្ច័យដៅកើតក្នុងអនាគត លុះដល់គ្រប់ កំណត់កាលហើយ ក៏ធ្វើកន្ទុះលើផុតចាកបញ្ចក្ខន្ធចូលកាន់ព្រះមហា-និព្វាន ។

ខ្ញុំយមកៈចប់ ។

X

X X

ឥធាវិ ខន្ធយមកស្ស បវត្តា អាយតនយមក-
ន្តិទ្ធសោ អនុប្បត្តា ទ្វាទសាយតនានិ ចក្ខាយតនំ
រូបាយតនំ សោតាយតនំ សទ្ទាយតនំ ឃានាយតនំ
គន្ធាយតនំ ជិវ្ហាយតនំ រសាយតនំ កាយាយតនំ
ផោដ្ឋព្ពាយតនំ មនាយតនំ ធម្មាយតនន្តិ ។

*លំដាប់អំពីខន្ធយមក: ព្រះពុទ្ធជាអម្ចាស់ទ្រង់ត្រាស់ទេសនា អាយ-
តនយមក: តទៅទៀត មានសេចក្តីតាមព្រះអដ្ឋកថាថា:*

អាយតនយមកនិទ្ទេសោ ការសំដែងនូវអាយតនយមក:
មកដល់ហើយ ក្នុងលំដាប់នៃខន្ធយមក:នេះ ខ្ញុំនឹងសំដែងដោយអំណាច
អនុលោមតាមព្រះពុទ្ធដីកាថា កតមា សម្ពុទ្ធមានព្រះភាគមានព្រះ
ភុទ្ធដីកាត្រាស់ប្តូចាំគួ ត្រាស់វិសជ្ជនាចាំគួគ្នា ដូចសំដែងក្នុងខន្ធ-
យមក: ផ្សេងគ្នាតែខន្ធយមក:នោះ ត្រាស់ប្តូចនឹងត្រាស់វិសជ្ជនាក្នុងខន្ធ
ចាំង ៥ ក្នុងអាយតនយមក:នេះ ត្រាស់ប្តូចនឹងវិសជ្ជនាក្នុងអាយតន: ។
ទ្វាទសាយតនានិ អាយតន:នោះមាន ១២ ប្រការគឺ *ចក្ខាយតន:*១
រូបាយតន: ១ *សោតាយតន:* ១ *សទ្ទាយតន:* ១ *ឃានាយតន:* ១ *គន្ធ-
យតន:* ១ *ជិវ្ហាយតន:* ១ *រសាយតន:* ១ *កាយាយតន:* ១ *ផោដ្ឋព្ពាយ-
តន:* ១ *មនាយតន:* ១ *ធម្មាយតន:* ១ *ត្រប់ដាអាយតន:* ១២ *ប្រការ* ។

ព្រះពុទ្ធអដ្ឋកថាចារ្យទ្រង់ត្រាស់ទេសនាក្នុងចក្ខាយតនៈនោះ ទ្រង់ត្រាស់បុច្ឆាជាគូ ហើយត្រាស់វិសជ្ជនាជាគូ ថា ចក្ខាយតនំ នាម ចក្ខុ នោះឬ ឈ្មោះថាចក្ខាយតនៈ ចក្ខាយតនៈនោះឬ ឈ្មោះចក្ខុ ? ឬចក្ខុមិនមែនចក្ខាយតនៈទេ ? ចក្ខាយតនៈមិនមែនចក្ខុទេ ? ។

ត្រាស់បុច្ឆាដូច្នេះហើយ ទើបត្រាស់វិសជ្ជនាថា អាមន្តា អើ ! ចក្ខុនោះឯងហើយឈ្មោះថា ចក្ខាយតនៈ ។ នោះឯងហើយឈ្មោះថាចក្ខុ ។ ត្រាស់ដូច្នេះហើយ ទើបត្រាស់បុច្ឆាតទៅទៀតថា រូបនោះឬឈ្មោះថា រូបាយតនៈ ? រូបាយតនៈនោះឬឈ្មោះថារូប ? ។

ការដែលព្រះពុទ្ធអដ្ឋកថាចារ្យទ្រង់ត្រាស់បុច្ឆា ឧទ្ធរិសជ្ជនាទ្វារបុច្ឆាកង្ខាវិតរណីអាយតនយមកនេះ មិនប្លែកគ្នាពីបុច្ឆា ឧទ្ធរិសជ្ជនាកង្ខាវិតរណីទុកយមកទេ ប្លែកតែទុកយមកថា ដោយរូបទុកក្នុងអាយតនៈ យមកនេះហៅថារូបាយតនៈតែការដែលសំដែងសេចក្តីនោះដូចគ្នា ។

ប្រការមួយទៀត កង្ខាវិតរណីនោះត្រាស់ទេសនាដោយរូបក្ខន្ធថា ដោយទុកតាំង ៥ ។ អ្នកប្រាជ្ញគប្បីជ្រាបថា ក្នុងសោតាយតនៈជាដើមដរាបដល់ធម្មាយតនៈ ក៏ត្រាស់បុច្ឆាឧទ្ធរិសជ្ជនាដូចជាក្នុងចក្ខាយតនៈ រូបាយតនៈដែរ ។

ចក្ខាយតនៈនោះ ជាទដ្ឋលក្ខុ ។ ដែលហៅថា ចក្ខុនោះ ដោយអត្ថថា យើញទ្វារបុ ។

ដែលហៅថា អាយតនៈនោះ ហេតុតែឃើញជាអណ្តូងនៃចក្ខុ ។ ឯអាយតនសត្វនេះប្រែថា អណ្តូង, ទីកើត, មិនចន្លែក, ទីទៅ, ទីអាស្រ័យ ក៏ជាន ។

ដែលហៅថា អាយតនៈគឺចក្ខុនោះ ជាន់ដល់ការអាស្រ័យចក្ខុវិញ្ញាណ ។ បើមានតែចក្ខុទេ ខ្វះវិញ្ញាណ ចក្ខុនោះមិនអាចឃើញនូវរូបតាំងតួនជាន់ឡើយ ទាល់តែមានចក្ខុវិញ្ញាណ ទើបអាចឃើញរូបសម្រេចសេចក្តីថ្លាថ្នាជាន ។ ឯចក្ខាយតនៈនោះ រមែងមានរូបាយតនៈជាអារម្មណ៍ អធិប្បាយថា ចក្ខុមានរូបជាអារម្មណ៍ រូបជាទីតាំងថ្កល់នៃចក្ខុ ។

សោតាយតនៈនោះ ក៏មានសម្លេងជាអារម្មណ៍ ឃានាយតនៈក៏មានក្លិនជាអារម្មណ៍ ជិវ្ហាយតនៈ ក៏មានរសជាអារម្មណ៍ កាយាយតនៈ ក៏មានផោដ្ឋព្វៈជាអារម្មណ៍ មនាយតនៈ ក៏មានធម៌ជាអារម្មណ៍ ។ អធិប្បាយថា សម្លេងជាអារម្មណ៍នៃសោត (ត្រចៀក) ក្លិនជាអារម្មណ៍នៃឃ្រាន រសជាអារម្មណ៍នៃអណ្តាត ត្រឿងផោដ្ឋព្វៈ គឺពួកកន្ទេលសំពត់ស្បែកសំពត់ដណ្តប់ ទឹងសេនាសនៈតាំងតួនជាដើមជាអារម្មណ៍នៃកាយ រឿងរ៉ាវតាំងឡាយ ដែលត្រូវគិតត្រូវដឹងដោយចិត្តជាអារម្មណ៍នៃចិត្ត ។

ចក្ខាយតនៈ សោតាយតនៈ ឃានាយតនៈ ជិវ្ហាយតនៈ កាយាយតនៈ មនាយតនៈ អាយតនៈទាំងនេះ ជាមួយប្រការនេះ ដាច់

កើតនៃកុសលនឹងអកុសល ។

ឧត្តុជា បុស្សរុន្តា តាលបុគ្គលបានឃើញរូបព្រះភុទ្ធបដិមាការនឹងរូបព្រះចេតិយ ឃើញដើមព្រះស្រីមហាពោធិព្រឹក្ស ហើយមានចិត្តត្រេកអរកែកយជ្រះថ្លា មានសទ្ធា ធ្វើសក្ការបូជាដោយគ្រឿងសក្ការៈបូជាផ្សេង ។ តាមសតិកម្មាំង ។

ប្រការមួយទៀត បានឃើញផ្ការីហើយមានចិត្តសទ្ធា គិតថាផ្កាឈើនេះ បើអាត្មាអញយកទៅធ្វើសក្ការបូជា ក៏នឹងមានផលានិសង្សក្នុងខាងមុខ ។

ម្យ៉ាងទៀត ឃើញរបស់ទាំងពួងមានដើមថា អង្គរស្រវៃសាល៍ នឹងមច្ឆមំសាហារក្តី ឃើញវត្ថុអ្វីក្តី ហើយកំណត់ទុកក្នុងចិត្តថានឹងធ្វើការកុសលមានទឿនជាដើម ក៏ឈ្មោះថាបានធ្វើការកុសលបង្កើតដល់ចក្ខុមានរូបជាអារម្មណ៍ទាំងអស់ ។ កុសលកើតដល់ចក្ខុមានរូបជាអារម្មណ៍នោះ គឺបុគ្គលបានឃើញរូបអ្វី ។ ហើយគិតប្រឹងនឹងធ្វើការកុសល ក៏ហៅថាកុសលបង្កើតអំពីចក្ខុថ្លាមានរូបជាអារម្មណ៍ទាំងអស់ ។

ឯកុសលបង្កើតអំពីចក្ខុថ្លាមានរូបជាអារម្មណ៍នោះ ដូចជាសាធុជនបានឃើញបុប្ផជាតិនឹងផលាផលប្លែកអ្វី ។ ក៏ចេះតែគិតក្នុងចិត្តថា នឹងបូជាព្រះតេនត្រ័យ ដោយហោចទៅ សូម្បីឃើញកំពុងមន្តតាមមាគិនឹងឃើញគេដង្ហែព្រះភុទ្ធរូបមកហើយ លើកហត្ថមស្សក្តី យ៉ាងនេះ

តំណើរថាកុសលបង្កើតអំពីចក្ខុទ្វារមានរូបជាអារម្មណ៍ជាដើម ។

ការកុសលដែលបង្កើតអំពីសោតទ្វារ មានសម្លេងជាអារម្មណ៍នោះ តើបុគ្គលបានឮសម្លេងជាច្រើនឬ ទើបធ្វើការកុសលហើយមានចិត្តត្រេកអរកើតសទ្ធាជ្រះថ្លាយ៉ាងនេះ តំណើរថាកុសលបង្កើតអំពីសោតទ្វារមានសម្លេងជាអារម្មណ៍ សូម្បីត្រាន់តែបានឮសម្លេងអ្វី ។ ហើយទើបមកបង្អោនចូលទៅខាងការកុសល តំរិះថាជាកុសលបង្កើតអំពីសោតទ្វារមានសម្លេងជាអារម្មណ៍ច្រើនដូច្នេះ ។

ការដែលបានឃើញព្រះពុទ្ធរស្មីហើយកើតសទ្ធាជ្រះថ្លាក្តី តំណើរថាកុសលបង្កើតអំពីចក្ខុទ្វារដូចគ្នា ។ សម្តេចព្រះពុទ្ធអង្គជាម្ចាស់នៃយើងកាលនៅជាព្រះពោធិសត្វទ្រង់ព្រះនាមបញ្ញត្តិឈ្មោះថា សុរុចិព្រាហ្មណ៍ បានឃើញព្រះរស្មីនៃព្រះសុមង្គលសម្មាសម្ពុទ្ធ ដែលប្រកបដោយព្រះរស្មីជាអស្ចារ្យ តិតនឹងនិមន្តព្រះសុមង្គលសម្មាសម្ពុទ្ធនោះ មកថ្វាយបង្គំប្បច្ចុយ្យាន ។ អញ្ជាសំ សរីរបូជា ព្រះរស្មីនៃសម្តេចព្រះពុទ្ធអង្គតាំងឡើងដរាប ។ នោះផ្សាយទៅបានចម្ងាយ ៩០ ហត្ថជាប្រក្រតី ។ ឯព្រះរស្មីនៃព្រះសុមង្គលសម្មាសម្ពុទ្ធនោះ មិនដូច្នោះទេ ឯបុគ្គលំ ផរិត្វា ព្រះរស្មីនៃព្រះសុមង្គលសម្មាសម្ពុទ្ធនោះផ្សាយទូលំទូលាយតាំងមួយម៉ឺនលោកធាតុជាន់ក្នុងកាល ព្រោះហេតុព្រះសុគតមង្គលសម្មាសម្ពុទ្ធជាម្ចាស់ បានបំពេញបុគ្គលទានហើយបានតាំងសេចក្តីប្រាថ្នាថ្កុក

ទីឯបានបូជា ព្រះភុទ្ធមួយព្រះអង្គដោយគ្រឿងបូជាដ៏ប្រសើរលើសគ្រឿងបូជានៃលោកទាំងឡាយ គឺធ្វើរូបកាយរបស់ខ្លួនឲ្យជាប្រទីបថ្វាយដល់ព្រះចេតិយបញ្ចុះព្រះបរមសារីរិកធាតុរបស់ព្រះភុទ្ធមួយព្រះអង្គ ក្នុងកាលនៅជាព្រះបរមពោធិសត្វ មិនទាន់បានត្រាស់ជាព្រះពុទ្ធនៅឡើយ ដូចមានសេចក្តីនិទានតទៅនេះ ៖

សោ កិរ តោនិ សត្តកាលេ បានឮរឿងៗមកថា ព្រះសុមង្គលសម្មាសម្ពុទ្ធជាម្ចាស់នោះ កុងកាលព្រះអង្គនៅសោយព្រះជាតិជាព្រះបរមពោធិសត្វនៅឡើយ បានកើតក្នុងព្រះបវរពុទ្ធសាសនា ប៉ុន្តែសម្តេចព្រះភុទ្ធអង្គនោះ ស្តេចរំលត់ខន្ធបួលកាន់ព្រះនិព្វានទៅហើយ ទុកតែព្រះធាតុចេតិយ ក្នុងព្រះពុទ្ធសាសនាៗមិនអស់ មិនបាត់សាបសូន្យឡើយ ។

ជនទាំងឡាយកសាងព្រះចេតិយបញ្ចុះព្រះបរមសារីរិកធាតុ ទុកជាឧទ្ទេសវត្ថុ ។ បុត្រនៃត្រកូល (កុលបុត្រ) គឺព្រះបរមពោធិសត្វនោះ បានឃើញជនទាំងឡាយនាំគ្នាមកថ្វាយបង្គំព្រះចេតិយ បូជាដោយគ្រឿងសក្ការៈផ្សេងៗ តាមសក្តិ ព្រះបរមពោធិសត្វគិតថា ជីវិតំ បរិច្ចជិតំ គួរអោគ្គអញបរិច្ចាគជីវិតបូជាដល់ព្រះធាតុចេតិយ ទើបនឹងបានឈ្មោះថាបូជាសម្តេចព្រះជិនស្រីសម្មាសម្ពុទ្ធ សក្កលសក្ការៈ ដ្ឋានបេត្វា ទើបភ្ញាក់ឡើងជនទាំងឡាយឲ្យរុំកាយដោយសំពត់ ដែលជ្រលក់ប្រេងក្រអូប

ដោក មានអាការដូចជាប្រទីប ធ្វើឲ្យមានប្រនេះជាច្រើន ហើយអុជភ្លើង
ឲ្យភ្លឺព្រោងព្រាតនេះរេចញាំងសរីរកាយថ្វាយព្រះបរមសាស្តាកជាតុ ដើរ
ប្រទក្សិណ តាមសំដាប់ដោយចិត្តសទ្ធាជ្រះថ្លា ត្រាំទ្រនៅអស់រាត្រីមួយ
រហូតដល់ព្រះអាទិត្យរះឡើង

សោមក្ខិបិ សូម្បីតែរណ្តៅនៃពេមមួយវិនាសអន្តរាយទៅក៏
ឥតអង្គីមានឡើយ សរីរាវយវៈនៃព្រះបរមគោធិសត្វមិនបានក្តៅក្រហាយ
សោះ ត្រជាក់ជាប្រក្រតី អគ្គីមិនបានដុតរោលឲ្យនេះ បរិដ្ឋោ វិយ
ហាក់ដូចជាព្រះបរមគោធិសត្វចូលទៅនៅក្នុងត្របកនៃផ្កាឈូក ។ ឯម្នា
ហិ ដាម មែនពិត សុចរិតធម៌រមែងរក្សាបុគ្គលអ្នកប្រព្រឹត្ត ។ អ្នកណា
ប្រព្រឹត្តធម៌ ក៏រក្សាអ្នកនោះ ។

តេជាហ ភគវា ហេតុនោះ សម្តេចព្រះមានព្រះភាគជាម្ចាស់
ទើបទ្រង់ប្រទានព្រះធម្មទេសនាពុកថា ឯម្នា ហាវេ រក្ខតិ ធម្ម.
ចារី សុចរិតធម៌រមែងរក្សានូវបុគ្គលប្រព្រឹត្តល្អប្រពៃដោយពិត ឯម្នា
សុចិណ្ណោ សុចរិតធម៌នោះ បុគ្គលណាបានសន្សំទុកហើយ ក៏កំណត់
យ៉ាងជាក់ប្លាស់ថា ទំនឹងនាំមកនូវសេចក្តីសុខឲ្យដល់បុគ្គលអ្នកសន្សំនោះ
ឯ ទុគ្គតិ ភយតិ ធម្មចារី បុគ្គលមានប្រក្រតីប្រព្រឹត្តនូវសុចរិតធម៌
នោះ រមែងមិនទៅកាន់ទុគ្គតិ មានព្រះភាគ្ជាដីការប្រទានព្រះធម្មទេសនា
ពុកដូច្នេះ ។ បណ្ឌិតទាំងឡាយគប្បីធ្វើមនសិការកំណត់ពុកគង់ចិត្តថា

អំតើណាជាខ្ញុំនឹងតបលេះបង់ចោលឲ្យស្រឡះកុំធ្វើអំពើនោះឡើយ អំពើណាជាសុចរិត ចូរខំធ្វើអំពើនោះចុះ ។

៥ មសព្ទបិ តកម្មណិ សព្វត្ថេន ហេតុតែផលនៃកុសលកម្មដែលព្រះសុមង្គល បានធ្វើព្រះអង្គឲ្យជាប្រតិបដិបទាដល់ព្រះបរមសាវ័កជាតុចតុយនេះឯង លុះបានត្រាស់ជាព្រះពុទ្ធហើយទើបមានព្រះរស្មីភ្លឺខ្លៅជាំដ៏មួយម៉ឺនលោកជាតុជាទិច្ចកាល ។

ស្តេចព្រាហ្មណ៍នោះ បានឃើញព្រះពុទ្ធរស្មីដ៏អស្ចារ្យដូច្នោះហើយទើបគិតថា អញនឹងនោមភាជនាទិមន្តព្រះពុទ្ធអង្គមកកាន់គេហស្ថាន គិតស្រេចក៏យាត្រាទៅកាន់ទីគាល់នៃព្រះសុមង្គលសម្មាសម្ពុទ្ធ ហើយក្រាបទូលអាភជនាទិមន្តព្រះពុទ្ធអង្គព្រមជាំនឹងព្រះភិក្ខុសង្ឃជាបរិវារ ដើម្បីនឹងឲ្យមកទទួលអាហារបិណ្ឌបាតជានក្នុងវេលាព្រឹកស្អែក ។ សម្តេចព្រះសុមង្គលសម្មាសម្ពុទ្ធក៏ទទួលទិមន្តដោយតុណ្ហីភាព ។ ស្តេចព្រាហ្មណ៍ដឹងច្បាស់ថា ព្រះពុទ្ធអង្គទ្រង់ទទួលទិមន្តហើយ ក៏ក្រាបថ្វាយបង្គំលាវិលមកលំនៅវិញ កាលកំពុងដើរតាមមាគ៌ាគិតថា អាត្មាអញនឹងថ្វាយបិណ្ឌបាតដល់ព្រះភិក្ខុសង្ឃមានព្រះពុទ្ធអង្គជាប្រធានប្រមាណប៉ុណ្ណោះ នឹងឲ្យព្រះភិក្ខុសង្ឃជាំនោះតង់ក្នុងទីកន្លែងណា បើអាសនៈរបស់អាត្មាអញមានមិនគ្រប់គ្រាន់យ៉ាងនេះ ។

(នៅមានត)

សម្តែងព្រះធម្មលិខិត ល្ងី-ឯម ប្រែរៀបរៀង

ព្រះញាណកោសល ញាណ-ឈិន ពិនិត្យ

(តមក)

កាលនោះ សេមទត្តព្រាហ្មណ៍ដែលមានជីវិតរស់នៅ លុះបានដឹងថា សេមព្រាហ្មណ៍ជាសម្លាញ់ស្លាប់ហើយ ក៏តោលពាក្យសោកស្តាយថា ឱសេមព្រាហ្មណ៍អើយ! សំឡាញ់បានដោះលែងជីវិតរបស់ខ្ញុំ ព្រោះអំពីសេចក្តីស្លាប់ ហើយស៊ូស្លាប់ជាយខ្លួនឯង មុខគួរឲ្យខ្ញុំស្តាយណាស់ ។ លុះព្រាហ្មណ៍តោលយ៉ាងនេះហើយ ក៏ចំណាយទ្រព្យសម្បត្តិធ្វើទានដ៏ធំ ជូនដាសពនៃសេមព្រាហ្មណ៍នោះស្រេចហើយ ទុកដាក់ចំណែកបុណ្យចំពោះសេមព្រាហ្មណ៍ ជាសំឡាញ់ដែលទុកលួសមរណភាពនោះឯង ។

ចំណែកខាងសេមទេវបុត្តបានដឹងច្បាស់ថា សេមទត្តព្រាហ្មណ៍ជាសំឡាញ់ បានធ្វើបុណ្យ ហើយទុកដាក់ចំណែកបុណ្យជូនមកឲ្យខ្លួនដូច្នេះហើយ ក៏រមិលមើលទិព្វសម្បត្តិរបស់ខ្លួនដ៏មានសិរីសួស្តី ទាំងបានឃើញនូវផលានិសង្សនៃសេចក្តីកតញ្ញូកតវេទី ដែលខ្លួនបានលះបង់ជីវិតដើម្បីសេមទត្តព្រាហ្មណ៍ជាសំឡាញ់នោះ លុះបានឃើញច្បាស់ហើយ

កំហោះផ្លែកផ្លោះចុះមកកាន់ស្ថានមនុស្សលោក ហើយលះបង់អត្តភាពទិព្វ
ទំម្ងិតអាត្មាថាមាណព ដើរចូលទៅកាន់សំណាក់សោមទត្តព្រាហ្មណ៍ ជាន
ឆ្លើយដំណាក់ស្រុះស្រួលហើយ កំប្រកាសប្រាប់អំពីបុញ្ញកាតបស់ខ្លួន
ដែលបានឡើងទៅកើតនាស្ថានទេវលោកនាយ ហើយនាំយកសោមទត្ត-
ព្រាហ្មណ៍ជាសំឡាញ់ហោះឡើងទៅកាន់ស្ថានសួគ៌ទេវលោក ដោយអា-
នុភាពបុញ្ញាទ្ធិបស់ខ្លួន ទើបនិយាយថា: សំឡាញ់អើយ! អ្នកចូរសោយ
ទិព្វសម្បត្តិសំគួរគោមសេចក្តីប្រាថ្នាអ្នកចុះ លុះនិយាយហើយ កំបានប្រ-
គល់នូវគ្រឿងឥស្សរិយយសនៃទេវតា ឲ្យសោយអស់រយៈ ៧ ថ្ងៃ រួច
នាំត្រឡប់ចុះមកកាន់មនុស្សលោកវិញ បានឲ្យស្ថិតនៅក្នុងផ្ទះបស់ខ្លួន
ដដែល ហើយហោះឡើងទៅកាន់ស្ថានទេវលោកវិញ ។ សេចក្តីពិតថា
បុគ្គលអ្នកបានឧបត្ថម្ភចំណែកបុណ្យក្តី អ្នកចែកចំណែកបុណ្យឲ្យគេក្តី រមែង
បានសោយនូវសម្បត្តិទិព្វ ទីឯសម្បត្តិមនុស្សដោយចំណែកមួយមែនពិត ។

ចាប់ដើមអំពីកាលនោះមក សោមទត្តព្រាហ្មណ៍ កាលបើនឹក
រលឹកឃើញ ។ នូវទិព្វសម្បត្តិដែលនៅសល់ហើយនោះ កំកើតទុក្ខដ៏ធ្ងន់ធ្ងរមាន
សម្បុរគ្រក់កើតជាពេតលឿនអស់ពាំងខ្លួនប្រាកដក្នុងកាលនោះឯង ។

អនេកជាតិសំ ថ្ងៃមួយជាខាងក្រោយ សោមទេវបុត្តបានមើល
ឃើញសោមទត្តជាសំឡាញ់នោះ កំបានដឹងថា សោមទត្តព្រាហ្មណ៍ដល់នូវ
សេចក្តីទុក្ខព្រួយមានពេតធ្ងន់ដូច្នោះហើយ កំតិតពិចារណាថា: ធម្មតា

មនុស្សជាតិតាំងអស់ មិនអាចនឹងសោយសម្បត្តិទិព្វបានឡើយ ហើយក៏ហោះចុះមកកាន់សំណាក់សោមទត្តព្រាហ្មណ៍ បានឱ្យកែវចិន្តាមណីមួយជាកែវអាចឱ្យសម្រេចសម្បត្តិតាំងពួងតាមសេចក្តីប្រាថ្នា ហើយធ្វើកែវនោះឱ្យក្លាយទៅជាកេទស្ត្រីមនុស្សដ៏មានរូបល្អ មានបរិវារច្រើន មានតន្ទីរស្នាដ៏ត្រចះត្រចង់ កន្ទុំរូបស្ត្រីមនុស្សតាំងឡាយដោយអាទុកភាពជាទីរបស់ខ្លួន ទើបធ្វើស្ត្រីកេទនោះ ឱ្យជាភរិយានៃសោមទត្តព្រាហ្មណ៍ជាសំឡាញ់ ហើយហោះឡើងទៅកាន់ស្ថានសួគ៌វិញហោង ។

ឯសោមទត្តព្រាហ្មណ៍ព្រមទាំងភរិយាបុត្ត , ដែលបានសម្បត្តិទិព្វយើញជាក់ឡាស់ដោយភ្នែកខ្លួនហើយ ក៏កើតមានសទ្ធាជឿកម្មជឿផលឥតកម្រើក បានឱ្យទានរក្សាសីលដរាបដល់អស់ជីវិត បានឡើងទៅកើតក្នុងសំណាក់សោមទេវបុត្តជាសំឡាញ់នោះឯង , សឹងប្រកបដោយសម្បត្តិទិព្វទាំង ១០ ប្រការជាសុខក្សេមក្សាន្តក្នុងស្ថានសួគ៌ទេវលោក ។

ព្រោះហេតុដូច្នោះ ទើបព្រះអរហន្តទាំងឡាយ សម្តែងជាបទព្រះគាថាដូច្នេះថា :

មិត្តេកិលញ្ញតមា ឧបការកេន
ឋានេសម្បិ ឯត្តិ សុខិតា ឥតិ ចិន្តយិត្វា,
មា មិត្តទុព្ភិ សតតំ ភវេថាបការំ
ភូសោបការិកតញ្ញូ ភវេវនិត្តភូ ។

សេចក្តីថា: បណ្ឌិតជាតិតាំងពីក្មេយ បើបានឮពាក្យណាដ៏ឆ្ងាញ់ប្លែកៗប-
ន្តិចជួបច្នេះថា: ជនជាសប្បុរសតាំងពីក្មេយតែងមានចិត្តត្រេកអរកែកយកក្តី
មិត្តដែលមានគុណចំពោះខ្លួន ហើយអាចលះបង់ជីវិតនៃខ្លួនតបទុបការ-
គុណរបស់មិត្តនោះវិញ, មួយទៀត ត្រូវតែកុំច្រឹះមិត្រដែលមានទុបការ:
ឲ្យសោះ ត្រូវតែធ្វើតបគុណវិញឲ្យមាំមួនផង ត្រូវមានចិត្តប្រកបដោយ
កតញ្ញូកតវេទិតាធម៌ផង ឲ្យប្រាកដដូក្រលែងដោយពិត ។

សម្តែងរឿងនិទានព្រាហ្មណ៍លះបង់ជីវិតខ្លួនដល់សំឡាញ់ ជាគំរប់
១០ កន្លះគ្គទីពីរបប់ដោយសង្ខេបប៉ុណ្ណេះឯង ។

X
X X

មក្ខុរសភិសាជម្ហទ្វីប

យក្ខវិញ្ញត្តិវគ្គទី៣ មានរឿងនិទាន ១០

១- យក្ខវិញ្ញត្តិវត្ថុកថា

សម្តែងរឿងនិទានបុរសបញ្ញត្តយក្ខជាបឋម ដោយពាក្យចាល់ថា:
កកវតិ បរិជិត្តម្ហិ ដូច្នេះជាដើម អធិប្បាយថា កាលព្រះមានព្រះ
ភាគជាម្ចាស់ ទ្រង់ចូលបរិនិព្វានទៅបើយ, ចានឮថា មានស្រុកមួយ
ឈ្មោះតុណ្ណកគ្រាម (ស្រុកនៃជាងដេរ) នៅកន្លងជនបទរបស់ព្រះចាន់កោ
សលរាជ ។

ឯក្នុងភុណ្ណកគ្រាមនោះ មានមនុស្សម្នាក់ឈ្មោះពុទ្ធសរ ជាអ្នកជ្ឈានដល់ខ្ចូវព្រះពុទ្ធជាទីពឹងស្មើដោយជីវិត ដោយបទជាលីដូច្នេះថា : យាវ.ជីវំ ពុទ្ធំ សរណំ គច្ឆាមិ តុន្ទោ មេ សរណំ តាណំ បភាយនំ ។ ប្រែថា "ខ្ញុំព្រះករុណា សូមដល់ខ្ចូវព្រះពុទ្ធជាទីពឹងទីរលឹកដរាបដល់អស់ជីវិត, ខ្ញុំព្រះករុណា មានតែព្រះពុទ្ធជាទីពឹងជួនជ្រកកោនប្រព្រឹត្តទៅខាងមុខ" ។ បុរសនោះ តែងចំរើនពុទ្ធគុណយ៉ាងនេះពុំដែលដាច់ឡើយ ហើយអាស្រ័យនៅក្នុងផ្ទះខ្ចូលនោះឯង ។

សម័យមួយ មានមនុស្សម្នាក់អ្នកនៅក្នុងជនបទដទៃ ចូលត្រចៀរដើរទៅក្នុងស្រុកនោះ។ ហើយចូលដល់ភុណ្ណកគ្រាម ក៏ចូលសុំទៅសំណាក់អាស្រ័យក្នុងផ្ទះពុទ្ធសរទោសកនោះឯង ។

វេលានោះ មានយក្សមួយ ក្រចូលទៅជ្រែកអាស្រ័យនៅក្នុងសរីរៈនៃបុរសអ្នកជនបទនោះ ក្រថ្នាថ្នាដើម្បីទំនងបៀតបៀនសំឡាប់យកជាចំណីអាហារក ។

កាលបុរសអ្នកជនបទនោះ ចូលទៅខាងក្នុងភុណ្ណកគ្រាមហើយ, ដោយតេជៈគុណនៃពុទ្ធសរទោសកអ្នកដល់ខ្ចូវព្រះពុទ្ធជាទីពឹងជាប់មិនដាច់ ទើបយក្សនោះក្រពុំអាចនឹងចូលទៅកាន់ផ្ទះរបស់ទោសកនោះបានឡើយ ហើយលះបង់លែងចោលបុរសអ្នកជនបទនោះចេញ

កន្លែងធំចំទាងស្រែស្រុក អស់រយៈកំណត់ ៧ ថ្ងៃ ទើលផ្លូវបុរសនោះ ត្រឡប់ចេញមកអំពីផ្នូរនៃទេពកន្យានោះវិញ ពន្លឺឆាប់បរិភោគជាអាហារបស់ពួកយោធ ។

ឯបុរសអ្នកដំនបទនោះ លុះបានទៅសំណាក់អាស្រ័យក្នុងផ្នូរទេពកន្យានោះ អស់រយៈកំណត់បាន ៧ ថ្ងៃហើយ ក៏មានសេចក្តីត្រូវថ្នាំនឹងត្រឡប់ទៅកាន់ដែនរបស់ខ្លួនវិញ ក៏បានលាទេពកន្យានោះចេញទៅអំពីស្រុកក្នុងកាលនោះឯង ។

កាលបើបុរសនោះ ដើរចេញមកអំពីស្រុកផ្នូរហើយ យក្សនោះក៏ស្នូរទៅចាប់បុរសនោះ បានក្នុងដៃតាក់កណ្តាលផ្លូវនោះឯង ។

ចំណែកឯបុរសអ្នកដំនបទនោះសួរយក្សថា អ្នកឯងដើរទៅណាអស់កាលយូរប៉ុណ្ណោះ អ្នកមកចាប់ខ្ញុំធ្វើអ្វី ។

ឯយក្សតបវិញថា យើងបានមកនៅធ្លាំចាំកន្លែងនេះ អស់កាល ៧ ថ្ងៃហើយ ។

បុរសអ្នកដំនបទនោះសួរទៀតថា ចុះអ្នកឯងត្រូវការអ្វីដោយខ្ញុំ ត្រូវឲ្យតែអ្វីដល់អ្នកឯង ។

យក្សបានស្តាប់ហើយឆ្លើយតបថា: ម្នាលបុរសដ៏ចំរើន ! ខ្ញុំមានសេចក្តីត្រូវការដោយអាហារនឹងបរិភោគ ដ្បិតខ្ញុំឃ្លានពេកណាស់ ។

បុរសនោះបានស្តាប់ហើយក៏ពោលថា កាលបើអ្នកឯងស្រែកយ៉ាងខ្លាំងយ៉ាងនេះហើយ ហេតុអ្វីក៏អ្នកឯងមិនចូលទៅចាប់យើងចំរើនគាងក្នុងស្រុកនោះ ។ ឯយក្សឆ្លើយថា : ម្នាលបុរសដ៏ចំរើន! ក្នុងផ្ទះនោះមានទុជ្ញាសកម្នាក់ដល់នូវព្រះពុទ្ធជាតិតឹងជាប់ជាមិត្ត ដោយគេដឹងនៃទុជ្ញាសកនោះឯង បានជាខ្ញុំពុំអាចនឹងចូលទៅកន្លែងនោះបានឡើយ ។

ចំណែកឯបុរសអ្នកដឹងបទ ក៏ពុំបានដឹងសេចក្តីថា តុន្ទ្រៈ នោះជាដូចម្តេចឡើយ, តែថាជាមនុស្សមានប្រាជ្ញាចេះនិយាយបញ្ឆោតយក្សនោះឲ្យដឿបាន ក៏ពោលថា ម្នាលយក្ស! បុរសដែលនៅក្នុងស្រុកនោះបានដល់នូវព្រះពុទ្ធជាតិតឹងយ៉ាងណា ខ្ញុំក៏បានដល់នូវព្រះពុទ្ធជាតិតឹងយ៉ាងនោះដែរ ។ លុះនិយាយហើយ ក៏សូត្រថាលើថា : តុន្ទ្រិ សរណំ គច្ឆាមិ ខ្ញុំសូមដល់នូវព្រះពុទ្ធជាតិតឹងទ្រលឹកដូចទុជ្ញាសកនោះតែត ។ កាលបើបុរសអ្នកដឹងបទនោះបានសូត្រយ៉ាងនេះហើយ យក្សគិស្ងាំងគាំងគាំងស្មារតីមិនដឹងជាខ្លួនថាអ្វីតែត ក៏ស្រែកសម្រែកលាន់ឮខ្លាំងគិតគ្រប់ញ្ជ្រែនត់តំបាត់ទៅក្នុងខណៈនោះឯង ។

បពិត្រសប្បុរសដ៏ចំរើន! តិច្ចដែលបានដល់នូវព្រះសម្មាសម្ពុទ្ធជាតិតឹងយ៉ាងនេះ ទើបមានផលានិសង្សជាអនន្តគុណ អាចការពារនូវភ័យអន្តរាយក្នុងលោកនេះបាន, ការពារមិនឲ្យសត្វធ្លាក់ចុះទៅក្នុងអបាយភូមិ

ជាន ទាំងអាចដឹកនាំសត្វទាំងឡាយទៅកាន់ស្ថានសួគ៌ ដកបង្ហស់ព្រះនិព្វានក៏ជាន ។ ហេតុដូច្នោះ ជានជាព្រះអរហន្តទាំងឡាយ តោលន្ទរបព្រះគាថាដូច្នេះថា :

តុន្នោតិ វចនំ ឯតំ អមនុស្សញ្ញំ កយាវហិ

តុន្នកតិត្តិសទ្ទំ សត្វជា មុនមាវហិ ។

សេចក្តីថា: ពាក្យដែលតោលថា តុន្នោ ដូច្នេះនេះ ជាពាក្យនាំមកន្ទរភ័យធំដល់ខ្មោចទាំងឡាយ ជាពាក្យនាំមកន្ទរសេចក្តីរីករាយចិត្តដល់ជនទាំងឡាយដែលជាតុន្ទបរិស័ទដោយតិត ។

សត្ថោបន្ទវិជាសាយ បច្ចន្តិំ ឥត្ថមោសថំ

ឥត្ថមន្តំ មហាតេជំ មហាយន្តំ មហាភូតំ ។

ពាក្យដែលតោលថា តុន្នោ ដូច្នេះនេះ ហៅថា ឧសថឥត្ថ ហៅថា មន្តឥត្ថ មានតេជៈច្រើន ជាយន្តដ៏ប្រសើរ ជាអស្ចារ្យដ៏ធំ អាចញ៉ាំងទុបត្ថរទាំងពួង ឲ្យវិនាសបាត់បង់ទៅជានដោយតិត ។

(នៅមានត)

លោក អ៊ឹម-ភង ចម្លងពីសាស្ត្រាស្លឹករឹត

ព្រះពុទ្ធវង្ស ភឹម-ភ្នុរតនទិត្យ

(តមក)

សេនកោ រីអាចារ្យសេនកៈស្រដីថា ម្នែអាចារ្យចាំង៣ អើយ! អាចម៍កំចាំងអញ្ចានេះ ប្រសិនបើជ្រួតជ្រាបទៅដល់ព្រះកាណិព្រះមហាក្សត្រ ហើយ អ្នកអើយ! រីឱសអញនឹងដល់ស្លាប់ ហៅតុអ្វីអញថា ឱសអញដល់ស្លាប់នោះ, ដ្បិតកាលនោះ ព្រះបាទកុសរាជ ជាព្រះវរបិតាព្រះមហាក្សត្រនេះឯង ស្តេចទៅប្រពាតកំសាន្តនាឧទ្យាន អញក៏បានម្នែស្តេចទៅកូវ បានយល់ស្ត្រីភ្លាមាសមួយ មានរូបឆោមលោមតណិនោះល្អ អញពុំអាចទប់ចិត្តបានឡើយ ហើយអញបានតាំស្ត្រីភ្លាមាសនោះចូលទៅក្នុងវិត្រស្ងាត់ សេតសម្ភតដោយនូវចំណង់បញ្ចកាមគុណ ហើយមានចិត្តលោភលន់តាន់ប្រមាណ សម្លាប់ស្ត្រីភ្លាមាសនោះ យកត្រឿងប្រដាប់ ដែលព្រះមហាក្សត្រព្រះរាជទាន្យ អញយកមកវេចរួចខ្ទុះនៅចន្លាស់ទឹក ជាទ្រព្យប្រពៃនៃអញ, ហេតុនេះឯង បានជាអញមិនច្រាប់អ្នកដទៃ តោះបើត្រែនឹងក្ងើសំឡាញ់អញនោះហោង ។ អើបុក្កុសៈ ឯងតើយល់ដូចម្តេច អាចម៍កំចាំងនេះ? ចូរថ្លែងច្រាប់មកហោង ។ រីឯអាចារ្យបុក្កុសៈសំដែងច្រាប់នូវអាចម៍កំចាំងនោះថា ខ្ញុំ

សោតមានឃ្លង់ដំបៅ . . ច្រេះដួចជាប់នៅដើមក្តៅ មានតឹករឹងនោះហូរ
ចេញគេចញសំតត់ដិតមកខ្ញុំលែ ឲ្យជាតិគាល់អំលុងយូរហើយ ឥតអ្នកឯណា
ទឹងដឹងឡើយ មានតែប្អូនស្រីខ្ញុំដឹង , កាលណាបើត្រឹកត្រាហាមអប់ណា-
ទ័យហើយ ប្អូនស្រីខ្ញុំយកតឹកមកលាងជ្រះដំរះខ្ទុះអស់ចឹងរួចហើយ យក
ថ្នាំបំពោក យកសំឡីមកប៉ះច្រើនជាន់ ហើយយកកំណាត់សំតត់មក
រុំថែមទៀត ទើបយកខ្សែបន្ទំឲ្យមានហ្មត់ចត់ឡើយ ទើបស្លៀក
សំតត់លើ ហើយខ្ញុំដើរទៅគាល់ព្រះមហាកស្សត្រ , ដួនថ្ងៃមួយ ស្តេច
គំសាន្តព្រះហឫទ័យ ហើយលិលាមកគន់លើក្តៅខ្ញុំ យកព្រះហស្តមក
អង្អែលសរសើរថា ក្តៅប្លុកស:នេះខន់ មានកាលសរសើរតែអម្បាលនោះ,
មានកាលក៏ស្តេចយកព្រះកេសមកផ្ទំលើក្តៅខ្ញុំបន្តិចទៅក្រៅ តឹករឹងនោះ
ជ្រាបជាប់ជាប់ចុងព្រះកេសាព្រះមហាកស្សត្រ, នែអ្នកអាចារ្យសេនក:អើយ!
អំតើកំចាំងខ្ញុំនេះឯងដូច្នេះ , ប្រសិនបើស្តេចជ្រាបសុភាពថា ខ្ញុំមានឃ្លង់
ដំបៅដូច្នោះហើយ ម៉្លេះសមស្តេចឱ្យអាមាត្យសម្លាប់ខ្ញុំបង់តុំលែងឡើយ,
ហេតុនេះឯង ខ្ញុំតុំសំដែងប្រាប់អ្នកដទៃ ពោះបើក្រែងចឹងប្អូនស្រីខ្ញុំនោះ
ឡើយ ។ អាចារ្យសេនក:ថានឹងអាចារ្យប្លុកស:ដូច្នោះហើយ ទើបដណ្តឹង
ទៅអាចារ្យកាមិនូវទៀតថា អាចារ្យកាមិនូវតើដូចម្តេច? ។ ទើបអាចារ្យកាមិនូ
តបថ្លែងនូវអាថិកំចាំងរបស់ខ្ញុំនថា ឯខ្ញុំនេះ កាលណាបើថ្ងៃ១ចោសថ
ជាប់ខែនោះ មានភ្លេចយកក្ស ១ ឈ្មោះ ឧរេវ: តែងមកបួលជាន់

នៃខ្ញុំ ហើយខ្ញុំស្រែកដូចឆ្កែឆ្កួត សំឡេងខ្លាំងក្រៃ ។ រីកូនខ្ញុំ ក៏ដឹងខ្លួនដំណើរដូច្នោះហើយ ក៏រាបចូលមកចាប់ខ្ញុំនាំទៅក្នុងផ្ទះ ហើយបានយកទៀមមកបង្ខំខ្ញុំឆ្លាប់ផ្តែត ពុតនៅលែងខានតែហើយបង្ខំគ្រាន់ឆ្លាប់ ទើបកូនខ្ញុំចេញមកក្រៅ ហៅអស់បរិវារយកភ្លេងមហោស្រពមកលេង ឲ្យប្រឡំសំឡេងភ្លេងនឹងសំឡេងខ្ញុំស្រែក តុំឲ្យអ្នកដទៃក្រៃលែងខ្លួនកូនខ្ញុំក្តៅឡើយ, រីអាចម៍កំផ្ចាំងនេះ បើស្តេចជ្រាបសុភាពជាខ្ញុំឆ្កួតហើយ រាជរិតនៃខ្ញុំឥតអង្គឹមានឡើយ, ហេតុនោះខ្ញុំថា គួរតម្បីក្រាប់កូននោះកំប្រុសើរក្រៃ ។ អាចារ្យសេនកៈស្តាប់ហើយឆ្លើយថា អើ! អាចម៍កំផ្ចាំងអាចារ្យកាមិនូវជាដូច្នោះហើយ, ឯអាចារ្យទៅនឹងឯងតើដូចម្តេចសោត? ។ ទើបអាចារ្យទៅនឹងថ្លែងសំដែងក្រាប់ថា ម៎ៃអាចារ្យអើយ! ឯសេចក្តីកំផ្ចាំងខ្ញុំនោះ, កាលនោះ ព្រះបាទកុសពជជាសម្តេចព្រះវរពជបិតាព្រះមហាសត្វត្រេយ៉ងនេះ ព្រះឥន្ទ្រាធិពជឲ្យកែវមណីរតនមកស្តេច ប្រយោជន៍នឹងឲ្យរុងរឿងថ្កើងជាមង្គលប្រសើរ លុះដល់ស្តេចទ្រង់ព្រះអាពាធជាខ្លាំងនោះ ខ្ញុំឡើងទៅចាំមើលព្រះរោគ ខ្ញុំឃើញកែវនោះហើយខ្ញុំលួចយកបាន ហើយខ្ញុំឲ្យទៅម្តាយខ្ញុំរក្សា ហើយខ្ញុំមានសិរីសួស្តី, រីម្តាយខ្ញុំតុំឲ្យអ្នកដទៃដឹងដល់តបឡើយ បើខ្ញុំនឹងឲ្យឮទៅតាល់ព្រះមហាសត្វត្រកាលណា ម្តាយខ្ញុំឲ្យកែវមណីរតនានោះមកខ្ញុំ ។ បញ្ហាលខ្លួរស្រមោលសិរីសួស្តីហើយ ទើបខ្ញុំឡើងទៅកាន់មន្ទីរស្តេច រីស្តេចមិនមានបន្ទូលនឹងអម្ចាស់ពាំងឡាយឡើយ

ស្តេចមានព្រះបន្ទូលតែនឹងខ្ញុំថា ម្នាលកាឡាយនីអើយ ! ចូរមកឯកាយ ខ្ញុំចូលទៅទៀបព្រះមហាក្សត្រហើយ ព្រះអង្គព្រះកជគានមាស ៨ ដំឡឹងម្តង, ១៦ ដំឡឹងម្តង, ៣២ ដំឡឹងម្តង, ៦៤ ដំឡឹងម្តង, សព្វថ្ងៃ ខ្ញុំអាស្រ័យដោយតែរមណីតែនឹងនោះឯង បើស្តេចជ្រាបបន្ទូលអាចកំចាំងតាំងអម្បាលនោះហើយ នែអ្នកអាចារ្យសេនកៈអើយ ! ដែរតែនៃខ្ញុំឥតអង្គីមានឡើយ, តែក្តីកំចាំងនេះ ខ្ញុំមិនច្រាប់អ្នកដទៃក្រៃលែងម្តាយខ្ញុំឡើយ ។

ទើបថ្ងៃដតព្រះបរមគោធិសត្វមិញ ព្រះអង្គគង់នៅក្រោមអាងចាយនោះ បានស្តាប់បន្ទូសដ៏អាចារ្យតាំង ៤ សំដែងថ្ងៃនៃអាចកំចាំងតាំងអម្បាលនោះហើយ អ្នកតស់សំគាល់ខុសក្នុងព្រះកជហាប្តូយសព្វគ្រប់ឥតមន្ទិលតិគាល់ឡើយ ។ នៃ (ចន្តាភេ បណ្ឌិតា) . . . រីអ្នកបណ្ឌិតតាំង ៤ និយាយគ្នា ដូចគេទំលាយផ្ទៃនៃអាត្មាឯងស្រេចហើយដោះឡើងទៅ ហើយស្រដីថា អ្នកតាំងឡាយកុំប្រហែស ចូរមកអំពីព្រឹកហោង, យើងនឹងសម្លាប់កូនគហបតីឲ្យបានដូចក្តីចំណង់យើងហោង ។ អាចារ្យតាំង ៤ ស្រដីដូច្នោះហើយ កំហួសទៅផ្ទះវិញ ។ ហោង ។

បតិត្រអើយ ! រីបរិតារគោធិសត្វដែលតាំយ៉ាំមើល យល់អាចារ្យតាំង ៤ ទៅដូច្នោះហើយ កំចូលទៅបើកអាងចាយឡើងឲ្យគោធិសត្វចេញមកហើយ អ្នកលីលាហេត្រទៅដល់លំនៅ ហើយអ្នកស្រង់ខ្លួនឲ្យគឹតអប់ត្រឡប់ខ្លួនតួរដោយប្រពៃស្រេចហើយនៃ អ្នកសោយខ្លួនគោជនាហារមាន

ឧដារសនោះត្រកាលផ្សេង។ ហើយទ្រង់ព្រះចិន្តាថា យប់នេះនាងទុម្មុរទេវី ជាអយិអគ្គមហេសីព្រះមហាក្សត្រ អ្នកនឹងឲ្យតតិមានមកច្រាប់អញតុំលែងឡើយ, ពោធិសត្វគិតដូច្នោះហើយ អ្នកប្រើប្រុសបរិភោគរាត្រីនាក់ឲ្យចាំនៅទ្វារ ហើយផ្តាំថា បើមានបំរើអំពីនាងទុម្មុរវរលក្ខណ៍ ជាអយិអគ្គមហេសីនៃស្តេចឲ្យមករកអញ ក៏ចូរអ្នកចាំនឹងឲ្យច្រាប់ថា អញនៅទេឲ្យចូលមកកាន់អញឆាប់តុំបីយូរឡើយ ។ ពោធិសត្វអ្នកផ្តាំនូវប្រការអម្បាលនោះហើយ អ្នកចូលទៅផ្ទំលើតត្រាលដ៏ប្រសើរ ជាសុខសប្បាយទៅហោង ។

ឥស្មឹ ខណេ ឧដា សិរីសយនបិដ្ឋេ និបជ្ជោ បណ្ឌិតសប្ប កុណោ សរិត្វា មហោសធបណ្ឌិតោ សត្តុវិសុទ្ធិកាលតោ បដ្ឋាយ . . . . . ឮដំកាលនោះ រីព្រះបាទវិទេហរាជ ស្តេចចូលទៅគង់លើគ្រែក្នុងព្រះបន្ទំ ព្រះអង្គពុំស្រណុកព្រះរាជហឫទ័យសោះ ស្តេចបានរំលឹកគុណព្រះពោធិសត្វថា មហោសធអ្នកប្រាជ្ញ អាចមកគាស់ហ្មៅទៅបំរើធ្វើប្រយោជន៍ឲ្យអញតាំងពីអាយុ ៧ ឆ្នាំ រហូតមកដល់ពេលនេះ អ្នកតុំដែលធ្វើនូវកំហុសណាមួយចំពោះបូបអញនោះឥតអង្គីមានឡើយ, កាលនេះគាជណ្តើងប្រាស្នាអញក្តូរមហោសធអ្នកប្រាជ្ញធ្វើយ៉ាងសោះអាចប្រាស្នាគាងអញ, ឥឡូវនេះ បើអញឥតតាមមហោសធអ្នកប្រាជ្ញហើយ រាជវិតនៃអញឥតអង្គីមានឡើយ ។

(នៅមានត)

ភាគ៣ក្បួ ៩

ឃុនសុវត្ថិរវិទ្ធ ឃួរ-អ៊ុន ធិពង្ស

បានទទួល

រង្វាន់លើកទឹកចិត្ត

ផ្នែកការនិពន្ធ ក្នុងការប្រឡងអក្សរសាស្ត្រ
របស់សមាជអ្នកនិពន្ធខ្មែរ នៅឆ្នាំ១៩៦១

ធម្មាវាកថា

ខ្ញុំសូមលើក ហត្ថទ្រតុំ បង្គំផ្តង់
ចំពោះត្រង់ អង្គវៃត្រែត្ន កង់លោកា
គឺព្រះពុទ្ធ ទីឯព្រះធម៌ ជាសរណា
ចាំឯព្រះសង្ឃ ជាគេត្រា នៃពួកសត្វ ។
ព្រះសម្ពុទ្ធ ព្រះសទ្ធម្ម ទីឯព្រះសង្ឃ
ចាំឯ៣ អង្គ ដែលឈ្មោះថា ព្រះវៃត្រែត្ន
ព្រោះជាកែវ មានតន្ទី ក្តីធ្វៀលធ្លាត់
អាចបំបាត់ កាត់ឯងឹត កង់សន្តាន ។
កែវដែវ(១) ពោះបីថ្លៃ ប្រើនអនេក

---

១ កែវមណី, កែវពៃទូរ្យ. កែវបវិត្ត, ពេជ្រ, មាស, ប្រាក់ ជាដើម ។

វស្សាប្លែក ធ្លុះចាប់ក្អែក អ្នកឃើញថាន
កំមិនអាច កំចាត់ស្ងួត ក្នុងគន្លួច្រាណ
មិនអាចច្រាន កន្ធកិលេស ឲ្យឃ្លាតឆ្ងាយ ។
ឯត្រែវត្ត ច្រកដងា តែវាថ្លង់
ញ៉ាំងច្រហ្មាញ មនុស្សរខ្ពាំ ឲ្យមែកសាយ
ឲ្យលះកាត់ គ្រឿងសៅហ្មង ផងចាំងឲ្យាយ
ឲ្យឆ្លាតគ្រាយ ផ្តាច់ចង្វាយ ខៀតណ្ហា ។
តែវាចាំងបី គុណពិសី គួរគោរព
ចាំងជាមួប ជំត្រជាក់ អ្នកសាសនា
ហេតុនេះខ្ញុំ សូមលើកផ្តុំ ម្រាមហត្ថា
នមការយា លុតជង្គង់ បង្គំថ្វាត់ ។
ដោយគេដះ នមស្ការ យ៉ាងខ្វីនេះ
ខ្ញុំសូមរិះ រកតាក្យកាត្យ ដោយវៃក្លាត់
ឲ្យចាប់ជួន ដួនជាន់ន័យ គ្មានវិបត្តិ
សូមកំចាត់ បំភ្លាត់មោហ៍ ទាំងគ្គល្អក់ ។

អារម្ភកថា

តពីនេះ ខ្ញុំសូមថ្លែង រឿងការខ្លះ
កស្សបៈ ដ៏មានជាក់ ក្នុងជាតក

នៃគម្ពីរ ព្រះសុត្តន្ត- បិដក
ដោយការធក់ បកប្រែកែ ជាភាសាគាត្យ ។
ជាភាសាបួន ប្រាំបួនម៉ាត់ ចាត់មួយវគ្គ
បួនឃ្លាជាក់ ជាក់ទំព័រមួយ ស្មាត់ដកប
តែភាសាខ្លះ ដែលអានធក់ ឮតិចតាប(๑)
ឃ្លាខ្លះឯង ទំនងប្រែភាត ជាភាសាដម៌(๒) ។
ការណ៍ដែលទាំ បង្ខំខ្ញុំ លើកឿងនេះ
ដោយគ្រែះរ៉ះ ឃើញតិតថា ជាឿងកប់
គ្មានទាន់ផ្សាយ កន្លងដែនខ្មែរ ជាច្រើនចប់
ជាកំណប់ កប់លិចទៅ កន្លងបាលី ។
ហើយជាឿង មានសារៈ ជាក់សំខាន់
ដូចព្រះបន្ទូ ព្រះអាទិត្យ ចាំងរន្ទឺ

---

๑ ភាសាដែលអានដកឮតិច ដីជាភាសាឮជាប់ទំយោយតំមាត់មកហើយ ដូច សៈណា, ប្រតិបត្តិការ, ករុណា, មនុស្ស, មហាក្សត្រ ជាដើម ។ ๒ ភាសាកាសាខ្មែរ បើតែងជាបទភាសា ៧ ក្នុងមួយឃ្លា ទំងមានឃ្លាខ្លះជាភាសា ៨, បើជាបទភាសា ៨ ទំងមានឃ្លាខ្លះ ជាភាសា ៩, បើជាបទភាសា ៩ ទំងមានឃ្លាខ្លះជាភាសា ១០ ដោយអាស្រ័យភាសាអានដកំនោះ ដូចគ្នាទំងភាសាបាលីដែរ តួយ៉ាង :

អទិក្ខសាវោ ភាសាវ៎ យោ វត្តុំ បវិទហិស្សតិ
អបេក្ខោ ទមសច្ចេន ន សោ ភាសាវមហរតិ ។

ឲ្យដឹងដឹង ដឹងមិនបាន ប្រាននអស់ខ្លី
បញ្ជាំងដី ឲ្យពួកសត្វ ប្រតិបត្តិការ ។
បើលោកអ្នក មានចិត្តស្មគ្រ ចាននអានហើយ
ខំដឹងប្រាសឲ្យ ចាត់សង្ស័យ ក្នុងធម៌អាថ
ដែលយល់ឆ្ងែង ឬមិនយល់ ដោយតិស្តារ
តាមហេតុការណ៍ ពោះតិចច្រើន ជាតុំខាន ។
ដោយអាស្រ័យ ន័យយ៉ាងនេះ ទើបខ្ញុំប្រែ
បកស្រាយកែ តែងជាភាសា ដោយក្លាហាន
ខុកជាកិច្ច ការស្មោដៃ នៃអង្គប្រាណ
ដូចនិទាន មានតរៅ ជាសង្កាត់ ។

វិត្តកថា

ឯសេចក្តីថា ក្នុងវិនេ- ហនគរ
ដ៏ឧត្តរ មានស្តេចមួយ ប្រសើរក្លាត់
ទ្រង់ព្រះនាម អង្គតិ ជាមហាក្សត្រ
សោយរាជ្យរដ្ឋ មានអំណាច ខ្លាំងអស្ចារ្យ ។
មានវេហ៍តស សុទ្ធតែកែ ច្រើនអនេក
អាចចូលជ្រែក ដែកតយុទ្ធ ទីដ៏ខ្លាំងមារ
ដោយក្លាហាន គ្មាននខ្លាច ហ៊ានតុះតារ

ស្តេចជនៃ តំយអន្ធការ ចុះចាញ់ដៃ ។
កន្ធវិជ្ជមួយ ស្តេចទ្រង់ហៅ ពាដសេះក
ាំងជាតាក់ ឲ្យចូលតាស់ ប្រញាប់រៃ
តីសុតាម, លោកអលាត ទីធរដ៏យ(១)
ហើយក្សត្រថ្លៃ មានបន្ទូល ត្រាស់ប្រឹក្សា ៖
នែអស់លោក កន្ធវិជ្ជនេះ ខ្ញុំទីកចង់
សប្បាយអង្គ ត្រង់រឿងមួយ ប្រពៃថ្លា
ចុះបងអ្នក ស្ម័គ្រជួយគិត តាមប្រាជ្ញា
ធ្វើយ៉ាងណា ឲ្យខ្ញុំបាន កក្ខន្ធរីករាយ ។
លោកអលាត ក្រាបទៀបបាទ បង្គំថ្វាត់
ខ្លួនមហាក្សត្រ តាមយោបល់ យល់កន្ធកាយ
ថាបពិត្រ ព្រះនរិន្ទ រិទ្ធិតណ្ហាកយ
ខ្លួនបង្គំ សូមក្រាបថ្វាយ ពាយយោបល់ ៖
ការពម្យាំង តាំងតយុទ្ធ ទីធរស្តេចណា
ដែលមិនខ្លាច ព្រះចេស្តា នៃចមតល

---

១ បណ្តាមន្ត្រីជាន់ខ្ពស់ទាំង ៣ នេះ, លោកសុតាម ទីធលោកវិជ័យ ក្នុងជាសឺ មិនឃើញប្រាប់ឋានន្តរស័ក្តិទេ; ចំណែកលោកអលាត មានប្រាប់ថា ជាសេនាបតី ធំជាងគេក្នុងមន្ត្រី ក្នុងសម័យនោះ ។

ក៏ឃស្តេចនោះ ឲ្យចុះញ៉ាំម ត្រមប្រគល់
ថ្វាយដីដល់ ព្រះភូមិន្ទ ឲ្យត្រួតត្រា ។
ធ្វើយ៉ាំងនេះ ទើបព្រះអង្គ ទ្រង់សប្បាយ
ដោយបានផ្សាយ ភតអំណាច រាជអាជ្ញា
បើទ្រង់សព្វ គាប់ព្រះទ័យ ស្រេចចិន្តា
ខ្ញុំសូមបង្គំ ក្តុំសេចក្តា ច្បាំងថ្វាយទ្រង់ ។
បន្ទាប់មក លោកសុនាម ក្រាបបង្គំ
ព្រះបរម មហាក្សត្រ ខត្តិយវង្ស
ខ្ញុំសូមថ្វាយ ទ័យ ឲ្យទ្រង់ជ្រាប មិនបង្អង់
ថាសូមទ្រង់ ជ្រាបក្រាមល្អង ឆ្លៀងបាទ ។
ខ្ញុំសូមបង្គំ យល់ថាការ ច្បាំងរាំងដល់
នាំអំពល់ ឲ្យវល់ ខួចបង់ខាត
ព្រោះព្រះអង្គ មានស្តេចច្រើន ស្តាប់ទុកខ
ជ្រកក្រោមបាទ មានមកហើយ ដូចជ្រាបស្រាប់ ។
បើព្រះអង្គ បង់កាយ ក្នុងព្រះទ័យ
សូមទ្រង់រៃ នៃគ្រួសារ ខាងស្បែនសត្វ
ប្រគំភ្លេង សេនង្គ្រង់តាំ ឲ្យគឹងគាប់
ទើបចិត្តចាប់ ក្នុងតន្ត្រែក នៃការមរ ។

តមកៈវៀត លោកវៃយ្យ លើកតំបន់
បង្គំអង្គ ព្រះទរិទ្ធ តិទូសរ្ទ
ក្រាបទូលន័យ រៃតាមយល់ យ៉ាំងនេះថា
សូមមេត្តា ទ្រង់ករុណា ជ្រាបសេចក្តី ។
ការស្តាប់ព្រឿង មៀនមើលរាំ ល្បែងនេះណា
ព្រះរាជា ទ្រង់សណ្តាប់ ពលំកត្រី
ចាំបាច់ទូល ឲ្យទ្រង់ជ្រាប ជាន់ការអ្វី
ព្រះចក្រី គួរមានក្តី យល់យ៉ាំងនេះ ៖
សូមព្រះអង្គ ទ្រង់ស្តេចយាង សាកសួរធម៌
ដោយស្មោះសរ ខំឯកត្រាជ្ញ ដែលឆាចវេះ
ដោះស្រាយរួច គ្មានខ្វែសង្ស័យ សល់ចំណេះ
ធ្វើយ៉ាំងនេះ ទើបតេញ្ញា សប្បាយតិត ។
គ្រានោះឯង ព្រះរាជា ទរសេដ្ឋ
ទ្រង់សង្កេត ន័យចាំង៣ ដោយតិន្តិត្ស
ឃើញដូចការ្យ លោកវៃយ្យ ស្តីនោះតិត
ទើបទ្រង់រិទ្ធ ប្រសិទ្ធពរ ឲ្យវៃយ្យ ។
រួចទ្រង់គ្រាស់ ព្រះបន្ទូល សួរទៅថា
ចុះលោកណា ឆ្លាប់ស្ទាល់ជាក់ អ្នកជ្រាបថ្លៃ

មានច្រើនជ្រា អាចដោះសា ដោយប្រពៃ
នៅអាស្រ័យ កល់ឃប់ថ្ងៃ ក្នុងខ័ណ្ឌ ?
លោកអណាត ជាទាយក ដ្ឋមន្ត្រី
ក្រាបទូលខ្ញុំ ថាសូមទ្រង់ ព្រះមេត្តា
មានអចលក់(១) ឈ្មោះគុណៈ(២) ស្នាក់នៅទា
ព្រៃមិគទាយ៍ មហាវ័ន ណាព្រះអង្គ ! ។
លោកគ្រូនេះ មានចំណេះ ច្រើនជ្រៅជ្រៅ
បើស្តេចទៅ សួរប្រស្នា យ៉ាងខ្លីតង្ហង់
លោកអាចថ្វាយ ឥឡូវសេចក្តី គ្មានបង្អង់
មុខជាទ្រង់ ជ្ញានរីកឡើយ ជាពុំខាន ។
ព្រះរាជា ទ្រង់សណ្តាប់ សព្វនាយក
ទើបទ្រង់ឆក់ ព្រះសរ្សៃ ទូលថ្វាយ
រួចទ្រង់គ្រាស់ ព្រះបញ្ជា ឲ្យរៀបយាន
សម្រាប់តស កងពាហន ទ័ន្ធមន្ត្រី ។
ស្តេចទ្រង់យាង ដោយមានឆាង ពាសពេញ
ទាំងសេនា អ្នករាជការ ហែចត្រី

---

១ អ្នកបួសអាក្រាត ដាក់ត្រឹងតែស្បៃ បួសក្រៅ ពុទ្ធសាសនា ។ ២ ហៅជាន ២ យ៉ាងដែរ ...ពុណៈ... កំណាន, ដែរ ...គុណ... កំណាន ។

ស្តេចដល់ហើយ ទ្រង់គោរព តាមវណ្ណ
រួចនរបតី ត្រាស់ទន្លាវ សួរទៅថា ៖

លោកគ្រូម្ចាស់ សុខស្រួលអង្គ ខេមប្តូម្ចី
ប្តូមានក្តី មិនសប្បាយ ដោយហេតុណា
ចាំឯព្រះនេត្រ អាចសង្កេត មើលឃើញច្បាំ
ប្តូកំជា ឯងឹតដឹត អស់ទៅហើយ ?

លោកគ្រូគុណា ថ្វាយព្រះតារ បវរក្សត្រ
ថាបែតុ កងរូបប្រាណ ពុំមានខ្លាយ
សឹងសុខសាន្ត គ្មានទុក្ខព្រួយ ជាសះស្បើយ
តែកកាំងតារ ក្តីនៅខ្លើយ គ្មានឯងឹត ។

– ខ្ញុំកុណា ដែលយាត្រា មកទីនេះ
ប្រាថ្នាចេះ នូវចំណេះ ជំពិចត្រៃ
ដោយសាកសួរ នូវសំនួរ តាមក្រមក្រឹត្យ
សូមម្ចាស់គិត ពិនិត្យដោះ សោះសង្ស័យ ។
ខ្ញុំសង្ស័យ សឹងមានន័យ ដូចតទៅ ៖
តើម៉ែនុ ត្រូវបុត្រធ្វើ កិច្ចយ៉ាងណា
តបគុណលោក ដែលមានមក លើអាត្មា
ឲ្យសុខា ជ័យមង្គល មានដល់ប្រាណ ?

មួយវិញទៀត ជាតិជាមនុស្ស កន្លែងកើយ
កាន់ជម្ងឺអ្វី ទើបមានក្តី សុខសម្រាន្ត
កន្លែងនេះ ទីឯណោកនាយ ពុំអាត់ខាន
សូមលោកគ្រូ គូរនិមាន កាត់ក្តីឲ្យ ។
- ថ្វាយព្រះពរ ! ផលនៃកម្ម អាក្រក់ល្អ
នៃសត្វក- សាធសឡំ ខំតំកល់
ជួបឲ្យាន រក្សាស៊ីល ផ្តិលកង្វល់
ដែលទីឯផ្តល់ ឲ្យសុខទុក្ខ នោះកំគ្មាន ។
ទាំងបរលោក លោកជវៃ ពីលោកយើង
ហានសួគ៌ឋេង ហានឧរក ទីឯនិព្វាន
ខេត្តាត្រហ្ម មារយក្សយម កំពុំមាន
សេចក្តីនេះ សូមរំឭកាន កុំភ្លៃតក្ត(១) ។
បើបាបបុណ្យ ទាំងពោសគុណ មិនឲ្យផល
ទៅវិលតបគុណអ្វី ម្តាយឪពុក
កិច្ចដែលគាំ ដែលរោកធ្វើ ទាំងត្រង់មុខ
ការនេះទុក ជាការៈដ៏ឥតដាមេ ។
សត្វបានសុខ ឬបានទុក្ខ កំបានឯង

---

១ អាន ភ្លៃតក តាមសំឡេងវៃ ។

គ្មានកម្មដែន ជាតំឡៃសុខ ឡើយក្នុងទេ
ឯមានសីល គឺជនភាល ធំជាងគេ(២)
ជាឧបត្ថម្ភ ពុកគ្រាន់តែ(២) ប្រយោជន៍ខ្លួន ។
ព្រោះហេតុនេះ មនុស្សយើង មុនស្លាប់ទៅ
មិនជាប់ត្រូវ តិតទៅមុខ ដែលឈឺឆ្អាលសូន្យ(៣)
តិតធ្វើអ្វី ទាំងក័យ មានដល់ខ្លួន(៣)
បើនឹងតិត តិតឲ្យមួន តែរកត្រឡាប់ ។
កន្លះលោះទោះ លោកអណាត ដង្កមន្ត្រី
មានសេចក្តី ដឿត្រគុណ ដែលរៀបរាប់
ទើបលើកហត្ថ គោលស្លាត់ថា ខ្ញុំមានភ័ព្វ
សូមតំនាប់ លោកគ្រូម្ចាស់ ដោយជ្រះថ្លា ។
ពាក្យលោកម្ចាស់ ដែលគោលនេះ គេញាំត្រូវ
ត្រង់តាមផ្លូវ តំនិតខ្ញុំ ឥតសង្ស័យ
ខ្លួនខ្ញុំឯង កស្តុតាងស្រាប់ ឆ្លាប់កើតជា

២-៣ សម្ផស្សពាក្យចូនមាន ៣ ធំ មុខុសម្ផស្ស ដ្ឋិចខ្សែ អឺ នឹង អែ, ខ្សែ អា នឹង អៀ. ខ្សែសៀញ្ជនី :) នឹងខ្សែ ស, ខ្សែ រ នឹង ឥត រ យកចូនគ្នា ១; មដ្ឋិមសម្ផស្ស ដ្ឋិច ខ្សែ អេ នឹង អែ,ខ្សែ អូ នឹង អួ. ខ្សែ អំ នឹង អុំ យកចូនគ្នា ១; ឧកដ្ឋិសម្ផស្ស ដ្ឋិចខ្សែ អ នឹង អ, ខ្សែ អា នឹង អា. ខ្សែ អះ នឹង អះ យកជូនគ្នា ១ ។ ការិនីពន្ធកាព្យ តែង ដៀសពាក្យចូនជា មុខុសម្ផស្ស ។

ចំឡែ(១) បឋមវោ. ភណាសិ ។

ចំឡែ: ជាតិជាអ្នក សម្លាប់គោ

ជាមនុស្សមោហ៍ ចាំងងងឹត ជិតរស្មី

មិនដែលធ្វើ ទ្វារអំពើ កុសលអ្វី

លុះស្លាប់ទៅ ម្តេចមិនទៅ នៅនរក ។

ត្រូវប៉ះកើត ឃកកំណើត ជាខ្ញុំនេះ

បុណ្យធំម៉ឺន ធ្វើមន្ត្រី ទីនាយក

ព្រោះរឿងនេះ ទើបខ្ញុំឃើញ ជានរក

ឋានសាមក សម្រាប់សត្វ តុំមានទេ ។

ចាំងឋានសួគ៌ គឺមិនគួរ ដឿជាមាន

ចាំងនិព្វាន គឺមិនគួរ ដឿតាមគេ

ផលនៃកម្ម ដឹកនាំជាតិ ឲ្យជាតិរេ

គ្មានសោះទេ ស្រែចនៅតែ ធម្មតាចាត់ ។

ខណៈនោះ មានបុរស កំសត់ម្នាក់

ឈ្មោះវីដក: អង្គុយស្លាប់ ដោយស្រឡឹមស្ងាត់

កាលបានឮ ពាក្យសន្ទនា ជាសន្ធឹកត់

---

១ ឈ្មោះ ។ ចំឡែ: ។ ខ តែដែលជា ។ ចំឡណ ។ ដើម្បីឲ្យបានចំវាក្យ ។ ជា ។ នៅឃ្លាខាងដើម ។

កើតរៀបត្តិ កាត់ពុំបាន យំហ៊ឺ ។ ។
ស្តេចទតឃើញ ទ្រង់ទឹកធ្លាល់ ទ្វល់ព្រះទ័យ
ទើបត្រាស់រៃ ឲ្យមន្ត្រី ទៅបំភ្លឺ
នាំយកមក ទ្រង់សួរកេ ហេតុយំក្អ
នោះតើតី មានកើតទុក្ខ ពុំសុខអ្វី ?
រីឯក: ស្តេចទុតិត ឱ្យត់ក្រោ
លើកហត្ថា បន្ទន់កាយ ថ្វាយសេចក្តី
ថាខ្ញុំឯង ចំរៃឆ័ចិត្ត ព្រោះដ្បិតអី
មានសេចក្តី ព្រួកឃើញ ជាតិតាមុន ។
កាលខ្ញុំកើត ជាសេដ្ឋី ឈ្មោះកាវ:
មានភោគ: ទ្រព្យសម្បត្តិ ជាដើមខ្លួន
ច្រើនអនេក ខ្ញុំរំលែក ចែកធ្វើបុណ្យ
យកទ្រព្យខ្លួន ដាក់ជាទាន គ្មានអាល័យ ។
តែដល់ខ្ញុំ ស្លាប់តាំងោះ លុះមកកើត
យកកំណើត ក្នុងត្រកូល ខ័ណ្ឌឡាំងក្រៃ
ជាជាតិថោក ធ្វើខ្ញុំគេ តែសព្វថ្ងៃ
ក្រហិនវៃហ៎ ក័យខ្លួនឯង ឥតគេលង់ ។
ទោះយ៉ាងនេះ ខ្ញុំគង់រិះ ស្មាទានសីល

ឥតមានខ្ជិល ខំរក្សា ទេជាសច(១)
កាលថ្ងៃវៃ ខំប្រឹងថែ ឲ្យបរិសុទ្ធ
ខំលំអុត ដុតកិលេស គ្មានសេរើ ។
ឥឡូវឮ លោកគ្រូគុណ ខ្ញុំដឹងអស្ចារ
ដែលមានភព ថាសីលទាន គ្មានតំលៃ
ទាំងឲ្យខ្ញុំ ស្តាយក្នុងចិត្ត គិតសេរើ
ឃើញទានធ្វើ តាំងតែមុន ឥតផលផាក់ ។
តាំងសីលសោត ដែលខ្ញុំកាន់ តែពាល់ថ្ងៃ
ក៏មានន័យ ប្រហែលគ្នា គ្មានស្មើរស្មាក់
ត្រូវដូចពាក្យ របស់លោក តាំងពីមោក
ទើបខ្ញុំភ្លាក់ ស្តាយកុសល ទៅជាយ៉ាំ ។
– ទេវីដក! អ្នកកុំយំ ខំកាត់ទៅ
បើតាមត្រូវ យើងធ្វើអ្វី ពោះតូចធំ
តែងមានខុស តែងមានត្រូវ មានមិនសម
ចុះរយើងកុំ ទាំងគ្នាឲ្យ បុណ្យខ្ញុំឯង ។
អង្គតិ ព្រះមហាពជ លុះទ្រង់ត្រាស់
បញ្ជាក់ឲ្យស់ ឲ្យទេវីដក ដឹងសព្វគត

---

១ អាន ទេជោសុចំ តាមសំនៀងថៃ ។

ព្រះគ្រូធំបែរ រេទ្រះតគ្រូ ដាក់បន្ទាប
ព្រះកាយកប ថ្វាយបង្គំ លោកគ្រូគុណា ។
លាចេញទៅ គាន់លំនៅ កំឆ្ងែប្រាសាទ
ប្រសើរស្អាត រៃមានចន្លុះ[1] តើតដោយបុណ្យ
ហើយតម្រូវ ខ្លួរគាមាត្យ ឈ្មោះដូចមុន
ឲ្យទទួល ទ្រព្រែកភូន ការផែនដី ៖
នៃអស់លោក ចាំឆ៍ ៣ នាក់ ឥឡូវនេះ
ខ្ញុំបានរិះ គិតសម្រាក លាកចេញទៅ
ឈប់ទទួល មើលទុំសត្រូវ ខ្លួរតឹតដី
នេះដើម្បី ប្រយោជន៍ឲ្យ បានក្តីសុខ ។
ប្តេះសូមលោក យោគយល់ខ្ញុំ កុំប្រកែក
សូមរំលែក ចែកការគ្នា កាន់ដោយមុខ
រក្សាពស្ត្រ ទាសកម្មករ កុំឲ្យខុក្ខ
រក្សាស្រុក ជាតិប្រទេស ឲ្យមាំមាំ ។
ប្រគល់ស្រែច ស្តេចបញ្ជា អស់ក្រុមភ្លេង
ឲ្យមកលេង តូរ្យតន្ត្រី ស្រីប្រឹងរាំ
លុះខ្លឹតត្រែក មានតម្រែក ក្នុងតាមមាំ
ខ្លឹកន្ទាំ នារីស្រស់ មកសេពសន្ថវ ។

---

១ ឈ្មោះប្រាសាទ ។

ទ្រង់សប្បាយ មិនដឹងណាយ ទឹងសម្ផស្ស
ស្រីទាំងអស់ មានសម្រស់ ល្អដេកតន់
នាំឲ្យទ្រង់ លង់ព្រះទ័យ លែងគិតគណ
ពីព្រះជន្ម ដែលមិនធន់ ជាកោតៈ ។

ស្តេរឿងខេះ បែរទៅពោល ពីធីតា
នាមវុឌា រូបសោភា ល្អមានជោគ
ជាបុត្រី នៃអង្គតិ ក្សត្រមានកោត
ស្រីក្នុងលោក យកមកផ្ទឹម ត្រឹមតុំបាន ។
នាងវុឌា មានប្រាជ្ញា ថ្លាជ្រាលជ្រៅ
យល់ខុសត្រូវ ផ្លូវធម៌អាថ ទាំងប៉ុន្មាន
នាងក្មេងពិត តែគំនិត ដ៏ក្លាហាន
បេះឲ្យគាន ហ៊ានកាន់សីល ទេជាសៈ ។
នៅថ្ងៃមួយ ដែលជាថ្ងៃ ឱដប់បួន
នាងរៀបខ្លួន ស្អិតស្អាងអង្គ ខ្ចង់ល្អផ្កុត
រួចនាំស្រី ជាបរិពារ ទៅលំអុត
គាល់កជម្ពុ ជាបិតា នៃព្រះនាង ។

ព្រះរាជា គ្រាទតឃើញ កដបុត្រី
មានក្មេងស្រី ជាបរិវារ ហែសន្ធឹកនាង

មើលទៅហាក់ ខេតអប្សរ ស្អប្រិយភេទ
ទើបត្រាស់ភ្ញាន សួរទៅកើ៖ ទៅធីតា៖
ឧកូនស្រី តែវតិស៊ី មាសនត្តុក!
នាងថានសុខ គ្មានក្តីទុក្ខ ប្តូយ៉ាន់ណា
នាងទៅលេង ឯស្រះស្រស់ ពីតរងថ្ងា
កល់ទ្រឹក តុំដែលខាន ខេប្តអ្វី ?
រូបតក្កតា ដូចរូបភ្ញា ប្តូរូបគោ
រូបសិង្ហគោ សេះក្របី រូបដំរី
នៅតែមាន គេធ្វើឲ្យ ខេប្តអ្វី ?
ចូរកូនស្រី ច្រាប់បិតា ឲ្យដឹងពំ ?
កម្រងផ្កា ចាប់មាលា រូបគ្រឹះស្ថាន
មាសកល្បាណ មានគ្រាន់លេង ឬ ធីតា!
ចុះមកនេះ តើកូនស្រី មានច្រាថ្នា
របស់អ្វី ឥហ្វូងចាំ ថាមកស្ងួន ?
នាងរុញ លើកហត្ថា បង្គំថ្វាយ
ចំពោះអង្គ ព្រះបិតា គុណធំជួន
ក្រាបទូលតប សម្រេចតាម រឿងក្នុងខ្លួន
ថ្វាយសេចក្តី លៃសំនួន ដូចច្នេះថា៖

ទុបិតា មហាគុណ ដ៏ធ្ងន់ក្រៃ ។
កូនសត្វថ្លៃ ថ្នាខ្លួន ក្តីសុខា
កូនខ្លៅលេង ឯស្រះស្រង់ ទឹករងថ្លា
ភាល់ទឹក ជាប្រក្រតី ពុំដែលខាន ។
រូបតក្កតា ផ្តាំតម្រង់ កូនមាលា
ដោយតេជះ ព្រះពជា ទ្រង់ប្រទាន
អ្នកបំរើ នៅតែផ្ទៃ ឲ្យតុំខាន
ខ្ញុំម្ចាស់ថ្នាន ថាត់ឥឡូក វិតក្កហ្មង ។
ដែលខ្ញុំម្ចាស់ មកតាលៃនេះ ដោយគ្រាថ្នា
ខ្មីឆ្មីសុំគ្រាក់ តាហ្លួងថ្នាំ មួយពាន់ហោង
ដើម្បីចែក ឲ្យជាខាន ដល់អ្នកផង
ដែលខ្វិលក្រ ដ៏កន្ទួង ណាព្រះអង្គ ! ។
ហើយថ្ងៃស្អែក ខ្ញុំជាថ្ងៃ ចំជប់គ្រាំ
តាមចំណាំ ត្រូវខ្ញុំម្ចាស់ ខះខ្ជង់
ខ្លួលស័ល រក្សាជិត្ត ឲ្យជួរធង់
ឲ្យខ្លួនត្រង់ តម្រង់តៅ កុងផ្លូវធម៌ ។
ព្រះពជា ទ្រង់សណ្តាប់ សត្វសន្ទៃយ៍
នៃបុត្រី ស្រីសម្លាញ់ គេញាទខ្ញុ

ទ្រង់មិនសព្វ ព្រះហឫទ័យ ដោយឮស្មោះសរ
ទើបភូធរ មានបន្ទូល តបមុត្រីៈ
ឧប្បា ធីតាកូន! នាងកុំកុំ
កុំខ្លាំង ធ្វើបុណ្យទាន ប្រយោជន៍អ្វី
ឈប់បំផ្លាញ ទ្រាក់ទុក ទៅកូនស្រី!
ឈប់ឃ្នាតខ្លី ស្មាតនស័ល ទៅណាកូន! ។
លោកត្រគុណ, លោកអលាត, រីឆកៈ
ជានយល់ជាក់ ថាផលកម្ម តឹសោះសូន្យ
ដោយគេអាង មានព័ស្តុតាង យ៉ាងសមសួន
ដូចេះកូន ដឿតេទៅ ទៅតុំជា! ។
លោកអលាត ជានដឹងជាតិ អំពីមុន
ជាជាតិកុន ដុនដាបអាប់ យ៉ាប់វេទនា
សម្លាប់គោ ចិញ្ចឹមទ្រាណ ជានសុខ
លុះមរណា មកកើតជា អលាតឯង ។
រីឆកៈ កំដឹងជាតិ កុងតភមុន
ជានាយខុន ជ័មានបុណ្យ ធនធានខ្លាំង
ជាអ្នកលះ ឈ្នះកំណាញ់ ទ្រព្យផងឯង
អាចចែកចែង ឲ្យជាទាន គ្មានស្តាយទេ ។

សុះសែងជាតិ រកតមក យកកតថ្មី
ប្រែជាតី ជាទាស: អ្នកខ្ញុំគេ
ដូនតីនេះ សឹងមានកម្ម ដែលជាមេ
កូនឃើញទេ តិតជាកម្ម គ្មានឡើយ ។
កុមារី ស្រីរុបា ប្រុងជាវៃ
ឃាតក្នុងយ ព្រះតម្រាស់ ខ្លះយោបល់
ទើបព្រះនាង គ្រាស់តបភ្លាង ដោយក្តីឈឺ
ទ្បែចមតាស យល់ឃើញត្រូវ ផ្លូវសាសនា ៖
បតិត្រព្រះ កដបិតា មានគុណធំ !
តើដើមខ្ញុំ គ្រាន់តែឮ គេស្តីថា
តម្រាវនេះ ឃាតឃើញច្បាស់ ទីឯនេគ្រា
សមដូចជា សុភាសិត តិតមិត្តចត់ ៖
ជនណាគប់ កប់ជនពាល ដែលល្ងង់ខ្លៅ
ទីឯគ្មាយគៅ ឃាតណា ជាក់ច្បាកដ
អ្នកណាគប់ ជនវាឆ្លួង ខ្លែងខ្ទុសបង
ទីឯលត់ ស្មាតើឈឺន ដែលស៊ុនស៊ុន ។
ព្រះបិតា មានពាសនា ជាស្តេចធំ
មិនគួរសម សម្លាប់ភ្លឺ ពាក្យត្រូវគុណា

លោកគ្រូនេះ មានចំណេះ ច្រើនជាជុំទ
ដោយស្មែងបុណ្យ ទើបតាំងខ្លួន ជាអ្នកច្រើនជ្រុ ។
កាលគ្រូនេះ តោលថាកម្ម គ្មានឲ្យផល
ទ្រង់គួរទ្វេល ផ្តល់សួរភៀ ដោយអធំអាច
ថាតួកមនុស្ស ទុំសាផ្សេងគ្នា ដោយស្មងច្រើនជ្រុ
តើអំណាច របស់អ្វី នៃឲ្យផ្សេង ? ។
ដូចកូនស្តេច ប្រសូតតា ១ នាមួយ
ខ្លះឥតព្រួយ មានច្រើនជា ថ្វាយលំឈ្មួន
ខ្លះលង់លិត ច្រើនជាអន់ ខន់ក្រៃលែង
ខ្លះខែងរែង ជាខេសាយកជ្រុ អំណាចតែង ។
ខ្លះតឹងរ៉ឹង អង្គុយនឹងដំ ពិភពណើត
ខ្លះក្អែកស្មើត ក្អែកងងឹតឆ្អឹត ដិតសូន្យឈឹង
ខ្លះកើតមក ឥតពិការ កាយសក្តិង
ការផ្សេងហ្នឹង គួរចង់ដឹង តើព្រោះអ្វី ?
សត្វផ្សេងគ្នា តិតតីជា ដោយសារកម្ម
កម្មតែងចាំ ទាំងបែរ ប្រែប្រក្រតី
កម្មជាតួដ ដូចដៅតង្ស មិត្រភ្លាប្រិយ
កម្មការត់ក្រៃ នៃសត្វទ្រី អាក្រក់ឬ ។

កម្មនាំសត្វ ឲ្យច្រាជ្រលង់ អង្គតមគាក់
ឲ្យខ្វិនខ្វាក់ ក្អែកងងឹត ឃ្លង់ឆ្អឹត
តិរ៌ណៈត្រេច តែម្ដង កំមានមក
ដួនកាលល លបឲ្យផល ដល់ខ្លួនចាស់ ។
ចុំក្លួនស្រី មានក្តីឆ្ងល់ ឧឹងគ្រគុណ
ដែលថាបុណ្យ តាំងថាធ្លាប គ្មានផលច្បាស់
ចុះហេតុអ្វី ថ្វីលោកបួស ទំប្រឹងណាស់
ការណ៍នេះច្បាស់ ពិតជាជាន់ ដើងខ្លួនឯង ។
ព្រោះការបួស ប្រតិបត្តិ កាត់កិលេស
ឲ្យវិលេស បរិសុទ្ធ ផុតគ្រឿងស្មែង
កិច្ចតាំងនេះ ចាត់ចប់ថា កម្មនោះឯង
បើផលស្អែង ឥតមានខេ ម្ដេចក៏បួស ។
មួយទៀតថា តាន់ស៊ីលា ឥតឲ្យផល
ការដែលឃាត់ ចៃបយាំងនេះ គឺឃាត់ជ្រួស
ដ្បិតតាន់ស៊ីល ជាគុណមួយ ដួងដុំលដួស
ឲ្យតួសត្វ ចៃបួស នារោកិយ ។
ដូចឲ្យតាន ចុំកជាស្ពាន ចង់ឆ្លាប់ម៉ត្រ
ឲ្យមានចិត្ត ភប់រកគ្នា ជាមេត្រី

បើខ្វះទាន គ្មានការឲ្យ តើជាទន្ទឹ
ឲ្យមានក្តី ស្និទ្ធស្នេហា អស្ចារ្យ ។
ម្ដេះសមប្រុត ហ៊ានតយុទ្ធ ទីធម៌ម៉ែ
ពស្ត្រខ្លួនៅ លែងគោរព ព្រះពាជា
ពួកនិស្សិត លែងកោតខ្លាច គ្រូអាចារ
ចាំងតែយោ លែងជឿស្តាប់ គោរពប្តី ។
ការឲ្យទាន មានតម្រៃ ទៅជាតម្មុ
ឲ្យរួចខ្លួន ធុកវេទនា ទ័លក្រក្រី
បើមានគ្រោះ គ្រោះកំហុស គេប្រណី
មានតក្តី មេត្រីដួយ ឲ្យទោសយ៉ាត ។
ចំណែកសីល ជាគុណមួយ ដួយលំអ
ឲ្យចិត្តស ល្អស្អាតស្អំ សមមនុស្សជាតិ
ពួកមនុស្សយើង បើគ្មានសីល ដូចគេស្រាត
ឬខ្លួចជាតុ ជាតិកែល រៀបដួងចៃ ។
ទៅជាមនុស្ស ហ៊ានលួចលាក់ ចាត់សម្លាប់
ហ៊ានកំណាប់ ចាប់ប្រវន្ត ជនជាទៃ
ក្លាយជាមនុស្ស មានទោសខ្លាំ ធ្ងន់ធំក្រៃ
ជនជាទៃ ខ្ពើមរៀយ ដូចគម្រេះ ។

ការគាន់ស័ល ដ្ឋិលមន្ទិល កុងសន្តាន
អាចគាញ្ជ្រាន ទុក្ខគោសពៃរ៍ ភ័យឰនឡង់
ឲ្យឃ្លាតចេញ ដេញឲ្យឆ្ងាយ ចាករូបអង្គ
ឲ្យតម្រង់ កុងក្តីសុខ នៅលោកិយ ។
កុងបរលោក សិលកំយោគ ដួយប្រសិទ្ធ
ឲ្យដួងចិត្ត ដួងវិញ្ញាណ មានសួស្តី
ធ្វើដំណើរ ដើរទៅកាន់ កពជាថ្មី
ដោយសិរី ជ័យមង្គល សុខក្រៃលែង ។
ម្ភាយឪពុក គ្រូគុណទុក ថាគ្មានគុណ
កិច្ចការុណ្យ(១) មកលើកូន ដោយជាក់ស្តែង
ជាការៈ លើមែនទែ ត្រូវប្រឹងប្រែង
ថែកូនឯង ឲ្យរស់កន មានសុខសាន្ត ។
ចុះការៈ អ្នកជាកូន តើយ៉ាងណា
ម្តេចមិនថា តាមដំនង ពង្សដើមដាន
ត្រូវដ្ឋិម្តេច ចំពោះលោក ជាកល្យាណ
ម្តេចកិហាន ថាមិនជាប់ គុណលោក ។

---

១ ការុណ្យ ជាភាសាស្រ្តឹត ជាលិខិត ការុណា ជានន័យថា សេចក្តីការុណា, ក៏អាណិត, អាសូរ ។

លោកធ្វើមុន[1] គេសង្គតុណ[2] នេះគារៈ

នៃនរៈ អ្នកមានជាមិ ល្អមានៈជាន

ជួបមែ៎ត្រូវមុខកូន សង្គតុណាលោក

តាមប្រយោគ ដែលលោកធ្វើ មកលើយើង ។

កាលដែលកូន នៅខន់ខ្ចី រ័យនៅក្មេង

មែ៎ឥតែង មានគារៈ ថ្នាក់ថ្នមសួន

ដល់ឥមែ៎ ប្រែចាស់ជោរ គោរខន់ខួន

គារៈកូន ត្រូវថែជួន ចិញ្ចឹមវិញ ។

ប្រពៃណី នៃមនុស្សយើង គ្រប់ជាន់ថ្នាក់

តែងជាប់ធ្នាក់ ភាក់ខង្គា ជាប្រដេញ

ជួចសិស្សគ្រូ គួនឹងគ្នា ត្រូវបំពេញ

គារៈវិញ តាមនាទី ទៅវគ្គា ។

គារៈគ្រូ ត្រូវប្រឹតប្រៀន បង្រៀនសិស្ស

ឲ្យប្រតិស្ឋ តំកល់ខួន សួនវិជ្ជា

គារៈសិស្ស ត្រូវជ្រើស្តាប់ ឆ្លាប់គារៈ

ត្រូវវៃខ្នា ធ្វើជួចគ្នា នឹងមែ៎ឥ ។

---

១ បុត្តការីបុគ្គល ។ ២ កតញ្ញូកតវេទីបុគ្គល ។

(នៅមានត)

ខ្លឹកអក្សរសាស្ត្រ

ការអានពាក្យវប្បធម៌

លោក ឆួច - កឹងឡេង

សាស្ត្រាចារ្យនៅគុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ រៀបរៀង

ពាក្យវប្បធម៌ គឺជាពាក្យដែលប្រកបដោយអត្ថប្រយោជន៍ ហើយសំខាន់យ៉ាងក្រៃលែងធង់ ក្នុងបច្ចុប្បន្នកាលនេះ សម្រាប់យុវជនខ្មែរព្រោះជាពាក្យ ដែលគណៈកម្មការខាងបកប្រែតាមផ្លូវការ សុទ្ធតែបានអនុម័តជាឯកច្ឆន្ទថា យកជាការបាន ។ ពាក្យវប្បធម៌ទាំងនោះ ច្រើនតែប្រែចេញមកពីអារ្យកាសា គឺភាសាបាលីនឹងសំស្ក្រឹតដែលជាភាសាបរទេស ដូចជាភាសាបាក់ឯ ឧទាហរណ៍គ្រូស (ល) ក្លាយចេញមកពីភាសាឡាតាំង ឧទាហរណ៍ដែលជាភាសាបរទេសដូច្នោះដែរ ។ ប៉ុន្តែបើគ្រាន់តែគណៈកម្មការវប្បធម៌បានបកប្រែពុំគង្សៃយើងប្រើប្រាស់ ហើយយើងមិនចេះប្រើប្រាស់ឱ្យបានត្រឹមត្រូវ ក៏ឈ្មោះថា យើងដែលជាអ្នកខ្វះប្រើប្រាស់តុំគាង់បានបំពេញភារកិច្ចរបស់ខ្លួនទៅវិញដែរ ប្រៀបបានដឹងបុគ្គលដែលគេឱ្យគ្រឿងសំលៀកបំពាក់ហើយ មិនចេះយកទៅស្លៀកពាក់តុបតែងកាយ ។

ពិតមែនណាស់ ក្រុមបញ្ហាវិន្តក៏ អប្បញ្ហាវិន្តក៏ នាបច្ចុប្បន្នកាលនេះ ច្រើនតែភ្លេចសូត្រ ក្នុងការអានភាសាជាតិឱ្យត្រឹមត្រូវ ព្រោះគេយល់ថា ភាសាជាតិយើង បើពុំសូត្រក៏មិនជាការអ្វី ។ បើអានភាសាចាក់ដុំពុំសូវតែបន្តិចបន្តួចទៅវិញនោះ គេនិន្ទាភ្លាមខ្លួន ហើយឡាសដូចតន្ត្រីលស៍ចឹង ។ សូមមិត្តចាំឱ្យកុំភ្លេចនូវមេរៀនសុភាសិតថា " សំដីសុជាតិ មារយាទ-សព្វជ្រុ " ឡើយ ។

ការអានភាសាខ្មែរ ដោយតាំងសេសគឺភាសាប្លែងមិនមែនពុំសូវគ្នានឹងការអានភាសាបរទេសប៉ុន្មានដែរទេ ។ ពាក្យដែលប្រែចេញមកពីភាសាចាលី ត្រូវតែអនុវត្តសូរសៀងឱ្យទៅតាមក្បួនភាសាចាលី វៀរលែងតែមានពាក្យខ្លះ ដែលវាលាយទៅជាពាក្យខ្មែរយើងសុទ្ធសាធទៅហើយ ។ រីឯពាក្យដែលត្រូវអានទៅតាមវេយ្យាករណ៍ភាសាចាលីនោះ ខ្ញុំនឹងពន្យល់ដោយសង្ខេបដូចតទៅនេះ ៖

អក្សរខ្មែរចាំង ៣៦ តួ គេចែកចេញទៅជា ២ ក្រុមគឺ ៖

ក្រុមទី ១

១-	អក្សរ ៥ តួ	គឺ:	កខគឃង	ហៅថា ក្រុម ក (ក វគ្គ:)
២-	-		ចឆជឈញ	- - ច (ច វគ្គ:)
៣-	-		ដឋឌឍណ	- - ដ (ដ វគ្គ:)

៨- អក្សរ៥តួគឺ: ឋ ឍ ឌ ធ ន ហៅថា ក្រុម ត (ត វគ្គ:)

៩- " បផ ព ភ ម - - ប (ប វគ្គ:)

ក្រុមទី ២

អក្សរ ៧ តួគឺ: យ រ ល វ ស ហ ឪ ហៅថា ក្រុមសេស (សេសវគ្គ) ;

កន្ទបណ្តាអក្សរតាំង ២ ក្រុមនេះអក្សរទី ១ ទី ២ នៃវគ្គតាំង ៥ គឺ: ក ខ, ច ឆ, ដ ឋ ត ថ, ន ប ផ ន ទី ៥ នៃសេសវគ្គគឺ: ស. អក្សរតាំង ១១ តួនេះហៅថា "អឃោស:" (soft letters) ប្រែថា អក្សរមានសម្លេងខ្ទប់ស្រាលឬក៏មិនគឹកកង៏ក៏បាន ។ អក្សរទី ៣, ទី ៤ នឹងទី ៥ នៃវគ្គតាំង ៥ គឺ គ ឃ ង, ជ ឈ ញ, ឌ ឍ ណ, ទ ធ ន, ព ភ ម នឹង អក្សរ ៦ តួគឺ: យ រ ល វ ហ ឪ តាំង ២១ តួនេះ ហៅថា "ឃោស:" (hard letters) ប្រែថា អក្សរមានសម្លេងធ្ងន់ឬរឹងឬក៏គឹកកង៏ក៏បាន ។ រីឯ អក្សរ ៥ តួគឺ: ង, ញ, ណ, ន នឹងម នៃវគ្គតាំង ៥ នឹងអក្សរ ៤ តួគឺ: យ រ ល ឪ នឹង វ នៃសេសវគ្គ- តាំង ៩ តួនេះហៅថា "អព្យាគតតនូ:" ប្រែថា អក្សរមានសម្លេងជាអព្យាក្រឹត ។ ហេតុដូចម្តេចបានជាថាអក្សរតាំងនេះមានសម្លេងជាអព្យាក្រឹត? ។ បានជាថាមានសម្លេងជាអព្យាក្រឹត ព័ត្រោះ

អក្សរទាំងនេះ អាចអានុវត្តសូរសៀងរបស់ខ្លួន ឲ្យនៅជួនដាំរយៈដូច ប្រក្រតីដើមក៏បាន ឲ្យខំប្រឹស្រាលទៅជាអរយៈទៅវិញក៏បាន ស្រេច តែនឹងការបើតនៅនៃអក្សរ ។ តាមក្បួនធម្មតាអក្សរទាំង ៩ តួនេះកប់ចូល ក្នុងពួកយោស:(សម្ងួនជួន)ទេ តែក៏អាចឆ្លុះទៅជាអរយៈវិញបាន កាលបើពាក់ទៅបិតនៅបន្ទាប់នឹងអក្សរជាអរយៈណាមួយ, បានសេចក្តី ថា អក្សរជាអរយៈទាំង ១១ តួនោះ អាចតាប់អក្សរជាអត្ថាគតតួរ: ទាំង ៩ តួនេះ ឲ្យបាត់សម្ងួនទៅតាមក្បួនបានគឺ:

អក្សរ	ឯ	ទៅជាឆ្លុះ	ឯ
–	ញ	–	ញ៉
–	ណ	–	ណ៉(១)
–	ន	–	ន៉
–	ម	–	ម៉
–	យ	–	យ៉
–	រ	–	រ៉
–	ល	–	ល៉
–	វ	–	វ៉

(១) ទៅជា ណ ដដែល ។

ទាហរណ៍ខាងក្រោមនេះ ខ្ញុំបានញាំងមិត្តអ្នកអានចាំងឡាយ ឲ្យយល់ច្បាស់ខ្លះតាមអាន:.

ទុស្សន្ធា (ល)

ពាក្យថា ទុស្សន្ធា មានពីរអក្សរគឺ: អក្សរ ទុ ជាអោស:, អក្សរ ស្ស (ស្សុ) ជាអោស:ខ្ងន់អក្សរ ន្ធា ជាអព្យាកតក្ខរ: ។ អក្សរ ន្ធា ដែលជាអព្យាកតក្ខរ:បិតនៅបន្ទាប់ខ្ងន់អក្សរ ស្ស ដែលជាអោស: ។ ហេតុដូច្នេះ អក្សរ ន្ធា ត្រូវតែបញ្ចេញសូរសៀងថា ន្ធា ទៅវិញ ។ ពាក្យថា ម្ភកំរ៉ា មានពីរអក្សរគឺ: អក្សរ ម្ភ ជាអោស:, អក្សរ កំ ជាអោស: ខ្ងន់អក្សរ រ៉ា ជាអព្យាកតក្ខរ: ។ អក្សរ រ៉ា ត្រូវតែបញ្ចេញសូរសៀងថា រ៉ា ទៅវិញ ដោយហេតុថា ខ្លួនបានទៅនៅអាស្រ័យនៃបន្ទាប់ខ្ងន់អក្សរ កំ ដែលជាអោស: ។ ពាក្យថា ប្បល្ហា មានពីរអក្សរគឺ: អក្សរ ប្ប អក្សរ ល្ហ ខ្ងន់អក្សរ ន្ធា ។ អក្សរ ប្ប សន្ធ័ត់សូរ ល្ហ ឲ្យទៅជា ល្ប៉, អក្សរ ល្ប៉ សន្ធ័ត់សូរ ន្ធា ឲ្យទៅជា ន្ធ៉, ពាក្យនេះទៅជាអានថា:(ប៉:ល្ប៉:ន្ធ៉) ។ ពាក្យថា អ្នតិប្បរមា មានបីអក្សរ, អក្សរ រ ទៅជា រ៉ ក្រោះខាងដិត ប្ប, កាលបើ រ ទៅជា រ៉ ហើយ អក្សរ ម្ប កំ ត្រូវទៅជា ម្ប៉ ដែរ ។ រីឯពាក្យថា ការិយាល័យ វិញ ដោយសំណាងអក្សរ ការ, រិ ទៅជា រ៉ិ, យា ទៅជា យ៉ា, ល័យ ទៅជា ល្ប័យ ។

ឧទាហរណ៍បន្ថែម

វិសេសនា	សមាធិ
ទេសនា	គុណ
ឧបមា	ទេសុត្តរាធ្តិ
កញ្ញា	អប្បមេយ្យ
សាលា	បណ្ណាល័យ

ពាក្យថា "អនុស្សរិយ" ។ល។ ត្រូវតែអានឲ្យឮថា . . រ៉ី (កុំថា រ៊ឺ) ព្រោះជាអញ្ញត្រសព្ទ (exception) ។

ស្រៈតាំង ៨ តួគឺ: អ, អា, ឥ, ឦ, ឧ, ឩ, ឯ, ឱ, ក៏ជាអោសៈដែលអាចតាញសម្លេងអក្សរជាអត្ថាកតក្ខរៈ ឲ្យផ្តុះទៅតាមខ្លួនបានដែរ។

ឧទាហរណ៍:

អនាគត អានថា អៈ- នា- គ៉ត់- ។ល។

កាលបើអត្ថាកតក្ខរៈនោះឯង ទៅបិតទៅបន្ទាប់នឹងអក្សរជាអោសៈ សូរសៀងរបស់វាត្រូវតែដើរតាមសូរអក្សរជាអោសៈ ។ ឧទាហរណ៍ខាងក្រោមនេះ នឹងធ្វើអ្នកអានឲ្យច្បាស់នូវចក្តីសង្ស័យៈ

សង្ខ្ជា (ល)

ពាក្យថា សង្ខ្ជា មាន ៣ អក្សរគឺ: អក្សរ ស, អក្សរ ខ្ជ (ខ្ជ) ខ័ណ្ឌ អក្សរ ជា ។ អក្សរ ជា ដែលនៅបន្ទាប់ខ័ណ្ឌ ខ្ជ ដែលជាឃោស: ត្រូវ មានសិទ្ធិក្សាសម្លេងរបស់ខ្លួនឲ្យនៅជា ជា ដូចប្រក្រតីដើមវិញបាន ។ ពាក្យថា ផ្ញើជា មាន ៣ អក្សរ, អក្សរ ជា នៅជា ជា ដដែល ។ ពាក្យ ថា គិមជាគិមន៍ មាន ៤ អក្សរ, អក្សរ ជា (អព្យាកតកន្លះ) ដែលបិតនៅ បន្ទាប់អក្សរ ម្ជ ដែលជាឃោសៈនោះ ឥតត្រូវគេបង្ខំឲ្យផ្លាស់ស្ទួរសៀងទេ តែនៅជា ជា ដដែល ។ ពាក្យថា គណាជា មាន ៣ អក្សរ, អក្សរ គ ធ្វើស្ទួរ ណា ឲ្យក្លាយជាស្ទួរ ធ រឹង ជា នៅជា ជា ដដែល ។

សេចក្តីពន្យល់អំពីការអានពាក្យប្រកបមិ គឺពាក្យខ្មែរដែលជាប់ពាក់-ខ័ណ្ឌដោយភាសាបាលី ដូចបានអធិប្បាយដោយសង្ខេបមកខាងលើនេះ ប្រាកដជាខ័ណ្ឌផ្តល់ខ្លួនពន្លឺដល់មិត្រយើងអ្នកស្នេហាអក្សរសាស្ត្រជាតិ បានខ្លះតុំខានខ្លះឡើយ ។ អ្នកសរសេរដើងឮសាស់ថា សេចក្តីពន្យល់នេះ តុំគាន់សព្វគ្រប់នៅឡើយទេ ប៉ុន្តែ សូមមេត្តាជ្រាបថា "មានគ្រាន់ បើជាងគ្មាន" ។

ពាក្យខ្មែរប្រែចេញពីបារាំង

ដោយគណៈកម្មការវិប្បធម៌

(តមក)

Civilité	*n.f.*	សេចក្តីថ្លៃថ្នូរសម
Méningite cérébro-Spinale		រោគខួរក្បាល, ឆ្អឹងខ្នង
Poliomyélite	*n.f.*	គ្រុនស្វាប់អវយវៈ
Trypanosomiase	*n.f.*	រោគងងុយ
Piroplasmose Aiguë		ពីរ៉ូប្លាស្មូស
Alastrim		អាឡាស្ត្រាំ(អុតធំនៅប្រទេសអាហ្វ្រិក)
Coqueluche	*n.m.*	ប្លាកមាន់
Grippe-influenza		គ្រុនផ្តាសាយធ្ងន់
Pneumonie	*n.f.*	គ្រុនរោគសួត
Broncho pneumonie	*n.f.*	គ្រុនរោគខាងក្នុងបំពង់សួត
Erésypèle	*n.f.*	ពិសស្បែក
Congestion	*n.f.*	រោគស្វាក់ឈាម
Accord à l'amiable		កិច្ចព្រមព្រៀងដោយស្រុះស្រួល
Afférent	*adj.*	បង្ហូរភាព
Argenterie	*n.f.*	ជើងកណ្តា
Aggravation	*n.f.*	ការធ្ងន់ធ្ងរ. (ការធ្វើឲ្យធ្ងន់)
Bijoux	*n.m.*	អលង្ការ
Bijouterie	*n.f.*	អលង្ការភណ្ឌ, អលង្ការផ្ទះ
Bijoutier	*n.m.*	ជាងទង, សុវណ្ណការ

(នៅមានត)

វិបត្តានុក្រមសំស្ក្រឹត-ខ្មែរ

ព្រះមហា ចាំន . ខាត់ រៀបរៀង

(តមក)

អតីវិទ្ធ គុ. ចោលក្រៃលែង, ចោលសរសើរ ។

អតីវិនិឯ នបុ. ការយោប្រព្រឹត្តទៅក្រៃលែង, ការយោរូបថាកាទាស ។

អតីវិនិឯិ គុ. ដែលប្រព្រឹត្តទៅក្រៃលែង, ដែលឆ្នងរួច ។

អតីវិត្តរ្យ គុ. ដែលគប្បីរៀបចំ ។

អតីវិទ្រ, អតីវិទ្រណ នបុ. ការយោភ្លៀងក្រៃលែង ។

អតីវិល្លភ គុ. ដែលជាទីស្រឡាញ់ក្រៃលែង, ដែលដំណែង, ដែលថ្លៃថ្នូ ។– ភ្ល, នបុ. ភាវនៃ . . . . ជាទីស្រឡាញ់ក្រៃលែង ។

អតីវិហ៊ គុ. តាំងទៅក្រៃលែង, ជម្ងឺ, ងឹកតាំ ។

អតីវិឍ គុ. បង់ក្រៃលែង (ខ្សល់) ។

អតីវិឍ្ឍ្យ នបុ. ភាវនៃ . . . ជាទីស្រឡាញ់ក្រៃលែង ។

អតីវិឍ ឬ. ពាក្យចោលក្រៃលែង, ពាក្យប្រទេច ។ សេះក្តីថ្នែងពាះណ៌, ពាក្យជាំចំពាត ។

អតីវិឍិឯ គុ. ដែលចោលក្រៃលែង, ដែលប្រទេច ។

(នៅមានតទៀត)

ភាគទី ៤៧

ទុតភ្លាំបុលភជរសេនា ឲ្យ-ឆ្លង ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាឃុទ្ធសាស្ត្រ
អ្នកសិក្សាវិជ្ជាសបើបានអាន
ទំនិះបេះទឃាយកលចំណាន
ទាំងមានសន្តានស្នេហាជាតិ

ឃ្ល - អ៊ុន

ខាងពីក្បើពីយើញសេចក្តីសំបុត្រទុងបេងប្លាប់ទី ៣ ហើយតាំងស៊ុនហ៊ូយិន រត់ទៅដួបទំងទុងបេងយកទុកមកទូល ដីរយើលើកទ័ពតាមហើយចូលឆ្ពងទាហាន ឡោសុកមកការស្រុកកេងដីវ ដីរយើធ្លាកលនយាយទៅរាយស្រុកសែឈួន ទុងបេងធ្លាតត្រូតកលដីរយើចាត់ទ័ពលើកទៅ ។

ខ្លៅតី ដំងសេចក្តីកងសំបុត្រនោះហើយ ក៏ត្រឡប់ទៅប្រាប់នាងស៊ុនហ៊ូយិនតាមសេចក្តីសំបុត្រនោះថា ពីដើមស៊ុនគួនទំងដីរយើតិតកលទុបាយថាទំងលើកបួនឯងទ្បើជាកំយោបង បំងទំងបញ្ជោតបងទ្បើមកឯស្រុកឡាំស៊ុ ហើយចាប់ខ្លួនបងជាក់តុត ដើបងូលស្រុកកេងដីវទ្បើវិញកាលណា ទំងប្រហារដីវិតបងចេញកាលណោះ មិនមែនទ្បើបួនដោយស្មោះត្រង់ទេ តីយកបួបួនធ្លើជាខុយទៅបញ្ជោតទ្បើបងមក, មួយទៀតបង

ដឹងច្បាស់ថា ខ្ញុំនប្អូនជាស្រីកំមែន តែមានតម្រេកច្រើនជាងបុរសទៅទៀត ចានជាបងប្រុយខ្ញុំនមកកប្អូនមិនមានភ្លាចសេចក្តីស្លាប់ នេះព្រោះមានតិងកៀវកុតឡើមានសេចក្តីមេត្តា ចានជាបងរួចពីសេចក្តីស្លាប់ ចុនកប់ប្រសព្វនឹងប្អូនរហូតមក ឥឡូវស៊ុនគួនឹងដីវយើចនៃតគិតគលៗចុយផ្សេងៗ ដោយចិត្តចងវេកឡាចារច្រើនថ្នាំនឹងធ្វើអន្តរាយដីវិតបងៗយល់ថា នៅកងស្រុកឡំស៊ុតទៅ មុខជាមិនរួចពីសេចក្តីស្លាប់ ទើបប្រញាប់គិតត្រឡប់ទៅស្រុកគេងដីវិញ ហើយក្លែងច្រាប់ប្អូនថា ស្រុកគេងដីវកើតសឹកនឹងស្រុតទៅធ្វើការសង្គ្រាមជាប្រញាប់ ប្អូនក៏មានចិត្តជាស័ត្យពិតត្រង់នឹងបងដាច់ចិត្តដិតដោយគាមមកផង ដោយស្នេហាអាល័យ គុណប្អូនដ៏ធ្ងន់ក្រាស់ក្រៃនឹងរកទីផុតគ្មានបងក៏នៅមិនទាន់ចានតបស្នងគុណសោះ, គ្រានេះ ស៊ុនគួនក៏គ្មានចិត្តសប្បុរសខុសយើងជាបងប្អូន លើកតែតាមតាក់តួនតាមមកទៀតច្រើនណាស់ ពាំនឹងដីវយើងនេះគឺឲ្យចាយមកចាំស្លាក់ពីមុខ បងនឹងធ្វើខុសក្តាប់ដីវិតយើងហើយ ឯការចាំងសងខាងនេះកំនៅកងអំណាចប្អូនបើប្អូនមិនជួយតែទៀងហើយ បងគឺត្រូវតែស្លាប់តងនឹងនេះជាប្រាកដ ដែលដីវិតបងនឹងស្លាប់បងក៏មិនអោកស្តាយប៉ុន្មាន ខ្លឹកស្តាយតែប្អូនតស្លាណា

បងមិនខាន់ចាននតបស្នងសងគុណប្អូន ដែលខៀងត្រង់សុចរិតចំពោះបង
នោះតាន់ប្រមាណណាស់ ។

នាងស៊ុនហ៊ីយិនឮដូច្នោះ គោមនស្សត្រូចចិត្តចំពោះស៊ុនតួនខ្លាំង
ណាស់ ទើបចេញវាចាថា ដែលស៊ុនតួនធ្វើគាំងម្ល៉ះ តែលះបង់អាល័យ
នៃសាច់ឈាមដែលជាបងប្អូនខឹងគ្នាអស់ហើយ ម្ល៉ះហើយនឹងត្រឡប់
ទៅមើលមុខស៊ុនតួនវិញធ្វើម្តេចបាន ការគាំងប៉ុន្មានក្នុងគ្រានេះ ខ្ញុំក៏សុំ
រិះគិតកែទៀងឲ្យត្រូចតាមអត្ថាយតាមត្រូវជាខ្ញុំចុះ នាងស៊ុនហ៊ីយិនក៏ឲ្យមនុស្ស
ប៉ះរបូងសក់ឡើងស្រឡះមុខមាត់ ហើយក៏ឡើងបរវេស្រួតទៅ យើញ
ឈើសេង, តេងហង លើកតងតាហានទៅស្លាក់តាមមុខ នាងស៊ុនហ៊ី-
យិនក៏ស្រែថាកៈ ខ្លួនតាំង ២ នាក់មកធ្វើការយ៉ាងនេះ ប្រុងនឹងប្រហារ
ជីវិតអញឬ? ឈើសេង, តេងហងឮដូច្នោះ ក៏ស្ទុះស្ទាំងកាំងកាំង
ស្មារតី លោតចុះពីលើសេះចោះអាវុធផុតពីដៃ ហើយចូលទៅគំនាប់
នាងស៊ុនហ៊ីយិនពីមុខរួចហើយថា យើងខ្ញុំនឹងបានរិះគិតដោយគំនិតឯង
ក្នុងមកធ្វើអត្ថាយអ្នកកំនៀ ដើយើប្រើយើងខ្ញុំឲ្យនាំតាហានលើកមកចាប់
ខ្លួនវិញ ។

(នៅមានត)

រឿងព្រេងជាតក

លោក ប៉ាយ.ប៊ុត្ត ប្រែរៀបរៀង

(តមក)

ជាងឈើ ក៏ចូលទៅគ្រាបបង្គំគាល់ព្រះមហាក្សត្រ ហើយបានយកសេះឈើមួយមកថ្វាយព្រះអង្គ ។

ព្រះរាជាទ្រង់មិនសប្បាយព្រះរាជហឫទ័យសោះ ដោយទ្រង់ទតទៅឃើញសេះឈើនោះហើយ ទ្រង់មានព្រះរាជឫទ្ធាវថា :

"ម្តេចក៏លោកយកសិល្បឯក្នុងមកដូច្នេះ ! ធ្វើម្តេចនឹងប្រៀបធៀបទៅនឹងត្រដែតរបៃជាងដែកបាន ! " ។

ជាងឈើក៏ក្រាបបង្គំទូលព្រះរាជាថា: "សេះឈើនេះ ប្រសើរជាងត្រដែក; សេះឈើនេះ មានកូនសោម្តុំមួយនៅលើកងកាយ ។ កូនសោមួយចាក់មួលទៅធ្វើឲ្យសេះឈើហោះ, កូនសោតិចសម្រាប់ញាំងសេះឲ្យមានល្បឿន, បើគេចាក់កូនសោទាំងអស់. សេះនោះកាន់តែហោះលឿន ។ ល. រហូតដល់សោតិចម្តុំ. សេះនោះក៏ហោះកាន់តែលឿនមែនទែនដូចជាបក្សា ។ សេះនេះ. គេអាចជិះវាហោះធ្វើដំណើរជុំវិញលោកបាន ។

គ្រានោះ ព្រះអគ្គមន្ត្រីសូមថាព្រះរាជបុត្រនៃព្រះមហាក្សត្រ ដែលទ្រង់គង់ប្រថាប់នៅជិតព្រះវរបិតាទ្រង់សព្វព្រះរាជហឫទ័យ ឱងសេះឈើនោះណាស់, ទ្រង់មានព្រះរាជបំណងចង់ធ្វើព្រះរាជដំណើរទៅលើអាកាស, ជាន់សូមព្រះរាជានុញ្ញាតព្រះវរបិតា ឲ្យទ្រង់គាំសោធន៍ទៅសេះឈើនេះ ។

ព្រះមហាក្សត្រទ្រង់មានព្រះរាជឧត្តរទៅកាន់ព្រះរាជបុត្រថា: "អ្នកណាថា សេះឈើនេះ អាចហោះទៅលើអាកាសបាន ? ហើយបើហោះទៅ សេះនោះវាត្រឡប់មកដី, តើវាយ៉ាងម្តេចទៅ ? ។

ជាងឈើក៏ក្រាបបង្គំទូលថា: " សូមទ្រង់ព្រះមេត្តាប្រោស ! សេះឈើនោះមិនត្រឡប់ទេ " ។

ព្រះអគ្គមន្ត្រី ទ្រង់មានព្រះបន្ទូលអង្វរកព្រះវរបិតាជាច្រើនលើកច្រើនគ្រា ។ ព្រះវរបិតា ក៏ទ្រង់ព្រះរាជានុញ្ញាតឲ្យព្រះរាជបុត្រសាកល្បងមើលសេះនោះតាមព្រះបំណង, ហើយទ្រង់មានព្រះរាជឧត្តរផ្តែផ្តាំថា, កូនឯងត្រូវមួលតែកូនសោមួយទេ, ហើយហោះហើរបន្តិចម្តងៗ កុំបង្ខំភ្លេក ។

ព្រះអគ្គមន្ត្រីទ្រង់ជាន់សន្យាខឹងព្រះវរបិតាថា: ខ្ញុំសូមព្រះបង្គំខឹងប្រតិបត្តិតាមព្រះរាជបញ្ជាមិនហ៊ានធ្វេសប្រហែសឡើយ, រួចទ្រង់គង់លើសេះឈើនោះយកកូនសោមួយមកចាក់ ស្រាប់តែសេះនោះហោះទៅលើអាកាស ទ្រង់ជាន់ឧត្តមកក្រាមឃើញមនុស្សក្រុងភ្នំ, វាំង, វត្តជាតិ, ទន្លេ,

ភ្នំគួច-ធំស្ថិតនៅដេរដាសពាសពេញប្រឹថពី... ។ ខ្ញុំឃើញដូច្នោះហើយ ព្រះអង្គម្ចាស់មានព្រះហឫទ័យសោមនស្សពន់ពេក, ទ្រង់មួលកូនសោមួយខ្មៅ, រួចមួលកូនសោពីបីរហូតដល់កូនសោពីម្តៃជ្រុំមួយ ។ សេះនោះកំហោះកាន់តែលឿនផ្លើង ។ បន្ទាប់មក, ទ្រង់បានខ្ញុំឃើញមនុស្សដែលយល់អម្បាញ់មិញនេះកាន់តែឆ្ងាយទៅ។ តមកខ្មៅ ទ្រង់ខ្ញុំលែងឃើញរូបភ្នំជាតិ ទឹងទីក្រុងផ្សេង ។ ទ្រង់គង់តែលើសេះហោះនោះ ពាល់តែឃ្លានព្រះស្ងោយ ស្រាប់តែខ្ញុំតមកខាងក្រោមម្តងខ្មៅឃើញទីក្រុងមួយ, បានមួលកូនសោបង្ក្រាសមកវិញ ។ សេះនោះកំបន្តយល្បឿនបន្តិចម្តង។ ហើយចុះមកដល់ដី ។ ព្រះអង្គម្ចាស់ទ្រង់ចូលទៅក្នុងគោជនីយដ្ឋានមួយដើម្បីទ្រង់សោយព្រះក្រយាទ្រង់ក៏មានព្រះហឫទ័យសោមនស្សជាយ៉ាងខ្លាំង ដោយទ្រង់ធ្វើព្រះដំណើរកន្លងគេលមួយរំពេចសោះ ស្រាប់តែមកដល់ទីនេះ ។

ព្រឹកឡើង ព្រះអង្គម្ចាស់ទ្រង់យាងទស្សនាទីក្រុង បានយាងទៅដល់កន្លែងមួយដែលមានមនុស្សមើរដេរដាស ក៏ទ្រង់ពិតល់ថា នៅទីនោះប្រហែលជាមានរបស់អ្វីប្លែកហើយ បានជាភ្លូកមហាជនដាំគ្នាចោមកេមច្រើនម្ល៉ុះ ។

(នៅមានត)

ភូមិសាស្ត្រសេដ្ឋកិច្ចនៃសហភាពអាហ្វ្រិកខាងត្បូង

លោក ប៊ុន រួមបែរត៌ អតីតសាស្ត្រាចារ្យ
នៃមហាវិទ្យាល័យច្បាប់ប្រទេសកម្ពុជា ជាន់ខ្ពស់ក្នុងឆ្នាំ ១៩៨៩-៦០
លោក ភ្លឿម-ចឹម ប្រែសម្រួល

(តបប់)

សម្បត្តិរ៉ែ : សហភាពអាហ្វ្រិកខាងត្បូង ជាប្រទេសសម្បូរទៅដោយធនធានរ៉ែជាងគេបង្អស់ក្នុងសកលលោកគឺ ៤/៣ នៃផលិតផលទៅដោយក្នុងសកលលោក ជាទេចញមកពីប្រទេសនេះ ។ អណ្តូងរ៉ែដែលចាស់ជាងគេស្ថិតនៅក្នុងផ្នែកអូរ៉ែន ជិតតំបែរឡើ ។ ទៅដែលគេយកជាងស្ថិតនៅក្នុងបំពង់នៃភ្នំភ្លើងដែលរលត់ ។ ដើម្បីនឹងជាងមាស គេត្រូវដឹកដូចជាគេដឹកយកផ្សិងដែរ ។

អណ្តូងរ៉ែទៅដែលថ្មីទៀត ទើបនឹងរកឃើញ នៅក្នុងផ្នែកត្រង់ស្វាល់ជិតទីក្រុងប្រតូរីយ៉ា ។

មានសហជីពតតួកផលិតករ ដើម្បីដំឡើងថ្លៃទំនិញ (trust) មួយជាអ្នកត្រួតត្រាលើផលិតផលទៅដែរ ហើយជាក្រុមហ៊ុនមានសិទ្ធិលក់ទៅដែរផ្តាច់មុខក្នុងសកលលោក ។

ចំពោះផលិតផលមាសវិញ កំមានសារៈសំខាន់ណាស់ដែរ គឺសហភាពអាហ្វ្រិកខាងត្បូងនេះហើយ ដែលជាប្រទេសមានមាសច្រើន

ជាងគេក្នុងសកលលោក ។ ក្នុងមួយឆ្នាំ ប្រទេសនេះយកមាសបាន
ចំនួន ៤៥០ តោន ចំនួននេះស្មើនឹង ៥០ ភាគរយ (៥០%) នៃផ-
លិតផលសកលលោក ។

អណ្តូងរ៉ែមាសដែលគេរកឃើញមុនគេ ស្ថិតនៅកងខេត្តត្រង់ស្វាល់
ជិតទីក្រុងហ្សូហាន់ណេស្ប៊ួរ ។ អណ្តូងរ៉ែមាស មានដំរៅជ្រៅណាស់
ដួនកាលដល់៧ ៣.០០០ ម៉ែត្រក៏មាន ។ ដូច្នេះឃើញថា គេស្ទារយក
អាច់ដីសម្បើមណាស់, ព្រោះកងទាបគេនដី មានមាសតែ ៥ ដល់ ២០ ក្រាម
ប៉ុណ្ណោះ ។ បន្ទាប់មក, គេយកមាសដែលគេយកចេញពីដី ទៅរំលាយ
ក្នុងរោងចក្រ ។ មានកម្មករចំនួន ៣៥០.០០០ នាក់ បានធ្វើការនៅ
ក្នុងអណ្តូងរ៉ែទាំងឆ្នាំយ ។

នៅកងសម័យមហាសង្គ្រាមសកលលោកលើកទីពីរ គេបានរក
ឃើញដុំលោហធាតុ (gisements) មាសជាច្រើនកន្លែងទៀត នៅកង
ដួអូរដំ តែចំណែកឯអណ្តូងរ៉ែ នៅកងដួត្រង់ស្វាល់នៅជាចង់អស់
មាសនៅឡើយ ។ ជាមួយនឹងមាសនេះ គេមានយកបានលោហធាតុ
មួយយ៉ាងទៀត ហៅថា អ៊ុយកាំនីញ៉ូម ដែលសហគាតអាហ្វ្រិកជាប្រ-
ទេសមួយសម្បូរលោហធាតុនេះជាងគេក្នុងសកលលោក ។ សហគាត-
អាហ្វ្រិកខាងត្បូង បានដឹកនាំអ៊ុយកាំនីញ៉ូមនេះ ទៅលក់ឯប្រទេសអង់គ្លេ
ទឹងសហរដ្ឋអាមេរិក ។

ក្រៅតែនេះ សហគ្រាសអាហ្វ្រិកខាងត្បូងជាប្រទេសលេខ ១ ក្នុងសកលលោកខាងផលិតផលជូរចាវីន ។ ជាចម្បងទៅក្នុងសហគ្រាសអាហ្វ្រិកខាងត្បូង, គេសង្កេតយើញមានលោហធាតុផ្សេង ។ ទៀតជូចជាឆ្នូតឬ (៣៦ ០០០.០០០ តោន) វែកដែក, ម៉ង់ហ្គាណែស, ក្រូម (១)

អំពីឧស្សាហកម្មសំខាន់ៗ

មកទល់នឹងសង្គ្រាមលោកលើកទីពីរ, ប្រទេសនេះមានតែឧស្សាហកម្មធ្វើគ្រឿងបរិភោគ, ប៉ុន្តែ ចាប់តាំងពីសង្គ្រាមសកលលោកលើកទីពីរលេតមក, ពេងឧស្សាហកម្មផ្សេង ។ ទៀតបានកើតឡើងជាច្រើន ។ ពេងឧស្សាហកម្មសូដែកមួយយ៉ាងធំ បានសង់នៅជិតប្រតូរីយ៉ា, ផ្តល់ដែកថែបបានក្នុងមួយឆ្នាំចំនួន ១.០០០.០០០ តោន ។ ដោយសារដែកថែបនេះ, គេក៏បានបង្កើតគ្រឿងសម្ភារៈសម្រាប់អាយស្វ័យយាន, គ្រឿងយន្តសម្រាប់ធ្វើបេកសិកម្ម, កប៉ាល់ ទឹងរថយន្ត ។

ពេងចក្រកាយនតិ្ត (Industrie textile) ក៏កើតចំរើនដែរ ។ ពេងចក្រនេះ មានធ្វើកមចៀមទឹងកប្បាស ។

ឧស្សាហកម្មគីមីក៏កើតមានដែរ ហើយបានធ្វើដី ស៊ុមីងត៍, ធ្វើថ្នាំ សម្រាប់ជ្រលក់តណ្ហា (Colorant) ។ ល ។

---

(១) ជាលោហធាតុមួយមានតណ្ហាស ពីង ព្រោះមិនចាប់ សំកប់ណាបលើផែកផ្សេង ។ ដែលយើងហៅថា ផែកក្រូមេ ។

មជ្ឈោបាយដឹកនាំនិងពាណិជ្ជកម្ម៖

សហភាពអាហ្វ្រិកខាងត្បូងមានផ្លូវរថភ្លើងយ៉ាងល្អ ហើយវែងប្រវែង ២២.០០០ គីឡូម៉ែត្រ ។ ផ្លូវរថភ្លើងច្រើនស្ថិតនៅបំពេកខាងកើតនៃប្រទេស ។ ផ្លូវថ្នល់ក៏ល្អគ្រាន់បើដែរ ហើយសហភាពអាហ្វ្រិកខាងត្បូងមានកំពង់ផែយ៉ាងល្អ ។ ឯកំពង់ផែដែលធំជាងគេ មានពីរគឺ: ឡឺកាប់ និងឌឿបង់ ។

ដំណួញក្រៅប្រទេសមានសារៈសំខាន់យ៉ាងសម្រាម តែផ្តល់ប្រាក់ចំណេញយ៉ាងច្រើនដល់ប្រទេស ។

ផលិតផលសំខាន់ ។ ដែលគេនាំចេញៗលក់នោះគឺ: មាស, អ៊ុយរ៉ាន់ញ៉ូម, គេជ្រ និងរោមចៀម ។

ក្រៅពីនេះ គេអាចរកបន្ថែមនូវផលិតផលឯទៀត ។ ដូចជា ស្រូវសាលី, ក្រូចពោធិសាត់, ស្រាទំពាំងបាយជូ ។

សហភាពអាហ្វ្រិកខាងត្បូងត្រូវការទំញផលិតផលផ្សេង ។ ចូលមកវិញមានដូចតទៅនេះ: ផលិតផលកម្មន្តសាល, ទំនិញគ្រឿងសម្ភារៈខាងបរិក្ខារ ។

គិតត្រឹមឆ្នាំ ១៩៣៩ មួយចំណែកធំនៃពាណិជ្ជកម្ម បានធ្វើជាមួយនឹងប្រទេសអង់គ្លេស ។ ប៉ុន្តែចាប់តាំងពីនោះមក, សហភាពអាហ្វ្រិកបានធ្វើដំណួញជាច្រើនជាមួយសហរដ្ឋអាមេរិកវិញ ហើយមានបំណងនឹង

ជាកន្លែងដែលតែងមានអង់គ្លេស ប៉ុន្តែនៅស្ងាត់ស្ងៀមចិត្តបន្តិច ដោយសារប្រទេសខ្លួន នៅត្រឹមតែអ្នកបង្កើតប្រទេសជាតិអង់គ្លេស នឹងដើមពុនអង់គ្លេសជាការចាំបាច់ ។

សេចក្តីសន្និដ្ឋាន៖

បញ្ហាដ៏សំខាន់ជាងគេ ដែលចោទឡើងនៅក្នុងសហភាពអាហ្វ្រិកខាងត្បូងសព្វថ្ងៃ គឺបញ្ហាមនុស្ស គឺបញ្ហាស្តីពីការប្រកាស់យកចាត់ចងគ្នារវាងពួកស្បែកសនឹងពួកស្បែកខ្មៅ ។ បើសិនជាបញ្ហានេះនៅតែចោទតទៅទៀតនោះ, មិនយូរប៉ុន្មាន, ពួកជនជាតិស្បែកខ្មៅដែលជាម្ចាស់ស្រុកតិចជាងគេ ។ ជាបន្តោញកំហឹងរបស់ខ្លួនឲ្យឃើញជាក់ស្តែងតុំខាន ។

តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

ទំនៀមទម្លាប់	នៃទេមរជាតិ
ខ្មែរគួរឱ្យឃ្លាត	សិក្សាពេញទំ ។
ព្រោះទេមរជាតិ	ជាជាតិសោភ័
ក្នុងទ្វីបអាស៊ី	ត្រាំដាប់ព្រៃងតាយ ។

ប.ព

រឿងព្រៃងត្រារត្នសុភាសិត ៤ បទ:

១- ឃ្លានទំរក់ ៣- គេឲ្យច្រើនកុំយក
២- ខ្យល់ទំរក ៤- ខ្លាចឲ្យចូលដឹត

កាលពីអតីតកាល មានរឿងមួយដំណាលថា: មានបុរសម្នាក់ អាយុ ២០ ឆ្នាំ ម្តាយឪពុករៀបចំឲ្យមានប្រពន្ធ ។ លុះរៀបអាពាហ៍ ពិពាហ៍រួចហើយ បុរសប្តីប្រពន្ធទំរកស៊ីតាមធម្មតា ។ ឪពុកម្តាយខាងប្រុស-ស្រី ចាត់ចែកទ្រព្យសម្បត្តិ ឲ្យបន្តិចបន្តួចស្លួចស្លើង ដោយខ្លួនជាមនុស្សខ្ចីខ្ចាំលក្រវែរ ។

បុរសប្តីប្រពន្ធចាយវាយក៏ខ្ជីខ្ជាតពីឪពុកម្តាយអស់ តំឡាក់ខ្លួនទៅជាមនុស្សខ្ចីខ្ចាំលក្រ រកព្រឹកខ្វះល្ងាច រកល្ងាចខ្វះព្រឹក ។ បុរសនោះ មានសេចក្តីព្រួយជាខ្លាំង ដោយការតំឡាក់ខ្លួនទៅជាមនុស្សក្រខ្សត់លំបាករវេទនាពន់ពេក ដេកគុំលក់ ។

ថ្ងៃមួយ បុរសនោះអង្គុយគិតតែម្នាក់ឯងថា "ខ្ញុំនេះ
មកពីអ្វី ? រកគិតតាំងយើញ" ។ មួយសន្ទុះក្រោយមក ក៏នឹកយើញថា
"នេះញ្រកនេះមកតាំគ្មានចំណេះវិជ្ជា អញឮសុភាសិតមួយគេនិយាយ
ថា "អ្នកណាមានចំណេះវិជ្ជា អ្នកនោះអាចប្រមូលបានទ្រព្យច្រើន
បើមានទ្រព្យច្រើនហើយ មុខជានឹងចំរើនដោយកោតសម្បត្តិ, ហេតុ
ដែលនាំឲ្យអញក្រនេះ មកពីអញគ្មានចំណេះវិជ្ជាអ្វីនៅក្នុងខ្លួនបន្តិចបន្តួច
សោះ ដូច្នេះ ត្រូវអញទៅស្វែងរកចំណេះវិជ្ជាទើបប្រសើរ បើមិនបាន
ជាអ្នកមានឈ្មោះល្បីនឹងគេ ក៏ឲ្យតែល្មមត្រប់គ្រាន់នឹងចិញ្ចឹមក្រុមញាតិ
របស់អញបានហើយ" ។ លុះគិតឃើញដូច្នេះហើយ, បុរសនោះក៏
ថ្វាយរឿងនេះ ក្រាបប្រតិទ្ធតាមដំណើរ ។ ប្រតិទ្ធបានឮប្តីក្រាបសូ
ត្រប់ហើយ មានចិត្តត្រេកអរជាខ្លាំង ក៏បើកអំណាចឲ្យស្វាមីទៅរកវៀន
ចំណេះវិជ្ជាតាមសេចក្តីត្រូវការ ។

បុរសនោះ បានទៅយាយលួងលោមប្រតិទ្ធហើយឆ្លាក់ថា "បងទៅ
រៀនតាំងយូរទេ កាលណាបងរៀនចប់ហើយ បងនឹងត្រឡប់មករកប្អូនវិញ
ចូរប្អូនបីបាច់រក្សាកូនឲ្យបានសេចក្តីសុខ បងទៅយ៉ាងយូរ ៥ ឆ្នាំ តែបើ
ហួសពី ៥ ឆ្នាំទៅ តាំងើយបងត្រឡប់មកវិញទេ ចូរប្អូនសម្លឹងមើលបុរស
ណាមួយ ល្មមប្អូនផ្ញើខ្លួនបាន ប្អូនខ្លួលយកគេធ្វើប្តីចុះ" ។ បុរស
កំសត់ លុះទៅយាយផ្តែផ្តាំប្រតិទ្ធរួចហើយ ក៏រៀបចំខ្លួនចុះដើរទៅតាយូរ

ខែ-ថ្ងៃ ជាន់ដួចនឹងអាចារ្យម្នាក់ គាំចូលទៅដាក់បស្សរដោយគោរព ។ លោកគ្រូអាចារ្យគាំខឹងលាក់ទាក់សួរថា "អើចៅ! ចៅឯងនៅស្រុកណា? ខែត្រណា ? ឈ្មោះអ្វី? មកនេះប្រាថ្នាអ្វី ?" ។ បុរសនោះដាក់បថា "ខ្ញុំបាទមកនេះ ប្រាថ្នាចង់បានតែចំណេះវិជ្ជា, បានដាំសុះស្វែងចោលប្រាន្ធក្លួនមក ដោយឮល្បីកិត្តិនាមរបស់លោកគ្រូថាចេះវិជ្ជា ទើបបានខ្ញុំបាទមកសុំរៀនចំណេះនេះ សូមលោកគ្រូមេត្តាបង្ហាត់បង្រៀនខ្ញុំបាទឲ្យបានចេះដឹងវិជ្ជានេះផងចុះ" ។ លោកគ្រូគាំខឹងលួចបង្ហាត់បុរសនោះ ។ ឯលោកគ្រូនោះ ចេះចប់ត្រៃវេទ បានបង្ហាញសិស្សមកពីគ្រប់ទិសទាំងប្រាំបី តំណត់ហៅថា អាចារ្យទិសាបាមោក្ខ ។ អាចារ្យទិសាមោក្ខបានឱយយៈទៅកាន់បុរសនោះថា "អ្នកត្រូវរៀន ៤ ឆ្នាំ ទើបបានចប់ចំណេះវិជ្ជា" ។ បុរសនោះ ហេតុតែចង់បានចំណេះវិជ្ជា គាំទ្រគោរពប្រតិបត្តិគ្រូ ពុំឲ្យលោកអាក់អន់ចិត្តអ្វីបន្តិចសោះ ។

តាំងពីចៅគាំសនោះ ចូលមកនៅជាមួយលោកគ្រូអាចារ្យនោះថ្ងៃណា លោកគ្រូពុំបានបង្ហាត់បង្ហាញវិជ្ជាអ្វីសោះ ។ បុរសនោះ ចេះតែខ្ជិល ចាំថ្ងៃដែលគ្រូបង្ហាត់ ចាំមួយខែដាំមួយខែ រហូតដល់ ៤ ឆ្នាំ គាំគិតថា "តាំងពីគ្រប់កំណាត់ ៤ ឆ្នាំហើយ គ្មានចេះអ្វីមួយមាត់សោះ តើអញនៅធ្វើអ្វី ត្រូវតែទៅរកស៊ីជំពាក់មិត្តភក្តិប្រាន្ធក្លួនវិញល្អជាង" ។ លុះគិតដូច្នេះហើយ បុរសនោះគាំចូលទៅសុំលាគ្រូត្រឡប់ទៅស្រុកវិញ ។ លោក

ត្រូវសួរថា "ឯងត្រឡប់ទៅស្រុកវិញឬ?" ។ បុរសនោះថា "ចាស! ខ្ញុំនឹងត្រឡប់ទៅស្រុកវិញថ្ងៃស្អែកនេះហើយ" គ្រូក៏ផ្តាំថា "បើឯងត្រឡប់ទៅស្រុកស្អែកនេះ ចូរឯងនេះទៅឲ្យឆ្លាប់ខ្លួនគាថា ៤ បទនេះ កុំភ្លេចឲ្យសោះ គឺ

១- ឃ្លោងចិត្តស់ ៣- កេងឲ្យច្រើនកុំយក

២- ឲ្យតែចំរក, ៤- ទ្វាទឲ្យទូលជិត

តមក លោកគ្រូអាចារ្យនិយាយបន្ថែមទៀតថា "ចូរទៅចាំកុំភ្លេចឲ្យសោះ ផ្ទាល់នេះហើយ នឹងបានសម្រេចប្រយោជន៍ជាច្រើនដ" ។ បុរសនោះគិតក្នុងចិត្តថា "នុះគ្មែអើយ! ងាយតេត", ក៏ទំភាំនៅឲ្យរួចៗ។ គ្រូបញ្ជាក់ទៀតថា "ចាំហើយឬនៅ?" ។ បុរសថា "ចាំហើយ" ។ គ្រូថា "ស្អែកឯងទៅស្រុកកំណើតឯងវិញចុះ ឲ្យបានសុខសប្បាយ" ។ បុរសមានសេចក្តីគោរមនស្សយ៉ាងខ្លាំងតែមិនចេញស្តីសោះ ដោយគិតថា "នុះគ្មែអញអើយ! មករៀន ៤ ឆ្នាំ គ្រូប្រាប់តែគាថ ៤ ម៉ាត់ ហើយថែមទាំងផ្តាំហើយផ្តាំទៀតផង" ។

ព្រឹកឡើង បុរសនោះ ក៏ចូលទៅលាលោកគ្រូត្រឡប់ទៅស្រុកកំណើតវិញ ។ លោកគ្រូឲ្យពរ ហើយផ្តាំទៀតថា "កុំភ្លេច" ។ រួចហើយ ចៅកំសត់ក៏ចំគ្រាច់ទៅតែម្នាក់ឯង កាត់ស្រុកតគ្រុកព្រៃយ៉ាងលំបាកវេទនា អស់រយៈប្រមាណជា ២០ ថ្ងៃ ពុំបានជួបប្រទះ

ស្រុកភូមិណាសោះ ម្ល៉ោះហើយបុរសនោះ ចេះតែដើរទៅមុខទៀត ដោយ
អត់អាហារ ១ ថ្ងៃ ទើបដួលក្រាសាខមួយ ដ៏ល្អវិចិត្រដោយក្បូរក្បាច់
រចនាគិតថា "ផ្ទះអ្នកណាគំហ្អម្ល៉េះ!" ។ បុរស មានចិត្តស្រេបស្រែង
ជាខ្លាំង ទំតយគន់មើលម្ចាស់ផ្ទះ គ្មានឃើញម្នាក់ឡើយ ក៏ទឹកភ្នែក
ចិត្តថា "ប្រហែលជាសាលាយក្សទេដឹង?" ។ គិតហើយ បុរសគំសត់
ប្រុងតេចចេញឲ្យឆ្ងាយ តែទឹកឃើញបណ្តាំគ្រូថា "ខ្លាចឲ្យចូលជិត" ។
ហើយបុរសនោះ លបចូលសន្សឹមៗទៅក្នុងក្រាសាទ ឃើញរបស់
ប្លែក១ នៅក្នុងបន្ទប់មួយ មានសុទ្ធតែតុតាំងល្អ ។ លើតុមានម្ហូប
ចំណីមានក្លិនឈ្ងុយឈ្ងប់ស្ទើរតែខប់ខល់ ខឹងសេចក្តីស្រេកឃ្លានពុំបាន,
គិតបរិភោគ ក៏ទឹកឃើញបណ្តាំគ្រូថា "ឃ្លានឲ្យទំអត់" ។ ដើរដូចេះ គួរ
អញបន្ថឹងចាំមើលសិន ពីព្រោះពេលនេះ ជិតដល់ពេលម្ចាស់នេមកគ.
ស្រ័យបាយផងទៅហើយ បើធ្វើរំលោភទៅ ម្ចាស់នេមកខាន តើធ្វើដូច
ម្តេច? បើដូចេះ គួរចាំមើល ក្រែងមានមនុស្សដើរមក អញនឹងសាកសួរ
ឲ្យដឹងច្បាស់ "បើគេជាម្ចាស់ អញសូមបាយបរិភោគ" ។ កំពុងតែ
គិតដូចេះ ស្រាប់តែឮសូរសន្ធឹកដូចខ្យល់ត្បុលសង្ឃរ ស្ទើរលើងសាលា
បុរសនោះភ័យណាស់ តុំដឹងជារត់ទៅតួនកន្លែងណា ក៏រត់ទន្ទឹងពេញ
បន្ទប់ សំឡឹងមើលទៅលើស្លាកឃើញនៅទំនេរ កំប្រញឹបប្រញាប់ឡើង
ទៅតួនទៅនោះ ហើយលបមើលតាមប្រហោងតូចមួយ ។ មិនយូរ

ប៉ុន្មាន ស្រាប់តែឃើញយក្សមួយមានឧត្តមសម្បើម ដើរចូលមកក្នុងសាលានោះ ហើយគ្រវត់ខ្សែមួយបង្វាយទំនងដំបងមួយទៅលើស្មាក ។ បុរសកំសត់ ឃើញដូច្នោះ ភ័យញាប់រន្ធត់ស្ទើរបាត់ស្មារតីគិតថា "នេះហើយដែលអ្នកផងហៅថាយក្ស, ខ្សែទំនងដំបងនេះ ប្រហែលជាខ្សែចងដំបងវាយឯងហើយមើលទៅ" ។ បុរសកំចាប់ខ្សែចងដំបងវាយ មកគយគន់មើលក៏ដឹងថា នេះជាខ្សែចងដំបងវាយតែម្តង ។ កាលយក្សកំពុងស៊ីបាយ, បុរសនោះគិតថា អញគិតប្រថុយប្រើខ្សែចងដំបងវាយនេះល្បងមើល មើស្លាប់ក៏ស្លាប់ទៅចុះ តែយូរបន្តិចទៀតយក្សស៊ីបាយអស់ អញបានអីស៊ី, គិតស្រេចក៏ចាប់ខ្សែទំនងដំបងទៅគ្រាប់ថា "ខ្សែចង! ដំបងវាយ!" ។ ភ្លាមនោះ, ខ្សែទំនងដំបងក៏ប្រតិបត្តិតាម បង្ក្រសោបវាយសំពងយក្សជាប់ក្រញោង ។ យក្សដាច់ចាយ ស្រែកគ្រហោយំស្ទើរដាច់ខ្យល់ស្លាប់ អង្វរគេឲ្យលែងខ្លួនថា "ទំនងដួងកំណែរឯងថែមទៀត" ។ បុរសនោះ ស្រែកគ្រាប់ទៅដំបងឲ្យឈប់វាយ ក្រាប់ខ្សែឲ្យបន្ធូរបន្ថែម ហើយចុះពីលើស្មាកទៅគម្រាមយក្សថា "តាំងតែថ្ងៃនេះតទៅ ចូរឯងកុំមកសង្កត់សង្កិនមនុស្សលោកទៀត បើគាលណា អញឃើញមកទៀត អញនឹងប្រហារដាច់តែចោលឥតត្រាប្រណី" ។ យក្សក៏ខ្លួចសច្ចា ហើយដួងកំណែរឯងថត់ជាយមួយឲ្យបុរសកំសត់ ។ ក៏ដោះយក្សលែងទៅ ។

(នៅមានត)

ផ្នែកកំណាត់ដំណឹងប្រវត្តិការណ៍

មហាសន្និបាតនៃសមាគមមិត្តពុទ្ធិកវិទ្យាល័យ

លោក ភ័យ-ប៊ុត រៀបរៀង

កាលពីថ្ងៃទី ៣១ មករា ១៩៦២ ពេលម៉ោង ៥ ល្ងាច សមាគមមិត្តពុទ្ធិកវិទ្យាល័យ បានធ្វើមហាសន្និបាត លើកទី ១៥ នៅវត្តលង្កាក្រុងភ្នំពេញ ។

បានចូលរួម- បានអញ្ជើញមករួមប្រជុំ :

ផ្នែកខាងបព្វជិត គឺ:

ព្រះតេជព្រះគុណ ព្រះធម្មលិខិត ម៉ឺង-សែស ចៅអធិការវត្តមហាមន្ត្រី ព្រះតេជព្រះគុណ ព្រះយោសធម្ម ចៅអធិការវត្តលង្កា, ព្រះមុនីកោសល ស្វាយ-ហាយ, ព្រះញាណកោសល ញ៉ាណ-ឈឺន, ព្រះមហាថ៉ាន់-ខាត់, ព្រមទាំងព្រះថេរានុត្ថេរាទាំងឡាយ រួមជាង ៧០ អង្គ ។

ផ្នែកខាងគ្រហស្ថ គឺ

លោកអ្នកតំណាងរដ្ឋសភា, ក្រុមប្រឹក្សាព្រះពុទ្ធសាសនាបក្រុ, បុគ្គលិកគ្រប់ក្រសួង ; ពួកសមាជិក-សមាជិកាក្រុមអតិថិជន, ពួកពុទ្ធមាមក. ជនទាំងបុរសទាំងស្ត្រី រួមទាំងអស់ប្រហែល ៦០ នាក់ ។

ពេលម៉ោង ១៧ លោក ភ័យ-ប៊ុត ប្រធានសមាគម បានបើក

សម័យប្រជុំមហាសន្និបាត ហើយបានថ្លែងសុន្ទរកថាមួយ រៀបរាប់អំពីលទ្ធផលនៃសមាគមក្នុងឆ្នាំ ១៩៦១ ដែលមានសេចក្តីដូចតទៅនេះ៖

សូមថ្វាយបង្គំព្រះថេរានុត្តរត្រង់ព្រះអង្គ,

សូមគោរពមហាសន្និបាត,

ខ្ញុំព្រះករុណា ខ្ញុំបាទ សូមថ្លែងនូវអំណរគុណដ៏ខ្ពង់ខ្ពស់ចំពោះព្រះថេរានុត្តរ អស់លោកជាសមាជិក សមាជិកា ឧបាសក-ឧបាសិកាដែលបានខិតខំមកកាន់ទីនេះ ដើម្បីរួបរួមប្រជុំធ្វើមហាសន្និបាត ជាគំរប់ឆ្នាំទី ១៩ នៃសមាគមមិត្តពុទ្ធិកវិទ្យាល័យ របស់យើងកល់ឆ្នាំ ។

ការប្រជុំធ្វើមហាសន្និបាតក្នុងពេលនេះ ជាមហាសន្និបាតសម្រាប់ឆ្នាំ ១៩៦២ ដែលជាប់តាមជាបវណីរៀងកល់ឆ្នាំមក ដូចជាអស់លោក-អ្នកភ្ជាប់បានដឹងរួចមកហើយ ។

ហេតុអ្វីក៏បានជាចាំធ្វើមហាសន្និបាត កំណត់ក្នុង ១ ឆ្នាំម្តងដូច្នេះ បានជាធ្វើ ព្រោះមានសារៈសំខាន់ជាការចាំបាច់ ក្នុងថ្លែងនៃសមាគម៖

ក- ដើម្បីដឹងនូវអាយុកាលនៃសមាគម,

ខ-សកម្មភាពនៃសមាគមដែលបានប្រព្រឹត្តទៅក្នុងឆ្នាំ ១៩៦១ តើបានលទ្ធផលយ៉ាងណាខ្លះ,

គ- ស្ថានភាពសេដ្ឋកិច្ចហិរញ្ញវត្ថុ ប្រាក់ចំណូល-ចំណាយនិងសំណល់,

ឃ- បោះឆ្នោតជ្រើសតាំងក្រុមអភិបាលថ្មីសម្រាប់ឆ្នាំ ១៩៦២.

ង- ការជួបជុំ សមាជិក- សមាជិកានៃសមាគម ដើម្បីពិភាក្សាប្តូរយោបល់គ្នាទៅវិញទៅមក រិះរកមធ្យោបាយរបៀបណា ធ្វើឲ្យសមាគមមានដំណើរទៅកាន់សេចក្តីចំរើនខាន់សម័យ ឥឡឹងមានសាមគ្គីរឹងរឹតតែជិតស្និទ្ធឡើង ។

អាស្រ័យដោយហេតុនេះហើយ ឋានជាថ្ងៃដែលយើងបានមកជួបជុំរួមដំនុំធ្វើមហាសន្និបាតនេះ ឥឡឹងត្រូវកត់ត្រាទុកជាថ្ងៃមួយដ៏ប្រសើរប្រកបដោយឧត្តុង្គឧប្បត្តិជាតដ៏យ នៃប្រវត្តិសមាគមមិត្តពុទ្ធិកវិទ្យាល័យ ដែលបានតាំងនៅជាប់បិតរៀបចំរកាលតាំងពីឆ្នាំ ១៩៤៨ រហូតមកទល់ឥឡឹងឆ្នាំ ១៩៦២ នេះ គឺមានអាយុ ១៤ ឆ្នាំហើយ ដោយសារតែពុទ្ធិមានមកជនមានព្រះសង្ឃខ្មែរចូលសក- ទៅសិក្សាជាដើម ដួយទទួលឧត្តម្ភគាំទ្រដោយកំលាំងសទ្ធា ឥឡឹងកំលាំងកាយ ទើបសមាគមនេះរស់នៅមានជីវិតរហូតមកទល់ឥឡឹងបច្ចុប្បន្នកាលនេះ ។

ខ្ញុំសូមជំរាបជូនក្នុងឆ្នាំ ១៩៦១ ដែលកន្លងទៅនេះសមាគមមានសកាភាគាន់តឹងស្តាំងស្តួមខាងឯវិកាជាអតិបរមា ស្ទើរតែអស់សង្ឃឹមថា មិនអាចឥឡឹងតាំងនៅបិតរៀបចំរកាលតទៅមុខបានឡើយ ព្រោះប្រាក់ចំណូលមានចូលតិចជាងប្រាក់ចំណាយ ដែលត្រូវចាយកាយកាលខែ ហើយគ្មានប្រាក់ចំណូលអ្វីសម្រាប់ផ្តល់ឲ្យគ្រាន់តែប្រាក់វិភាគទាន ដែលសមាជិក

សមាជិកាបានបង់ប្រចាំខែ ប្រចាំឆ្នាំនោះទេ ទម្ងាំរហើយការសង់ទៅរបស់សមាគមនេះ តឹងតែងតែទៅលើកំឡាំង សមាជិក-សមាជិកាតែម្យ៉ាងប៉ុណ្ណោះ ។ បើតែលណាមានចំនួនសមាជិក-សមាជិកាច្រើន ថវិកាក៏បានចំរើនជាន់បន្តិចឡើង បើចំនួនសមាជិកតិចក៏អន់ថយដូនជាបទៅតាមចំនួនតិចដែរ តែជាភ័ព្វរសនាល្អរបស់សមាគម ទៅតែលបំណាច់ឆ្នាំ ១៩៦១ ឧកញ៉ាព្រះមហា អាំ-ស្ងួន ជាសមណានុសង្គ្រិតដែលសមាគមបានតម្កើងឲ្យមានតំណែងជាបន្តិចជ្រុលជាន់ខ្ពស់ ទៅប្រទេសឥណ្ឌាអស់រយៈ ៧ ឆ្នាំនោះ ក៏បានមានត្រឡប់មកកាន់ប្រទេសកម្ពុជាវិញ ។

ដោយឃើញថា សមាគមមានសភាពដូនជាបដូច្នោះ លោកក៏បានសុំព្រះអង្គលោក ចូលចំរើសមាគមតាមសមត្ថភាពរបស់លោក ដែលគួរបំរើបាន ដើម្បីតបស្នងសងគុណសមាគម ។

គណៈកម្មាធិការនាយកនៃសមាគម ក៏បានពិភាក្សាព្រមព្រៀងគ្នាបើកឲ្យមានបង្រៀនភាសាអង់គ្លេសមួយនៅសាលាគ្លស្ថាំ ដោយចាត់លោកឲ្យធ្វើជាសាស្ត្រាចារ្យក្រោមសេចក្តីអនុញ្ញាតពីក្រសួងធម្មការ ដើម្បីយកកម្រៃសម្រាប់ជាប្រយោជន៍ដល់ថវិកានៃសមាគម ។ ព្រះថេរៈអង្គនេះក៏ព្រមទទួលដោយសោមនស្សរីករាយ ហើយក៏បានចាប់បង្រៀនភាសាអង់គ្លេស តាំងពីដើមខែ តុលា ១៩៦១ រហូតមកទល់នឹងសព្វថ្ងៃនេះ ។

លទ្ធផលនៃការបង្រៀនក្នុងរយៈ ៣ ខែនេះ គឺបានកម្រៃចូលមកក្នុងថវិកាជាង ៤ ម៉ឺនរៀល ។

មានការជាពិសេសទៀត ដែលគួរឲ្យសរសើរដល់សេចក្តីប្រឹងប្រែងរបស់អស់លោកគ្រូអធិការខ្លះ ដូចជាលោកស្រី ភួង-ស្នាត លោកស្រី ង៉ាយ-ប៊ុត លោក ឆែ.វង្ស លោក យ៉ង.គីមលន លោក ប៊ឹង-ហាក ជាដើម បានទៅច្រៀស្រែយតត់ខន់ជាមួយនឹងអស់លោកអស់អ្នកសប្បុរសប្រុសស្រី បានចូលជាសមាជិក សមាជិកាសាមញ្ញខ្លះ ជាពិសេសខ្លះ ខ្ញុំសូមរាយនាមក្នុងនេះ ចំពោះតែសមាជិកសមាជិកាពិសេស ដែលបានបង់ប្រាក់ប្រចាំឆ្នាំតាំងពី ៥០០ រៀលឡើងទៅ ហើយនឹងសូមអភ័យទោស ដោយមិនបានរាយឈ្មោះសមាជិក សមាជិកាសាមញ្ញ ដែលបានបង់ប្រាក់ប្រចាំឆ្នាំតិចជាងពី ៥០០ រៀលចុះមក ព្រោះសមាជិកប្រភេទនេះមានចំនួនច្រើន ហើយពេលនេះក៏ខ្លីពេក ចាំថ្ងៃក្រោយនឹងរាយឈ្មោះផ្សាយជូនតាមវិទ្យុជាតិរៀងរាល់ថ្ងៃសៅរ៍ ។

តាមសមាជិកនីសមាជិកាពិសេសក្នុងឆ្នាំ ១៩៦១ មានដូចតទៅនេះ ៖

១- លោកគហបតី សុត-ហុក បានបង់ក្នុង១ឆ្នាំ ២.០០០ រៀល

២- លោកគហបតី តាន់-ថាំ - - ១.២០០រៀល

៣- លោកស្រី មែរ-ម៉ាលី - - ១.២០០រៀល

៤- លោក ឃុន នេត សាវ៉ាត - - ១.០០០រៀល

៥-ឯកឧត្តម	សឺន-សាន	ចាន់បង់កូន ១ ផ្ទាំ	៦០០រៀល
៦-លោក	តាន់-ភីយ៉ុង	- -	៦០០រៀល
៧-លោកស្រី	រ័ត្ន-ឆុត	- -	៦០០រៀល
៨-លោកស្រី	សុន-ប៊ីនសៃ	- -	៦០០រៀល
៩-អ្នកស្រី	រស់-ឆ្ម	- -	៦០០រៀល
១០-អ្នកស្រី	ហ៊ុន-ឆឺ.ប៊ិន	- -	៦០០រៀល
១១-អ្នកស្រី	ភ័ក-ឈីវហាង	- -	៦០០រៀល
១២-អ្នកស្រី	កែង	- -	៦០០រៀល
១៣-លោក	តាន់.ដេង	- -	៥០០រៀល
១៤-លោក	ឆា.ប៊ុនឆ្នង	- -	៥០០រៀល
១៥-លោក	សេង-ស៊ឹម	- -	៥០០រៀល
១៦-	ពេងតុម្ពកោគសិរី	- -	៥០០រៀល

សូមដំណឹងមហាសន្និបាតថា: កន្លងទៅថ្មីៗនេះ លោកគហបតី សុក-ហុក ខាងលើនេះ បានធ្វើអំណោយដល់សមាគមនូវចង្កៀងម៉ែត្រ អគ្គិសនី ៤ និងផ្ទឹតបញ្ជាអគ្គិសនី ២ តម្លៃជាប្រាក់ ៦.០០០រៀល ដើម្បីគុណជាសម្បត្តិផ្ទាល់របស់សមាគម ។

សមាគមសូមថ្លែងអំណរគុណជាអនេកប្បការចំពោះ អស់លោក សមាជិកសមាជិកាថ្មី ដែលបានបរិច្ចាគកោតក្រឡដល់សមាគមនេះ សូម

ស្បែបានប្រកបដោយឥដ្ឋមនុស្សផលដែលជាទីគាប់ចិត្តជានិរន្តរ៍ ។

អំពីកិច្ចការសមាគម ដែលបានប្រព្រឹត្តទៅកន្លងមក ក្នុងឆ្នាំ ១៩៦១ នេះ :

សមាគមមិត្តពុទ្ធិកវិទ្យាល័យ ទោះបីមានការខ្វះខាតដូចម្តេចក៏ដោយ ក៏ពុំដែលលះបង់នូវភាពក្លាក្នុងចរបស់ខ្លួន ដែលត្រូវតែបំពេញដោយមិនដែលមានខ្ជោះខ្ជាយ ។

១- បានចំណាយប្រាក់ ៦០០ រៀលទិញកម្រងផ្កា ទឹងប្រគេនព្រះសង្ឃឆង្ឃកូល ១ខ្នើសកុសលដួនចំពោះវិញ្ញាណក្ខន្ធសពលោក អ៊ុំ-កង់ ទឹងលោក លី-ស៊ីឆន ជាឧបការសមាជិកដែលទទួលមរណភាពកន្លងទៅក្នុងឆ្នាំ ១៩៦១ នេះ ។

២- បានចំណាយប្រាក់ ១.០០០រៀលទិញសៀវភៅកេតប្រគេនព្រះតេជព្រះគុណព្រះឃោសធម្មវត្តលង្កា នៅពេលដែលលោកនិមន្តទៅឆ្ការចាលកេតនៅមន្ទីរពេទ្យ ព្រះកេតុមាលា ។

៣- បានចំណាយប្រាក់ ៥.០០០ រៀល ប្រគេនព្រះមហា អាំ-សួន សមណានិស្សិតជាតិខ្មែរយានដ៏ទៃ ដែលនិមន្តត្រឡប់ពីប្រទេសវៀតណាមត្រលប់ទៅប្រទេសកម្ពុជា ។

៤- បានសម្រេចគ្រោងការចំណាយប្រាក់កន្លង ១ ទៃ ២.៤០០រៀល សម្រាប់ជាអាហារូបករណ៍ ដើរទៅប្រគេនសមណានិស្សិតភាគច្រើនគឺ ១ តិក្ខុ ទៅ-រៀន, ២ តិក្ខុ ឆ្លង-លាង, ក្នុ សាមណេរ តែង-ចាំ-ម៉ា

ដែលកំពុងសិក្សាបន្តវិជ្ជានៅប្រទេសឥណ្ឌាសព្វថ្ងៃនេះ ចាប់តាំងពីឆ្នាំ
មកក ១៩៦២ នេះទៅ ។

សូមដឹកជញ្ជូនៈ សមាជិកដែលកំពុងសិក្សាបន្តវិជ្ជាសព្វថ្ងៃនៅ
ប្រទេសឥណ្ឌាក្រោមការទទួលខុសត្រូវនៃសមាគម មានចំនួន៩អង្គហើយ ។

៩-នៅឧកាសបុណ្យសន្និសីទលើកទី ៦ នៃពុទ្ធិកសមាគមពិភពលោក
ពីថ្ងៃទី ១៤ ទៅ ថ្ងៃកើត ១៩៦១ សមាគមបានទទួលភ្ញៀវកៅ ធម្មសង្គីតិ
ចំនួន ១០១០ ក្បាល សម្រាប់ចែកជូនដល់តុទ្ធបរិស័ទខ្លួនៅ ដោយទទួ-
លការមែរ-ម៉ាលី មានសទ្ធាជ្រះថ្លាចំណាយប្រាក់ផ្ទាល់ខ្លួនចំនួន ៣០០០
រៀល ក្រោមការអំពាវនាវរបស់សមាគម ។ ជាទៃអំពីនេះទៅទៀត
សមាគមបានចាត់ក្រុមអភិបាលរូបខ្លះ ឲ្យទៅរួបរួមជាមួយនឹងពុទ្ធិកសមា-
គមកម្ពុជវដ្ឋ សម្រាប់ជួយធ្វើការកេងកិច្ចការផ្សេងៗ មានបំរើកៀវព្រះសង្ឃ
បរទេសជាដើម រហូតទៅលំនឹងថ្ងៃចប់តិធីបុណ្យ ចំណែកក្រុមអភិបាល
ខ្លះទៀត ដូចជារូបឯុកោនឹងអ្នកស្រី សារ១ន.សាម៉ន ក៏ត្រូវ
សមាគមចាត់ឲ្យទៅធ្វើជាប្រតិភូ សម្រាប់ប្រទេសកម្ពុជា រួបរួមប្រជុំជា
មួយនឹងគណៈប្រតិភូបរទេសនានាកងឧកាសបុណ្យនោះដែរ ។

៦- ថ្ងៃទី ១-៩-៦១ តិធីបុណ្យដាក់ចុតព្រះសង្ឃ ៩០០ អង្គ
នៃពួកតុទ្ធបរិស័ទនៅភាគតូចផ្សារឧលតាតូច ដែលមានលោកអនុសេ-
នីយឯក តុល-ឈុន កងវរមក្លូមិន្ទ លោក សឺង-ស៊ីម នាយកា-

វិយាល័យនៃពន្ធទី ៣ លោក ដែ-វង្ស នាយកម្រួតព្រះនគរបាលជាតិ លោក យ៉ឹង-គឹមលង តាណិជ្ជករ ជាអ្នកផ្តើមបុណ្យ បានចំនួនប្រាក់ ១០.០០០រៀល សម្រាប់ផ្តល់ជំនួយដល់សមាគម ។

៧- ថ្ងៃទី ១០ ខែ មិថុនា ១៩៦១ សមាគមបានរួបរួមជាមួយពួកភ្ញៀវបរិស័ទវត្តលង្កា ធ្វើតាធីបុណ្យដាក់បាត្រទទួលកុសល ថ្វាយចំពោះសម្តេចព្រះប្រមុខរដ្ឋជាព្រះបិតាឯករាជ្យជាតិនៃប្រទេសកម្ពុជា ព្រមទាំងសម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ ដែលទ្រង់យាង-ទិមន្តទៅតាមព្រះពេត ទីឯចក្ករោតទៅប្រទេសបាកីង ។

៨- ថ្ងៃទី ២៩ មេសា ១៩៦១ សមាគមបានរួបរួម ទីឯសមាគមគិលានសង្គ្រោះសម្តេចព្រះមហាក្សត្រិយានី ពុទ្ធិកសមាគមមជ្ឈមណ្ឌលកម្ពុជរដ្ឋ ធ្វើពិធីបុណ្យនមស្ការព្រះសក្យមុនីចេតិយ៍ នៅមុខស្ថានីយ៍ភាពអាយស្ម័យយានកម្ពុជា បានបច្ច័យជាង ៧.០០០ រៀល គណៈកម្មាធិការក៏បានសម្រេចចែកកុសលទាននេះ មកសមាគមយើង បានប្រាក់ ២.៤០៩រ០០ ។

៩-ថ្ងៃទី ៧ តុលា ១៩៦១ សមាគមបានធ្វើការប្រជុំស្រាយចាក់ទីឯមួលនិធិអាស៊ី មួលនិធិអាស៊ី បានធ្វើអំណោយមកសមាគមនូវម៉ាស៊ីនសម្រាប់ភាញក្រដាសឱ្យបានច្រើន យ៉ាហោ-វ៉ូកូ តម្លៃ ១៣ ៩០០រៀល ។

សមាគមបានធ្វើការជ្រុះស្រង់យកតំណែង នឹងមូលនិធិអាស៊ីមួយដែរ មូលនិធិអាស៊ី បានជួយជាអាហារូបករណ៍ ចំពោះសមាជិសិស្សត ដែលនិមន្តទៅសិក្សាឯប្រទេសផ្សេង គឺសមាជិសិស្សតកំ-យ៉ាវ១ មាស-ចន១ អ៊ុន-សំបេត ១ ប្រុសើដ្ឋ ១ ឈឹម-ចន ១ បាន ២០០ រៀល ១ ដែ ១ អង្គ ។

១០- សមាគមបានធ្វើការគោរមទាគមន៍ នឹងឯកទត្តមឯកអគ្គរដ្ឋទូតប្រទេសផ្សេងប្រចាំប្រទេសកម្ពុជា រង្គាតិចាលកណ្តាលប្រទេសផ្សេង បានជួយជាអាហារូបករណ៍ចំពោះសមាជិសិស្សត ៣ អង្គ គឺ តិក្ខ ប៊ែន-សាអឿន តិក្ខ អ៊ុក-អ៊ន តិក្ខ សួន-សាវឿម បានបច្ច័យ ២០០ រៀល ១ អង្គ ។

១១-ថ្ងៃទី ២ តុលា ១៩៦១ សមាគមបានធ្វើពិធីបើកសាលាបង្រៀនភាសាអង់គ្លេស ដើម្បីយកកម្រៃជាក់ថវិកាសមាគម ដោយលោក មហា អាំ-សួន មានប៉ំណងតបស្នងសងគុណូបការៈសមាគមដែលបានជួយទុបត្ថម្ភលោក ក្នុងការសិក្សាឯប្រទេសផ្សេង បានបច្ច័យជាង ១១.០០០រៀល ក្នុង ១ ថ្ងៃ ។

១២- អំពីសមាជិកនៃសមាគមគ្រប់ប្រភេទក្នុងឆ្នាំ ១៩៦១ ខ្ញុំព្រះករុណាខ្ញុំ សូមតាំងជូនតទៅនេះ៖

๑- សមាជិកកិត្តិយស ๙ នាក់

๒- ជនកសមាជិក ๒๓ នាក់

๓- ឧបការីសមាជិក ๘๖ នាក់

๔- ពាយកសមាជិក ๓๗ នាក់

๕- កម្មិកសមាជិក ๖๘๕ នាក់

๖- ចូសាធិកសមាជិក ๘๒๒ នាក់

បូកសរុប . . . . . ๑.๖๕๘ នាក់

ឆ្នាំ ๑๙๖๐ មានចំនួន ๑.๕๕๓ នាក់ ឃើញកើនជាងឆ្នាំចាស់ចំនួន ๑๐๕ នាក់ ។

๑๓- សូមប្រគេនន័យដូនដំណឹងដ៏ជាទីរីករាយមួយជូនលម្អិតថា ព្រះករុណាតថា ព្រះករុណាជាអម្ចាស់ជីវិតលើក្បាលទូលព្រះបង្គំ ដែលមានអង្គសម្តេចព្រះបិតាឯករាជ្យជាតិដ៏ជាទីគោរព បានទទួលស្គាល់នូវសមាគមយើងជាផ្លូវការហើយ ព្រមទាំងបានធ្វើសេចក្តីគ្រោងការសម្រាប់ចំណាយប្រាក់ចំនួនប្រាំម៉ឺនរៀល ផ្តល់ជូនសមាគមតាំងពីឆ្នាំ ๑๙๖๒ តទៅ ។

ដូច្នេះសមាគមយើង ទើបមានសភាពមាំមួនតាំងពីពេលនេះតទៅ ។

មុននឹងបញ្ចប់នូវសុន្ទរកថានេះ ខ្ញុំព្រះករុណាខ្ញុំបាទ សូមធ្វើកត្តាសពេលនេះ ដែលនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅ ចំពោះសមាជិក សមាជិកាក្រុមអតិថិជន ដែលបានជួយចំពេញការណ៍យកចិត្តទុកដាក់ក្នុងការរៀន

ខ្ញុំ ដោយសុទ្ធចិត្ត ហើយសូមដាស់តឿនក្រែនរំលឹកនូវសមាជិកក្រុម
អតិថិជនថា សមាគមមានលក្ខន្តិកៈជាប្រជាន សូមលោកអ្នកភ្ញាំង
បញ្ញានា ។ មានហ៊ានភ្លាត់ក្នុងដើម ឱ្យប្រព្រឹត្តទៅដោយត្រឹមត្រូវ តាម
លក្ខន្តិកៈកុំបីឃ្លៀងឃ្លាត ។

ម្យ៉ាងវិញទៀត ខ្ញុំព្រះករុណា-ខ្ញុំបាទ សូមសរសើរចំពោះមុខមហា.
សន្និបាត នូវការព្យាយាមនៃលោក-អ្នក ដែលមានទាមទាងក្រោម ក្នុង
ការពង្រីកសមាជិករៀងរាល់ខែគឺ៖

លោក ឌី-រ៉ង់ ជំណាងក្រសួងធម្មការ

- ម៉ៅ-ម៊ី ជំណាងក្រសួងមហាផ្ទៃ

- ឆៃ-វង្ស ជំណាងក្រសួងគំនាប

- យ៉ង-គីមលង ជំណាងបរិស័ទខ្មែរតាមបណ្តែត

លោក មាស-ដាន់ ទីឆ លោក ប៊ុល-ចឹង ជំណាងក្រសួង
ឃោសនាការជាតិ

- សម សុខុម ជំណាងកាកបាទក្រហម

- ឈុត មាលីស ជំណាងព្រះបរមរាជវាំង

ជាអាសាន ខ្ញុំព្រះករុណា ខ្ញុំបាទ សូមថ្លែងនូវបុញ្ញាភិសេកដែល
កើតឡើងដំណាលបុញ្ញាភិសេកនេះ ថ្វាយចំពោះព្រះវិញ្ញាណក្ខន្ធ
ព្រះករុណាព្រះមហាកាញ្ចនកោដ្ឋ សុំព្រះអង្គជ្រាបថ្វាយព្រះបរមសុខ

គ្រប់ប្រការក្នុងសុគតិភព ខ្ញុំសូមថ្វាយចំពោះសម្តេចព្រះមហាសង្ឃរ៉ាជ-
ឃោខ្ញុំជាអម្ចាស់ដ៏វិសេសលើសលួង ព្រមទាំងសម្តេចព្រះប្រមុខរដ្ឋ សូមព្រះអង្គ
មានមហិទ្ធិរុទ្ធិ ខ្ញុំព្រះមហាក្សេមក្សាន្តគ្មានឈ្នះអស់ទាំងសត្រូវគ្រប់ទិសទី
មានព្រះបរមសុខុមាលភាព ក្នុងព្រះសិរីវិភវសម្បត្តិ មានព្រះជន្មាយុ
យឺនយូរអស់រយៈព្រះវស្សា ដើម្បីជាទីពឹងពុំនាក់ជាមួយដ៏ត្រជាក់ នៃប្រ-
ជាពលរដ្ឋក្នុងព្រះរាជអាណាចក្រ ព្រមទាំងប្រគេនខ្ញុំឯកជនទូទៅគ-
ណៈកុសលកាសីនេះ ដល់ព្រះសង្ឃមានសម្តេចព្រះសង្ឃនាយកជាប្រធាន
ខ្ញុំឯកអស់លោកអ្នកជាសមាជិក សមាជិកាគ្រប់រូប សូមឲ្យបានប្រកបដោយ
ពុទ្ធពរទាំង ៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ជាទីរាប់រៀហោង ។

លំដាប់តមក លោក ង៉ៅ-ម៉ី អគ្គលេខាធិការ បានថ្លែងនូវស្ថានភាពណ៍
ហិរញ្ញវត្ថុសមាគម អំពីប្រាក់ចំណូល-ចំណាយ ខ្ញុំឯកស្រង់ក្នុងហិប
ដូចខាងក្រោម៖

ប្រាក់ចំណូល-ចំណាយ របស់សមាគម ដែលបានប្រព្រឹត្តទៅ
ក្នុងឆ្នាំ ១៩៦១

ប្រាក់ចំណូល	១៤២.១២៧ រៀល
ប្រាក់ចំណាយ	៧០.៩១៦ រៀល
ប្រាក់នៅសល់ក្នុងហិប . . .	៧១.២១១ រៀល

នៅលើម៉ោង ៩.៣០ នាទី មហាសន្និបាតបានចាត់តាំងការិយាល័យមួយ សម្រាប់ចោះឆ្នោតជ្រើសតាំងសមាជិកក្រុមអគិបាលថ្មី ក្រោយដែលក្រុមអគិបាលឆ្នាំចាស់សូមលាលែងពីមុខតំណែង ។

នៅលើម៉ោង ៩.៥០ នាទី លោក ប៊ឹង.ហាក់ បានឡើងលើវេទិកា បានសុំមហាសន្និបាតកែប្រែលក្ខន្តិកៈត្រង់ចំនួនសមាជិកក្រុមអគិបាល ១៦ នាក់ ឲ្យកែថា ២០ នាក់ ហើយសុំមហាសន្និបាតអនុម័តជាឯកច្ឆន្ទ ទូវនាមឈ្មោះដែលបានសរសេរលើក្តារខៀនចំនួន ២០ នាក់ថា ជាក្រុមអគិបាលសម្រាប់ឆ្នាំ ១៩៦២ ។

ឯសមាជិកក្រុមអគិបាលថ្មី ដែលមហាសន្និបាតបានជ្រើសតាំង ហើយអនុម័តជាឯកច្ឆន្ទ បានសម្រេចទូវលទ្ធផលដូចតទៅ :

១-	លោក ង៉ាយ-ប៊ុតា	អធិបតី
២-	លោក ជេង-ត្រីវ	អធិបតីរង
៣-	- អឹង-ឌួង	-
៤-	- ប៊ឹង-ហាក់	លេខាធិការ
៥-	លោកស្រី សាខន.សាម៉ន	អនុលេខាធិការ
៦	លោក ឆែ-វង្ស	-
៧-	- ម៉ៅ-ម៉ី	អគ្គហេរញ្ញិក

៨-	លោក	ស្សរ.ស៊ីដន	ហេរញ្ញិក
៩-	-	យ៉ែន.គឹមសន	-
១០-	-	ញន.សឿង	អណ្តាតរក្សា
១១-	-	ម៉ែន.ធន់	-
១២-	លោកស្រី	ភ័យ.ប៊ុត	ស្នងការ
១៣-	-	ឆួច.ស្អាត	-
១៤-	-	មែរ.ម៉ាលី	-
១៥-	-	សម.ណៃ	-
១៦-	លោក	ជា.ធន់	-
១៧-	-	លុយ.ឌឹម	-
១៨-	-	អាស.ជាន់	-
១៩-	-	អាស.ឆេង	-
២០-	-	ង៉ី.រ័ន	-

គេសមាជិក ៦ ល្អាច មហាសន្និបាត ក៏បានប្រកាសហៅនាម សមាជិក.សមាជិកា ក្រុមអគិបាលសមាគមថ្មីសម្រាប់ឆ្នាំ ១៩៦២ ហើយ ព្រះសង្ឃក៏បានប្រគេនសព្វសាធុការពរ ទំនងដ៏ឃម្ពីរសរីរសួស្តីគ្រប់យ៉ាង ដល់ក្រុមអគិបាលថ្មី ជាកិច្ចបញ្ចប់សម័យមហាសន្និបាត ។

មហាសន្និបាតក៏បានចប់សព្វគ្រប់នៅម៉ោង ៦ ទំនង ១០ នាទី ។


គិលានដ្ឋាន បំរើសុខភាព

សម្តេចព្រះមហាសុមេធាធិបតី ជ.ណ. ជោតញ្ញាណោ សង្ឃនាយកគណៈមហានិកាយ បានចាត់ការស្ថាបនាគិលានដ្ឋានបេតុង-អារម៉ែ ១ ខ្នង ក្នុងឃុំកោកកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ចាប់ផ្តើមស្ថាបនាតាំងក្នុងខាងចុងឆ្នាំ ១៩៦០ ដល់ខាងចុងឆ្នាំ ១៩៦១ ទើបហើយស្រេច បានឲ្យឈ្មោះថា គិលានដ្ឋាន "ចំរើនសុខភាព" ។ គិលានដ្ឋាននេះ មានបណ្តោយ ១៨ ម៉ែត្រ ទទឹង ៩ ម៉ែត្រ ចែកជា ៤ ល្វែង មានយំចេញមកខាងមុខ ៤ ម៉ែត្រ ៤ ជ្រុង គ្រឿងឈើស្រេច ប្រក់ក្បឿងក្បាច់ ក្រាលឥដ្ឋឥណ្ឌូស.លឿងចាស់ មានយំចេញមកខាងក្រោយ ៤ ម៉ែត្រ ៤ ជ្រុងដែរ មានផ្ទះបាយបណ្តោយ ១១ ម៉ែត្រ ទទឹង ៤ ម៉ែត្រ ចែកជា ៣ ល្វែង, ផ្ទះបាយនេះធ្វើភ្ជាប់ពីយំខាងក្រោយមក មានដំបូលកបស្មើ ក្រាលឥដ្ឋដូចពីលើ- ចាំងផ្ទះធំទឹងផ្ទះបាយមានម៉ាស៊ូនទឹកសម្រាប់ប្រើប្រាស់ត្រប់ត្រាន់ ម៉ាស៊ូនទឹកចាំងនោះ បូមយកពីអាងទឹកខាងក្រោយផ្ទះបាយ ដែលទទួលយកទឹកភ្លៀងពីផ្ទះធំទឹងផ្ទះបាយ ឬបូមយកពីអណ្តូងនៅជិតនោះក៏បាន ។ គិលានដ្ឋាននេះ សង់លើទីដីមានបណ្តោយ ១០០ ម៉ែត្រ ទទឹង ៥២ ម៉ែត្រ ជាដីរបស់ឈ្មោះ សួស.យ៉ា ភរិយាឈ្មោះ ខាង ច្រាក់.សាប៊ូ បានប្រគេនសម្តេចព្រះសង្ឃនាយក ដោយឥតយកថ្លៃបន្ទិចបន្តួចឡើយ ។ សម្តេចព្រះសង្ឃនាយក បានចាត់ការស្ថាប-


នាក់តែងបេតុនអារម៉ាត់ខ្ញុំវិញមានបណ្តាយ ១០០ ម៉ែត្រ ទទឹង ៥២ ម៉ែត្រ តាមចំហៀង ។ តម្លៃគិលានដ្ឋាន ត្រូវចំនួនកំពែងដុំវិញផង ៤១៨.២០៨ រៀល, តម្លៃគ្រឿងសម្ភារៈសម្រាប់ប្រើប្រាស់ក្នុងគិលានដ្ឋាន តវៅចំនួនជាង ២ ម៉ឺនរៀល, តម្លៃទេសចរជាង ១០ ម៉ឺនរៀល ។ គិលានដ្ឋាននេះ បានសាងត្រង់ជ្រុងទិសឦសានតំបន់ភូមិកោះតាកែវ ទិសនិរតីជាប់ព្រំដែនវត្តពោធិព្រឹក្ស ចម្ងាយពីវត្តជាង ២ ខេះ ២ គីឡូម៉ែត្រកន្លះដូចគ្នា ចម្ងាយពីក្រុងកំពតវិញ ប្រមាណ ៣៨ គីឡូម៉ែត្រ ប្រមាណពីទីរួមស្រុកត្រពាំងប្រាសវិញ ប្រមាណ ៤៤ គីឡូម៉ែត្រ ។

នៅថ្ងៃព្រហស្បតិ៍ ១១ កើតខែមាឃ ឆ្នាំឆ្លូវត្រីស័ក ព.ស. ២៥០៦ ត្រូវនឹងថ្ងៃទី ១៥ កុម្ភៈ ១៩៦២ សម្តេចព្រះឧបយុវរាជ ព្រះប្រមុខរដ្ឋ បានស្តេចយាងទៅជាព្រះរាជាធិបតី ក្នុងពិធីសម្ពោធគូរគិលានដ្ឋាន "ចំរើនសុខការ" នេះ ស្តេចយាងទៅដល់ទីតាំងនៅវេលាម៉ោង ៩ ហួសដល់ម៉ោង ១៣ កន្លះ ទើបស្តេចនិវត្តមកកាន់ព្រះរាជដំណាក់តំបន់ពោធិវិញ ដោយព្រះឥរិយាបថក្តៅក្រហាយ ។

សម្តេចព្រះមហាសុមេធាធិបតី បានមានព្រះរាជតំណាលថ្លែងយ៉ាងថា គិលានដ្ឋាននេះ ជាសាធារណៈប្រយោជន៍ដល់ប្រជាពលរដ្ឋ ៨ ឃុំ ដល់តិចុំសាមណេរ ១៨ វត្ត ថាតាំងពីសម្ពោធគូរមកហើយរៀងមកសព្វថ្ងៃនេះ ក្នុង ១ ថ្ងៃ។ លើកលែងតែថ្ងៃអាទិត្យ មានប្រជាពលរដ្ឋចូលមក



រូបគំលាននដ្ឋាន ចំរើនសុខភាព ថតពីខាងលិច ចំពីមុខ




រូបគំលាននដ្ឋាន ចំរើនសុខភាព ថតពីខាងត្បូង ឃើញទាំងផ្ទះបាយផង

ប្រជាស្រុកយន្ទីតិលានដ្ឋាននេះ ច្រើនហួសពីការស្មានទុកពីមុនមក គឺក្នុង ១ ថ្ងៃ ។ យ៉ាងតិចជាង ១០០ នាក់ យ៉ាងច្រើនជាង ៣០០ នាក់ ពេទ្យ ម្នាក់នឹងអ្នកជួយធ្វើការម្នាក់ផង ស៊ើរតែនឹងធន់មិនឈ្នះទៅហើយ ដោយ មកពីតិលានដ្ឋាននេះ មានទុសថបរិបូណ៌ណាស់ ព្រោះនៅថ្ងៃសម្ពោធ ឆ្នងរៀងរហូតមកដល់សព្វថ្ងៃនេះ មានអស់លោក-អ្នកមានសទ្ធានៅក្រុងភ្នំពេញ ចាន់ជាវេទុសថល្អ ។ យកមកចូលថាប់កុសល ចំពោះសម្តេច ព្រះមហាសុមេធាធិបតី សម្តេចក៏ចេះតែយកទុសថតាំងនោះ ទៅបន្ថែម មិនឲ្យខ្វះខាត ។

នៅពេលសម្ពោធឆ្នងតិលានដ្ឋាននេះ សម្តេចព្រះប្រមុខរដ្ឋទ្រង់ព្រះមេត្តាប្រោសប្រទានបច្ច័យចំនួន ១០ ម៉ឺនរៀលចំពោះសម្តេចព្រះមហាសុមេធាធិបតី ដើម្បីឲ្យស្ថាបនាថាវរវត្តអ្វីមួយដែលជាសាធារណៈប្រយោជន៍ តទៅទៀត សម្តេចព្រះសង្ឃនាយក ប្រទានផ្តើមនឹងស្ថាបនាប្រសូតគ្រឹះ គឺផ្ទះឆ្លុះ ១ ខ្នងឲ្យមានផ្ទះថ្មយនឹងមាំស៊ុនទឹកជាដើម ដូចតិលានដ្ឋាននេះដែរ នឹងសង់ក្នុងកំពែងតិលានដ្ឋាននោះ បំរុងនឹងឲ្យហើយស្រេចក្នុងកាលខាងចុងឆ្នាំ ១៩៦២ នេះ ថ្វាយសម្តេចព្រះបិតាឯករាជ្យជាតិ ។ បើអាចលៃលកបាន សម្តេចព្រះសង្ឃនាយកនឹងចាត់ការស្ថាបនាសាលា ១ ខ្នង សម្រាប់អ្នកជម្ងឺសំណាក់ នឹងអាស្រម ៤ ឬ ៥ ខ្នង នៅភ្នំស្រែធំខាងលិចកំពែងតិលានដ្ឋាន សម្រាប់តិក្ខុសាមណេរសំណាក់អាស្រ័យឲ្យពេទ្យចាត់ថ្នាំឲ្យ ចំពោះតិក្ខុសាមណេរដែលមានអាពាធភ្លាំរ៉ៃ ។

ភគ្គមសទិយា


ទស្សនាវដ្តី ផ្សាយចំណាំងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ៣៤ លេខ ៣ ខែ មីនា

ព.ស. ២៥០៤ គ.ស. ១៩៦២

- ភ្នំពេញ -



អង្គុលិសន្ទេសរ

ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពរៀងរាល់ខែពីព្រះពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	មេរៀន	ទំព័រ
– សោកុប្បត្តិចិត្ត	អ្នកឧកញ៉ា ទា-សាន អតីតរដ្ឋមន្ត្រី	រៀបរៀង ២៤៦
– ព្រះអភិធម្មបិដក (គម្ពីរព្រះយមកៈ) (ត)		លោកប៉ូ-ប៉ុំ ប្រែរៀបរៀង ២៥៧
– មធុរសរសៀហ៍ណី(ត)សម្តេចព្រះធម្មលិខិតសុ-ឯម		ប្រែ ព្រះញាណកោសលវ-ឈឺនតិនិត្យ ២៦៣
– មហោសថជាតក(ត)	លោក អឹម-ភាន	ជម្លងពីសាស្ត្រស្នាំការិតព្រះពុទ្ធវង្ស កឹម-ឆ្នុះ ពិនិត្យ ២៧១
– រឿងនាទេកស្សប	ភាគ្យភាក្យ ៩ (ត១ប់)	លោក យ៉ូ-ស៊ុន និពន្ធ ២៧៩
– សម្ភោទមាទាជាតក		ព្រះញាណកោសល ញាណ-ឈឺន រៀបរៀង ៣០០

ផ្នែកអក្សរសាស្ត្រ		
– បញ្ហាដំណូលអក្សរសាស្ត្រនៅបច្ចុប្បន្នកាល		លោក លី-ឆាមតេង រៀបរៀង . . . ៣០៦
– ពាក្យខ្មែរប្រែតបទេស		ដោយគណៈកម្មការជាតិនៃការសិក្សាផ្នែកអក្សរ « ក » . . . ៣១៤
– វចនានុក្រមសំស្ក្រឹត-ខ្មែរ (ត)		ព្រះមហា ជាំង-ខាត់ រៀបរៀង ៣១៥
– រឿងសាមកុក (ត)	ឧកញ៉ា ទូ-កន	ប្រែ ៣១៦
– រឿងត្រែងចិន (ត)		លោក ភ័យ ប៊ុក ប្រែរៀបរៀង ៣៣៤
– រឿងត្រែងប្រាក្ខសុភសិត ៤ ជា (ត១ប់)		. . . . . ៣៤០
– រឿងត្រែងប្រទេសយូរហ្គាស្លាវី		កិកុ ម៉ែន-រៀម ប្រែពីភាសាអង់គ្លេស . . . ៣៤៦

ផ្នែកកំណត់ទំនឹងប្រវត្តិសាស្ត្រ	
– បណ្ណាល័យពុទ្ធសាសនាមួយនៃប្រទេសកម្ពុជា	នៅក្រុងភ្នំពេញ (សហការកម្ម) . . . ៣៥៧

មួយឆ្នាំមាន ១២ លេខ តម្លៃដាវ ២៣០រ០០

34è Année — N° 2 — Février 1962

KAMBUJASURIYA

Revue mensuelle de culture religieuse et littéraire
publiée par l'Institut-Bouddhique de Phnom-Penh

SOMMAIRE

Partie religieuse

—Lokottaracitta par l'Oknha TEA-SAN. 246
—Prah Abhidhamma pitaka (Kampi prah Yamaka)
par M. BOU-PO (suite) 257
—Madhurasavahini traduit par Samdech Prah Dhamma-
likhita LOUIS-EM, revu et corrigé par Vén.
NHEAN-CHHŒUN (suite) 263
—Mahosotha Jataka relevé du manuscrit sur feuilles
de latanier par M. IM-PHON, revu et corrigé
par Vén. KEM-TO (suite). 271
—Histoire de Naradakassapa en vers par M. YOU-OUN
(suite et fin) 278
—Sammodamanajataka par Vén NHEAN-CHHŒUN. . . 300

Partie littéraire

—Diffusion de la littérature Contemporaire par
M. LY-THEAM TÉNG 306
—Activités de la Commission Nationale de l'Education
section « A » 314
—Dictionnaire Sanscrit-Khmèr par Vén. PANG-KHAT (suite) 315
—Histoire de Sam-Kok traduite par l'Oknha NOU-KAN (suite) 316
—Contes et Légendes populaires de la Chine traduits
par M. RAY-BUC (suite). 334
—Commentaires des proverbes cambodgiens par la
Commission des Mœurs et Coutumes (suite et fin). 340
—Légende de Yougoslavie traduit par Vén. MEN-REAM. . . 346

Notes et Chroniques

—Bibbliothèque bouddhique Khmère à Rangoon (Birmanie) 357

Abonnement annuel (comprenant 12 numéros) : 230 f 00

សព្ទសាធុការពរឆ្នាំថ្មី

ឧកាសឆ្លាស់ឆ្នាំឆ្លូវ, ខ្ញុំលួចលូនទៅជាកសិ
នៃជនខ្មែរប្រុសស្រី, សកពជថ្មីកើនដើរគាំទ្រ
គឺព្រះពុទ្ធសិក្ខ តែរតាន់ជាក់ច្រាំរយច្រាំ,
គ្រិស្តសិក្ខមួយតាន់ឆ្នាំ ច្រាំជួនរយហុកសិបតែរ ។

ពុទ្ធសាសនៈ បណ្ដាំព្យុះ ជាមន្ទិរ
ផ្សាយធម៌ដ៏គម្ពីរ ដែលជាភ្លើងពុទ្ធសាស្ត្រ ។
សូមបួងសួងប្រសិទ្ធិ ត្រៃរត្នតតកង់លោកា
តាំងសូមភួងខ្ពស់ ថែរក្សាការពារជាតិទ្រង់
ម្ចាស់ សូមព្រះមហា- ក្សត្រិយានីជាអាទិ
ជាព្រះមាតាជាតិ បំពេនសុខជោគសួស្តី !
ព្រឹរ សូមព្រះប្រមុខ ជាឥតុកឯកជថ្មី
ប្រកបដ៏យសិរី មានព្រះជន្មជាន់រយឆ្នាំ !
ប្រឹ សូមកជដ្ឋា- តិជាលជាអ្នកឧបត្ថម្ភ
ឲ្យភួងខេត្តថែទាំ ជួយឲ្យបានសុខមនោរម្យ !
ប្ញូ សូមភួងតលរដ្ឋ ខ្មែរប្រុងជកក្នុងសង្គម
បំពេនសុខឧត្តម សំបូរធនធានគោគា !
ពិសេសសូមសន្ដាន ជាអ្នកមានចិត្តជ្រះថ្លា
អាន កម្ពុជសុរិយោ កបសុភនិន្នរំហោង !

យ.អ៊ិ.

លោកុត្តរចិត្ត

អ្នកឧកញ៉ា ឆា-សាន អតីតរដ្ឋមន្ត្រីរៀបរៀង

ពាក្យយោគមិនខ្ជះ ធ្វើការអោយត្រាក់
ជាការលោមក ខ្ជះធ្វើល្អទៅ ។
ខ្ជះចុំសាងចិត្ត កុំឲ្យហួងសៅ
នេះឯងលោកហៅ ពុទ្ធសាសនា ។

ច.ព.

១– អត្ថន័យនៃលោកុត្តរចិត្ត

ដើម្បីឲ្យងាយយល់ ខ្ញុំអត្ថាធិប្បាយនៃលោកុត្តរចិត្តជាខណ្ឌសំលាស់ទោះ ខ្ញុំយល់ឃើញថា គួរតែលើកយកលោកិយចិត្តមកបញ្ជាក់ឲ្យដឹងន័យអត្ថន័យដូចម្តេចជាមុនសិន ពីព្រោះលោកុត្តរចិត្តនឹងលោកិយចិត្តមានន័យផ្ទុយគ្នាស្រឡះ ដូចមានសេចក្តីអធិប្បាយបញ្ជាក់ខាងក្រោមនេះស្រាប់ ។

ឯលោកិយចិត្ត គឺចិត្តរបស់សត្វដែលមានកង្វល់លោក ពោលគឺចិត្តរបស់លោកិយសត្វ ដែលសៅហ្មងដោយមន្ទិលផ្សេង ។ ពោះឯង ។ រីឯលោកុត្តរចិត្តវិញ គឺសំដៅចិត្តរបស់អរិយបុគ្គលដែលបានត្រាស់ដឹងនូវលោកុត្តរធម៌ ពោលគឺចិត្តដែលអរិយបុគ្គលបានដុសខាត់ដំរេះដោយសីល

សមាធិខ័ន្ធបញ្ញា ឲ្យស្អាតបរិសុទ្ធផ្លូវផង់រួចផុតស្រឡះចាកគ្រឿងសៅហ្មង តាំងឡាយនោះឯង ។

កង់ចំនួនចិត្ត ៨៩ ដួង ដែលប្រព្រឹត្តទៅកង់ភូមិតាំង ៤ មានកាមាវចរភូមិជាដើមនោះ មានលោកុត្តរចិត្ត ៨ ដួងចែកចេញជាមគ្គចិត្ត ៤ ដួង ខ័ន្ធផលចិត្ត ៤ ដួង ។

- តើមគ្គចិត្ត ៤ ដួង ខ័ន្ធផលចិត្ត ៤ ដួងនោះ ជាចិត្តរួចចាកគ្រឿងសៅហ្មងអ្វីខ្លះទៅ ? ។

រីឯមគ្គចិត្ត ៤ ដួង ខ័ន្ធផលចិត្ត ៤ ដួងនោះគឺ សំដៅយកចិត្តដ៏បរិសុទ្ធផ្លូវផង់រួចផុតស្រឡះចាកអាសវៈ ៤ ខ័ន្ធសំយោជនៈ ១០ ហើយខ័ន្ធតណ្ហា ៣ តែព្រោះតិលេសតាំង ៣ ប្រភេទនេះ កាលបើមកកើតនៅកង់ខន្ធសន្តាន ហើយ រមែងពុំកជាបុព្វហេតុអាចកាត់ដាច់ដាស់ម៉ិនឲ្យលោកុត្តរចិត្តកើតឡើងបានសោះឡើយ ។

ដោយហេតុនេះ ទើបមគ្គចិត្ត ៤ ដួងនោះ ពុំកជាចិត្តដែលកើតមានឡើង ដោយសមុច្ឆេទប្បហាន គឺការលះដោយដាច់ខាតនូវអាសវៈ ៤ ខ័ន្ធសំយោជនៈ ១០ ហើយខ័ន្ធតណ្ហា ៣ នោះ រីឯផលចិត្ត ៤ ដួងនោះ ពុំកជាចិត្តដែលកើតមានឡើងដោយសមុច្ឆេទៈម៉ុត្តិ គឺការរួចចាកដោយដាច់ខាតនូវអាសវៈ ៤ ខ័ន្ធសំយោជនៈ ១០ ហើយខ័ន្ធតណ្ហា ៣ នោះឯង ។

មុខខ័ន្ធធ្វើអត្ថាធិប្បាយបញ្ជាក់អំពីលក្ខណសម្បត្តិនៃមគ្គចិត្តខ័ន្ធមួយ ។

ឧទ្ធំដល់ចិត្តឧម្មុយ។ មានដូចម្តេចខ្លះនោះ ខ្ញុំយល់ឃើញថា គប្បីលើកយកអាសវៈ ៤ ឧទ្ធំសំយោជនៈ ១០ ហើយឧទ្ធំតណ្ហា ៣ នោះមកអធិប្បាយបញ្ជាក់ឲ្យដឹង តើកិលេស ៣ ប្រភេទនេះ មានន័យឧទ្ធំមានលក្ខណៈដូចម្តេចខ្លះ ទើបកិលេស ៣ ប្រភេទនោះ ត្រូវបានចាត់ទុកជាបុព្វហេតុកំណត់ដាស់មិនឲ្យលោកុត្តរចិត្តអាចសម្រេចកើតឡើងបាន ដូចមានសេចក្តីបរិយាយតទៅនេះ ៖

២- អាសវៈ ៤

ឯ អាសវៈគឺសំដៅយកកិលេសដែលជាគ្រឿងត្រាំខៅក្នុង ១ ខន្ធសន្តាន មាន ៤ យ៉ាងគឺ កាមៈ ១ ហៅថា កាមាសវៈ, ទិដ្ឋិ ១ ហៅថា ទិដ្ឋាសវៈ, ភព ១ ហៅថា ភវាសវៈ ឧទ្ធំ អវិជ្ជា ១ ហៅថា អវិជ្ជាសវៈ ។

តើកិលេស ៤ យ៉ាងគឺ កាម, ទិដ្ឋិ, ភព, ឧទ្ធំ អវិជ្ជា មានអត្ថន័យដូចម្តេចខៅ ? ។

បើតាមខ្ញុំយល់ អត្ថន័យនៃកិលេស ៤ នោះគឺ៖

១- កាម សំដៅយកសេចក្តីប្រាថ្នា ២ ប្រការ គឺសេចក្តីប្រាថ្នាខ្លួនវត្ថុដែលជាគ្រឿងលួងលោមចិត្តឲ្យរីករាយ ហៅថាវត្ថុកាម ១ ឧទ្ធំសេចក្តីប្រាថ្នាខ្លួកិលេសដែលជាគ្រឿងញុះញង់ចិត្ត ឲ្យស្រើបស្រាលសប្បាយ ហៅថា កិលេសកាម ១ ។

๒- ទិដ្ឋិ សំដៅយកសេចក្តីយល់ឃើញខុស មានសេចក្តីយល់ឃើញខុសចំពោះរូបកាយហៅថា សក្កាយទិដ្ឋិដាដើមនោះ ។

๓- កង សំដៅយកដំណើរកើតនៃសត្វ ដោយកម្មជាកុសលនិងកម្មជាអកុសលនោះ ។

๔- អវិជ្ជា សំដៅយកសេចក្តីល្ងង់មិនដឹងខ្លួនអរិយសច្ច ๔ ប្រការ ។

រីឯកិលេស ๔ នេះ កាលបើមកកើតគ្រាំគ្រានៅក្នុងខន្ធសន្តានហើយតែងធ្វើចិត្តឲ្យសៅហ្មង ឲ្យជាប់ដំពាក់យ៉ាងស្អិតនិងកាមគុណជាលំដាប់ ។

ម្យ៉ាងទៀត កិលេស ๔ នេះ បណ្ឌិតលោកចាត់ពុកថាជា ឱឃៈ គឺអន្ទង់ទឹកមាន ๔ គឺ អន្ទង់កាម ๑ ហៅថា កាមោឃៈ, អន្ទង់ទិដ្ឋិ ๑ ហៅថា ទិដ្ឋោឃៈ, អន្ទង់កង ๑ ហៅថា ភវោឃៈ និងអន្ទង់អវិជ្ជា ๑ ហៅថា អវិជ្ជោឃៈ ។

ឯអន្ទង់ ๔ នេះ គ្រឿមចាំតែតន្ទង់សត្វឲ្យលង់លិចក្នុងជលសាគរគោលគឺវដ្តសង្សារ មិនឲ្យសត្វធ្វើដំណើរឆ្លងចេញរួចផុតចាកត្រៃលោកបានឡើយ ។

ម្យ៉ាងវិញទៀត កិលេស ๔ នេះ បណ្ឌិតលោកចាត់ពុកជាគ្រឿងប្រកបហៅថា យោគៈ មាន ๔ គឺ ទិដ្ឋិយោគៈ គ្រឿងប្រកបគឺ ទិដ្ឋិ ๑, កាមយោគៈ គ្រឿងប្រកបគឺ កាម ๑, ភវយោគៈ គ្រឿងប្រកបគឺ កង ๑ និង អវិជ្ជាយោគៈ គ្រឿងប្រកបគឺ អវិជ្ជា ๑ ព័ព្រោះ

១- ឯដ្ឋយោគៈ ឧកជាគ្រឿងប្រកបសំយោជនៈ ៣ ខាងដើម គឺ សក្កាយទិដ្ឋិ ១ វិចិកិច្ឆា ១ ឧទ្ធច្ចសីលព្វតបរាមាសៈ ១ ឲ្យមានដំណើរប្រព្រឹត្តទៅបានជាប្រក្រតីនោះ ។

២- តាមយោគៈ ឧកជាគ្រឿងប្រកបសំយោជនៈ ២ បន្ទាប់មក គឺ កាមរាគៈ ឧទ្ធច្ចៈ ឲ្យមានដំណើរប្រព្រឹត្តទៅបានជានិច្ចនោះ ។

៣- ភវយោគៈ ឧកជាគ្រឿងប្រកបសំយោជនៈ ៤ បន្ទាប់មកទៀត គឺ រូបរាគ, អរូបរាគ, មានៈ ឧទ្ធច្ចៈ ឲ្យមានដំណើរប្រព្រឹត្តទៅបានជាអចិន្ត្រៃយនោះ ។

៤- អវិជ្ជាយោគៈ ឧកជាគ្រឿងប្រកបសំយោជនៈ ១ ខាងបុព្វ គឺ អវិជ្ជា ឲ្យមានដំណើរប្រព្រឹត្តទៅបានជាធម្មតានោះឯង ។

ដោយហេតុនេះ ទើបតាសវៈ ៤ ត្រូវចាត់ឧកជាបុព្វហេតុ ១ ដែលកាត់ផ្តាស់មិនឲ្យលោកុត្តរចិត្ត អាចសម្រេចកើតឡើងបានដោយប្រការដូច្នេះឯង ។

៣- សំយោជនៈ ១០

ឥដ្ឋាប់តទៅនេះ ខ្ញុំនឹងលើកយកសំយោជនៈ ១០ មកធ្វើអត្ថាធិប្បាយបញ្ជាក់វែកញែកឲ្យឃើញ តើសំយោជនៈ ១០ នោះ ជាកិលេសមានលក្ខណៈដូចម្តេចខ្លះ? ដែលជាហេតុនាំឲ្យបណ្ឌិតលោកចាត់ឧកដូចជា

ចំណងអាចជាន់តួរតែត្បូងសត្វបង្កើតជាខ្លួក ឲ្យនៅរំលែកក្នុងវដ្តសង្សារបាន ដូចម្តេចខ្លះ? ដូចមានសេចក្តីអធិប្បាយបញ្ជាក់តទៅនេះ ៖

១- សក្កាយទិដ្ឋិ គឺសេចក្តីយល់ឃើញខុសចំពោះរូបកាយ ។ ឯសក្កាយទិដ្ឋិនេះ គឺសំដៅការយល់ឃើញខុសចំពោះកាយមាន ២០ ប្រការ មានការយល់ឃើញរូបថាជាខ្លួន, ឃើញវេទនាថាជាខ្លួន, ឃើញសញ្ញាថាជាខ្លួន ។ ល ។ ជាដើម ។

ឯសេចក្តីយល់ឃើញខុសដូច្នេះ ជាហេតុទាំឲ្យប្រកាន់ម៉ាំថា រូបកាយនេះ ជារបស់អាត្មាអញ, ជាអាត្មាអញ ខ្លឹងជាខ្លួនប្រាណរបស់អាត្មាអញ ។

សត្វណាមានសន្ដានចិត្តសៅហ្មង ដោយសក្កាយទិដ្ឋិនេះហើយ សត្វនោះរមែងជាប់ដំណាក់ចិត្ត ខ្លឹងរូបកាយ ឬខន្ធ ៥ យ៉ាងស្អិត, រាឆ្នូងក្តេចខ្លួន, ក្តេចស្មារតី មិនដឹងថាខន្ធ ៥ នោះជាទោសសោះ ព្រោះខន្ធ ៥ នោះជាគំនរនៃទុក្ខ ខ្លឹងជាបន្ទុកមួយដ៏ធ្ងន់ គួរតប្បីតែទម្លាក់ចោលចេញកុំខានឡើយ ។ ដោយហេតុនេះ ទើបបណ្ឌិតលោកចាត់ទុកសក្កាយទិដ្ឋិនេះជាចំណងទី ១ ។

២- វិចិកិច្ឆា គឺសេចក្តីសង្ស័យ ។ ឯវិចិកិច្ឆានេះ សំដៅសេចក្តីសង្ស័យចំពោះហេតុបច្ច័យនៃខន្ធ ៥ ក្នុងកាលទាំង ៣ មាន ១៦ ប្រការ មានសេចក្តីសង្ស័យថាអាត្មាអញកាលពីអតីតភ្លាមបានកើតមែនឬជាដើម ។

ឯវិចិកិច្ឆានេះ កាលបើមានកើតកង់ខន្ធសន្តានៃសត្វហើយ រមែងជាហេតុធ្វើឲ្យសត្វនោះវង្វេងក្នុងភ្លាំងស្មារតី ពុំដឹងច្បាស់នូវហេតុបច្ច័យដែលជាដើមកំណើតនៃខន្ធ ៥ ព្រមទាំងពុំដឹងច្បាស់នូវទុក្ខដែលអាចឲ្យរលាស់ខ្លួនចេញផុតពីខន្ធ ៥ នោះទៀត ។

ដោយហេតុនេះ ទើបវិចិកិច្ឆាត្រូវទុកជាចំណងទី ២ ដោយប្រការដូច្នេះឯង ។

៣- ស័ីលព្វតបរាមាស គឺសេចក្តីជឿចូលចិត្តកប់អាទន្ធវ៍ថ្កុំប្រតិបត្តិខុសច្បាប់ទន្ធ ។ ឯស័ីលព្វតបរាមាសនេះ សំដៅសេចក្តីជឿហើយត្បាយាមបដិបត្តិ តាមវត្តបដិបត្តិក្រៅភ្នែសាសនាដែលជាវត្តបដិបត្តិខុសច្បាប់ទន្ធ ពុំអាចនឹងដឹកនាំដំណើរសត្វឲ្យឆ្ពោះទៅកាន់មគ្គ ផល និព្វានបានឡើយ ។ ដោយហេតុនេះ បានជាបណ្ឌិតលោកចាត់ទុក ស័ីលព្វតបរាមាស ជាចំណងទី ៣ ។

៤- កាមរាគ គឺសេចក្តីត្រេកកង់កាម ។ ឯកាមរាគនេះ សំដៅសេចក្តីត្រេកត្រអាលចំពោះវត្ថុកាម្មណ៍ គឺអារម្មណ៍ដែលជាទីគាប់ចិត្តមានរូបជាដើម ។ ឯកាមរាគនេះ កាលបើមកកើតកង់ខន្ធសន្តានៃសត្វណាហើយ រមែងញាំងសត្វនោះឲ្យជាប់ជំពាក់ចិត្តនឹងកាមគុណ្ហា គឺសេចក្តីប្រាថ្នាចង់ឲ្យបានកើតកង់កាមភពជាលំដាប់ ។ ដោយហេតុនេះ បានជាកាមរាគត្រូវទុកជាចំណងទី ៤ ។

๕- ปฏิฆ: គឺសេចក្តីថ្នាំងថ្នាក់ចិត្ត ។ ឯបដិឃៈនេះសំដៅសេចក្តីថ្នាំងថ្នាក់ចិត្ត ដោយអំណាច គឺអារម្មណ៍ដែលមិនជាទីពេញចិត្តមានរូបជាដើម ។ ឯបដិឃៈនេះកាលបើកើតកន្លងខន្ធសន្តានខ្លួនសត្វណាហើយ រមែងញ៉ាំងសត្វនោះឲ្យអាក់អន់ចិត្ត, ឲ្យគាស់ចិត្ត, ឲ្យខឹងក្រេវក្រោធចំពោះអនិដ្ឋារម្មណ៍នោះ ដែលជាហេតុនាំឲ្យត្បាថា គឺសេចក្តីគុំគួនខឹងធ្វើអ្នកដទៃឲ្យវិនាសកើតមានច្រើនជាលំដាប់ ។ ដោយហេតុនេះ ចានជាបណ្ឌិតលោកចាត់ទុក បដិឃៈជាចំណែកទី ៥ ។

៦- រូបរាគ គឺសេចក្តីត្រេកត្រអាលចំពោះរូបភព ។ ឯរូបរាគនេះ ជាតវាគ គឺជាតម្រេកចង់កើតកន្លងកើត, កាលបើកើតកន្លងសន្តានចិត្តសត្វណាហើយ រមែងតែញ៉ាំងសត្វនោះឲ្យជាប់ដំពាក់ចិត្តខ្លាំងតវាគណា គឺសេចក្តីស្រេកឃ្លានឲ្យចានកើតកន្លងរូបភពជាលំដាប់ ។ ដោយហេតុនេះ រូបរាគនោះត្រូវចាត់ទុកជាចំណែកទី ៦ ។

៧- អរូបរាគ គឺសេចក្តីត្រេកត្រអាលចំពោះអរូបភព ។ ឯអរូបរាគនេះជាតវាគ គឺតម្រេកចង់កើតកន្លងកើតដែរ, កាលបើកើតកន្លងខន្ធសន្តានខ្លួនសត្វណាហើយ រមែងញ៉ាំងសត្វនោះឲ្យជាប់ដំពាក់ចិត្តខ្លាំងតវាគណា គឺសេចក្តីស្រេកឃ្លានឲ្យកើតកន្លងអរូបភពជាលំដាប់ ។ ដោយហេតុនេះ ចានជាបណ្ឌិតលោកចាត់ទុក អរូបរាគនេះ ជាចំណែកទី ៧ ។

๘- មានៈ: គឺសេចក្តីប្រកាន់ខ្លួន ។ ឯមានៈនេះ សំដៅមានៈ ๗

ប្រការ គឺសេចក្តីប្រកាន់ខ្លួនថា អាត្មាអញប្រសើរជាងគេ ១ អាត្មាអញស្មើនឹងគេ ១ អាត្មាអញអន់ថយជាងគេ ១ ។

កាលបើសត្វណាមានខន្ធសន្តានរសៀហ្មងដោយមានះ ត្រង់ប្រការណាមួយហើយ, សត្វនោះរមែងចុះបង់ចោលខ្លួរគេរណាយកិច្ចដែលកំពុងបំពេញ ព្រោះសត្វនោះគិតយើញថា អាត្មាអញបានប្រសើរជាងគេទៅហើយ, ឬគិតយើញថា អាត្មាអញបានស្មើនឹងគេទៅហើយ, ឬគិតយើញថា អាត្មាអញអន់ថយជាងគេភាក ដែលជាហេតុនាំឲ្យសត្វនោះពុំអាចនឹងសម្រេចខ្លួរឲ្យតួមប្រយោជន៍ជាទីបំផុតនោះបានឡើយ ។ ដោយហេតុនេះ ទើបបណ្ឌិតលោកចាត់ខ្លុកមានះជាចំណងទី ៩ ។

៩- ឧទ្ធច្ចៈ គឺសេចក្តីក្រយាយ ។ ឯឧទ្ធច្ចៈនេះ សំដៅសេចក្តីក្រយាយដែលញាំងចិត្តឲ្យរើរែកយកវែក មិនដឹងជាឆាកទៅខាងណាឲ្យប្រាកដសោះ ។ ឯឧទ្ធច្ចៈនេះ កាលបើកើតក្នុងខន្ធសន្តានរៃសត្វណាហើយ រមែងញាំងសត្វនោះឲ្យចាប់នេះចាប់នោះមិនឆ្ពោះត្រង់ណា ដែលជាហេតុនាំឲ្យសត្វនោះពុំអាចនឹងសម្រេចប្រយោជន៍អ្វីជាប្រាកដបានឡើយ។ ដោយហេតុនេះ បានជាឧទ្ធច្ចៈត្រូវបានចាត់ខ្លុកជាចំណងទី ៩ ។

១០- អវិជ្ជា គឺសេចក្តីល្ងង់ ។ ឯអវិជ្ជានេះ គឺសំដៅសេចក្តីល្ងង់៤ ប្រការ គឺល្ងង់មិនដឹងច្បាស់ខ្លួរខ្លុក ១, ល្ងង់មិនដឹងច្បាស់ខ្លួរហេតុនៃខ្លុក ១, ល្ងង់មិនដឹងច្បាស់ខ្លួរកិរិយារលត់នៃខ្លុក ១ នឹងល្ងង់មិនដឹង

ច្បាស់ខ្លួនវិបដិបត្តិ ដែលអាចញ៉ាំងកិរិយាលះតំនៃទុក្ខ ឲ្យសម្រេចឡើងបាន១ ។ គឺសេចក្តីល្ងង់ខ្លាំង ៤ នេះហើយ ដែលជាហេតុនាំសត្វឲ្យវង្វេងខឹកតិតរកទុក្ខយ ដើម្បីដោះខ្លួនឲ្យរួចផុតពីកងទុក្ខតុំយើញសោះឡើយ ។ ដោយហេតុនេះ ទើបអវិជ្ជាត្រូវបានចាត់ទុកជាចំណងទី ១០ ដោយប្រការដូច្នេះឯង ។

រីឯចំណង ១០ ប្រការនេះ មានចំណង ៣ ខាងដើម ទុកជាចំណងយ៉ាងមាំ ដែលអរិយបុគ្គលត្រូវព្យាយាមកាត់ផ្តាច់ឲ្យអស់ជាមុន ទើបជាហេតុនាំឲ្យកាត់ផ្តាច់នូវចំណង ៧ ទៀតបានដោយស្រួល គឺចំណង ១០ នេះហើយដែលនៅត្រឹមចាំ តែងចងសត្វទុកឲ្យនៅវិលកើតវិលស្លាប់លើត្រែគតជាប្រក្រតីមិនឲ្យសត្វដោះខ្លួនរួច ដើម្បីនឹងធ្វើដំណើរឆ្ងាយចេញចាកត្រៃលោកបានឡើយ ។

ដោយហេតុនេះ ទើបសំយោជនៈ ១០ ត្រូវចាត់ទុកជាបុព្វហេតុទី ២ ដែលកាត់ដាច់ជាសំមិនឲ្យលោកុត្តរចិត្តអាចសម្រេចកើតឡើងបាន ដោយប្រការដូច្នេះឯង ។

៤- ឆណ្ណា ៣ ប្រការ

ម្យ៉ាងទៀតបើតាមនិស្ស័យនូវលក្ខណៈនៃសំយោជនៈ ១០ នេះឲ្យបានល្អិតល្អៀតទៀត គេអាចដឹងបានថា គឺសំយោជនៈ ១០ នេះហើយដែលទុកជាបច្ច័យតាក់តែងនូវតណ្ហា ៣ ប្រការគឺ កាមតណ្ហា ១, ភវតណ្ហា ១,

ទីនេះ វិភវតណ្ហា ១ ឈ្មោះថា ជាតិដែលប្រព្រឹត្តទៅក្នុងភពទាំងឡាយ ដែលជាប្រក្រតីនោះ ។

មែនពិតមែន សំយោជនៈ ៥ ខាងដើមដែលជា ឱរម្ភាគិយសំយោជនៈ ត្រូវបាត់ទុកជាបច្ចយតាក់តែងនូវកាមតណ្ហា ឈ្មោះថា ជាតិដែលប្រព្រឹត្តទៅបានជាជម្មតា, ហើយសំយោជនៈ ៥ ខាងចុងដែលជា ឧទ្ធម្ភាគិយសំយោជនៈ ត្រូវបាត់ទុកជាបច្ចយតាក់តែងនូវភវតណ្ហា ទីនេះ ភវតណ្ហា ឈ្មោះថា ជាតិដែលប្រព្រឹត្តទៅបានជាប្រក្រតីនោះ ។ តណ្ហា ៣ ប្រការនេះហើយ ដែលជាមេដាំដុះនៅត្រឹមតែបានទៅជា ភព ៩ ឈ្មោះកើតមានក្នុងកាលជាខាងមុខទៀតជានិច្ចនោះ ។

ម្យ៉ាងទៀត កាមតណ្ហា, ភវតណ្ហា, ទីនេះ វិភវតណ្ហា នោះ បណ្ឌិតលោកចាត់ទុកជាអន្លាក់កាម ៣ សម្រាប់ចាំតែចាក់សត្វទុក មិនឲ្យសត្វអាចធ្វើដំណើរឆ្ងាយចេញរួចផុតចាកត្រៃលោកបានសោះឡើយ ។

ដោយហេតុនេះ ទើបតណ្ហា ៣ ប្រការត្រូវបាត់ទុកជាបុព្វហេតុទី៣ ដែលពាក់ព័ន្ធដាស់មិនឲ្យសោកុត្តរចិត្តអាចសម្រេចកើតឡើងបាន ដោយប្រការដូច្នេះឯង ។

(នៅមានត)

ព្រះអភិធម្មបិដក

គម្ពីរព្រះយេមកា:

លោក ប៊ី - ប៊ី ប្រែរៀបរៀង

(តមក)

កាលសុរុចិព្រាហ្មណ៍ កំពុងតែដើរបណ្តើរគិតបណ្តើរដូច្នេះ អាការដំណើរ កំភើតមានដល់បណ្តាកម្ពលសិលាសន៍ នៃសម្តេចអមរិន្ទ្រទេវរាជ ទ្រង់គាវដ្ឋនាការតិចារណាមើល កំជ្រាបរឿងនោះច្បាស់ ក្នុងព្រះហឫទ័យ ទើបចុះចាកតាវត្តឹង្សមកកាន់មនុស្សលោក ហើយនិម្មិតជានាយជាងឈើមកឈរនៅចំពោះមុខសុរុចិព្រាហ្មណ៍ ហើយមានទេវបញ្ញត្រាស់សួរព្រាហ្មណ៍ថា បុគ្គលណាត្រូវការកដួលជាងឈើដែរឬទេ ។ សុរុចិព្រាហ្មណ៍ឮពាក្យនោះត្រេកអរណាស់ ធ្វើយយាំងរហ័សថា ខ្ញុំបាទនិមន្តសម្តេចព្រះភុវនេត្រអង្គព្រមទាំងព្រះភិក្ខុសង្ឃជាបរិវារ នឹងឲ្យមកទទួលអាហារបិណ្ឌបាតគង់នៅគេហស្ថានរបស់ខ្ញុំ ប៉ុន្តែ ខ្ញុំគ្មានមណ្ឌបនឹងអាសនៈប្រគេនលោកម្ចាស់ទាំងអស់នោះគង់ទេ អ្នកចូរសង្គ្រោះដល់ខ្ញុំជួយធ្វើមណ្ឌបឲ្យបានន៎ាវេលាព្រឹកស្អែកនេះ ។ សម្តេចព្រះវជិរបាណីកំទទួលពាក្យធ្វើជាមណ្ឌបដោយទេវឫទ្ធិ ធ្វើពុទ្ធាសនៈជាតិគង់នៃព្រះពុទ្ធអង្គ នឹងអាសនៈដែលព្រះភិក្ខុសង្ឃ នឹងគង់ធ្វើកក្តកក្តិច ។ ព្រះឥន្ទនិម្មិតស្រេចហើយ គឹត្រឡប់ទៅទេវលោកវិញ ។

លុះព្រឹកព្រាងស្ងាងព្រះសុរិយោឡើងហើយ សម្តេចព្រះភុទ្ធអង្គទាំ
ព្រះកិក្ខុសង្ឃមកទទួលបិណ្ឌបាតខាន សុរុចិព្រាហ្មណ៍ថ្វាយចង្ហាន់បិណ្ឌ-
បាតចំពោះសម្តេចព្រះភុទ្ធអង្គព្រមទាំងព្រះកិក្ខុសង្ឃជាបរិវារ ។ លុះព្រះ
ភុទ្ធអង្គព្រមទាំងព្រះកិក្ខុសង្ឃធ្វើកត្តកិច្ចស្រេចហើយ ក៏ទៅគង់នាការលៀត
ព្រះវិហារវិញ ។

សុរុចិព្រាហ្មណ៍បានបំពេញតាមចិត្តខាន តែឲ្យបេះត្រៃរូបកាង
កាយទ្វេនៅជាខាងយ៉ាងច្រើនដល់ម្ល៉ោះហើយ ក៏នៅតែមិនខាន់ស្លាប់ចិត្ត
គិតចង់ឲ្យអស្ចារ្យខាន តែឲ្យអាយុវែងកូនកាងកាយទ្វេនៅជាខានទៀត ក៏
ក្តៅទៅដល់អាសនៈព្រះឥន្ទ្រ ទ្រង់ជ្រាបហេតុនោះហើយ ស្តេចចុះពីតា-
វត្តឹង្សត្រិតភពមិម្តិតកេះជាព្រាហ្មណ៍ចូលទៅសួរក្តែរបេះសុរុចិព្រាហ្មណ៍ ។
គ្មានចិត្តតក់ស្លុតញាប់ញ័រសោះ ត្រែកអរណាស់ ក៏ឆ្អៀលក្តែតាំងភ័រ
ខាងដាក់ខានដោយសទ្ធាជ្រះថ្លា ។ ព្រះឥន្ទ្រទទួលយកក្តែកមកហើយ
ក៏បណ្តាលឲ្យក្តែកាំងគូ នៃសុរុចិព្រាហ្មណ៍ត្រឡប់កើតមានជាប្រក្រតីដូច
ដើមវិញ ដោយទេវឫទ្ធិ រួចហើយយាងត្រឡប់ទៅគង់ទេវលោកវិញ ។

ការដែលសុរុចិព្រាហ្មណ៍បានបំពេញខាន នឹងធ្វើការជាកុសល
តាំងអស់ខោះឈ្មោះថា ការកុសលបន្តឹតអំពីកុព្វារ ព្រោះថាបានឃើញ
ព្រះស្មើនៃព្រះសុមន្តលសាស្តាចារ្យ ហើយទើបបានកើតសទ្ធាជ្រះថ្លាធ្វើ
ការកុសល ។

ចំណែកការស្តាប់វិញ សម្រេចដោយការចូនឮចូនស្តាប់សម្លេងអ្វីៗ ហើយកើតសទ្ធាជ្រះថ្លាប្រាថ្នាខ្ជិនធ្វើការជាកុសល ក៏ចូនឈ្មោះថា កុសលបន្ថែតអំពីសោតទ្វារ ។

បើចូនធុំក្លិនអ្វីៗហើយ តែតប្រុងខ្ជិនធ្វើការជាកុសល ក៏ចូនឈ្មោះថា កុសលបន្ថែតអំពីឃានទ្វារ ។

បើចូនលិទ្ធក្លែក្លាសអ្វីៗ ហើយតែតចង់ធ្វើការកុសល ក៏ចូនឈ្មោះថា កុសលបន្ថែតអំពីជិវ្ហាទ្វារ ។

បើចូនតាល់ត្រូវខ្លួវគ្រឿងសម្ផស្សដោយកាយហើយ កើតចិត្តសទ្ធាជ្រះថ្លាក្នុងការកុសល ក៏ចូនឈ្មោះថា កុសលបន្ថែតអំពីកាយទ្វារ ។

បើត្រិះរិះតែតហេតុចាំង់ឮយដែលជាកុសលហើយប្រុងខ្ជិនធ្វើកុសលនោះ ក៏ចូនឈ្មោះថា កុសលបន្ថែតអំពីមនោទ្វារ

អ្នកប្រាជ្ញតម្រាំសន្ទិដ្ឋានចូលចិត្តចុះថា ការជាកុសលនឹងការជាអកុសលចាំង់ពីរប្រការនេះ ក៏បន្ថែតអំពីទ្វារឬអាយតនៈចាំង ១២ ដោយន័យដែលចូនរៀបរាប់មកហើយខាង់ដើមនោះ គ្រាន់តែការជាអកុសលផ្ទុយនឹងការជាកុសលប៉ុណ្ណោះ ឯរបៀបបន្ថែតអំពីទ្វារ ឬអាយតនៈចាំង ១២ ប្រការដូចគ្នា ពោះជាកុសលក្តី ជាអកុសលក្តី ។

អាយតនយមកៈ ចប់ ។

X

X X

ជាតុយមកៈ

អដ្ឋារសធាតុយោ ចក្ខុធាតុ សោតធាតុ ឃានធាតុ ជិវ្ហាធាតុ កាយធាតុ មនោធាតុ រូបធាតុ សទ្ទធាតុ គន្ធធាតុ រសធាតុ ផោដ្ឋព្វធាតុ ធម្មធាតុ ចក្ខុវិញ្ញាណធាតុ សោតវិញ្ញាណធាតុ ឃានវិញ្ញាណធាតុ ជិវ្ហាវិញ្ញាណធាតុ កាយវិញ្ញាណធាតុ មនោវិញ្ញាណធាតុ។

លំដាប់អំពីអាយតនយមកៈ សម្តេចព្រះបរមសាស្តា ទ្រង់ត្រាស់ទេសនាធាតុយមកៈតទៅទៀត មានសេចក្តីថា ឧភតិឧភៃ ព្រះមានព្រះភាគជាសុទ្ធិទៅតាកន្ធដ៏បដិទ្ធទៅតាតាំងឡាយ គឺសម្មត្តទៅតានឹងមិច្ឆត្តទៅតា កាលព្រះអង្គត្រាស់ទេសនាទូវអាយតនយមកៈចប់ប្លែកហើយ ទើបទ្រង់ត្រាស់ទេសនាទូវធាតុយមកៈតទៅទៀត ។ ធាតុយមកៈនោះ ទ្រង់ត្រាស់សំដែងនូវធាតុតាំង ១៨ ប្រការ ។

ឯធាតុតាំង ១៨ ប្រការនោះគឺ ចក្ខុធាតុ ១ សោតធាតុ ១ ឃានធាតុ ១ ជិវ្ហាធាតុ ១ កាយធាតុ ១ មនោធាតុ ១ រូបធាតុ ១ សទ្ទធាតុ ១ គន្ធធាតុ ១ រសធាតុ ១ ផោដ្ឋព្វធាតុ ១ ធម្មធាតុ ១ ចក្ខុវិញ្ញាណធាតុ ១ សោតវិញ្ញាណធាតុ ១ ឃានវិញ្ញាណធាតុ ១ ជិវ្ហាវិញ្ញាណធាតុ ១ កាយវិញ្ញាណធាតុ ១ មនោវិញ្ញាណធាតុ ១ គ្រប់ជាធាតុ ១៨ ប្រការ ។

ព្រះពុទ្ធអង្គទ្រង់ត្រាស់ទេសនាជាគុយមកនោះ កំទ្រង់ត្រាស់បុច្ឆា ជាគួរ ត្រាស់វិសជ្ជនាជាគួរ ។ ទ្រង់ត្រាស់បុច្ឆាថា ចក្ខុនោះឬ ឈ្មោះថា ចក្ខុជាតុ ? ចក្ខុជាតុនោះឬ ឈ្មោះថា ចក្ខុ ?

ទ្រង់ត្រាស់វិសជ្ជនាថា អាមន្តា អើ ចក្ខុនោះឈ្មោះថា ចក្ខុជាតុ នោះឯងហើយឈ្មោះថា ចក្ខុ ។

អ្នកប្រាជ្ញគប្បីសន្និដ្ឋានចូលចិត្តថា ព្រះពុទ្ធអង្គទ្រង់ត្រាស់បុច្ឆានឹងវិសជ្ជនាក្នុងចក្ខុជាតុដូចម្តេច កំទ្រង់ត្រាស់បុច្ឆានឹងវិសជ្ជនាក្នុងជាតុទាំង. ខ្សាយមានសោតជាតុជាដើម មានធម្មជាតុជាបរិយោសាន ដូច្នោះដែរ ។

ចក្ខុជាតុនោះ ចាន់ដល់ចក្ខុ មានសេចក្តីដូចគ្នានឹងចក្ខុបសាទ តែផ្សេងអំពីអាយតនៈ ព្រោះអាយតនៈប្រែថា ជាទីកើត ឯជាតុប្រែថា ជាទីទ្រទ្រង់ទុក ។

សម្តេចព្រះមានព្រះភាគទ្រង់ត្រាស់ទេសនាក្នុងជាតុទាំង ១៨ ប្រការនោះ ដោយអំណាចមានព្រះពុទ្ធបំណងនឹងឲ្យព្រះយោគាវចរកុលបុត្រពិចារណាខ្លួនជាតុទាំងពួងនោះ ឲ្យឃើញថាជារបស់សូន្យ ជារបស់ទទេ, ជារបស់ល្បួងលួងលោមមនុស្សសត្វ ឲ្យលះចំណង់វង្វេងនៅក្នុងវដ្តសង្សារមិនឲ្យគេចរួចពីផ្លូវកន្ទារ គឺជាតិ ជរា ព្យាធិនឹងមរណៈទាំងបាន ។

ប៉ុន្តែ បុគ្គលដែលអាចនឹងពិចារណាឲ្យឃើញថា ជាតុទាំងអស់នោះជារបស់សូន្យ, ជារបស់ទទេ ត្រូវអាស្រ័យមានសតិ ទើងសម្បជញ្ញៈ ។

កន្លះនេះ លើកសតិទុកដោយឡែកមិនអធិប្បាយទេ សូមអធិប្បាយតែ
សម្បជញ្ញៈមួយចំណែកប៉ុណ្ណោះ ។ តាមតិត សតិជាគ្រួនឯសម្បជញ្ញៈ ។
សតិគឺស្មារតី តែឯកើតមុនសម្បជញ្ញៈជាដរាប បើគ្មានសតិគឺស្មារតីទេ
សម្បជញ្ញៈក៏គ្មានដែរ ។ បើមានសតិគឺស្មារតីហើយ ទើបមានសម្ប-
ជញ្ញៈ ។ ហេតុនេះ សូមជ្រាបដោយន័យថ្វីថា បើមានសម្បជញ្ញៈ
ណា ណាមួយនោះឈ្មោះថា មានសតិ គឺស្មារតីជាមុនរួចមកហើយ ។

អធិប្បាយអំពីសម្បជញ្ញៈ

ចតុព្វិធំ ហិ សម្បជញ្ញំ ។ សម្បជញ្ញៈ ប្រែថា សេចក្តីដឹង
ខ្លួន ។ សម្បជញ្ញៈមានលក្ខណៈឲ្យដឹងខ្លួនពាក់កន្លងវេលាកំពុងធ្វើ, កំពុង
និយាយ, កំពុងគិត តម្រែតម្រង់អំពើ, សំដីនឹងគំនិតនោះឲ្យបានល្អត្រឹម
ត្រូវតាមផ្លូវដែលសតិឆ្លុះឃើញរួចមកហើយនោះដរាបទៅ ។ សម្បជញ្ញៈ
មានកិច្ចឲ្យកំចាត់បង់នូវសេចក្តីខ្ជិលច្រអូស នឹងគំនិតលួងលំភ្លេចកន្លងវេលាធ្វើការងារ
ជាដើម ។ សម្បជញ្ញៈ មានផលដោយធ្វើឲ្យអំពើ, សំដី នឹងគំនិតត្រឹម
ត្រូវល្អ ឥតខ្ចុស មិនអាក្រក់ ។

(នៅមានត)

สម្តែងព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង

ព្រះញាណកោសល ញាណ-ឈិន ភិនន្ទ

(តមក)

តស្មា សោ នារុណោ យក្ខោ ឥស្សា តំ សរណា ឋិតំ
ខុត្តិតោវ កយប្បត្តោ លោមហត្ថោវ ឆម្ភិតោ ។

ព្រោះហេតុដូច្នោះ យក្សកាចអាក្រក់នោះ ឋានឃើញទុក្ខសកវដ្ដ
ឋិតនៅក្នុងពុទ្ធសរណៈ ក៏ភ្ញាក់ភ័ន្តតក់ស្លុត ព្រឺព្រួចពេម
មានកាយញាប់ញ័រខ្លួនតក់ត ។

កមន្តោ ជានិតំ ឥស្សា តិកេវ សុវិយុក្ខតា
សិទ្ធលិតុលកដ្ឋិវ មណ្ឌាកនេន ហារិតំ ។

លុះយក្សឋានឃើញបុរសអ្នកជនបទគោលថា តុច្ចំ ជាដើមហើយ
ក៏ស្លុតរលត្បិតខ្លួនស្ទុះរត់ទៅខាងក្រៅ ដូចជាព្រះអាទិត្យរះឡើងហើយ
កំចាត់ងងឹតចេញទៅខាងក្រៅដូច្នោះផង ដូចជាបុំយរកា ឬ បុំយតរលែ
អណ្តែតឡើងដោយខ្យល់ទាំកួចបន្ទក់ទៅដូច្នោះឯង ។

យំ ទុក្ខំ ភដទោភនិ យក្ខបេតានិសម្ភវំ
និច្ចន្តេន មនុស្សេន កន្តព្វំ សរណាគ្គយំ ។

សេចក្តីទុក្ខណាដែលកើតអំពីមនុស្ស មានស្តេចនិងចោរជាដើមក្តី

ខុក្ខវៃដលកើតអំពីអមនុស្សមានយក្សទឹងប្រែតជាដើមក្តី ជនមានសន្តានខ្ពស់ អ្នកមិនប្រាថ្នាខ្លួវសេចក្តីខុក្ខពាធអំបាលនោះ ត្រូវតែយកព្រះរតនត្រ័យជាទីបំ តឺ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងដោយពិត ។

យោ ច ពុទ្ធញ្ច ធម្មញ្ច សំឃញ្ច សរណាគតោ
សោ តំ សរណមាគម្ម សព្វទុក្ខា បមុច្ចតិ
ចត្តារិ អរិយសច្ចានិ សម្មប្បញ្ញាយ បស្សតិ ។

បុគ្គលណាមួយបានដល់ខ្លួវព្រះពុទ្ធផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹងទីលើកហើយ, បុគ្គលនោះទឹងរួចពាកខុក្ខពាធពួង ទឹងបានត្រាស់ដឹង នូវព្រះអរិយសច្ចៈពាន់បួនដោយប្រាជ្ញាដ៏ឧត្តម ព្រោះអាស្រ័យនូវអានិសង្សនៃត្រៃសរណាគមន៍នោះឯង ។

លំដាប់នោះ បុរសអ្នកជនបទកំបានដឹងជាក់ច្បាស់ដោយខ្លួនឯងនូវគុណទឹងអានិសង្សព្រះត្រៃសរណាគមន៍ដ៏ប្រសើរ ពាន់បានដល់នៅអាបាណរកាដ៏សរណាគមន៍ តឺដល់នូវព្រះពុទ្ធជាទីពឹង មានដីតែជាទីបំផុតដូច្នេះថា ខ្ញុំព្រះអង្គសូមគោរពកក្តឹងព្រះពុទ្ធជាម្ចាស់ សូមដល់នូវព្រះពុទ្ធជាទីពឹងមានដីតែជាទីបំផុត ។ បុរសនោះកំបានដល់នូវព្រះពុទ្ធជាទីពឹងដូចបានតាំងនាហើយ, ដោយអំណាចផលានិសង្សនោះ លុះឆ្នើមរណកាលក្រោយ ក្រោយដីតែ កំបានអន្តោលទៅកើតកក្តឹងឋានទេវលោក ក្តឹងមួយរំពេចបីដូចជាបុរសក្បាក់អំពីដេកលក់ បានសោយសម្បត្តិទិព្វពាន់ ១០

ប្រកាសជាអស្ចារ្យក្រៃលែង ព្រោះហេតុដូច្នោះ ព្រះគន្ធវចនាចារ្យលោក
ពោលជាបទព្រះគាថាដូនខ្មែរថា:

ឥស្សាធ ឃរំ សរណំ កច្ចន្តំ
អបេន្តិ យក្ខាបិ មហាភយេន
តាលេថ សីលំ សរណាញ្ច តស្មា
ឥហាថ ធុក្កំ សុកតឹ កវ៉ាភ្លៃ ។

អធិប្បាយថា ចំណែកឯយក្សទាំង ដែលមានសម័ក្តីធំ លុះបាន
ឃើញទុក្ខសក ដែលបានដល់នូវព្រះសរណាគមន៍ជាអស្ចារ្យយ៉ាងនេះ
ហើយ ក៏មានសេចក្តីតក់ស្លុតខ្លាំងរត់ចៀសចេញទៅគ្រានោះឯង ។

ព្រោះហេតុដូច្នោះ អ្នកជាសប្បុរសចាំងឡាយ ត្រូវតែរក្សាសីលនឹង
សរណាគមន៍ឲ្យខ្ជាប់ខ្ជួន ត្រូវលះបង់នូវសេចក្តីទុក្ខ ហើយសេពគប់នូវ
សុគតិភពវិញហោង ។

សម្តែងរឿងនិទាន មនុស្សបញ្ឆោតយក្សជាបឋមកថាវគ្គទី៣ ចប់
ដោយសង្ខេបតែប៉ុណ្ណេះឯង ។

X X X

២- មិញ្ជាឥដ្ឋវត្ថុកថា

សម្តែងរឿងនិទាន ពីកុមារជាបុត្តនៃជនជាអ្នកមិច្ឆាទិដ្ឋិ តរៀនខ្មែរ
ដោយឈ្មោះចុលសិថា កកវតិ បរិនិព្វុតេ ដូច្នេះជាដើម អធិប្បាយថា

v កាលព្រះមានព្រះភាគទ្រង់ចូលចំណែកទីភ្លាន់ទៅហើយ ក៏មានឮមកថា មាន
ព្រាហ្មណ៍ម្នាក់ជាមិច្ឆាទិដ្ឋិ ទៅអាស្រ័យក្នុងឥន្ទគរកជគ្រឹះ ហើយមាន
ព្រាហ្មណ៍ម្នាក់ទៀតជាសម្មាទិដ្ឋិ ទៅអាស្រ័យក្នុងឥន្ទគរនោះដែរ ។

ព្រាហ្មណ៍ចាំងពីរនាក់នោះ មានបុត្តប្រុសមួយ ។ ម្នាក់ ។
ឯកុមារចាំងពីរនាក់នោះ តែងលេងអង្គញ់ភ្លាស់គ្នាកុងធំជាមួយគ្នា ពុំ
ដែលដាច់ ។

លុះចំណេរកាលមកជាខាងក្រោយ បណ្តាកុមារចាំងពីរនាក់នោះ
មុនកាលលេងអង្គញ់ភ្លាស់គ្នា កុមារជាបុត្តនៃព្រាហ្មណ៍អ្នកសម្មាទិដ្ឋិ មុន
ធំជាងបោះអង្គញ់ទៅក៏ពោលថា ឧមោ តុន្ទ សុ្ន ហើយបោះអង្គញ់ទៅ
តែងបានឈ្នះកុមារជាសំឡាញ់នោះសត្វថ្ងៃជាដរាប ។

ឯកុមារជាបុត្តនៃព្រាហ្មណ៍អ្នកមិច្ឆាទិដ្ឋិ កាលដែលធំជាងបោះអង្គញ់
ទៅក៏ពោលថា ឧមោ ព្រាហ្មណោ ហើយបោះអង្គញ់ទៅ តែងតែ
ចាញ់កុមារជាបុត្តនៃព្រាហ្មណ៍អ្នកសម្មាទិដ្ឋិសត្វ ។ ថ្ងៃ ។ លុះថ្ងៃមួយ
ជាខាងក្រោយ កុមារជាបុត្តនៃព្រាហ្មណ៍អ្នកមិច្ឆាទិដ្ឋិ បានឃើញកុមារ
ជាបុត្តនៃព្រាហ្មណ៍អ្នកសម្មាទិដ្ឋិ ចេះតែបានឈ្នះខ្លួនជាដរាបដូច្នោះហើយ
ក៏សួរថា ម្នាលសំឡាញ់មានឆុះស្ទើ! សំឡាញ់អ្នកតែងបានឈ្នះខ្ញុំជាដរាប
បុះមុនធំជាងបោះអង្គញ់ទៅ តើអ្នកគោលខ្ជិលាក្យថាដូចម្តេចខ្លះ ? ។

ឯកុមារជាបុត្តព្រាហ្មណ៍ អ្នកសម្មាទិដ្ឋិបានស្តាប់ហើយ ក៏ឆ្លើយ

ទ្រង់ប់ថា ម្នាលសំឡាញ់! ខ្ញុំគោលថា ឧមោ តុន្ទុសឬ ហើយខើបចោះអង្គញ់ៅ ចានជាខ្ញុំឈ្នះអ្នកឯងជាខិច្ច ។

ឯមិច្ចាទិដ្ឋិកបុគ្គ ចាប់ដើមអំពីកាលនោះមកតែងគោលថា ឧមោ តុន្ទុសឬ ហើយខើបចោះអង្គញ់ៅជាខិច្ច ដូចសំឡាញ់របស់ខ្លួនដែរ ។

កាលដែលកុមារទាំងពីរនាក់នោះ ចានគោលដូចគ្នាថា ឧមោ តុន្ទុសឬ ដូច្នេះហើយ ខើបចោះអង្គញ់ៅកំចានឈ្នះនឹងញាស្មើ ។ គ្នាតុំលើសតុំខ្វះគ្នាឡើយ ។ លុះដល់កាលជាខាងក្រោយទៀត សម្ចាទិដ្ឋិកបុគ្គ ចានចេញៅរកកាប់ទុសជាមួយនឹងបិតារបស់ខ្លួន ហើយចានដឹករនេះទុសត្រឡប់មកវិញ កំជាក់រនេះឈប់សម្រាកក្នុងទីជិតក្រុង ហើយលែងគោទ្បើចេញៅរកស្មៅបរិភោគក្នុងកាលនោះឯង ។

ចំណែកឯគោនៃនាយរនេះនោះ ភារដើរស្វែងរកស៊ីស្មៅរឿង ។ ៅកំចានចូលៅខាងក្នុងទីក្រុងជាមួយនឹងហ្វូងគោទាំងឡាយដែរៅ ។

កាលនោះបិតារបស់កុមារ កំរំដើរស្វែងរកគោតុំចានបានឃើញ ខើបនិយាយៅនឹងបុគ្គថា ម្នាលចា! ឯងត្រូវត្រឡប់ៅមើលរនេះវិញចុះ លុះនិយាយហើយកំដើរតាមរកគោ ដែលចូលៅក្នុងទីក្រុងកាលនោះឯង ។

គេលនោះ ជាវេលាសាយណ្ហាសម័យថ្ងៃល្ងាចដិតយប់ មនុស្សតាំងឡាយ ដែលរក្សាទ្វារក្រុងតំគេបបួលគ្នាចាក់សោបិទទ្វារក្នុងវេលានោះដែរ

ឯបុរសជាបិតាពុំអាចនឹងចេញមកបានឡើយ ។

លំដាប់នោះ កុមារនៅចាំរង់ចើរចាំមើលផ្លូវបិតាក៏ពុំបានឃើញបិតាត្រឡប់មកសោះឡើយ ហើយក៏ដេកតែម្នាក់ឯងនៅក្រោមរោងទុសលន់លក់ទៅ ឮដំបាងក្រៅទីក្រុងនោះហោង ។

កងរក្សាយប់នោះមានយក្សតិរនាក់ យក្សម្នាក់ជាមិត្តទីដ្ឋ យក្សម្នាក់ជាសម្លាទីដ្ឋ យក្សទាំងពីរនាក់នោះជាសំឡាញ់នឹងគ្នា ហើយបណ្តើរគ្នាចេញទៅស្វែងរកចំណីតាមហានេនឹងបរិភោគ ក៏បានឃើញកុមារតូចម្នាក់ដេកនៅខាងក្រោមរោងនោះ ។ បណ្តាយក្សទាំងពីរនាក់នោះ ឯយក្សជាមិត្តទីដ្ឋក៏និយាយថា អញនឹងចាប់កុមារតូចនេះទំពាស៊ីឥឡូវនេះឯង ។ ចំណែកយក្សជាសម្លាទីដ្ឋក្រៅនេះបានស្តាប់ហើយ ក៏ហាមឃាត់ថា: អ្នកឯងមិនត្រូវធ្វើយ៉ាងនេះទេ ដ្បិតកុមារនេះតែងតែសូត្រ ឥមោ តុទ្ធ សុទ្ធ ពុំដែលដាច់ឡើយ ។ ឯយក្សជាមិត្តទីដ្ឋពុំបានស្តាប់ ក៏តបវិញថា អញនឹងចាប់កុមារនេះទំពាស៊ីដោយតែឯង, កាលបើយក្សជាសម្លាទីដ្ឋនេះឃាត់តាមដងមិនជាដ ក៏ពុំបានស្តាប់ឡើយ ហើយស្ទុះទៅចាប់ដើងកុមារនោះពាក់ត្រាក់មកដើម្បីនឹងសំឡាប់ ហើយទំពាស៊ីជាអាហារ ។ណៈនោះ កុមារភ្ញាក់ឡើងតបថា: ឥមោ តុទ្ធ សុទ្ធ ។ ញាប់មាត់ដោយបុព្វចរិតដែលខ្លួនធ្លាប់សន្សំទុកមកអស់កាលជាយូរហើយ ។

ឯយក្សដាមិច្ឆាទិដ្ឋិលុះបានស្តាប់ភាក្យកុមារនោះពោលថា ឯមោ ពុទ្ធិស្ស ដូច្នេះហើយ កំដល់នូវសេចក្តីតក់ស្លុតតក់ស្លុតយ៉ាងក្រៃពន្លត់ ត្រឹត្រួចរកមាលែងដៃជាប្រញាប់ហើយចុះក្រោយមកឈរក្នុងទីឆ្ងាយ ។

(មានភាក្យតាំងត្រួតកោតស្ញប់ស្ញែងថា) ឧហ្ន៎ ! យើងតាំងឮភ្លាយគួរឃើញនូវអានុភាព នៃពុទ្ធគុណជាទីអស្ចារ្យពេកណាស់ កុមារតូចតុំបានថ្វាយខ្លួនឲ្យជាទីពឹងទេ ត្រាន់តែពោលថា ឯមោ ពុទ្ធិស្ស តែវិយោ នមស្សការចំពោះព្រះពុទ្ធ តែប៉ុណ្ណោះ ដោយចរិតដែលខ្លួនធ្លាប់សន្សំពុំកមកកំតន់មានផលានិសង្សដ៏វិសេសពន់ពេក តក់ស្លុតនឹងសេចក្តីចង្រៃ ឧបទ្រពតាំងពួន តុំបានកើតមានដល់កុមារនោះឡើយ, ចាំបាច់និយាយថ្វីដល់បុគ្គលដែលបានថ្វាយខ្លួនដល់ព្រះសម្មាសម្ពុទ្ធ ជាទីពឹងទីរលឹកស្មើដោយជីវិតនោះនឹងរឹងតែមានផលានិសង្ស ពុំតុបានស្មានពុំអស់ឡើយ, ព្រោះហេតុដូច្នោះ បានជាព្រះអរហន្តតាំងភ្លាយ លោកពោលជាបទព្រះគាថាដូច្នេះថា :

យថាបិ សិខិនោ ឆាឆំ កុដិតាឆំ កយោវហំ
ឯវំ តុន្ទោតិវចនំ អមនុស្សាឆំ កយោវហំ ។

អធិប្បាយថា កិរិយាបង្អាត់ដុតបំពាក់នូវគំនរភ្លើងឲ្យឆេះឡើងខ្ទាំងជាទីតាំមកនូវភ័យនឹងសេចក្តីតក់ស្លុតខ្លាំងដល់ពាក់តាំងភ្លាយ មានឧបមាយ៉ាងណា, ភាក្យដែលបុគ្គលពោលថា តុន្ទោ ៗ នេះ ជាភាក្យដ៏ក្លួម

នាំមកនូវភ័យនឹងសេចក្តីតក់ស្លុត ដល់អមនុស្សពាំនឹងឃ្លាយមានយក្សជាដើម ក៏មានឧបមេយ្យយ៉ាងនោះឯង ។

យថា មច្ចុស្ស ជម្ពុយ វិលយំ យាតិ តត្ថិ សំ
ឯវំ តុច្ឆាឧកាវេន កាយន្តិ តុណាថាឧតា ។

ពិសពស់ដ៏ក្លៀវក្លា អាចដល់នូវការលាយសូន្យទៅ ដោយកំរិះយ៉ាងណាមិញ យក្សពាំនឹងឃ្លាយដែលទំនាស់នូវសាកសពរមែងតិតភ័យតក់ទៅដោយភ្លុំខ្លាំនុភាព ក៏មានឧបមេយ្យយ៉ាងនោះឯង ។

អត្តិបត្តា យថា សិតំ ឧរគោវ លិយតិ
បត្វា ឯវំ សរណាគតំ បេតា បេត្តិវ ទ្ធរគោ ។

ដូចព្រះជាក់គោ លុះបានត្រូវកំដៅហើយ រមែងរលាយបាត់សូន្យទៅអំពីមុខយ៉ាងណា, ប្រេតពាំនឹងឃ្លាយ បើបានដល់នូវទីសំណាក់អាស្រ័យរបស់បុគ្គលអ្នកដល់នូវពុទ្ធរតនៈជាទីពឹងហើយ តែងតិតភ័យខ្លាចចៀសចេញទៅកាន់ទីឆ្ងាយដោយពិត ក៏មានឧបមេយ្យយ៉ាងនោះឯង ។

(នៅមានត)

លោក អ៉ឹម-ភន ចម្លងពីសាស្ត្រាស្ងឹកវិត

ព្រះពុទ្ធវង្ស ភ្នំម-ភ្នួរតំនិត្យ

(តមក)

ស្តេចទ្រង់ព្រះចំណាំដូច្នោះហើយ កំទ្រង់ព្រះតម្រែងថ្វែងព្រះខ្នួញ ខ្លួញពិលាបអាណិតអនាថពោធិសត្វហើយថា មេ្តចឡើយ អញកំយកភាក្យអាចារ្យតាំង ៤ ជាអ្នកតំណៀងអន្ធពាលស្រាលសេចក្តីស្រដីតាច់ថា មហាសធក្សត់ កំពុំពិចារណាខ្លួរអាថនោះឡើយ្រកាជ កំយកព្រះខ័នឲ្យ ទៅវាតាំង ៤ សម្លាប់កូនកំសត់បងំតាមចំណង់ក់ជាអ្នកខ្លៅ ទៅតាំនាំពាក្យ អតមង្គលមកប្រាប់អញ កំអញនោតដោយវាក់ ឧមហាសធបុត្រពុំដឹងអាតុកអើយ! អ្នកមានពាក្យនោះតើកេះ អតមានអ្នកឯណាមួយស្មើ រំអើតើ អញធ្វើនេះពុំគួរសោះឡើយ, ឧត្រឹកថ្ងៃស្អែកហើយ សមអញមិនយល់មុខទៅមហាសធអ្នកប្រាជ្ញ ឡើងមកតាល់ហ្មាទៅបំរើដោះសាសារតើ តាំងពួនឡើយ, ស្តេចខ្លួញដូច្នោះហើយ កំបែកញើសតេញតាំងព្រះអង្គ ទ្រង់ព្រះតំលាបធ្ងន់ពន់ប្រមាណ អតមានហៅសុខក្នុងព្រះហឫទ័យដល់តិចឡើយ ។ ឮដំកាលនោះ, នាងមុត្តវរលក្ខណ៍ ជាអយិអគ្គមហេសី ទើបនាងលើលាយាត្រាទៅតាន់ក្រឡាព្រះបន្ទំបរមសុខ នៃព្រះរាជស្វាមីដូចអំពីដើមប្រក្រតី, នាងយល់ស្តេចពុំសប្បាយកេះកាយដូចសព្វដង

នាងតិតក្នុងព្រះទ័យថា ព្រះមហាក្សត្រអ្នកមានបញ្ញាស់ ទីនេះមានន័ង
អ្នកឯណា ឬ ញាស់ខ្លះអញ ហើយនាងរំពឹងខ្លួនតែហុសបេះនាងខុស
នោះតុំយល់ឡើយ, ទើបតិតថា សមបើមានហេតុអ្វីមួយមកដល់អម្ចាស់
អញ តំតួអញទូលជណ្តើនហោង ហើយនាងសូត្រទូវព្រះគាថា
នេះថា :

កឹ តុំ វិមនោសិ ភជសេដ្ឋ
ឯបនិច្ច រថនំ សុណោមិ តេ តំ
កឹ ចិន្តយមានោ ឧម្មនោសិ
ន ហិ នេវិ អបភនោ អត្ថំ មយ្ហន្តិ ។

ព្រះនាងទូលថា បតិត្រព្រះមហាក្សត្រប្រសើរអើយ! អម្ចាស់មាន
ព្រះហឫទ័យតុំសប្បាយព្រោះហេតុអ្វី ? ឬអម្ចាស់មានបើរំពឹងដញ្ជឹងគិត
ខ្លួវអាថិម្តេច ? ឬមួយអញខ្ញុំមានបើខុសគ្គនឹទ្យេសៅហ្មងព្រះភជហឫទ័យ
នៃអម្ចាស់ទាស់ព្រះទេត្រ ? ដ្បិតហេតុនោះហោង ព្រះអង្គតុំសុខក្នុងព្រះ-
ភជហឫទ័យ, រីខ្លួនខ្ញុំបាម្តេតុំដឹងទោសខ្លួនជាមានសុភាតដូច្នោះ, បតិត្រ
អម្ចាស់អើយ! ខ្ញុំស្មានជាខ្លួនឥតទោសណាអម្ចាស់ ។

រីព្រះបាទវិទេហភជ ស្តេចស្តាប់នាងទូលទូវប្រការអម្បាលនោះ
ហើយ ស្តេចសូត្រទូវព្រះគាថានេះថា :

ปญฺญา วิชฺชา มหาสโต
อาณาตฺตา เม วิสาย ภูริปญฺโญ
ตํ จิรสฺสมาโน ธมฺมโสสฺมิ
ฯ หิ เรวิ อปกาโร อตฺถิ ตุยฺหนฺติ ฯ

ดูก่อนนางพระยาเรวดี ดูก่อนนางผู้เจริญ! ก็ท่านพระสารีบุตรเถระนี้ ได้ทำอุปการะแก่เราเป็นอันมาก ดูก่อนนางผู้เจริญ! ก็ในกาลใด เราได้ทำกาลกิริยาลงในกาลนั้น ท่านพระสารีบุตรเถระนี้ ได้ทำการสงเคราะห์เราด้วยอามิสทาน ด้วยธรรมทาน ด้วยอาการอันประเสริฐ ด้วยอาการอันไพบูลย์ ด้วยอาการอันยิ่งใหญ่ ด้วยอาการอันมากมาย ด้วยอาการอันกว้างขวาง ด้วยอาการอันหาประมาณมิได้ ด้วยอาการอันหาที่สุดมิได้ ด้วยอาการอันหาที่เปรียบมิได้ ด้วยอาการอันหาที่เทียบมิได้ ด้วยอาการอันหาที่เสมอมิได้ ด้วยอาการอันหาที่เทียมมิได้ ด้วยอาการอันหาที่เปรียบเทียบมิได้ ด้วยอาการอันหาที่เปรียบปานมิได้ ด้วยอาการอันหาที่เปรียบด้วยมิได้ ด้วยอาการอันหาที่เปรียบเสมอมิได้ ด้วยอาการอันหาที่เปรียบเทียมมิได้ ด้วยอาการอันหาที่เปรียบเท

តប្បីព្រះអង្គឲ្យសម្ងាប់ចោលបង់កុំស្តាយឡើយ ។ ស្តេចស្តាប់ពាក្យនាង
ខួលដូច្នោះហើយ រ៉ែកុតាំងសម្លាយកំសោយបង់មោង, ព្រះអង្គផ្ទុលក់
ជាសុខទៅហោង ។

កាលនោះ, នាងទុម្មេធវី ចូលទៅកន្ទំលាំទៅនាងហើយ ទើប
នាងសរសេរសំបុត្រ, ឯកន្ទំសេចក្តីសំបុត្រនោះថា " ឲ្យប្រាមប្រាប់
មហាសថឲ្យបានដឹង ដ្បិតអាចារ្យទាំង ៤ តាំងពាក្យមកក្រាបទូលព្រះ
មហាក្សត្រថា បាឯងតែងក្សត់ ស្តេចភ្ញាល់ទើបបង្គាប់ប្រើអាចារ្យទាំង ៤
ឲ្យមកឃ្លាំចាំទៅលង្វែកមាត់ទ្វារ ថាបើបាចេញមកនាព្រឹកស្អែក គេ
នឹងសម្ងាប់បាពុំខាន, ហេតុនេះ កុំប៉ះបាឡើងមកតាល់ស្តេចឡើយ,
គេះយោបល់បានឮឡើងមក ក៏ចូរបាធ្វើឲ្យអស់អ្នកនគរទាំងអំណាចបា
ហើយលុះខ្លួរភ្លាត់ដៃបា ហើយសន្សឹមបាឡើងមកហោង " ។ នាង
សរសេរសំបុត្រនោះស្រេចហើយ នាងដាក់សំបុត្រនោះក្នុងខ្ទំ យកអំបោះ
រុំត្រួតខ្លួរភ្លាជនិថ្មី បិទខ្ចាប់ហើយដៃ នាងឲ្យទៅដៃខ្ញុំស្រីតែងបំរើ ហើយ
នាងផ្តាំថា ចូរហង៍នាំខ្លួរបាយនេះ ទៅដូនចៅមហាសថជាប្អូនអញ
ហោង ។ រំមេនោះ ក៏ធ្វើដូចនាងទេវីប្រើនោះហោង, រំពាក្យ
ចំណោទថា នាគត្រីយប់ត្រលប់នោះ ធ្វើម្តេចក៏ខ្ញុំស្រីនោះនឹងចេញ
បាន ហេតុដ្បិតតែក្នុងស្តេចឲ្យនាងទេវីអែតដើមហើយ ដ្បិតហេតុនោះ
ហោង រ៉ែអ្នកឯណាមួយក៏ពុំហ៊ានយោគឡើយ ។

រីពោធិសត្វអ្នកឧលូកជាយដំខ្លួនពីមេនោះហើយ អ្នកឲ្យដំណើរមេ
នោះវិលទៅហោង, មេនោះវិលមកឧលូកខ្លួវប្រគានាងដូនរួចហើយៗក្សណៈ
នោះ នាងទុម្មរទេវី នាងមកផ្ទំមួយអន្ទឹងនូវព្រះជាទេវរាទេហាកជាវិញហោង។
រីពោធិសត្វអ្នកស្រាយចំណាយជាយនោះចេញហើយ អ្នកយល់ខ្លួវសំបុត្រ
នោះ អ្នកក៏ដឹងអាថិសេចក្តីពីនាងទុម្មរនោះហើយ អ្នកតិចារណាប្រ-
ការកិច្ចតប្បីធ្វើហើយផ្ទំលក់ទៅហោង ។ រីអាចារ្យទាំង ៤ មិញ ព្រឹក
ព្រហាមឃ្លានព្រះខ័ន ខ្លាមចាំទៅញ៉ាំងខ្លាមិនយល់ព្រះមហាសថឡើយ
តំណាខ្លួមានចិត្តពុំប្រពៃ ហើយអ្នកទាំង ៤ នោះ ទៅគាន់សំណាក់ព្រះ
ជាទេវរាទេហាក ក្សណៈនោះ ព្រះជាទេវរាទេហាកជបន្ទូលដណ្តឹងថា ដូចម្តេច
កូនគហបតី អ្នកទាំងឡាយសម្លាប់ហើយឬ ? ។ អ្នកទាំង ៤ ទូលថា
បពិត្រមហាកជ! យើងខ្ញុំមិនយល់ក៏ចេញមកឡើយ ។ រីពោធិសត្វ ក្សណៈ
ព្រះអាទិត្យអរុណាទ័យឡើង ទើបអ្នកធ្វើអស់អ្នកនគរទ្បើលុះកណ្តាប់ដៃ
នៃអ្នកហើយ អ្នកមានមហាជនជាបរិវារច្រើន អ្នកឡើងជិះរទេះបរទៅ
កាន់ទ្វារជំនឹង ខ្លួបរិវារច្រើន ។ ព្រះជាទេវរាទេហាក ស្តេចចេញបង្ហិច
រមិលមើលទៅឃើញលំពោធិសត្វ ។ លំដាប់នោះ, ពោធិសត្វអ្នកចុះអំពីរទេះ
ហើយថ្វាយបង្គំព្រះជាទេវរាទេហាក ព្រះអង្គឃើញហើយគិតថា ជាមហា.
សថទេះ ថាបើកដាសត្រូវនឹងអញហើយ ក៏ជាមិនសំពះអញឡើយ ។

លំដាប់នោះ, ព្រះបាទវិទេហរាជឲ្យហៅព្រះមហាសត្វចូលទៅ ព្រះមហាសត្វចូលទៅដូចព្រះបន្ទូលព្រះមហាក្សត្រ ហើយក្រាបថ្វាយបង្គំអង្គុយក្នុងដំហានមួយអន្លើ។ អ្នកប្រាជ្ញទាំង ៤ ក៏អង្គុយនៅទាំហាននោះដែរ។ លំដាប់នោះ, ព្រះបាទវិទេហរាជធ្វើដូចមិនដឹងដល់តិចឡើយ ក៏ដណ្តឹងថា ឱហ្ន៎មហាសត្វ! បានៅបងអញអំពីមុនៃ លុះថ្ងៃនេះ ទើបបានមក បានបងអញដូច្នេះ ហេតុអ្វីបានដូច្នោះ ហើយទើបបន្ទូលជាគាថានេះថា:

អកិច្ចោ សកតោ ឥធាឯ ឱសិ
កឹ សុត្វា តាមាសង្កិតេ មច្ចោ តេ
កោ តេ តាមភេទ ភូរិបញ្ញ ឥង្ឃ
តំ វិទ្ធំ សុណាម ភ្រូហិ មេ ឥត្តិ ។

ឱហ្ន៎មហាសត្វមានប្រាជ្ញាក្រាស់ដូចផែនដីឥតគេស្មើ បានៅតាំងពីព្រលប់យប់បឋមរំពឹងមកម្ល៉េះ លុះថ្ងៃនេះទើបបានមក, បានឮអ្វី ប្តូចិត្តនៃបាសង្កាថាម្តេច? ឬអ្នកឯណាថាអ្វីបា? ប្លែកបាសំដែងថ្លែងសេចក្តីនោះមកអញនឹងស្តាប់តាក្យបាហោង ។

លំដាប់នោះ, តោដិសត្វទូលព្រះបាទវិទេហរាជថា បពិត្រមហារាជដ៏ចម្រើន! អម្ចាស់យកតាក្យអាចារ្យទាំង ៤ នោះហើយ អម្ចាស់បង្គាប់ឲ្យ

សម្តាប់ខ្លួលព្រះបង្គំ ហេតុនោះ អញ្ជុំមិនមក ថាតែអម្បាលនោះហើយ
ក៏សូត្រជាគាថាខេះថា :

បញ្ញា វជ្ជា មហោសធ
យទិ តេ មន្តយិ តំ ជនិន្ទ នោសំ
ភរិយា រហោ កតោ អសំសិ
តុយ្ហំ ហាតុកតំ សុតំ មមេតន្តិ ។

បពិត្រមហាក្សត្រជាសេរីវៃក្រវែលដ៏ក្រស្តែផង ព្រះអង្គជាអម្ចាស់មាន
ព្រះបន្ទូលអំពីត្រលប់ឃប់បឋមយាមថា វ័មហោសធមានប្រាជ្ញា ប្រស្នា
ច្រើនអញក្រវើនបង្គាប់អ្នកប្រាជ្ញទាំង ៤ ឲ្យសម្តាប់, ពាក្យនេះអម្ចាស់ទៅ
នាឋានស្ងាត់ ហើយបន្ទូលប្រាប់ព្រះពរជទេពី ខ្លួវត្តិកំចាំងនោះប្រាកដ
កំណាត់អញនុ៎ះហើយ ។

ព្រះបាទវិទេហរាជ ស្តាប់ពាក្យព្រះមហោសធថាដូច្នោះហើយ ស្តេច
មើលទៅនាងទុម្មេធាវីភ្លឺកស្មារតី ក្រាលតាល់ក្នុងព្រះពរជហឫទ័យថា
សមនាងនេះ ស្បែត្រមានមហោសធនេះឯងមិនខេខ្លីយ ។

(នៅមានត)

ភាគ៣ភាគ្យ ៩

ប្រុងសុវត្ថិរៀងទី យ្យរ-អ្នក ធំពាក្ខ

ជនទទួល

រង្វាន់លើកទឹកចិត្ត

ផ្នែកការពិនិត្យ ក្នុងការប្រឡងអក្សរសាស្ត្រ
របស់សមាគមអ្នកទិន្នន័យខ្មែរ នៅឆ្នាំ១៩៦១

(ត-ចប់)

ត្រូតុណាស្តី តោលកាត់ក្រី ខ្លួវបរលោក
ទ្រង់តួរយោគ ប្រមោកសប តបសួរទៅ
ថាតាទិត្យ ទីឯព្រះចន្ទ តើគាំងនៅ
លោកខេះក្លៅ ឬក៏នៅ លោកឯណា ?
តាមដែលពិត ព្រះអាទិត្យ ទីឯព្រះចន្ទ
យើញជាក់ស្លាន់ កណ្តា[1]ច្បាស់ខែង ទីឯខេត្រា
មិនបិតនៅ កូនលោកយើង ខេះកាលណា
គឺពិតជា បិតនៅនា លោកជាខែ ។
បើលោកខែ ទីឯលោកថ្ងៃ ជាលោកផ្សេង

---

១ កំណាត់, សង្កាត់, កំណត់, ពួក, ដុំ; ក្នុងទីនេះ សំដៅ ដុំ ។

ទ្រង់គួរឈ្នះ ថាបរលោក មានតិតវ៉ែក
ព្រោះតាស្យនេះ បើតិតរិះ ប្រែមកវិ
ក៏ជានន័យ ថាលោកធ្វើង ពីលោកយើង ។
ទ្រង់អង្គ ទ្រង់មានគុណ ធ្ងន់ដ៏ធំ
ឥឡូវខ្ញុំ សុំបែរពោល ដោលដេញដើង
ពីអលាត ជាតិនាយក មន្ត្រីថ្កើង
ដែលស្តីឡើង ថាបុណ្យជាប សាបគ្មានផល ។
លោកអលាត ថ្លីមិនចាំត ក៏ដូច្នោះ
ព្រោះលោកនោះ តំនិតខ្លី ស្តីឥតឆ្ងល់
ដឹងជាតិខ្លួន តែមួយមួន មិនឱ្យខ្លួល
តិតឱ្យឃល់ ដល់មនុស្សយើង មានជាតិច្រើន ។
កង់ជាតិខ្លះ ខះខំធ្វើ អំពើបុណ្យ
ជាតិខ្លះសុំន ធ្វើសុទ្ធជាប ឆ្ងាបឆ្នេះកើន
ជាតិខ្លះធ្វើ ខ្លះអំពើ ហាំងតិរច្រើន
លោកអលាត មិនគ្រវើន តិតដល់សោះ ។
តិតតែជាតិ មានខ្លួនកើត ជាមិនឆ្លៀស
ឃាតក:(១) សម្លាប់គោ មោហ៍(២) ចាំងស្មោះ

---

១ អ្នកសម្លាប់សត្វ. អ្នកបៀតបៀនសត្វឲ្យជាទុក្ខវេទនា ។ ២ អ្នកវង្វេង. អ្នកឯងឯតងដល់មិនយល់ខុសត្រូវ ។

លុះលែងជាតិ រាត់តរចេញ មកពីនោះ
ផលចាបលោះ ត្រោះផលបុណ្យ ជាតិមុនផ្តល់ ។
ទាំឲ្យកើត យកកំណើត ជាអលាត
បុណ្យជួយរាត លាតឲ្យមុខ សុខសែនសល់
ត្រោះរឿងនេះ ខើបអលាត ជ្រៀតការយល់
ថាបុណ្យចាប ឥតឲ្យផល គាល់តែសោះ ។

ចំណែកខាង រឹដក: អ្នកតំសត់
តំកំណាត់ កត់យល់តាម ស្នាមគេនោះ
ដោយសំគាង តាងថាខ្លួន ដឹងជាតិស្មោះ
ដែលមានឈ្មោះ ច្រាកដថា តាវសេដ្ឋី ។
សេដ្ឋីនេះ បេះធ្វើទាន ចែកជាន់ធន
ដល់ពួកជន ទុក្ខលំបាក យាំកប្រក្រតី
លុះលះជាតិ ឃ្លាតពីនោះ មកវិញទៀ
យកជាតិ ជារឹដក: ថ្នាក់ខ្ញុំគេ ។
រឹដក: មិនដឹងជាក់ ជាតិដទៃ
ជាជាតិថ្មី ប្លែកថាតក្រៃ ផ្សេងខ្លៅគេ
ខើបកំណាត់ កត់រឿងនេះ យកជាមេ
ថាឲ្យទាន គ្មានផលទេ ឥតសង្ស័យ ។

លោកអលាត, រីដក: ចាំងពីរនាក់
ជាមនុស្សក្រែក ខ្វីច្រាំជ្រា អន្ធការក្រៃ
ដឹងជាតិខ្លួន តែមួយជាតិ ឆ្កឿតវិនិច្ឆ័យ
ថាសិលាទាន គ្មានដំរៀ ឥតប្រយោជន៍ ។
ចើដឹងជាតិ ឥតបានច្រើន ដូចខ្ញុំម្ចាស់
ទើបគួរណាស់ វិនិច្ឆ័យ នៃស្ថិតស្ថេរ
ចេះព្រះអង្គ ទ្រង់សណ្តាប់ ចាប់ច្រាមោរ
ខ្ញុំនឹងស្រោច ទឹកព្រះធម៌ បវរថ្វា ។
ខ្ញុំអម្ចាស់ ដឹងជាតិខ្លួន ដប់បួនជាតិ
ដប់បួនឥត ចែកជាខ្វី តីរកាលា(១)
គឺអតីត អនាគត ជាគូគ្នា
កាលមួយៗ ឃើញជាក់ជា ច្រាំពីរតិត ។
ជាតិអតីត តិតចាំងអស់ ច្រាំពីរតត់
ដឹងច្រាកដ គ្មានភ្លេចភ្លាំង ចាំងដួងចិត្ត
ខ្ញុំម្ចាស់ចាំ អាចខួលទ្រង់ ស្ងួនភ្ងាតិស្យ
មានកម្រិត តិតដូចខ្លែង ចែងទៅថា ៖
ជាតិទី ១ កាលនោះខ្ញុំ កេទជាប្រុស

---

១ កាលា ប្រែថា "កាល, ពេល, សម័យ" ។

ចេះសត្វសុស ខាងធ្វើជាង មាសចេនរ
នៅខនរ កដគ្រឹះ ប្រសើរថ្លា
អ្នកហ៊ឺហា នៅស្រណុក សុខក្សេមក្សាន្ត ។
តែជាឯមាស ខាសក្នុងចិត្ត គប់មិត្តខូច
មិត្តនាំល្ងួច លួចស្រីគេ ដោយក្លាហាន
ដោយយកទ្រព្យ ភ្ជាប់ចិត្តស្រី ស្តីពប់អាន
ដោយអាងមាន ទ្រព្យធនធាន គ្មានរលោះ ។
អំពើខេះ ជាកំណាប់ កប់ក្នុងចិត្ត
ចាប់ជាប់ស្អិត ឥតរសាត់ ជាត់ខ្មៅសោះ
ដូចភ្លើងកប់ ខ្ទប់ក្នុងផេះ ឆេះដូច្នោះ
ជាបគ្រោះ តឯមានកាល បណ្តាលទុក្ខ ។

ជាតិទី ២ លុះខ្ញុំឃ្លាត ជាតិជាឯង

ជាបនោះឃ្លាង មិនចាន់ផ្តល់ ផលខ្មៅមុខ
បែរជាមាន កុសលមួយ ជួយទំនុក-
បម្រុងទុក លុកឱ្យកើត ជាសេដ្ឋី ។
សេដ្ឋីនោះ មោះមុតមាំ ចំសីលទាន
ដោយសារមាន កល្យាណមិត្ត ចិត្តឃ្នាតខ្ជិ
ណែនាំឱ្យ ប្រព្រឹត្តធម៌ ល្អប្រក្រតី

មួយដរិត ឥតរង្វើអ្វី អាក្រក់សោះ ។
កុសលនេះ ជិតស្អិតនៅ ជៅសព្ពាន
ដូចកំណប់ ទ្រព្យកល្យាណ ក្នុងទឹកទ្រោះ
គន់គេលណា ផ្តល់សុខា ឥតមានមោះ
គ្មានគេចដោះ ដូចស្រមោល តាំរចេលច្រាណា ។

ជាតិទី ៣ លុះសេដ្ឋី ផុតជីវិត
ទៅកើតតាត ក្នុងភពត(១) តាថាកហាន
ដោយផលកម្ម ចាំកាលកើត ជាឯមាសមាន
ដែលបំពាន ហ៊ានបំពារ ភរិយាគេ ។
ជាបនោះឯង ស្វែងឲ្យផល ដល់អត្តា
កើតទៅជា សត្វនរក ទុក្ខគ្មានល្អ
ចំណែកបុណ្យ បែរជាជុន ត្រឡប់ខ្វៃ
គ្មានចេញផ្លែ ប្រែមិនផ្តល់ ផលគេលនោះ ។

ជាតិទី ៤ ខ្លួនខ្ញុំរួច ពីនរក
ហានលាមក រងតែទុក្ខ ផុតឥតសោះ
មកកើតជា កូនស្វាឈ្មោល ពេលជាបត្រោះ
ត្រូវមេហ្វូង នៃស្វាខោះ ដេះ(២)តង្កាយ ។

---

๑ ឈ្មោះហានទេះកមួយ នៃលមានសូរសម្រែកកងរំពង ។ ๒ ទាំឆ្កើះ, ទាំប៉ែបក ។

ជាតិទី ៥ កម្មខ្ញុំប្រែ ខ្វែតស្លា

មកកើតជា កូនគោរឈ្មោល ចោលតង្កាយ
ដោយគេក្រៃ កាយកតូច ដូចគ្នាទស្ពាយ
ហើយគេកាយ ប្រើបង្ខំ ក្រែគ្នាទស្ស័យ ។

ទី ៦ លុះខ្ញុំស្លាប់ តំរោមក

ចាន់យោនយក ជាតិជាមនុ ឬសកេខ្វេយ
មានអង្គជាត មិនដូចមាតុ គេសោះឡើយ
ជនប្រុសស្រី ពុំកៀកកើយ យកជាគ្នា ។

ទី ៧ ខ្លួនខ្ញុំលែ ទៅកើតឮ

សួគ៌ាល័យ ត្រៃត្រឹង្ស ជាទេវតា
ដោយគេដះ តបះ(១)ផ្លែ កាលកើតជា
ជាតិសេដ្ឋី បិតទៅនា គោសម្ពី(២) ។
ដោយអំណាច នៃកុសល ផលផែល
នាំខ្ញុំហែល ទ្វែលមកកើត ជាបុត្រី
នាមវុឌា ជាជីតា ព្រះចន្ទ្រី
តែមិនទាន់ អាចកាត់ក្រី គេទស្រីជាន ។

បតិត្រព្រះ ខវ៉ែន្ត្រា ជាម្ចាស់ដ្ឋ

---

១ ការប្រព្រឹត្តកាន់វត្ត ។ ២ ឈ្មោះទីក្រុងមួយ នៅប្រទេសឥណ្ឌា សម័យពុទ្ធកាល ។

ហេតុប្រាកដ សឹងកើតមាន នៅទីព្រាន
ឈ្មោះខន្ធវ័ន ជាខ័ណ្ឌត្រកូលស្ស ជាសូតិហាន
ឥឡូវមាន ខេតច្រើនប្រាណ មកជួបជុំ ។
ហើយនាំគ្នា ធ្វើកម្រង ចងជាចង្កា
ច្រើនត្រៀបត្រា រៀបតុកដាក់ តាមថ្នាក់ក្រុម
ដើម្បីធ្វើ កិច្ចមង្គល ខួលខ្ញុំ
រៀបផ្សំផ្គុំ នឹងខេវបុត្រ ឈ្មោះដវៈ ។
តុំយូរយារ ខ្ញុំនឹងលា ព្រះបិតា
ទៅកើតជា ខេតកញ្ញា សមហាន:
ជាប្រពន្ធ ដ៏ប្រពៃ នៃដវៈ
សោយសុខ: ថ្នាក់ខេត្តា ណាព្រះអង្គ ! ។
ខ្ញុំអម្ចាស់ នឹងអន្ទោល យោលទៅមក
កន្លះលក ឥលសង្សារ ត្រាំមួយវង់
លុះដល់ជាតិ ពីត្រាំតីរ វិលវៃប្រអង្គ
ជាខេតខ្ចី អង្គជាប្រុស ឆ្នុះឫទ្ធិក្រៃ ។
ចាប់តីនោះ ខ្ញុំអម្ចាស់ ប្រុសរហូត
លែងរហូត កេខប្រុសឆ្លៀវ ទៅវិញវៃ
ដោយសារខ្ញុំ ដ៏ងសុខុម ធម៌ប្រពៃ

មិនហ៊ានលៃ លួចសេពសន្ថវ៌ ប្រពន្ធគេ ។
តាមការណ៍តិត ជនគេខ្ជិល បើប្រាថ្នា
ឲ្យអាត្មា មានខ្លួន ប្រុសឥតវេ
ត្រូវតែតម កុំលួចលាន់ ប្រពន្ធគេ
ទ្រង់ឃើញខេ ខ្ញុំអម្ចាស់ ជាដើមប្រុស ។
ជនគេខស្រី បើប្រាថ្នា គេខប្រុសវិញ
ត្រូវបំពេញ តែស្វាមី កុំឲ្យខុស
គោរពប្តី ខុកដូចជា ខេត្តាមនុស្ស
គេខប្រាណប្រុស ឱដ៏សម្រេច ស្រេចមិនខាន ។
សម្បត្តិពិភ្ព តីអាយុ សុខនិរ៌យស
តុំដែលលស់ លះបង់ចោល ជនកល្យាណ
ដែលជាអ្នក រៀរចាកចាប អំបាលម៉ាន
ធ្វើតែខាន រៀនកាន់សីល មួយជីវិត ។
ហេតុនេះខ្ញុំ សុំព្រះអង្គ ផ្តង់ព្រះទ័យ
កាន់វិន័យ ប្រពៃណី តាមជមិតិត
សូមលះចោល កម្មកម្រោល ខុសក្រមក្រឹត្យ
សូមប្រតិត្ត ផ្តិតផ្ចង់ធម៌ ដ៏ខ្ពង់ខ្ពស់ ។

សេះខុកឈើន នាងរុចា តែត្រឹមនេះ

សូមត្រិះរិះ តិចារណា ការណ៍ព្រះព្រហ្ម
នៅព្រហ្មលោក កំពុងរយោគ ដើរចង្រ្កម(១)
រួចហើយផ្លូ សម្ងំអង្គុ ត្រង់អាស្នា ។
ព្រះព្រហ្មនេះ មានឈ្មោះថា នារទៈ-
កស្សបៈ លោកជាអ្នក មានវិជ្ជាក្លា
អាចនំម្ចិត តិតតំណែង តែងកាយា
ចង់ឃាំងណា ក្លាធ្វើបាន ប្រាណដូច្នោះ ។
គេលសម្រាក លោកក៏ឆាក បែរនេត្រា
ប្រើប្រាជ្ញា ឆ្លាប្រមើល ដោយសង្រ្កោះ
មកឯហាន មានមនុស្សនៅ ក្រែងកើតមោះ
កើតដល់ខ្លោះ ឬមានហេតុ កេទដូចម្តេច ។
លោកឆ្មៀងនេត្រ សង្កេតឃើញ ឆាងវុចា
មានប្រាជ្ញា កំពុងទំ រំពូកស្តេច
តែគោះបី ឆាងប្រឹងស្តី ក៏មិនស្រេច
ដ្បិតអង្គុស្តេច ត្រាច់ព្រះទ័យ ទៅស្រៀងឆ្ងាយ ។
លោកយល់ថា បើអាត្មា ចេញទៅដួយ
ឆាងចាត់ព្រួយ ដោយស្តេចនោះ ទំនងប្រែក្លាយ

---

១ ការដើរទៅដើរមក, ការដើរសាចុះសាឡើងច្រើនលើក ដើម្បីឲ្យស្រួលខ្លួន ។

យល់ឃើញត្រូវ ត្រង់តាមផ្លូវ ធម៌ចាំងឡាយ
បែររកកយ ចាយកម្ចាំង តាំងប្រព្រឹត្ត ។
នាវេ: អ្នកគ័ហោះ ផ្លោះតិត្រហ្ម(១)
សំដៅចំ រំមានចន្លុះ(២) សោកណ៌តិត
លុះដល់ហើយ ព្រះនាវេ សូត្រប្រសិទ្ធ
សំដែងដូច្នេ នំម្ចិតទ្ធន ជាឥស៊ី ។
ឥស៊ីនោះ បិតនៅឮ អាកាសហាន
ជិតតិតាន ល្ងែងប្រាសាទ ស្ពានឥស៊ី
ដែគ្នានកាន់ ដើងគ្នានជាន់ គ្នានជាប់ដី
ធ្វើអាការ ឲ្យចក្រី ខតយើញក្លាង ។
ព្រះមហាសូត្រ អង្គតិ ទ្រង់យើញជាក់
ទ្រង់ក៏ក្បាក់ ដូចតន្ត្រាក់ ផ្ទាកស្រាងង
ទ្រង់តក់ស្លុត រន្ធត់ខ្លាំង តាំងហៅនាង
ឲ្យមើលទាង ជិតតិតាន ហានប្រាសាទ ។
នាងរុចា ខតយើញថា តាឥស៊ី
កំពុងតែ តាវៈ(៣) សំតះថ្ងាត់
រួចបែរកេវ ក្រាបទូលន័យ ព្រះមហាសូត្រ

---

១ ហានព្រហ្ម, ព្រហ្មលោក ។ ២ ឈ្មោះប្រាសាទ ។ ៣ ការធ្វើតាវេ ។

ទ្បាក់ចាត់ ការគ់ការកែយ ក្តីខយោ ។

ព្រះកជា ក្រាបវន្ទា តាឥសី

រួចគ្រាស់ខ្ញុំ ដោយសេចក្តី យ៉ាងនេះថា

ចុះលោកម្ចាស់ ច្បាស់ជាអ្វី មកឥណា

រូបសោភា ឆើតឆ្ងា(១) ល្អអ្វីម្ល៉េះ ?

លោកមានឫទ្ធិ ឥទ្ធិលោក អស្ចារ្យក្រៃ

ឋិតលើផ្ទៃ នៃអាកាស ប្រាសាទនេះ

តើលោកមាន វិជ្ជាអ្វី ប្រពៃអេះ

ទើបអាចនេះ សំដែងឫទ្ធិ ពិតអស្ចារ្យ ?

ឥសីព្រហ្ម ថាអាត្មា ឈ្មោះនារទ(២)

ជាព្រហ្មព្រត(៣) នៅព្រហ្មលោក យោគធម៌អាថ

ដែលរូបល្អ ខ្ញុំមានឫទ្ធិ ច្រើនប្រការ

គឺដោយសារ ការប្រព្រឹត្តិ ធម៌សុចរិត ។

កាលដែលកើត យកកំណើត ក្នុងកតាមុន

---

១ ជាវ ប្រែថា « ស្បែកសម្បុរថ្ងៃ » ជាស្បែកស្លឹង ដែលនៅក្រៅសាច់ សម្រាប់ទទួលកំដៅថ្ងៃ ។ ២ ហៅជាន ២ យ៉ាង ថា « នារទ » ក៏ជាន ថា « នារទៈ » ក៏ជាន ។ ៣ ព្រត ជាភាសាសំស្ក្រឹត, ជាលីថា « វត្ត » ប្រែថា « បព្រឹត្តធម៌, ចាំសីល » ។ នារទ អាន នារ៉ទ, ព្រត អាន ព្រត់ ដូច អស្ចង្គត, ប្រាកដ, ដើតពន, ទ្រព្យធន, កុសល ជាដើម ។

ចានធ្វើបុណ្យ តាំងដឹងគុណ ដ៏ពិសិដ្ឋ
គាន់សច្ចៈ តោលខឿនចាត់ ច្រោកជំពិត
តាំងប្រព្រឹត្ត អហិង្សា ការពារសត្វ ។
ហើយខ្ជិនាន ប្រឿនច្រោបខ្ជិន ស្លូនពោសៈ
មានចាតៈ លះកំណាញ់ កាញ៉ាស្លិតក្តាត់
បែកវៀលក ញែកធនជាន ឲ្យចានសត្វ
កុសលនេះ ជាសម្បត្តិ ឲ្យមានបុទ្ធិ ។
-ចុះលោកម្ចាស់ ជ្រាបហ្នាស់ខេ ម្តាយឪពុក
តើគួរទុក ជាមានគុណ ធួនមែនពិត
បើមានមែន គួរកូនតប កបពេញចិត្ត
ខ្ញុំតែងតិត តំនិតវល់ តុំយល់សោះ ។
តាំងខេត្ត ហានសួគ៌ា មានឬទេ
សូមរិះរេ ពីបរលោក ឯនាយនោះ
តើមានពិត ឬមិនមាន សូមចានដោះ
ដោយចិត្តស្មោះ ធ្វើសង្គ្រោះ សោះសង្ស័យ ។
-បពិត្រខ្ញុំ ត្រង់រឿងនេះ រូបអាត្មា
មិនដោះសា ឲ្យវែងខេ នាំយូរក្រៃ
ព្រោះរឿងនេះ ខ្ញុំបានជ្រាប ពីស្រីថ្លៃ

នានវែកវៃ រៃលុះហើយ ណាចមតង្ស!
អាត្មាភាព ថ្វាយសេចក្តី យ៉ាងខ្វីថា
ជនពាលា ច្រើងភ្លេចភាក់ ខ្វាក់ខ្វៃលួងឆ្ងំ
ថាមែន ឥតមានគុណ ធួនលើអង្គ
ថានេះចង់ បំបាត់ចោល ព្រហ្មវិហារ ។
ឯអ្នកច្រើង អាចយល់ថា លោកមានគុណ
ព្រោះចិត្តបុណ្យ ស្រោចស្រពបុត្ត រៃក្រអស្ចារ្យ
អាស្រ័យហេតុ ដែលលោកមាន ព្រហ្មវិហារ
ខើបដឹកនៃ កុមារ រស់ពន់ពាន ។
ពួកខ្ពើ ហ៊ានសួតា នឹងបរលោក
ពាលច្រើយព្រោក ដោយចេតនា ថាមិនមាន
បើខ្ពើ ហ៊ានសួតា បរលោកគ្មាន
ចុះរូបអង្គ អាត្មាមាន ជាតីស្រាប់ ។
ឯអាត្មា ជាពួកខ្ពើ នៅសួតា
ដែលខុកជា ហ៊ានបរលោក តាមផ្លូវប្បាប់
អ្នកថាគ្មាន ព្រោះហេតុខ្លួន ច្រើងអាប់
សំដៅពាប់ ឃើញទឹងក្អែក ខើបថាមាន ។
ឃើញម្តេចកើត បើហ៊ានសួតា ឆ្ងាយពេកក្រៃ

ឆ្ងាយហួសថ្ងៃ ហួសព្រះចន្ទ ជាប្រជាន
ដែលយើញបាន លុះតែលោក ចំរើនឈាន
ធ្វើជាយាន ទើបហោះឆ្ពាន ដល់ពីនោះ ។

- ទេវសី! បើបរលោក ពិតជាមាន
ខ្ញុំសូមទាន ខ្ចីប្រាក់លោក មួយតាន់ចុះ
ដល់ខ្ញុំសង សងមួយម៉ឺន គ្មានគេចដោះ
តែសង្គ្រោះ សូមកាត់ឯបរលោក ។

- ព្រះចមពង្ស ទ្រង់ជ្រាបពេ មនុស្សក្រៃក្រ
មានលិទិត ពិតឥស្សរជន យ៉ាងនរគោក
ច្បាប់តាត់ទោស ឲ្យជាប់គុក តាមផ្លូវលោក
អស់ដំណើរដោត ដោតតែពុក ធុកឥតក្ស័ន្ធ ។
តើមានច្បាប់ សម្រាប់ដូច ឲ្យអ្នកខាត
អាចបើកទ្វារ ពារភ្នុះដល់ អ្នកខាសបាន
ខាបំណុល បុលចំពាក់ ពាក់ប៉ុន្មាន
តើខាបាន ប្តូរពុំបាន សូមទ្រង់ថ្លែង?

- ទេវសី! គ្មានច្បាប់អ្វី ឲ្យចូលខាត
ខោះបើទ្វារ អនុញ្ញាត ឲ្យចូលស្តេច
ក៏អ្នកខាស គ្មានជនជាន លើងឆេង

តើបានអ្វី ខ្ញុំសង្ឃឯង ណាលោកគា !

-ព្រះមហាកដ! សេចក្តីនេះ យ៉ាងណាម៉ិញ
រឿងទ្រង់វិញ ដែលខ្ញុំប្រាក់ ជាក់ដូចគ្នា
ទ្រង់មានពេស ជាទ្រព្យធ្ង ដ្បិតពាលា
ថាបង្គន់ឲ្យទ្រង់ទៅ ទៅខាងក ។
ប៉ោមមានស្បែ កំពុងទ្រង់ សោយគ្រោះថ្នាក់
ដោយការភ្លាក់ ទៅរងទុក្ខ មុខពភ្លក់
មានក្តៅងនេះ សត្វកាចខាំ គ្រាំលាមក
លិចកងកក់ ឈ្លក់ជាប់ស្អិត កន្ទិបខ្លា ។
ឬកំពុង លង់លិចក្នុង ខ្លះទឹកក្តៅ
ឬគំទៅ ផឹកទឹកក្រូត ហុតគូថា
ឬទៅរង លំបាកអង្គ ត្រង់ទីណា
ឲ្យអាត្មា ទៅការប្រាក់ ដូចម្តេចបាន ។

ព្រះកដា ទ្រង់ឮលំប្រាជ្ញ មិនគាចតប
ទើបសម្រេច ស្រេចចុះញ៉ឹម ប្រគល់ប្រាណ
ទ្រង់តក់ស្លុត ខ្លាចបាបធ្ងន់ ពន់ប្រមាណ
បន្ទុលថ្ពាល ដោយសូរសៀង ខន់កូនថា ៖

សូមលោកគា មេត្តាប្រោស សង្គ្រោះខ្ញុំ

លោកតាកុំ ផ្តុំប្រកាន់ ទឹងកំណាច
ធ្វើម្តេចហេតុ តែខ្ញុំខ្លៅ នៅច្រាជ្រា
សូមលោកតា ជួយជ្រោងគ្រាហ៍ ឲ្យផុតទុក្ខ ។
សូមច្រាប់ផ្លូវ ដែលទឹងទៅ កាន់ហ៊ានសួគ៌
ជាផ្លូវត្នូរ ធ្វើដំណើរ ដើរកសុទ្ធ
ជាផ្លូវត្រង់ តម្រង់ចៀស អបាយមុខ
ខ្ញុំសូមទុក លោកតាជា គ្រូប្រដៅ ។
ឥសីព្រហ្ម ទទួលស្តាប់ សព្វគម្រាស់
ទើបប្រកាស ព្រះសទ្ធម្ម ទុត្តមជ្រៅ
ស្រោចស្រង់ស្តេច ឲ្យចរាច់ តាមផ្លូវត្រូវ
រួចហោះស្ទុះ សំដៅទៅ ព្រហ្មលោក ។
រឿងនាវេ: ជាក់ចប់សព្វ ត្រឹមប៉ុណ្ណេះ
តពីនេះ ទឹងប្រដុំ ផ្តុំប្រយោគ
សមោធាន ខ្លួរជាតក ឆក់ជាតិលោក
ខ្ញុំទឹងត្រេក យោគពាយនាម ដូចតទៅ៖
លោកអលាត ជានាយក រដ្ឋមន្ត្រី
កាលនោះឯ៎ ឥឡូវបែរ ចេរីឆ្ងល់ស្ទើ
ជាកិកុ ខេវខត្ត តាត់ចិត្តខ្លៅ

ពាលកំរឡៃ ពៅប្រពូស្ត ព្រះសម្ពុទ្ធ ។
លោកសុនាម ពជអាមាត្យ កាលនោះណា
បានកើតជា តពូជ ប្រាជ្ញាមុត ;
លោកវិជ័យ ក្នុងកាលនោះ គឺសារីបុត្ត
ប្រាជ្ញាផុត ជាឯកអគ្គ សាវ័កស្តាំ ។
វីជកៈ ជាទាសៈ អ្នកដរៃ
កាលនោះវៃ ឥឡូវបុណ្យ ជួយទបគ្គម្ម
ជាមោគ្គល្លាន មានឫទ្ធិខ្លាំង ដោយបុញ្ញកម្ម
ជួយដឹកនាំ ឲ្យបានជា សាវ័កធ្វើន ។
លោកអចេលក៍ ដែលឈ្មោះគុណ មានបុណ្យសក្តិ
កាលនោះជាក់ ឥឡូវនេះ បុណ្យតុបតែង
ជាកូនស្តេច លិច្ឆវី ប្រាជ្ញាខ្ពង
មានទាមស្តើង សុនក្ខត្ត ពិតប្រាកដ ។
ខាងវុឌ ជាធំតា ប្រាជ្ញាឆើត
បានមកកើត ជាអានន្ទ អនុជវ័ត្ត ;
ឯព្រះជាន អង្គតំ មហាកស្សប
គឺកស្សបៈ ភ្លេកចាស្យ ទុរវ៉ែឡ ។
នារទៈ កស្សបៈ មហាព្រហ្ម

តិបរមេ សម្ពុទ្ធោស្មិ ត្រាស់ពុកកុំ
ជាព្រះមួយ ជួយស្រង់សត្វ គ្មានខំនេរ
សាស្ដាទ្រង់ គង់បិតថេរ យ៉ាងឧត្តម ។

បរិយោសានកថា

រឿងនាវេ: ដែលលោកអ្នក កាន់នៅដៃ
បើតាមន័យ សេចក្ដីយល់ យោបល់ខ្ញុំ
ថាជារឿង ជាមានអាថ៌ ការណ៍សុទ្ធុម
ដូចនឹងដុំ ប្រដុំគោល យ៉ាងនេះថា ៖

គោលទី ១ ចំណងឲ្យ រៀបចាបមិត្រ

ឲ្យចូលដិត មិត្រកល្យាណ មានប្រាជ្ញា
ព្រោះចាបមិត្រ ពិតនាំដើរ ផ្លូវសោភ័
មិត្រកល្យាណ៍ នាំដើរផ្លូវ ត្រូវប្រពៃ ។
គួយ៉ាងដូច អង្គតិ ព្រះមហាសូត្រ
ស្ដេចទ្រង់ស្គាត់ ទៅរកចួប តាលចង្រៃ
នាមគុណ: ជាអចេលក៍ បួសនៅព្រៃ
ទ្រង់ក៏លង់ ព្រះហឫទ័យ តាមតាណ ។
លុះទ្រង់ចួប នាវេ: មហាព្រហ្ម

អ្នកប្រាជ្ញធំ ដែលតំណាង ក្នុងកាយា
ជាឥសី ចុះមកស្តី សទ្ធនា
ព្រះរាជា ក៏យល់ត្រូវ ផ្លូវអាថ៌ជាមិ ។

គោលទី ២ ឲ្យសំគាល់កម្មផល

ថាកុសល ផ្តល់អារម្មណ៍ គួរត្រេកអរ
អកុសល ផ្តល់អារម្មណ៍ ទាំរីវែរ
កម្មចាំងពីរ នាំសត្វចរ ទៅសួគ៌និរក ។
ព័ស្តុតាងដូច រាជកុមារី ស្រីវុឌ្ឍា
កាលកើតជា ជាងមាសពិត ចិត្តអាក្រក់
ហ៊ានប្រព្រឹត្ត ធ្វើអំពើ ដ៏សាមក
កម្មតម្រក់ នេះនាំទៅ រងទុក្ខធ្ងន់ ។

គោលទី ៣ ស្តាប់ភ្លឺ ឲ្យស្គាល់ជាក់

ខ្លួរលោកអ្នក ដ៏មានគុណ ជាអនន្ត
ដូចខ្មៅមែ ថែរក្សា បុត្តរ៉ែតន់
តុំដំនន្លះ ធន់លំបាក យ៉ាកក្រៃគ្រួន ។
បុត្តធីតា បើដឹងថា ខ្លួនរស់កន
ដោយសារមាន ត្រហ្មវិហារ ជាម៉ាមួន

នៃមែន ដែលមានគុណ ជួនលើខ្លួន
គួរថែជួន តបលោកវិញ ទើបគេញត្រូវ ។
គោលបំណង បំនិទាំង ៣ នៃរឿងនេះ
ខ្ញុំបានរិះ គិតពិនិត្យ សង្កេតមើ
ឃើញជាក់ថា បើមនុស្សយើង ដើរតាមផ្លូវ
គោលនេះក្តី នឹងបានទៅ ជួបសួស្តី ។
កូនលោកនេះ ក៏ជាមនុស្ស មានចរិយា
គួរស្នេហា ពប់រកគ្នា ជាមេត្រី
មានចិត្តត្រង់ សង្គ្រោះគ្នា ជាប្រក្រតី
ដោយសារគុណ គោលទាំងបី ដែលបានតាន់ ។
បើជឿថា ស្លាប់តាលណា តែងតើតវិញ
គួរបំពេញ នូវធម៌នេះ ទើបសោភ័ណ
ដើម្បីខុត ជាកំណប់ ទ្រព្យសំខាន់
ជារង្វាន់ គ្រាន់តិចតិច តំនឹងខ្លួន ។
ថ្ងៃទី ៣ នៃកញ្ញា ដូតវាសេស
ទៅកូនគ្រិស្ត សតវត្សរ៍ ដប់ប្រាំបួន
ហុកសិបគត់ ជាឆ្នាំសល់ កល់ចំខួន

ពុទ្ធស័កសួន ជួនពីរគាន់ ច្រាំរយប៉ ។

កន្លងដំនាន់ ជាន់សម័យ ព្រះប្រមុខរដ្ឋ

នាមច្រកដ ព្រែះសីហ៊ុ មានចារម៉

មានតេជៈ ឈ្នះសត្រូវ សួយដែនដ

កម្ពុជា ឯករាជ្យថ្មី ល្បីខ្ចរខ្ចាយ ។

នេះជាគោល ដែលខ្ញុំចាប់ ច្រារឮតែង

រឿងនេះឯង រហូតចប់ សព្វបរិយាយ

ឥឡូវខ្ញុំ សុំបង្គំ ឈប់អធិប្បាយ

លែងអគតិច្រាយ ត្រឹមប៉ុណ្ណេះ សូមលាអើយ ។

សម្មោទមានជាតក

ព្រះញាណកោសល ញាណ-ឈឺន ប្រែរៀបរៀង

កាលព្រះបរមសាស្តាទ្រង់ប្រថាប់នៅទីគ្រោងពាម ជិតក្រុងកបិល-ព័ស្តុ ទ្រង់ប្រារព្ធរឿងដំណោះរបស់ក្រុមព្រះញាតិ ហើយទ្រង់សំដែងនូវព្រះគាថាមានបទថា សម្មោទមានា ដូច្នេះជាដើម ។

រឿងដំណោះនេះ មានសេចក្តីតំណាកេងក្នុងកុណាលជាតកឯណោះ ។ សេចក្តីថា ក្នុងកាលនោះ ព្រះបរមសាស្តា ទ្រង់គ្រាស់អញ្ជើញពួកស្តេចធំ ៗ ជាព្រះញាតិមកកាន់សំណាក់ព្រះអង្គហើយ ទ្រង់គ្រាស់ថា "បពិត្រមហាកដ៏ចាំងខ្លាយ ! ការប្រកួតប្រកាន់គ្នាឯងកេងពួកញាតិបែបនេះ មិនសមហេតុផលសោះឡើយ ដ្បិតកាលពីមុនមានពួកសត្វតិរច្ឆានជាច្រើន កាលដែលនៅរួមមូលគំនិតមានសេចក្តីព្រមព្រៀងគ្នា មានកម្លាំងត្របសង្កត់ពួកបច្ចាមិត្តដ៏ខ្លាំង ហើយបានដល់នូវសុវត្ថិភាព លុះចំណេរកាលជាខាងក្រោយមក កើតវិវាទាស់ចិត្តខ្វែងគំនិតគ្នា ក៏ដល់នូវការវិនាសកន្ត្រឹកាលនោះ", លុះទ្រង់គ្រាស់ប៉ុណ្ណេះហើយ ទើបពួកកដត្រកូលជាព្រះញាតិសូមអាយាចនាឱ្យទ្រង់សំដែងជាតកនោះ ព្រះអង្គក៏នាំអតីតនិទានតទៅថា :

អតីតេ ពារាណសិយំ ព្រហ្មទត្តេ រដ្ឋំ...

សេចក្តីថា ក្នុងកាលដែលកន្លងទៅហើយ មានព្រះមហាក្សត្រមួយព្រះអង្គ ទ្រង់ព្រះនាមព្រះចុះទ្រហ្មទត្ត សោយរាជ្យសម្បត្តិក្នុងក្រុងពារាណសី ។ កាលនោះ ព្រះពោធិសត្វជាអម្ចាស់នៃយើងកើតជាចាបតួកជាមេហ្វូង មានចាបច្រើនពាន់ជាបរិវារ តែងនៅក្នុងដងព្រៃមួយជាទីសប្បាយ ។ កាលនោះ មានព្រានសត្វស្ទាបម្នាក់ចានទៅគាន់ព្រៃជាទីទៅរបស់ចាបទាំងនោះ ចានធ្វើទ្រុងសម្រាប់ឲ្យចាបរត់ចុះ លុះដឹងថា ចាបទាំងនោះចុះជុំគ្នាហើយ ក៏ដំឡើងលប់ (សម្រាប់គ្រប) លើតួកចាបទាំងឡាយ រួចហើយរាយដំព្រៃជុំវិញ ដេញចាបទាំងឡាយទៅមកមូលជាមួយក្នុងផ្លូវតែមួយ ហើយចាប់ជាក់ត្រកន់ នាំយកទៅគាន់ផ្ទះលក់ចំណាយចិញ្ចឹមជីវិតរបស់ខ្លួនសព្វៗកាល ។

ថ្ងៃមួយជាខាងក្រោយ ពោធិសត្វចានទៅយាយនឹងតួកចាបទាំងអស់ជាបរិវារថា ‘‘ព្រានសត្វស្ទាបនេះគង់តែនឹងធ្វើភ្លក្លាតរបស់យើងឲ្យដល់នូវសេចក្តីវិនាសជាមិនខាន (ជាប្រាកដ) ខ្ញុំស្គាល់ឧបាយមួយថា ចាប់ដើមពីថ្ងៃនេះទៅ មុខជាព្រានសត្វស្ទាបនេះ មិនអាចនឹងចាប់យើងចានដោយងាយទេ កាលណាយើញមានលប់គ្របពីលើតួកយើង តាមការញាយាមរបស់ព្រាន, កាលនោះ តួកយើងម្ខាក់ៗ ត្រូវតែយកក្បាលច្រកក្នុងក្រឡាលប់មួយក្រឡាម្នាក់ៗ ហើយនូលលប់លើកឡើងនាំយកទៅគាន់ទីគួរតាមប្រាថ្នាចំលាក់ចោលលើតុម្ពបន្ទាណាមួយ លុះធ្វើដូច្នេះរួចហើយ

ពួកយើងនឹងហើរទៅតាមចន្លោះខាងក្រោមដើងលប់នោះដោយសួស្តី" ។ ពួកចាបតាំងអស់កំរខ្លួលត្រមថា "សាធុប្រពៃហើយៗ" ។ ក្រោយពីនោះមកមិនយូរប៉ុន្មាន ព្រានសត្វស្ទាបបានដំឡើងលប់គ្របពីខាងលើ (ទ្រនំចាបតាំងនោះ) ដូចធម្មតា ។ ចាបតាំងនោះកំរខ្លួលលប់នាំយកទៅចោលលើគុម្ពបន្លា ហើយហើរចេញទៅអំពីកន្លែងនោះ តាមចំណែកវៀងខ្លួន ដូចន័យដែលចាបតោងសត្វនិយាយហើយនោះ ។ ព្រានសត្វស្ទាបចំកំតែងដោះលប់រួចចេញពីគុម្ពបន្លាបាន តេលវេលាកន្ត្រុលហួសទៅចាកប្រប្រតី ។ ព្រានសត្វស្ទាបនោះ មានតែដៃទទេដើរទៅកាន់ផ្ទះរបស់ខ្លួនឥតបានលាភអ្វីតិចតួចស្មើតែកល់ថ្ងៃ ។ លុះថ្ងៃតមក តំរាយរបស់ព្រានវិងអន់ចិត្តណាស់គិស្តាបន្ទោសថា "អ្នកឯងត្រឡប់មកកាន់ផ្ទះដោយដៃទទេតែកល់ៗថ្ងៃ ប្រហែលជាមានត្រកួលត្រសាដទៃៗដ៏ខាងត្រៃដែលខ្លួនត្រូវចំភ្លឹមតុំលែងឡើយ" ។ ព្រានសត្វស្ទាបនិយាយដោះសាថា "ម្ចាស់ភាន ! យើងតុំមានត្រកួលណាដទៃ ដែលយើងត្រូវចំភ្លឹម (ដូចខាងស្ថាននោះ) ទេ, ប៉ុន្តែ ចាបពួកតាំងនោះមានសេចក្តីត្រមត្រៀងគ្នាជាខ្លួនាំយកលប់ដែលយើងលាតត្រដាងភ្លឺខាងលើ ទៅចោះចាលនៅគុម្ពបន្លាហើយហើរទៅ កំឯចាបពួកតាំងនោះមិនមែនស្រុះស្រួលគ្នាសព្វកាលទេ (គន្លឹះនឹងខាស់ខែងខ្វែងយោបល់គ្នាវិញ) នាងតុំគិតឡើយ

កាលណាបើចាបភូតទាំងនោះពាស់ខែងគ្នាហើយ យើងនឹងចាប់យកវាទាំងនោះនាំមកបង្ហាញ ទើងធ្វើទានឲ្យមានមុខស្រស់ស្រាយក្នុងកាលជាខាងក្រោយ លុះទៀយយហើយ ក៏សូត្រជាបទព្រះគាថានេះថា :

សម្មោទមានា កច្ចន្តិ
ជាលមានាយ បក្ខិនោ
យទា តេ វិវទិស្សន្តិ
តទា ឯភិន្តិ មេ វសន្តិ

ប្រែថា សត្វស្វាបទាំងឡាយ កាលដែលមានសេចក្តីព្រមព្រៀងគ្នា តែងខួលលប់នាំយកគ្នាទៅចោលហើយហើរទៅ លុះកាលណា សត្វស្វាបទាំងនោះពាស់ខែងគ្នា វានឹងមកកាន់អំណាចនៃយើងក្នុងកាលនោះ ។

អធិប្បាយថា ព្រានសត្វស្វាបញ្ជាំងការយោគ្រែស្រុះស្រួល ដោយភាសាជាបទព្រះគាថាដូចខាងលើនេះ ។ បណ្តាបទទាំងឡាយនោះ ត្រង់បទថា កាលណាសត្វស្វាបទាំងនោះពាស់ខែងគ្នាដូច្នេះ ចាបភូតទាំងនោះមានលទ្ធិផ្ទុយពីគ្នា មានការប្រកាន់ខុសគ្នា ហើយនឹងតតាំងវាទៈឈ្លោះប្រកែកគ្នាឯង ។ ត្រង់បទថា វានឹងមកកាន់អំណាចនៃយើង ក្នុងកាលនោះ ចាបានដល់ភាសថា ចាបភូតទាំងអស់នោះវានឹងលុះអំណាចយើង ក្នុង

កាលនោះ ។ កាលមានករណីដូចជាន្តរាយមកយ៉ាងហ្នឹងហើយ យើងនឹងចាប់យកកំពាំងនោះទាំងមកកាន់ដីលំនៅនៃយើង នឹងធ្វើទាន ឲ្យមានមុខស្រស់ស្រាយ (តាមតួដល់សេចក្តីថ្នាថា) ។

លុះកន្លងទៅ ២-៣ ថ្ងៃហើយ មានចាបភ្លុកមួយចុះកាន់ដីគោចរភូមិ មិនបានដឹងជាមុនក៏ទៅជាន់ក្បាលចាបដទៃមួយទៀត ។ ឯចាបដែលរងគ្រោះត្រូវគេជាន់ក្បាលនោះ កើតខឹងគួចចិត្តថា "នរណាមកជាន់ក្បាលយើងដូច្នេះ?" ។ ចាបដែលមានកំហុសតបថា "ខ្ញុំមិនបានដឹងជាមុនទើបចុះមកជាន់ សុំអ្នកកុំខឹងគួចចិត្តឡើយ" សូម្បីចាបនោះអង្វរដូចម្តេចក្តី ចាបអ្នករងគ្រោះក៏នៅតែខឹងខ្លាំង ។ ចាបពាំងពីរនោះដដែកតបតនឹងគ្នាទៅវិញទៅមកដដែល ។ កើតដំណោះនឹងគ្នាដោយពាក្យថា "ខ្ញុំឯងជាអ្នកម្នាក់ឯងនេះ ខ្លួលខ្លាយលប់តែឯងបានឬ? ។ កាលដែលចាបពាំងពីរកើតទាស់ខែងខ្វែងយោបល់គ្នាដូច្នោះ ភោជិសត្វគិតថា "សុវត្ថិភាពនឹងមិនកើតមានដល់ការទាស់ខែងខ្វែងយោបល់គ្នាទេ, ឥឡូវសត្វស្វាបពាំងនោះនឹងមិនបានខ្លួលខ្លាយលប់ដូចមុនទៀតទេ យើងនឹងដល់នូវមហាវិនាសកន្លងវេលានោះ ព្រានសត្វស្វាបក៏បានឧកាស (ចាប់យកបានដោយងាយ) បើដូច្នោះ យើងមិនអាចនឹងទៅកន្លងហ្នឹងបានឡើយ" ។

តោងឯសត្វតិតហើយកំទាំបរិស័ទរបស់ខ្លួនទៅនៅក្នុងទីដទៃវិញ ។ លុះ
កន្លង ៤ ៣ ថ្ងៃទៀ ព្រានសត្វស្អាបនោះ មកកាន់ទីដម្រំចាបពួក ដំឡើង
លប់ពីលើទីប្រជុំសត្វស្លា ឯនោះដូចគ្រាមុន ។ កាលនោះ ចាបមួយ
និយាយថា កាលបើអ្នកទូលំលាយលប់នេះ ពេមក្សាលរបស់អ្នកនឹង
រះចាចចុះដោយតិត, ឥឡូវចូរអ្នកទូលំលាយតែម្នាក់ឯងចុះ ។ ចាបដទៃ
ឆ្លើយថា កាលបើអ្នកទូលំលាយលប់នេះ ស្លាបទាំងសងខាងរបស់អ្នក
នឹងជាក់ជាមិនខាន ឥឡូវនេះ ចូរអ្នកទូលំលាយតែម្នាក់ឯងចុះ ។ លុះ
ចាបទាំងពីរពួកនោះដដែកគ្នាថា ចូរអ្នកទូលចុះ ចូរអ្នកទូលចុះ មិនដាច់
ស្រេចដូច្នេះ ព្រានសត្វស្អាបក៏ំលាក់លប់គ្របពីលើមកជាប់ជាមួយគ្នា
រួចហើយចាប់ដាក់ក្រកនាំយកទៅកាន់គេហស្ថាន ញ៉ាំងឥរិយាទ្បែក្រកអា
ក្នុងគ្រានោះឯង ។

ព្រះបរមសាស្តាជ្រង់ត្រាស់ថា ..ភិក្ខុត្រកំ ។ មិនគួរនឹងធ្វើដំណោះ
ចំពោះក្រុមញាតិ (របស់ខ្លួនឡើយ) ធម្មតាដំណោះនេះ ជាមូលដ្ឋាន
នៃសេចក្តីវិនាសតិតប្រាកដ រួចហើយទ្រង់សំដែងធម៌ទេសនាបន្តអនុសន្ធិ
ប្រជុំជាតកថា « ចាបពួកអ្នកលួងនៅ ក្នុងកាលនោះ គឺរូបខេវខ្ពត្ត (នេះ)"
ឯចាបបណ្ឌិតអ្នកចេះដឹង គឺអង្គតថាគតនេះឯង ។

ចប់សម្តែងមោឝាឝាតក ។

អក្សរសាស្ត្រខ្មែរ	ខ្មែរជូរក្រវែន
ឲ្យរីកចម្រើន	គង់វង្សគង់មាំ ។
ព្រោះអក្សរជាតិ	ដោលជាតិប្រាកដ
អក្សរលត់	ជាតិក៏រលាយ ។

ប.ព.

បញ្ហាដ្ឋាយអក្សរសាស្ត្រនៅបច្ចុប្បន្នកាល

លោក លី.ជាមនេន រៀបរៀង

ការកសាងជាតិគ្រប់ផ្នែកគ្រប់វិស័យ ពុំងាយទទឹងអស់ហ៊ើយ នៅ
គេលធាប់ៗ មួយជំនួមួយគ្រាទៀត តែតែងតែជាប់ដើកបន្តគ្នាជាយូរយារ
គេលវែលមិនងាយផុត ។ ហេតុនេះ បញ្ហាកសាងទទឹងផ្សាយនូវអក្សរ.
សាស្ត្រដែលជាមែកជាងមួយសំខាន់ក្នុងការស្នាបនាជាតិដែរនោះ កំពុងបះ
អស់ហ៊ើយនូវបញ្ហាដែលត្រូវតែដោះស្រាយដែរ ។ ក្នុងបច្ចុប្បន្នកាលនេះ
ការផ្សាយអក្សរសាស្ត្រជួបទទឹងបញ្ហាសំខាន់ ៣ យ៉ាងគឺ៖

១- ខ្វះអ្នកជំនាញ,

២- ពុំជាន់សម្បុណ៌អ្នកអាន,

៣- ពិបាកខាងការចាត់ចែងដឹកជញ្ជូន ។

ចំពោះបញ្ហាជាទូបសត្តពាំងប៊ីខនេះ យើងអាចតាំងការណាយើញនូវ
មូលហេតុនឹងវិធីដោះស្រាយខ្លះៗដូចតទៅ ៖

១- បញ្ហាខ្វះអ្នកឯកទេស· ចំពោះបញ្ហានេះ យើងសញ្ជឹងតែ
បន្តិច ក៏យល់បានភ្លាមថា ប្រទេសជាតិយើងនៅតែបានឯកភាពជ្រុះបូណិ
ដោយអធិបតេយ្យ ដែលមានរដ្ឋធម្មនុញ្ញាបើកសេរីភាពខាងការបោះឆ្នោ
មតិ មានការតែងតាំងពុម្ពផ្សាយស្ថាដែអក្សរសាស្ត្រនេះជាដើម ម្ល៉ោះ
ហើយ តើដើមមកអ្នកប្រកបរបរតែងនិពន្ធបោះពុម្ពផ្សាយនេះតុំសម្បូណិទេ
បើថាគ្មានផងក៏បាន ព្រោះគេតុំបានប្រទះនឹងអ្នកនិពន្ធណាមានវិជ្ជាជីវៈ
ជាអ្នកនិពន្ធសុទ្ធសាធ ដោយគ្មានប្រកបមុខរបរដទៃទៀតសោះឡើយ ។
បើមានអ្នកនិពន្ធ ការខ្លះ ។ នោះ ក៏សុទ្ធតែអស់លោកសប្បុរសនិតនិ
សរសេរតែងដោយទុគ្គមគតិលោកបង្ខំឲ្យមានៈសរសេរតែងឡើងចែកជូន
ដល់ជនរួមជាតិយើងអានជាហូរហែមកប៉ុណ្ណោះ ។ ឯមតិដែលលោក
លោតត្រជាងឡើងក្នុងស្ថាដែរបស់លោក ក៏តុំសូវហានបោះពុម្ពឲ្យអស់
តាមការយល់ឆ្ងល់ខ្លួនដែរ ព្រោះមានច្បាប់ទីងការត្បាបាលតឹងតែងរបស់
បរទេសតុំអនុញ្ញាតឲ្យធ្វើបានតាមចង់ ។

លុះមកដល់ពេលដែលប្រទេសជាតិយើងដោះខ្លួនរួចពីអាណាត្យា
ចាលបរទេសដោយព្រះរាជកិច្ចដឹកនាំដ៏ឈ្លាសវៃ នៃសម្តេចសហជីវិនជាទី

ស្រឡាញ់ទឹងគោរពនៃយើងគ្រប់គ្នា អ្នកនិពន្ធដែលមានឧត្តមគតិចំញឹម
ចិត្តបំណងក្នុងការផ្សាយអក្សរសោស្ត្រនោះ ក៏មានលេចឈ្មោះលេចនាម
ឡើងជាច្រើនដូចផ្សិតនៅរដូវភ្លៀងដំបូង ដើម្បីបំផុសទូរគោលមតិផ្សេងៗ
ដោយរចនាជាអត្ថបទបែបសិក្សាខ្លះ បែបប្រលោមលោកខ្លះ ។ ប៉ុន្តែ
ពេះបីជាយើញមានឆាមអ្នកនិពន្ធច្រើនលើសលុបដូច្នេះក៏ដោយ ក៏គេ
ត្រូវតែសង្កេតចំពោះខ្លឹមសារនៃស្នាដៃរបស់អ្នកនិពន្ធទាំងនោះផង ព្រោះ
ថា ការចំរើនលូតលាស់តុំមែនសំដៅដល់ការកើនឡើងចំនួនប៉ុណ្ណោះទេ ត្រូវ
មានគុណភាពល្អប្រសើរថែមទៀត ។ បើសង្កេតត្រង់គុណសម្បត្តិនេះ
គេតែងមានយោបល់ថា ស្នាដៃទាំងនេះតុំបានប្រកបដោយគុណភាពល្អ
ទាំងអស់ឡើយ ដូច្នេះចំនួនច្រើនក៏ដូចជាតិចដែរ ។ បើយើងដេញ
ដោលតទៅទៀតថា ហេតុដូចម្តេចបានជាអ្នកនិពន្ធខ្មែរយើងតុំចិតចំសំ-
តែសំពាំងស្នាដៃខ្លួនឱ្យឆើតឆាយឡើង ? ឱ្យមានខ្លឹមសារសមរម្យតាម
វិស័យនាការកែងលោកឡើង ? ចំពោះសំនួរទាំងនេះ គេឆ្លើយបានថា៖

ក- មកពីស្រុកយើងជាស្រុកឯកកាជាថ្មី អ្នកនិពន្ធយើងភាគច្រើន
ទើបតែបានធ្វើសិក្ខាការកែងមុខរបរខ្លួនកន្លងយ៉ះតែលទៅថ្មីនៅឡើយ ។

ខ- ពេះបីស្នាដៃណាល្អតិសិដ្ឋគ្រាន់បើ ក៏តុំបានផលកន្លងការផ្សាយ
ល្អប្រុំគ្នាដែរ ព្រោះសៀវភៅនៅស្រុកយើងចោះពុម្ពកន្លងមួយលើកមិន
បានលើសពីពាន់ក្បាលផង (ចំពោះប្រលោមលោកធម្មតា តែលជា

កណ្តាល) ។ ដូច្នេះ អ្នកនិពន្ធតុំអាចមកផ្តើជំរឹតខ្លួនលើរបរបោះពុម្ពផ្សាយ
បានឡើយ ហើយវាលែតែមានរៀបប្រកបមុខរបរដទៃ ។ ល ។ តែ តុំមាន
ឧកាសហ្វឹកហ្វឺនក្នុងវិជ្ជាជីវៈជាអ្នកនិពន្ធឡើយ ។

គ- ពីដើមមកប្រទេសយើង តុំមានការសិក្សាអក្សរសាស្ត្រជាតិ
ឲ្យបានជ្រាលជ្រៅ ម្ល៉ោះហើយ អ្នកដែលចេះតែនិពន្ធក៏មកតែពីខេត.
កោសល្យរបស់ខ្លួនប៉ុណ្ណោះ ។

សេចក្តីបរិយាយមកនេះ បង្ហាញឲ្យយើញថា បញ្ហាដែលថាខ្វះ
អ្នកនិពន្ធនេះ គឺស្ថិតនៅលើគុណភាពតុំមែនលើចំនួនច្រើនតិចទេ ឬន
សេចក្តីថា ស្នាដៃដែលប្រកបដោយគុណភាពប្រពៃនោះ នៅមានចំនួន
តិចនៅឡើយ ។ ដូច្នេះបញ្ហាដែលយើងត្រូវដោះស្រាយតទៅទៀតគឺ
បញ្ហារិះរកទីមសារល្អ សំពាប់ការផ្សាយអក្សរសាស្ត្រយើង ជាពិសេស
ខាងផ្នែកប្រលោមលោក ។

២- បញ្ហាពុំជាន់សម្បុ ណាអ្នកអាន.- ជាការពិតណាស់
នៅស្រុកយើង តិតមែនតែពីដើមមកយើងជាជាតិមានវប្បធម៌ចាស់បរមបុ.
ព ណា ប៉ុន្តែជនជាតិយើងច្រើនខ្លះមកតែការស្គាប់ជាជាងការអាន ឬន
ន័យថា បើមានអ្នកម្នាក់អានសាស្ត្រាឬនិពន្ធរឿងប្រាកដជាមានមនុស្ស

ប្រើនទាក់មកចោមរោមស្តាប់ ប៉ុន្តែឲ្យអានពាំងអស់គ្នាវិញមិនចូលចិត្ត ឡើយ ។ ចំណាប់នេះមានរហូតមកដល់សព្វថ្ងៃ ទោះបីជាបានយល់ ហើយថា ការអានជាការប្រកៃមួយខាងបណ្តុះសតិអារម្មណ៍ក៏ដោយ ។ បើ គោលចំពោះប្រលោមលោក មានអ្នកខ្លះបានយល់ខុសថា សៀវភៅ ចែបនេះជាគ្រឿងនាំឲ្យខូចចិត្តខូចគំនិតទៅវិញ ហើយបានសំគាល់ក្នុង ចិត្តខឹងពោលប្រាប់គ្នាថា កុំឲ្យអានសៀវភៅចែបនេះទៀត ។ ចែតាមពិត យើងសូមរំលឹកថា រឿងប្រលោមលោកពាំងអស់ពុំមែនសុទ្ធតែជារឿងខូច រឿងអាក្រក់ទេ ដូច្នេះគួរតែនិយមពិនិត្យលើរឿងពាំងនោះសិនមុនខឹង រិនិច្ឆ័យថា រឿងនោះយ៉ាងណា ។ ប្រសិនជាយើញថារឿងនោះអាក្រក់ ក៏ចោះបង់ចោលទៅ តែបើយើញថាជារឿងល្អវិញក៏គួរតែណែនាំគ្នាគ្នា អានដើម្បីដកស្រង់យកបញ្ញាខ្លះ ។ ក្នុងរឿងនោះមកធ្វើជាបទពិចារណាក្នុង ដំណើរដើរតែយើង ព្រោះថារឿងប្រលោមលោក សុទ្ធសឹងជារឿងសម្តែង ឥរិយាវស់នៅធម្មតារបស់មនុស្ស ។ បានសេចក្តីថា បើមនុស្សរស់នៅមាន បញ្ញាអ្វី ប្រលោមលោកក៏ត្រូវមានបញ្ញានោះដែរ ដ្បិតគួរឿងតំណាមនុស្ស, មនុស្សធម្មតា ក៏សុទ្ធតែជាតួរឿងក្នុងប្រលោមលោកដែរ ។ តាហាណ៍ ដូចជា អ្នកដើរលេងមុខកំផ្លិច គឺជាតួសម្តែងរឿងដើរកំសាន្ត, អស់លោក អ្នកកំពុងអានសៀវភៅ គឺជាតួសម្តែងរឿងមនុស្សសិក្សាអានសៀវភៅ

ឯលៗ ម្យ៉ាងទៀតគួរដកចិត្តព័ការយល់ច្រឡំថា "ប្រសោមលោក គឺជារឿងលួងលោមចិត្តមនុស្សឲ្យត្រេកត្រអាងកាម" នោះចោលចេញ ហើយតម្បីយល់ថា "ប្រសោមលោក គឺជារឿងនិទានព័មនុស្សកំពុងជួបបញ្ហាក្នុងកាមកិលេស ហើយរិះរកវិធីដោះស្រាយឲ្យរួចព័កាមកិលេសទាំងនោះ" ដូច្នេះវិញ ។

៣- បញ្ហាពិចារណាការចោះពុម្ពផ្សាយ .- ក្រុងបញ្ហានេះ ស្ថិតនៅលើសម្ភារៈពាំងស្រុង ព្រោះប្រទេសយើងជាប្រទេសឯកភាពថ្មី ដែលព័មុនមកពុំមែនសម្បូណ៌ដោយទស្សាហកម្ម ជាពិសេសទស្សាហកម្មខាងពេងពុម្ពចោះផ្សាយនេះឯង ។ លុះប្រទេសយើងបានឯកភាពឡើង យើងក៏ចាប់មានការខាងពេងពុម្ពជាហូរហែមក ប៉ុន្តែសម្ភារៈសំពាប់ប្រើក្នុងនេះ ដូចជាម៉ាស៊ីនចោះអក្សរ, តួអក្សរ, ទឹកខ្មៅពុម្ព, ក្រដាស, . . . ព័មុនមក សុទ្ធតែទិញមកព័ប្រទេសក្រៅទាំងអស់ តែសព្វថ្ងៃយើងស្រាយបានខ្លះ ដូចជាមានពេងចក្រធ្វើក្រដាស នៅស្រុកយើងជាដើម ។ ដោយសារសម្ភារៈពេងពុម្ពមានតម្លៃច្រើន ព្រោះសុទ្ធតែជាវត្ថុនាំមកព័បរទេស ហើយការចោះពុម្ពសៀវភៅយើង ១ លើក ។ មានចំនួនតិចក្បាល ជាហេតុនាំឲ្យចុះសោហ៊ុយក្នុងការងារបៀបអក្សរពុម្ព ដូច្នេះហើយបានជាសោហ៊ុយចោះពុម្ពសៀវភៅនៅស្រុកយើងមានតំលៃខ្ពស់ នាំ

ឲ្យតិចបានដល់អ្នកមានប្រាក់ខាសតិចតួច ពុំអាចទិញសៀវភៅអានបានឡើយ ។

ចំពោះបញ្ហាជាខសំខាន់ចំនួន ៣ ដូចពោលមកខាងលើនេះ មានបច្ច័យខាក់ខន្ធគ្នាជាខ្លាំង ប៉ើដោះស្រាយតែមួយ ។ ជាប់ខ្នាពុំបានឡើយ តោងតែដោះទាំងបីត្រមគ្នាទើបខើរួច ។ ព្រោះថាប៉ើយើងម្នាក់ ។ ស្ថិតនៅខាងបញ្ហាមួយជាប់គ្នា ហើយយើងតាំងសំនួរនោះ ប្រាស់ជាការបកស្រាយសំនួរនោះដរត្រឡប់មកវិញជាពុំខាន ឧបមាថា ប៉ើយើងជាអ្នកទិញ យើងស្រែកថា " ខ្ញុំប្រកបរបរជាអ្នកលក់ខ្លួនពុំរួសទេ ព្រោះអ្នកអានមានចំនួនតិចណាស់ ! " ។ ប៉ើយើងជាអ្នកអាន យើងទំនស្រែកឡើយថា " ខ្ញុំចង់អានដែរតែសៀវភៅខាំងនោះមិនទាន់មានខ្មែរសារល្អ ហើយលក់ថ្លៃ ។ ណាស់ " ។ ប៉ើយើងជាអ្នកពេញភូមិ យើងទំនឆ្លើយតបមកខ្មៅថា " មិនឲ្យខ្ញុំយកតម្លៃច្រើនបែណាបាន ប៉ើសម្ភារៈខ្ញុំមានតម្លៃច្រើន ។ ណាស់ ហើយអ្នកលោះម្តង ។ មានចំនួនតិចក្បាលតេកក ប៉ើអ្នកលោះម្តង ។ ភាប់ហ្មឺនក្បាលទៅ ខ្ញុំនឹងយកថោកបំផុត " ។ ហើយអ្នកទិញទំនឹងស្រែកបន្តខ្មៅថា " ឲ្យខ្ញុំលោះច្រើន ។ បែណាបាន

បើអ្នកអានខ្មែរមានតិចណាស់" ។ ដូចពាក្យហារណ៍មកនេះ
ទាំងយើងយើញថា បញ្ហានេះវាពាក់ព័ន្ធគ្នាច្រើនជាមែន ។ ដូច្នេះ តួ
យើងផ្តន់ចិត្ត រកវិធីដោះស្រាយត្រឹមត្រូវទាន់ពេលដូចខាងក្រោមនេះ ៖

១- អ្នកនិពន្ធយើងគប្បីហ្មឹកហ្មឺនខ្លួនដើម្បីសរសេរកាន់ស្មាដៃផ្សេង ។
ឲ្យរឹងរឹតតែមានខ្លឹមសារវិសេសវិសាលឡើង ។

២- អ្នកអានគួរតែខំព្យាយាមអាន ទើណាតាំងតែគ្មានឲ្យស្គាល់ច្បាស់
ខ្លួនតម្លៃនឹងប្រយោជន៍នៃការអានសៀវភៅ ដែលនៅប្រទេសគេ គេពុក
ដូចជាចំណីអាហារ ទើងមានអាស្រ័យពុំបានឡើយ ។

៣- គប្បីរិះរេយ៉ាងណា ឲ្យមានអ្នកនិយមអានសៀវភៅកើនច្រើន
ឡើង ដើម្បីឲ្យបានការបោះពុម្ពកើនចំនួនច្រើនឡើង ទើងឲ្យចុះខ្លួនតម្លៃ
សៀវភៅនោះវិញ ត្រូវតាំងបង្កើតឲ្យសម្បូណិខ្លួសម្ភារៈសម្រាប់
ប្រើប្រាស់ក្នុងការងារនេះ ដោយមានជាផលិតកម្មនៅក្នុងស្រុកយើង
ផ្ទាល់ផង ។

ដោយគណៈកម្មការជាតិនៃការសិក្សា ផ្នែកអក្សរ « ក »

ក្នុងខែនេះ គណៈកម្មការបច្ចេកទេសផ្នែកអក្សរ « ក » បានប្រជុំពិភាក្សា ហើយបានសម្រេចយកជាបានការ នូវពាក្យដូចខាងក្រោមនេះ ៖

Alinéa	*n.m.*	វគ្គៈ សង្កាត់នៃសេចក្តី ពីបន្ទាត់ល្អកមួយទៅទល់នឹងបន្ទាត់ល្អកមួយ ។
Appliquer la peine		អនុវត្តទោស
Autochtone	*adj.*	ដើមកំសៅ
Condamné	*n.m.*	ទណ្ឌិត
Condamner	*v.*	ដាក់ទណ្ឌកម្ម
Concussion	*n.f.*	រឹតក្រម : បទល្មើសរបស់អ្នកកាន់ការដែលបង្ខាំប់ ឬបង្ខិតបង្ខំឲ្យទាំ ឬ កំទូលទ្រព្យវត្ថុដែលខ្លួនបានដឹងថាគេមិនដំណាក់ក្នុងមុខពន្ធអាករ ជ្រាក់ខែ ។ល ។
Corruption passive		សំណូកអកម្ម : បទល្មើសរបស់អ្នកកាន់ការ ដែលទទួលដំណូន ឬ កំច្នូរប្តេជ្ញា ដើម្បីប៉ះពាល់ ឬ មិនប៉ះពាល់កិច្ចណាមួយក្នុងមុខងាររបស់ខ្លួន ក្រៅអំពីបៀវត្សរ៍ទោះបីកំច្នូរនោះ ធ្វើដោយយុត្តិធម៌ក៏ដោយ ។
Corruption active		សំណូកសកម្ម : បទល្មើសរបស់ជនណាមួយ ដែលស្នូកអ្នកកាន់ការឲ្យធ្វើ ឬ មិនឲ្យធ្វើនូវកិច្ចការណាមួយជាមុខងាររបស់អ្នកកាន់ការនោះ ដើម្បីជាប្រយោជន៍ដល់ខ្លួន ។

(នៅមានត)

វិបត្តានុក្រមសំស្ក្រឹត-ខ្មែរ

ព្រះមហា ចាំង . ទាត់ រៀបរៀង

(តមក)

អតិវិហង្គ ន.ប៉ុ. ការិយាតាំទៅក្រៅលែង, ការៈក្រៅលែង ។

អតិវិហ្ស ន.ប៉ុ. ការិយាតាំទៅក្រៅលែង, ការិយាកន្ទុងទៅក្រៅលែង, (ឃប់), ការិយាទៅវិលត្រឹក ។

អតិវីក្រម គុ. នែលក្លៀវក្លាក្រៃលែង ។

អតិវីក្ស្បែ ឆគុ. យ៉តក្រៃពេក (ឆ្នូ) ។

អតិវីតបិ គុ. នែលងុំដ្ឋោះក្រៃលែង, នែលមិនមានប្រយោជន៍សោះ ។ – ភ្ជ គុ. នែលកោលងុំដ្ឋោះក្រៃលែង, នែលកុហកក្រៃពេក ។

អតិវីទ្ធ គុ. នែលមុតក្រៃពេក, នែលត្រូវរបួសហើយ ។

អតិវីធ្ស គុ. នែលមុខគួរអាស្រូវក្រៃពេក ។

អតិវិបយ៌ាយ ប៉ុ. សេចក្តីឆ្ងុយឆ្ងាក្រៃលែង ។

អតិវិបន គុ. នែលមានក្តៅក្រៃពេក ។

អតិវិប្រកម៌ ប៉ុ. ការឆ្ងាយក្រៃលែង ។

(នៅមានតទៀត)

ភាគ្លាទី ៤៧

ទេសនាវិបុលភជសេនា ឬ-ភាគ ប្រៃរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃធ្វើសបើបានអាន
ទឹងបេះទាយកលចំណាន
ចាំងមានសន្ធានស្នេហាដាត់

យូរ-អ៊ុន

នាងស៊ុនហ៊ូយ៉ងឮដូច្នោះខឹងណាស់ ក៏ដេរប្រទេចដាំយើថា អាចោរកំណាចមិនមានសេចក្តីតតាសោះ ក៏មកនៅកន្លែងស្រុកតាំងតាំងនេះ បានស៊ីបាយផឹកទឹកបងអញ ។ ក៏បានតាំងក៏ឲ្យធ្វើជានាយទាហានធំ ហើយចិញ្ចឹមកម្សាមិនឲ្យមានហ្នឹង , គួរប្តាក់មិនជាងគុណទុសត្រូវ ឲ្យតាជាមាត្រះចៅហៀនគេ ម្តាយអញនឹងស៊ុនគួន ក៏បានលើកអញឲ្យធ្វើកំយោឲ្យតែ តាលះឲ្យតាដឹកនាំអញមកនេះ ម្តាយអញនឹងស៊ុនគួនក៏បានត្រមអនុញ្ញាតឲ្យអញមក ដើយើយល់ថា អញបានចេះស្រឡាញ់តែមកប្រើនឬ? បានជាប្រើឯងតាំងតែនាក់ឲ្យលើកទាហានបន្ទុំធ្វើចាមកបន្ទំដណ្តើមសម្បត្តិបេស់អញ ។

ឈើសេង, គេងហាត់ឮដូច្នោះ កំខ្ញាចខ្លួនក្រែងមានសេចក្តីខុសខ្លះ ធ្វើយថា ខ្ញុំចុះចាំង ២ នាក់នេះ នឹងចាំនគិតប្រឆូសក៏យអ្នកគំរេ ព្រោះខ្លាចអាជ្ញាដីវយើប្រើ ចានជាលើកគាហានមក អ្នកចូរមេត្តាលើកគេសខ្ញុំចុះចាំងពីរចុះ ។ នាង់ស៊ុនហ៊ួយនក៏ស្រែកតំហឹកថា ដីវយើមានអាជ្ញាសំខ្លួនឲ្យសម្លាប់ចាន ។ ជាខ្លួនធ្វើតាម ឯខ្លួនយើងនឹងសម្លាប់ខ្លួនវិញមិនចាន ឬ ចានជាមកតាលោធ្វើការដូច្នេះ នាង់ស៊ុនហ៊ួយនក៏ដេរប្រគេចដីវយើជាច្រើនណាស់ ហើយក៏បង្ខំចរវាជស្រួតគៅ ឡៅតិនឹងដូឡុងក៏លើកគាហានតាមពីក្រោយ ។

ឯឈើសេង, គេងហាត់ខ្លាចនាង់ស៊ុនហ៊ួយន ក្រឡេកឃើញដូឡុងជាគាយគាហាន មានថ្ងៃដៅពីក្រោយឡៅតិ កំមិនអាចធ្វើប្រការម្តេចឲ្យគាហានវែកបើកផ្លូវគៅ តាលឡៅតិគៅឆ្ងាយហើយ ចម្ងាយផ្លូវប្រហែល ៦០ សិន (៦៤គ.ម.) ឃើញតាន់ចូនឹងក្តូជឿងលើកតាមឡៅតិមកដល់ពីនោះ ឈើសេង, គេងហាត់ក៏អធិប្បាយកំយរឿងឲ្យតិនប៊ូ,ក្តូជឿងស្តាប់ ។ តិនប៊ូថា អ្នកបណ្តោយឲ្យឡៅតិគៅរួចនោះខុសណាស់ហើយតឡូវ ស៊ុនគួនប្រើខ្ញុំចាំងពីរ មកចាប់ឡៅតិនឹងនាង់ស៊ុនហ៊ួយនឲ្យចាននាំគៅវិញ ។ ឈើសេង, គេងហាត់ឮដូច្នោះក៏ព័យស្តុតលើកគាហានតាមគៅចាំង ២ កន់ជាមួយគ្នា ។

ឯឡៅតិ ចានឮសំឡេងគាហានស្រែកហៅពីក្រោយ កំនំយាយនឹង

នាងស៊ុនហ៊ូយិនថា ឥឡូវគាហានតាមមកខ្លាំងហើយ យើងនឹងគិតប្រការម្តេច ? ។ នាងស៊ុនហ៊ូយិនថា អ្នកចំស្រុតទៅមុនចុះ ខ្ញុំនឹងជួយឆ្ងល់ទៅតខ្លាំងក្រោយ ។ ខ្មៅតិនឹងគាហាន ៣០ កំស្រុតទៅតាមមាត់ទន្លេ ជួយឆ្ងល់កំឲ្យគាហានឈរជុំគ្នាកណ្តាលផ្លូវ ឯខ្លួនជួយឆ្ងល់កំបរសេះកាន់លំពែងឈរអមមេទាងស៊ុនហ៊ូយិន ខ្លួលគាហានតាំង ៤ នាយ លើកតាមមកគាន់ កំចុះពីលើសេះចូលទៅគាប់នាងស៊ុនហ៊ូយិន ។ កំសួរគ្នាថា ក្មួយជឿងថា ខ្លួនគិតតាមមកនេះ ដោយគិតច្បាស់ការដូចម្តេច ? ។ គ្នាបប្ញី, ក្មួយជឿងឆ្លើយថា ស៊ុនគួនប្រើខ្ញុំបាទឲ្យតាមមកអញ្ជើញអ្នកនឹងខ្មៅតិវិញ ។

នាងស៊ុនហ៊ូយិនឮដូច្នោះ កំឆ្លើងវាំងក្រវែលក្រោធស្រែកគំហកថា ព្រោះមនុស្សពួកនេះខេតើ ក៏ធ្វើឲ្យយើងបងប្អូនខុសអធ្យាស្រ័យចិត្តនឹងគ្នា មាតាយើងនឹងស៊ុនគួន កំបានរៀបការយើងនឹងខ្មៅតិ ឲ្យជាស្វាមីភរិយា តាលយើងនឹងខ្មៅតិមកនេះ កំបានលាមាតា ត្រមឲ្យយើងទៅនៅស្រុកកេងដ៏វែជាមួយនឹងស្វាមីយើងហើយ យើងមិនមែនលបគេមកតាមអំពើចិត្តឯងកំខេ សូមប្រិស៊ុនគួនជាបងយើងកំគង់និយាយអនុលោមយល់ត្រមតាមវិលាប់ខ្លះខ្មៀមយកចិត្តយើងខ្លះ តែខ្លួន ២ នាក់នេះឯង បង្គាប់ស៊ុនគួនឲ្យលើកគាហានមកបំនឹងធ្វើអន្តរាយយើងឬ ? ។

នាយគាហាន ៤ នាក់ ឮដូច្នោះកំគិតថា នាងស៊ុនហ៊ូយិន នឹងស៊ុនគួនជាបងប្អូនគ្នា នាងនឹកស្រមៃជាមាតាស្រឡាញ់ស្មើដែរ បើយើង

ទីដែរធ្វើបំពានគ្រានេះទៅ ស៊ុនគួនដែលមានចិត្តកតញ្ញូដ៏ធំគុណមាតាមិន
អាចរំដែលចិត្តមាតាបាន យើងក៏ដឹងមានទោសទុស ព្រោះស៊ុន-
គួនខ្វាចមាតាណាស់ តដ៏ទីក្រឡាស់យកឡែរួចខ្លួន សេចក្តីទុសក៏ដឹង
ដូនធ្លាក់មកលើយើងពីរនាក់គ្នា បើយើងធ្វើសេចក្តីតាប់ប្រសើរពុកទីដឹងល្អជាង
យូរទៅក៏មិនមានសេចក្តីសុខ ហើយក៏មិនយើញឡៅតីក្នុងគ្រានេះសោះ
ចំពោះយើញតែជូឡុង ទីដឹងនាងស៊ុនហ៊ូយិន ឯជូឡុងក៏ដឹងរសេះកាន់លំតែង
ចេញអាការយ៉ាងម៉ាមួនបីដូចទីដឹងចូលសង្គ្រាម នាយពហាន៤ នាក់គិត
ត្រូវតែទីតគ្នាជូរបោះ ពាំងអស់គ្នាក៏ខ្មែនតំនាប់ ហើយបើកឡែនាងស៊ុនហ៊ូយិន
ទីដឹងជូឡុងចេញទៅ ។

នាងស៊ុនហ៊ូយិនក៏បង្ខំពហានឡែបរបៀតាមទៅពាន់ឡៅតី ។ ឈើសេង
ក៏ទីយាយទីដឹងពហានពាំងតួងថា អញ្ជើនាងស៊ុនហ៊ូយិនកំពៅហួសទៅ
ហើយ យើងទីដឹងរំលៃទៅវិញ តើទីដឹងយកសេចក្តីអ្វីទៅទីយាយ មានតែយក
តាក្សដែលនាងស៊ុនហ៊ូយិនថានោះ ទៅប្រាប់ដីរយើចុះមិនជាអ្វីទេ ប្រឹក្សា
គ្នាក៏មិនចុះរុះខ្លួលដីរយើម, ដីរថាយមកដល់ កំសួរនាយពហានពាំង ៤
ថា អ្នកពាល់គ្នាបានដួបប្រទះទីដឹងឡៅតីឬទេ? ។ នាយពហានពាំង ៤ នាក់
ធ្វើយថា ដួបប្រទះតីត្រឹក អញ្ជើឡៅតីលើកស្រែតរតៅហួសហើយ ដីរ-
យើមថា អ្នកពាល់គ្នាបានដួបប្រទះទីដឹងឡៅតីហើយ ហេតុម្តេចមិនចាប់ខ្លួន
ឡែបាន តីនបើ ទីដឹងភ្លេងក៏អធិប្បាយកំយើងឡែដីរយើមស្តាប់ ។ ដីរយើម

ថា អ្នកកាលគ្នាតែតវែងឆ្ងាចនាងស៊ុនហ៊ួយិន មិនបានចាប់ខ្លួនឡៅតីខុក
នោះមុខជាមានទោសខុសជាមិនខានសោះហើយ បើស៊ុនគួនតែស្រឡាញ់
នាងស៊ុនហ៊ួយិនជាប្អូន ហើយនឹងអារម្មណ៍ភ្ញាចមានជាប្រាកដ តាល
ណានឹងប្រគល់ក្រប៉ិអាជ្ញាសិទ្ធិនេះមកឲ្យយើងបង្គាប់យើងថា បើជួបប្រទះ
នឹងឡៅតីនៅទីណា ត្រូវឲ្យប្រហារជីវិតនាងស៊ុនហ៊ួយិនជាមុន រួចសឹម
សម្លាប់ឡៅតីជាក្រោយ ហើយឲ្យកាត់យកក្បាលទាំង ២ នាក់យកទៅ
ឲ្យបាន បើមិនបានក្បាលអ្នកទាំង ២ ទៅឲ្យស៊ុនគួនទេ ស៊ុនគួននឹងឲ្យ
កាត់ក្បាលយើងជាដំណូសវិញ ។

នាយភាហានទាំង ៤ នាក់ឮដូច្នោះ ក៏ព័យតក់ស្លុតឆ្ងើយថា ឥឡូវ
ឡៅតីលើកទៅជាយូរហើយ យើងនឹងតិតយ៉ាងម្តេចទើបស្រួល?។ ជីវយឹម
ប្រាប់ទៅឈីសេង , តេងហង់ថា ឡៅតីលើកទៅនោះសុទ្ធតែភាហាន
ដើរដើង ទោះដូចម្តេចក៏ស៊ុះតែតីយើងមិនផុត ឲ្យអ្នកទាំងពីរស្រួតទៅប្រាប់
ជីវយីឲ្យលើកភាហានខ្លួកយ៉ាងហ៊ោស ទៅចាំស្លាក់នៅផ្លូវមានតំនខ្នេរខ្លួនយើង
បួននាក់នឹងពួកភាហានក៏ស្រួតលើកតីខាងណោះ ទៅតាមផ្លូវគោកឲ្យខាង
តែខាន់ ម្តងនេះបើនាងស៊ុនហ៊ួយិនទាំងឡៅតីនិយាយយ៉ាងណាក៏ពុំត្រូវ
ដៀស្តាប់ ត្រូវតែចាប់កាត់ក្បាលឲ្យខាងតែបាន ឈីសេង, តេងហង់ស្តាប់
យល់យើញថាត្រូវ ក៏ទាំងគ្នាស្រួតតែតទៅប្រាប់ជីវយឹងស្រុកធសង់គុណ
ជីវយឹម, ជីវថាយ, តិនប៊ូ, កូដៀងក៏ដេញភាកងទ័ពស្រួតតែតប្រញាប់ទៅ ។

ឯខ្លៅតីនឹងខាងស៊ុនហ៊ីយិន នាំគ្នាទៅផុតដែនស្រុកសេងគុណ ហើយក៏ចុះទៅដល់មាត់ទន្លេកន្លែង ១ ឈ្មោះតំបន់ខ្លៅឡងវៃ ខ្លៅតីក៏នាំគាហានកមើលកន្សែរមាត់កំពង់ ដើម្បីនឹងរកទូកឆ្លងទៅស្រុកកេងដីវ ក៏មិនឃើញមានទូកឆ្លងទៅមកសោះ ខ្លៅតីរឹតតែត្រួយវិតក្តួលណាស់ ជូឡុងក៏និយាយនឹងខ្លៅតីថា យើងមកដល់ទីនេះផុតដែនស្រុកសេងគុណហើយ ចូលមកជាប់ដែនស្រុកកេងដីវ បើដូចជាខ្លាវួចតីទ្រុង លោកកុំរិតក្តួលអី យើងធ្វើសង្គ្រាមសម្រេចមកពល់ត្រា ក៏ដោយសារតម្រុះខ្លួនបេងរិះគិត ឥឡូវយើងមកដល់ដីតស្រុកហើយ មុខជាខ្លួនបេងជំងឺនឹងគិតឲ្យជាស្រេចមិនចាប់ព្រួយរវល់ប៉ុន្មាន ខ្លៅតីស្តាប់ជូឡុងនិយាយក៏គិតដល់សេចក្តីលំបាកព្រួយដោយខ្លួនមកតាមផ្លូវ ហើយក៏នឹកដល់សេចក្តីសុខសម្រាន្តដែលស៊ុនគួនបានខំនុកបំរុងក្នុងស្រុកតងងឹ ខ្លៅតីក៏អង្គុយសោកអាណិតអនាថខ្លួនទៅមាត់កំពង់ ខ្លួលក្មួសំឡងគាហានសេះលើកតាមមកជាច្រើន ក៏ប្រឹក្សានឹងជូឡុងថា គ្រានេះគាហានសេះលើកតាមមកច្រើនណាស់ មុខជាយើងដល់ខ្លួវសេចក្តីស្លាប់ក្នុងគ្រានេះហើយ ជូឡុងក៏មិនទាន់នឹងធ្វើយតបថាម្តេច ខ្លួលក្រឡេកទៅឃើញទូកប្រហែល ២០ ចែវមកតាមមាត់ទន្លេ ជូឡុងក៏ថា បុណ្យរបស់យើងដល់ហើយបានជាមានទូកមកដល់ សុំឲ្យលោកស្រួតប្រញាប់ដេញគាហានចុះដោយសារទូកនេះចុះ ឆ្លងទៅឲ្យរួចតីក៏យអន្តរាយ ។

លុះខ្លួកនោះចូលមកដល់ដំណាក ខ្លៅតាំ ពីរគ្រានមើលឃើញជាខ្លួកអ្នក
ដំនួញ ក្រឡេកមើលទៅខ្មៅតំឃើញខ្លួនបងរាត់អាវនឹងមួកចេញមកពី
ក្នុងដំបូល ខ្លៅតាំក៏អរណាស់នឹងប្រៀបតុំថ្នាន ទើបនាំទាងស៊ុនហ៊ូយិន
នូវបណ្តាពាហានលោតឡើងលើខ្លួកនោះគ្រប់គ្នា ខ្លួនបងឃើញខ្លៅតាំ
ក័យកំណាំ ក៏អស់សំណើចហើយថា តាំងតិចុំពាក់ពាហានបន្ទុំជាខ្លួក អ្នក
ដំនួញមកចាំខ្លួលលោកកំយូរណាស់ហើយ ខ្លៅតាំក្តដូច្នោះក៏ដេញពា-
ហានឲ្យថយខ្លួកផុតពីមាត់ច្រាំងទៅដល់កណ្តាលខ្នេ ខ្លួលដាវយឹម, ដាវ-
ថាយ, តន់ប៊ូ, កូដៀងលើកពាហានមកដល់មាត់ខ្នេ ។

ខ្លួនបងស្រែចចំអកហើយលើកដៃចង្អុលទៅថា នែអស់អ្នកពាល់គ្នាចូរ
ត្រឡប់ពិលទៅប្រាប់ដាយើជានាយខ្លួនចុះថា យើងបណ្តោយឲ្យដាយើនឹង
ស៊ុនគួនធ្វើកលៗបាយមកច្រើនគ្រាហើយ យើងក៏ខ្លួលតាមកលមកដល់
ថ្ងៃនេះ ការកំសម្រេចមកខាងយើងតាំងអស់ ដែលដាយើនឹងស៊ុនគួនមាន
ចិត្តសប្បុរសលើកខាងស៊ុនហ៊ូយិនឲ្យជាកវិយោខ្លៅតាំ ហើយថែមឲ្យអស់
អ្នកពាល់គ្នាលើកគ្នាមកតាមជូនដំណើរខ្លៅតាំខ្មៅនោះ យើងក៏គាប់ចិត្ត
ណាស់ខ្លៅតាំមិនមានក័យអន្តរាយអ្វីទេ កុំឲ្យដាយើគិតកលៗបាយអ្វីតទៅ
ខ្មៅឡើយ ពួកពាហានតាំងនោះឮហើយ ក័យកដ្ឋបាញ់ចម្រុះទៅដូច
គ្រាប់ភ្លៀង ព្រួញក៏ស៊ុះទៅមិនដល់ ។ ខ្លួនបងក៏ចង្អុំឲ្យពាហានចៃវខ្លួកឆ្ងាយ
ទៅត្រើយខាងនាយ ជិតទៅមាត់ច្រាំង ។

ឯដាវយីដែលដំនឹងសេចក្តីដោយឈឺសេន, គេនហនពៅប្រាប់ កំ
ប្រញាប់លើកខ័ពខ្លួកឲ្យអ៊ុយកាយជាបែកស្តាំ, ហ័នតុងជាបែកឆ្វេង ខ្លួន
ដាវយីជាខ័ពលួនស្រួតលើកតាមឲ្យពីពៅ ដាវយីឃើញឲ្យពីឆ្វេងពៅដល់
ត្រើយខាងណោះ ហើយក៏ដេញពាហានបែរខ្លួកពៅឲ្យពាន់ ខុនបេនឃើញ
ដាវយីដេញត្រសុកចូលមក កំឲ្យពាហានចតខ្លួកឲ្យើនប្រាំនខាងដើនទាំ
ឲ្យពីនឹងខាងស៊ុនហ៊ូយិនឲ្យើនគោកតែពៅ ដាវយីក៏ជិះសេះនាំអ៊ុយកាយ,
ហ័នតុង, ឈីសេង, គេនហន, នឹងពាហានពាំងពួនលើកតាមពៅ ។

ឯខុនបេនឹងឲ្យពីតែពៅដល់កុំ កុងដែនដំបន់អធិដាវដែលឲ្យគួនអ៊ូ
បង្កប់ពាហាននៅទីនោះ កំទាំឲ្យពីនឹងខាងស៊ុនហ៊ូយិនឲ្យើនពៅលើ
កុំពួលកុំ លុះឃើញដាវយីលើកតាមពៅដល់កុំនោះ គួនអ៊ូនឹងអ៊ុយអឿន,
ហង់តុង, កំលើកពាហានចេញស្កាត់ពីមុខ ដាវយីនឹងដេញពាហានចូល
ច្បាំងនឹងគួនអ៊ូកំនឹកញើតខ្លាច ព្រោះពាហានខ្លួនចំណានតែខាងដើន
ទឹក មិនប៉ុនប្រសប់ច្បាំងខាងផ្លូវគោក ហើយកំគ្នាននេះដែរគ្រប់គ្នា ដាវ-
យីក៏ថយពាហានត្រឡប់ក្រោយពៅវិញ គួនអ៊ូក៏ដេញចាក់កាប់សម្លាប់
ពាហានដាវយីស្លាប់អស់ជាច្រើន ហ័តតុងនឹងអ៊ុយកាយកំចូលប្រយុទ្ធគ្នា
ដាវយីក៏ម៉ាន់ពាហានចុះខ្លួកបាន គួនអ៊ូក៏លើកពាហានតាមពៅដល់មាត់
កំពង់ កំឲ្យពាហានស្រែកឲ្យដាវយីថា អ្នកឯងប្រើកលទុយយបញ្ឆោត
យើង ។ កំដឹងដល់ស្គាល់តំនិតអ្នកឯងពាំងអស់ ឥឡូវអ្នកឯងចាញ់កល

យើងវិញ ថែមទាំងលើកតាហានមកដូនដំណើរឡើតឲ្យខូចខាតតាហានទៅទៀត តំនិតអ្នកឯងយ៉ាងនេះឬ ដែលទីបបង្ក្រាបផែនដីតទៅ! ។

ដាវយីក្នុងដួងចិត្តកំត្រេកឡែកមើលទៅលើយើញខ្លើតទីងនាងស៊ុនហ៊ួយិនខ្លួនពួកស្រីចំរើនទៅលើកតួលក្នុង កំទឹកចិត្តក្តៅគគុកចិត្តខ្លាំងណាស់ ទើបបង្គាប់តាហានឲ្យឡើងទៅច្បាំងទៀត ។ ហ៊ានតុងទីងអ៊ុយតាយកំនិយាយឃាត់ថា តាហានយើងគ្មានសេះដុះសោះ តាហានទាំងនោះគេសុទ្ធតែជិះសេះគ្រប់ខ្លួន យើងតសូទីងគួនអ៊ូមិនបានទេ ។ ដាវយីយល់យើញត្រូវ កំគិតតែក្នុងចិត្តថា យើងគិតការចាយឲ្យស៊ុនគួនធ្វើគ្រានេះ បំផ្ទីងចាប់ខ្លួនការយកស្រុកកេងដីវឲ្យបាន កំថែមឲ្យរំខានខូចខាតបេះដូងតអំពើសោះ យើងទីងត្រឡប់ទៅស្រុកតង់ដីមើលមុខស៊ុនគួនកំមិនពេញក្នែក ដាវយីគិតក្តៅក្តួលរំជួលចិត្តស្ទើរទីងបែកទ្រូងរហែកជា ២ ឯពិសត្រូញដែលជ្រួតជ្រាបទៅក្នុងឥន្ទ្រីយតាមុនទោះ កំកំរើកតើតពិសឲ្យដួលសន្លប់ទៅមិនដឹងស្មារតីពួកតាហានក៏គិតភ័យច្រួលច្របល់ ទាំងគ្នាកៃរកាសឲ្យលស់ឲ្យដាវយីដឹងខ្លួនឡើងវិញ ហើយក៏លើកតាហានត្រឡប់ទៅស្រុកឆសងគុណ ។

ខណៈនោះ ខុងបេងក៏ទាំងឡើតត្រឡប់ទៅស្រុកកេងដាវ ហើយក៏ចែកបំណាច់ផ្ញើនពួកសេនាតាហានតាមសមគួរ ។ ឯដាវយឺម, ដាវថាយ, តីនប៊ូ, កួដឿង ក៏លើកតាហានទៅស្រុកឡាំស៊ី លុះទៅដល់ហើយក៏ទាំងគ្នាចូលទៅតណ្ឌិនាវឿងក៏ដំណរបស៊ុនគួនគ្រប់ប្រការ ។ ស៊ុនគួនឮដូច្នោះកំរឹងចិ

ណាស់ ទើបចាត់ទៀកៀងជាមេទ័ពតតែតលើកទៅវាយស្រុកកេងដ៏វែ ទទួល
ដ៏វែយ៉ែងនាំសំបុត្រមកដល់ស៊ុនគួនសេចក្តីថា ដែលខ្ញុំចាទចាន់ដែតតលទ
ទបាយគ្រានេះ ព្រោះតំនិតនឹងតម្រេះក្រែងថាខ្លួនជេនខ្ពស់ជាងខ្ញុំចាទ ចាន
ជាខ្លួចការអស្សារទៅ ទេសខ្ញុំចាទក៏ខុសណាស់ទៅហើយ វេលានេះខ្ញុំ
ចាទនឹងសុំតហានលោកលើកទៅវាយយកស្រុកកេងដ៏វែយ៉ែងគ្រាតែចាន ជា
ទីសង្ឃឹមតែវិញ ។

ស៊ុនគួនយើញសំបុត្រដូច្នេះ ក៏យ៉ែងកណ្តាតហានលើកទៅដោយខ្លួន
ឯង ។ ទៀវដៀវក៏និយាយហាមឃាត់ថា លោកនឹងលើកទ័ពទៅវាយយក
ស្រុកកេងដ៏វែគ្រានេះ ខ្សែរគិតពិគ្រោះមើលកលការឲ្យស្រួលបួលសិន
ព្រោះចួនួបកដ៏យនឹងយើងមែកទ័ពទៅគ្រានេះ ក៏ទៅរែចង់ចិត្តគិតអាយាត
ត្បាចាទមិនរសាយទេ តែដោយសារវាយើញថា លោកនឹងឡៅតីសត្វ
ថ្មីច្រាស្រែយកចំគ្នាជាចិត្តមួយ វាក៏នៅព្រួយមិនអាចនឹងលើកទ័តមក
ច្បាំង វេលានេះ ទើវាយល់ដឹងថា លោកលើកទ័ពទៅវាយស្រុកកេង
ដ៏វែហើយ តាសណាឡើយចួនួនឹងមិនលើកទ័តមកព្រួតវាយយកស្រុកកាំង
តាំងខាងណេះ ព្រោះវាយើញថា លោកនឹងឡៅតីមែកចិត្តតីគ្នា គ្រា
ក្រោយនេះយើងក៏នឹងចំលៅដោយកម្រណាស់ ។

កោះយ៉ុងនិយាយនឹងស៊ុនគួនឡើងទៀតថា សត្វថ្មីចួនួបានប្រើ
មនុស្សមកលួបស្តាប់ការជាជកច ទើយើញថា លោកនឹងឡៅតីមែកចិត្ត

តីគ្នាហើយ ចូចូតង់ឆ្លើយប្រើកលទៅលួងខ្លៅតី។ ភ្លាចរើងលើកទៅកាយ
យកស្រុក តំប្រមុខទៅចូលនឹងចូចូមិនបាន បើចូចូបានខ្លៅតីជាពួក
មួយហើយ កំតង់នឹងរួមតំនិតគិតការអ្វី។ ត្រូវគ្នាចាំងអស់ អំណើះតទៅ
ស្រុកកាំងតាំងនេះកំនឹងអន្តរាយនាសជាមិនបាន តំនិតខ្ញុំបានយល់ដោយ
ស្មានថា បើលោកធ្វើចុតហ្នាយចូលទៅគ្រាបបង្គំទូលព្រះចៅហៀនតេ
ឲ្យតាំងខ្លៅតីជាចៅហ្វាយស្រុកកេងដីវៃតេញទីតែម្តង ប្រពៃហាលស្រួល
ជាជាង ព្រោះចូចូប្លុកយើញថា លោកនឹងខ្លៅតីត្រូវគ្នាជាខ្លួនមួយចិត្តមួយ
ហើយ តាលណាឲ្យយកនឹងលើកទ័ពមកច្បាំងនឹងយើងខ្ញុំ ១ខ្លៅ
ខ្លៅតីកំមិនមានតំតួនទឹងអ្វីនឹងលោកសោះ រួចអំពីនោះសឹមយើងរិះរក
ឧបាយទៅនិយាយបញ្ឆោតឲ្យខ្លៅតីនឹងចូចូទុសអញ្ជាស្រុយគ្នាវិញ តង់តែ
អ្នកចាំងពីរនេះមិញនឹងតតាំងច្បាំងគ្នាឡើង យើងកំត្រូវលើកទ័ពទៅកាយ
ទ្រូបយកស្រុកកេងដីវៃយើញនឹងបានដោយងាយ ស៊ុនគួនស្តាប់និយាយ
កំតតយើញត្រូវ ទើបសួរកោះយ៉ុងថា អ្នកសំឡីងមើលទៅយើញនរណា
ដែលគួរនឹងប្រើឲ្យកាន់ចុតហ្នាយ ទៅថ្វាយដល់ស្រុកហ៊ូគោបាន កោះ
យ៉ុងថា យើញតែហ៊ូហ៊ុមមួយនោះ មានតម្រេះប្រាជ្ញាកងវៃណាស់
ចូចូកំឮបង់ដួបប្រទះស្គាល់កប់កន្ទុំគ្នាមកតាំដើម។ ស៊ុនគួនយល់ត្រូវ កំឲ្យធ្វើ
ចុតហ្នាយតាមវាក្យកោះយ៉ុងនិយាយ។ លុះធ្វើរួចកំប្រុកស្រោមប្រគល់ឲ្យ
ហ៊ូហ៊ុម។ កំលោះចេញទៅស្រុកហ៊ូគោ ខ្លួលចូចូនាំទាម៉ឺនមុខមន្ត្រីទ្វីបជ.

ការពៅស្រែនិងលែនឯស្រុកនឿបគុន ហ៊ូហ៊ុំមកតំស្រួតតាមពៅ ។

ឯបួនក្លួនោះ តាន់តាបែកខ្ញែកខ្ចែកខ្ចាតទ្រព្យរបស់ស្បៀងអាហារនិងសេនាពាហន កំមានសេចក្តីអប្បាយសអៀនខ្មាស ដេះតែរំតិតតំខ្ញុំតំគួនៅមិនជាប់ តែយើញថា ស៊ុនគួនទំនងខ្លាតាមៅធ្វើការរួបរួមយកចិត្តគ្នាក៏មិនអាចនឹងលើកកងទ័ពមកប្លន់ដណ្តើមយកស្រុកតាន់តាងនោះ ។ លុះព្រះពៅហៀនតេរសោយរាជ្យសម្បត្តិបាន ១៦ ឆ្នាំ ជារដូវខេសកាលគិមួន ។ បួនក្លួនតាំស្រឡាំងរបរាំរន្ធូរបណ្តាតាមុីនសព្វមុខមន្ត្រីពៅមើលប្រាសាទ ។ តនឹងសេកវែង ។ ដែលកសាងថ្មីនៅស្បែរមាត់ទន្លេដៀងហោ បួនក្លួនតាក់តែងរៀបខ្លួនប្រាណតាក់អាវខៀវពាក់មួកមាសឡើងអង្គុយលើប្រាសាទ ឯបណ្តាតាមុីនសព្វមុខមន្ត្រីនឹងសេនាពាហនកំឈរជាសង្ឃាត់គ្នានៅស្បែរប្រាសាទ បួនក្លួនគិតចង់មើលថ្មីដែតាហាន កំឱ្យយកសំពត់ព្រៃក្រហមយ៉ាងល្អៅចងតាក់លើមែកឈើថ្មាន់ ហើយឱ្យយក (វង់ប្តាញ់) វង់ឡៅពៅដោតទុកនៅចំមុខប្រាសាទចម្ងាយ ៤៥ ព្យាម ឱ្យតាហានតែងខ្លួនជាតំរួត តាហានណាសែជាមួយនឹងបួនក្លួន ឱ្យស្លៀកតាក់តណិក្រហមមួកក្រហម តាហានក្រៅពីនោះឱ្យស្លៀកតាក់តណិខៀវមួកខៀវ ឈរវៀងគ្នាត្រង់មុខប្រាសាទហើយបង្គាប់ថា បើអ្នកបាញ់ត្រូវ (វង់ប្តាញ់) ត្រង់វង់ឡៅយើងនឹងឱ្យបំណាច់រង្វាន់អាវ ១ បើបាញ់មិនត្រូវ យើងនឹងឱ្យផ័កខ្ចៅ ១ តែង ។

តួតតាហានក៏រៀបគ្នាឡើងដំរេះ ដោយប៉ុវាតាក់អាវក្រហមមួក

ក្រហមបរេះសេះវង់រំលេចញទៅមុខតាហានបាន ៣ ដុំ ហើយយើងធ្វើបាញ់ត្រូវត្រង់វង់ទៀ តាហានតាំងតួងកំពុងតន់ឃ្មោះស្គរហៅកងរៀបអីងកងចូលមានចិត្តត្រេកអរណាស់ថា មិនបង់ឬតែដែលចោទហ៊ុំរៀបសេះសោហិតនឹងយើង ហើយស្រែកបង្គាប់តាហានឲ្យទៅយកអាមែកឲ្យចោទហ៊ុំ ។ ណៈនោះ ប៊ុនផងនាយតាហានក៏បំផាយសេះចេញមកនិយាយនឹងចូលធ្វើថាសោកកុំអាលយកអាឲ្យចោទហ៊ុំសិន ហើយប៊ុនផងក៏យិតធ្វើបាញ់ត្រូវត្រង់វង់ទៀតទៀត តាហានតាំងតួងក៏ស្រែកហៅអីងកងឡើងទៀត ។

ប៊ុនផងស្រែកថា តាហានទៅយកអាមែកឲ្យយើង ចោហងឮដូច្នោះក៏បំផាយសេះចេញមកទៀត ស្រែកប្រាប់ប៊ុនផងថា អ្នកកុំអាលទៅដណ្តើមកយកអាវនោះឡើយ យើងនឹងបាញ់ឲ្យស្លាប់អ្នកទៅទៀត ចោហងក៏យិតធ្វើបាញ់ទៅត្រូវត្រង់វង់ទៀ ព្រួញក៏ដោតសៀតគ្នានឹងព្រួញមុន ខៀវទាប់ឃើញដូច្នោះក៏ថា ដែលអ្នកតាំង ៣ បាញ់ធ្លុមុនទោះមិនវិសេសដូចយើងទេ ខៀវទាប់ក៏ងាកខ្នងលើកធ្វើបាញ់ទៅ ព្រួញដោតជាប់ជិតព្រួញមុនជា ៤ ជ្រុងស្មើគ្នា, ហៃហ៊ូអឿន ពាក់អាវក្រហមមកបញ្ជរេះសេះទៅមុខតាហាន ឃើញដូច្នោះ ក៏យិតធ្វើបាញ់ប្រៃក្រាយទៅត្រូវចន្លោះព្រួញ ៤ ដែលជាប់មុន ក៏ស្រែកថា យើងបាញ់ប្លែកជាងអ្នកកល់គ្នា ហើយក៏បំផាយសេះរួលទឹងដណ្តើមយកកដ្ឋ ។

ស៊ីឡុងស្រែកថា អ្នកទាំង ៥ ចាញ់ត្រូវតែងរំខ្មៅ ហើយខនឹងយកអាវនោះមិនគួរទេ ខ្ញុំនឹងចាញ់ឲ្យបែកជាងអ្នកណាល់គ្នាទៅទៀត ហើយស៊ីឡុង ក៏យកឆ្នូចាញ់ទៅត្រូវមែកចង្រ្កាន់ដណ្តើកអាវនោះ ដាច់ភ្លាក់អាវចុះមក ស៊ីឡុងក៏ប់ផាយសេះទៅយកអាវនោះពាក់ត្រឡប់មកគត់នាប់ចូនតាហានទាំងពួងឃើញដូច្នោះក៏ស្រែកសរសើរស៊ីឡុងថា ប៉ុនចាញ់ឆ្នូនឹងភ្លេកអ្នកឯណាស្មើគ្នាន ស៊ីឡុងក៏បរសេះចេញមក ទៅជួយឃើញដូច្នោះក៏ស្រែកឲ្យស៊ីឡុងថា អ្នកកុំអាល់យកអាវនោះ ត្រូវទុកឲ្យយើងវិញ ស៊ីឡុងថា អាវខ្នះយើងចាញ់ត្រូវហើយ ត្រូវចានមកយើង ។ មិនត្រូវឲ្យអ្នកទេ ទៅជួញដូច្នោះក៏មិនធ្វើយតប ប់ផាយសេះចូលទៅដណ្តើមយកអាវ ស៊ីឡុងក៏យកដងធ្នូវាត់ទៅត្រូវទាំងជួ ។ ក៏យកដៃចាប់ចានកន្ត្រាក់មកនឹងឲ្យស៊ីឡុងភ្លាត់ពីលើសេះ ស៊ីឡុងលែងធ្នូរលោតចុះពីលើសេះ ទៅជួក៏ចុះពីលើសេះដូចគ្នា ទាំង ២ នាក់ក៏ចាប់ដណ្តើមយកអាវគាល់តែអាវនោះដាច់រហែកទៅទាំងអស់ ។

ជួនូរឃើញស៊ីឡុងនឹងទៅជួចាប់គ្នា ដោយខោសាទៅវិញទៅមកទាំងសងខាងដូច្នោះ ក៏ឲ្យតាហានស្ទុះទៅហាមឃាត់ចាប់តាញាចញពីគ្នា ហើយហៅឲ្យឡើងមកលើប្រាសាទ ឯទៅជួនឹងស៊ីឡុងក៏គត្រឹតឆ្នេញធ្វើអាការបើដូចនឹងចូលតស៊ូគ្នាទៀត ជួនូរក៏អស់សំណើចថា អ្នកទាំង ២ ជាតាហានមានចិត្តក្លៀវស្មើគ្នា ហើយមកធ្វើឲ្យតាស់ខែងគ្នាតើព្រោះអាវ ១ ដូច្នេះ

មិនគួរសោះ ចូរឲ្យកំហែងតាំងអស់ឡើងមកលើប្រាសាទ ចែកគ្រែច្រើនបែបឲ្យម្នាក់ៗជាប់ ហើយកំឲ្យរៀបតុលៀងអាហារគ្រប់គ្នា ចូរនូវថា យើងមកលេងគ្រានេះ មានសេចក្តីសប្បាយណាស់ ព្រោះបានយើញថ្ងៃដែ.ហានផ្សេង ។ ហើយក៏និយាយទំនងហានតាំងតួនថា អ្នកកល់គ្នាសុទ្ធតែជាអ្នកមានតម្រេះប្រាជ្ញាមានបណ្ឌាសក្តិ ត្រូវឲ្យតែងតាក្យកាត្យឃ្លោងសរសើរប្រាសាទថ្មីនេះ ដើម្បីឲ្យសប្បាយចិត្ត ។

នាម៉ឺនតាំងតួន កំខ្លួលប្រសាសន៍ចូរនូ គឺ: អង្គឡង ១ ចុងហ៊ុរ ១ អង្គធំន ១ តំនលឹម ១ កំតែងតាក្យកាត្យឃ្លោង ១ បទម្នាក់ សេចក្តីថា :

រីមហាទេបកដអាចជាធំ យើងគេនិយមព្រមចេតនា
លើកលោកឲ្យខ្ពស់តេញយសា ដូចមហាក្សត្រាជុតដែនដី ។
ជានតាំងប្រាបប្រាមសង្គ្រាមសឹក ហាត់ហ្វឹកសកលតលសេនីយ
ប្រឡងដ៏យជាញឲ្យយើញថ្មី ពេញតិតបច្ចុល្លីក្រៃអស្ចារ្យ ។
ទីប្រាថ្នាដែលសាងឡើងខ្ពង់ខ្ពស់ កំពុំស្មើឈ្នោះយសស័ក្តា
គួរសោងឡើងទៀតសុទ្ធសិលា ហៅមហាមណីនិវេសន៍ដ្ឋ ។
ឲ្យមានឋានតាំងបល្ល័ង្កតេជ្រ រំលេចក្បាច់ក្បាំងកំងកដតែ
ទើបសមជាទីមហាចក្រតិត្តិ គ្រប់គ្រងក្នុងកខ្ញុសីមាអើយ ។

លុះតែងហើយ កំដូនៅឲ្យចូរនូ ។ ខ្លួលកាត្យនោះមកហើយកំថា កាត្យនេះល្អប្រពៃណាស់ តែអ្នកសរសើរលើសណាស់ កាលតំដើម

យើងគឺជាមនុស្សប្រថុជ្ញាតិច ប្តេជ្ញាចិត្តគិតការនៃសេចក្តីស័ត្យតិតត្រង់ជាដំ
តាំង លុះដល់គ្រាព្រះចៅហៀនតេបានសោយរាជសម្បត្តិ ផែនដីក៏កើត
វិប្បរិតផ្សេង ។ យើងគឺបានសង់គ្រឹហាឋានៅក្រៅស្រុកចៅគុណាខាង
ទិសឯកើត ចម្ងាយពីស្រុកចៅផ្លូវប្រហែល ៥០០ សិន លុះដល់គ្រឹម្ភនៃរដូវ
ធ្លឹវស្សន្តរដូវ យើងគឺចៅមើលខំសាច់ខំនៀមផ្សេង។ លុះដល់ហេមន្ត-
រដូវ យើងគឺចៅស្វែងចាញ់សត្វលេងក្នុងចិត្តគិតថា បើផែនដីសុខភប
ាចហើយ ធឹងចង់ចូលធ្វើកជការជានាម៉ឺនឡុំផែនដីមិនបានដឹងថា ព្រះចៅ
ហៀនតេ ធឹងចំពោះឲ្យយើងជានាយឧហានដូច្នេះសោះ ឥឡូវនេះយើង
គឺមានចិត្តកតញ្ញូធឹងព្រះមហាក្សត្រ គិតតែធឹងប្រាថប្រាថ្នាមសឹកសត្រូវឲ្យ
ផែនដីភប្ញាប់ជាសុខថ្កាយប៉ុណ្ណោះ ចំពោះយកតែសេចក្តីតាប់ប្រសើរ
តទៅមុខ ឲ្យខ្ញុំឮថា យើងជានាយឧហាន បានជួយខំនុកបំរុងផែនដី
នៃព្រះចៅហៀនតេ វេលានេះគំរើញថា លុមសមគួរតាមតម្រិះគិតខ្លះ
មកហើយ ព្រោះយើងបានប្រាថប្រាថ្នាមកំចាត់សត្រូវកាជសម្បត្តិចេញជា
ច្រើន តាំងតីកាលគ្រាខៀវកុក តួតរចាវដួតក្បាលលៀងនោះ ដកបមក
ដល់សព្វថ្ងៃនេះ ព្រះចៅហៀនតេគំប្រាសតាំងយើងជាមហាឧបកជធំ
ជាងនាម៉ឺនតាំងតួង ហើយយើងធឹងបានគិតយកយសស័ក្តិឲ្យលើសជាង
នេះទៅទៀតគំនេ តែយើងនៅរិះគិតថា បានជួយខំនុកបំរុងផែនដីហើយ

កំត្រូវធ្វើឲ្យហួតតទៅ មួយទៀតផែនដីព្រះចៅហៀនតេនេះ បើកុំបាន
យើង គង់ខឹងមានមនុស្សកំណាចមកតាំងខ្លួនជាស្តេចគ្រប់ដំបន់មិនខាន ឯ
មនុស្សដែលគ្មានតម្រេះប្រាជ្ញាក៏មិនមានគិតដល់គុណូបការៈយើងឲ្យយើញ
ថា យើងបានជាធំខឹងបង្កាប់បញ្ជាអ្វីក៏ជាកម្មសិទ្ធិ នៅតែគិតសង្ស័យថា
យើងដូច្នេះដូច្នោះគំនុំសងទេតើ មិនត្រូវសោះឡើយ ខ្ញុំរហើយខ្លះក៏
ចាស់ក៏យខ្លួនឯង សព្វថ្ងៃនេះយើងក៏តាំងចិត្តគិតធ្វើកជការគេបស្នងធ្វើព្រះ
គេជព្រះគុណព្រះចៅហៀនតេដោយសុចរិត គិតតែក្តព្រួយមួយយ៉ាងៗ
ទៀតថា ចង់ខឹងលើកទ័ពមហាឧបកដនេះ ឲ្យដល់ព្រះញាតិវង្សព្រះ-
ចៅហៀនតេ ក៏មិនបានយើញប្រយោជន៍ដែលល្មមនឹងដួយគំនុកបំរុងផែនដីបាន
បើយើញមិនចេះស្មានលើកឲ្យតែម្តងក៏គង់ខឹងទាំងសៅ-
ហ្មងខ្លួនផ្ទាល់ជាមិន ដំណាតៅមុខខ្លួនយើងខឹងក្មួយបានពុក្តក្តៅក្រហាយ
ជាមួយគ្នាដែលយើងថាដូច្នេះ ជាសេចក្តីពិត មិនមែនគិតថា តែមាត់ក្រៅ
នោះទេ អ្នកទាំងពួងមិនទាន់ដឹងចិត្តយើងទេឬ? បើមិនដឹងហើយក៏ខឹង
សំគាល់ថា យើងយកតែពាក្យល្អមកបោក ។

នាម៉ឺនទាំងអស់គ្នាគំទាប់ហើយថា គំនិតរបស់មហាឧបកដដែល
គំនុកបំរុងផែនដីគ្រានេះ ល្អប្រសើរជាង អ៊ុំអិន ខឹងជាកង ដែលដួយគំនុក
បំរុងផែនដីនៃព្រះចៅសេងថងខឹងព្រះចៅសេងហងនោះទៅទៀត ។ ចូរឆ្ងួ

ជូរញ្ជុះ ក៏រឹតតែកំរើកចិត្តផឹកស្រាជារច្រើនតែឆន់ហើយយកពិតនឹងក្រដាសមកនឹងសរសេរឃ្វាង ។ ខ្ញុលចំរើសុំនគួនឈ្មោះហ៊ូហ៊ុមនាំសំបុត្រមកដល់ជូនទៅចូរឆ្ងួ សេចក្តីថា ឲ្យក្រាបទូលព្រះចៅហៀនតេ ព្រោះខ្ញុំតែនៅស្រុកគេនឹងដីវាយ ចាន់អាណាខេត្តជាចំណុះច្រើនដំបន់ហើយ តែឥឡូវស៊ុនគួនចាន់លើកបួនស្រីឲ្យជាការិយាខ្ញុំតែ សុំឲ្យតាំងខ្ញុំតែតេញ៉ាជាចៅហ្វាយស្រុកគេនឹងដីវ ចូរឆ្ងួយើញសេចក្តីសំបុត្រជូរញ្ជុះក៏តត់ស្តុតស្មារតីដៃដែលកាន់តិតក៏ចូតធ្លាក់ចុះ ដៀយុំកយើញជូរញ្ជុះក៏សួរថា មហាឧបភាជចូលកនឹងតែជ័យសង្គ្រាមប្រជុំយស្មាប់អាយុជីវិតដូចមិនមានតិតតិតភ័យចារម្ភប៉ុន្មាន ថៃ្ងនេះគ្រាន់តែឮតិមានមកប៉ុណ្ណោះ ក៏របេះជ្រុះពិតធ្លាក់ពីដៃសេចក្តីប៉ុណ្ណោះ តើនឹងយ៉ាងម្តេចទៅ ។ ចូរឆ្ងួថា ខ្ញុំតែនោះឧបមាដូចមករធ្លាប់នៅកនឹងតែត្រតាំងបីងបួតាំងពីកំណើត មិនធ្លាប់ស្គាល់តែរជ្រៅរសោះហើយវេលានេះ ទៅបានចុះកនឹងតែនតមហាសមុទ្រដ៏ជ្រៅតន្ទឹក ដូចជាខ្ញុំតែបានស្រុកគេនឹងដីវ តែរឹតតែមានតម្ងាំងក្លៀវក្លាឡើង ដូចមកវរនោះឯង អំណើះតទៅមុខ មុខជាយើងនឹងមានព្រួយដោយកំចាត់ខ្ញុំតែពុំបានតាមប្រាថ្នាដោយអាការដូច្នេះ បានជាយើងតក់ស្តុតកនឹងចិត្ត ។

(នៅមានត)

លោក កាយ.ប៊ុត ប្រែរៀបរៀង

(តមក)

គ្រានោះ ព្រះអង្គម្ចាស់ទ្រង់យាងចូលទៅកន្លែងហ្វូងមហាជន ហើយ ដាក់ព្រះសំរែតទៅលើនាល់យដូចអ្នកផងទាំងពួង, តែទ្រង់មិនយើញ អ្វីសោះឡើយ ទ្រង់សួរអ្នកដែលស្ថិតនៅជិតថា: តើអ្នកឯងមើលអ្វី ? ។ អ្នកនោះមុនទីតបទ្បើយ, ក៏បានភ័ន្តភ័ន្តយកឫកខ្ពស់ដាក់ប្បកិរិយាព្រះ អង្គម្ចាស់យ៉ាងហ្មត់ចត់ហើយទោលថា:

"ព្រះអង្គម្ចាស់ក្សត្រីនៃយើង ជាព្រះពុទ្ធតាមួយព្រះអង្គ មានព្រះ រូបឆោមស្រស់ប្រិមប្រិយប្រកបដោយព្រះធរិវ័ណ្ណល្អក្រៃគេក ។ ចំណែក ព្រះមហាក្សត្រយើង, ព្រះអង្គមានព្រះពុទ្ធហឫទ័យស្រឡាញ់ព្រះពុទ្ធ បុត្រីខ្លាំងណាស់ មិនឲ្យអ្នកណាក្រៅតព្រះអង្គយើញព្រះពុទ្ធបុត្រីនោះ សោះឡើយ, ដោយខ្លាចក្រែងមានមនុស្សចូលមកយើញព្រះពុទ្ធបុត្រីព្រះ អង្គក្នុងព្រះបរមពុទ្ធកំង, ក៏បានគ្រាស់បង្គាប់ឲ្យមេជាងយ៉ាងដំនាញម្នាក់ សាងព្រះដំណាក់មួយនៅលើអាកាស ។ ព្រះអង្គម្ចាស់ក្សត្រីទ្រង់គង់ នៅក្នុងព្រះដំណាក់តែមួយព្រះអង្គឯង, កន្លះ ១ ថ្ងៃ ក្រោយដែលទ្រង់បាន បន្ទើយព្រះពុទ្ធភាតភ្ញាក់ចូលក្នុងព្រះពុទ្ធអាណាចក្ររួចហើយ ព្រះពុទ្ធរបស់

យើងនេះស្តេចយាងទៅកាន់ព្រះរាជដំណាក់នៃព្រះអង្គម្ចាស់ក្សត្រី, ពេលនេះ ព្រះអង្គយាងទៅទីនោះហើយ, ប៉ុន្តែស្តេចនឹងយាងត្រឡប់មកវិញក្នុងពេលឆាប់ៗនេះ, យើងចាំងអស់គ្នានៅទីនេះរង់ចាំទទួលព្រះអង្គ" ។

គ្រានោះ ព្រះអង្គម្ចាស់ទ្រង់មានព្រះបន្ទូលសួរថា: "តេសាងព្រះដំណាក់ព្រះនាងយ៉ាងណា ចានផ្ទាទៅលើមេឃឯណោះ?" ។ អ្នកនោះក៏ក្រាបបង្គំទូលថា: "ព្រះដំណាក់ព្រះនាងគឺ ខេវតាសាង មានតែព្រះមហាក្សត្រិយតែមួយព្រះអង្គប៉ុណ្ណោះ ដែលទ្រង់មានព្រះសិទ្ធិយាងទៅកាន់ព្រះដំណាក់នោះបាន" ។

ព្រះអង្គម្ចាស់ ទ្រង់ចានកត់សំគាល់នូវតតិមានដោយសព្វគ្រប់ដែលបុរសនោះក្រាបបង្គំទូល, លុះពេលសន្យាកត្រី ទ្រង់ចានគង់លើអស្សតរហោះទៅកាន់ប្រាសាទព្រះនាង ដែលមានរស្មីភ្លឺរុងរឿងប្រាសផ្លេកល្អអស្ចារ្យ, លុះយាងដល់ខ្វាងភ្នំរាធដែលចូលទៅមហាប្រាសាទ, ទ្រង់ចុះពីលើអស្សតរ ហើយចូលទៅកន្លងមហាប្រាសាទ ។

គ្រានោះ ព្រះរាជធីតាទ្រង់ទតទៅឃើញមនុស្សដើរចូលមកកន្លងមហាប្រាសាទ ស្មានថាព្រះវរបិតា, តែតិទិត្យពិចយឃ្លាត់ចត់ នូវបុរសដែលដើរនោះ ព្រះនាងក៏ទ្រង់ឈ្វេងយល់ថា បុរសនេះមិនមែនព្រះវរបិតារបស់អញទេ, ប្រហែលជាខេវតាហើយ មនុស្សសាមញ្ញមិនអាចមក

ដល់ទីនេះទេ ។ ភ្លាមនោះ ព្រះនាងដ៏មានព្រះកាយស្រស់បំព្រង ដូចនាងទេវតាដ៏ឥត ទ្រង់យាងចេញពីក្រឡាព្រះបន្ទំទៅស្ទុះបុរសដែលដើរចូលមកនោះដោយឥតរវែកក្តីយ៉ាងក្រៃលែង ។ ឯព្រះអគ្គមហេសីឥតមានទ្រង់ព្រះទេ ត្រេតត្រអែលយល់ព្រះនាងភ្លាម ក្នុងព្រះហឫទ័យព្រះអង្គ ក៏ពុះពារដោយសេចក្តីស្នេហាយ៉ាងក្រៃលែង ទ្រង់ព្រះតម្រិះថា: " ឱ! ធ្វើម្តេចបាននាងជាព្រះទេតើ! " ។ ចំណែកនាង ព្រះពជ្រធីតាវិញ កាលបើទតទៅឃើញព្រះអគ្គមហេសីហើយ ព្រះនាងទ្រង់មានព្រះហឫទ័យរន្ធត់ជ្រួលច្រំដែរ ដោយឃើញសម្រស់ព្រះកាយរបស់ព្រះអគ្គមហេសីមានលក្ខណៈប្លែកពីជនសាមញ្ញ ។ ស្រាប់តែមួយរំពេចនោះ ព្រះនាងទ្រង់អាក់អន់ព្រះហឫទ័យជាខ្លាំងចំពោះព្រះវរបិតា ដោយទ្រង់ព្រះតម្រិះថា ព្រះបិតាបានបង្កាំងអញ ឲ្យនៅក្នុងមហាប្រាសាទតែម្នាក់ឯង មនុស្សគ្រប់រូបសុទ្ធតែត្រូវការដោយសេចក្តីស្នេហាចាំងអស់ ។ ក្រោយដែលព្រះអគ្គមហេសីទ្រង់ធ្វើសន្ទនាការ អស់កាលដ៏យូរបន្តិចមក ព្រះនាងទ្រង់សំដែងនូវព្រះពជ្រចំណងចំពោះព្រះអគ្គមហេសី ហើយទ្រង់កំសម្រេចនូវសមគ្គីសំវាសទៅតាមព្រះពជ្រចំណង ។

លុះព្រះអាទិត្យរះឡើង ព្រះអគ្គមហេសីទ្រង់យាងចេញពីមហាប្រាសាទ តម្រង់លើអស្សតរហោះមកចុះដឹតកោដន្ទីយដ្ឋានខាងក្រោម ។

តាមធម្មតា ព្រះមហាក្សត្រិយអង្គនេះ កាលបើស្តេចយាងទៅកាន់មហា-ប្រាសាទព្រះរាជបុត្រីហើយ ទ្រង់ចាប់យកព្រះរាជបុត្រីទៅថ្ងូនទ្រង់ជញ្ជឹង ព្រោះព្រះអង្គទ្រង់ជ្រាបថា បើនារីណាមានបុរសមករៀបរួម, នារីនោះ ទឹងឡើងទម្ងន់ជាមិនខាន ។ ពេលថ្ងូង ព្រះអង្គទ្រង់ចាប់ទតទៅឃើញថា ព្រះរាជធីតាព្រះអង្គមានទម្ងន់លើស ២ លីត្រ (១ លីត្រតាមធម្មតា កន្លះគីឡូក្រាម, ១ លីត្រអង់គ្លេសមាន ០គ.ក. ៤៥៣) ។ ព្រះមហា-ក្សត្រទ្រង់បើកព្រះនេត្រធំ ហើយមានព្រះកាយញ័រចំប្រប់ ទ្រង់ព្រះពិ-រោធយ៉ាងខ្លាំង, រួចទ្រង់ព្រះតម្រិះថា "ប្រហែលជាមានហេតុអ្វីហើយ" ហើយស្តេចយាងវិលត្រឡប់ទៅកាន់ព្រះបរមរាជវាំងវិញ ដោយប្រញាប់ប្រញាល់យ៉ាងក្រៃលែង ។ ពួករាជមន្ត្រីបានឃើញព្រះមហាក្សត្រិយទ្រង់មិនសប្បាយព្រះរាជហឫទ័យ គិតក្រាបបង្គំទូលសួរព្រះអង្គចំពោះរឿង នេះ ។ ព្រះអង្គទ្រង់ប្រាប់រាជមន្ត្រីឲ្យដឹងនូវតតិមានសព្វគ្រប់ ។

ព្រះរាជាទ្រង់មានព្រះរាជបន្ទូលសួរសីហនាទថា: "តើមានបុរស ណាអាចហ៊ានឡើងមកកាន់មហាប្រាសាទនេះក្រៅពីអញ! ចូរលោករាជ-មន្ត្រីពាំនាំយកជួយរិះរកនូវមេល្បាចុយ ដើម្បីទប់ទូវបុរសក្បាលាន នេះឲ្យបាន" ។

គ្រានោះ មានរាជមន្ត្រីម្នាក់ បានក្រាបបង្គំទូលថា: "នៅក្នុងព្រះ

ពជអាណាចក្រយើងនេះ មានយោធា ៤ នាក់ទ្វាប់មានទ្វីដៃ ប៉ើតាមទូលព្រះបង្គំជាខ្ញុំយល់ថា គួរស្តេចយាងព្រះបាទ ត្រាស់បង្គាប់ឲ្យយោធា ៤ នាក់នោះ ទៅយាមគ្រប់ទិសទាំងបួននៃមហាប្រាសាទព្រះនាង ប៉ើយើញបុរសណាមួយចូលមក ត្រូវចាប់បុរសនោះយកមកថ្វាយព្រះអង្គ" ។

ព្រះមហាក្សត្រិយទ្រង់មានព្រះបន្ទូលស្រួបតាមថា: "យោបល់លោកដូចម្តេចនេះសមមេឃណាស់, គួរយកមកអនុវត្តភ្លាមឥលូវនេះ" ។ លុះដល់សាយណ្ហសម័យ, ព្រះមហាក្សត្រិយស្តេចនាំពួកយោធាទាំង ៤ នាក់ យាងទៅកាន់មហាប្រាសាទព្រះពជបុត្រ ហើយទ្រង់ដាក់ឲ្យយាមមហាប្រាសាទនោះគ្រប់ទិសទាំងបួន ហើយស្តេចយាងត្រឡប់មកកាន់ព្រះបរមរាជវាំងវិញ ។ ឯពួកយោធាទាំង ៤ នាក់ជាអ្នកល្មោភខាងជេក ដល់ពេលព្រះអង្គម្ចាស់យាងចូលមកផ្ទំនឹងព្រះនាង, ពួកយោធានោះក៏ដេកលក់ឥតដឹងអ្វីទេ ។ ព្រះអង្គម្ចាស់ទ្រង់យាងចូលទៅកន្លែងមហាប្រាសាទផ្ទំជាមួយព្រះនាងរហូតដល់បច្ចូសសម័យ ។ លុះព្រះមហាក្សត្រស្តេចយាងមកកាន់មហាប្រាសាទព្រះនាង, ទ្រង់មានព្រះពជហឫទ័យក្រេវក្រោធជាខ្លាំង ដោយទ្រង់យកព្រះនាងទៅថ្នឹង, ស្រាប់តែព្រះនាងមានខមូនដល់ទៅប្រាំបីលិត្រ លើសពីកាលថ្នឹងម្សិលមិញៗទៀត។ ដំណឹងអកុសលនេះ បានឮទៅតាសេភញ្ញ, មានអ្នកទាយតាលតាក្ស

ខ្ញុំបខ្សៀវគ្នាអំពីរឿងនេះ ។ ព្រះរាជាទ្រង់មានព្រះរាជហឫទ័យអៀន អន់តតអប្បមា ហើយទ្រង់ស្ទើរមិនហ៊ានចេញពីព្រះបរមរាជវាំង, ទ្រង់ត្រាស់បង្គាប់ឲ្យអញ្ជើញលោករដ្ឋមន្ត្រីមួយរូបទៀតមកប្រឹក្សាទីព្រះអង្គ ។

លោករដ្ឋមន្ត្រីនេះក្រាបបង្គំទូលថា : " សូមល្អង់ធូលីព្រះបាទត្រាស់បង្គាប់ឲ្យលាបព្រះខន្ធសយនា, ព្រះសុវណ្ណគោច្ចៈព្រះនាង ខ្ញុំប្រទ្រង់ស្អិតពណិខ្មៅ ។ ដល់ពេលស្អែក, ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នានឹងនៃកនេ ពិនិត្យឲ្យហ្មត់ចត់ខ្លួរមនុស្សទាំងឡាយក្នុងរាជធានី ។ បើខោ អាមនុស្សណាមានប្រឡាក់ដោយប្រទ្រង់ស្អិតខ្មៅនេះ, មនុស្សនោះគឺជាអ្នកប្រព្រឹត្តបទទ្រង់នោះហើយ ។

ព្រះមហាក្សត្រទ្រង់ក៏ធ្វើតាមលោករដ្ឋមន្ត្រីនេះ ទ្រង់ត្រាស់បង្គាប់ឲ្យយកប្រទ្រង់ខ្មៅស្អិតទៅលាបក្រឡាព្រះបន្ទំ, ព្រះសុវណ្ណគោច្ចៈ ... ។ ល ។ ព្រះនាង ។ ឯព្រះអង្គម្ចាស់ទ្រង់ស្តេចយាងទៅគាន់មហាប្រាសាទព្រះនាងវិត ។ ដល់ព្រះអង្គម្ចាស់ទ្រង់ចេញពីមហាប្រាសាទពេលព្រឹក, ទ្រង់ទតឃើញថា ព្រះតស្ត្រារបស់ព្រះអង្គមានប្រឡាក់ដោយប្រទ្រង់ស្អិតខ្មៅ ។ ទ្រង់ក៏ផ្ញាស់គ្រឿងទ្រង់នោះ ដែលមានដាំតជាច្រើនទីតាមជង្គង់ជាច្រើន គ្រវែងចោលតាមបង្អួចនោះទៅ ។

(នៅមានត)

ទំនៀមទម្លាប់ នៃទេមរជាតិ
ខ្មែរគួរឱ្យឃ្លាត សិក្សាពេញទី ។
ព្រោះទេមរជាតិ ជាជាតិសោភ័
ក្នុងទ្វីបអាស៊ី តាំងតាំងតែងតាយ ។

ច.ព

រឿងព្រេងទ្រាវភ្នុសុកាសិទ ៤ បន្ទះ

១- ឃ្លានទំអត់ ៣- គេឲ្យត្រែនកុំយក
២- ឃ្លត់ទំរក ៤- ឱ្យចឲ្យចូលដិត

(តបប់)

បុរសនោះ គិតចូលទៅបរិភោគថ្វាយសំណល់តាយក្ស តែគិតឃើញថា គួរអញរកថ្វាយថ្នីខ្មែតទើបគួរ, ឥឡូវ ខ្មែ-ដំបង-កន្ទែងបក់-ភ្លោយទៅកន្លែងណាបង់ដែអញហើយ គួរអញសាកល្បងមើល តើតូកែយ៉ាងណាទៅ, គិតស្រេចហើយ ក៏និយាយទៅកាន់កន្ទែងថា "ចូរឯងទៅយកថ្វាយដង្កើយមកឲ្យអញ" ។ មួយសន្ទុះក្រោយមក បុរសនោះបានឃើញអហារគោជនរៀបជាថ្នីតាសេតព្រាលើតុ ក៏ចាប់បរិភោគទៅ ហើយធ្វើដំណើរតទៅទៀត ដើរកាត់ព្រៃតូច-ធំ អស់ពេលយូរថ្ងៃ ទើបដល់ទៅជនបទមួយ បានជួបទឹងតួកឈ្មួញ ៥០០ នាក់ ក្នុងម្នាក់ ។ មានរទេះ

មួយរយៈ, លុះឃើញដូច្នោះ បុរសកំសត់ កំចូលទៅសុំទឹកបរិភោគ
សន្ធឹតគ្នាដោយសេចក្តីកត់ទាក់, ទើបផុតក៏សាកសួរថា លោកតូ! ហេតុ
ដូចម្តេច ចានជាលោកតូមិនឈប់នៅទីនេះសិន ដើម្បីសម្រាកឲ្យគោផឹក
ទឹក ស៊ីស្មៅស្រួលបួលផង ។ ពួកឈ្មួញស្រែកច្រាបប់ថា ឧលោកអើយ!
ឈប់នៅទីនេះយូរពុំបានទេ ព្រោះទីនេះមានទុបស័គ្គដោយយក្សស្រីម្នាក់
វាចាំកំភ្ញើញមិនឲ្យពួកខ្ញុំសំចតនៅទីនេះ ។ បុរសក្មួដូច្នោះក៏សួរថា ចុះ
យក្សស្រីនោះនៅទីណា? ជួនខ្ញុំទៅចានឬទេ? ។ ពួកឈ្មួញនិយាយ
ថា កុំទៅអីលោក! យក្សស្រីនេះកាចសាហាវណាស់ វានៅឆ្ងាយពីទី
នេះប្រហែល ៤-៥ សិន ។ ដោយបុរសនោះខ្លួចខ្លាំងពេក, ពួកឈ្មួញ
ក៏ជូនទៅដល់កន្លែងយក្សស្រីនោះ ។ បុរសឃើញដូច្នោះ ក៏ដើរចូលទៅ
គ្មានកោតញញើតអ្វីឡើយ ។

យក្សស្រី កាលបើបានឃើញពួកឈ្មួញដើរចូលមក ក៏ស្រែក
កំភ្ញើញដោយប្រការផ្សេង១ ។ បុរសនោះ ក៏ប្រើខ្សែចងដំបងវាយយក្ស
ស្រីនោះ ។ យក្សស្រីដោយត្រូវនឹងដំបងយ៉ាងខ្លាំង ក៏ស្រែកគ្រហាយ
សួមចុះចាញ់ ខុកតែជីវិតតទៅ ទោះបើលោកបង្គាប់ដូចម្តេច ពុំហ៊ានរឹង
ទទឹងឡើយ ។ បុរសនោះថា "បើដូច្នោះអញ្ជើដោះលែងនានឯងបាន
ប៉ុន្តែ តទៅមុខកុំមកទីនេះទៀត" និយាយហើយ បុរសកំសត់ចានដោះ

លែងយកស្ត្រីនោះ ។ យកស្ត្រីមានចិត្តត្រេកអរណាស់ សំតះលាបុរសនោះរត់ចាត់ទៅ ។

ឯពួកឈ្មួញ មានសេចក្តីស្រមៃចំពោះឫទ្ធិរបស់បុរសកំសត់ជាខ្លាំងថា "យី! បុរសនេះខ្លាំងពូកែណាស់ហ្ន៎! ពួកយើងគួរជូនទ្រព្យសម្បត្តិដល់គាត់ខ្លះទើបគួរ ព្រោះគាត់បានជួយយើងឲ្យបានរួចពីសេចក្តីអន្តរាយ", គិតគ្នាស្រេចហើយ ពួកឈ្មួញក៏យកវត្ថុផ្សេង ។ ជូនបុរសនោះ ។

បុរសគិតថា បើអញយកបេះនេះទុសបណ្តាំគ្រូថា "គេឲ្យច្រើនកុំយក" លុះគិតយើញដូច្នោះហើយ ក៏និយាយទៅពួកឈ្មួញថា ខ្ញុំមានចិត្តត្រេកអរចំពោះអំណោយរបស់លោកជាខ្លាំងបំផុត ប៉ុន្តែសូមឲ្យលោកយកទ្រព្យសម្បត្តិនេះ ទៅប្រកបការងាររបស់លោកវិញចុះ ខ្ញុំសូមលាលោកទៅកាន់ស្រុកកំណើតវិញ ខ្ញុំចេញពីស្រុក ៤ ឆ្នាំហើយ តុំដឹងជាមាតាបិតាប្រពន្ធកូនបានសុខទុក្ខដូចម្តេចទេ ។

ពួកឈ្មួញបានសាកសួរឈ្មោះ ទីលំនៅ ឃុំ ស្រុក ខែត្រ នៃបុរសកំសត់ ។ កំប្រាប់ឈ្មោះទីលំនៅសព្វគ្រប់ដល់ពួកឈ្មួញ ហើយលាពួកឈ្មួញចេញដើរទៅ បានដល់គេហដ្ឋានរបស់ខ្លួន យើញប្រពន្ធកូនពាំងអស់សុខសប្បាយតាមដម្នាក, បុរសកំសត់សប្បាយចិត្តណាស់ គិត

ថា អញចេញទៅរៀនសិល្បសាស្ត្រអស់រយៈវេលា ៤ ឆ្នាំ ឥតបានវិជ្ជាអ្វីសោះ បានតែពាក្យបណ្តាំ ៤ ម៉ាត់ប៉ុណ្ណោះ ។

អ្នកស្រុកដឹងខាង កាលបើបានឃើញបុរសកំសត់ត្រឡប់មកពីរៀនវិជ្ជាវិញ គ្មានឃើញវត្ថុអ្វីមួយ ជាកំស្តុតាងយកមកផ្ទៀងប្រពន្ធកូន ក៏និយាយចំអកឡកឡឺយឡាថា ប្រពន្ធនៅផ្ទះ រកត្រីកខ្វះល្ងាច រកល្ងាចខ្វះត្រីក ដើរតែសូមទានគេ ។

បុរសនោះ ខឹកខ្មាស់គេជាខ្លាំង ប៉ុន្តែមិនដឹងធ្វើដូចម្តេច ។

ឯពួកឈ្មួញ លុះទៅដល់ផ្ទះខ្លួនវិញ ក៏ពិគ្រោះគ្នាថា យើងតាំងពីកើតមក តុំដែលបានឃើញមនុស្សណា មានឫទ្ធិដូចបុរសនោះសោះ, យើងត្រូវនឹកគុណគាត់កុំភ្លេច កន្លះពេលដែលយើងជួនទ្រព្យគាត់វិញ យកដូច្នេះ យើងត្រូវនាំគ្នាទៅលេងទឹងគាត់ម្តង យកទ្រព្យសម្បត្តិទៅជូនគាត់ដល់ផ្ទះក្រែងគាត់ខ្លួលយក ។ គិតគ្នាស្រេចហើយ ពួកឈ្មួញទាំងនោះក៏ផ្ទុកទ្រព្យសម្បត្តិលើរទេះ សេះ ដំរី បរឆ្ពោះទៅកាន់ស្រុកបុរសកំសត់ប្រមាណជាង ៩ ថ្ងៃ ទើបដល់ទៅភូមិនោះ, បានសាកសួរអ្នកស្រុកនូវឈ្មោះភូមិស្រុកនឹងឈ្មោះបុរសកំសត់ ។ គេក៏ចង្អុលបង្ហាញថា ផ្ទះរបស់បុរសនោះតូច បើយប្រក់ស្បូវមើលទៅឃើញលឹម។ ។ ពួកឈ្មួញក៏តម្រង់ទៅយ៉ាងប្រញាប់ លុះទៅដល់ផ្ទះបុរស បានជួបនឹងបុរសម្នាក់ទៀត

ក៏សួរថា លោកដែលទើបត្រឡប់មកពីរៀនវិជ្ជានៅផ្ទះទេឬ? ។ មនុស្ស
នោះឆ្លើយថា ហៅវាលោកធ្វើអ្វី! អាហ្នឹងអោមិនអោ អាមែនអាវ
ប្រពន្ធកូនរកតែបាយស៊ីគ្មាន រកព្រឹកខ្លះល្ងាច រកល្ងាចខ្លះព្រឹក ។ ពួក
ឈ្មួញបានស្គាល់ផ្ទះបុរសនោះហើយ ក៏នាំគ្នាចូលត្រសងៀវ លុះឃើញ
បុរសវិជ្ជានោះហើយ នាំគ្នាលុតជង្គង់ប្រណម្យអញ្ជលីគ្រប់ ។ គ្នា ។ បុរស
នេះ កំក្រោកឡើងទទួលពួកឈ្មួញដោយសេចក្តីពាក់ព័ន្ធក្រៃលែង ។ មនុស្ស
ជិតខាងឃើញហេតុដូច្នោះ, ក៏នឹកកង់ចិត្តថា ឈ្មួញចាំងនេះវង្វេង ឬ
អី? បានជាលុតជង្គង់សំពះមនុស្សអនាថា កំសត់ទុគ៌តរកបាយស៊ីគ្មាន ។

ឈ្មួញចាំងឡាយបានសាកសួរតើដំណើរបុរសនោះ ដែលមកតាម
ផ្លូវ ។ បុរសក៏បានប្រាប់វិញតាមដំណើរ ។ គមកពួកឈ្មួញសួរថា ដី
ភូមិនេះ ជាដីរបស់លោកឬ? ។

– ដីនេះ ជាដីរបស់គេទេ ខ្ញុំគ្រាន់តែសុំគេសង់ខ្ទមមួយប៉ុណ្ណោះ
(បុរសឆ្លើយ) ។

ពួកឈ្មួញក្តីដូច្នោះ ក៏តំរែតំរង់គ្នាថា "យើងគិតទិញដីនេះ ឲ្យបាន
៩០០ ក្បាម ៤ ជ្រុង សម្រាប់សង់ផ្ទះមួយដូចលោក ហើយធ្វើឃ្លាំង ជង្រុក
ក្រោលគោ.ក្របី នឹងធ្វើកំពែងព័ទ្ធជុំវិញ" លុះតំរែតំរង់គ្នាហើយ ក៏
រកទិញដីអ្នកស្រុកគ្រប់ចំនួន ៩០០ ក្បាម នាំគ្នាសង់ផ្ទះមួយយ៉ាងស្អាត

ព្រមទាំងឃ្វាំង ជង្រុកនឹងសម្ភារៈជាច្រើនទៀតជារបស់ខ្លួន, លុះសង់រួចហើយ
ក៏ជញ្ជូនព្រួយសម្បត្តិជាក់ឃ្វាំង ជាក់ជង្រុក ហើយអញ្ជើញបុរសវិជ្ជា
ព្រមទាំងប្រពន្ធកូនឲ្យឡើងទៅលើគ្រឹះស្ថានដ៏ស្អាតស្អមានោះ ។

ទៅបុរសព្រមទាំងប្រពន្ធកូន ក៏ឡើងទៅលើគ្រឹះស្ថានដោយរីករាយ
ទៅជាអ្នកមានមួយយ៉ាងធំ ។

ឯពួកឈ្មួញ ចានសូមចងជាមិត្តដ៏ស្និទ្ធនៅអនាគត ។

បុរសនោះ មានកេរ្តិ៍ឈ្មោះល្បីសុសសាយពេញទាំងព្រះនគរ ។
ដំណឹងនេះមិនចាត់ស្ងាត់ក៏ជ្រាបទៅដល់ព្រះមហាក្សត្រម្ចាស់ផែនដី ។ ព្រះ
អង្គទ្រង់ត្រាស់បង្គាប់ឲ្យបុរសនោះចូលគាល់, លុះទ្រង់សាកសួរបុរសនោះ
ជ្រាបសព្វគ្រប់ហើយ ក៏ទ្រង់ព្រះរាជទានឋានដល់បុរសកំសត់ជាមហាសេដ្ឋី
ក្នុងទីក្រុងនោះ ។

មហាជនពេញទាំងព្រះនគរ មានសេចក្តីកោតស្ញប់ស្ញែងនឹងបុរស
នោះយ៉ាងអស្ចារ្យ ។

រឿងត្រៃដប្រទេសយូហ្គោស្លាវី

ចែនអំពី «ប្រណីតភាព»

ប្រែពីភាសាអង់គ្លេស

ដោយ កិក្ខុ ម៉ែន-រៀម

សិស្សពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ

សម័យមួយ មានបុរស ៣ នាក់ ដែលមានដើមគ័រមួយដើម ហើយ ជាក់លេខគ្នាថែរក្សាឈើនោះ ។ កាលណា ជនពីរនាក់ទៅធ្វើការ, អ្នកទី ៣ តែងបិតទៅផ្ទះ ដើម្បីថែរក្សាដើមគ័រ កុំឲ្យមានសេចក្តីអន្តរាយណាមួយ ឬអ្នកណាមួយមកលួចបេះផ្លែឈើនោះបាន ។

គ្រានោះ មានខ្មាន់ក្តាមួយក្រុម ដែលត្រូវគេបញ្ជូនចុះពីស្ថានសួគ៌ ដើម្បីមកតាំសោធមើលចិត្តថ្នូរនៃជនទាំងបីក្រុមនោះ, ក្មេងកេតធ្វើជាយាចកលួច ហើយ, បានចូលទៅដិតដើមគ័រកន្លែងថ្ងៃដែលបងប្អូនបំផុតនៃជនទាំង ៣ នាក់ត្រូវនៅនោះ ហើយ ក៏បានលាដៃលួកទៅខាងមុខរួចនិយាយថា :

– ប្អូនប្រុស, កន្លែងនៃព្រះជាម្ចាស់សួគ៌ សូមប្អូនចែកផ្លែគ័រឲ្យបងមួយមក ! ។

បុរសឆ្លើយតប ដោយដួនផ្លែមួយទៅយាចកក្មេងក្លាយថា :

– ខ្ញុំសូមដួនមួយនេះ , ប៉ុន្តែថ្លៃដង្ហែទៀត ខ្ញុំដួនមិនបានទេ ព្រោះជារបស់ក្រុមបងប្អូនខ្ញុំ ។

ខេត្តាថ្លែងអំណរគុណបុរសនោះហើយ ក៏ធ្វើដំណើរចេញចាកទៅ ។

ថ្ងៃក្រោយមក ដល់វេនបងប្អូនទៅចាំ ។ ពេលនោះ ខេត្តាបានក្លែងកេងជាយាចក រួចមកសុំថ្លៃដង្ហែពីខ្ញុំម្ចាស់ទៀត ។ បុរសជាបងប្អូនបានដួនថ្លៃមួយទៅយាចកដោយពាក្យថា :

– សូមអញ្ជើញយកមួយនេះទៅចុះ , ប៉ុន្តែថ្លៃដង្ហែទៀត ខ្ញុំដួនមិនបានទេ ព្រោះជារបស់បងប្អូនខ្ញុំ ។

យាចកបានដំរាមបុរសនោះហើយ ក៏ធ្វើដំណើរដើរចេញទៅ ។

ថ្ងៃទី ៣ ជាថ្ងៃដែលប្អូនទៅត្រាំវេនយោម ហើយយាចកក្លែងក្លាយ ក៏ចូលទៅសុំដួចមុន ។ បុរសទី ៣ ក៏ធ្វើដួចបង ។ របស់ខ្លួនដែរ ។

នៅថ្ងៃជាបន្ទាប់មក, ខេត្តាកាលក្លែងកេងជាព្រះភិក្ខុមួយរូបរួចហើយ ក៏ចូលទៅរកក្រុមបងប្អូនទាំង ៣ នាក់នោះ តាំងពីព្រលឹម គឺនៅពេលដែលពួកនេះកំពុងតែបិតនៅក្នុងផ្ទះនៅឡើយ ។ ព្រះភិក្ខុបានមានថេរដីកាថា “ កូនប្រុស , មក ! , មកតាមអាត្មា ; ប្រហែលជាអាត្មាអាចរកវត្ថុអ្វីមួយដួនកូនឱ្យបានប្រសើរជាងការនៅឃ្លាំងដើមព្រៃតែមួយដើមនេះ” ។

បុរសទាំងបីនាក់ បានដើរតាមភិក្ខុក្លែងក្លាយនោះ អស់កាលយ៉ាងយូរ ទើបបានទៅដល់មាត់ប្រឹនមួយ ដែលមានភក់មូល ហើយមានទឹក

ស្រី ។ កិក្ខុ ចានសួរទៅបង្ហាញបំផុតថា ៖

- កូនប្រុសខ្ញុក, បើប្រសិនណាជាអាត្មាជូនតវដល់កូន, តើកូនត្រូវការតវបែបណា ?

- ឥន្ទឹងទៅជាការមួយអស្ចារ្យណាស់ បើប្រសិនជាទឹកបឹងតាំងមូលនេះ ក្លាយទៅជាស្រាទំពាំងបាយជូរ ហើយចានមកជាបស់ខ្ញុំ, (បុរសឆ្លើយ) ។

ក្នុណោះ ខេត្តាចានលើកដំបងរបស់ខ្លួន ហើយវាស់ជាសញ្ញាកកចុន ហើយក្លាមនោះ ទឹកបឹងតាំងមូលចានក្លាយទៅជាស្រាទំពាំងបាយជូរដែលកើតពីការបិតយ៉ាងធំ ។ មនុស្សតាំងឡាយ នាំគ្នាចាក់ស្រាបំតេញធុងដ៏ច្រើន រួចប្រមៀលចុះទៅ ។ មហាទស្សាហកម្មមួយក៏ប្រាកដទៅ ជាមួយគ្នានឹងកេង ផ្លុះហោង ហើយមនុស្សតាំងឡាយតេចុះទៅ ដោយវេល់ ហើយចានគាំគ្នាលើកបុរសជាបង្ហាញបង្ហស់ ធ្វើជាចៅហ្វាយរបស់ខ្លួន ដោយសេចក្តីគោរព ។

ឥឡូវ តវរបស់អ្នកចានសម្រេចហើយ, (កិក្ខុតោល) ប៉ុន្តែទៅតេលដែលអ្នកចានទៅជាអ្នកស្តុកស្តម្ភនេះ ចូរកុំភ្លេចនូវលិខិតាភនៃព្រះអាទិទេពទៅ ។

តេលនោះ កិក្ខុនឹងបុរសតាំងពីរនាក់ទៀតចានចេញដំណើរតេទៅមុខ, ចោលបុរសជាបង្ហាញទៅវិញ ឯនឹងទស្សាហកម្មស្រារបស់ខ្លួន ហើយតេ

ទៅរហូតបានដល់ភ្លេចការមួយ ជាទីដែលគេចង់ញ៉ាំមហូរគ្រាចជាច្រើន ។

- បើប្រសិនណាជាអាត្មាជួនពរមួយដល់អ្នក (តិចក្នុងពេលទៅតាន់បងបន្តាប់), តើអ្នកត្រូវការអ្វី ? ។

- ភាន់ធីនទៅជាហេតុដ៏អស្ចារ្យសម្បើមណាស់, (បុរសធ្វើយ), បើប្រសិនណាជាហូរគ្រាចតាំងអស់នេះ ក្លាយទៅជាហូរចៀម ហើយបានមកជារបស់ខ្ញុំ ! ។

ខេត្តបានលើកដំបងខ្លួនរួចត្រីវធ្វើជាសញ្ញាគាកបាទ ហើយមួយរំពេចនោះ ចំការតាំងមូល ក៏ពោរពេញទៅដោយហូរចៀម ។ ហើយមានពេងចង្រ្កា, មានផ្លុះច្រើនខ្នង, ស្ត្រីតាំងឡាយ តាំគ្នារែកដោះមេចៀម ហើយដួសយកភ្ញាស់ចេញពីដោះតាំងនោះមកធ្វើជា ហ្វ្រូមាំស ។ មានហូរបុរសរៀបចំចាត់ចែងដឹកជញ្ជូន ហើយមនុស្សដទៃទៀត តាំគ្នាសំអាតកេមចៀម ។ មនុស្សតាំងឡាយនោះ កាលដែលរត់សស្រាំចុះ - ឡើង ក៏មកញ៉ើញបុរសជាបងបន្តាប់ទៅធ្វើជាចៅហ្វាយនាយរបស់ខ្លួន ដោយគោរព ។

គេសួរនោះ ខេត្តបានតបថា :

- ឥឡូវ អ្នកបានសម្រេចសេចក្តីប្រាថ្នារបស់អ្នកហើយ, ប៉ុន្តែនៅគ្រាដែលអ្នកបានក្លាយខ្លួនទៅជាបុរស ប្រកបដោយសុភមង្គលបែបនេះចូរអ្នកកុំភ្លេចខ្លួនថាខ្លួនតែងតែជា ខៃព្រះអាទិត្យសោះ ! ។

ខេត្តាទីឯបុរសដាប្អូនៅ ចានបន្តដំណើរទៅមុខទៀត ហើយ ខេត្តាចានគោលថា:

– កូនប្រុស, ចូរឯងធ្វើសំណូមពរមួយទីឯគេចុះ ! ។

បុរសធ្វើយតបខេត្តាដោយសូមស្រឡាំងថា:

– បពិត្រលោកឪពុក, របស់ដែលខ្ញុំអង្វរកព្រះម្ចាស់សួគ៌ឲ្យជួយ នោះ មានតែមួយទេ គឺកំយាប្រកបដោយគុណសម្បត្តិ, សប្បុះ គួរឲ្យ គោរព តែប៉ុណ្ណោះ ។

– កូនឯង ស៊ុំតែនេះ ជាតែមួយក្រជាទីបំផុតក្នុងលោក ! (ខេត្តា ធ្វើយ); កង្វល់លោកនេះស្ត្រីដែលប្រកបដោយគុណសម្បត្តិ, សប្បុះ គួរ គោរពនោះ មានតែបន្តាក់ទេ, ហើយតាំនាក់ត្រូវគេដណ្តឹងទៅហើយ, ចំណែកឯស្ត្រីទី ៣ ជាព្រះអង្គម្ចាស់ ហើយគេលនេះ កំពុងតែត្រូវ ព្រះមហាក្សត្រតាំព្រះអង្គ បញ្ចុះបញ្ចូលឲ្យរៀបការជាមួយ ។ បើ ដូច្នេះ, ចូរយើងទៅគេព្រះមហាក្សត្រ ដើម្បីក្រាបទូលទ្រង់តាំសេចក្តីសុំ របស់ឯង ។

គេលនោះ គេដើរដោយស្ងៀតស្ងៀតមកផ្ទះឆ្ពោះទៅទីក្រុង ជាទីដែល ព្រះអង្គម្ចាស់គង់នៅ, ដល់ហើយ ក៏ចូលទៅក្នុងព្រះបរមរាជវាំង, មានអា-ការៈដូចជាជុនជាបយ៉ាំប៉ាយ៉ីនេះដាយដំណើរ ។

ព្រះមហាក្សត្រទ្រង់អនុញ្ញាតឲ្យដនតាំង ២ រូប ចូលក្រាបបង្គំគាល់

ហើយកាលដែលដន់ ២ រូបគ្រាបទូលតាមសេចក្តីរបស់ខ្លួន ព្រះមហាក្សត្រក៏លាន់ព្រះឧស្ឋថា:

– ឃើ, ឲ្យខ្ញុំសម្រេចយ៉ាងណាទៅហ៊ឺ? ស្តេចតែអង្គ ហើយឥឡូវថែមបុរសកំឡោះមួយទៀត ចូលមកសុំចង់មេត្រីភាពដើម្បីបុត្រីខ្ញុំ ក្នុងថ្ងៃជាមួយគ្នា! តើឲ្យខ្ញុំថាម៉េចទៅ? ។

– ក្រាបទូល រឿងនេះ ទុកឲ្យព្រះអង្គម្ចាស់សួគ៌សំរេចវិញចុះ! (ខេត្តាធ្វើយ) ។

– អ៊ីចឹងមែនហើយ, ប៉ុន្តែត្រូវធ្វើយ៉ាងម៉េច? ។

– តាមរបៀបនេះ សូមទ្រង់មេត្តាប្រកាសកាត់មែកខំពាំងចាយដូរចំនួនបីមែកមក ហើយសូមឲ្យព្រះកដឹតាព្រះអង្គ ធ្វើសញ្ញាលើមែកពាំងបីសំគាល់ខ្លួវឈ្មោះផ្សេង។ គ្នា នៃគូដណ្តឹង។ រួចហើយ, សូមព្រះកដឹតា យកមែកពាំងបីទៅដោតជាំទៅក្នុងទន្សាន, ទាក្រឹះ។ បើមែកណាមានផ្ការីកនៅវេលាយប់នេះ, មានចង្កើមខំពាំងចាយដូរខ្ញុំ ក្នុងវេលាព្រឹក, សូមទ្រង់អនុញ្ញាតឲ្យឈ្មោះ ដែលមានជាប់នៅលើមែកនោះ មកជួលព្រះមន្ត្រីលាក់សេកជាមួយព្រះកដឹតា នៃព្រះករុណាក្រាបទូល! ។

– អើ! យោបល់នេះ ចំជាគេតមែន! (ព្រះមហាក្សត្រទ្រង់ប្រកាស) ។

ពេលនោះ ព្រះអង្គម្ចាស់ក្សត្រី ទីឆ័ត្តដណ្តឹង បានយល់ព្រម តាមយោបល់នេះ, ហើយព្រះអង្គ បានសរសេរឈ្មោះគូដណ្តឹងលើ មែកចំពាំងបាយជូរបើមែករួចយកទៅដាំ ។

ព្រឹកឡើង គេឃើញមែកពីរ បានស្ងួតស្រពោនជ្រុះស្លឹកស្ងើអស់, មែកទីបី មានស្លឹកខៀវខ្ចី មានចង្កោមផ្លែចំពាំងបាយជូរពុំ, ឯឈ្មោះដែលចារឹកនៅលើមែកមានក្តា គឺជាឈ្មោះនៃបុរសជាប្អូនពៅគេនោះឯង ។ ព្រះមហាក្សត្រទ្រង់ខ្លួលអាជ្ញានៃព្រះម្ចាស់សួគ៌នេះ ដោយឥតមានសាកសួរដេញដោលអ្វីឡើយ, ទ្រង់នាំព្រះកដឹតាទៅគាន់ព្រះរាជា ហើយអនុញ្ញាតឲ្យបុត្រីរៀបមង្គលការសេក ជាមួយបុរសប្អូនពៅ ។ បន្ទាប់មក, ព្រះមហាក្សត្របានប្រសិទ្ធពរ រួចបញ្ជូនអ្នកចាំងពីរ ចេញពីប្រាសាទ ឲ្យទៅតាមទេព្តា ដែលនាំអ្នកចាំងពីរចូលទៅក្នុងព្រៃ រួចទុកអ្នកចាំងពីរចោលក្នុងព្រៃនោះ ។

មួយឆ្នាំកន្លងផុតទៅ ទេព្តាត្រូវគេបញ្ជូនត្រឡប់មកគាន់ផែនដីម្តងទៀត ដើម្បីពិនិត្យមើលឲ្យដឹងថា តើបុរសជាបងប្អូនចាំងបីនាក់ ក្លាយទៅជាយ៉ាងណាហើយ ។ គាន់យកទូរស័ព្ទលៀកបំភាក់ជាស្នួមយាចកដូចជាន់មុន, ទេព្តាបានចូលទៅកេបងឡងបង្ហស់ ដែលកំពុងតែរៀបរៀងជាមួយនឹងស្រាទឹងការបិតស្រាបេស់ខ្លួន ។

- សូមលោកមេត្តាប្រទានស្រាឲ្យយាចកខ្ញុំ មួយតែងមក: (ទេព្តាសុំ) ។

- ថយចេញ, អាយាចកកញ្ជាស់! (បុរសគំហកឲ្យ ដោយគំរោះគំរើយ), បើអញចេះតែឲ្យមួយដែនៗគ្រប់តែយាចកដូច្នេះទៅ ខ្លួនអញមុខតែនឹងក្លាយទៅជាយាចកមិនខាននេះ! ថយចេញទៅ! ។

ខេត្តា លើកដំបងត្រៀ ធ្វើជាសញ្ញាកាកចាខ, ចូរមើល! ស្រា, ការចិតស្រា, កេង នឹងកម្មការចាត់អស់រលីង ហើយខន្ធកងមូល មានតែកង្រៅ ក៏ច្រាកដូច្បើងដូចមុន ។

- ដោយបានដួបភ័ព្វវាសនាល្អ គាត់ឯងទៅជាក្តេចសេចក្តីត្រេកត្រប់របស់ព្រះអាទិទេពអស់, (ខេត្តាពោល ដោយមធ្យត), ត្រឡប់ទៅរដើមពីរគាត់ឯងវិញទៅ! ។

ឯខេត្តា ចានបន្តដំណើរទៅដួបបុរសជាបងប្អូនជាច់ខ្លែក ដែលកំពុងតែរវល់តងតិចួការធ្វើតែដោះនឹងហ្វូងមាំសរបស់គេ ។

- ខ្ញុំសូមគោរព, សូមលោកមេគ្រាប្រចានមកយាចកខ្ញុំ ខ្លួរហ្វូងមាំសមួយដុំមក! (ខេត្តាសុំ), ។ អញឲ្យហ្វូងមាំសទៅមនុស្សកំដរក្តក់ គ្មានចានគុណបំណាច់ ដូច្នេះ ម្តេចកើត! ។

ខេត្តាលើកដំបងច្បើងត្រៀជាសញ្ញាកាកចាខ, ចៀមនឹងពុហខង្ហាន ហើយនឹងកិច្ចការរវល់តាំងអស់ កិរិយាសអស់រលីង, ហើយលេចចេញឯចំការជាទីនៅនៃហ្វូងត្រាប ដែលគេចត្តឹមដូចដើមវិញ ។ គេលនោះ ខេត្តាពោលដោយម៉ឺងក្រាយថា ៖

- អ្នកឯងកំពុងសេចក្តីទុក្ខក្រវេរស់ព្រះគាងខេត , ថយក្រឡប់ទៅ
វិញដើមតាអ្នកឯងវិញចុះ ! ។

ខេត្តា ចាប់បន្តដំណើរដោយប្រញាប់ប្រញាល់ឆ្ពោះទៅកាន់ព្រៃ
ដែលខ្លួនចាប់យកបុរសជាប្អូនទៅទីដ៏ប្រតិទ្ធដែលជាព្រះអង្គម្ចាស់នោះទៅ
ចោល ។ លោកចាប់ឃើញ អ្នកតាំងតាវេស់នៅក្នុងមហាទុគ៌តភាពក្នុង
កូនខ្លួនកំព្រាកនោះ ។

ខេត្តា ដែលនៅតែក្តីងកេងជាយាចកគោកយ៉ាកនោះ ចាប
គោលថា ៖

- សូមឲ្យព្រះអាទិទេពបិតនៅជាមួយអ្នក ! តាមនាមព្រះជាម្ចាស់
សួគ៌ , សូមលោកប្រទានចំពោះខ្ញុំ នូវសាយភត្តបន្តិចមក , ហើយ
ខ្ញុំសូមជ្រកនៅទីនេះមួយយប់ផង ។

- ខ្លួនយើងនេះ ជាមនុស្សទីទ័លសម្បើមណាស់ , (បុរសឆ្លើយ) ,
ប៉ុន្តែ សូមអញ្ជើញចូលមក , យើងនឹងចែកឲ្យអ្នក "នូវអ្វីដែលយើងមាន" ។

បុរសជាប្អូនទៅ ទីព្រះអង្គម្ចាស់ក្សត្រី ចាបសំរួលយាចក ដោយ
ជូនភ្លើងសំកប់អាំង , ឯព្រះអង្គម្ចាស់ក្សត្រីចាបរៀបកន្ទែងបី សម្រាប់
អង្គុយបរិភោគចុយល្ងាច ។ ប្តីប្រពន្ធនេះ ក្រឡាំងដល់ថ្នាក់ថា ដុំ
ទំប៉ុងដែលចំអិននៅលើចង្ក្រាន មិនមែនធ្វើពីមៀសោះឡើយ គឺធ្វើពី
សម្បកឈើបុក ដែលបុរសជាស្វាមីសែងកេតីត្រៃមក ។

ប្រពន្ធ ថានទៅយៗតិចៗថា :

- អ្នក, ខ្ញុំភ្ញាសអ្នកណាស់ដោយគ្មានខំប្រឹងពិតប្រាកដដូនអ្នក ដែលជាភ្លៀវរបស់ខ្ញុំពីសា ។

- ខ្ញុំត្រូវការបន្តិចបន្តួចទេ, (ខេត្តាឆ្លើយដោយញញឹម) ។

ប៉ុន្តែ នៅពេលដែលគេទៅបើកចង្ក្រានម៉ើលហើយស្រាប់តែប្រទះឃើញដុំខ្ទប៌ក្រហមឆ្អិនឆ្អៅពីមេឡូស្រវែសាលី, ព្រះអង្គម្ចាស់ក្សត្រី ក៏ស្រែកយំឡើងថា, "ខ, ខេត្តាដួយហើយគេ!" ហើយនាងក៏យំសោកដោយការភ្ញាក់ ខឹងដោយសេចក្តីសប្បាយចិត្តខ្លាំងពេក ។

ព្រះអង្គម្ចាស់ក្សត្រីបានទាញយកថូដ៏ ដែលពេញដោយទឹកជ្រោះមក, ហើយកាលចាក់ទឹកនេះទៅក្នុងពែង វាស្រាប់តែក្លាយទៅជាសុភទំពាំងបាយជូរដ៏ផ្អែមមួយថែម ។ ចំណែកខាងបុរសជាស្វាមី ក៏គេមានសេចក្តីសប្បាយហួសប្រៀបដូចជាព្រះអង្គម្ចាស់ក្សត្រីដែរ ។

ខេត្តាបានពោលថា :

- ដោយហេតុតែសុភមង្គលរបស់អ្នក, អ្នកមិនបានបំភ្លេចចោលនូវសេចក្តីល្អរបស់ព្រះអាទិទេព, ដូច្នេះ អាទិទេពនឹងផ្តល់រង្វាន់ចំពោះអ្នក! ។

ជាដូច្នេះហើយ, ខេត្តាបានលើកដំបងរបស់ខ្លួនឡើងហើយ ត្រឹមធ្វើជាសញ្ញាភាកបាទ ហើយភ្លាមនោះ ខ្លួនពុតតែវិនាសបាត់ទៅ ។

ប្រាសាទអស្ចារ្យមួយ គោរពតាំៅដោយជនជាន ទីដ៏វិសេស ។ កំប្រាកដឡើង ត្រង់ទីដែលខ្ញុំមជាត់ៅ ។ ភាសាសំាង់ឱ្យ ច្រើនភាក់ កំដើរចុះឡើងប្រាត់, រួចគេបានលើកបុរសកំសត់ធ្វើជា "ចៅហ្វាយប្រុស" របស់គេ, លើកព្រះអង្គម្ចាស់ក្សត្រីជាភរិយានៃបុរស នោះធ្វើជា "ចៅហ្វាយស្រី" ។

យាចកគោកយំាក បានក្រោកឈរឡើងដោយមានមុខញញឹម រួច ស្តីថា :

- សម្បត្តិតំាង់នេះ គឺព្រះអាទិត្យបានឱ្យដល់អ្នក, ហើយសម្បត្តិ តំាង់អស់នេះ ទីតាំៅជារបស់អ្នក ដកបណាអ្នកចេះចែកលែកដល់អ្នក ដទៃផង ។ ខ្ញុំសូមប្រសិទ្ធិពរសិរីសួស្តីឱ្យកើតមានដល់អ្នក ហើយខ្ញុំសូម លាហើយ ណាកូន ! ។

តេលរួច, ខ្ញុំបានត្រឡប់ៅកាន់ស្ថានសួគ៌វិញ ដើម្បីធ្វើសេចក្តី ពយាករណ៍អំពីសោភណភាពនៃបេះដូងរបស់បុរសជាប្អូនៅ ។ ឯបុរស ជាប្អូនៅគេនេះ បានរស់នៅជាមួយភរិយារបស់គេដោយមេត្រីភាព ទីតំា សេចក្តីស្នេហាដ៏ជ្រាលជ្រៅតមក ។

ថ្នៃកកំណាត់ដ៏ឆ្ងប្រវត្តិការណ៍

បណ្ណាល័យពុទ្ធសាសនាមួយនៃប្រទេសកម្ពុជា

នៅក្រុងវ៉ាស៊ីនតុន (សហភាពភូមា)

លោក ភ័យ - ប៊ុក រៀបរៀង

បណ្ណាល័យពុទ្ធសាសនាមួយរបស់ប្រទេសកម្ពុជា ចានទទួលត្តិឡើង នៅទីក្រុងវ៉ាស៊ីនតុន (សហភាពភូមា) ដោយសម្តេចសហជីវិនព្រះបិតាឯក-ឧត្តមជាតិជាទីស្នេហារបស់យើង ទ្រង់ចានសព្វព្រះរាជហឫទ័យព្រះរាជបញ្ជាឲ្យស្ថាបនាឡើង ។

ឯកឧត្តមឯកអគ្គរាជទូតប្រទេសកម្ពុជាប្រចាំទីក្រុងចាងកុក(១)ចានអញ្ជើញទៅបំពេញបេសកកម្មឯទីក្រុងវ៉ាស៊ីនតុន ពីថ្ងៃទី ២៧ ទៅរសៀលថ្ងៃទី ៣ មិថុនា ១៩៥៩. ឯកឧត្តម អ៊ូ-ចាន់ ពុទ-អូន រដ្ឋមន្ត្រីក្រសួងការបរទេស សហភាពភូមា ចានមានប្រសាសន៍ចំពោះឯកឧត្តមឯកអគ្គរាជទូតថា: " ពុទ្ធិកសមាគមពិភពលោកប្រទេសភូមាចានស្ថាបនាបណ្ណាល័យមួយ ធ្វើពីបេតុង៣ជាន់ ដ៏តសាលសន្ធិស័ខ សាសនាអន្តរជាតិ ដើម្បីនឹងតម្កល់ពុទ្ធិកសារខាងព្រះពុទ្ធសាសនា

១- សព្វថ្ងៃពុំមានឯកអគ្គរាជទូតខ្មែរ ប្រចាំក្រុងចាងកុកទេ ព្រោះខ្មែរយើងចានផ្តាច់សម្ពន្ធមេត្រីភាព ជាមួយសៀមតាំងពីថ្ងៃ ២៣ តុលា ១៩៦១ នេះ ។

គឺគម្ពីរ, សៀវភៅ, ក្បួនច្បាប់ប្រពៃណីខាងព្រះពុទ្ធសាសនា ។ ល ។
ការស្ថាបនាទូរមហាបណ្ណាល័យនេះ គឺធ្វើឲ្យបានជាប់រហូតដល់ ២.៥០០
ឆ្នាំទៀត, គឺឲ្យបានដល់អាយុនៃពុទ្ធសកាជគម្រប់ ៥០០០ ព្រះវស្សា ។
នៅក្រោមមហាបណ្ណាល័យនេះ មានសង់បណ្ណាល័យនៃប្រទេសពុទ្ធ-
សាសនិកគឺ ប្រទេសស៊ីឡង់, ថៃឡង់ ដែលត្រូវស្ថាបនា ហើយរចនា
ទៅតាមសិល្បៈប្រពៃណីនិយមនៃប្រទេសរៀង ។ ខ្លួន . . . ។

ឯកទុតម អ៊ូ-ចាន់-ខុន-អូង មានប្រសាសន៍តទៅទៀតថា បើ
ប្រទេសកម្ពុជា ចង់ស្ថាបនាបណ្ណាល័យនោះ, ឯកទុតមនឹងបម្រុងខុក
កន្ទែងមួយក្រោមមហាបណ្ណាល័យនោះ ។

ឯកទុតម ខ៊ី-គីមសួរ ថា នឹងធ្វើតទុកាសកន្លងតេលដែលសម្តេច
សហជាតិនៃព្រះប្រមុខរដ្ឋ ព្រះអង្គទ្រង់យាងចុះព្រះទីនាំងអាកាសយាន
ទៅចំណតអាកាសយាន « ម៉ាំង់ហ្គាឡាដុង » ឯកទុតមនឹងក្រាបបង្គំទូល
សម្តេចសហជាតិនៃ ចំពោះរឿងនេះ ។

កន្លងតេលនោះ, សម្តេចសហជាតិនៃព្រះប្រមុខរដ្ឋជាទីគោរព នឹង
ជាទីស្នេហាស៊ោះជាយជាតិនៃយើង, ទ្រង់បានយាងចុះព្រះទីនាំងអាកាស-
យានទៅទីនោះ, ក្រោយដែលព្រះអង្គទ្រង់វិលត្រឡប់អំពីការចំតេញ

ព្រះរាជទេសកកម្មនៅទ្វីបអឺរ៉ុប, ទ្រង់គាំទ្រសព្វព្រះរាជហឫទ័យតាម
សេចក្តីស្នើរបស់ឯកឧត្តម អ៊ូ-ចាន់-ខុន-អូង, ទ្រង់ឲ្យស្ថាបនាបណ្ណាល័យ
ពុទ្ធសាសនា របស់ប្រទេសកម្ពុជាមួយនៅទីនោះ ទ្រង់ទ្រាស់បង្គាប់
ឲ្យសហដ៏ខិនរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ, សាធារណការ, ឃោសនាការ,
សិល្បការ ឲ្យប្រជុំដើម្បីនឹងរិះរកនូវមធ្យោបាយ ឲ្យបានសម្រេចនូវ
សមិទ្ធិ មានការរៀបចំក្បាច់រចនាសិល្បៈដ៏វិចិត្រ ដើម្បីដាក់លៀវគៅ
ក្បួនតម្រា, ទីដ៏បុកណាវត្តផ្សេង ។ ល ។

ក្រសួងទាំង ៤ គាំទ្រប្រជុំគ្នា ហើយបានចាត់ឲ្យលោក ភាន់-
មូលីភាន់ ជាវិស្វកឲ្យទៅតាំងតាំងដាក់ឥដ្ឋនៅប្រទេសភូមា ចំពោះរឿង
នេះ ។ លោក ភាន់-មូលីភាន់ បានអញ្ជើញទៅដាក់ឥដ្ឋនោះ គាំទ្រតួរ
ផែនដី បណ្ណាល័យពុទ្ធសាសនា របស់ប្រទេសកម្ពុជា នៅក្រុងរ៉ង្គុន
នោះសព្វគ្រប់ ។

បណ្ណាល័យ ពុទ្ធសាសនាប្រទេសកម្ពុជានៅទីក្រុងរ៉ង្គុននេះ មាន
សារៈសំខាន់ពន់ពេក ព្រោះថា បណ្ណាល័យនេះ ពុកជានិមិត្តរូបនៃ
ប្រទេសកម្ពុជា ដែលបញ្ចេញនូវស្នាដ៏ស្វាងរុងរឿង ព្រមទាំងធ្វើក្បាច់
រចនាតាមទំនៀមទម្លាប់ប្បជមិទេមរជាតិ . . . ។ល។ ភ្ញៀវទេសចរអន្តរ-

ជាតិដែលធ្វើដំណើរមកតាមទឹកក្រុងឆ្លើន (ប្រទេសភូមា) តែងមកទស្សនាបណ្ណាល័យនេះ ដែលមានបណ្ណាល័យប្រទេសឯទៀតដូចជាប្រទេសថៃឡង់, ប្រទេសស៊ីឡង់ជាដើមស្ថិតនៅដាច ។ គ្នាទីជប្រទេសយើងដែលចេញតាមប្រពៃណីរៀង ។ ខ្លួន ។

បណ្ណាល័យនេះ ជាសំឡេងមួយនៃប្រទេសកម្ពុជា ដែលបានស្ថាបនាឡើង សម្រាប់ដំកល់ទូរឯកសារខាងព្រះពុទ្ធសាសនា ព្រមទាំងរៀបចំឲ្យមានលំអ ប្រកបដោយសិល្បៈខ្មែរសុទ្ធ ។ ឲ្យវិសេសវិសាល ដើម្បីញ៉ាំងកិត្តិសព្ទនៃប្រទេសកម្ពុជាឲ្យល្បីល្បាញពេញសកលលោក ។

ម្យ៉ាងទៀតបណ្ណាល័យពុទ្ធសាសនានេះ ជាជាវត្ថុបស់ប្រទេសកម្ពុជាយើងដែលសម្តេចសហជីវិនជាព្រះអគ្គមគ្គុទ្ទេសក៍ ជាព្រះបិតាឯកភាជាតិជាទីស្នេហានៃយើង ទ្រង់សព្វព្រះកជហឫទ័យឲ្យស្ថាបនាឡើងដើម្បីញ៉ាំងវប្បធម៌នៃប្រទេសកម្ពុជាឲ្យមានមុខមាត់លើឆាកអន្តរជាតិ ។

ភក្តីសទ្ធា


ទស្សនាវដ្តី ផ្សាយចំណាំងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ៣៤ លេខ ៤ ខែ មេសា

ព.ស. ២៥០៤ គ.ស. ១៩៦២

- ក្តីពេញ -



ភ័ន្តមុខសុទិយរ

ទស្សនាវដ្តី ផ្សាយខាងសាសនា ធំងអក្សរសាស្ត្រ

ចេញរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	ទំព័រ
– វិចារណកថា	៣៦៥
– លោកុត្តរចិត្ត (ត) អ្នកឧកញ៉ា ទា-សាន អតីតរដ្ឋមន្ត្រី រៀបរៀង	៣៧០
– ព្រះអភិធម្មបិដក (គម្ពីរព្រះយមកៈ) (ត) លោកម៉ូ-ប៊ុ ប្រែរៀបរៀង	៣៨១
– មធុរសៅហិណ៍(ត)សម្តេចព្រះធម្មលិខិតឡុ-ឯម ប្រែ ព្រះញាណកោសលញ-ឈឹនពិនិត្យ	៣៨៧
– មហោសថជាតក(ត) លោក អឹម-ភន ចម្លងពីសាស្ត្រាស្ងាត់ព្រះពុទ្ធវង្ស កឹម-ឆ្លារ ពិនិត្យ	៣៩៨
– ការសាយនៃភពផែនដីនិងកំណើតជាថ្មីសារឡើងវិញ ការ្យលោកញ៉ុង-សឿង ឱពន្ធ	៤១០
ផ្នែកអក្សរសាស្ត្រ	
– អំពីអក្សរធម្មខ្មែរ លោក លី-ឆាមរេង រៀបរៀង	៤៣០
– ពាក្យខ្មែរប្រែតបរទេស (ត) ដោយឧណៈកម្មការដ៏ឥតនៃការសិក្សាផ្នែកអក្សរ "ក"	៤៣៧
– វចនានុក្រមសំស្ក្រឹត-ខ្មែរ (ត) ព្រះមហា ជាំង-ខាត់ រៀបរៀង	៤៣៩
– រឿងសាមកុក (ត) ឧកញ៉ា ន្ធូ-ពន ប្រែ	៤៣៩
– រឿងព្រេងចិន (ត) លោក ភំយ ប៊ុក ប្រែរៀបរៀង	៤៥៨
– រឿងព្រេងប្រទេសហ្សីវ៉ា កិក្ខុ ម៉ែន-ជៀម ប្រែពីភាសាអង់គ្លេស	៤៦៤
ផ្នែកកំណត់ទំនឹងប្រវត្តិការណ៍	
– ពិធីប្រគេនសង្ឃាប័ត្រឡូកឧត្តមសិក្ខាបវរមភូមិ ជិលស្ងមណៈទិស្សិត លោក ប៊ីង-រ៉ង រៀបរៀង	៤៦៨

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជាវ ២៣០រ០០

34è Année — N° 4 — Avril 1962

KAMBUJASURIYA

Revue mensuelle de culture religieuse et littéraire
publiée par l'Institut-Bouddhique de Phnom-Penh

SOMMAIRE

Partie religieuse

—Editorial 365
—Lokuttaracitta (suite) par l'Oknha TEA-SAN. 370
—Prah Abhidhamma pitaka « Kampi prah Yamaka » (suite) traduit par M. BOU-PO 381
—Madhurasavahini (suite) traduit par Samdech Prah Dhammalikhita LOUIS-EM, revu et corrigé par le Vén. NHEAN-CHHŒUN. 389
—Mahosotha Jataka (suite) relevé du manuscrit en feuilles de latanier par M. IM-PHON, revu et corrigé par le Vén. KEM-TO 398
—La fin du monde et sa formation nouvelle en vers par M. NHOUNG-SŒUNG. 410

Partie littéraire

—La Civilisation Khmère par M. LY-THEAM TÉNG . . 430
—Activités de la Commission Culturelle (suite) chapitre «Ka» 437
—Dictionnaire Sanscrit-Khmèr (suite) par Vén. PANG-KHAT 438
—Histoire de Sam-Kok (suite) traduite par l'Oknha NOU-KAN 439
—Contes et Légendes de la Chine (suite) traduits par M. RAY-BUC 458
—Contes juifs traduits de l'anglais par le bonze MEN-RIEM... 461

Notes et Chroniques

—Remise du Diplôme d'Etudes Supérieures du 1er degré aux lauréats religieux par M. THANG-VONC. . . 468

Abonnement annuel (comprenant 12 numéros) : 230 f 00

ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការណាមក ឲ្យធ្វើល្អទៅ ។
ឲ្យចិត្តខាត់ចិត្ត កុំឲ្យហ្មងសៅ
នេះឯងលោកហៅ ពុទ្ធសាសនា ។

ច.ព.

វិចារណកថា

សូមពុទ្ធបរិស័ទ អ្នកកាន់ព្រះពុទ្ធសាសនា រួបរួមសាមគ្គីគ្នាដើម្បីញ៉ាំងឯកជវអព្យាក្រឹតភាពនឹងត្រៃសរណដ្ឋាន គឺជាតិ សាសនា ព្រះរាជបល្ល័ង្ក នៃប្រទេសយើង ឲ្យមានដំហរនឹងប៉ុងតទៅអនាគត ។

ព្រះពុទ្ធបរមគ្រូ ទ្រង់ប្រទានប្រៀនប្រដៅពុទ្ធបរិស័ទចាំងឡាយ ឲ្យខានការព្រមព្រៀងគ្នាជាដរាប ព្រោះការរួបរួមសាមគ្គីព្រមព្រៀងគ្នាជាតបធម៌ដ៏ទុត្តមក្រៃលែង អាចញ៉ាំងសេចក្តីសុខ-ចំរើនដល់សង្គមគ្រួសារខ្មែរយើង ដល់វត្តអារាមខ្មែរយើង ឬដល់ប្រទេសជាតិចាំងមូលបាន ការបើសង្គមគ្រួសារ ពុទ្ធសាសនា - សិក្ខាដើងវត្ត ឬប្រជាពលរដ្ឋនៃប្រទេសខ្មែររួបរួមសាមគ្គីគ្នា ។

តាមការសង្កេតរបស់ក្រសួងធម្មការយើញថា សព្វថ្ងៃនេះ ពួកពុទ្ធបរិស័ទមានសាមគ្គីធម៌ គឺការរួបរួមគ្នា ព្រមព្រៀងគ្នាបានប្រមូល

ផ្តុំគ្នាកសាងព្រះពុទ្ធសាសនា ខឹងដួយស្ថាបនាកិច្ចការរបស់រដ្ឋ មានស្ថាន - ថ្នល់ - សាលារៀនជាដើម ច្រើនជាអនេក ដោយបានស្ម័គ្រចិត្តធ្វើតលិកម្មតាមព្រះពាជនយោបាយដ៏ខ្ពង់ខ្ពស់ នៃសម្តេចព្រះប្រមុខរដ្ឋជាព្រះបិតាឯករាជ្យជាតិ ។ ប៉ុន្តែ នៅមានវត្តខ្លះ ពួកពុទ្ធបរិស័ទខ្លះ មានការខាស់ខែនខ្វែងគំនិតគ្នា ដែលបណ្តាលមកពីសេចក្តីប្រតិបត្តិយ៉ាងគ្មានបច្ចុប្បន្ន បង្កើតទៅជាអធិករណ៍ប្តឹងផ្តល់ពីគ្នារកទីបំផុតគ្មាន ដែលជាអំពើនាំឲ្យបែកសាមគ្គីគ្នា ។

ឯហេតុនៃការបែកសាមគ្គីគ្នានេះ អស់លោកអ្នកជាពុទ្ធបរិស័ទបានជ្រាបសព្វគ្រប់ហើយ មិនដែលនាំផលល្អមកប្រគល់ឲ្យទេ មានតែនាំផលអាក្រក់ គឺ សេចក្តីខ្ពុលខ្មាសជាដរាបមានមកផ្តល់ឲ្យ ប្លែកាលអាចផ្តល់ឲ្យដល់ខ្លួនសេចក្តីស្លាប់ក៏សឹងមាន គួយ៉ាងដូចពួកសត្វចាបដែលជាប់លប់របស់ព្រាន ដល់ខ្លួនសេចក្តីស្លាប់ជាទីបំផុត ក៏មកតែពីហេតុនៃការបែកសាមគ្គីគ្នានេះឯង ។

ឯការកើតអធិករណ៍ រកឫងហេតុគ្នា នាំឲ្យបែកសាមគ្គីគ្នានេះមានច្រើនវត្តស្ទើរតែគ្រប់ខែត្រ ក្នុងព្រះពាជអាណាចក្រ គឺ :

ពាជធានីភ្នំពេញ	មានកើតអធិករណ៍	២ វត្ត
ខែត្រកណ្តាល	-	១៣ -
- កំពង់ចាម	-	៦ -

ខែត្រ	កំពង់ធំ	មានកើតអធិករណ៍	៣	វត្ត
–	កំពង់ឆ្នាំង	–	២	–
–	ចាត់ដំបង	–	១	–
–	តេជោសាត់	–	១	–
–	សៀមរាប	–	១	–
–	តាកែវ	–	១	–
–	កំពង់ស្ពឺ	–	១	–
–	កំពត	–	១	–

រួមទាំងអស់ . . . ៣២ វត្ត

ក្រសួងធម្មការ សូមអំពាវនាវដោយបវរ ចំពោះពួកគណៈបរិស័ទ ចំណុះវត្តទាំងលើខេះ សុំឲ្យឈប់ទាស់ខែងខ្វែងគំនិតគ្នា ឈប់ប្តឹងផ្តល់គ្នាចាប់តាំងពីថ្ងៃខេះតទៅ ហើយសុំឲ្យរួបរួមសាមគ្គីគ្នាឡើងវិញ ដើម្បីរួមកម្លាំងគ្នា ជង្អែតាមក្រោយអគ្គសម្តេចព្រះបរិតាឯកឧត្តមជាតិព្រះអគ្គមគ្គុខ្ញុសក៍ដ៏ឆ្នើម ដែលអស់លោកអ្នកគ្រាប់បានផ្ញើសេចក្តីខុកចិត្ត ភ្ជាប់ផ្ញើអាយុដ៏វែងនឹងព្រះអង្គមកយូរទៅហើយ ដើម្បីបានជាកម្លាំងជួយព្រះអង្គកងការពារឯកឧត្តម អត្ថាក្រឹតភាពនៃប្រទេសយើង ឲ្យមានដំហរវែងបុងតទៅអនាគត ព្រោះប្រទេសកម្ពុជាយើងសព្វថ្ងៃខេះ ដូចអស់លោកអ្នកជ្រាបស្រាប់ហើយ គឺកំពុងត្រូវឈ្លានពានសង្ឃឹកចោកបក់យ៉ាងខ្លាំង តោល

គឺមានការគំរាមគំហែងពីប្រទេសជិតខាង ដោយគេចង់ធ្វើឲ្យថាប់ចង់ឯក-
ភាពនៃអត្ថាក្រឹតភាពនៃប្រទេសយើងខ្ញុំ ។

សូមពួកពុទ្ធបរិស័ទជ្រាបថា កាលបើប្រទេសមានទុក្ខលំបាកធ្ងាក់
ចុះខ្លាំងហើយ ព្រះពុទ្ធសាសនាក៏ត្រូវទទួលទុក្ខលំបាក បើប្រទេស
បានសុខចំរើន ព្រះពុទ្ធសាសនាក៏បានសុខចំរើនដែរ ។ ឯព្រះពុទ្ធសា-
សនាក្នុងប្រទេសកម្ពុជានាបច្ចុប្បន្ននេះ មានការលូតលាស់ដុះដាលចំរើន
យ៉ាងខ្លាំង ព្រោះបានបិតនៅក្នុងហាន ជាប្រទេសឯករាជ្យការពារយោធយ
អត្ថាក្រឹត មានសិទ្ធិសេរីភាពគ្រប់បែបណា ជាប្រទេសមានភ័ព្វវាសនា
ដោយសារមានអង្គសម្តេចព្រះប្រមុខរដ្ឋជាព្រះអគ្គមគ្គុទ្ទេសក៍ ជា
ព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ ព្រះអង្គនាយកដឹកនាំប្រទេស ឲ្យប្រជា-
ពស្ត្រួចផុតពីទុក្ខភ័យ ពីគ្រោះថ្នាក់ ឲ្យបានបិតនៅក្នុងសន្តិភាព ឲ្យ
បានជួបនឹងការសម្បូណិសប្បាយ ។

ហេតុនេះ ក្នុងកាលៈទេសៈនៃប្រទេសយើង ដែលត្រូវទទួល
ការគំរាមកំហែងពីប្រទេសជិតខាង ត្រមាំងនៅពេលដ៏ខ្លីខាងមុខនេះ
ជាពេលបើកសម័យយោសនាថោះ ខ្ញុំតសាកល្ប៥ ដ
ថោះ សូមពួកពុទ្ធបរិស័ទ មេត្តាជួយធ្វើពលិកម្មត្រប់គ្នា ដោយលះ
បង់ការខាស់ខែនខ្ជីនតិចតួច លះបង់ការប្លន់ច្រណែនគ្នា លះបង់ការបង្កើត
អធិករណ៍ផ្សេង ។ ឲ្យបានជ្រះស្រឡះ ហើយស្រុកស្រុះគេញាកបរកគ្នា

ស្រឡាញ់គ្នាឡើងវិញ ដើម្បីភ្ជាប់ចំណងគ្នាដ៏ថ្លៃតាមអង្គសម្តេចព្រះបិតាឯករាជ្យជាតិ ក្នុងការរក្សាឯករាជ្យនឹងអត្ថក្រឹត្យភាពនៃប្រទេស ឲ្យបានបរិបូរណ៍ចីរកាលផង ដើម្បីកុំឲ្យ សង្រ្គាម ខ្មែរគ្រាប់ចាម ដូចខ្មែរសេរី អាចទ្វៀតទាស់យកលេសថា ពួកភ្នំពេញបរិស័ទ មិនរួបរួមសាមគ្គីគ្នា មកសំអាងក្នុងការយោសនាប្រឆាំងនឹងសង្គមកម្ពុជយើង ដែលមានអង្គសម្តេចព្រះជាព្រះអគ្គមគ្គុទ្ទេសក៍ផង ។

អស់លោក-អ្នកជាពុទ្ធបរិស័ទចាំដែរឬយ៉ា ?

បើពុទ្ធបរិស័ទត្តណាខ្លះ ក្នុងចំណោមវត្តខាងលើនេះ បានធ្វើពលិកម្មដូចពោលមកនេះហើយ សូមមេត្តាជូនដំណឹងទៅក្រសួងធម្មការ ក្រសួងនេះនឹងនាំយកសេចក្តីក្រាបបង្គំទូលសម្តេចព្រះបិតាឯករាជ្យជាតិ សូមព្រះអង្គទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ ហើយនឹងចុះផ្សាយតាមវិទ្យុជាតិ - សារតេតិមាន ស្តីពីអាកប្បកិរិយារបស់លោកអ្នកដែលបានធ្វើពលិកម្ម គឺការលះបង់ការប្រកួតប្រកាន់គ្នា ហើយបានរួបរួមគ្នាឡើងវិញនេះ ។

ក្រសួងធម្មការ មានសេចក្តីសង្ឃឹមយ៉ាងមាំថា ពុទ្ធបរិស័ទនឹងរួបរួមសាមគ្គីគ្នា តាមន័យខាងលើនេះតរៅ ។

លោកុត្តរចិត្ត

អ្នកឧកញ៉ា ឆា-សាឧ អតីតរដ្ឋមន្ត្រីរៀបរៀង

(តមក)

សរុបសេចក្តីពៅឃើញថា មានតែការកំចាត់បង់នូវបុព្វហេតុ ពោលគឺការលះអាសវៈ ៤, សំយោជនៈ ១០ នីវរណៈ ៣ ឲ្យអស់ពីខ្លួនសន្តាន ដោយដាច់ខាតនោះទេ ដែលជាមូលហេតុនឹងញុំាងលោកុត្តរចិត្ត ៨ ដួងគឺ មគ្គចិត្ត ៤ ដួង នឹង ផលចិត្ត ៤ ដួង ឲ្យសម្រេចកើតមានឡើងជាលំដាប់តុំាមានឡើយ ។

ដោយហេតុនេះហើយ ឆានជាព្រះពុទ្ធទំាងឡាយ ព្រះអង្គតែងតែប្រដៅខ្លួនសត្វដោយពុទ្ធវចនានុសាសន៍ត្រង់ចរតៈ ៣ ថាៈ សចិត្តបរិយោទបនំ, ឆានសេចក្តីថា ចូរដុសខាត់ដំរះចិត្តឲ្យចរិសុទ្ធផូរផង់នោះ គឺព្រះអង្គមានវត្តុបំណងចង់ដកទំាសត្វឲ្យតំាងចិត្តភ្សាយាមលះបង់នូវអាសវៈ ៤ សំយោជនៈ ១០ ហើយនីវរណៈ ៣ ឲ្យអស់ពីខ្លួនសន្តាន ដើម្បីលោកុត្តរចិត្តនោះឯង ។

ម្យ៉ាងទៀត ចំពោះអរិយបុគ្គលទំាងឡាយ ដែលលោកតំាងអធិដ្ឋានប្រាថ្នានូវការគ្រាស់ដឹងលោកុត្តរធម៌ គឺធម៌សម្រាប់ចម្លងសត្វឲ្យឆ្លងចេញពីលោកនោះ អរិយបុគ្គលនោះគឺរមែងដឹងប្រាស់ថា នៅតាមដងផ្លូវដែលត្រូវធ្វើដំណើរឆ្លងចេញពីកន្លែងលោក នោះមានអន្ទល់ទឹក ៤ កន្លែង ត្រូវឆ្លង

កាត់ទៀត្រូច, ទឹងមានចំណង ១០ ត្រូវកាត់ផ្តាច់ចោលទៀអស់ហើយទឹងមាន
អន្លាក់កាម ៣ ត្រូវតំបាត់បង់ចោលទៀអស់ទើបធ្វើដំណើរទៅរួច, ហើយ
លោកដឹងច្បាស់ ម្យ៉ាងទៀតថា មានតែការលះអាសវៈ ៤ ទឹងសំយោជន:
១០ ហើយទឹង តណ្ហា ៣ ទៀអស់តិទ្ធសន្តានដោយដាច់ខាតនោះទេ
ដែលជាមូលហេតុអាចទៀលោកធ្វើងកាត់អន្ទង់ ៤ ទឹងទៀដោះខ្លួនរួចផុតពីចំ-
ណង ១០ ទឹងអន្លាក់កាម ៣ ដើម្បីទឹងបន្តដំណើរធ្វើងចេញរួចផុតចាកត្រៃ
លោកបានឥតមានឧបសគ្គអ្វីអាចមកកាត់ងដំណើរលោកបានទៀតឡើយ។

៥- សមុច្ឆេទប្បហាង

រីង សមុច្ឆេទប្បហាង គឺការលះកិលេសផុតស្រឡះដោយដាច់
ខាតនោះ ពុកដាក់ចំណួមួយតិចាកទឹងបំពេញទៀបានសម្រេចកើតមានឡើង
ណាស់ តិព្រោះអារម្មណ៍ ៩ មានរូបជាដើម ចេះតែមកលួងលោមនាំ
ចិត្តទៀសប្បាយរីកយដែលជាហេតុនាំទៀកិលេសមានកតៈជាដើម កើត
មានឡើងជាប្រក្រតីតុំដែលមានពេលណាចន្លោះឡើយ។ ដោយហេតុនេះ
ទើបបុគ្គលដែលគ្មានបញ្ញា តុំអាចទឹងលះកិលេសទៀដាច់អស់តិទ្ធសន្តាន
ទៅបានឡើយ តិព្រោះបុគ្គលដែលគ្មានបញ្ញា, កាលបើមានចិត្តប្រាថ្នាទឹង
លះកិលេសនោះ គឺរមែងតែចាប់ផ្តើមលះដោយ វីរិយ សិវៈ:គឺដោយ
ការសេ្រមរិយ, ឬដោយ ១ ឆ្លឺ សិវៈ: គឺដោយការសេ្រមចិត្តអត់ធន់ ឬ
ដោយ ឥទ្ធិ សិវៈ: គឺដោយការសេ្រមឥទ្ធិ។ល។ តែម្តង ដែល

ជាហេតុធ្វើឲ្យការលះកិលេសតុំបានសម្រេចដូចគោលបំណងសោះ គឺ
គ្រាន់តែបានបណ្តោះចិត្តឲ្យឃ្លាតឆ្ងាយពីកិលេសបានក្នុងមួយខណៈដ៏ខ្លីតែ
ប៉ុណ្ណោះ រួចអារម្មណ៍ ៥ នោះកំតាំងញ៉ាំងកិលេសឲ្យកើតមានឡើងវិញ
ជាធម្មតាខ្លាំង ។ រីឯបុគ្គលដែលមានបញ្ញាជ័ងក្លាស់ខ្លួរហេតុបច្ច័យនៃ
កិលេសនោះ គេមិនចាប់ផ្តើមលះកិលេសតែម្តងឡើយ, គេរមែងតែស្វែង
រកខ្លួរទុច្ចរិតដែលអាចកំចាត់បង់បានដោយសក្តិសិទ្ធិខ្លួរសមុដ្ឋាន តោល
គឺឫសគល់នៃកិលេសឲ្យអស់ពីខ្លួសន្តានជាមុនដរាប ដើម្បីកិលេសតុំអាច
នឹងកើតឡើងបាន ដែលជាហេតុនាំឲ្យលះជាច់ផុតស្រឡះខ្លួកិលេសនោះ
បានដោយងាយ ។ រីឯឫសគល់នៃកិលេសនោះគឺអាសវៈ ៤ ដែលជាគ្រឿង
គ្រាំនៅក្នុងខ្លួសន្តាន ត្រូវមានតែប្រកបភាវនាចិត្តលើសឲ្យប្រព្រឹត្តទៅជា
ប្រក្រតីនោះឯង ។

រីឯទុច្ចរិតដែលអាចញ៉ាំងខ្លួសន្តាន ឲ្យក្តៅរំងួលហួតស្ងួតផុតស្រឡះ
ពីគ្រឿងគ្រាំ ៤ ប្រការគឺ កាម ទិដ្ឋិ ភព ទុន្ធ អវិជ្ជា បានន័យតែ
សមថកម្មដ្ឋាន ១ ខន្ធ វិបស្សនាកម្មដ្ឋាន ១ ពីព្រោះការចំរើន
ខ្លួកម្មដ្ឋាន ២ ប្រការនោះ រមែងជាហេតុនាំឲ្យយោគាវចរបានសម្រេចខ្លួ
សមាធិ ខន្ធឈានចិត្ត ៨ ហើយខន្ធវិបស្សនាញាណ ១០ ជាតិតក្រោកដល់
ភាពខ្លាំង ។ គឺគុណធម៌ទាំងអស់នេះហើយ ដែលទុកជាគ្រឿងដុត
កំដៅខ្លួសន្តានឲ្យក្តៅរំងួលហួតស្ងួតផុតស្រឡះបាត់គ្រឿងគ្រាំ តោលគឺ

អាសវៈ៤ បានយ៉ាងស័ក្តិសិទ្ធិ ដែលជាហេតុនឹងធ្វើឲ្យ សំយោជនៈ ៣០ នឹង ឧឡ្ហាភាគិយ ដែលជាផល តុំអាចនឹងមានដំណើរប្រព្រឹត្តទៅក្នុងខន្ធសន្តានរបស់ខ្លួនបានទៀតឡើយ ។

ឯឈានចិត្ត ៨ នោះគឺសំដៅបុគ្គល ៤ នឹងអរូបភ្លាន ៤ នោះឯង ។

ឯរូបភ្លាន ៤ ដែលមានចតុត្ថជ្ឈានប្រកបដោយអង្គឯកគ្គតា នឹងទុបេក្ខាជាប្រធាននោះ ពុំជាឈានចិត្តតាំងនៅជាកណ្តាលជានិច្ច ធ្វើត្រង់ឆើយកន្លែយមិនអើតើ គឺមិនសោមនស្សមិនទោមនស្សចំពោះឥដ្ឋានិដ្ឋារម្មណ៍ តាំងឡាយដែលមកប៉ះទង្គិចនឹងអាយតនៈខាងក្នុងមានភ្នែកជាដើម ដែលជាហេតុធ្វើឲ្យខន្ធសន្តានក្តៅរំងើបហួតសូតចាកគ្រឿងគ្រាំពោលគឺ កាមាសវៈ ១ ដែលពុំជាប្រុសកែវនៃ កាមកត នឹង បដិឃ នោះឯង ។

ចំណែកឯអរូបភ្លាន ៤ ដែលសុទ្ធតែប្រកបដោយអង្គឯកគ្គតា នឹងទុបេក្ខានោះ ពុំជាឈានចិត្តតាំងនៅក្នុងអារម្មណ៍ជាអរូបធម៌មានអាកាសជាដើមប្រព្រឹត្តផ្សាយទៅលើអាកាសដ៏ល្អក្លៀវក្លៃបំផុតគ្មាន ដែលជាហេតុធ្វើឲ្យអរូបភ្លានចិត្តនោះត្រង់ឆើយកន្លែយ គឺមិនសោមនស្ស នឹងមិនទោមនស្សចំពោះដំណើរកើតក្នុងប្រភពនឹងអរូបភពរៀងៗបុគ្គល លុះត្រាតែខន្ធសន្តានក្តៅរំងើបហួតសូតផុតចាកគ្រឿងគ្រាំពោលគឺ កាមាសវៈ នឹង អវិជ្ជាសវៈ ដែលពុំជាប្រុសកែវនៃសំយោជនៈ ៥ មានរូបកតជាដើមអស់ទៅ ។

ដោយហេតុនេះ ឈានជាយោគាវចរដែលចំរើនឈានជានសម្រេច
នូវរូបជ្ឈាន ៤ ទើងអរូបជ្ឈាន ៤ បរិបូណ៌ហើយរមែងតែលះដោយដាច់ខាត
នូវអាសវៈ៣គឺ : កាមាសវៈ១, ភវាសវៈ១, ទើង អវិជ្ជាសវៈ១
ហើយទើងសំយោជនៈ៧ មានកាមរាគៈជាដើម ព្រមទាំងតណ្ហា ៣ មាន
កាមតណ្ហាជាដើមដោយប្រការដូច្នេះឯង ។

ឯវិបស្សនាញាណ ១០ នោះគឺ សំដៅញាណដែលដឹងច្បាស់ទៅ
តាមហេតុពិតនូវដំណើរប្រព្រឹត្តទៅនៃសង្ខារធម៌ទាំងឡាយមានបញ្ចក្ខន្ធជា
ដើម ។ រីឯវិបស្សនាញាណ ១០ នោះកាលបើសម្រេចកើតឡើងហើយ
រមែងតាំងនៅជាកណ្តាលធ្វើព្រនើយកន្តើយមិនអើពើគឺ មិនសាមនស្ស
មិនពោមនស្សចំពោះមុខនូវទិដ្ឋទាំងឡាយមានសក្កាយទិដ្ឋជាដើម ដែលជា
ហេតុធ្វើឲ្យខន្ធសន្ដានក្តៅរើឆួតស្ងួតផុតចាកគ្រឿងត្រាំគឺ ទិដ្ឋាសវៈ
ដែលពុំជាប់ជាប់ស្អែកនៃសំយោជនៈ ៣ មានសក្កាយទិដ្ឋជាដើមអស់ទៅ ។
ដោយហេតុនេះ ឈានជាយោគាវចរដែលចំរើនវិបស្សនាភាវនា ដោយ
យកនាមរូបជាអារម្មណ៍នោះ រមែងតែលះដោយដាច់ខាតនូវទិដ្ឋាសវៈ ១
ទើងសំយោជនៈ ៣ គឺ សក្កាយទិដ្ឋិ វិចិកិច្ឆា ទើងសីលព្វត-
បរាមាស ដោយប្រការដូច្នេះឯង ។

បំប្រួញសេចក្តីទៅយើញថា ឈានដំបូង ៤ ទើងវិបស្សនាញាណ ១០
រួមទាំងសុចរិត ១០ ផ្នែកខាងមួលផង កើតទៅជាគំនរគុណធម៌ ៣ ហៅ

ជាគ្រែខ្នងគឺ សីលខន្ធ ១ សមាធិខន្ធ ១ ទស្សនៈខន្ធ ១ ពុក
ជាគ្រឿងសម្រាប់ជុំសាងតំរិះចិត្តឲ្យស្អាតបរិសុទ្ធផូរផង់ ដើម្បីវិសុទ្ធិគឺ
សេចក្តីបរិសុទ្ធិ ៧ ប្រការផង ទំនងដើម្បីលោកុត្តរចិត្ត ៨ ដួងគឺ មគ្គចិត្ត
៤ដួង ទំនង ផលចិត្ត៤ដួង ទៀតផង ។

៦-វិសុទ្ធិ ៧ ប្រការ

រីឯឈានចិត្ត ៨ ទំនងបៃបូរនាញាណ ១០ ដែលបានលះអាសវៈ ៤
ទំនងសំយោជនៈ ១០ ហើយទំនងតណ្ហា ៣ នោះ ឈ្មោះថា បានជុំសាងតំ
រិះចិត្តឲ្យស្អាតបរិសុទ្ធផូរផង់ប្រកបដោយវិសុទ្ធិ គឺសេចក្តីបរិសុទ្ធិ ៧ ប្រការ
ទៀតក្រៅពីសីលវិសុទ្ធិគឺ ៖

១- ទិដ្ឋិវិសុទ្ធិ សេចក្តីបរិសុទ្ធិនៃការយល់ឃើញត្រូវមួយ,

២- កង្ខាវិតរណវិសុទ្ធិ សេចក្តីបរិសុទ្ធិនៃទិដ្ឋិដែលជាហេតុ
នាំឲ្យកន្លងផុតសេចក្តីសង្ស័យមួយ ,

៣- មគ្គាមគ្គញាណទស្សនវិសុទ្ធិ សេចក្តីបរិសុទ្ធិនៃ
ការឃើញប្រកបដោយញាណ ដឹងច្បាស់ពាំង សម្ភាមគ្គ ទំនង មិច្ឆា-
មគ្គ មួយ ,

៤-បដិបទាញាណទស្សនវិសុទ្ធិ សេចក្តីបរិសុទ្ធិនៃការ
ឃើញប្រកបដោយញាណដឹងច្បាស់ខ្លួនបៃបៃបៃ ដែលតាចញ៉ាំងលោកុត្តរ-
ចិត្ត ៨ ដួង ឲ្យសម្រេចឡើងបានមួយ ។

๕- ญาณทสฺสนวิสุทฺธิ សេចក្តីបរិសុទ្ធិនៃការឃើញប្រកបដោយញាណដែលជាគ្រឿងដឹងច្បាស់មួយ ។ រីឯវិសុទ្ធិ ๕ ប្រការនេះ កើតមានឡើងដោយចិត្តបានលះផុតស្រឡះខ្លួន ដោយសារៈនៃ សំយោជន៖ ๓ គឺ សក្កាយទិដ្ឋិ ๑ វិចិកិច្ឆា ๑ នឹង សីលព្វតបរាមាស ๑ ។

๖- ចិត្តវិសុទ្ធិ សេចក្តីបរិសុទ្ធិនៃចិត្ត ๑ ។ ឯចិត្តវិសុទ្ធិនេះកើតមានឡើងដោយចិត្តបានលះផុតស្រឡះខ្លួន ដោយសារៈនៃ កាមរាគៈ នឹង សំយោជន៖ ๒ គឺ កាមរាគ ๑ នឹង បដិឃៈ ๑ ។

๗ ទិដ្ឋិវិសុទ្ធិ សេចក្តីបរិសុទ្ធិនៃការរួចចាកកិលេស ๑ ។

๘- បញ្ញាវិសុទ្ធិ សេចក្តីបរិសុទ្ធិនៃបញ្ញា ๑ ។ រីឯវិសុទ្ធិ ๒ ខាងចុងនេះកើតមានឡើងដោយចិត្តបានលះផុតស្រឡះខ្លួន ដោយសារៈនៃ អវិជ្ជាសវៈ ហើយនឹង រូបភព អរូបភព មានៈ ឧទ្ធច្ចៈ នឹង អវិជ្ជា ។

រីឯវិសុទ្ធិ ๔ ប្រការនេះ កាលបើបានសម្រេចកើតមានក្នុងខន្ធសន្តាននៃអរិយបុគ្គលហើយ រមែងតែផ្តល់ឲ្យអរិយបុគ្គលនោះនូវអានិសង្ស ๒ ប្រការគឺ យ៉ាងថា ភូតញាណទស្សនៈ គឺខន្សែនប្រកបដោយញាណជាគ្រឿងដឹងច្បាស់ដោយសេចក្តីពិត ๑ នឹង ទិដ្ឋិវិញ្ញាណទស្សនៈ គឺខន្សែនប្រកបដោយញាណជាគ្រឿងដឹងច្បាស់នូវការរួចចាកកិលេស ๑

សម្រាប់ការត្រាស់ដឹងខ្លួនមគ្គចិត្ត ៤ ទី១ផលចិត្ត ៤ ដែលទី១សម្រេចកើតឡើងដោយភាតប្រាកដហើយនោះ ។

ម្យ៉ាងទៀត តិចិត្តដ៏បរិសុទ្ធផ្លូវផងដែរប្រកបដោយវិសុទ្ធិ៩ប្រការ ដែលកើតមានឡើងដោយការលះផុតស្រឡះខ្លួន អាសវៈ ៤ ទីនសំយោជន: ១០ ហើយទីនតណ្ហា ៣ នោះហើយដែលត្រូវបានទាមបញ្ញត្តិហៅថាមគ្គចិត្ត ទីន ផលចិត្តនោះឯង ។ រមគ្គចិត្ត ៤ ដួង ទីនផលចិត្ត ៤ ដួង នោះមានលក្ខណៈខុសផ្សេង ។ ឆ្លាដូចម្តេចនោះ ដូចមានសេចក្តីអធិប្បាយបញ្ជាក់ខាងក្រោមនេះ ។

៣- មគ្គចិត្ត ៤ ដួង

មគ្គចិត្តទី ១- ឯមគ្គចិត្តទី ១ នោះ តិសំដៅចំពោះមគ្គចិត្តដែលកើតមានឡើងដោយបៃស្សនាញាណ ១០ បានលះផុតស្រឡះដោយដាច់ខាតខ្លួនចិដ្ឋាសវៈ ១ ទីនសំយោជន: ៣ មានសក្កាយទិដ្ឋិជាដើមនោះឯង។ ដោយហេតុនេះ ទើបមគ្គចិត្តទី ១ ត្រូវបានតំណុកជាមគ្គចិត្តប្រកបដោយវិសុទ្ធិ ៩ មានទិដ្ឋិវិសុទ្ធិជាដើម ហើយត្រូវបានទាមបញ្ញត្តិហៅថា សោតាបត្តិ-មគ្គ នោះ ។

មគ្គចិត្តទី ២- ឯមគ្គចិត្តទី ២ នោះ តិសំដៅចំពោះមគ្គចិត្តដែលកើតមានឡើងដោយ បឋមជ្ឈាន ទីនពុតយជ្ឈាន បានញ៉ាំង សកាមា-សវៈ ១ ទីន សំយោជន: ៦ តិកាមរាគ ទីនបដិឃៈឬសាឋរលោភ

ស្រាលស្តើងនោះឯង ។ ដោយហេតុនេះ ទើបមគ្គចិត្តទី ២ នេះត្រូវបាន
នាមបញ្ញត្តិហៅថា សកទាគាមិមគ្គ នោះ ។

មគ្គចិត្តទី ៣ - ឯមគ្គចិត្តទី ៣ នោះ គឺសំដៅចំពោះមគ្គចិត្តដែល
កើតមានឡើងដោយ តតិយជ្ឈាន ទើបចតុត្ថជ្ឈាន ចូលដោយដាច់ខាត
ខ្លួវ តាមាសវៈ ១ ទើបសំយោជនៈ ៦ គឺកាមរាគ ទើបដាយៈ
ហើយទើបកាមតណ្ហានោះឯង ។ ដោយហេតុនេះ ទើបមគ្គចិត្តទី ៣ ត្រូវ
ចាត់ទុកជាមគ្គចិត្តប្រកបដោយចិត្តវិសុទ្ធិ ហើយត្រូវបានតាមបញ្ញត្តិហៅថា
អនាគាមិមគ្គ នោះ ។

មគ្គចិត្តទី ៤ - ឯមគ្គចិត្តទី ៤ នោះ គឺសំដៅចំពោះមគ្គចិត្តដែល
កើតមានឡើងដោយ អរូបជ្ឈាន ៤ មានអាកាសានញ្ចាយតនជ្ឈានជាដើម
ចូលដោយដាច់ខាតខ្លួវ ភវាសវៈ ១ ទើប អវិជ្ជាសវៈ ១ ហើយ
ទើប សំយោជនៈ ៥ មានរូបរាគជាដើម ព្រមទាំងភវតណ្ហា ទើបវិ-
ភវតណ្ហានោះឯង ។ ដោយហេតុនេះ ទើបមគ្គចិត្តទី ៤ នោះ ត្រូវចាត់
ទុកជាមគ្គចិត្តប្រកបដោយវិមុត្តិវិសុទ្ធិ ទើបញាណវិសុទ្ធិ ហើយត្រូវបានតាម
បញ្ញត្តិហៅថា អរហត្តមគ្គ ដោយប្រការដូច្នេះឯង ។

រួមសេចក្តីពោលមកថា មគ្គចិត្ត ៤ ដួងនេះត្រូវចាត់ទុកថាចូលដោយ
ដាច់ខាតខ្លួវ អាសវៈ ៤ ទើបសំយោជនៈ ១០ ហើយទើបតណ្ហា ៣

ប្រកបដោយវិសុទ្ធិ ៤ ប្រការមានសីលវិសុទ្ធិជាដើម គ្រប់តាមកំណែដែលកំណត់ទុកនោះហើយ ។

៨-សម្មុច្ឆេទវិមុត្តិ

ឯសម្មុច្ឆេទវិមុត្តិ គឺសំដៅការរួចចាកកិលេសដោយដាច់ខាតដែលជាផលកើតមានឡើងដោយសម្មុច្ឆេទប្បហាន គឺការលះកិលេសដោយដាច់ខាតជាបុព្វហេតុនោះឯង ពីព្រោះចិត្តលុះណាតែលះកិលេសដាច់ជាមុន ទើបរួចចាកកិលេសនោះបានជាល់ជាប់ ។

ឯសម្មុច្ឆេទវិមុត្តិ កាលបើបានសម្រេចហើយ រមែងតែញ៉ាំងឱបដឋសប្បវិមុត្តិ គឺការរួចចាកកិលេសដោយសប្បកិលេស ឧឡិនិសប្បវិមុត្តិ គឺការរួចចាកកិលេសដោយលោស់កិលេសចោលចេញ ឲ្យកើតមានឡើងជាល់ជាប់ទៀត ចាំងនេះគឺជាយោបល់ដែលខ្ញុំបានត្រិះរិះយើញដូច្នេះឯង ។

ដោយហេតុនេះ ទើបផលចិត្តខ័ណ្ឌមួយ។ ដែលបានរួចចាកសំយោជនៈនោះត្រូវមានលក្ខណៈជាសម្មុច្ឆេទវិមុត្តិ. គឺការរួចចាកកិលេសដោយដាច់ខាត ១ ឧឡិនជាឱឡដឋសប្បវិមុត្តិ គឺការរួចចាកកិលេសដោយសប្បកិលេស ១ ហើយជាឧឡិនិសប្បវិមុត្តិ គឺការរួចចាកកិលេស ដោយលោស់កិលេសចេញ ១ ។

តែវិមុត្តិ ៣ ប្រការដូចបានអធិប្បាយខាងលើនេះ ឧឡិរិះមាតិ ៣

ប្រការមានអត្ថរសផ្សេងគ្នាដូចម្តេចខ្លះ បើវិមោក្ខ ទី៨ វិមុត្តិសុទ្ធតែសំដៅការរួចចាកកិលេសដូចគ្នា ?

ចំពោះរឿងនេះ បើតាមយោបល់ខ្ញុំគឺវិមោក្ខ ៣ មានអត្ថរសល្អិតហើយជ្រៅជាងវិមុត្តិ ដោយហេតុថាវិមុត្តិ ៣ គឺ សមុច្ឆេទវិមុត្តិ ១ បដិបស្សទ្ធិវិមុត្តិ ១ ទី៨ និស្សរណវិមុត្តិ ១ នោះគឺជាវិមុត្តិបញ្ជាក់ឲ្យដឹងថា ចិត្តដែលរួចចាកកិលេសនោះ គឺរួចចាកដោយដាច់ខាត ដោយកិលេសស្ងប់ ទី៨ដោយរលាស់កិលេសចេញតែប៉ុណ្ណោះ ។

ឯវិមោក្ខ ៣ គឺការរួចផុតស្រឡះចាកកិលេសនោះមាន៣ ប្រការគឺ៖

១-សុញ្ញតវិមោក្ខ គឺការរួចផុតស្រឡះចាកកិលេស ដោយសូន្យកិលេស ១ ។

២-អនិមិត្តវិមោក្ខ គឺការរួចផុតស្រឡះចាកកិលេស ដោយគ្មានត្រឿងសំគាល់កិលេស ១ ។

(នៅមានត)

ភិម្ពារព្រះយមក:

លោក ជ្រួ - ប៉ុង ប្រែរៀបរៀង

(តមក)

សម្បជញ្ញៈនោះមាន ៤ ប្រការគឺ

១- សាត្ថកសម្បជញ្ញៈ ការដឹងខ្លួនចាន់ភ្លាមក្នុងហានៈដែលមានប្រយោជន៍ ។

២- សប្បាយសម្បជញ្ញៈ ការដឹងខ្លួនចាន់ភ្លាមក្នុងហានៈជាទីសប្បាយ ។

៣- គោចរសម្បជញ្ញៈ ការដឹងខ្លួនចាន់ភ្លាមក្នុងហានៈដែលគួរត្រាច់ទៅនឹងមិនគួរត្រាច់ទៅក្នុងទីចាំងពួន ។

៤- អសម្មោហសម្បជញ្ញៈ ការដឹងខ្លួនចាន់ភ្លាមក្នុងហានៈដែលមានសេចក្តីមិនវង្វេងក្នុងប្រឡំ ។

១- អធិប្បាយអំពីសាត្ថកសម្បជញ្ញៈ

ព្រះយោគាវចរកុលបុត្រតែងណាក្នុងកន្លែងចាំងពួនមានការធ្វើដំណើរជាដើម ឲ្យដឹងថាមានប្រយោជន៍ ឬឥតប្រយោជន៍ ដូចជាលោករៀបនឹងចេញដើរទៅកាន់ទីណាមួយ តែតម្រិលជាមុនថា បើអាត្មាទៅ

ដល់ខ័ណ្ឌនោះហើយ មានប្រយោជន៍ដល់ខ្លួនអាត្មានឹងអ្នកដទៃដែរឬទេ ។ បើយល់ឃើញថាមានប្រយោជន៍ទើបបានទៅកាន់ទីនោះ បើយល់ឃើញថាឥតប្រយោជន៍អ្វីទេ ក៏ឈប់ខានលែងទៅកាន់ទីនោះ ។ សូម្បីធ្វើកិច្ចការអ្វី ។ ឬក៏និយាយរឿងរ៉ាវអ្វី ។ ឬនគិចារណារកប្រយោជន៍ឬឥតប្រយោជន៍ឲ្យយល់ច្បាស់ ដូចការធ្វើដំណើរនោះ រួមហៅថា សាត្ថកសម្បជញ្ញៈតាំងអស់ ។

២- អធិប្បាយអំពីសប្បាយសម្បជញ្ញៈ

ការដឹងខ្លួនខាន់ភ្លាមក្នុងហទៈជាទីសប្បាយ ឈ្មោះថា សប្បាយ.សម្បជញ្ញៈ ។ សប្បាយសម្បជញ្ញៈនេះ បើពោលសរុបឲ្យតិចមកនៅត្រឹម ៤ យ៉ាង គឺ៖

- ១- សេនាសនសប្បាយ ដឹងខ្លួរសេនាសនៈជាទីសប្បាយ ;
- ២- ឧតុសប្បាយ ដឹងខ្លួរដូវជាទីសប្បាយ ;
- ៣- គោជនសប្បាយ ដឹងខ្លួរគោជនជាទីសប្បាយ ;
- ៤- បុគ្គលសប្បាយ ដឹងខ្លួរបុគ្គលជាទីសប្បាយ ។

ខ័ណ្ឌទាំងនេះសម្រាប់នៅអាស្រ័យត្រូវបែប ហៅថា សេនាសនៈ ។ ទីសេនាសនៈណាដែលព្រះយោគាវចរនៅហើយ កើតមានជំពប់លោត, ក្រោធ, រំខឹង ទីសេនាសនៈនោះចាត់ជាទីមិនសប្បាយ ។ ទីសេនាសនៈណាធ្វើចិត្តអ្នកនៅឲ្យស្ងប់ស្ងាត់មិនសូវកើតមានលោត, ក្រោធ,

វេទ្ធិ៍ អាចចំរើនកម្មដ្ឋានបាន ទើសេនាសនៈនោះចាត់ជាទីសប្បាយ ។ ព្រះយោគាវចរដែលគេចេញពីទីមិនសប្បាយ ទៅនៅក្នុងទីសប្បាយវិញ យ៉ាងនេះឈ្មោះថា អ្នកដឹងខ្លួនសេនាសនសប្បាយក្នុងសប្បាយសម្បជញ្ញៈ ។

អាសនៈត្រជាក់, ក្តៅនឹងយ៉ាងកណ្តាល មិនត្រជាក់ពេក មិនក្តៅពេក ឬកាលមានភ្លៀងនឹងគ្មានភ្លៀង ហៅថា វេជ្ជៈ ។ ព្រះយោគាវចរដឹងថា វេជ្ជៈនេះត្រូវនឹងកម្លាំងរបស់ខ្លួន គឺធ្វើឲ្យខ្លួនបានសុខសប្បាយ វេជ្ជៈនេះខុសពីកម្លាំងខ្លួន ហើយប្រុងប្រយ័ត្នក្សាការពារខ្លួនឲ្យបានសុខសប្បាយ យ៉ាងនេះ ឈ្មោះថា អ្នកដឹងខ្លួនវេទុសប្បាយក្នុងសប្បាយ-សម្បជញ្ញៈ ។

ចាយទីកន្លែងណាគ្រប់មុខដែលសម្រាប់ចរិកោគនឹកលេបបាន ហៅថា គោចរ ។ ព្រះយោគាវចរចៀសវាងមិនបរិភោគគោចរដែលបណ្តាលឲ្យកើតទោសដល់ខ្លួន គឺថាធ្វើឲ្យខ្លួនឈឺចាប់ បរិភោគតែគោចរដែលមិនឲ្យទោសដល់ខ្លួន យ៉ាងនេះឈ្មោះថា អ្នកដឹងខ្លួនគោចរ-សប្បាយក្នុងសប្បាយសម្បជញ្ញៈ ។

មនុស្សប្រុស, ស្រី, ក្មេង, ចាស់, គ្រហស្ថ, បព្វជិត រួមហៅឲ្យខ្វៃតែមួយម៉ាត់ថា បុគ្គល ទោះមនុស្សជាតិអ្វីក៏ដោយ តាសាបាលីហៅថា បុគ្គល ។ ដូចគ្នា ។ បុគ្គលនេះ មាន ២ ពួក គឺពួកអ្នក

ប្រព្រឹត្តសុចរិតហៅថា បណ្ឌិត ១ ពួក ពួកមកប្រព្រឹត្តទុច្ចរិតហៅថា ពាល ១ ពួក ។ ព្រះយោគាវចរមិនសេចគប់នឹងបុគ្គលពាល សេចគប់តែនឹងបុគ្គលបណ្ឌិត យ៉ាងនេះ ឈ្មោះថា អ្នកដឹងខ្លួនបុគ្គលសប្បាយ គឺសប្បាយសម្បជញ្ញៈ ។

ព្រះយោគាវចរដែលបរិបូណ៌ដោយសប្បាយសម្បញ្ញៈ ៤ យ៉ាង ដូចបានពោលមកហើយនេះ តែងបានសម្រេចផលប្រយោជន៍តាមចិត្តចង់បានដែលជាប្រយោជន៍មិនហួសពីវិស័យរបស់ខ្លួន ដូចជា :

រឿងភិក្ខុធំងសាមណេរ

ឯកោ កិរ ឧបាភេ មានដំណាលថា ភិក្ខុកម្លោះមួយរូបនាំសាមណេរមួយរូបទៅឯព្រៃមហាវន ដើម្បីស្វែងរកឈើស្តួច ។ មគ្គា ឱក្កម្ម ដល់ទៅមហាវន សាមណេរនោះគេចចេញពីផ្លូវចូលទៅជិតកែវតែម្នាក់ឯង ឃ្លាតឆ្ងាយពីភិក្ខុ ។ អសុភំ ឱស្សា សាមណេរបានឃើញសាកអសុភមួយទៅស្ថិតពីខាងមុខ គំនិតថាណាអសុភកម្មដ្ឋាន ញុំាងឈបឈមដល់ខ្លួនឲ្យកើតមានឡើងហើយតិចាណាខ្លួនបង្កសង្វារដោយព្រះត្រៃលក្ខណញ្ញាណ គឺ អនិច្ចំ, ទុក្ខំ, អនត្តា បានសម្រេចអនាគាមិផល ទំរ្រាំនឹងចំរើនព្រះកម្មដ្ឋានតទៅទៀត ដើម្បីឲ្យបានសម្រេចអរហត្តផល ។ តំ អប្បស្សន្តោ ភិក្ខុកម្លោះនោះ កាលនឹងមកវិញ

សាមណេរមិនយើញក៏ស្រែកហៅសាមណេរ ។ ពួកបក្ខិតស្រែកហៅតតិយ បក្ខិតគោ បន្ទាយ ចាប់ដើមតំនឹតអាត្មាបួសមក អាត្មាមិនដែលដំណើរឲ្យគេកុអង្គណាស្រែកហៅដល់ពេលនេះទេ ចុះបើ ឯភ្លេះសព្វមិ ណ្ហើយចុះ អាត្មាឈប់ចំរើនកម្មដ្ឋានសិន ដល់ពេលថ្ងៃមុខចាំចំរើនទៀតឲ្យបានដល់អរហត្តផល ។ សាមណេរធ្វើយថា ហៅខ្ញុំព្រះករុណាធ្វើអ្វី ។ គេកុប្រាប់ថា អ្នកចូរមកខាងនេះ ។ សាមណេរចូលទៅជិតគេកុហើយ ប្រាប់គេកុនោះថា សូមព្រះករុណាមន្តទៅខាងនោះឈរបែរមុខទៅខាងកើត ត្រង់កន្លែងដែលខ្ញុំទៅឈរមួយរំពេចនោះ រួចសូមសំឡឹងមើលទៅខាងមុខ ។ សោ តថា តថា តេ គេកុនោះ ធ្វើតាមពាក្យសាមណេរប្រាប់ដូច្នោះ ទៅឈរនៅត្រង់ខាងនោះហើយសំឡឹងមើលទៅមុខបានឃើញសាកអសុភ គឺបញ្ចាងបញ្ចាតិចាណាអសុភកម្មដ្ឋាន បានដល់បឋមជ្ឈាន តិចាណាសង្ខារដោយព្រះត្រៃលក្ខណ៍ គឺបានសម្រេចអនាគាមិផល ដូចជាសាមណេរនោះដែរ ។

គេកុនឹងសាមណេរដែលបានសម្រេចអនាគាមិផលក្នុងខាងនោះ ដោយសារបានខាងសេនាសនៈជាទីសប្បាយ គឺថាត្រូវចំណុចចិត្តខ្លួនឯងបានបុគ្គលជាទីសប្បាយ គឺថា គេកុនឹងសាមណេរប្រព្រឹត្តសុចរិតដូចគ្នា ចូលចិត្តចំរើនអសុភកម្មដ្ឋានដូចគ្នា ជាកល្យាណមិត្តយ៉ាងវិសេស ។ មិនតែប៉ុណ្ណោះទេ គេកុនឹងសាមណេរនោះ ជាអ្នកបានគេសាងកុសលច្រើនជាតិណាស់

មកហើយ ជាអ្នកមានបុព្វហេតុសិស្សឃើញសាសនាចាស់ក្នុងជាតិនេះ ទើបបានសម្រេចមគ្គផល ដោយហេតុចំរើនអសុភកម្មដ្ឋានតែមួយខណៈប៉ុណ្ណោះ ។

ចំណែកពួកបុថុជ្ជនអ្នកកើតជាន់ក្រោយដែលក្រាស់ខៅដោយកិលេស ទើបពុំបានជាបានសេនាសនសប្បាយ, អាហារសប្បាយ ឥរិយាបុគ្គលសប្បាយ ឬបានឃើញសាកអសុភច្រើនដងក៏ដោយ ក៏មិនបានសម្រេចមគ្គផលអ្វីដែរ ព្រោះនិស្ស័យឃើញសាមិនខាន់ចាស់ក្នុង គឺថា មិនខាន់តែញ៉ាបរិបូណ៌ ។

៣- អធិប្បាយអំពីគោចរសម្បជញ្ញៈ

ពាក្យថា "គោចរ" នេះ មានន័យច្រើនយ៉ាង គឺការត្រាច់ខៅស្វែងរកអាហារបស់តិក្ខុ មានអាការដូចគោស្វែងរកស្មៅ ក៏ហៅថា គោចរ ដូចអ្នកស្រុកឆ្ងាប់ន័យយកថា តិក្ខុត្រាច់គោចរបិណ្ឌបាត ។

ការចំរើនកម្មដ្ឋានរបស់ព្រះយោគាវចរ ក៏ហៅថា គោចរ ។

ព្រះយោគាវចរពិចារណាដឹងច្បាស់នូវធម៌គួរត្រាច់ខៅនឹងធម៌មិនគួរ ត្រាច់ខៅ ហើយត្រាច់ខៅតែក្នុងទីដែលគួរ គឺជាទីឥតគោស ចៀសចេញទីមិនគួរ គឺជាទីមានគោស ដូចទីនៃស្ត្រីគេស្បា, ទីសម្រាប់ផឹកសុក, ទីសម្រាប់លេងល្បែងផ្សេងៗមានល្បែងគ្នាស់ជាដើម យ៉ាងនេះឈ្មោះថា អ្នកមានគោចរសម្បជញ្ញៈ ។

ព្រះយោគាវចរតាបាវណាដ៏ឆ្ងាស់ខ្លះតូមិប្តូស្រុកដែលឥតគោស ជា
ទីគោចរបិណ្ឌបាតគាចត្រាច់ទៅស្វែងរកអាហារបាន ហើយត្រាច់ទៅស្វែង
រកអាហារតែក្នុងភូមិស្រុកដូច្នោះ ចៀសចេញភូមិ ប្តូស្រុកដែលមានគោស
មិនគួរត្រាច់ចូលទៅ យ៉ាងនេះ ឈ្មោះថា អ្នកមានគោចរសម្បជញ្ញៈ ។

ម្យ៉ាងទៀត ព្រះយោគាវចរបានគាស្រ័យនៅកន្លែងសេនាសនៈជាទី
សប្បាយ គឺជាទីស្ងប់ស្ងាត់ ជាទីប្រាសចាកគោស ហើយចំរើនព្រះ
កម្មដ្ឋានបានណាមួយជាអារម្មណ៍ យ៉ាងនេះឈ្មោះថា អ្នកមានគោចរសៈ
ម្បជញ្ញៈ ព្រោះព្រះកម្មដ្ឋានជាអារម្មណ៍របស់ព្រះអរិយបុគ្គលតាំងពួង ។

ព្រះយោគាវចរដែលប្រកបដោយគោចរសម្បជញ្ញៈហើយ បើអង្គុយ
ចំរើនព្រះកម្មដ្ឋានបានណាមួយកំចាត់បង់កិលេសមិនបានទេ ត្រូវឆើបឈរ
ឡើងចំរើនកម្មដ្ឋានកំចាត់បង់កិលេស បើឈរហើយនៅតែកំចាត់កិលេស
មិនបានទៀត ត្រូវដើរទៅដើរមកចំរើនកម្មដ្ឋាន ទំព្យាយាមកំចាត់បង់
កិលេសឲ្យគាល់តែបាន ដូចព្រះមហាបុស្សទេវត្ថេរជាគួយាំង ដែលមាន
សេចក្តីដំណាលថា ៖

សោ កិរ បានត្តមកថា ព្រះមហាបុស្សទេវត្ថេរោ៖ ប្រកប
ដោយគោចរសម្បជញ្ញៈ គឺលោកស្គាល់ទីគោចរបិណ្ឌបាតនឹងស្គាល់ទីចំ-
រើនកម្មដ្ឋាន លោកប្រកាន់ឥរិយាបថដើរទៅដើរមកចំរើនកម្មដ្ឋានអស់
ចំនួន ១៨ ឆ្នាំ ។

ពួកអ្នកស្រុកនាំគ្នាដើរទៅជើរមកធ្វើស្រែចម្ការរបស់ខ្លួន ឃើញព្រះមហាបុស្សវេវាត្តរ ចេះតែនិមន្តត្រឡប់ចុះឡើងដូច្នោះ គំនិយាយគ្នាថា ព្រះមហាថេរនេះប្រហែលជាវង្វេងផ្លូវ ឬក្តៅគ្រឿងបរិក្ខារណាមួយ ឃានជាលោកនិមន្តទៅមកមិនឈប់ ។

ព្រះមហាបុស្សវេវាត្តរសួរសព្វសុំដល់អ្នកស្រុកនិយាយគ្នាដូច្នោះ កំលោកនៅតែស្ងៀម មិនឆ្លើយថាអ្វី មិនយកព្រះទ័យទុកដាក់នឹងសំដីអ្នកស្រុកនោះសោះ លោកនៅតែចំរើនព្រះកម្មដ្ឋាន ចំរើនសមណធម៌ គឺពិចារណាអាការ៣២ ក្នុងរូបកាយកំពុងសម្រេចព្រះអរហត្តកាត់កិលេសជាច់ផ្សេមុខ្លួនឯង ឃាន ។ ក្នុងថ្ងៃដែលព្រះមហាបុស្សវេវាត្តរបានសម្រេចព្រះអរហត្តនោះ ខេត្តា ព្រះឥន្ទ្រនឹងមហាព្រហ្មមកកាន់ទីលំដ្ឋាន ។

បុគ្គលដែលមានគោចរសម្បជញ្ញៈហើយឃើញសម្រេចមគ្គផល ជាព្រះអរិយបុគ្គលវិសេសនោះច្រើនរូបណាស់ នឹងកប់ចំនួនមិនអស់ទេ ។ ព្រះអដ្ឋកថាចារ្យទាំងឡាយកត់ទុកនៃព្រះមហាបុស្សវេវាត្តរមកសំដែងទុកក្នុងទីនេះ ដើម្បីឲ្យយើងឃើញថា ភិក្ខុប្រកបក្នុងគោចរសម្បជញ្ញៈ ជាហេតុនឹងឲ្យបានសម្រេចនូវព្រះអរិយមគ្គអរិយផល ។

(នៅមានត)

សម្តែងព្រះធម្មវិនិច្ឆ័យ ល្ង-ឯម ប្រែរៀបរៀង

ព្រះញាណកោសល ញាណ-ឈ័ន ពិនិត្យ

(តមក)

ឯវំ ពុទ្ធំ ឥច្ចេតេ- មក្ខានច្ឆយមញ្ជសំ
សត្ថោបច្ឆាជាសាយ ឯវមាគារមុត្តមំ ។

ប្រជុំពីរនៃអក្សរដូចនេះគឺ ពុទ្ធំ ជាគុណដ៏ប្រសើរកើតជាអស្ចារ្យ ជាកំពែងដ៏ខ្ពស់មួន ឧត្តម ខ្ពង់ខ្ពស់ អាចការពារសេចក្តីទុក្ខគ្រប់ប្រភេទ ពាំងពួន មិនឲ្យកើតឡើងបាន ព្រមទាំងធ្វើឲ្យនៅសុខក្សេមក្សាន្តចាត់បានដោយពិត ។

សត្ថាតេនប្បសាទំ តមេវេវ ឯវំ តុមាំ
តមេវ ជាវនីបញ្ញំ តមេវ កាវចំ សុភំ ។

ប្រជុំពីរនៃអក្សរថា ពុទ្ធំ នោះឯង ជាប្រាសាទកែវពាំង ៧ ប្រការ ពុំនោះសោត ដូចគូហាមាសដ៏ស្តុកស្តម្ភយ៉ាងនោះឯង ប្រជុំពីរនៃអក្សរ ថា ពុទ្ធំ នោះឯង ប្រាកដដូចជាកេត្រាសម្រាប់ឲ្យសត្វដាំធ្វើសង្ឃរាវដ្ត ពុំនោះសោត ដូចជាប្រទីបតង្វើសម្រាប់បំភ្លឺសត្វឲ្យឃើញព្រះអរិយសច្ច ពាំងមួន ប្រជុំពីរនៃអក្សរ ថា ពុទ្ធំ នោះឯង ដូចជាគ្រឿងក្រោះ ឬគ្រឿងកូដដ៏មាំជាទីលំអុងរឿងរបស់ស្តេចព្រះបរមក្សត្រដោយពិត ។

តញ្ច សិរសិ កាសន្តំ កិរិដំ រតនាមយំ
លលាដេ តិលកំ រម្មំ កប្បរុំ ឧយទ្ធុយេ ។

ប្រជុំតីរនៃអក្ខរថា ពុទ្ធិ នោះឯង ប្រាកដស្មើដូចមកុដដ៏សម្រែច ដោយកែវជាទំនុងរឿងលើសិរសា ជាទីសម្រែចដំរេក ដូចជាគ្រឿងប្រដាប់សម្រាប់ថ្វាស ដែលបុគ្គលធ្វើឲ្យមានសណ្ឋានដូចតំពូលកែវ ។ ពុំនោះសោត ដូចកប្បរជាថ្នាំនសថសម្រាប់កែរោគក្នុងភ្នែកពាំងគូ ឲ្យភ្លឺរុងរឿងដោយពិត ។

កតាកតកល្លាយុត្តេន សោវណ្ណមាលិតលេសុភា
ឯកាវលី ក្ខជាហារ ជនុសុមុត្តលច្ឆតា ។

អក្ខរៈថា ពុទ្ធិ នោះ ប្រាកដស្មើដោយកុណ្ឌលមាសឫទ្ធិកំរងមាសសំពាប់ប្រដាប់ត្រចៀកពាំងគូ ពុំនោះសោត ដូចជាកែវមុត្តាហារមានលំអត្រង់ផ្ទៃ មានខ្សែនតែមួយ សម្រាប់ធ្វើប្រដាប់ត្រចៀកពាំងពីរជាទំនុងរឿងដូច្នោះ ។

ព្រោះហេតុនោះ បុរសជាបណ្ឌិតដែលបានដល់នូវព្រះសាស្តាចារ្យជាទីពឹង ទីឰកហើយ អ្នកប្រាជ្ញពាំងឲ្យលោកសន្មតថាជាបុគ្គលប្រសើរលើស ក្នុងលោកដោយពិត ។

កាលនោះ យក្សជាសម្ភាទិដ្ឋិ ឃើញភាលទៅនឹងយក្សជាម៉ច្ឆាទិដ្ឋិថា ម្នាលអ្នកដ៏ចំរើន ! អំពើដែលអ្នកធ្វើនេះពុំគួរសោះឡើយ កិរិយា

ប្រហារត្រះភ្នំខ្ញុំដែលអ្នកបានធ្វើហើយនេះពុំប្រតែរទេ អ្នកឯងត្រូវតែធ្វើ
ខ្លាកម្មដ៏ធ្ងន់ខ្លាំងនេះទើបបាន ។

ឯកស្សជាមន្ត្រីដ៏លុះបានស្តាប់ហើយ ក៏សួរថា ខ្លាកម្មដូចម្តេចដែលឯង
ត្រូវធ្វើ តើធ្វើដូចម្តេចខ្លះ? ។ ឯកស្សជាសម្តីដ៏នោះតបថា ខ្លាកម្ម
ដូចនេះ គឺត្រូវអ្នកឯងចេញទៅស្វែងរកអាហារយកមកឲ្យកុមារនេះបរិភោគ
ឲ្យស្កប់ស្កល់ទើបបាន ។

ឯឯកស្សជាមន្ត្រីដ៏ក៏ខ្ជួលត្រមតាមថា សាធុ ស្រួលហើយសំឡាញ់
ហើយនិយាយផ្តាំទៀតថា បើខ្ញុំចេញទៅស្វែងរកអាហារមិនទាន់ត្រឡប់
មកដរាបណា អ្នកត្រូវធ្វើចាំខ្ញុំកុំឲ្យនេះដរាបនោះ លុះតោលយ៉ាងនេះ
ហើយក៏ដើរចេញទៅស្វែងរកអាហារ បានចូលទៅកន្លែងព្រះបរមរាជវាំង
ហើយនាំយកគោជនដ៏មានឧជារសដែលនាយរំសេវអ្នកចាត់ចែងព្រះក្រ-
យោស្វាយបានដាំងដាក់ក្នុងថាសមាស ទុកបម្រុងថ្វាយព្រះបាទអជាត-
សត្រូវបរមក្សត្រិយ៍ដែលជាព្រះរាជបុត្តព្រះបាទពិម្ពិសារវរាជ, ក៏នាំយកមក
កាន់សំណាក់កុមារបរិយោនិមិត្តអាត្មាដូចជាបិតានៃកុមារនោះ បានចាត់
ចែងឲ្យកុមារបរិភោគអាហារដរាបដល់ឆ្អែត ស្រេចហើយសរសេរអក្សរ
ដាក់សេចក្តីសត្យត្រង់ទៅថាសមាសទៀតថា «ពាក្យគោលថាពុទ្ធំ គឺកុមារ
នេះបានគោលហើយ សេចក្តីព្យាយាមបំពេញខ្លាកម្មនេះក៏ខ្ញុំបានធ្វើ
ហើយដែរ » លុះសរសេរហើយអធិដ្ឋានថា អក្ខរៈនេះឲ្យឃើញច្បាស់ដ

ចំពោះព្រះពុទ្ធតែមួយព្រះអង្គប៉ុណ្ណោះ ស្រេចហើយបបួលគ្នាចៀសចេញទៅក្នុងកាលនោះឯង ។

លុះកត្រីភ្លឺឡាស់ស្រឡះឡើងហើយ ក្នុងកាលព្រះបរមគ្រូត្រេយ៍ដ៏តទំនងសោយព្រះក្រយាស្ងោយ កំពង់បុរសតាំងឡាយស្ងែរកថាសមាសសំពះដំកល់ព្រះក្រយាស្ងោយតុំចាន់ឃើញ ទើបកើតជាគោឡាហលគឺកកងនាំគ្នាដើរល្បាតគយគន់រកក្នុងព្រះបរមកំងកំពុំចានឃើញ ទើបចេញទៅស្ងែរកខាងក្រៅ កំចានឃើញថាសមាស នៅកងរនេះរបស់ព្រាហ្មណ៍អ្នកដឹកអុសនោះ ហើយចាប់កុមារដែលនៅក្នុងរនេះនាំយកមកព្រមតាំងថាសមាសចូលទៅថ្វាយព្រះបរមគ្រូត្រេយ៍ក្នុងកាលនោះឯង ។

ចំណែកឯព្រះចាន់អជាតសត្រូវបរមគ្រូត្រេយ៍ ព្រះអង្គចានទតទៅឃើញអក្សរចារឹកជាក់នៅថាសមាសនោះ ទ្រង់ចានអានមើលជ្រាបសេចក្តីសព្វគ្រប់ហើយ កំមានព្រះពុទ្ធហឫទ័យសោមនស្សជ្រះថ្លា ដៅទៅលើកុមារនោះ ហើយព្រះអង្គព្រះពុទ្ធចានតាំងជាសេដ្ឋត្រមតាំងយសសក្តិដ៏ប្រសើរដល់កុមារនោះឯង ឯកុមារដែលចានសម្លាប់ឆ្មាំងនេះ ទំនងថាចានព្រោះមាតាបិតាចែកឲ្យតិចទេ ឬជាទេវបុត្តទេវធីតាឡើងយកឲ្យដ៏មានវិច្ចិអានុភាពច្រើនចែកឲ្យតិចទេ តំចានដោយផលនៃសីលរក្សានៃសម្ចាំងដែលខ្លួនធ្លាប់ត្រេវហើយចានចំរើនថា ខេមា ភុម្ហស្ស ប៉ុណ្ណោះឯង ។

ព្រោះហេតុដូច្នោះ ព្រះអរហន្តទាំងឡាយលោកបានតោលនូវបទ ព្រះនាថាថែមទួនទៀតថា :

ជិនស្ស ជាមំ សុចិនេន ទេវំ
ន ហោតិ កិតិ កណាតោ ជិនស្ស
តស្មា មុនិន្ទំ សតតំ សរេថ
តុណោ វិនស្ថា សរណាតុមេថ ។

អធិប្បាយថា សេចក្តីកិតក៏យតក់ស្ទុតរមែងមិនមាន ដល់ជនអ្នកតោលនូវព្រះនាមនៃព្រះជិនស្រី ដោយហោចទៅគ្រាន់តែទាន់ក្នុងសុបិនក៏យ៉ាងនេះឯង, ព្រោះហេតុដូច្នោះ អ្នកជាសប្បុរសទាំងឡាយ ត្រូវតែនឹករលឹកនូវព្រះនាមព្រះពុទ្ធដែលជាធំជាងអ្នកក្រាជ្ញ ឲ្យរឿយ ។ កាលបើអ្នកទាំងឡាយបានតោលសរសើរនូវពុទ្ធគុណហើយ ត្រូវដល់នូវព្រះពុទ្ធជាទីពឹងជាទីរលឹកឲ្យទាំមួនដោយប្រពៃចុះ ។

សម្តែងរឿងនិទានកុមារជាបុត្តនៃព្រាហ្មណ៍មិត្តទិដ្ឋនិងសម្ភាទិដ្ឋជាគំរប់ពីរ កណ្ឌវគ្គទី៧ កំចប់សេចក្តីជាសង្ខេបតែប៉ុណ្ណេះឯង ។

៣- ចាទបិដ្ឋកាយវត្ថុកថា

សម្តែងរឿងនិទានទុច្ចរិតអ្នកបួសជាព្រះចាទបិដ្ឋជាតុ គឺឈ្មោះទ្រនាប់ព្រះចាទ ដោយពាក្យថា ជម្ពុទីបេ មហោតេជិតោ តាវ ឧត្តិណាបសុ្ស ឯកំ បច្ចន្តជនបំ អហោសិ ដូច្នេះ

ជាដើម អធិប្បាយជាសេចក្តីថា ចូនឮរឿង ។ មកថា កុដុម្ពិកបុរសម្នាក់ក្នុងក្រុងសាវត្ថីនេះ ជាអ្នកមានមានទ្រព្យច្រើនសន្ធឹកសន្ធាប់ ។ ថ្ងៃមួយ កុដុម្ពិកបុរសនោះ ចូលទៅកាន់ផ្ទះរបស់ភរិយាដែលមានឈ្មោះថា ឧត្តរា ក្នុងពេលថ្ងៃត្រង់ ហើយសួរនាងថា ម្នាលនាងដ៏ចម្រើន ឥឡូវនេះ ពួកមនុស្សដែលជាអ្នកបម្រើរបស់យើងទាំងឡាយ ធ្វើអ្វីគ្រប់ៗគ្នាដែរឬទេ ? ឧត្តរានាងក៏ឆ្លើយតបទៅថា ម្នាលលោកដ៏ចម្រើន ពួកមនុស្សដែលជាអ្នកបម្រើរបស់យើងទាំងឡាយ ធ្វើអ្វីគ្រប់ៗគ្នាដែរ ។ ចំណែកឯលោកវិញ ចូរលោកបរិភោគចុះ ។ កុដុម្ពិកបុរសនោះ ក៏ពោលតបទៅនាងថា ម្នាលនាងដ៏ចម្រើន ខ្ញុំមិនបរិភោគទេ ខ្ញុំនឹងទៅកាន់ទីដែលព្រះសាស្តាគង់នៅ ហើយនឹងបរិភោគ ។ ឧត្តរានាងក៏ពោលតបទៅថា ម្នាលលោកដ៏ចម្រើន ចុះលោកនឹងទៅកាន់ទីដែលព្រះសាស្តាគង់នៅ ដើម្បីធ្វើអ្វី ? កុដុម្ពិកបុរសនោះក៏ពោលតបទៅនាងថា ម្នាលនាងដ៏ចម្រើន ខ្ញុំនឹងទៅកាន់ទីដែលព្រះសាស្តាគង់នៅ ដើម្បីធ្វើការបម្រើព្រះសាស្តា ។ ឧត្តរានាងក៏ពោលតបទៅថា ម្នាលលោកដ៏ចម្រើន ចុះលោកនឹងទៅកាន់ទីដែលព្រះសាស្តាគង់នៅ ដើម្បីធ្វើការបម្រើព្រះសាស្តាដែរឬ ? កុដុម្ពិកបុរសនោះក៏ពោលតបទៅនាងថា ម្នាលនាងដ៏ចម្រើន ខ្ញុំនឹងទៅកាន់ទីដែលព្រះសាស្តាគង់នៅ ដើម្បីធ្វើការបម្រើព្រះសាស្តាដែរ

ភាពធនាទិមន្តដូច្នេះហើយ ក៏ចាត់ចែងកសាង នូវបណ្ណាសាលា (សាលាប្រក់ស្បូក) មួយ ក្នុងដងព្រៃជាទីមនោរម្យ ទៅដិតព្រះខនតហើយប្រគេនបណ្ណាសាលានោះដល់ព្រះថេរៈ ។ ចាស់កនោះតែងផ្គត់ផ្គង់ដោយបច្ច័យ ទាំងបួនអស់កាលជានិច្ចតុំដែលជាចំឡើយ ។

ចំណែកឯព្រះថេរៈចាន់ទៅកន្លងទីដ៏សប្បាយនោះហើយ ចានយកដីខ្សាច់មកកសាងធ្វើតាលុកចេតិយ បញ្ចុះព្រះចុងបង្គិធាតុ នៃព្រះមានព្រះភាគ ស្រេចហើយតាក់តែងបូជាព្រះធាតុនោះដោយសក្ការៈបូជាទាំងឡាយមានគ្រឿងក្រអូបទឹងប្រទីបជ្វាលា ព្រមទាំងផ្កាកយផ្កាកម្រងជាដើមអស់កាលជានិច្ច ហើយតាត់ទៅអាស្រ័យក្នុងសាលានោះឯង ។

សម័យនោះ មានបុរសម្នាក់អ្នកបម្រើនូវឥស្សរៈខេរវៈបួ គេនៅក្នុងផ្ទះជិតលំនៅ នៃចាស់កនោះ ជាបុគ្គលមិច្ឆាទិដ្ឋិតែងនមស្សការគោរពប្រតិបត្តិបូជាឥស្សរៈខេរវៈបួរបស់ខ្លួនជាប់ជាប្រចាំឡើយ ។

ឯចាស់កបានឃើញបុរសនោះ តែងបូជាកប់គាន់ឥស្សរៈខេរវៈបួដូច្នោះហើយ ក៏និយាយតណិទាសរសើរគុណជាអស្ចារ្យផ្សេង ។ ចំពោះបុរសនោះដូចនេះថា ម្នាលសំឡាញ់អ្នកមានធុរៈស្មើ សូមសំឡាញ់កុំធ្វើព្យាយាមកន្លងទីដែលមិនមែនជាបុព្វាភេតដូច្នេះឡើយ ចូរសំឡាញ់លះបង់នូវទិដ្ឋិមិច្ឆាទិដ្ឋិនេះចេញ ។

កាលនោះ បុរសអ្នកបម្រើឥស្សរខេរ៉ូបបានស្តាប់ហើយ ក៏ពោលតបវិញថា: ម្នាលសំឡាញ់ បុះអានុភាពគុណព្រះសាស្តាជាគ្រូរបស់អ្នកតើរសេសដូចម្តេចខ្លះ ? ឯអានុភាពគុណនៃខេរ៉ូបជាធំរបស់យើង ទើបប្រសើរជាងគុណនៃព្រះសាស្តាជាគ្រូរបស់អ្នកដោយពិត ។ លុះបុរសនោះបានពណ៌នាសរសើរគុណខេរ៉ូបរបស់ខ្លួនរួចហើយ, ក៏ក្រឡប់ពោលថាព្រះសម្មាសម្ពុទ្ធជាបុគ្គលឥតគុណវិញ, ហើយពោលសរសើរគុណខេរ៉ូបរបស់ខ្លួនផ្ទួនថ្មីមកទៀត ដោយបទព្រះគាថាដូច្នេះថា:

តំបុរំ សោ វិនាសេសិ ឧលាឧយនក្ខិនា
អសុរេបិ វិនាសេសិ តំសុលេន បតំសរេ...

អធិប្បាយថា: ខេរ៉ូបជាឥស្សរៈ គឺព្រះឥស្សរជាធំជាអម្ចាស់នៃយើងនោះ ព្រះអង្គមានអានុភាពខ្លាំងណាស់ បើទ្រង់ពិរោធហើយអាចញ៉ាំងស្ថានត្រៃត្រឹង្សបុរីឲ្យវិនាសទៅបាន ដោយអគ្គិនេត្រដ៏តាំងនៅឰដ៏ថ្ងាសតាំងអាចញ៉ាំងពួកអសុរតាំងឲ្យវិនាសទៅដោយលំពែង ដែលមានមុខបីបានផងដោយពិត ។ ព្រះអង្គចងក្រងភ្ជាប់ក្តងសក់ដ៏កណ្តាញ់ធ្វើឲ្យទៅជាសែ្បងភ្លៅប្រតិមាប្រតំស្តុះតួបស្តុះធំជាដើមបាន ទ្រង់មានតំរោយបីអង្គមាននាងទេវកញ្ញាតតាំជាដើម សឹងប្រកបដោយជជាក្តងសក់ពាក់ស្រែះពិតស្ថិតល្អ ព្រះអង្គតែងតាំងតំរោយមួយជាប់ទៅតាមព្រះអង្គ ទៅវិលាដែលត្រាច់ទៅលើផែនដី, ព្រះអង្គតែងទ្រង់ទេវកញ្ញាដ៏តំណាក់ស្បែកដ៏ប្រកបដោយ

ស្មើដំណើរ ព្រះអង្គទ្រង់ស្តាយតែកន្ទបកម្ម ដូចបុគ្គលទ្រង់ស្តាយតែដំ
ណាវសម្លៃមាំងពួងគ្រប់ពាក្រើ ព្រះអង្គទ្រទ្រង់នូវធ្នូធ្នឹមទុស្សជាប្រក្រតី
តែងបរិភោគអាហារតែកន្ទលលាក្សាលភ្លោចមាំងឡាយដោយតិត, ព្រះ
អង្គមិនបានតើតខ្មៅ មិនភ័យ មិនបានស្លាប់ ជាខ្មែរតាខ្មៀងមាត់
តិត ខ្មែរប្រែបបស់ខ្ញុំប្រសើរជ្រាកដដូចនេះឯង បុគ្គលដ៏ទៃនឹងមានគុណ
ជ្រាកដស្មើដោយឥសរ្យរខ្មែរប្រែបបស់ខ្ញុំក្នុងលោកនេះពុំមានឡើយ ។

ឯទ្បាសក លុះបានស្តាប់ពាក្យនេះហើយ ក៏និយាយតបវិញថា
ម្នាលសំឡាញ់ គុណមាំងឡាយនៃឥសរ្យរខ្មែរប្រែបបស់អ្នកនេះលើកពុក
សិនចុះ លុះពោលយ៉ាងនេះហើយ ក៏នាំយកគុណមាំងពួងនៃព្រះមាន
ព្រះភាគមកសម្តែងជ្រាប់ សូត្រជាបទព្រះគាថាដូច្នេះថា :

ណោកោ សត្ថុសាវិត្តិ- មាជាវោ សាកវោ យថា
សត្ថុសំ គុណាភស៊ីនំ អាជាវោវ តថាកតោ . . .

(នៅមានត)

(តមក)

ពោធិសត្វដ៏ឆ្លាតជាស្តេចទ្រាល់ កំពូលមហាក្សត្រាធិរាជថា បពិត្រមហាភ ព្រះចុតអម្ចាស់ទ្រាល់ខ្ញុំឆ្លាតព្រះភជាខេពីរដ្ឋូវ្ហ, សេចក្តីកន្ធឆ្លាតហើយក្តី, សេចក្តីនាឆ្លាតមកដល់ក្តី, សេចក្តីនាបច្ចុប្បន្នឥឡូវនេះឯងក្តី, កំអញខ្ញុំសឹងដឹងច្បាស់ឥតកំចាំងឡើយ, បពិត្រមហាភ នាសេចក្តីសុខុមកំចាំងព្រះចុតអម្ចាស់មានព្រះចំនាថា នាងទុម្មរាខេវីប្រាប់ខ្ញុំ កំពុកនៅនោះហោង, អម្ចាស់ ក្តីកំចាំង អាចារ្យសេនកៈ អាចារ្យបុក្ខសៈជាដើមមិញ តើនរណាប្រាប់ខ្ញុំ, មួយសោត ប្រស្នាបង្ហើយមិញ នរណាប្រាប់ខ្ញុំ, មួយសោត ប្រស្នាខេវតាមិញ នរណាប្រាប់ខ្ញុំ, មួយសោត ឯក្តីកំចាំងតាំងអម្បាលនោះ អញខ្ញុំសឹងដឹងច្បាស់ឥតកំចាំងនឹងប្រាប់ខ្ញុំឡើយ, ថាដូច្នោះហើយ កំសូត្រខ្លួតាថានេះថា :

យំ សាលវនស្មឹ សេនគោ
ចាបកាម្មមកាសិ អសត្តិរូបំ
សច្ចំនោវ រាហោគតោ អសំសិ
តុយ្ហំ ចាតុភតំ ស្តុតំ មមេតន្តិ ។

បតិត្រមហាកដអើយ ! រីអាចារ្យសេនកៈនោះ ឆ្ពោះទៅអំពើតើថ្កាច
ឯណា មិនគួរសេប្យុសេងតំាងឡាយឆ្កើ មានមាខៀបដើមសាលព្រឹក្ស,
បតិត្រមហាកដអើយ ! អាចារ្យសេនកៈឆ្ពោះមុខទៅទៅហានស្ងាត់ហើយ
កំស្រដីក្តីកំចាំងប្រាប់សណ្តាប់ក្នុមួយ, រីសេចក្តីកំចាំងនោះ ធ្វើឲ្យប្រា-
កដកំណត់អញ្ចឹងឮច្បាស់ហើយ, បតិត្រមហាកដអើយ ! នាអំពើអាចារ្យ
សេនកៈនោះ ថាមានមេដក់ខង(១)មួយ មានឈ្មោះដូច្នោះ។ នៅឮដំនួរ
នេះឯង, អាចារ្យសេនកៈឯងសម្លាប់មេដក់ខងនោះស្លាប់ មានឮដំខៀច
សាលវនុទ្យានហានស្ងាត់ យកគ្រឿងប្រដាប់ក់នោះមួរក្នុងសំពត់ នាំ
រត់មកខុកក្នុងផ្ទះគាត់ឯង, មហាកដអើយ ! អាចារ្យសេនកៈនេះ ទៅ
នាហានស្ងាត់ហើយ មកប្រាប់នាសេចក្តីកំចាំងនូវក្តើសំឡាញ់; បតិត្រ
មហាកដអើយ ! រីសេចក្តីកំចាំងនោះ អញឮសឹងដឹងច្បាស់ប្រាកដហោង,
អញឮមិនជាសត្រូវនឹងព្រះបាទអម្ចាស់ឡើយ ; រីអាចារ្យសេនកៈក្តៅ ជា
សត្រូវនឹងព្រះបាទអម្ចាស់វិញ បតិត្រមហាកដ រីអំពើជាសត្រូវនឹងព្រះ-
បាទអម្ចាស់ដូច្នេះ ក៏ព្រះបាទអម្ចាស់ឲ្យចាប់អាចារ្យសេនកៈហោង ។

ព្រះបាទវិទេហកដ មើលទៅអាចារ្យសេនកៈបន្ទូលដណ្តឹងថា ម្តេច
ទៅអាចារ្យសេនកៈ មែនដូច្នោះឬម្តេច? អាចារ្យសេនកៈទូលព្រះមហា-
ក្សត្រថា អម្ចាស់មែនតិតហោង, ស្តេចបង្គាប់ថា គ្នាយើងយកអាចារ្យ

១- ជ្ឈាមស ។ ពាក្យនេះក្លាយមកពីពាក្យសៀម ។

សេនកៈទៅកុកកន្ទ្រៈ ។ ទើបចៅមហាសថទីនសំដែងថ្លែងសេចក្តីកំចាំងរបស់អាចារ្យបុក្កុសៈ សូត្រគាថាខេះថា:

បុញ្ញសម្បទិសស្ស តេ ជនិន្ទ
ឧបន្នោ កោតោ អភជបត្តោ
ភាតុវ រហោកតោ អសំសំ
កុយ្ហំ ចាតុកតំ សុតំ មមេតន្តិ ។

បពិត្រមហាកជប្រសើរអើយ ! រីអាចារ្យធម្មជិឃ្លាំកើតកុងអង្គអាចារ្យបុក្កុសៈ ដ៏ជាសត្រូវព្រះជាតអម្ចាស់ច្បាស់ មិនគួរបំរើស្តេចចៅថៃសព្វថ្ងៃ អម្ចាស់ខុកជាខុនណាង. អាចារ្យបុក្កុសៈនោះ ឆ្ពោះទៅហានស្ងាត់ហើយ កំប្រាប់សេចក្តីកំចាំងនោះដល់ប្អូនស្រីមួយ, បពិត្រមហាកជអើយ ! ក្តីកំចាំងនោះច្បាស់ប្រាកដ អញខ្ញុំបានឮហើយ ។

ព្រះជាតវិទេហកជ មើលទៅឃើលអាចារ្យបុក្កុសៈ ស្តេចបន្ទូលដណ្តឹងថា ម្តេចអាចារ្យបុក្កុសៈ តិតដូចគាត្យមហាសថនោះឬម្តេច ? អាចារ្យបុក្កុសៈ ទូលស្តេចថា: អម្ចាស់ ! អញខ្ញុំមែនតិតហាន ។ ស្តេចបន្ទូលនឹងអ្នកឆងថា គ្នាយើងយកអាចារ្យបុក្កុសៈនោះទៅកុកកន្ទ្រៈ ។ ទើបចៅមហាសថអ្នកប្រាជ្ញទីនសំដែងថ្លែងប្រាប់ក្តីកំចាំងអាចារ្យកាមិន្ទ សូត្រជាគាថា ខេះថា :

អាតាលោ យំ អសត្ថិភូតោ
កាមិន្ទោ នរនេវោន ដុន្ទោ
បុត្តស្ស រហោគតោ អសិសិ
តុយ្ហំ ចាតុកតំ សុតំ មមេតន្តិ ។

បពិត្រមហាកដអើយ ! អាចារ្យកាមិន្ទនេះ មានអាតាធតក្សាធំធ្ងន់ ដែលមិនជាអ្នកសប្បុរសឡើយ, ដូចដែលធ្លាប់ បានមានយកក្សមួយឈ្មោះនរនេវសេតសមចាំនួនហតុនោះ មិនគួរព្រះបាទអម្ចាស់ត្រាស់ឲ្យគាត់ឡើងលើក្រឡាគំនាល់, ព្រះបាទអម្ចាស់អើយ ! អាចារ្យកាមិន្ទនោះឆ្ពោះទៅនាហានស្ងាត់ហើយ ក៏មកច្រាប់ក្តីកំចាំងនោះនូវកូននោះ, បពិត្រមហាកដ រឿងក្តីកំចាំងនោះច្រាកដ អញខ្ញុំបានឮហើយ ។

ស្តេចបន្ទូលដណ្តឹងអាចារ្យកាមិន្ទថា ម្តេចអាចារ្យកាមិន្ទពិតឬម្តេច? អាចារ្យកាមិន្ទទូលព្រះមហាក្សត្រថា អម្ចាស់មែនពិតហោង, ស្តេចតំបន្ទូលនឹងអ្នកផង ឲ្យយកអាចារ្យកាមិន្ទទៅទុកក្នុងឆ្រោះ ។ ឯចៅមហាសេដ្ឋអ្នកច្រាប់ជំនឹងសំដែងក្តីកំចាំងអាចារ្យខ្មៃនូ កំសួរគាថានេះថា :

អដ្ឋវង្កំ មណិរតនំ ឧប្បរំ
សង្កោ តេ អធនា បិតាមហស្ស
ឆេរិន្ទស្ស កតំ តទជ្ជ ហាត្តុំ

មាតុ ច រហោគតោ អសំសិ

កុយ្ហិំ ថាតុគតំ សុតំ មមេតន្តិ ។

បពិត្រមហាភន្ត ! រីកែវមណីរតនៈដ៏មានវង់ប្រាំបី ស្មើរឿង តើ ព្រះឥន្ទ្រាធិរាជ ឲ្យព្រះចុតាតុសភពជាំជាព្រះវរបិតា ព្រះចុតាអម្ចាស់ បង្គាស់សន្ធតជាកែវមន្តល ឥឡូវជាទ្រព្យកណ្តាប់ដៃនៃអាចារ្យទេវិន្ទហើយ អាចារ្យទេវិន្ទនោះគ្គោះទៅនៅឋានស្វាត់ហើយ ប្រាប់ក្តីកំចាំងនោះស្មោះនឹងម្តាយឯង; បពិត្រមហាភន្ត ក្តីកំចាំងចាំងអម្បាលនោះសឹងប្រាកដអញខ្ញុំបានត្បាហើយ ។

ស្តេចបន្ទូលជណ្តើងអាចារ្យទេវិន្ទថា អ្នកចាត់ដូចពាក្យមហាសច្ចឬ? អាចារ្យទេវិន្ទក្រាបទូលថា អម្ចាស់ មែនតាតហោង ។ ស្តេចបន្ទូលថា គ្នាយើងរង់អ្នកឡើយយកវាចាំង ៤ នោះទៅពុកក្នុងជ្រោះ ។ ឯអាចារ្យចាំង ៤ ត្រមួនទៅកន្លងតាងកន ហើយគិតថា នុយើងនឹងសម្លាប់មហាសច្ចកូវម្តេចឥឡូវប្រែជាដូច្នេះវិញ ។ ទើបតោធសត្វទូលព្រះមហាសត្វគ្រាធិរាជថា បពិត្រមហាភន្ត នាអញខ្ញុំថា ក្តីកំចាំងអាត្មាគំមិនគួរសំដែងថ្វែងប្រាប់អ្នកដទៃនោះបន្តុហេតុនោះហោង, ថាបើប្រាប់អ្នកដទៃក្តី គោសនោះនឹងមានជន្ម៍អាត្មាមិនវែងឡើយ, ព្រះមហាសត្វនឹងសំដែងថ្វែងធម៌ទេសនាដទៃក្រៅពីបុរសូត្រទូវព្រះគាថាដូច្នេះថា :

កុយ្ហស្ស ហិ កុយ្ហមេវ សាទុ
ន ហិ កុយ្ហស្ស បសន្នមានិកម្មំ
អនិប្ផន្នាយ សហេយ្យ ន័រេ
និប្ផន្នត្ថេ យថា សុខិ កណេយ្យ ។

បពិត្រមហាឥន្ទ! ព្រ័ត្តសុខុមកំចាត់ឥតប្រ័ក្សាខុតនូវអាត្មាឯង មិនឥតប្រ័ធ្វើអំពើឲ្យចៃដន្យាស់នូវក្តីកំចាត់ឥនោះ, បពិត្រមហាឥន្ទ កាលណាចិត្តប្រ័ថ្នាមិនទាន់បរិបូណ៌, ព្រ័អ្នកមានប្រ័ថ្នា កំតួរទស្សាហ៍អត់សង្កត់នៅកុំអាលស្រដ៏ឡ័យ, បើក្តីប្រ័ថ្នានោះបរិបូណ៌ហ៊ីយ កំឥតប្រ័ស្រដ៏ដោយចំណាន់ហោង ។ បពិត្រមហាឥន្ទ ព្រ័អ្នកប្រ័ថ្នាជ្រងមិនដែលបើកស្រាយឲ្យអ្នកពាន់ឡាយដួងឥតនូវក្តីសុខុមកំចាត់ឥនោះ សឹងស្មោះរក្សាក្តីកំចាត់ឥកំងុកដួចបុរសមួយរក្សាកំណប់មាសហោង, ព្រ័ប្រយោជន៍ក្តីសុខុមកំចាត់ឥ បើពុំរក្សាទេ កំធ្វើឲ្យប្រ័កដកំណាត់ដោយដំណឹងនោះមិនប្រ័តៃឡ័យ; បពិត្រមហាឥន្ទ, ព្រ័អ្នកប្រ័ថ្នាជ្រងមិនដែលប្រ័ចាប់ស័ត្តុសេចក្តីកំចាត់ឥនោះ ឆ្ពោះនូវស្រ័ក្តី សត្រូវក្តី ន្រ័អ្នកឯណាកំប្រ័ណោមយកចិត្ត យកនូវអាមិសទ្រ័ព្យជនក្តី, ន្រ័អ្នកឯណាជាសត្រូវ កុំធ្វើជាមិត្ត ឯមាត់ថាផ្សេង ក្នុងចិត្តផ្សេង មិនឥតប្រ័ចាប់ស័ត្តុសេចក្តីកំចាត់ឥដល់អ្នកនោះឡ័យ, បពិត្រមហាឥន្ទ ន្រ័អ្នកឯណាមួយមកស្រដ៏ប្រ័ចាប់ស័ត្តុសេចក្តីកំចាត់ឥ អ្នកដទៃ មិនទាន់ដឹង កំឲ្យដឹង, អ្នកនោះមកអត់កត់នៅវិញ, សូម្បីអ្នកនោះដេរតោលដំរ៉ាយ ហោតុ

ខ្ញុំចង់បែកគំនិតដ៏តដល់អ្នកដទៃហោង ។ បពិត្រមហាភាគ! រឿងអម្បាលម៉ាន
ក៏ដឹងអាថ៌សេចក្តីកំចាំងនៃបុរស, រីអ្នកចាំងអម្បាលនោះ ខំនឹងជាបន្ទើល
បំភិតបំភ័យនៃបុរសនោះ ហេតុនោះហោង រីអ្នកមានប្រាជ្ញ កំមិនគួរ
ស្រដីចេញឲ្យច្បាស់នៃ (គុយ្ហៈ) ក្តីកំចាំងនោះឡើយ, បពិត្រមហាភាគ!
រីអ្នកប្រាជ្ញផង សូម្បីស្រដីសុខុមកំចាំង នាថ្ងៃគប្បីកែកវៀត ស្រដី
សុខុមនាកត្រី កំមិនគប្បីស្រដីពាក្យខ្ចាំងឡើយ ក្រែងអ្នកដទៃខឹងឈ្លោះ
លបស៊ើបសៀបចូលទៅខៀបហើយកំស្តាប់គំនិតនោះជាក់ហើយ រីក្តីកំ-
ចាំងនោះនឹងបែកខ្ញុំយសាយហោង ។

ព្រះចាតុរិទេវភាគ, ស្តាប់ធម៌ទេសនាព្រះមហាសត្វហើយ ស្តេច
មានព្រះហឫទ័យខ្ញល់មហិមា ជន្លួសថា ភាំងខ្ញុំនភជាគោសនឹងអញ
ហើយក៏ត្រូវមហោសថជាតៀនឹងអញវិញ, ស្តេចបន្លួសដូច្នោះហើយ
បង្គាប់ទៅថា ពះគ្នាយើងចាំងឡាយ ទៅចាប់ភាំង ៤ នោះ នាំចេញទៅ
អំពីនគរនេះ (ក្នែង) ដោតក្បាលលើឈើអណ្តែតក្តី ក្នែងកាត់ក្បាលក្តី
ដោយចិត្តក្នែងហោង ។ ឯអ្នកប្រាជ្ញចាំង ៤ នោះ គេចង្រៃតន់ត្រកួត
រួតដើមដៃទៅឯក្រោយ ឲ្យនាំទៅក្នុងដីផ្លូវត្រៃឡែងកែងប្រដែងភាយដំ ដំណាំ
ជាមួយរយដង ។ ទើបចៅមហាសថអ្នកប្រាជ្ញទូលព្រះមហាសត្វត្រាថ
បពិត្រមហាភាគ! រឿងណាដ៏មហាភាគដើមនៃព្រះចាតុរអម្ចាស់នេះ សូម
មានព្រះករុណាអត់ទោសទុកឲ្យណាចាំងនោះហោង ។ ព្រះចាតុរិទេវ.

ពាដបន្ទូលថា តាប់ហោង ។ ស្តេចឲ្យទៅនាំអ្នកច្រាជ្ញទាំង ៤ នោះមក ឲ្យធ្វើជាខ្ញុំតោធិសត្វនោះឯង, ឯតោធិសត្វសោត ពុំយកអាចារ្យទាំង ៤ ជាខ្ញុំឡើយ ថ្វាយឲ្យជាខ្ញុំស្តេចដូចដែលវិញឡើយ ។ ព្រះបាទវិទេហរាជ មានព្រះបន្ទូលថា បើដូច្នោះ តប្បីបំបរបង់កុំបីឲ្យនៅឰដ៏ស្រុកអញនេះឡើយ ។ លៅមហាសេដ្ឋអ្នកច្រាជ្ញទូលព្រះមហាសត្វត្រាធិរាជថា បពិត្រមហារាជ សូមទានព្រះករុណាអត់ទោសអ្នកអន្ធពាលទាំងនោះ ហើយសូមឲ្យសេសសល់អ្នកទាំង ៤ ដូចដើមវិញ ។ ព្រះបាទវិទេហរាជមានព្រះហប្ញទ័យត្រេកអរថ្វាសត្ថវត្រៃឰដ៏តោធិសត្វ ហើយថាវ៉ា ទាំង ៤ នាក់ជាសត្រូវមានប្រការដូច្នោះ ចិត្តវាចំរើនមេត្រីមានសុភាពដូច្នេះ កុំចេញអ្នកដទៃនឹងស្រដីអ្វីឡើយ ។ ចាប់ដើមអំពីនោះ អ្នកច្រាជ្ញទាំង ៤ ដូចគេដកចង្កឹមឥតពិស មិនអាចនឹងស្រដីអ្វីដល់គេបឡើយ ។

ឯ: បញ្ចាបណ្ឌិតប្បញ្ញោ និដ្ឋិតោ ព្រះប្រស្នាទៃអ្នកច្រាជ្ញទាំង ៥ សូរចប់ដោយខ្លួវប្រការទាំងឥម្បាលនេះហោង ។

តតោ បដ្ឋាយ . . . ចាប់ដើមអំពីនោះទៅ ព្រះមហាសេដ្ឋអ្នកច្រាជ្ញ ប្រដៅអាថ៌សេចក្តីលោកិយលោកា ឬ ហោរាដ្ឋព្រះបាទវិទេហរាជនោះហោង ។ ចំណោលដំទៅ តោធិសត្វតែងតែឥតអនាថក្រៃ ទៅកើតភ័យសត្រូវអំពីស្តេចដទៃ គួរបើអញធ្វើឧតន្ទ្រវបន្ទាយឲ្យធំខ្លួលាយ ថ្វាយអម្ចាស់អញហោង ។ តោធិសត្វអ្នកតែងស្រេចហើយធ្វើបន្ទាយធំ

(តីក្ខាវេល្លហាងក្រាស) ហើយអ្នកឲ្យដឹកគូបី គឺ គូទឹក, គូកក់, គូដី-ខ្សាច់ កាច់ខ្ទមផ្ទះចាស់ក្នុងនគរពុកហើយ ឲ្យដឹកស្រះធំបើកទឹកចូលហើយ, រីឯប៉ាងមានកំឡុងក្នុងនគរនោះហើយស្រេច ឲ្យបំពេញទីទៅខ្ទមស្រែវែងវិញ, អ្នកតាបសដំជាដ៏គុន ឃកភួងកុមុទអំព័ប្រទេសហេមពាន្តមកពុក ហើយឲ្យដំរះទឹកស្រះស្រដីកំពង់ឲ្យស្រឡះ រីសាលាចាស់ប្បាស់ជាក់ចែក មានទាលង្វែកគ្រាំបន្ទាយស្រេច ឲ្យតលាំងឡាយប្រជាចំតាក់តែងក្រៃលែងប្រពៃ ។ ពាក្យចំណោទថា តោធិសត្វអ្នកឲ្យធ្វើដូច្នោះហេតុអ្វី ? ពាក្យចម្លើយធ្វើឃើញថា នាអ្នកឲ្យធ្វើដូច្នេះ ប្រយោជន៍ធំធាតោះកើយសត្រូវដ៏អនាគតឯក្នុងមិញ្ញាហោង ។ តោធិសត្វ ព្រះអង្គដល្បីឈ្មោះញ្ញាផងដែលមកអំព័ហានោះស្រែកចំតោះថាអ្នកតាំងឡាយមកអំព័ហានឯណា ពាក្យឈ្មោះញ្ញាថា យើងខ្ញុំមកព័ហានោះដូច្នោះ, តោធិសត្វអ្នកដឹងដូច្នោះហើយ អ្នកឲ្យរង្វាន់ឈ្មោះញ្ញាអស់តាំងនោះ តាមដោយទូវប្រពៃណា ទើបឲ្យដំណើរទៅហោង, តោធិសត្វអ្នកឲ្យហៅយោធាអ្នកឯងបានមួយរយទើងមួយមកថា ម្នាលយោធាតែងតាំងឡាយ យកគ្រឿងបណ្ណាការអំណោយអញានោះ ទៅដោយភាជនីស្តេចមួយរយទើងមួយ ហើយតែងយកបណ្ណាការនេះ ថ្វាយស្តេចផងនោះដោយចំតោះអាត្មាឯងនីមែន ។ ហើយ តែងបំរើស្តាម័ត្តិស្តេចនោះ តែងឆ្ពោះគណនាមើលមើលកិច្ចការក្តី តំនែងដំរះស្តេចតាំងនោះ

ហើយ តែងប្រើមកត្រមានអញ ឯតែងឯងនៅនោះហោង, ដាអញ
ទិដ្ឋចំភ្លឺមកក្អកញាប់ចាលកូនប្រពន្ធតែងតាំងឡាយហោង ។ ទើបពោធិ
សត្វរៀបបណ្តាឲ្យអស់យោធាតាំងឡាយ យោធាខ្លះ ពោធិសត្វឲ្យព្រះ
ភាន់, ខ្លះឲ្យព្រះសុវណ្ណមាលា, ខ្លះឲ្យក្ងែមាស, ខ្លះឲ្យកុណ្ឌល, ខ្លះឲ្យ
សុតណាជពុក ហើយពោធិសត្វអ្នកសរសេរជាអក្សរខ្លះអស់បណ្តាការ
ហើយពោធិសត្វអធិដ្ឋានផ្សងថា បើអញមានហេតុកិច្ចការអ្វី ។ កាល
ឯណារអក្សរផងចូរឲ្យឃល់ច្រាកដកាលនោះហោង ហើយឲ្យអស់គ្រឿង
តាំងនោះខុកនៅដៃនៃយោធាតាំងនោះ ឲ្យដំណើរទៅហោង ។ រី-
យោធាផងតាំងឡាយនោះ ទៅដោយហានោះហើយ យកគ្រឿង
បណ្ណាការទៅថ្វាយស្តេចនោះហោង ស្តេចតាំងនោះដណ្តឹងថា តែងមក
ប្រាថ្នាអ្វី? យោធាផងថា យើងខ្ញុំមកប្រយោជន៍ទីដំរើស្វាមីភ័ក្តិព្រះបាទ
អម្ចាស់ហោង ។ ស្តេចដណ្តឹងថា តែងមកអំពីឯណា ? យោធាមិន
ថាអំពីហានៅនោះឡើយ ធ្វើយប្រាប់ថាហានឯទៀតវិញ ស្តេចតាំងនោះ
ទទួលថា គួរគប្បីតែងដំរើរហោង ។ រីអស់យោធាតាំងនោះ សឹងបាន
ជាអ្នកដំរើរអស់ហោង ។

កាលនោះ, មានស្តេច ១ អង្គ ទ្រង់ព្រះនាមព្រះបាទសំខលកជ
នៅឰដ៏ស្រុកកម្ពលវដ្ឋនោះ កំទ្បបបួលមូលចូលដុំសេនាយោធា ផ្តុំឲ្យ
សម្ងាចគ្រឿងអាវុធ, ឯទេពនិកូត្តបុរសដែលពោធិសត្វឲ្យទៅនៅផង យល់

ស្តេចធ្វើខ្លួនអំពើនោះមិញ កំប្រើតតែមានមកតាន់តោងសត្វថា រឹតតែមាន
នោះ មានឮដំស្រែកនេះ ស្តេចធ្វើអំពើនេះ យើងខ្ញុំមិនដឹងជាស្តេចធ្វើអំ-
ពើនោះម្តេច ចូរទៅអ្នកច្រោដប្រើតតែមានឯង កំយើងដឹងច្បាស់ហោង ។
លំដាប់នោះ, តោងសត្វអ្នកស្រែដឹងថាសេកសុវបណ្ណិតថា ម្នាលសុវបណ្ណិត
មិត្តសំឡាញ់អើយ! ព្រះស្តេងទៅទ្បែចាន់ដឹងស្តេច១អង្គ ឈ្មោះសំខាត-
កាជ នៅឮដំស្រែកតម្ពលរដ្ឋ ដូចតែស្តេចនោះ ភ្លុំខ្លួវយោធាសេនាតហាន
ស្តេចមានបើទៅឯណា ហើយព្រះស្តេងហ៊ីរទៅឮដំសកលជម្ពូទ្វីប ហើយ
ព្រះស្តេងយកពតតែមានមកច្រាប់អញ្ជើហោង, តោងសត្វផ្តាំសេកនោះហើយ
ទ្បែសុវបណ្ណិតនោះធ្វើសាច់ប្រឡាក់ធំងំតយ៉ាំ ហើយទ្បែផឹកងំតផ្អែម ហើយ
លាបឮដំលង្អែកចំអេងស្តាបខ្លួវប្រែងពាំដោះដំអប់មួយរយដង មួយភាន់
ដង ហើយដាក់លើបង្ហិចឯកើតលែងទៅហោង ។ រីសេកសោមបណ្ណិត
នោះសោត លោតហ៊ីរទៅសំដៅហានតម្ពលរដ្ឋ ដំងំសេចក្តីពតតែមានស្តេច
នោះច្បាស់អំពីសេនារបស់ស្តេចនោះ ហើយហ៊ីរទៅអស់ពាំងសកល
ជម្ពូទ្វីបតុំមានហេតុអ្វីឡើយ ហើយទៅដល់ខត្តរបញ្ជាលខត្ត មានឮដំ
កប្បិលរដ្ឋ ។ កាលនោះ, ព្រះចាខបុលទ្រង់ត្រហ្មខត្តកាជ សោយរាជ្យ
នៅឮដំខត្តនោះ, រីរាជគ្រូកេរដ្ឋព្រាហ្មណ៍នោះមានច្រាជ្ញាឈ្លាស តែង
ប្រដៅអាចិធមិអាថ៌សេចក្តីដល់ស្តេចបុលទ្រង់នោះហោង ។ រាជគ្រូនោះ
ភ្ញាក់ឆោះទ្បើងកាលដាស់ខ្ញុំ មកអំលះអំលួកក្តីលែងដំណោកដំមានសិរី

សួស្តី តតដ៏អ្នកប្រដាប់ប្រពៃនៃអាត្មាឯង ខ្ញុំតែងប្រទំបថ្វាយយសអាត្មានោះដំណត្តមរឿងរឿងថ្លែង ក៏រំពឹងថា យសសម្បត្តិអញជាទ្រព្យសំបត់អ្នកឯណា? រំពឹងដូច្នោះហើយថា នាយសសម្បត្តិនេះ មិនជាទ្រព្យសំបត់អ្នកឯណាដទៃឡើយ ជាទ្រព្យសំបត់ព្រះបាទបុលទីព្រហ្មទត្តជាហោង, ដូច្នោះគួរអញនឹងណាប់ស្តេចជាអ្នកឲ្យយសអញ។ ធ្វើឲ្យប្រសើរក្រៃដ៏សកលជម្ពូទ្វីបនេះគួរ ហើយអញនឹងជាបុពេហិតាចារ្យប្រសើរសោតហោង។ រំពឹងដូច្នោះហើយ ក៏ទៅគាល់ព្រះមហាសត្វគ្រាធ្លាប់អំពីព្រហ្មទូលថា ព្រះបាទអម្ចាស់ផ្ទួសប្បាយឬទេ? ហើយទូលថា បពិត្រមហាភទ្រនិងតមិនតប្បីយើងខ្ញុំតតឡើយ ស្តេចបន្ទូលថាអើ! អាចារ្យសំដែងថ្លែងទៅហោង, ភជគ្រូកេវដ្តព្រាហ្មណ៍ទូលថា បពិត្រមហាភជ នាបីហៅថាហានស្ងាត់ក៏នឹងមានឮដ៏ក្នុងនគរនេះ ឥតអង្គីមាន មកយើងខ្ញុំទៅទទ្បានក៏បានហានស្ងាត់។ ព្រះបាទបុលទីថាគាប់ហោង ស្តេចទៅនាទទ្បានទ្វារភជគ្រូកេវដ្តព្រាហ្មណ៍នោះ ជាត់អស់អម្បាលយោធាសេនាផងនៅឯក្រោយ ហើយស្តេចចូលទៅនឹងអាចារ្យកេវដ្តព្រាហ្មណ៍ឯងទៅតង់លើថ្មសិលាបិដ្ឋ។ រីសេកសុវបណ្ឌិតមិញ ឃើញអំពើស្តេចនឹងអាចារ្យកេវដ្តព្រាហ្មណ៍នោះ ហើយគិតថា សូមឲ្យមានការឮដ៏ស្តេចនោះហោង មិនទេឡើយ, ឥឡូវនេះ អញស្តាប់សព្ទឬទ្ធិចមើលហ៊ឺ! នេះសមគាត់ជាអ្នកប្រាជ្ញហោង។

(នៅមានត)

ការរលាយនៃកន្ទែនដ៏

និង

កើតជាថ្មីសារធ្បើងវិញ

ភាគ្យភាគ្យ

លោក ញ្ជង់.សៀង ឥពន្ធ

បានទទួល

វន្ទាន់លើកទឹកចិត្ត

ផ្នែកការិនីពន្ធ ក្នុងការប្រឡងអក្សរសាស្ត្រ

របស់សមាគមអ្នកពិពន្ធខ្មែរ នៅឆ្នាំ ១៩៦១

សេចក្តីផ្តើម

ភាគ្យ ៧

ខ្ញុំសូមលើកហត្ថាត់ប្រណម្យ ឆ្ពោះព្រះបរមចមកតម្រៃ

ទ្រនំសាងសម្ភារបួនអសង្ខ្យេយ្យ កម្រៃសល់សែនកែលុកលុយ ។

ដើម្បីលើកសួយដួយយោងសត្វ ដែលកើតរៀបត្តិកាត់ភ្ជាំងគ្នា

ឡើងជាន់ត្រើយកើយព្រះមហា- និក្ខាន្តសុខាថ្លាឯកន្ត[1] ។

បង្គំព្រះធម៌ថ្លាវិសុទ្ធ វិសេសបំផុតដូតមោហន្ធ

១– ឃ៉ាងក្រៃលែង, ណាស់, បំផុត ។

អរិដ្ឋាកំលេសទីឆ៍កឆ៍ត- ណ្ហាដែលតិក្ខត្តិន្ទ្រិយសត្វលោក ។
ឥឡូវព្រួយសាបសូន្យអូនគាប់អស់ រលាយលេស់លើឆ៍គោក
ពុកដូចប្រទីបក្នុងត្រៃលោក ដែលព្រះមានជោគយោគ(១)សំដែង ។
បន្ទំព្រះសង្ឃអង្គសាវ័ក ស័លសេយ្យអន្ទង្គ(២)ឥតថ្នឹងថ្លែង
ឧរសៃគោតមទំនុះស្មែង ប្រឹតប្រឿងប្រឹងប្រែងតែងស្មឹងស្មាធ៍ ។
រឿនសូត្រធម៌អាថ៌អត្ថបាលី បរិលោកលោកយាមឧត្តម
ពុកជាស្រែបុណ្យមានគុណស្អាត នៃអ្នកសង្វាតដឿកម្មផល ។
ដោយគុណគេជះព្រះត្រ័យរ័ត្ន សូមយាត់ទុបទ្រូតមេរំបល់
ទុក្ខសោកពេគភ័យក្តីកង្វល់ សូមលាញ្ជឥតសល់កុំបីខាន ។
សូមឲ្យក្តក់ក្តើងដើងសង្គ្រាម ពួកមេទុក្ខមកម្បាលម៉ាន
លែតរលាយពាយសត្វហាន សាកលលោកបានស្រស់សួស្តី !
តទៅសូមថ្ងៃឆ៍ចំរើយ ដោះស្រាយជាថៃបសង្ខ័បខ្ចី
ពីការលាយតតែផែនដី ហើយកើតជាថ្មីសាឡើងវិត ។
ឆ៍ដើមកំណើតកកើតមនុស្ស ជាកេនស្រីប្រុសពេញបន្ទុំត
សម្បុរគួចធំក្នុងប្រចៀត ស្តឹមស្តែសិតសៀតជ្រៀតដីផែន ។
ឈើព្រៃត្រឹកស្រុលតាវល្លី ពាបខ្ពស់គ្រប់ពិណិតាសពេញលែន
ពាំឆ៍គ្រប់ធម្មជាតជាតុកប់សែន ចំរើនកើនកែណ្តាដល់សត្វថ្លៃ ។

១- ព្យាយាម, ទំនង ។ ២- ដែលពាត់ថ្ងៃមិនបាន,ប្រសើរខ្ពង់ខ្ពស់ ។

ថ្លែងតាមជាលីអដ្ឋកថា(១) ភាគព្រះសាសនាដ៏ថ្លាថ្លៃ
ដែលព្រះសោតាដសេ្តចចមកគ្រែ ទ្រង់គ្រាស់តែងសំដែងមក ។
ហើយដែលសាវ័កថ្លាក់អរហន្ត ជាន់ក្រោយតតិតន់គ្នេរលែងក
តាំងតស្សាវជ្រាវរកវិនិច្ឆ័យ បន្តែមយោលយកមកពន្យល់ ។
រឿងនេះប្រសិនបើមានល្អៀង លើសខ្វះមិនទៀងតាមឫសគល់
បណ្ឌិតអង់អាចជ្រាជ្រួតជ្រែក សូមយល់ថាមកពីពុទ្ធជួន ។
ព្រោះពាក្យកាត្យឃ្លោងយោងតំនុក ជាក់ខ្សាច់ក្រោយមុខពុកប្រជួន
ប្រជុំយកត្រូវតម្រូវក្សួន(២) ឮយ៉ាំ ! កម៌ដួងតាំងជាតសៃ ។
អ្នាំរហើយគេងសែមថែមឃ្លាល្បះ យោបល់ខ្លួនខ្វះរះចំក្លៃ
បំផ្លើសបំភ្លាត់ពាត់កែន័យ រាវសម្រួលឲ្យស្រួលស្តាប់ ។
មួយទៀតជើងកាត្យបើតក់ធ្លង មិនត្រូវតំនងរង់សូរសព្ទ
ដោយខ្សាច់ឆក់យារឃ្លាជួនចាប់ ខុសច្បាប់តាក្យកាត្យកំណាត្យខ្លះ ។
ខ្ញុំសូមបណ្ឌិតពិតកវី ចាំងជាន់ចាស់ថ្មីស្ថាត់កាត្យដែរ
សូមជួយរិះគន់កុំគ្រញាំគ្នែរ តម្រង់ចំដែរកែឲ្យទាន ។

១- អត្ថញ្ញាសូត្រ (សុត្តន្តបិដកភាគ ១៨. ទីឃនិកាយ ជាដំណាវគ្គ) ព្រមទាំងអដ្ឋកថា ។ សត្តសុរិយសូត្រ (សុត្តន្តបិដកភាគ ៤៣. អង្គុត្តរនិកាយ សត្តកនិបាត) ព្រមទាំងអដ្ឋកថា ។ វិសុទ្ធិមគ្គ អភិញ្ញានិទ្ទេស ។ ២- ...ក្សួន... ក្នុងទីនេះ សំដៅយកពម្លីជាលីដែលនិយាយតំ-រឿងតិភពលោក. មិនមែនសំដៅយកក្សួនកាត្យទេ ។

ប៉ុន្តែរឿងនេះគេយល់ឯណា ខ្ញុំនឹកស្មានថាគង់នឹងមាន
សារៈប្រយោជន៍ខ្លះតុំមាន ដល់លោកអ្នកអានបានតិចតួ ។
ដែលមានប្រាជ្ញាថ្លាវៃឆ្លាត ចូលចិត្តសង្កាតរកការពិត
គ្រាន់បានជាគោលយោលគំនិត គៃតិតប្រៀបធៀបក្នុងលោកិយ ។

ការរលាយនៃពិភពលោក

ឆ្នើមរឿងសត្រូវបំផ្លាញលោក តាមបទប្រយោគក្នុងបាលី
អ្នកប្រាជ្ញបុកណាគិតានស្តី ថាមែនមានមតិតដូច្នេះ ។
តែមួយតឹកសន្ធឹកលិច តែក្តីបំផ្ទិចបំផ្លាញនេះ
ប៊ីឡាល់កំហល់បក់ប្រឡេះ ប្រល័យជាផេះគ្មានសេសសល់ ។
តែមានកប្បខ្លះនេះដោយភ្លើង កប្បខ្លះលើងទៅដោយខ្យល់
កប្បខ្លះដោយទឹកតន្ត្រីកខ្លាល់ មិនមែនច្របល់ត្រួតគាំងប៊ី ។
កប្បណាសត្វសត្វជាប់ចិត្តឈ្លក់ ញៀនញាំមជ្ឈគជ់កំរៃប្រុសស្រី
កាមភគ្លាំងចាំងស្មារតី កប្បនោះតប្បីនេះដោយភ្លើង ។
កប្បណាគោរសោដុះដាលភ្លាំង កាប់ចាក់ប្រហាំងតាំងពើតតើង
ស្តាប់គ្នាលែងបានតាំងគេរើង កប្បនោះរលើងដោយទឹកតិត(១) ។
កប្បណាមោហោសោសែនសល់ វិនាសឆាំងឆាំងសល់សល់ចរិត

១- អ្នកប្រាជ្ញបុកណាខ្លះយល់ថា: កប្បណាដែលមនុស្សលោកមានទោសៈភ្លាំង ត្រូវដេះដោយភ្លើង ។ ដែលមានភគៈភ្លាំងត្រូវសោយដោយទឹក ។

ក័ប្បនោះអ្នកប្រាជ្ញបានពិនិត្យ ថាសូន្យដោយឫទ្ធិនៃឱសថ ។
តែកន្លែងនេះគឺជាទីឱសថ ដែលនាំកង្វល់ផលភ្លៅភ្នំ
ពុកមួយចំណែកចែកខាងទាំង សូមតាំងគិតតែតែពីក្មេង ។
ឧលោកអ្នកអើយចូរប្រុងស្តាប់ កាលក្មេងនេះក័ប្បមុនក័ប្បយើង
កតញ្ញលោកតាំងបីត្រូវរលើង ដោយក្មេងប្រលំយកឫទ្ធិសល់ ។
លោកថានៅខ្លះមួយសែនឆ្នាំ ឱនកើតវង្សកម្មកោលាហល
កាលណោះខេត្តផ្ទៃលរចល់ ខ្លាយខ្លួលសាស័ក្តប្រាប់ឱ្យដឹង ។
ដំបូងសម្តេចព្រះកោសិយ ទ្រង់ជ្រាបសេចក្តីពីរឿងហ្នឹង
កំព្រួយថាអម្ចាស់ជញ្ជឹង ទើបដាក់ប្រៃប្រឹងប្រកាសហៅ ។
ពួកខេពនិករាំងអស់គ្នា ក្នុងហានសួតាំងក្នុងក្រៅ
ឲ្យមកប្រញាប់ឆាប់គាល់ហ្អើ ដើម្បីចមចៅទ្រង់ចាត់ការ ។
គ្រានោះខេវះលោក ៦ ជាន់ ខេត្តផ្ទៃលលាន់ក័ន្តខៀវភ្លារ
ខ្លួលស្រមតាមព្រះឧណ្ហារ ទើបនាំចរាវថ្ងាយប្រញាប់ ។
ក្នុងខេវះសាចន្លើតណែន ខេត្តម៉ឺនសែនម៉ឺរាន់តាប់
អ្នកមានបុណ្យស័ក្តិថាត់ស់ដាប់ ប្រញាប់រួសរាន់ចាន់វេលា ។
ស្រីខេពអប្សរបវរឆើត ដំណើរតើតស្អើតមាយា
ញឹកញាក់ញ៉ាញ៉ាញើបណ្តើរគ្នា ខ្លះខំស្ទុះស្ទារតំណាក់ខ្លួន ។
ខ្លះដើរតើតឆើតនៅខាងក្រៅ ខ្លះលឿនស្ទុះស្ទារកកំខ្លួន

ខ្ញុះចូលប្រមៀតជ្រៀតគេឯង ញាញីមចាត់ចែងខ្លួលក្បៀវ ។
ខេវបុត្រដើងចិលអើលមាត់ សំដីក្មួយក្មាត់តិខ្ចីបរឿរ
ថានាងខ្ញុះអេះចង្កេះរៀវ បំរះសាច់អញស្រែវញាក់ដល់ឆ្នើម ។
មួយថាស្អីខ្ញុះនៅក្រោយអញ ក្រអូបឈ្មួយធ្វាញ់យ៉ាងសម្បើម
អញស្ទើរស្រយុតផុតដង្ហើម ខេះចំណ្តើមក្តងត្រែត្រីង្វ ។
មួយខែតធ្វែតធ្វើយយ៉ាងប្រញាប់ អាចារគេកាប់ស្ទាប់មិនដឹង
របស់គេខេមេម្នាក់ហ្នឹង ប្រយ័ត្នគេប្តឹងលៀនក្បែកក្តែ ។
ខ្ញុះន៍ៈឯណោះមានមួយក្រុម សុទ្ធសឹងក្រមុំទឹងសាវែក
ពងាបកន្ត្រែតស្មែតមាន់ចែក ក្បែកជាលតែវ៉ែក្រឡែកសព្វ ។
មើលចុះនាងខ្ញុះបើបានបួប និយាយមួយខួបមិនចេះចប់
ចំប៉ាំចំប៉ីចាំចោចវ៉ៃតប់ មិនឆាយស្តាប់ស្តួចតីរឿងខ្ញុង ។
កេះហើយកេះខែតធ្វែតមិនឈប់ តាំងថ្ងៃតាំងយប់រង្វេងស៊ីង
ប្រតងប្រគាក់ក្នាក់ក្នាយមុង អាឆុង(១)ចង់បានអញតែតឲ្យ ។
– ខេ-ខេ! ខ្លួនអញមិនបួលដៃ អាចារចង្រៃកុំដង្ហើយ
បើសិនជានាងនៅខាងក្រោយ ឯងជួយតែតឲ្យអញអានុគ្រោ ។
– យី! អាងងើលត្រើលតកថ្ងាស កុំមាត់ផ្តេសផ្តាសឲ្យស៊ីយស៊ុន

---

១ ខេវបុត្រម្នាក់ ហៅជាឧកនរបស់ខ្លួនដែលមានតួនាទីលក្ខន្តិកៈធំជាងគេ ហើយដែលនៅស្រុកក្រៅឡាយតិចក្រុង ។

អញ្ជើញបានជ្រាប់ហើយតាំងពីមុន កុំលេងចូលហ៊ុនស្រីញីគេ ។
ប្រយ័ត្នគេទីឆ្ងីឆ្ងល់ព្រះវន្ទ ព្រះអង្គនឹងកំនមុខដួចគេ
តាំងការដោះស្រាយមិនងាយទេ រិះរេមិនរួចក្លួចកើតហេតុ ។
គ្រានោះទេពធីតាកញ្ញាឆើត ក្រោកឈរចំអើតស្តីប្រែត ។
ប្រុសក្សាលកំផ្លូចខ្លួចដួចប្រែត ភ្នែកស្មែតមុខស្ងាំងខ្ចាំងអប្រិយ ។
ចូលចិត្តចំអកឡកក្អាកក្អាយ ម៉ិតជ្រុយកុបតិនបុំនសំដី
កេះកៀតតែតែតឿនស្រី ស្អប់អីសែនស្អប់ប្រុសបែបហ្នឹង ។
– ឮយាំតែចស្អប់ប្រុសបំចូល ស្រីស្រស់បណ្តូលតួចច្រឡឹង
បងឡកលេងទេតាក្សប៉ុណ្ណឹង កុំអាលខេះខឹងប្រឹងត្រួតស្អប់ ។
ខេវតានឹងមនុស្សក្នុងលោកិយ រឿងប្រុសនឹងស្រីមិនចេះចប់
កាប់ចាក់ប្រដាំងច្បាំងវាយតប់ ព្រោះតែកំណាច់មួយហ្នឹងហើយ ។
បើនាងរអើមខ្ពើមមុខបង ខ្លួនល្អងជំងឺអ្វីស្រីគ្រាណាត្រើយ
ដៃលទាងតេញចិត្តកិតកៀកតើយ ជ្រាប់ចុះនាងអើយកងបែបណា ។
– ខ្ញុំកប្រុសល្អសត្រប់លក្ខណ៍ វង់តក្តែផ្លូវធនឹងឆ្ងល់សង្ឃា
សមរំដាំងរូបឫកកិរិយា សោតដាំងវាចាកំសោះក្សាយ ។
កុំក្សាលកំផ្លូចដួចបងឯង កួតតរហុយផ្សែងក្តែងថែមក្សាយ
រូបកងក្រងិតក្តិតឆ្មាំងជ្រុយ មុខមុនសុះសាយចង្កាខ្ចី ។
កងវៀមើលទៅធំតន្ត្រូល ដើងស្លុកស្លាកលេដូចដំរី

បែបនេះប៉ែកុតជាខ្វះប្តី ស្រស់ស្រីសុំសួរថអត់ហូត ។
- អ្ញុំខ្ញុះមែន ។ ម៉េចអាជុង កុំលេងទាន់ខ្ញុំមិនមែនស្លូត
អញ្ជាថាត្រង់ហ្នឹងកុំប្រឹងស្រួត អញ្ជាញាចង្អុតអាមិនស្តាប់ ។
ទាល់តែគេទឹងប្រឹងប្រកាស ស្តីឡែផ្តេសផ្តាសឱ្យសុខយ៉ាប់
ល្អម្ខាណាស់អីស្រីបង្អាប់ អាចារគេកាប់តែចាក់ថែម ។
មិនបានខ្លៅស្រែតាតែង្វរ នរណាមិនដឹងឃើញមាត់ក្រែម
ញញឹមតប្រាយលាយញាក្បែម តែចលោចដំក្បែមមុខជាខក ។
អាឯងខ្លៅតានៅស្រុកស្រែ សម្បុរអោបខ្មៅសៅសកញឹក
ល្ងីល្ងើភ្លឺកើចដំឡឺយឡក ប្រយ័ត្នស្រីត្បូកក្រែងធកក្បាល ។
ខុកជាគ្រាន់ហើយដៀលប៉ុណ្ណឹង បើសិនគេប្តឹងតឹងជាលក់ល
ព្រះវន្តុកោះហៅខៅកណ្តាល- ជំនុំផ្តាញ់ផ្តាលតែធ្វន់ខ្លៀត ។
អញ្ជើងអ្នកក្រុងឥតភ័យសោះ ឮថាប់ស្គាល់កៀនកោះសព្វកន្លៀត
តែមានរឿងធំតែបាលបៀត ប្រុះជ្រៀតគេចបាត់ស្ងាត់ឥឡូវ ។
ចំណែកអាឯងនៅម្ខ័ងអាក់ ពក្លៀពក្លាក់កើតអាស្រូវ
តាមតើមដូចចោរគេស្តុកផ្លូវ តង់ត្រូវគេយាត់ត្នោចាប់ត្រីប ។
ម៉្លេះសមល្អមើលមុខអាជុង ហាមាត់ចង្រ្កង់បុកតោះតឹប
គេចាមចាប់ចងចំណងរឹប តួយក្តាមតឹប ។ ជ្រុះជ្នាក់ឃយ ។

ចំអន់លេងខេអាតួកមាំក ត្រោះអញ្ចេចដំសាកលក្លែងក្លាយ
តាន្ធើសតខ្លួតកួតបរិយាយ ឲ្យបានសប្បាយកែអង្គុក ។
-ខ្មោចអាគេជោគបញ្ឆោតអញ ញ៉ែរហាក់គ្រុនចាញ់ពោះបំផុក
ភ័យតឹតដិតងាប់ស្រេចាប់មុខ កើតខ្លុកខ្លានតឹងរឹងចំបែង ។
អួតអាងដើងខ្លួនទៅស្រុកក្រុង ស្គាល់ល្បិចគ្រៅក្នុងប្រុងស្មៀតខែង
មកកួតតែអញថ្នាញ់ជាល្បែង អាឯងតិចជាក់ចំបាក់ស្មា ។
រឿងនេះបរិយាយបន្ទាយហួស ដោយខ្ញុំជ្រលួសចុងចំការ
រវៃខ្លាយខ្លះតិចតួច ដើរលេងហ៊ឺហាទៅត្រែត្រឹង្ស ។
សូមលោកអ្នកអានគ្រប់ជាន់ថ្នាក់ ដែលមានចិត្តស្ម័គ្រមើលរឿងហ្នឹង
កុំគាលមួមៅក្តៅខេរខឹង សូមប្រឹងសង្កត់អត់ទោសផង ។
ខ្ញុំសូមបៃតែមកតែដើមដាន ខេត្តគ្រប់ប្រាណតតង្រៃផ្សែង
នាំគ្នាបួបជុំដុំអឺងកង ច្រើនកៃក្រែកខ្លួងមីរតាន់តាប់ ។
រងាំចាំខ្លួលព្រះកាសិយ ខ្លែងថ្លែងសេចក្តីប្រកាសប្រាប់
ដោយមានបញ្ញត្តិចាត់ចេញប្បាប់ ប្រញាប់ដូរតែងរុំរែងយ៉ាងណា ។
គ្រានោះសម្តេចព្រះខេវកដ ខ្លែងឮខ្ញុំអំណាចអាចហានក្លា
មានស្រើអប្បរេខតកញ្ញា ខ្លែងឃាតបួលតាន់ខែនមណ្ឌល ខ្លែងតាយខ្លែងមិលស្រស់បញ្ចង់
តឿរក្រាគខ្លួលជ្រលែងហង់ តោរតង់ដល់អង្គព្រះបេស្តា ។

សម្តេចខេរិន្ទូវង្ឌឯកអគ្គ គង់រួចជៀងជាក់ខេបត្រាស់ថា
ហៃអស់កូនចៅដៅខេត្តា ដែលមកត្រៀបត្រាចាំឯប៉ុន្មាន ។
យើងហៅមកនេះមានរឿងមួយ នាំព្រួយស្តេរប្រេះលេះក្រាណា
ពោះទំប្រឹងប្រែកែកំសាន្ត ម្តេចកំពុងបានធូរស្បើយសោះ ។
ចូរអ្នកចាំឯឡាយចាំប្រុងស្តាប់ យើងនឹងសាស័ត្តុត្រាប់ឲ្យស្មោះ
គឺរឿងកតញ្ញូលោកខ្លួលគ្រោះ សូន្យសោះគ្រោះអស់អាយុកប្ប ។
នៅភ្នំមួយសែនផ្ទាំក្រាកដ កំណាត់កពប៉កសិអាប់
ត្រូវភ្លើងប្រលំយក្សយក្សក្រឡាប់ មនុស្សសត្វនឹងស្លាប់ចាំងសាកល ។
តាំងពីមនុស្សលោកយោកខេត្តា កូនធកាមាខ្លួចផតសល់
ធៀតធាថាបានេះប្រឡេះដល់ ព្រហ្មលោកមណ្ឌលខ្ពស់កន្ទួង ។
ជួនេះចូរអ្នកចាំងអស់គ្នា តាំងចិត្តល្អជាថ្នាម៉ត់ម៉ង
សិក្រាំពុកព្រួយជួយចម្ងួង ច្រាប់មនុស្សសត្វផងកន្លះលោកិយ ។
ឲ្យទំស្មើនឹងសំអាតចិត្ត សម្រឹតសម្រាំងតាំងស្មារតី
ធ្វើបុណ្យឲ្យទានមានមេត្រី គ្រប់រូបប្រុសស្រីកុំបីឃ្លាត ។
ចំណែកតួកយើងជាខេត្តា កំចូរកេរ្តិ៍ឯកមានយោង
កុំឲ្យតត្រើមដ្រើមហួសមាន ចូរទំនឹងឃ្នាតសាងសុចរិត ។
ណ្តើយចុះវង្សត្រែវនាំគ្នា ម៉ែម៉ាលៃថ្ងានៅឋានបិត
ដល់ហើយរៀបចំទំដួងចិត្ត ប្រត្រឹត្តចងចាំបណ្តាហ្ន៎ង ។

គ្រានោះខេត្តាតាំងសែនទាក់ ស្តាប់ដាក់ស្រុះស្រួលខ្លួលឆឹង
បង្គំរាជាលាវិលវឹង សញ្ជឹងសញ្ជប់ជ្រប់តគ្រា ។
ក្នុងក្តើងនេះតិប្បស្រាប់តែត្រួយ ផុតផ្តើលរត្នាយឆកាមា
សន្ធៃសន្ធឹកនឹកអនិច្ច ស្ងួនស្ងុតអាត្មាមុខក្រៀមក្រំ ។
ដល់ហានវិមានរៀងខ្លួនហ៊ាយ តាំរៅកន្តើយតួនសម្ងំ
ញាប់ដើងញាប់ដៃលែបង្គុំ រៀបចំដំណើរដើរច្រកយច្រាប់ ។
រីឯកេត្តាតាំងនោះឯង កាឡាខ្លួនក្លែងគេចអន់អាប់
រូបសាកបំត្រាកយ៉ាកយ៉ឺនយ៉ាប់ សេ្ងកតាក់ប្រដាប់ប្រហមផ្តៅ ។
សក់វែងសំយាកធ្លាក់ហួសស្មា រង្វង់តគ្រាតាំមង់សៅ
ខន្ធឹះខ្សឹកខ្សួលអួលមួមៅ ក្នុងច្រាណហាក់ស្តៅស្ទើរលួយ ។
ដៃដួតទឹកភ្នែកយំបណ្តើរ យីតយាវដំណើរពងមួយ ។
បញ្ឆាក់កិរិយាអាការត្រួយ ខិតខំប្រឹងដួយយកអាសា ។
ចរច្រប់សត្វហានក្នុងមនុស្សលោក ពោះទីទឹកគោកតែខ្លួនណា
តេលនោះគេយើញតែខេត្តា ក្លែងក្លាយកាយាយាំងនេះឯង ។
ដំបូងតួកមនុស្សតាំងក្នេងថាស់ យើញភ្លាមខ្លាចណាស់ត្រីសូម្បីស្លែង
ស្ងួនស្ងោគោខ្លោតត់ខ្លាតខ្លែង ច្រាប់គ្នាឯងថាខ្លោចលង ។
ខ្លះភ័យខ្លួតត់តោលផ្លះ អ្នកខ្លះអឺអ៊ះចង់សំតង
ខ្លះចាញ់យាំអាខ្លោចលង តួយតិតភម្ពង់ឡដ៏ឆ្ងៃ ។

ខ្លះថាខេ ។ កុំលេងរ៉ូ មិនដឹងសត្វអីគួរសង្ស័យ
ខោអាវស៊ុបយុលយុវរវៃ ចូលស្រុកតាំងចិត្តគេលេងហ្នឹង ។
គ្រានោះខេត្តាចែងសាស័ក្ត រួសពន់ប្រញាប់ប្រាប់ឲ្យដឹង
នែអ្នកតាំងឡាយកុំខេវខឹង កុំតិយៈស្មោសូមប្រទីងតែប្លាត់ ។
ខ្លួនយើងនេះជាខេតបំរើ ព្រះឥន្ទបាត់ប្រើតាមសង្កាត់
ឲ្យចុះមកដួយសួយយោងសត្វ ប្រាប់រឿងវិបត្តិកន្លងលោកិយ ។
ឥឡូវចៅអ្នកចាំប្រុងស្តាប់ យើងទឹងកិយកាប់ប្រាប់សេចក្តី
ឲ្យដឹងដើមដានតាំងប្រុសស្រី ដរាតអំលោកនេះត្រូវវិនាស ។
នៅខ្លះមួយសែនឆ្នាំខ្មែរខេ តាំងយើងតាំងគេនឹងនឹកស
ដោយភ្លើងនេះកប្បស្វាច់ពេញ៣ស ពោះឈ្មោសដូចម្តេចគេចមិនបាន ។
សូម្បីពោះតាំងមហាសមុទ្រ ធំជ្រៅបំផុតពីបុកណា
គង់ត្រូវរីងហួតស្ងួតតុំភាន បពិតប៉ុន្មានក៏រលាយ ។
ដំបូងផ្តើមឆេះហានមនុស្ស ធាបដល់ខេត្តាស្វាប់តោយ
រហូតត្រហ្មលោកយោកចំលាយ នេះឆ្លាយទល់ទីឆកសួ្រក ។
ដូច្នេះអស់អ្នកតាំងឡាយអើយ ចូរកុំកន្តើយត្រូវខុសឆ្គាំ
ធ្វើបុណ្យចែកទានមានមេត្តា កប់រកគ្នាជាដរាប ។
ត្រូវតែមានចៀសកងអកុសល ដែលតែងឲ្យផលផ្តល់ទុក្ខវិបាប
គឺកម្មនាក្រត់ល្អក់ឆ្អែះឆ្អាប កុំឲ្យដិតជាប់ជាមដល់ខ្លួន ។

ជូរទំប៉ំរើមាតាបិតា ដោយចិត្តជ្រះថ្លាយ៉ាងខ្លាំងក្លា
គោរពថាស់ពុំឲ្យម៉ាមួន ប្រព្រឹត្តសមសួនតាមលំដាប់ ។
ពេលនោះរើមនុស្សពាំងប្រុសស្រី ឮនូវសំដីខេត្តក្រាប់
អំពីរឿងក្តៅរំលើងកំប្យ សត្វលោកទាំងស្លាប់ឥតសែសសល់ ។
នាំគ្នាកើតទុក្ខមុខស្រងូត គាំងចិត្តល្អស្លូតស្រូតក្លាយទ្រូល
សទ្ធាកសាងស្ថាងមគ្គផល ដំកល់ចិត្តខ្ជួនតាមឧត្តរ ។
លុះដល់ពេលស្លាប់ចាប់កតង្គ តាមលោកស្រដីកុងកុសួនខ្លាត
ឃ្លានកើតកុងដ៏សួគ៌តួរស្រស់ស្អាត សង្ឃឹតចរកម្ចាស់កសិណ ។
ផ្តិតផ្តង់តម្រង់ខប់អារម្មណ៍ ទំតរំប៉ំរើនឲ្យកើនឆ្អិន
វិលច្រាសត្រឡប់សព្វត្រឡិន សង្ឃឹនបញ្ចាន់ពប់ពាន់សា ។
ដកបដល់ឃ្លានសម្រេចឈាន អាចខុកជាស្ថានយានថ្លៃថ្លា
លុះអស់អាយុពីខេត្ត កាលណាឃ្លានកើតកុងដ៏ឋានព្រហ្ម ។
ដល់មានតំណើតកើតទីនោះ តាំងចិត្តស្ម័គ្រស្មោះប្រឹងសន្សំ
ឃ្លានឈានមានធម៌ជាអារម្មណ៍ ឡើងថ្នាក់ឧត្តមព្រហ្មជាន់លើ ។
គេទំសាងចិត្តប្រឹងដកប តាំងពីជាន់ពប.ខ្ពស់ត្រាន់បើ
បន្តបន្ថាប់ជាប់វគ្គសេដ្ឋី ហូតថ្នាក់លើផុតអន្តរាយ ។
បន្ថាប់តំរើរឿងខេត្តាក្រាប់ ឲ្យមនុស្សប្រញាប់ពាប់ខ្លួនឲ្យ

ធ្វើបុណ្យរឿយៗ កុំខឿយណាយ ខ្ទុះមានអធិប្បាយទៅទៀតថា ។
ដើមហេតុដំបូងគឺទេសកាល មានភ្លៀងបណ្តាលធំមហិមា (១)
បង្អុរស្រោចស្រប់សត្វតស៊ុគា កតដែនភាពក្រៀវឡើយ ។
ហៀរហូរតោរតេញគ្នាខន្ធោះ កន្ទឹតកៀនកោះត្រឹងឆ្ងាយ
រុក្ខជាតិលំតាស់លាស់ដុះដាល មនុស្សត្រេកត្រអាលតេញដែនដី ។
ទាំងគ្នាម៉ាមាំក្លាកេស់ ធ្វើការគាប់គាស់ចាំនប្រុសស្រី
សាបព្រោះតម្រើះស្រែសាលី ធញ្ញជាតអ្វី ។ ចាំនប៉ុន្មាន ។
តែកាលសន្ធឹងលូតបន្តិច ល្មមគោប្រចិចក្តិចស៊ីបាន
ស្រាប់តែមហាមេឃកេទ័សត្វហាន ប្រៀបបានដូចជាសត្វណាស្រែក ។
លាន់ឮក្រលួចកួចភ្លាវខ្លែ រំពើកញាប់ញ័រអស្ចារ្យខ្លែក
ដូចជាប្រផ្លេមបួលចំឡែក ផ្សាយចែកដំណឹងឲ្យដឹងថ្នាក់ ។
ថាផុតអស់ភ្លៀងត្រឹមនេះហើយ អ្នកអើយចូរចាំចំណាំជាក់
សូមីមួយគ្រាប់ក៏គ្មានភ្លាក់ ជាប់សូន្យហើយអ្នកកុំសង្ស័យ ។
ពិតមែនដូចមេឃឲ្យដំណឹង មនុស្សខ្វល់ខ្វាយចាំនយប់ថ្ងៃ
ក្រែងបានទឹកភ្លៀងត្រាន់អាស្រ័យ ធ្វើស្រែកែវៃលៀងដីរៃ ។
តែការខន្ធឹងឥតប្រយោជន៍ សន្ធឹងក្តៅភ្លោចហ៊ានហោចស្ងួត
ពួកមនុស្សត្រួយប្រាណរំខានចិត្ត ព្រោះដង្វៃគ្មានភ្លៀងខៀងជាងាប់ ។

១- កម្ពុជវិទាសភមហាមេឃ (ភ្លៀងដ៏ប៉ិនប្រាជ្ញកំប្លេ) ។

ឯការកាន់នោះមិនតិចឡើយ លំបាករងកម្ចាត់អត្តូ

ក្តៅស្ទើរឆេះខ្លួនប្រជួនជាប់ គ្មានក្រៀងមួយគ្រាប់ពាល់តែសោះ ។

ថ្កុកអូរត្រពាំងចឹងបួស្មឹង រីងហួតស្ងួតរីងក្រិនក្រៀមក្រោះ

រត្រីអណ្តើកខ្វែកតៀនកោះ ងាប់ឥតចន្លោះសោះសល់អ្វី ។

ចំណែកបែកខាងពួកមនុស្សវិញ កើតទុក្ខពោម្នេញគេញផែនដី

ខ្លាយខ្លះច្របល់ពាំងប្រុសស្រី ឃ្លានខ្ចីពីព្រោះតែគោះឃ្លាន ។

ណាមួយព្រួយចិត្តដ្បិតអត់ថ្នាយ ណាមួយរូបកាយកើតទន្ទ្រាន

ជម្ងឺឈឺស្ទាប់អន្តរាធាន បន្តស្ទើរគ្មានលស់ថ្ងៃណា ។

ម៉ែស្ទាប់ចោលកូនសូន្យជីវិត ៥ពាល់គំនិតអនាថា

ខ្លះកូនស្ទាប់ពៅនៅមេថា យំសោយសោកាពួញក្តែង ។ ។

ពោះចង់ជួយគ្នាក៏មិនកើត មុខស្ងាត់ក្អែកស្ទើរត្រដែងចំបែង

ខ្លួនត្រមស្គមស្គាំងតាន់តេងឆ្អែង ស្ទាប់គ្មានតែសែងយកទៅកប់ ។

ភូមិស្រុកមួយ ។ ខ្វិនអសោច ព្រោះសុទ្ធតែភ្ញោចធ្មុំស្មុយឡប់

អ្នកស្ទាប់ក្រាយគេញ៉ាំចំប្រប់ ដេកឃឹកកើយសពភ្ញោចអ្នកមុន ។

ខ្លះថ្ងូរឯសត្វគោក្របី តាន់សេះដំរីក៏ឈឺគ្រុន

ឆ្កែឆ្មាមាន់ទាគ្នាដាច់ដុន តគ្រុនស្តាំងស្គមត្រមគ្មានសល់ ។

ឈឺព្រោះពោះឃ្លានគ្មានអាហារ តិចតិចការផ្ទៃរចល់

ប្រកិនប្រកាច់ផេកដាច់ឱ្យល់ ម្ចាស់ឥតវៀស់មើលដម្បី ។
មានពេលឯណាទ័ដួយសត្វ បើមនុស្សរៀបត្តិតឹតតែឈឺ
ត្រឹតខល់ត្រលប់យប់ទើសត្តី ស្រែកថ្ងូរហ៊ុំៗតេញតែស្រុក ។
ខុសោកអ្នកអើយគ្រានោះឯង មនុស្សស្រួចំបែងវែងជាទុក្ខ
ថ្ងៃលោកចាំងមួលគ្មានថ្ងានសុខ សំកុកងើកម្ចាំតែស្ងាប់ ។
ប៉ុន្តែអកស្ងាប់ជាន់នោះក្លែ សុទ្ធសឹងមានថ្លៃចំណាប់
តម្លៃថ្នានចែងសំដែងច្បាប់ ថាស្ងាប់ក្លាមកើតក្នុងសួគ៌ ។
ដោយថ្នានតាន់តាមដំបូន្មាន ខេត្តាប្រថានដូចតណាទា
ទាន់ដើមមកហើយប៉ុន្មានឃ្លា អ្នកអានកល់គ្នាគន់ជ្រាបហើយ ។
តតីកំងឹកូនឯយូរអង្វែង ផែនដីសូតហែងក្តៅឥតស្បើយ
ព្រះអាទិត្យមិនតិតតែមួយឡើយ ទីពីរអ្នកអើយរះឡើងទៀត ។
មួយលិចមួយរះបន្តគ្នា ឯព្រះចន្ទ្រាមិនហ៊ានបៀត
ពុំដឹងជាមានឫក្លាត់ស្មៀត ប្រជ្រៀតសិកសៀតទៅណាបាត់ ។
ទំព័កត្រីមិនច្រកផង លែងមានកំណត់តាមសង្កាត់
មិនដឹងត្រីមណាជាយប់ស្ងាត់ ត្រីមណាបញ្ចូតថាត់ជាថ្ងៃ ។
ពីព្រោះសកលចក្រវាឡ ភ្លឺខែងសត្វកាលអចិន្ត្រៃយ
ស្មើខែងចាំងភ្លាំងភ្លេកភ្លែក មានសុទ្ធតែថ្ងៃក្តៅឥតស្រាក ។

ក្តៅហែងយាំនិនេះយូរសែនយូរ　ឥតមានគេលួងថយសម្រក
សុរិយោម៉ិបច្ចុចេញពាក　រះខ្លាកមួយខៀតជ្រៀតបន្ត ។
ខន្ធគួចធំនៅកន្លែកក　រឹងអស់តើលគោកដីសួតស
ក្រៀមក្រោះសោះសឹងរឹងដូចឫ　ប្រែប្រះច្រហែមក្រហែង ។
មិនតែប៉ុណ្ណឹងតឹងប្រឆួន　សុរិយោម៉ិបួនរះចាំងចែង
បក្ខេញឫទ្ធិគួរស្ញប់ស្ញែង　ក្តៅសព្វកន្លែងតន់ប្រមាណ ។
គ្រានោះមហាស្រះច្រាំពីរពាត(១)　តាំងពីព្រេងព្រឹទ្ធជាន់បុរាណ
ដែលហូរតែកុំហ៊ឹមតាន្ត　រឹងអន្តរធានគ្មានសែសស្រស់ ។
បន្តពីហ្នឹងសឹងយូរឆ្នាំ　សុរិយោម៉ិច្រាំចាំជួយផ្តល់
រះកែវភ្លឺចាំងចាំងសាកល　ឲ្យផលក្តៅក្តួលឆួលអនេក ។
ម៉ឺនមហាសមុទ្រត្រៀកប់យោជន៍　លន្លាមលន្ធោចធំចំឡែក
ករញ្ជោលដូចម៉ឺកក្នុងខ្លះដែក　តពុះត្បុះបែកក្តៅខ្លាំង ។
ឯសត្វធ្លាមម្តងក្នុងសមុទ្រ　ដូចគេស្ងោរដុតសុតអស្ងោរ
ប្រកឹនប្រកាច់ដាច់សន្លាំង　ស្ងាប់ជង្ឃឹមអាសារគួរអាណិត ។
ម៉ឺនច្រើនសន្ធឹកវើងកលៃថ្ងូ　ដោយគ្រឿងប្រល័យព្រះអាទិត្យ
បក្ខេញកំឡាំងខ្លាំងពេកពិត　តន្ត្រឹតតន្ត្រើរលើងសួត ។

១- ស៊ីហជាតនេះ, ហ៊ាសជាតនេះ ភណ្ឌមុណ្ឌាកៈ, បរិការទេហៈ, អនេតតន្តទេហៈ, ឆទ្ទន្តទេហៈ, កុណាលទេហៈ ។

តទៅសុវិយោធីជ្រាំមួយ ព្រះថមសឿងដួយភួយតម្រួត
ហាក់ដូចមួមៅក្តៅប្រកួត ប្រឹងព្រួតត្រួតគ្នាដាល់ជាប់ ។
គ្រាខោះសែនកោដិចក្រក់ឡ ខ្ទោចឈ្លឹមបណ្តាលហុយផ្សែងអ័ព្ទ
ខ្មៅទួលរំដួលស្ទើរក្រឡាប់ តីក្លើងនេះកប៏ជិតដល់ហើយ ។
ក្តៅធំធ្ងន់អស្លាប្យុំង ដូចឡដុតឆ្នាំងណាអ្នកអើយ
ដៃលគេបំពង់ជិតពុតខ្នើយ ផ្សែងហុយឥតស្បើយគួរឲ្យស្បើម ។
ក្តៅធំយ៉ាងនេះយូរឆ្ងាំណាស់ ផែនដីធំក្រាស់តាំងពីដើម
ដៃលឆ្ងាប់មានជាតុដីជាតិសើម តង់ត្រូវក្លើងឆ្អើមផ្តើមឲ្យខ្ទោច ។
សុវិយោរះទីជ្រាំពីរក្រោយ មិនមែនអន់ខ្លួយកម្លាំងហោច
សឹងមានតេជះតួរះរុងកេចន៍ អាចនេះកំឡោចឲ្យខ្ទេចម៉ត់ ។
សូមអស់លោកអ្នកគ្រប់ថ្នាក់ជាន់ ប្រុងស្តាប់ឲ្យគាន់ជាក់ច្បាស់ជ
ខ្លួរកាលវេលាត្រាំកំណត់ ផែនដីកំសត់ទីឯសូន្យសោះ ។
រឿងហេតុនេះឯងដូច្នោះពិត ព្រោះអាទិត្យច្រាំពីរស្មោះ
រះភ្លែតប្រកួតព្រួតប្រកោះ នេះឥតចន្ទោះសោះសល់ទី ។
គ្រាខោះកណ្តាប់ចក្រក់ឡ ធាបតីបង្ហោះដាលដោយអគ្គី
សន្ធោដ្ឋិនដ្ឋៅក្តៅសែនខ្លី ពាសពេញប្រថពីទីលោកធាតុ ។
កំពូលភ្នំធំខ្ពស់ក្រលួច ត្រូវខ្យល់ក្របួចក្លួចរៀបឃ្នាត

បក់ជោគកំចាត់ផាត់ព្រោងព្រាត ប៉ើងខ្ពុតទៅលើខគាល័យ ។
សូរស៊ីតូតគីកសន្ធឹកញ៉ែរ ភ្ញាវខ្លែអស្ចារ្យទទ្បារព្រៃ
អគ្គីស៊ីរចេះចូចហ៊ានវៃហែ ឥតមានសំចីយដល់ប៉ុនសក់ ។
ឆេះខេះហៅឆេះសែនអនេក ឆេះឆួលសន្ធៃកសត្វនរក
ខៀកនឹងរណ្តៅជ្រៅផុងតក់ ប្រកាច់រឹតស្ទាប់រចល់ ។
រួចព័ទ្ធខ្សែរលោកយោកខ្ពស់ សួគ៌ឆកាមាខ្លួចឥតសល់(១)
អណ្តាតភ្លើងឆាបឆាបឆេះដល់ ព្រហ្មលោកមណ្ឌលតំឆ្ងល់ជាន់(២)។
តីឆេះខ្លាំងនឹងអាកសរ្ក ខេត្តានឹងព្រហ្មយំស្រែកលាន់
តែទំនប់ចិត្តប្រឹតឥតកាន់ ជួលឈានឮៗតន់ពេលវេលា ។
ស្ងាប់ភ្លាមកើតភ្លែតព្រហ្មជាន់លើ(៣) ដោយប្រុងអើតើតាំងអស់គ្នា
តាំងពួកខេត្តានឹងព្រហ្ម រួចព័ទ្ធវេទាគ្រាអាសន្ន ។

១- ឆកាមាវចរសួគ៌ឬទេវលោក ៦ ជាន់គឺ ចាតុម្មហារាជិក. តាវត្តឹង្ស, យាមា. តុសិតា. និម្មានរតី, បរនិម្មិតវសវត្តី ។ ២- ព្រហ្មលោក ១៦ ជាន់គឺ ព្រហ្មបរិសជ្ជ, ព្រហ្មបុរោ. ហិតា. មហាព្រហ្មា, បរិត្តាភា, អប្បមាណាភា, អាភស្សរា. បរិត្តសុភ អប្បមាណសុភា. សុភកិណ្ហា, វេហប្ផលា. អសញ្ញីសត្តា, អវិហាៈ, អតប្បៈ. សុទស្សា. សុទស្សី. អកនិដ្ឋក ។ ក្នុងប្រស័យអស់ ៥ ជាន់ពីព្រហ្មបរិសជ្ជដល់អប្បមាណាភា ។ ៣- រាប់តាំងពីថ្នាក់អាភស្សរឡើងទៅដែលក្នុងនេះមិនដល់ ។

កើនកើតពីថ្ងៃប្រលឹយកប្ប ជាខនេះសម្លាប់ទាប់ទាន់ហាន់
ផែនដីតិតតគ្រប់តំបន់ រួចទៅបង្ហិនរលត់អស់ ។
ឥតមានសែសស់តំញាមផេះ ប្រៀបដូចកើនឆេះប្រែជាស្រស់
កាលណាឆេះរលីងស្ងួតរលេស់ តំអស់គ្មានអ្វីសល់ឲ្យដឹង ។
គ្រានោះអស្ចារ្យទឡាំក គ្មានដីគ្មានទឹកសែនល្បីយល្បឹង
សុទ្ធតែអាកាសជាសន្ទឹងឆ្ងាយ ឆង្ងឹតសូន្យឈឹងយូរអង្វែង ។
ឯព្រះអាទិត្យទីឆព្រះច័ន្ទ ដែលមានលំក្នុងំណាត្បាប់ចាំងចែង
ចាំងពួកតារាកញ្ចារស្តែង ចាំងអស់នេះឯងលែងប្រាកដ ។
រីកាលបរិច្ឆេទសង្កេតចាំ ថ្ងៃខែទីឆឆ្នាំតាមបែបបទ
ឥតមានចំណែកចែកកំណត់ ភប់កត់គិតគួរខូរឲ្យឃល់ ។
ជាខអ្នកឯណាទីឆគ្នាភប់ បើមនុស្សសត្វឆាប់គ្មានសែសស់
ចាំងព្រះអាទិត្យចន្ទមណ្ឌល តើជុតឋសគល់ត្រីមហ្នឹងហ៊ាយ !

(នៅមានត)

អក្សរសាស្ត្រខ្មែរ	ខ្មែរជួរក្រវែន
ឱ្យរឹកចម្រើន	គង់វង្សតំណាត់ ។
ព្រោះអក្សរជាតិ	ដោលជាតិជ្រោកជង
អក្សរលត់	ជាតិក៏រលាយ ។

ប.ព.

អំពីអារ្យធម៌ខ្មែរ

លោក លី-ជាមតេង រៀបរៀង

១- ន្ទើមសេចក្តី៖

អត្ថបទក្រោមចំណងដើងថា "អំពីអារ្យធម៌ខ្មែរ" នេះ យើងមានបំណងលាតត្រដាងឱ្យបានវែងឆ្ងាយល្អិតល្អន់អំពីពាក្យថា អារ្យធម៌ នឹងជាពិសេស តើអារ្យធម៌របស់ជនជាតិយើង ព្រោះអ្នកផងតែងនាំគ្នាសំគាល់ថា ខ្មែរយើងជាជាតិមួយ មានអារ្យធម៌ជាក់លាក់ តាំងពីបូរាណយូរយារវែងឆ្ងាយហើយ ។ ប៉ុន្តែ មុននឹងបញ្ចាក់ដូចអំពីចំណុចចំនៃអត្ថន័យរបស់អត្ថបទយើងនេះ យើងសូមបញ្ជាក់ជាមុនអំពីពាក្យថា "អារ្យធម៌ ឬ អរិយធម៌" នេះជាមុនសិន សំរាប់ជាប្រដាប់ជួយសំរួលការយល់ដូលដូលាយនៃបទសិក្សានេះ ។

តាស្ស អារ្យធម៌ ឬ អរិយធម៌ កើតចេញមកពីពួកជនជាតិមួយក្រុម ស្ថិតនៅដែនដីឥណ្ឌាបុរាណផ្នែកភូមិភាគឦសានបន្តិចបន្តួច គឺលើខ្ពង់ដីតខាងជួរភ្នំហិមាល័យ(១) ។ ជនជាតិនោះឯងមានឈ្មោះថា អាយ: ឬ អរិយ: ដែលតាំមែនមានដើមកំណើតជាឥណ្ឌាសុទ្ធទេ គឺជាសង្គមមនុស្សមួយពួកបែកចេញមកពីប្រទេសបែរស៊ី ដែលសព្វថ្ងៃច្រើនហៅក្លាយថា "ពែរ្ស (perse)"(២) ។ សញ្ជាតិមនុស្សបែកចេញពីដែនបែរស៊ីនេះឯង បានចូលមកទន្ទ្រានទឹកដីពួកជនជាតិដើមបានជោគជ័យ គឺដេញពួកអ្នកស្រុកតំណើតដែលមានឈ្មោះថា ជ្រាវីត ឲ្យតេ្ងាត់ខ្ចាត់ខ្ចាយពីកន្លែងដើមទៅនៅឯភូមិភាគនេ្លសមុទ្រឯនោះទៅវិញ ។ កាលណាបានជ័យជំនះហើយ ពួកអ្នកឈ្នះនេះ បានតាំងឈ្មោះថ្មីរបស់ខ្លួនថាជា អាយ: ឬ អរិយ: នេះឡើង បានសេចក្តីខ្មែរថា ពួកគេនេះជាពួកអ្នកចេះដឹង ពួកអ្នកចំរើន ។ តាមពិត ពួកនេះគេចេះដឹងមែន ។ គេចាប់ចាត្តិតចំណេះវិជ្ជាក្បួនខ្នាតសព្វសារពើឡើង តែជាពិសេសវិជ្ជាខាងនោះសុទ្ធសឹងបែកចេញជាចំនែកចំលាប់ ឬលទ្ធិសាសនា ប៉ើនិយាយឲ្យចំគឺខាងជំនឿផ្សេង ។ (Croyances) ។ វិជ្ជាដែលគេឮយាមចង់ពុកជាតម្រាប់តម្រានេះ ក៏មានឈ្មោះភ្ជាប់ខាងនាមដើមរបស់គេថា "អារ្យធម៌ ឬ អរិយធម៌" បាន

---

១ ហិម = ទឹកសន្សើម + អាល័យ = កន្លែង, បានន័យថា កន្លែងដែលភ្ជាក់ឬមានទឹកសន្សើមច្រើន (សូមកុំនិយមថា ហិមាល័យ) ។ ២ មកពីនិយាយសរសេរ Parsee ក្លាយទៅ Perse ។

ន័យថា « ជាក្បួនច្បាប់របស់ពួកអ្នកចំរើន » ។ យូរៗទៅ ក្បួនច្បាប់ជាមូលដ្ឋានខ្មែរនៃវិជ្ជានេះ ចាន់ផ្សព្វផ្សាយទៅគ្រប់ទិសទីក្នុងភូមិភាគអាស៊ី ខ្មែរឆ្នើរហួតទៅកាន់ទ្វីបដទៃទៀតមានទ្វីបអឺរុបជាអាទិ ។ អាស្រ័យលើឥទ្ធិពលនេះហើយចានជាភាសាអារ្យធម៌ផ្សាយរហូតមកដល់ប្រទេសខ្មែរយើងដ្បិតយើងចាត់ទុកដូចជាភាជនៈមួយ ដែលចានខ្វះលុងផុតពេញទៅដោយចំណេះវិជ្ជាការចេះដឹង តាគ្រប់ប្រទេសនានាដែលល្បីល្បាញថា មានការចំរើនលូតលាស់អំពីបូរាណ មិនតែប៉ុណ្ណោះជនជាតិយើងចានចាំនឹងប្រមូលយកនូវចំណេះវិជ្ជាចាំនឹងនោះមកបន្ថែមផង ដើម្បីសំអិតសំអាងផ្សំថែមឡើងហើយផ្សាយឲ្យសាយភាយទៅលើប្រទេស ឬជនជាតិថ្មី ។ ចាំនឹងឡាយដែលត្រូវការស្ថាបនាជាតិខ្លួនជាបន្តទៅទៀត ដូចជាជាតិដែលនៅដិតខាងយើងនេះជាដើម ។

ពេលមកខាងលើនេះ គ្រាន់តែបញ្ជាក់រកប្រភពនៃពាក្យថា « អារ្យធម៌ » ឬឲ្យដឹងថា តើកើតចេញមកពីពួកណា ? មជ្ឈដ្ឋានណា ? ឥឡូវយើងចានដឹងហើយ យើងបន្តការចរិយាយទៅទៀត ចូលទៅក្នុងអារ្យធម៌របស់ខ្មែរយើង ។

មានអ្នកប្រាជ្ញធំ ។ ជាច្រើនណាស់ ចានសរសេរពុះពារក្នុងសៀវភៅសំខាន់ ។ ដែលចោះត្មុតផ្សាយក្នុងសាកលលោកថា « អារ្យធម៌ខ្មែរជាអារ្យធម៌ដ៏ឧត្តុង្គឧត្តមបំផុត ព្រោះកើតចេញមកពីអារ្យធម៌ឥណ្ឌា ដ៏ឧ

អារ្យធម៌ចិន ។ ។ អ្នកប្រាជ្ញខ្លះសរសេរថា «អារ្យធម៌វណ្ណៀ ចាន់មក
ប៉ះពាល់ច ហើយរឿងគាចាប៉ាតិភាហ៍ ជាមួយនឹងអារ្យធម៌ចិនទៅលើទឹកដី
សុវណ្ណភូមិ កើតចាន់ជាប្រភេទមួយ គឺអារ្យធម៌ខ្មែរ» ។ មតិរបស់អ្នក
ប្រាជ្ញទាំងនេះ ជាការគិតជាក់ស្តែងណាស់ យើងពុំអាចប្រកែកចាន់ទេ
ព្រោះបើយើងគ្រាន់តែក្រេឡេកមើលមកកន្លែងបៀបរស់នៅ ជាពិសេសខាង
ប្រភៃណីនៃជាតិយើង ក៏យើងត្រូវទទួលថា ប្រភៃណីខ្មែរ គិតជាចាក់
ឥន្ទ្រដើមកំណើតមកពីប្រភៃណីវណ្ណៀ ទឹងប្រភៃណីចិនមែនក្នុងការដេក
ដើរឈរអង្គុយជាដើម ។ ប៉ុន្តែយើងបន្ថែមទទួលក្នុងមតិខាងលើទៀតថា
អារ្យធម៌ពុំមែនមានតែត្រឹមអារ្យធម៌វណ្ណៀ ទឹងចិនប៉ុណ្ណោះទេ នៅមាន
អារ្យធម៌ដើម ដែលទទួលឥទ្ធិពលកើតឡើងក្នុងសង្គមជាតិដើមរបស់ខ្មែរតែម្តង
ប៉ុន្តែអារ្យធម៌នោះប្រែប្រួលចេញមកពីតួកមនុស្ស ដែលរស់នៅជាសង្គមតូច
តាចតុំសុទ្ធមានឥទ្ធិពលខ្លាំងក្លា ម្ល៉ោះហើយបើមានឱន្ទាការខ្លាំងចូលមក
ពីទិសណាមួយ ឱន្ទាការនោះប្រាកដជាមានឥទ្ធិពូលមកជ្រៀតជ្រែក
គ្រប់ជណ្តាប់ឋានៃមលើខ្លួនចាន់ជាមិនខាន ។ ប៉ុន្តែការចូលមកគ្រប
ជណ្តាប់នៃឱន្ទាការ អារ្យធម៌ចិនទឹងវណ្ណៀនេះ ពុំមែនចាន់ន័យថា
ធ្វើឲ្យអារ្យធម៌កំណើតរបស់ខ្មែរចាន់បង់សោះសូន្យទេ បែរជាចាន់បែក
ជាន់ត្រសុំត្រសាយទៅវិញ រឹតតែនាំឲ្យមានភាពស្មុគស្មាញកាន់ត្រប់បែបត្រប់
យ៉ាងឡើងទៀត ។ ត្រង់នេះ មានឧបមាដូចជាជនបរទេសយកយ៉ាងណោះ

ម្នាក់តិតមែនតែខ្លួនឯងតែប៉ុណ្ណោះ តែខ្លួនស្រាប់ស្រេចញ៉ាំរឿនសូត្រ
បន្តែមណាស់ តុំមានខ្ជិលច្រអូសទេ, លុះបានជួបប្រទះនឹងពួកអ្នកចេះ
ដឹងមុតមាំ បុរសឯត់ចំណេះនោះតុំមែនលិចឈ្លោះកប់ចុតទេ ថែរជា
រឹងរឹតតែលេចឮកេរ្តិ៍ឈ្មោះឡើង ព្រោះអាស្រ័យដោយការក្រេបជញ្ជក់
ពីតពួកអ្នកចេះដឹងច្រើនោះឯង ។ ដោយហេតុនេះហើយ បានជា
អ្នកប្រាជ្ញរបស់ខ្មែរតាំងពីបុរាណមក តុំដែលយកអាវុធមិនេមកប្រើប្រាស់
សុទ្ធ ។ ចាំងដុំចាំងដុលនោះឡើយ លោកតែងតាំ្រយាមយកមកថ្នែរបនា
ថែបណាឲ្យក្លាយទៅតាមចំនង ឬទៅតាមទស្សនិយមរបស់ខ្មែរពោរពៃ
សូម្បីតែម្ចាស់ដើមមកពីមើលឲ្យឃើញថា យើងយកអាវុធមិនេ កំពុង
ឃើញប្លាស់ដែរ ។ ចំណុចនេះ បញ្ជាក់ឲ្យយើងឃើញទៀតថា ខ្មែរ
យើង ឬជនជាតិដើមរបស់យើង តែងជាមានទេពកោសល្យ មាន
ទុត្តមគតិ មានទស្សនិយមមួយដោយឡែកប្រចាំជាតិជាពិតប្រាកដ ។
ឯមនុស្សដែលមានទេពកោសល្យ មានទុត្តមគតិ មានទស្សនិយម
យ៉ាងល្អតុំមែនមនុស្សល្ងង់ខ្លៅនៅតំពេលឡើយ គឺជាមនុស្សមានការ
ចេះដឹងខ្លួនឯង បានន័យថា មានអាវុធមិរបស់ខ្លួនខ្លះប្លែកហើយ ។
មិនតែប៉ុណ្ណោះ យើងនៅតែមានតតាំងតាមដាំជាដរាបថា អាវុធមិរយើង
ញ៉ាំ
ប្លាស់ជាមានន័យការផ្សេង ។ មកពីអាវុធមិបានន័យដូច្នេះ ព្រោះ
កស្តុតាងកំរយើងរក្សាខ្លួនទៅជាគោលចរិតរៀងរហូតមក ដូចជាលទ្ធិ-

សាសនា, ចំនៀមកន្ធងការរៀបចំវិធីបុណ្យផ្សេងៗ, បែបសិក្សាភាសាសំដី, ភូរ្យតន្ត្រី ។ល។

ដោយសារការិច្ចរចារបស់អ្នកប្រាជ្ញបុរាណយើង ទើបការមានរូបភាពច្បាស់ថែងឡើងតាំងពីសតវត្សទី ៣ ទី ៤ នៃគ្រិស្តសករាជ រហូតមក ត្រមាំងបញ្ចេញឥទ្ធិពលខ្លួនផ្សាយឲ្យទៅពួកអ្នកដែនខាងត្បូងទិសទីថែមទៀត ទោះបីជាមានអ្នកប្រាជ្ញនៃប្រទេសទាំងនោះ ពុំក្បាលតញ្ញាតាធម៌ដូចយើង ចង់បង្កែរក្បែងបន្ទំថា ការរាមិនែពុំមែនបែកចេញពីការរាមិយើងក៏ដោយ ក៏នៅមានអ្នកប្រាជ្ញឯប្រទេសឆ្ងាយៗ មាននៅខ្លីបអ៊ីរុបជាដើម នែនៅតែធ្វើសាក្សីឲ្យយើងដោយសារសេរសេរសើរ ឧទ្ធិនខ្លួលស្គាល់ថា ការរាមិខ្មែរនេះហើយដែលផ្សាយ បែកជូនដល់ជនជាតិដែនខាងក្នុងភូមិភាគឧបទ្វីបឥណ្ឌូចិនទាំងមូល ។ តែដោយសារតែការយុនៃការរាមិយើងមានមកជាអង្វែងដូចនេះហើយ ទានជាក្តីរឹងឈ្មោះយើងឮល្បីខ្លួនឯងយ៉ាងពុំអាចលុបបានដោយការបំភ័ន្តបែបណាមួយឡើយ ។

នៅភាគខាងក្នុងនៃសតវត្សទី ១៤ ការរាមិអ៊ីរុប ដែលជាការរាមិភ្ញាំងភ្លឺ មានឥទ្ធិពលមហិមាចូលមកគ្របដណ្តប់លើការរាមិយើងមួយលើកទៀត ។ តាមសន្ទុះនៃកំឡាំងការរាមិអ៊ីរុប ដែលឮបាត់តែមានដោតជ័យជាន់ខ្លួលើប្រទេសជាច្រើនមកហើយនោះ គេពុំស្មានថា ការរាមិខ្មែរគេចខ្លួនរួចពីកណ្តាប់ដៃដ៏មាំនៃការរាមិអ៊ីរុបទានឡើយ តែផ្ទុយស្រឡះ

ការស្មានខ្លះ យើងបែរជាបានអារ្យធម៌អ៊ីរុបមកធ្វើជាដំនួយបន្ថែមឲ្យអារ្យ-ធម៌យើងមានសភាពកាន់តែខាន់សម័យនិយមទៅវិញ ដ្បិតនៅក្នុងគ្រាបច្ចុប្បន្ននេះ មនុស្សភាគច្រើនក្នុងសាកលលោក គេតំពុងចាប់អារម្មណ៍ខ្លាំងអារ្យធម៌អ៊ីរុបនេះ ថាជាគោលចំណេះជើងឯង ផ្នត់គំនិតរៀបរយគួរនិយមកប់អាន ទុកជាវណ៌ ដូចជាសុដីវធម៌, សិល្បៈគុបតែងកាយជាដើម ។ ក្នុងពេលនេះ នៅប្រទេសយើងក៏កើតបានពាក្យមួយម៉ាត់យ៉ាងថ្មីសំរាប់ជាវោហរ:ជាមួយនឹងពាក្យអារ្យធម៌ គឺពាក្យ "ស៊ីវីល្យ" ដែលក្លាយមកពីពាក្យបារាំងថា ស៊ីវីលីហ្សេ (Civilisé) ឬ ស៊ីវីលី-ហ្សាស្យុង (Civilisation) ។ រីពាក្យស៊ីវីល្យនេះសោត, យើងបានការ-ល្អៅជាច្រើនអានបែបខ្មែរ ហើយមានគ្នាច្រឡំលាប់ប្រើយ៉ាងរត់មាត់ត្រូប-ស្រុតត្រូវក្តីមិនថាខ្មែរណាជាខ្មែរណា ពុំចាំបាច់ដឹងដោលរកប្រភពដើមនៃពាក្យនេះផង ។

លំក្នុងខ្ញុំណូតាំងអម្បាលមាន ដែលក៏យកក៏ប់មកទាំងលើនេះ បង្ហាញឲ្យយើញច្បាស់ថា ខ្មែរមានអារ្យធម៌មួយប្រាកដជាយូរយារណាស់ហើយ ដោយហេតុនាំឲ្យបូកបាន់បញ្ចូលទំនើណាដែលល្អ ។ របស់អារ្យធម៌ជាតិសាសន៍ដទៃផងទៀត, តែយ៉ាងណាក៏ដោយ គឺនៅតែមានលក្ខណៈមួយជាខ្មែរដដែរមក ។

(នៅមានត)

ដោយគណៈកម្មការជាតិនៃការសិក្សា ផ្នែកអក្សរ « ក »

(តមក)

Corrupteur	(n.m.)	អ្នកស៊ូក
Corruption	(n.f.)	សំណូក
Corrompu	(n.)	អ្នកស៊ីសំណូក
Corrompre	(v.)	ស៊ូក
Chapitre		ចំពូក : ចំណែកនៃមាត្រា, ការប្រជុំសេចក្តីក្នុងចំណែកមួយនៃមាត្រា ។
Classement	(n.m.)	ការចុះបញ្ជី (ព. សិល្ប)
Classification	(n.f.)	វគ្គីការណ៍ : ការធ្វើឲ្យមានពួក, ការដាក់ជាពួកជាក្រុម ។
Classifier	(v.)	វគ្គីក្រឹត : ធ្វើឲ្យមានពួក, ដាក់ជាពួកជាក្រុម ។
Classificateur	(n.m.)	វគ្គីការី : អ្នកធ្វើវគ្គីការណ៍ ។
Classer	(v.)	ចុះបញ្ជី (ព. សិល្ប)
Disposition préliminaire		បទបញ្ញត្តិប្រាះពេ្ញ (ព-ឬ.): បទស្មើសភោសាដំបូង ។ ន. ក្នុងភាពនៃក្រមព្រហ្មទណ្ឌ ស្តីអំពីនរណាដែលគេអាចធ្វើទោសបាន មានមាត្រា ៣ ជាបទបញ្ញត្តិប្រាះពេ្ញ ។
Déclasser	(v.)	ចំណាយបញ្ជី (ព. សិល្ប)
Exécuter la peine		ទទួលទោស

(នៅមានខ្លះ)

វិបុលានុក្រមសំស្ក្រឹត-ខ្មែរ

ព្រះមហា ចាំង . ខាត់ រៀបរៀង

(តមក)

អតិរីភ៌ន្ន ឧ. ដែលបែកធ្លាយក្រៃលែង ។

អតិរីរាជ ឆាឧ. ភ្ញាក្រៃលែង, រុងរឿង ។

អតិរីរាជ្ញ ស្រ. ឈ្មោះរង្វាស់ (ម៉ែត្រ) ។

អតិរីរុប៌ ឆាឧ. ភ្ញាព្រោងព្រាតក្រៃលែង ។

អតិរីលង្ឃ្ន ឆាឧ. លោតរំលងក្រៃលែង ។

អតិរីលុឝ្ន ឆាឧ. ទ្រូសប្របល់ក្រៃលែង ។

អតិរីគ្រហ្ន ឧ. ដែលធឿងាក់ក្រៃលែង ។

អតិរីគ្ហ្ន័ស៌ ឆាឧ. ធឿងាក់ក្រៃលែង ។

អតិរីឆ ឧ. ដែលមានពិសក្រៃលែង ។

អតិរីឆ្ម ឧ. ដែលមានពិៈយោស្មើទៅគ្រាស់ហើយក្រៃលែង, ដែលកាច, ដែលភ័យ ។

អតិរីឆ្ត្ថ ឧ. ដែលឋិតនៅក្រៃលែង ។

កណ្ឌទី ៤៧

ទុកញ៉ាំរំលុកជនសេនា ដួ-កកន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃធ្វាសបើបានអាន
ទំនងបេះទុយាយកលចំណាន
ទាំងមានសន្តានស្នេហាជាតិ
——ឃ្លោ-អ៊ុន——

ធៀយ៉ុកថា ដែលហ៊ូហ៊ុមកាន់សំបុត្រមកនេះ លោកគ្រាបកលខ្លះឬទេ ? គឺស៊ុនគួនតតែងបាយយ៉ាំដែរម្តេចខ្លះ ? ។ ប៊ូធូថា គឺតមិនយល់ទេ ។ ធៀយ៉ុកថា ស៊ុនគួនធ្វើកលឲ្យសំបុត្រមកនេះ មិនមែនទើបតែនឹកបំរុងដោយស្រាប់ញ៉ាំឡើយ ស៊ុនគួនទើបតែស្មោះត្រង់នោះទេ ស៊ុនគួនទើបតែ មុខជាបែកចិត្តពីគ្នាហើយ តែបើស៊ុនគួនលើកទ័ពទៅកាយយកស្រុកកេងដីវិញ ក៏ឲ្យអាម្នេណ៎ាភូចមហាឧបាជ ទើបលើកទ័ពទៅរាយយកស្រុកតាំងតាំងបានជាចំបាំងធ្វើឲ្យមានសំបុត្រមកក្រាបទូលព្រះចៅហៀនតេ ឲ្យតាំងឡើតតេញទ័ជាចៅហ្វាយស្រុកកេងដីវិញតែម្តងចំងន់ទើបឲ្យឡើតទុកចិត្ត

ហើយខ្ញុំឲ្យលោកប្រឡប់គិតថា ស៊ុនគួនខ្ញុំឲ្យតែត្រូវគំនិតគ្នា មិនអាចខ្ញុំលើកតាលយោងទៅវាយស្រុកកាំងតាំង បើលោកកាន់តាំងហើយ ស៊ុនគួនក៏ខ្ញុំឯងបានធ្វើការជាមាំមួន ខ្ញុំបានខ្ញុំគិតកលទុបាយមួយយ៉ាងឲ្យឡៅតីខ្ញុំស៊ុនគួនកើតវិវាទច្បាំងគ្នាឲ្យខាងតែបាន ។

ចូនូសួរថា កលទុបាយរបស់អ្នកប្រការម្តេច ? ។ ឆៀយ៉ុកថា សព្វថ្ងៃនេះស៊ុនគួនជាធំក្នុងស្រុកកាំងតាំង ក៏អាស្រ័យសេចក្តីរិះគិតរបស់ជីវយីតែម្នាក់ សុំឲ្យលោកក្រាបទូលព្រះចៅហៀនតេ ឲ្យតាំងជីវយីជាចៅហ្វាយស្រុកឡាំគុន ឲ្យខៀគៅជាចៅហ្វាយស្រុកកាំងវែហ ឯខ្លួនហ្ហ៊ីហ៊ុំមដែលកាន់សំបុត្រមកនេះ ត្រូវយកទុកប្រើការក្នុងទីក្រុង ខាងជីវយីនោះនៅមានចិត្តព្យាបាទឡៅតី, ខុងបេងជាដរាប បើកាលណាព្រះចៅហៀនតេទ្រង់តាំងឲ្យធ្វើធំហើយ ក៏ខ្ញុំងមានចិត្តកំរើកលើកទ័ពទៅវាយស្រុកតេងជីវសងសឹកឡៅតីខ្ញុំងខុងបេងជាប្រាកដ បើស៊ុនគួនខ្ញុំងឡៅតីកើតវិវាទច្បាំងគ្នាឡើង សឹមយើងរិះគិតតទៅទៀត ។

ចូនូយល់ឃើញត្រូវ, ក៏ឲ្យហៅខ្ញុំនហ្ហ៊ីហ៊ុំមឡើងទៅលើប្រាសាទ ឲ្យបំណាច់រង្វាន់តាមសមគួរ រួចនាំខ្ញុំនហ្ហ៊ីហ៊ុំម ខ្ញុំង នាហ្ម៊ីនខ្ញុំកជាតាំងភ្លូងឡើងក្រុងហ្ហ៊ូតោ, ចូនូក៏ទូលទៅក្រាបបង្គំគាល់ព្រះចៅហៀនតេ ក្រាបទូលសុំតាំងជីវយីជាចៅហ្វាយស្រុកឡាំគុន តាំងខៀគៅជាចៅហ្វាយស្រុកកាំងវែហ ។ ព្រះចៅហៀនតេក៏ប្រោសព្រះរាជទាន ។ ចូនូក៏តាំង.

ហ្លួហ៊ុមឲ្យជានាហ្មឺនធំមៅស្រុកហ៊ូតោ ហើយប្រើភាហានជាប់តើឲ្យតាន់
សំបុត្រព្រះរាជតម្រាស់ទីន្រ្តាតាំង ហើយមានសំបុត្រទ្រុបទៅដល់ស៊ុន-
គួន សេចក្តីថា ដ្បិតមានព្រះរាជតម្រាស់តាំងឲ្យដើរយើជាចៅហ្វាយស្រុក
ឡាំគុន ។ ប៉ះតើកិនាំសំបុត្រព្រះរាជតម្រាស់ទៅដល់ដើរយើទីន្រ្តាតៅ ។

ដើរយើទទួលព្រះរាជតម្រាស់ទីន្រ្តាតាំងហើយ មានសេចក្តីត្រេកអរ
ណាស់ ធ្វើសំបុត្រចាត់ប៉ះតើឲ្យនាំសំបុត្រ ចូទួ ទីន្រ្តាសំបុត្រទៅស៊ុនគួន
សេចក្តីថា ដ្បិតមានព្រះរាជតម្រាស់ទីន្រ្តាតាំងព្រះចៅហៀនតេប្រោស
ព្រះរាជទាន ឲ្យខ្ញុំឡើងទីជាចៅហ្វាយស្រុកឡាំគុនហើយ ដែល
ពុំបានទីន្រ្តាខ្លាតធ្វើការសងសឹកលោកនោះ ខ្ញុំទីន្រ្តាសុំការសងសឹកវិញ
ឲ្យបាន, សូមឲ្យលោកប្រើខ្លោសុកទៅរំលឹកការយកស្រុកកេងដីវ៉ា ស្តាប់
សំខ្លួនខ្លោតាទីន្រ្តាពុំបានមើលមុខសិន រួចសឹមគិតការតទៅ ។

ស៊ុនគួនដឹងសេចក្តីកង់សំបុត្រដូច្នោះ កំឲ្យហៅខ្លោសុកទៅនិយាយ
ថា ស្រុកកេងដីវ៉ានោះ មុនដំបូងអ្នកកំបានខ្ញុំឲ្យខ្លោតា ហើយអ្នកកំ
ពុំលួលជាអ្នកជានាផង ឥឡូវខ្លោតាធ្វើត្រងើយកន្តើយ មិនចង់ឲ្យស្រុក
នោះមកយើងសោះ អ្នកនឹងគិតយ៉ាងណា ។ ខ្លោសុកថា សេចក្តីកាង
អម្បាលនេះ ខ្លោតាកំបានទិយាយ ដូចមានសេចក្តីកង់សំបុត្រស្រាប់ ។
ស៊ុនគួនឮដូច្នោះកំរឹងណាស់ គំហកឲ្យខ្លោសុកថា កង់សំបុត្រខ្លោតា
ថា បើកយបានស្រុកសៃឈួនការណា ទីន្រ្តាបង្វិលស្រុកកេងដីវ៉ាឲ្យ

កាលនោះ តាំងពីពេលនោះមក មិនឃើញាខ្មៅពីរនាក់ទៅវាយយកស្រុក
សៃឈ្នួនសោះ ខ្ញុំឲ្យយើងរំងាប់យកពាល់តែបាស់ទៅឬ ។ ខ្មោសុក
យើញាស៊ុនតួនខ្ញុំដូច្នោះក៏ឆ្លើយថា ខ្ញុំបាទនឹងសុំលាលោកទៅបង្ខំការយក
ស្រុកកេងដាវ ស្តាប់ដំណឹងខុងបេងម្តងទៀតមើល ។ ស៊ុនតួនក៏បាត់
ខ្លួកឲ្យខ្មោសុកចេញទៅស្រុកកេងដាវ ។

ឯខ្មៅពីនឹងខុងបេងតាំងពីបានឱនស៊ុនហ៊ូយិនទៅដល់ស្រុកកេងដាវ
ហើយ ក៏តាំងតែប្រមូលបញ្ចុះបញ្ចូលពាហានសន្សំស្បៀងអាហារហើយ
បង្ហាត់បង្រៀនកងួនអាវុធកាលថ្ងៃ អ្នកដែលមានតម្រេះប្រាជ្ញានឹងច្បាំងដៃខ្លាំង
ពួកៗ សឹងតែមកចុះចូលនៅនឹងខ្មៅពីច្រើន ខ្លួលមនុស្សចូលមកជាច
ខ្មៅពីថា ស៊ុនតួនប្រើខ្មោសុកមកដួចនឹងលោក ខ្មៅពីក៏សួរខុងបេង
ថា ដែលខ្មោសុកមកនេះមានចំណាំដូចម្តេច ? ។ ខុងបេងថា តាំដើម
ស៊ុនតួនឲ្យមានសំបុត្រចូលទៅក្រុងហ៊ូតោ ក្រាបខ្លួលត្រះចៅហៀនតេ
សុំឲ្យតាំងលោកពេញទីជាចៅហ្វាយស្រុកកេងដាវ បំងនឹងឲ្យចូលគោត
ញាក្បៀតថា ស៊ុនតួននឹងលោកនៅរួមគំនិតចិត្តជាមួយគ្នា ។ ចូលដល់
ភលមចាយស៊ុនតួន ទើបត្រឡប់ក្រាបខ្លួលត្រះចៅហៀនតេ តាំងដាយើ
ជាចៅហ្វាយស្រុកឡាំគុនវិញ តាំងទៀតជាចៅហ្វាយស្រុកតាំងហៃ
ប្រាជ្ញានឹងឲ្យដាយើ កំរើកចិត្តគិតខ្លើសគ្រាមតនឹងលោកទៅថ្ងៃមុខ ទើប

ចូរទូន្មានឯងបានតិតការបានមាំមួន ដែលខ្លាសុកមកនេះ មុខជាគំនិតស៊ុនគួន
នឹងដាវយ៉ា ប្រើឲ្យមកការស្រុកកេងដាវជាក្រាកដ ។

ខ្លាតាំងសួរទុងបេងថា លោកនឹងឲ្យខ្ញុំធ្វើយដោះសាដូចម្តេច ។
ទុងបេងថា បើខ្លាសុក មកកេលោក ហើយនិយាយពីរឿងការស្រុក
ខេស លោកកុំគាលធ្វើយតបឲ្យសោះ ត្រូវធ្វើជាយំសោកខ្លឹកខ្លួលឲ្យភ្ញាំង
ខ្ញុំនឹងមកនិយាយទូនឯងជាថ្មីវិកៃខៃតាមតម្រេះប្រាជ្ញ ខ្លាតាំងអញ្ជើញ
ខ្លាសុកចូលមក ហើយតំនាប់គ្នាតាមគួរសម ខ្លាតាំងអញ្ជើញខ្លាសុក
ឲ្យអង្គុយទូន្មឹងគ្នា ខ្លាសុកក៏និយាយថា លោកជាមាព្រះថៅហៀនតេ
ហើយក៏ជាបួនថ្លៃថៅហ្វាយខ្ញុំទៀត នឹងឲ្យខ្ញុំអង្គុយស្មើតំនួរសម ខ្លាតាំង
អស់សំណើចហើយនិយាយថា អ្នកនឹងខ្ញុំជាមិត្តភក្តិកប់អានគ្នាមកតាំងដើម
ហេតុម្តេចបានជាអ្នកមកនិយាយបន្ទាបខ្លួនដូច្នេះ ខ្លាសុកឮដូច្នោះ ក៏
អង្គុយចុះហើយថា ខ្ញុំមកកេលោកគ្រានេះ ព្រោះស៊ុនគួនប្រើមកឲ្យការ
យកស្រុកកេងដាវ ឯលោកនឹងស៊ុនគួន ក៏បានជាបងថ្លៃនឹងបួនថ្លៃនឹងគ្នា
ហើយ ចូរយើញដោយសេចក្តីមេត្រី កុំឲ្យទាស់អញ្ជាស្រ័យគ្នា ចូរ
បង្វិលស្រុកកេងដាវឲ្យស៊ុនគួនចុះ លោកនឹងស៊ុនគួននឹងបានរួមចិត្តគំនិតជា
មួយគ្នាធ្វើការតទៅ ។

ខ្លាតាំងឮដូច្នោះ ក៏ធ្វើជាយំសោកខ្លឹកខ្លួល មិនបានធ្វើយតបថា
ម្តេចសោះ ។ ខ្លាសុកយើញដូច្នោះក៏សួតចិត្តសួរថា លោកយំសោក

ដោយហេតុអ្វី ? ។ ឮដូច្នោះហើយ ព្រះបាទអណ្តើកក៏ពោលទៅកាន់ព្រះបាទកូនថា ។ ខ្ញុំឯងមែនទៅមានការក្រោយនឹងក្រ កំដរការដើរចេញមកនេះយូរយ៉ាងណាស់ ទើបលួងលោមឮដូច្នេះថា ម្តាយចាំស្តាប់ជាយូរមកហើយ មិនឃើញថាមានសេចក្តីអ្វីសោះ អ្នកដឹងឬទេ ? ហេតុអ្វីបានជាកូនយំសោកដោយហេតុអ្វី ? ។ ឮសុកថា ខ្ញុំមិនយល់សោះ ។ ខ្ញុំឯងថា អ្នកមិនដឹងខ្ញុំនឹងពោលឲ្យស្តាប់ ពីរឿងឮពីឪឲ្យសំបុត្រសញ្ញាទៅដល់ស៊ុនតួនថា បើបានស្រុកសែសឈួនកាលណា នឹងបង្វិលស្រុកកេងដីវឲ្យស៊ុនតួនកាលណោះ ឥឡូវនេះឮដឿងជាហៅហ្វាយស្រុកសែសឈួននោះគឺជាបង់ជាតូជព្រះពជវង្សព្រះហៅហៀនតេជាបង់ក្រសែសលោហិតគ្នានឹងហៅហ្វាយខ្ញុំ បើនឹងលើកទ័ពទៅវាយស្រុកសែសឈួនហើយមនុស្សពាំងតួងនឹងនរហានិន្នាបាន បើនឹងស្នៀមទានទៅកងស្រុកកេងដីវ គំនាបស៊ុនតួនខឹងសម្បា បើនឹងបង្វិលស្រុកកេងដីវឲ្យទៅគំនឹងរកទីនៅពុំបានសោះ ហេតុនេះ បានជាហៅហ្វាយខ្ញុំយំសោកដូច្នេះ ។ ឮដូច្នោះក៏ធ្វើជាយំខ្លាំងច្រើនទៅទៀត ។

ឮសុកក៏មានចិត្តអាណិតអនាថជនប្រមាណណាស់ ទើបលួងលោមឮដឿងថា លោកកុំយំសោកពីការធ្វើអ្វីឡើយ ចូរតែតិនឹងខ្ញុំឯងតែម្នាក់ឯងឲ្យតែខាងស្រួលទៅចុះ ។ ខ្ញុំឯង ឃើញឮសុកចិត្តខ្លាំងក៏និយាយថា បើដូច្នោះ ចូរអ្នកអនុគ្រោះ យកសេចក្តីទុក្ខវេទនានេះទៅនិយាយប្រាប់ស៊ុនតួនឲ្យអាណិតបង្អង់សិន ។ ឮសុកថា ដែលខ្ញុំទៅ

ទិយាយខ្ញុំស៊ីនគួនខោះ កំប្រហែលជាបាន តែថាបើស៊ីនគួនមិនត្រូម តើលោកនឹងរៃគិតម្តេចទៅវិញ ។ ខុនបេនថា ចៅហ្វាយខ្ញុំកំដាប្អូនថ្លៃស៊ីនគួនហើយ ដែលថាស៊ីនគួនមិនយល់ត្រូមសោះនោះ ខ្ញុំមិនយើញផងសោះ ចូរអ្នកអនុគ្រោះទៅទិយាយដាបដោយល្អសុភាពចុះ ។ ឯខ្មោសុកនោះជាមនុស្សត្រង់កំគិតអាណិតអាសូរខ្មៅតិត្រូមខ្លួលពាក្យហើយកំលាខុនបេនចុះខ្លួកទៅស្រុកធសង់គុនវិញ ទើបចូលទៅដួចនឹងដាវើយហើយតណិនាតាមសំដីដែលខុនបេនទិយាយនោះឲ្យដាវើយស្តាប់ ។

ដាវើយនឹងតន្ត្រែដើងហើយថា ខ្មោសុកនេះចាញ់ប្រុជាខុនបេនទៀតហើយ ឯចិត្តខ្មៅពីនោះមិនមែនដួចមាត់ទិយាយទេ កាលខ្មៅពីនៅនឹងខ្មៅពៀវ កិតិតប្រខូសក់យខ្មៅពៀវនឹងដណ្តើមយកស្រុក ឥឡូវខ្មៅពីនឹងទៅយោគយល់ខ្មៅដៀងនោះដោយប្រយោជន៍អ្វី តែហាក់ថាមិនឲ្យស្រុកកេងដាវមកយើង ចាន់ជាក្លែងថាតាមទំនើងចិត្តដួច្នេះ ខ្ញុំជាអ្នកចាក់ក្លួយចាន់ខុក្លវែនាមកផង ខ្ញុំគិតចាន់កលទុជាយមក៏ងទៀត បើខុនបេនមានគំនិតគិតកិចកិតងំមិនរួចពីដៃយើង តែឲ្យអ្នកទស្សហ៍លែត្រឡប់ទៅស្រុកកេងដាវិញទៀត ខ្មោសុកថា កលទុជាយលោកគិតដួចម្តេច, ដាវើយថា អ្នកកុំបាច់ទៅប្រាប់ស៊ីនគួនឡើយ ចូរត្រឡប់ទៅស្រុកកេងដាវិញប្រាប់ខ្មៅពីថា ដែលខ្មៅពីមិនទៅយកស្រុកសែឈួនោះ ព្រោះខ្មៅដៀងជាសែជាមួយគ្នានឹងខ្មៅពី ខ្លាចមនុស្សចាំងពួងតហោនិទ្ធាកំ

ត្រូវហើយ ឥឡូវស៊ុខគួនប្រឹក្សាយល់ឃើញថា ខ្ញុំត្រូវលើកទ័ពទៅវាយយកស្រុកសែឈួនឲ្យបាន បើបានហើយកំនត់លើកឲ្យខ្លៅតា ដើម្បីខ្ញុំប្តូរយកស្រុកកេងជាវិញ ខ្លោសុកថា ដែលលោកគិតទៅវាយស្រុកសែឈួនខោះជាផ្លូវធ្ងាយដាច់ស្រយាលណាស់, ជាវិញឮដូច្នោះ កំអស់សំណើចហើយថា ខ្លោសុកខេះ ត្រង់ពេកណាស់ មិនមែនយើងខ្ញុំទៅវាយស្រុកសែឈួនដោយពិតខោះទេ យើងខ្ញុំបញ្ឆោតឲ្យខ្លៅតាគេញ៉ាចិត្តថា យើងខ្ញុំលើកទៅវាយយកស្រុកសែឈួនឲ្យ បើយើងលើកទៅដល់មុខស្រុកកេងជាវិការណា យើងខ្ញុំឲ្យទៅសុំស្បៀងខ្លៅតា។ មិនដាច់ខ្លួនកំនត់ចេញមកទទួលគួរសមខ្ញុំងយើង។ ត្រូវចាប់ខ្លួនខ្លៅតាសម្លាប់ចេញ ហើយយកស្រុកកេងដើងតែម្តង់ទៅ ខ្ញុំងបានសងសឹកដែលយើងចាញ់ប្រជ្ញាខ្លួងបេងតាំងខ្លួនអ្នកកំផុតពីសេចក្តីទុស។

ខ្លោសុកឮដូច្នោះ កំយល់ឃើញត្រូវ ទើបលាជាវិយើចុះខ្លួកទៅស្រុកកេងជាវិម្តង់ទៀត លុះទៅដល់ចាហានកំចូលទៅដំកបខ្លៅតាថា ខ្លោសុក មកវិក, ខ្លួងបេងកំនំយោយខ្ញុំងខ្លៅតាថា ដែលខ្លោសុកត្រឡប់មកគ្រានេះ មុខជាមិនទៅដល់ស៊ុខគួនទេ អាក្រក់ល្អតីជាវិយើតិតកល។ ចាយឲ្យខ្លោសុកមកបញ្ឆោតយើងជាពិតប្រាកដ បើខ្លោសុកចូលមកដល់ខ្ញុំងនិយាយការអ្វី ឲ្យក្រខ្លោកមើលមុខខ្ញុំសិន លុះប្រឹក្សាគ្នាហើយ ខ្លៅតាកំឲ្យទៅខ្លួលខ្លោសុកឡើងមកតំទាប់គ្នាហើយ ខ្លោសុកកំនិយាយថា

ខ្ញុំបានត្រឡប់ទៅស្រុកកាំងគាំង ថ្ងៃនិតនិមានទុក្ខសុខរបស់លោកឱ្យស៊ុន
គួនស្តាប់ត្រប់ប្រការ, ស៊ុនគួនក៏មានចិត្តអាណិតមេត្តាសសើរលោកថា
មានតម្រេះប្រាជ្ញាដ៏ឆ្លុះត្រង់ ស៊ុនគួនក៏ឱ្យហៅនាហ្មឺនមុខមន្ត្រីមកប្រឹក្សា
នឹងលើកកងទ័ពទៅកាយស្រុកសៃឈ្នួនដូចនេះលោក បើបានស្រុកសៃឈ្នួន
ហើយ នឹងបានប្តូរយកស្រុកកេងដ៏រឹងរឹញ, នាហ្មឺនចាំងតួងក៏យល់ឃើញ
ត្រូវត្រមគ្នាចាំងអស់ បានជាស៊ុនគួនប្រើខ្ញុំត្រឡប់មកដំកបលោកថា បើ
កាលណាលើកទ័ពទៅកាយស្រុកសៃឈ្នួននោះ គឺជាផ្លូវដាច់ស្រយាល
ឆ្ងាយណាស់ ខោះបើខ្វះភាតដោយស្បៀងអាហាររបស់អ្វីក្តី ឱ្យលោក
អនុគ្រោះផង ។

ខ្ញុំនិងឮដូច្នោះ កំញាក់មុខឱ្យខ្មៅតិចថា ដែលស៊ុនគួនមានចិត្ត
អាណិតមេត្តាដូច្នេះ គឺយល់ថា មានសេចក្តីទុក្ខក្តៅក្រហាយ បានជារិះ
រកឧបាយជួយជាពុះ ខ្មោតតិកំលើកដៃឡើងគំនាប់ហើយថា ដែលស៊ុន-
គួនមានចិត្តមេត្តាខ្ញុំ ចាំងអំបាលនេះ កំព្រោះខ្មោសុកជួយនិយាយ គុណ
របស់ខ្មោសុកនៅលើខ្លួនខ្ញុំក៏ជាខម្ងន់ណាស់ ។ ខ្ញុំនិងថា បើស៊ុនគួន
នឹងលើកកងទ័ពមកវិលាណា ខ្ញុំនឹងលើកគ្រប់គ្រួចេញទៅខួលនៅ
ក្រៅស្រុក ហើយនិយាយនឹងខ្មោសុកថា ឱ្យអ្នកត្រឡប់ទៅជ្រាបស៊ុន-
គួនចុះភា ដែលនឹងលើកទ័ពទៅកាយស្រុកសៃឈ្នួននោះ កុំឱ្យត្រួយគិត

ខ្ញុំនឹងស្បៀងអាហារឲ្យយ ។ ចៅហ្វាយខ្ញុំនៅអាយ ហើយជាប្អូនរៀងខ្លួនតូរមិនឲ្យខ្វះខាត ។ ខ្លោសុកកំមានចិត្តត្រេកអរណាស់ ។ ខ្លៅពីលុះអញ្ជើញខ្លោសុកចរកោគអាហារហើយ ខ្លោសុកកំលាត្រឡប់ទៅស្រុកធសង្គីតុនវិញ ។

ខ្លៅពីកំសួរខុនបេងថា ដែលខ្លោសុកមកនិយាយអំពាញ់មិញនេះ លោកគិតយើញប្រការម្តេចខ្លះ ? ។ ខុនបេងអស់សំណើចហើយថា ជីវិយគ្រានេះ មុខជាដល់នូវសេចក្តីស្លាប់ពុំខាន ព្រោះតម្រេះប្រាជ្ញាជីវិយគ្រានេះ សូម្បីតែក្មេងតូចមួយ ក៏គិតនឹងដឹងបាន គួរឬមកគិតបញ្ឆោតយើងជាមនុស្សចាស់ ។ ខ្លៅពីសួរថា គំនិតជីវិយគិតគោះដូចម្តេចខ្លះ ? ។ ខុនបេងថា ជីវិយរិះគិតការនេះ ដូចកាលព្រះចៅដំនហៀនកុងនឹងលើកទ័ពទៅវាយស្រុកខេក ផ្លូវឆ្លងស្រុកនឹទៅ ស្រុកចាំង ៣ ដំបន់នេះជាផ្លូវត្រូវលើគ្នា ព្រះចៅដំនហៀនកុងគិតប្រជុំទីប្រឹក្សាថា យើងនឹងលើកទៅវាយស្រុកខេកគ្រានេះ ខ្លាចចៅហ្វាយស្រុកនឹនឹងលើកទ័ពមកស្កាត់ផ្លូវតាមក្រោយ យើងមិនឲ្យសំការខេច ? ស៊ុនសេងជាខាម៉ឺនធំក្រាបទូលថា ចៅហ្វាយស្រុកនឹជាមនុស្សលោភស្រឡាញ់ទ្រព្យណាស់ សុំឲ្យព្រះអង្គរៀបគ្រឿងបណ្ណាការ ទឹងវៃមណីជីវិសេសសម្រាប់ស្រុកយើងនេះទៅឲ្យចៅហ្វាយស្រុកនឹ ដើម្បីទឹងខ្លួនផ្លូវទៅច្បាំងឯស្រុកខេកមុខជាទឹងបានដោយងាយ ព្រះចៅហៀនកុងថា វែកមណីសម្រាប់ខ្លួនគ

របស់យើងជាគ្រឿងស្លៀកសេសមានដំរៀរច្រើនណាស់ ដែលអ្នកទិញឲ្យ
យកទៅឲ្យពៅហ្វាយស្រុកនឹងនោះ ទោះបីយើងទិញរាយយកបានស្រុក
ខេត កំមិនទាន់ស្មើដំរៀទិញតែរបស់យើងនោះឡើយ ស៊ុនសេងទូលថា
សុំកុំឲ្យព្រះអង្គត្រាយព្រះទ័យឡើយ ដែលយើងទិញយកតែរៀងៗពៅឲ្យ
ហ្វាយស្រុកនឹងនោះ គឺបីដូចជាយកទៅឆ្លើយក្បាលកុកដូចនៅក្នុងដៃព្រះហ្ងាំង
ដូចគ្នា យើងរាយយកស្រុកខេតបានការណា ទឹងលើកតង់តែគ្រឿងប៉ម
មករាយយកស្រុកនឹងទៀត គឺទឹងបានដោយងាយ សូម្បីតែទឹងគ្រឿង
បណ្ណាការទាំងឡាយ គឺតង់នៅជារបស់យើងទាំងអស់ ។

ហ៊ានឡើងទីប្រឹក្សា ក៏ទ្រើយតបទៅស៊ុនសេងថា: លោកកុំគាល
មើលងាយពៅហ្វាយស្រុកនឹងនោះឡើយ ព្រោះកុងជីតីដែលជាមាម៉ឺនធំក្នុង
ស្រុកនឹង មានតម្រេះច្រើនជាងនឹងរៀងណាស់ មុខជាដំណាស់មិនឲ្យពៅហ្វាយ
ស្រុកនឹង ខ្ជិលតស៊ូការបណ្ណាការរបស់យើងទេ ។ ស៊ុនសេងថា កុង-
ជីតីមានតម្រេះច្រើនតិចតួចមែនហើយ ប៉ុន្តែ ខ្លាចអាជ្ញាពៅហ្វាយស្រុក
នឹណាស់ ព្រោះពៅហ្វាយស្រុកនឹជាមនុស្សលោភមិនដឹងខុសត្រូវ ។

ព្រះពៅដឹងហឿនកុង ទ្រង់ព្រះសណ្តាប់ក៏ចាប់ព្រះទ័យយល់ត្រូវ
ទើបរៀបគ្រឿងបណ្ណាការ ទឹងតែមណីដ៏មានតម្លៃបញ្ជូនទៅឲ្យពៅហ្វាយ
ស្រុកនឹតាមពាក្យស៊ុនសេង ។ ពៅហ្វាយស្រុកនឹ ឃើញគ្រឿងរបស់មិន
ធ្លាប់តិចាណា ក៏ត្រមះខ្ជិលតែតាំងនោះ ។ កុងជីតីក៏និយាយទឹង

ទៅហ្វាយស្រុកនីថា ដែលលោកខ្ញុំលួចគ្រឿងបណ្ណាការទុក ដើម្បីនឹងឲ្យព្រះទៅជិនហៀនកុង លើកទ័ពទៅវាយស្រុកខេកនោះមិនគួរសោះ ព្រោះស្រុកខេកជាកម្ចាំងរបស់យើង បើព្រះទៅជិនហៀនកុងវាយយកបានហើយ ក៏នឹងលើកមកវាយយកស្រុកយើងខ្មែរបានដោយងាយ ។ ទៅហ្វាយស្រុកនីមិនស្តាប់ ក៏ស្រែកតំហកឲ្យកុងជីតី ។

តមក ព្រះទៅហៀនកុង ក៏លើកទ័ពចំលុះស្រុកនីទៅវាយយកស្រុកខេកបាន ហើយក៏លើកទ័ពត្រឡប់មកវាយយកស្រុកនីបានខ្មែត ។

គ្រានោះដាវយី គិតកលឧបាយនឹងលើកទ័ពទៅវាយស្រុកសៃឈួនឲ្យយើង ក្រុងថ្នាំនឹងឲ្យយើងជឿទុកចិត្ត បើដាវយីលើកកងទ័ពមកដល់ស្រុកយើងហើយ លោកនឹងនាំស្បៀងអាហារទៅជួយឲ្យសេនាពាហនពាំងនោះ មុខជាដាវយីនឹងចាប់លោកសម្លាប់ដណ្តើមយកស្រុកកេងដាវតែម្តង ខ្ញុំគិត ក៏សួរខុងបេងថា បើដូច្នោះយើងនឹងគិតដូចម្តេច? ខុងបេងថា លោកកុំព្រួយឡើយ ការគ្រានេះជាធុរៈលើខ្លួនខ្ញុំ នឹងរិះគិតទុកឲ្យព្រមជាស្រេច បើដូចលើកអង្គប់ជាក់ខ្លា ធ្វើដុះជាក់ត្រី មិនត្រូវចាំយើញខ្លានឹងត្រីផុសឡើងទើបតាំងធ្វើការនោះមិនបានទេ, ឯដាវយីគ្រានេះ មុខជានឹងចាញ់ប្រាជ្ញារបស់យើង ត្រង់ចិត្តស្តាប់ជាប្រាកដ ។

ខុងបេងក៏ឲ្យហៅដូឡុងមកបង្គាប់ថា ការយើងនឹងបានធ្វើតបនឹងដាវយីនោះយើញចង្អៀតចង្អល់តែគាលគ្រាម្តងនោះទេ អ្នកត្រូវឲ្យអ្នកទៀប

ប៉ុន្តែ ភាហានខុកឲ្យត្រមង់ដោយគ្រឿងសស្ត្រាវុធ ឡើងក្បួនសេនបន្ទាយឲ្យ
ម៉ាំមួន បើដីយើលើកកងទ័ពមកដល់មុខស្រុកណាណា ត្រូវការសួរកេ
យើងទីធីឡើតិ អ្នកចូរតបទ្វើយតាមពាក្យដែលយើងផ្តាំខុកគ្រប់ប្រការ ។
ដូឡ្ហឹងខួលពាក្យបណ្តាំខុនបងហើយ ក៏ទៅរៀបចំត្រៀមភាហានតាម
ពាក្យខុនបងបង្គាប់, រួចសរសេរសំបុត្រមួយច្បាប់ប្រាប់ទៅឡៅហង ឧីង
គួនបើង ហើយផ្តាំថា អ្នកតាំង ២ ចូរលើកភាហានទៅចាំស្កាត់ផ្លូវខាង
លើទឹក ត្រង់ផ្លូវឧីងទៅលើស្រុកសែឈួនោះ បើយើញដីរយើលើកទ័ព
មកដល់មុខស្រុកកេងដីវ ចាន់ញគួនអ៊ូនិយាយបញ្ជាចិត្ត ដីរយើកំឧីងគិត
ទៅកយស្រុកសែឈួនដោយមាន: ទៅចូរយកសំបុត្រនេះ ទៅឲ្យដីរយើ ។

ឡៅហងឧីងគួនបើង ក៏ខួលពាក្យបណ្តាំគំនាប់លាខុនបងចេញ
ទៅ ហើយខុនបងក៏ឲ្យគួនអ៊ូលើកភាហានទៅតាំងនៅផ្លូវស្រុកតាំងឡង
ឲ្យខៀវហ៊ុយទៅតាំងនៅស្រុកដីកុយ ឲ្យហងតុងទៅតាំងនៅឈួងតាំង
អ័ន ឲ្យអ៊ុយអៀនទៅតាំងនៅដំបន់អ៊ីឡង ផ្លូវដៃតស្រុកកេងដីវទាំង ៤
អន្លើ ហើយផ្តាំថា បើអ្នកពល់គ្នាឃើញដីរយើលើកមកដល់ដើងកំផែង
ក៏ឲ្យភាហានស្រែកហ៊ោថា ឧីងចាប់ដីរយើ តែត្រូវថាតែមាត់ មិនត្រូវទៅ
ធ្វើអន្តរាយអ៊ូឡើយ តាំង ៤ នាយក្នុងហើយ ក៏ខួលតាមបង្គាប់គំនាប់លា
ចេញទៅ ។

X

X X

សាមកុកខ្សែ ៤៨

តាំងពីដីវយើលើកទ័ពទៅតាមផ្លូវស្រែកកេងដីវ ចាញ់កលទុងចេង ហើយឈ័ចត្តប្រែះថ្នើមស្ងាប់. ទុងចេងទើសួរសេពដីវយើ ដួចនឹងបាំងចិត្ត ។ ទើនៅនឹងឡើត, ចូរឲ្យសំបុត្រទៅហៅខ្លួនមកចេង ។ លើកទ័ពទៅ លុះដល់ទាហានចូរជួចាប់ខ្លួនមកចេងជាន ។

ឯខ្សោសុក កាលទៅដល់ស្រុកឆសង៏គុន កំចូលទៅជួបនឹងដីវ-យើ ហើយអធិប្បាយកាំយរឿងត្រាប់សេចក្តី តាមពាក្យទុងបេងនឹងខ្សោ ពីនិយាយនោះត្រចំប្រការ ។ ដីវយើឮដូច្នោះ កំទះដៃសើចហើយថា ទុងបេងម្តងនេះ មុខជាចាញ់កលរបស់យើងហើយ យើងនឹងបានសង សឹកទុងរបេងក្នុងគ្រានេះវិញ អ្នកចូរនាំយកពតិមាននេះ ទៅជំរាបសុន-គួនឲ្យជ្រាបផងចុះ ។ ខ្សោសុកកំលាដីវយើ ទៅជួបនឹងសុនគួន ហើយ បានពណ៌នារឿងកំវ្រាប់សព្វប្រការ ។ សុនគួនបានឮសព្វត្រប់គំមាន អំណរណាស់ ទើបចាត់ប្រើខ្សៅគៅឲ្យលើកទាហានទៅជួយកាជដីវ-យើ ។ ដីវយើក៏រៀបចាត់ការប្រមូលសេនាទាហានបាន ៩ ម៉ឺននាក់ ចែកចេញជា ៤ កង ឲ្យតាំងឡើងលើកទាហានជាកងមុខ ឲ្យឈ្មោះសេង ឆឹងគេងហង៏ជាកងកណ្តាល ឲ្យឡេងចឹងឆឹងលីបងជាកងក្រោយ ខ្លួន ដីវយើនឹងខ្សៅគៅ រួមបញ្ជាលទាហានគ្នាជាកង៏ឥតហ្មង ។ លុះបាន ប្រុស្ស កំចុះខ្លួនចម្បាំងលើកទ័ពចេញពីស្រុកឆសង៏គុនទៅ ។

ខុងជេងដឹងដំណឹងថា ដាវយើលើកកងទ័ពមកហើយ ក៏ហៅបីតុកមកបង្គាប់ថា អ្នកចូរស្រួតទៅចាំទទួលដាវយើនៅមាត់ឈូងហែវទៅចុះ បើដាវយើសួរកេរយើនទីនេះឬទេភិ ត្រូវប្រាប់ថា ចេញទៅម្រមូលគ្រួសារចាំទទួលនៅក្រៅស្រុកកេងដាវហើយ ឲ្យដាវយើស្រួតលើកទ័ពទៅចុះ ។ បីតុកទទួលប្រសាសន៍ខុងជេងហើយក៏លាចេញទៅ ។ ខុងជេងក៏នាំខ្លៅតិទៅដើរលេងលើកំភូលក្នុងក្បែរស្រុកកេងដាវ ។

លុះដាវយើលើកទ័ពទៅដល់មាត់តំពន់ឈូងហែវទៅ ក៏សួរគាហានទៅទីនោះថា ខ្លៅតិឲ្យអ្នកណាមកចាំទទួលយើងខ្លះឬទេ ? ថាមិនមានផុតមាត់ ទទួលគាហានចូលទៅដំណាលថា ខ្លៅតិឲ្យបីតុកមកចាំទទួលលោក, ដាវយើក៏ឲ្យហៅបីតុកចូលមក ។ បីតុកគំនាប់ហើយថា ខ្លៅតិទៅហ្វាយខ្ញុំបានឮថា លោកលើកកងទ័ពមក ក៏មានចិត្តសោមនស្សត្រេកអរណាស់ ហានត្រៀមការទាំងភួងទុកស្រេចហើយ តែឬវេចេញតាំងកេងលៀងនៅក្រៅស្រុក ចាប់តែងស្រា ចាំចាក់ជូនលោកពិសាប្រើខ្ញុំបានឲ្យមកចាំដំណលោកនៅទីនេះ សុំឲ្យលោកស្រួតលើកទ័ពទៅមុខចុះ ។

ដាវយើឮដូច្នោះក៏អរណាស់ ទើបនិយាយទីងីបីតុកថា យើងលើកកងទ័ពមកគ្រានេះ គឺជាកិច្ចព្រះបេស៍ទៅហ្វាយអ្នកឯងទេ ឲ្យអ្នកស្រួត

ត្រឡប់ទៅជ្រុងប់ឡៅតាថា ឲ្យត្រៀមបំរុងស្បៀងអាហារដែលត្រូវបញ្ជូនទៅឲ្យកងទ័ពបរិភោគ ។ ប៉ុន្តែកាត់នាប់លា ។ ជាវយើលើកទ័ពទៅដល់ឈូងកាងអន កំមិនឃើញមានមនុស្សម្នាមកចាំទទួលដូចពាក្យប៉ុន្តែជ្រុងប់សោះ កំតិតមន្ទិលប្លែកក្នុងចិត្ត ទើបស្រួតកងទ័ពទៅដល់ស្រុកកេង. ជាវ ជិតកំផែងស្រុកឃើញស្ងាត់សូន្យ គំរប្រែតហានឡើងទៅស៊ើបស្តាប់ការ ក្នុងស្រុកកេងដឹង, ឃើញតែទ្វារស្រុកចំទំជិត មិនឃើញមានមនុស្សម្នាដើរទៅមកសោះ ឃើញតែទន់ស ២ ដើម ដោតទុកលើសើន, ជាវយ សង្ឃឹយណាស់ កំឲ្យចតទូកចម្ការទុកនៅទីនោះ ហើយឡើងគោកជិះសេះនាំគាំឡើង ឈើសេង តេងហង នឹងតហាន ៣.០០០ នាក់ចូលទៅដល់ដើងតំផែងស្រុកកេងជាវ ប្រើតហានចូលទៅស្រែកហៅអ្នកចាំទ្វារឲ្យបើកទទួល ។ នាយទ្វារស្រែកសួរមកវិញថា អ្នកឯងឈ្មោះអ្វី? មានការអ្វីមកនេះ? ។ តហាននោះឆ្លើយថា យើងជាតហានជាវយ ឥឡូវជាវយើលើកកងទ័ពមកដល់ហើយ ។

ដូឡូងកំឡែកយឈ្មោះ តង ខូងស្តេ សញ្ញាហៅតហានតាំងតួងដែលកាន់គ្រឿងសាស្ត្រាវុធនៅលើសើនបន្ទាយ ឲ្យឈរឡើងត្រមគ្នា ហើយកំស្រែកថា លោកលើកកងទ័ពមកនេះ ត្រូវការលើកហួសទៅឯណា ។ ជាវយើស្រែកតបថា អ្នកឯងមិនដឹងទេឬ? យើងលើកទៅកាយស្រុកសែឈួនឲ្យទៅហ្វាយអ្នកឯង ។ ដូឡូងថា លោកគិតគល.

ទេជួយយាងត្រេះពេវដ៏នេហ៊ុនកុន ខ្ញុំផ្លូវពេវហ្វាយស្រុកដ៏ទៅកាយស្រុកខេកនោះឬ? ខុដ៏បេងដ៏ងអស់ហើយ ចានជាប្រើយើងឲ្យលើកតាហានមកនៅរក្សាសើនបន្ទាយ ចាំដំកបឲ្យលោកគ្រាប ដែលលោកនឹងទៅកាយស្រុកសែឈួននោះ កំឲ្យស្រួតទៅកាយចុះ បើស្រុកសែឈួនវិនាសហើយ ខ្ញៀតពៅហ្វាយខ្ញុំកំមិនលុបសេចក្តីអៀនខ្មាស ត្រោះខ្ញៀតជឿនឯងខ្ញៀតជាជនជាប់លោហិតគ្នា ចានជាផ្តាំឲ្យយើងដំកបលោកថា បើលោកកាយស្រុកសែឈួនចានដូចបំណងមែន ខ្ញៀតឯងខុដ៏បេងនឹងបង្វិលស្រុកគេងដ៏ឲ្យលោកវិញ ហើយកំនាំសេនាតាហានឯងគ្រួសារទៅនៅក្នុងព្រៃ មិនរិះគិតធ្វើការសង្គ្រាមតទៅទៀតទេ ។

ដ៏យើញដូច្នោះ កំពើងយើញថា ខុដ៏បេងដ៏ងខ្លួន ចានប្រុងប្រយ័ត្នការខុតព្រមអស់ហើយ កំញាក់សេះវិលថយទៅក្រោយ ។ ខ្លួលគួនអ៊ូ, ខៀវហ៊ុយ, ហង់តុង, អ៊ុយអៀន ដែលខុដ៏បេងឲ្យលើកតាហានទៅតាំងបង្គំបំទៅតាំង ៤ ផ្លូវនោះ កំលើកមកប្រជុំព្រមគ្នាហើយស្រែកថា ឲ្យចាប់ខ្លួនដ៏យើងឲ្យចាន ។ ដ៏យើញដូច្នោះ ក្រុងឡកមើលទៅក្នុងព្រៃមិនដឹងថា តាហានច្រើនឬតិចប៉ុន្មាន ចានឮតែសំឡេងស្រែកហ៊ោចម្ងាយផ្លូវប្រហែល ១០០ សិន (៤ គ.ម.) ដ៏យើទឹកតូចចិត្តដោយចាញ់តម្រេះខុដ៏បេង, តិសត្រាញដែលត្រូវបួសតិមុនោះ កំកំរើតរំជួលសត្វសតិង្គកាយ កំឮក់តិលើសេះសន្ទប់ចាត់ស្មាតើ, ពួកតាហានកំស្ទុះទៅ

គ្រាហ៍តាំងពីដាក់កូនមក. កាលប៉ើដាវយើដឹងខ្លួនវិញហើយ ពាហានតាំង
ពួនក៏ដំណាលថា យើងខ្ញុំឃើញខុនបេនទំនងឡៅតា ឡើងពៅអង្គុយផឹកស្រា
សប្បាយលើកំពូលភ្នំប្រចស្រុកកេងដាវ ។

ដាវយើញដូច្នោះ ក៏ទឹកភ្នាញ់កន្ត្រំចិត្តពាន់ប្រមាណណាស់ គិតថា បើ
លើកពាហានពាន់ពាលំណាយ ពៅវាយយកខ្លួនឡៅតាខុនបេន ក៏មិនដឹងកលទុបាយ
ដែលខុនបេនទំនងគិតដូចម្តេចខ្លះ គិតហើយក៏និយាយ
ទំនងពាហានតាំងពួនថា ដែលខុនបេនមើលងាយប្រមាពយើង មកធ្វើការ
ចំអកបញ្ជាំចិត្តយើងដូច្នេះ បើយើងនឹងមិនពៅវាយយកស្រុកសែឈួន
នោះក៏មិនបាន ព្រោះយើងបានបញ្ជូញវាចូរពៅហើយ ត្រូវតែលើក
កងទ័ពពៅវាយយកស្រុកសែឈួនឲ្យបាន ។ ខណៈនោះ ខុលស៊ុន
គួនប្រើស៊ុនយើជាប្អូនឲ្យលើកពាហានដំនួយមកជួយដាវយើ ។ ក៏ឲ្យស៊ុនយើ
ចូលមក ហើយពណិនាសេចក្តីដែលខុនបេនធ្វើត្រឡប់ត្រឡិន ឲ្យស៊ុន
យើស្តាប់គ្រប់ប្រការ ហើយដាវយើទំនងស៊ុនយើក៏ឲ្យពាហានចេញទូកចម្បាំង
បីនឹងទំនងពៅវាយយកស្រុកសែឈួន លុះពៅដល់ដំបន់ចាំយើវ ខុលឡៅ-
ហានទំនងគួនបើង ដែលលើកពាហានពៅស្កាត់ចាំតាំលើទឹកនោះ ឃាតស់-
បុត្រខុនបេនពៅឡើងដាវយើ ។ ខុលស់បុត្រនោះមកមើលឃើញសេចក្តីថា
« ខុនបេនឲ្យតាមកដល់ដាវយើ ដែលជាទីប្រឹក្សាធំបំផុតក្នុងស្រុកគាំនតំង

ត្រោះខ្លួនខ្ញុំតាំងតាំងពីឃ្លាតចាកអ្នកមកកំយុះលង់ហើយ តែនៅមានគំនិតគិតដល់ដួងមេត្រីនឹងអ្នកត្រប់ពេលមិនដែលភ្លេចសោះ ត្រានេះ ខ្ញុំដឹងថា អ្នកនឹងលើកកងទ័ពទៅវាយស្រុកសៃឈ្មួននោះ ស្បៀងអាហារនឹងសេនាពាហានក៏មានបរិបូណ៌ សូម្បីខ្លាំងដៀង មិនស្មើមានតម្រេះច្រើនជាក់គង់នឹងការពារក្សាស្រុកបាន ដែលអ្នកនឹងលើកទ័ពទៅវេលានេះ ផ្លូវកន្លាងស្រយាលឆ្ងាយណាស់ បើនឹងប្រែផ្លាស់ជញ្ជូនស្បៀងអាហារកំលំបាក, មួយទៀត ចូរនោះ ចាប់ដើមតាំងពីទ្វេបសេនាពាហាន ៨៣០.០០០ នាក់ កាលត្រាមុន កំសុំនហួសចិត្តគិតតែនឹងសង្គ្រាមវិញមិនរលត់សោះ, ពេលនេះបើដឹងថា អ្នកលើកទ័ពទៅខាងណោះ ចោះបង់ស្រុកទៅទំនេរដូច្នេះ កំនឹងរិះគិតលើកទ័ពមកវាយស្រុកកាំងតាំងកុំឲ្យដឹងខ្លួន ចោះបើសុំនគួនទៅឯអាយកំមិងងាយតស៊ូជាមួយចូរួចបាន, ស្រុកកាំងតាំងកំនឹងរួចអាសារបានទៅចូរួចជាក្រុកដ ខ្លួនខ្ញុំនឹងអ្នកកំបានសន្ធតចិត្តជាមេត្រីនឹងគ្នាមកហើយ បើនឹងនៅស្ងៀមកន្តើយមិនយាយកំដូចជាចាំមើលបំណាំ ចាំឲ្យធ្វើទុសស្រាប់តែខុសដៃត្រូកអាដូចជាតុំគួរសោះ ហេតុនេះ បានជាខ្ញុំដួយដាស់តឿនស្មានតើ ចោះបើជឿឬកុំជឿក៏ស្រេចនូវចិត្តអ្នកចុះ" ។

(នៅមានត)

រឿងត្រៃថ្នដ៏ចិន

លោក ភ័ក្ត្រ.ប៊ុនធ ប្រែរៀបរៀង

(តមក)

ក្នុងគេលនោះ នៅក្នុងរាជធានី, មានតាចាស់ម្នាក់ជាអ្នកក្រីក្រ លំបាកគាត់យ៉ាកពន់ពេក ។ គេលព្រឹកព្រហាម, តាចាស់នោះក្រោកពីដំណេក, ទៅពីទ្វារផ្ទះមួយទៅទ្វារផ្ទះមួយ, ដើម្បីជាស់មនុស្សប្រុសស្រីពាំនាំយកឲ្យចូលទៅក្នុងព្រះវិហារសូត្រធម៌ តាចាស់កំពុងដើរតាមវិថីរាជធានីគឺស្រាប់តែមានវត្ថុអ្វីមួយជ្រុះពីលើមេឃមកដល់ដី តាត់បានរើសខ្លួវត្ថុនោះយកមក គឺគ្រឿងទ្រង់ប្រកបដោយលំអអស្ចារ្យ ។ តាចាស់នោះក៏នឹកក្នុងចិត្តថា: "គ្រឿងទ្រង់នេះ គឺជាអំណោយព្រះអាទិទេពដែលលោកបវរិញ្ញាគចំពោះខ្ញុំជាផលកុសល ដែលខ្ញុំបានបំពេញជាច្រើនឆ្នាំនោះឯង" ។ តាចាស់ក៏យកគ្រឿងទ្រង់នោះមកកាន់គេហដ្ឋានរបស់គាត់ ដោយសេចក្តីសោមនស្សជាខ្លាំង ។

តាមទំនៀមក្នុងគេលល្ងាច តួកមហាជនតែងចូលទៅក្នុងព្រះវិហារដើម្បីសូត្រធម៌ ។ គេលនោះតួកភាជអាមាត្យក៏ចូលទៅពិនិត្យដោយស្ងៀមស្ងាត់ខ្លួវែងលៀកបំពាក់មនុស្សពាំនោះ, គឺស្រាប់តែឃើញតាចាស់ម្នាក់មានសំលៀកបំពាក់ដ៏ប្រណិត តែមានប្រឡាក់ដោយប្រេងខ្លា

ស្ងួត ។ ពួកជាអាមាត្យក៏ចាប់ខ្លួនតាចស់នោះយកមកថ្វាយព្រះមហា-
ក្សត្រ ។ ព្រះមហាក្សត្រទ្រង់ត្រាស់សួរថា: "ម្តេចតាឯងមានភោគៈ
ប្រឡាក់សុទ្ធតែប្រេងស្អិតភ្លាំដូច្នេះ ?" ។

តាចស់ក្រាបបង្គំទូលថា: "សូមទ្រង់ព្រះករុណាជ្រាស, សំលៀក
បំពាក់នេះប្រឡាក់ដោយប្រេងស្អិតភ្លៀតាំងពីមុន ខ្ញុំលព្រះបង្គំជាខ្ញុំបាទ
រើសនៅវាលជាន់ ។ សូមឲ្យឆ្លើយព្រះបាទជ្រាប ។

ព្រះមហាក្សត្រ ទ្រង់មិនជឿនូវពាក្យតាចស់នោះសោះឡើយ ទ្រង់
បង្គាប់ពួកជាអាមាត្យឲ្យចាប់ខ្លួនតាចស់យកទៅឃុំក្នុងឥន្ទនាគារ ។ ក្រោយ
ដែលគេបានធ្វើការណកម្មដល់តាចស់តាមជងវិថីនានា ដើម្បីនាំតាចស់
ទៅកាន់ទីសម្លាប់ ដំណឹងនេះក៏លាន់ឮទ្ធឹងាសគេញប្រទេស ។ មហា-
ជនក៏តាំងអ្នកណាន់តាន់តាប់ទៅកាន់ទីនោះ ព្រោះមានបំណងចង់
ឃើញបុរសគ្មាហានដែលហោះទៅលើអាកាស បានទៅរួមសេដាមួយ
ព្រះអង្គម្ចាស់ក្សត្រី ។ លុះមហាជនក្រឡេកឃើញតាចស់ទៅវិញ, ក៏
ពុំជឿថា តាចស់នេះ ជាវីរបុរសអាចហោះឡើងទៅលើអាកាសបាន
សោះឡើយ ហើយតាចស់នេះ គឺគេចាប់ដោយកន្តច្រឡំពុំមាន ។
ព្រះអង្គម្ចាស់ក្រោយដែលទ្រង់ត្រេះសណ្តាប់ធ្នាក់ពាមហាជនសោសត្រប់ ។
គ្នា, ទ្រង់ក៏តង់លើសេះឈើហោះចុះមកកាន់ទីដែលគេបម្រុងនឹងប្រហារ
ជីវិតតាចស់នោះ ដោយទ្រង់មិនចង់ឲ្យអ្នកស្មូតត្រង់ស្លាប់ដួសព្រះអង្គ

សោះឡើយ, លុះយាងដល់ទីនោះ ព្រះបន្ទូលថា:

"កុំធ្វើខ្ញុំឯកម្មតាបសនេះ, តាត់គ្មានកំហុសអ្វីទេ; កំហុសនេះ ជាតាត់មកលើខ្ញុំខ្ញុំ; ខ្ញុំនេះឯងបានទៅគាន់មហាជ្ឈាសាទព្រះនាងដែលស្ថិតនៅលើអាកាស! តើខ្ញុំនេះឯងបានទៅរួមរសជាមួយព្រះអង្គម្ចាស់ក្សត្រ! តើខ្ញុំនេះហើយ ដែលមានគ្រឿងទ្រង់ប្រឡាក់សុទ្ធតែប្រេងស្អិតៗ, ចូរលោកជាក់ឯកម្មមកលើខ្ញុំវិញ! ហើយលែងតាបសស្លូតត្រង់នោះចុះ។

នាយតេជ្ឈាតតំបន្ធន់ធ្វើតាមកម្មផ្សេង។, បានចាត់អ្នកបម្រើម្នាក់ឲ្យទៅក្រាបបង្គំទូលព្រះរាជាថា:

"មានបុរសក្លាហានម្នាក់បានមកសុំឲ្យគេធ្វើឯកម្មជំនួសតាបស ដែលវាបានទិយាយឲ្យគេវាថា កំហុសនោះខ្លួនវាបានប្រព្រឹត្ត, មិនមែនតាបសនោះទេ, តើព្រះមហាក្សត្រទ្រង់មានព្រះរាជឫឲ្យធ្វើឯកម្មបុរសឬតាបស?" ។

ព្រះមហាក្សត្រទ្រង់មានព្រះរាជឱង្ការថា: "ធ្វើឯកម្មចំពោះអ្នកណាដែលខ្លួនថា ខ្លួនបានប្រព្រឹត្តបទទ្រង់ឆ្នោះចុះ"។

នាយតេជ្ឈាតលែងតាបសហើយតំយែកខ្សែមកចងព្រះសូរ៉ងព្រះអង្គម្ចាស់វិញ។ តែព្រះអង្គម្ចាស់ទ្រង់លោតទៅលើព្រះទីនាំងសេះឈើហោះទៅលើអាកាសបាត់, ឯនាយតេជ្ឈាតយកខ្សែចងទេ ឥតជាប់សោះឡើយ។ ព្រះមហាក្សត្រដោយទ្រង់យល់ថា ទ្រង់មាន

កង់តាដ៏មានមហិទ្ធិឫទ្ធិ, មានកាដអាមាត្យជាច្រើន, ម្តេចតំបាត្យាំងបាក
មនុស្សម្នាក់ដូច្នេះ! ទ្រង់ព្រះតម្រិះយ៉ាងនេះ, ឃានជាទ្រង់ព្រះពិរោធ
ជាខ្លាំង ។

ព្រះអគ្គមហេសីទ្រង់ប្រថាប់លើសេះហោះទៅដល់មហាប្រាសាទព្រះ
នាងហើយ ទ្រង់មានព្រះបន្ទូលថា: "នុប្អូនសំឡាញ់បងអើយ សេចក្តី
ស្នេហានៃយើងតាំងពីនោកំកាន់តែខ្លួយជាពីរោលទៅក្រៅ, យើងមិន
អាចរស់នៅដោយឡែកពីគ្នាបានទេ, តែព្រះវរបិតាអូនបានជ្រាបសព្វ
គ្រប់ហើយ អំពើអាក្រក់របស់យើងមិនអាចនឹងឲ្យព្រះមហាក្សត្រជាព្រះ
វរបិតាអូនអត់ទោស ប្រាសប្រណីបានឡើយ, អនុញ្ញាតឲ្យបងដូនបង្ហា
ដែលត្រូវដោះស្រាយកងពេលនេះ តែបងត្រូវតែនាំអូនទៅនៅឯប្រទេស
ព្រះវរបិតាបង, បងយល់ថា ព្រះវរបិតាបងមុខជាព្រះអង្គខ្លួលអូនដោយ
សោមនស្សយ៉ាងក្រៃលែង" ។

ព្រះនាងទ្រង់មានបន្ទូលថា "ទ្បុំម្ចាស់ សូមប្រគល់កាយថ្លាយ
ជីវិតចំពោះព្រះបង, ព្រះបងនាំអូនទៅណា, អូនសុខចិត្តតែតាមព្រះបង
ជាដាច់ខាត" ។

ព្រះអគ្គមហេសីនឹងព្រះនាងទ្រង់តង់លើតាដំឈើយាងចេញពីមហា-
ប្រាសាទជាប្រញាប់ ។ ការហោះហើរទៅនោះបានប្រព្រឹត្តទៅអស់
កាលដំយូរ, ស្រាប់តែព្រះនាងមានព្រះបន្ទូលថា: "ព្រះបង! ទ្បុំម្ចាស់

ក្មេងស្នងតាំងគ្រាប់តែរ ដែលព្រះវរបិតាព្រះរាជទានចំពោះខ្ញុំម្ចាស់ ដើម្បីទុកឲ្យខ្ញុំម្ចាស់ធ្វើជង្វាយថ្វាយព្រះវរបិតាមាតាក្មេក នៅថ្ងៃធ្វើពិធីព្រះរាជសមរស ។

ព្រះអង្គម្ចាស់ទ្រង់មានព្រះបន្ទូលថា: "យើងមកឆ្ងាយហើយ, ខុកស្នងនៅនោះចុះ, កុំអូនវៃល់អ្វី!" ។

ព្រះនាងទ្រង់មានបន្ទូលតបទៅវិញថា: " មិនបានទេព្រះអង្គ! ខ្ញុំម្ចាស់ត្រូវតែថ្វាយព្រះវរបិតាមាតាក្មេក នូវជង្វាយមួយជាប្រសើរក្នុងពេលដែលខ្ញុំម្ចាស់ចូលទៅក្នុងព្រះបរមរាជវាំងជាលើកដំបូង ។ គេអាចរិះគន់ថា ខ្ញុំម្ចាស់គ្មានសុជីវធម៌, ឥតសណ្ដាប់ធ្នាប់ " ។

ព្រះអង្គម្ចាស់ទ្រង់បណ្ដោយតាមព្រះហឫទ័យព្រះនាង, ទ្រង់មួលក្អូនសោងាច្រើន, ហើយព្រះទីនាំងនោះចុះមកដល់ដី ។

ព្រះអង្គម្ចាស់ទ្រង់មានបន្ទូលថា: " បងចាំអូនទៅទីនេះ, ចូរអូនប្រញាប់ទៅយកស្នងនោះ ដោយគន់លើតាដីនេះយ៉ាងប្រញាប់ប្រញាល់"។

ក្រោយដែលបានឮដូច្នេះ, ព្រះអង្គម្ចាស់ស្ត្រី កំគន់លើអស្សតរហារទៅលើអាកាសភ្លាត់ ។

ក្រោយដែលព្រះអង្គម្ចាស់យាងចេញអំពីមហាប្រាសាទជាមួយនឹងព្រះនាងភ្លាត់, ពួករដ្ឋមន្ត្រីបានចូលមកគ្រាបបង្គំគាល់ព្រះមហាក្សត្រិយ៍ដែលកំពុងតែគេងជាយូរនឹងខ្លាំង តាល់តែភ្ញាក់ដឹងស្មារតី ។ ពួករដ្ឋមន្ត្រី

កំធ្វើព្រះមហាក្សត្រឲ្យដឹងព្រះអង្គឡើងវិញ ។ ព្រះអង្គទ្រង់ទឹកទៅព្រះ
រាជបុត្រីភ្លាមមួយរំពេច ។ ទ្រង់យាងទៅកាន់មហាប្រាសាទដែលស្ថិត
នៅឰដ៏អាកាស មិនឃើញព្រះនាងគង់នៅទីនោះសោះ ។ ស្រាប់តែ
ក្រោយបន្តិចមកឃើញព្រះនាងទ្រង់គង់លើតាដំរីហោះវិលត្រឡប់មកមហា
ប្រាសាទវិញ ។ ក្នុងពេលនោះ, ព្រះអង្គទ្រង់គង់តួនទៅម្ខាងព្រះខែន
ធំចាំព្រះនាងយាងទៅកាន់ក្រឡាព្រះបន្ទំ ។ បន្តិចមកស្រាប់តែព្រះ
នាងយាងទៅដល់, ព្រះមហាក្សត្រក៏ចាប់ព្រះនាងនាំយកទៅព្រះបរម-
រាជវាំង ហើយយុំព្រះនាងក្នុងបន្ទប់មួយនៃមហាប្រាសាទ ។ ព្រះអង្គ
ទ្រង់បានឲ្យគេយកសេះឈើនោះមកដែរ, តែដោយព្រះអង្គមិនចេះប្រើ,
ទ្រង់ក៏យកសេះឈើនោះទៅទុកក្នុងបន្ទប់មួយទៀត ។

មុនពេលដែលមានព្រឹត្តិការណ៍នេះ, មានព្រះមហាក្សត្រប្រទេស
ដទៃមួយព្រះអង្គទ្រង់បានជ្រាបថា ព្រះមហាក្សត្រប្រទេសនេះ មាន
ព្រះរាជបុត្រីមួយព្រះអង្គប្រកបដោយព្រះរូបដ៏ល្អអស្ចារ្យ ។ ព្រះមហា-
ក្សត្រអង្គនោះ ទ្រង់បានចាត់អាមាត្យឲ្យមកដណ្តឹងព្រះនាងឲ្យជាព្រះទេវី
ព្រះរាជបុត្រព្រះអង្គ ។ ព្រះមហាក្សត្រអង្គនេះ ទ្រង់មានព្រះរាជឱង្ការ
តបទៅវិញថា ទ្រង់មិនត្រមះឆ្ងល់ស្មានមេត្រីនឹងព្រះមហាក្សត្រដទៃទេ ។

(នៅមានត)

រឿងព្រេងប្រទេសហ្ស៊ីវ

"បែងអំពីចោរឆ្លាតហួស"

ប្រែចេញពីភាសាអង់គ្លេស

ដោយភិក្ខុ ម៉ែន-រៀម

សិស្សពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ

មានពាណិជម្នាក់ ចាន់ធ្វើដំណើរទៅកាន់ទីមួយឆ្ងាយ ដើម្បីរកទិញទំនិញផ្សេង ។ គាត់ចាន់យកជាប់ទៅជាមួយខ្លួនផង នូវដុំមាសចំនួន ៥០០ ដែលជាកត្តិយសរបស់ខ្លួន ។ កាលចាន់ទៅដល់ទីដៅ គាត់ក៏ចាប់ផ្តើមខ្វល់ចិត្ត ។ គាត់និយាយតែម្នាក់ឯងថា "អញជាជនបរទេសម្នាក់ក្នុងទីនេះ ថែមទាំងគ្មានស្គាល់អ្នកណាមួយសោះ, បើប្រសិនណាជាអញបេះតែយកជាប់ទៅជាមួយខ្លួន នូវដុំមាសទាំងនេះជានិច្ចទៅនោះ, អញប្រហែលជានឹងត្រូវគេលួចយកអស់មិនខាន. ដូច្នេះ ជាការល្អ គឺអញត្រូវកប់វា ដរាបដល់ពេលដែលអញត្រូវការប្រើប្រាស់" ។ ដោយគំនិតនេះ ពាណិជចាន់ទៅកាន់កន្លែងស្ងាត់កំបុំងមួយ ហើយងាកមើលដុំវិញខ្លួនគាត់យ៉ាងប្រយ័ត្នប្រយែង; លុះចាន់ដឹងថាគ្មានអ្នកណាមួយមើលគាត់ឃើញ, គាត់ក៏ជីករណ្តៅមួយ រួចដាក់មាសកប់លាក់ទៅក្នុងរណ្តៅនោះ ។ គាត់អតចាន់ដឹងជាមុនថា នៅក្បែរនោះ មានគេលបមើល

តាមប្រហោងជញ្ជាំងផ្ទះរបស់គេ យើញគាត់លាក់មាសនោះឡើយ ។

មិនយូរប៉ុន្មានពីរោលដែលតាណាដចេញពីរណ្តៅមាស, ប៉ុសដែលលបមើលតាមប្រហោងជញ្ជាំងផ្ទះ ចូនចេញពីផ្ទះមកដើរយកមាសនោះអស់ ។

ថ្ងៃជារច្រើនកន្លងផុតទៅហើយ ។ ឥឡូវនេះ តាណាដត្រូវមកយកមាសទៅសងថ្ងៃខំទិញ ដែលគាត់ចូនទិញ ។ ពេលនោះគាត់ចូនទៅកាន់ទីដែលគាត់កប់មាស ។ កាលចូនដឹងថា មាសត្រូវគេលួចអស់ដូច្នេះ, គាត់កំពេញទៅដោយសេចក្តីអស់សង្ឃឹម ។ គាត់សោយសោកថា "ខ្ញុំ, អញត្រូវធ្វើយ៉ាងណាឥឡូវនេះ ? តើអញត្រូវទៅតវ៉ាកមាសពីអ្នកណា ? បើកាលអញកប់គ្មានអ្នកណាឃើញអញសោះ" ។

ដោយសេចក្តីតប់ប្រមល់ខ្លាំងក្នុងចិត្ត, តាណាដចូនគយគន់មើលជុំវិញខ្លួនគាត់ហើយក្នុងពេលដ៏ខ្លីនោះ ក៏ចូនឃើញប្រហោងជញ្ជាំងផ្ទះដែលនៅក្បែរនោះ ។ គាត់ចូនផ្តើមសង្ស័យថា ប្រហែលជាម្ចាស់ផ្ទះនេះឯងហើយ ជាចោរលួចមាសរបស់គាត់ ។ ដូច្នេះ, គាត់ក៏ចូនចូលទៅកម្ចាស់ផ្ទះហើយនិយាយថា :

ខ្ញុំចូនឮគេនិយាយថា លោកជាអ្នកថ្នាតវាងវៃម្នាក់ក្នុងទីនេះ ហើយមុខជាលោកអាចឲ្យខ្ញុំដំបូន្មានដ៏ល្អ។ ខ្ញុំចង់ពោះខ្ញុំមិនភាន ។ ខ្ញុំមកកាន់ទីនេះ ដើម្បីមកកេខិញខំទិញផ្សេង ។ ហើយចូនយកជាប់មកជាមួយខ្លួន

ខ្ញុំ ខ្លះថង់មាសចំនួន ២ ថង់ ។ មួយថង់ មានដុំមាសចំនួន ៩០០ ដុំ ហើយមួយថង់ទៀតមាន ៨០០ ដុំ ។ ដោយហេតុខ្ញុំជាជនបរទេសក្នុងទីនេះ ហើយឥតស្គាល់អ្នកណាមួយសោះនោះ, ខ្ញុំបានសំរេចចិត្តថា នឹងលាក់ថង់ដែលមានមាស ៩០០ ដុំ នៅក្នុងរណ្តៅដី, ហើយថង់មួយទៀត ដែលមានមាសចំនួន ៨០០ ដុំនោះ ខ្ញុំតែងតែយកជាប់នៅជាមួយខ្លួនខ្ញុំ បន្តើតជាបន្ទុកដ៏ធ្ងន់មួយតាមកក្នុងការធ្វើដំណើរ, ដូច្នេះ សូមលោកមេត្តាជួយប្រាប់ថា តើឲ្យខ្ញុំធ្វើយ៉ាងណា ? តើខ្ញុំត្រូវតែយកជាប់ជាមួយខ្លួនជាដរាបដូច្នេះទៅ ឬមួយត្រូវកប់ក្នុងរណ្តៅជាមួយថង់មាសមួយនោះ ? ឬមួយខ្ញុំត្រូវយកវាទៅកប់ក្នុងរណ្តៅផ្សេងវិញ ?, តាមដែលអាចទៅបាន, លោកប្រហែលជាមានស្គាល់ជនសប្បុរសណាមួយដែលអាចឲ្យខ្ញុំពុកចិត្តយកមាសទៅផ្ញើបានមិនខាន,, ។

ពុះសម្ងាស់ផ្លុះ គិតមួយសន្ទុះ ទើបធ្វើយដោយរបៀបចង់ប្រាកដថា :

– ត្រូវធ្វើតាមដំបូន្មានខ្ញុំ កុំពុកចិត្តអ្នកណាមួយដល់ថ្នាក់យកមាសទៅផ្ញើឲ្យសោះ ពីព្រោះ, តាមដែលអាចប្រព្រឹត្តទៅបាន, អ្នកខ្លះញ៉ាំនោះអាចនឹងថាដំសេធចោលថា «គេឥតបានខ្លួន» ដូច្នេះបានឥតការស់, ម្យ៉ាងទៀត ខ្ញុំសូមជូនយោបល់អ្នកថា កុំបាច់ទៅរកកន្លែងថ្មីសម្រាប់កប់ឲ្យសោះ, គឺត្រូវតែកប់ក្នុងរណ្តៅតែមួយ ជាមួយនឹងថង់មាសពីមុននោះ ជាការស្រួល ។

ចោរដែលនិយាយដូច្នេះ ត្រេកអរយល់ហេតុផលថា "ភាណិជ
ក្លៅក្លៀនេះ មិនមានគំនិតថា មាសខ្ញុំនេះដែលខ្ញុំទុកបំពាក់មុនគេមាសអស់ទៅ
ហើយ នៅឡើយផង; ដូច្នេះទុំបាយដំឆើតបំផុត ដើម្បីនឹងយកខ្ញុំថង់
មាសទី ២ ឲ្យបានទៀត គឺត្រូវយកថង់ទី ១ ទៅដាក់កន្ទុំនឹងដដែលវិញ.
ព័ត្រោះថា, បើអញមិនធ្វើដូច្នេះ គាត់មុខជាអោនលែងកប់ថង់ទី ២ ទៀត
មិនខាន, តាមរបៀបនេះ អញមុខជាបានមាស ២ ថង់យ៉ាងពិត" ។

នាយភាណិជ បានយល់ដាមុនថា ចោរមុខជាអនុវត្តរបៀបនេះមិន
ខាន ម្ល៉ោះហើយគាត់ក៏និយាយទៅកាន់ម្ចាស់ផ្ទះនោះថា, "ខ្ញុំសូមថ្លែងខ្ញុំ
សេចក្តីអំណរគុណលោក ចំពោះដំបូន្មានរបស់លោកនេះ ហើយខ្ញុំនឹង
ធ្វើតាមសេចក្តីបង្គាប់របស់លោកក្នុងពេលនេះ" ។

មិនយូរប៉ុន្មានពីពេលដែលភាណិជលាម្ចាស់ផ្ទះចុះមក, ចោរក៏យក
ថង់មាសទី ១ ដែលគាត់បានលួចទៅនោះ ទៅដាក់នៅកន្ទុំនឹងដដែលវិញ
ដោយប្រញាប់ប្រញាល់ជាខ្លាំងបំផុត ។ ភាណិជ ដែលលាក់ខ្លួននៅក្បែរ
ទីនោះ, កាលឃើញចោរដាក់ថង់ទៅកន្លែងណាហើយ ក៏តេ៉ាយាំង
ញាប់ដើរទៅគាស់យកដោយសេចក្តីសោមនស្ស រួចធ្វើដំណើរចេញ
បាត់ទៅ ។

ពិធីប្រគេន សញ្ញាប័ត្រពុទ្ធិកឧត្តមសិក្សាបឋមភូមិ ជូនសមណនិស្សិត ក្រោមព្រះរាជាធិបតីភាព នៃសម្តេចព្រះប្រមុខរដ្ឋ

លោក ឌឹង-វង់ រៀបរៀង

កាលពីថ្ងៃទី ៩ មេសា ១៩៦២ ពេលម៉ោង ៧ ទឹង ៣០ នាទីព្រឹក នៅក្នុងឃ្លាំនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត មានធ្វើពិធីប្រគេនសញ្ញាប័ត្រពុទ្ធិកឧត្តមសិក្សាបឋមភូមិ ជូនសមណនិស្សិត ២៤ រូប ដែលទើបទទឹងបានប្រឡងជាប់ជាលើកដំបូង ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់នៃសម្តេចព្រះប្រមុខរដ្ឋ ជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ ។

នៅមុនពេលដែលសម្តេចព្រះចៅគាងឯករាជ្យជាតិស្តេចយាងដល់ យើងបានសង្កេតឃើញសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ សម្តេចព្រះសុធម្មាធិបតី សង្ឃនាយកគណៈធម្មយុត្តិកនិកាយ ព្រះតោនាំង្ស ហួត-តាត អគ្គាធិការនៃពុទ្ធិកសិក្សា ព្រះសង្ឃរាជាគណៈហានាទុក្រម ព្រះសង្ឃជាសាស្ត្រាចារ្យ ត្រមាំងសមណនិស្សិតដែលត្រូវទទួលសញ្ញាប័ត្រ ។

ផ្នែកខាងត្រហស្ត ដើម្បីបានសង្កេតឃើញសហជីវិន ចៅសែន-
កុសល អ្នកអង្គម្ចាស់ នរកត្តម-កន្ទុល ជាប្រធានៃសភាខាងតាវ ឯកទត្តម
ញឹក-ជូរ្យុង រដ្ឋមន្ត្រីទី១ ស្តីទី សមាជិកផ្នែកតិចបាល សមាជិកនៃសភា
ខាងតាវ សហជីវិន ចៅ-សេង នាយកនៃតុទ្ធិកមហាវិទ្យាល័យ ព្រម
ទាំងឥស្សរជនអ្នកមុខអ្នកការជាច្រើន បានទិមន្តអញ្ជើញទៅចូលរួមយ៉ាង
កុះករ ក្នុងពិធីប្រគេនសញ្ញាប័ត្រជល់សមណនិស្សិតទាំងនោះ ។

នៅវេលាម៉ោង ៩ សម្តេចព្រះប្រមុខរដ្ឋ ព្រះអគ្គតុទ្ធសាសនូបត្ថម្ភក៍
ដោយមានសមាជិកទត្តមក្រុមប្រឹក្សាព្រះរាជបល្ល័ង្ក ព្រមទាំងឥស្សរជន
ព្រះរាជបរិវារជាច្រើនហែអមព្រះដំណើរផង បានស្តេចយាងដល់តុទ្ធិក-
វិទ្យាល័យព្រះសុរាម្រិត តាមព្រះទីនាំងវេយ្យន្ត ។

សម្តេចព្រះបិតាជាតិ ស្តេចបានទទួលតាវកិច្ចពីក្រុមគាហានរក្ស
ព្រះអង្គ ឧទ្ទិសក្រមក្លែងព្រះរាជទ្រព្យ ដែលបានលើកវាត្បាវុធ ឧទ្ទិសបន្ទប់
ក្លែងចរលើលាថ្វាយជាព្រះរាជកិត្តិយស ។ បន្ទាប់មក ព្រះអង្គបាន
ទទួលការក្រាបថ្វាយបង្គំ នៅត្រង់ខ្លោងទ្វារចូលទៅកាន់ខ្នែងក្រោតពិធី
ពីសមាជិកពផ្នែកតិចបាល សមាជិកនៃសភាខាងតាវ ឧទ្ទិសឥស្សរជន
សាស្ត្រាចារ្យនៃតុទ្ធិកមហាវិទ្យាល័យ ព្រមទាំងអ្នកមុខអ្នកការជាច្រើន
ទៀត ។

តមក សម្តេចជាតិគោរព បានស្តេចយាងចូលទៅថ្វាយបង្គំព្រះ

សង្ឃ ដែលមានសម្តេចព្រះសង្ឃនាយកគង់គ្រប់គណៈជាដើម ។

ក្រោយដែលបានថ្វាយបង្គំព្រះសង្ឃរួចហើយ ក៏មានធ្វើពិធីគោរពខន់ជាតិ ជាកិច្ចចាប់ផ្តើមញ៉ាំងពិធីនោះឲ្យប្រព្រឹត្តទៅ ។

លុះចប់ពិធីគោរពខន់ជាតិនេះរួចហើយ សហជីវិន ទៅ-សេង ក្នុងហាន:ជានាយកនៃមហាវិទ្យាល័យ បានថ្លែងសុន្ទរកថាមួយ ដែលមានសេចក្តីសំខាន់ៗ ដូចតទៅនេះ :

បន្ទាប់ពីពេលដែលបានថ្លែងព្រះអំណរគុណរួចហើយ សហជីវិនអធិបតី បានរៀបរាប់អំពីប្រវត្តិយ៉ាងសង្ខេបនៃពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ដែលជាអង្គការសំខាន់បំផុតនៃពុទ្ធិកទត្តមសិក្សានៅប្រទេសកម្ពុជាថា :

កាលពីឆ្នាំ ១៩៥៣ ព្រះតេជព្រះគុណព្រះពោធិវង្ស ហួត - តាត ជាចាងហ្វាងសាលាថ្នាល់ជាន់ខ្ពស់ បានថ្វាយចំពោះព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម - សីហនុវរ្ម័ន នូវសេចក្តីស្នើអំពីការរៀបចំសាលាថ្នាល់ជាន់ខ្ពស់ ហើយបានព្រះរាជានុញ្ញាតនិមន្តនៅតាន់បរទេស ដើម្បីពិនិត្យមើលរបៀបការសិក្សាខាងព្រះពុទ្ធសាសនា អស់រយៈពេលមួយខែ, លុះនិមន្តត្រឡប់មកវិញ បានធ្វើសេចក្តីរាយការណ៍អំពីការសិក្សាខាងព្រះពុទ្ធសាសនានៅបរទេសដោយពិស្តារ ថ្វាយព្រះករុណាជាអម្ចាស់ជីវិតលើត្បូងខ្ពង់ខ្ពស់ ។ ព្រះអង្គខ្ពង់ខ្ពស់តេញព្រះរាជឋិយាសន៍ ចំពោះ

សេចក្តីពិភាក្សាណែនាំ ព្រោះព្រះអង្គជ្រាបច្បាស់ពីតម្រូវការចាំបាច់ខាងព្រះពុទ្ធសាសនា ហើយទ្រង់យល់ព្រមសម្រេចឲ្យបង្កើតពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជនេះ ដោយព្រះរាជក្រមលេខ ៨៧៨ ន.ស. ចុះថ្ងៃទី ១ កក្កដា ១៩៥៤ ដែលគណៈរដ្ឋមន្ត្រី រដ្ឋសភា និងក្រុមប្រឹក្សាព្រះរាជអាណាចក្រ បានអនុម័តត្រាមត្រឿងផង ។

ដោយអនុវត្តន៍តាមព្រះរាជក្រមខាងលើនេះ ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ បានកើតជារូបរាងឡើង ដោយការទទួលត្តម្ភនៃសម្តេចជាអម្ចាស់ ការគង់លើព្រះរាជបល្ល័ង្កនៅឡើយ ទ្រង់បានប្រោសព្រះរាជទានទីដ៏មួយកន្លែង និងព្រះរាជទ្រព្យ ១៦០ ម៉ឺនរៀលមកក្រសួងធម្មការ ឲ្យចាត់ចែងកសាងគ្រឹះស្ថានពុទ្ធិកមហាវិទ្យាល័យនេះ ។

ក្រសួងធម្មការបានប្រគល់ការនេះមកព្រះតេជព្រះគុណព្រះពោធិវង្ស ឲ្យរៀបចំស្ថាបនាគ្រឹះស្ថានថ្មីនេះ ។

លុះដល់មកឆ្នាំ ១៩៥៥ ក៏បានធ្វើពិធីបើកការសិក្សាក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់នៃសម្តេចព្រះមហាក្សត្រិយានី នរិន្ទសម្តេចព្រះប្រមុខរដ្ឋ ។ ក្នុងគ្រានោះ បានជ្រើសរើសយកសមណនិស្សិតជារើសដំបូងបង្អស់ចំនួន ៤០ រូប អំពីក្រុមសមណនិស្សិតដែលបានប្រឡងជាប់ចេញពីពុទ្ធិកវិទ្យាល័យព្រះសុកមម្រិត ឲ្យចូលសិក្សាក្នុងថ្នាក់ឆ្នាំទី ១ ។

នៅខែកុម្ភៈ ១៩៥៦ សមណនិស្សិតជាំងំ ៤០ រូបនោះ បាន

ប្រឡងបញ្ចប់ការសិក្សា ដោយមានសមណនិស្សិត ២៤ រូប ជាន
ខ្លួលលទ្ធផលក្នុងការប្រឡង ត្រូវជាខ្លួលសញ្ញាបត្រពុទ្ធិកទុតិយ
សិក្សាបឋមភូមិ ។

ក្រោយពេលដែលពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ កើតឡើង
ហើយ ការសិក្សាខាងព្រះពុទ្ធសាសនាដែលមានមកពីមុន ត្រូវបានកែ
ប្រែរៀបចំជាថ្មីវិញ ចាំងអស់ គឺ:

- សាលាចុលិរង ត្រូវបានកែប្រែជាពុទ្ធិកបឋមសិក្សា ដោយ
ព្រះរាជក្រឹត្យលេខ ៦០៧ ន. ស. ចុះថ្ងៃទី ១៦ ធ្នូ ១៩៥៧ ។

- សាលាចុលីជាន់ខ្ពស់ ត្រូវបានកែប្រែជាពុទ្ធិកមជ្ឈមសិក្សា
ដែលហៅថា ពុទ្ធិកវិទ្យាល័យព្រះសុរាម្រិតសព្វថ្ងៃនេះ ។

រីឯពុទ្ធិកបឋមសិក្សា ក្នុងព្រះរាជអាណាចក្រចាំងមូល មើតិត
ត្រឹមឆ្នាំ ១៩៦០-៦១ មានចំនួន ៦០០ សាលា មានសមណសិស្ស
១០.១៦៦ រូប ។

ឯវិជ្ជា ដែលត្រូវសិក្សា គឺ:

១- វេយ្យាករណ៍ចុលិ ប្រែជាលិងាខ្មែរ,

២- វិន័យ ពុទ្ធប្បវត្តិ ទីងពុទ្ធសាសនា,

៣- ភាសាជាតិ: វេយ្យាករណ៍ សារៈសាតៈមសូត្រ-ភាសាខ្លឹង
ភាសា តែងរៀបក្តីអក្សរផ្ទាល់;

៤- គណិតសាស្ត្រ. រ៉ូម៉ាស់ង៉ូល. ធរណីមាណសាស្ត្រ,

៥- ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ,

៦- ភូមិសាស្ត្រប្រទេសកម្ពុជា ,

៧- វិទ្យាសាស្ត្រ. អនាម័យ ,

៨- លោកនីតិ ,

៩- វិជ្ជាកសិកម្មយ៉ាងសង្ខេប ។

ការសិក្សាខាងលើនេះ កំណត់កាល ៣ ឆ្នាំ ត្រូវប្រឡងយកវិញ្ញាបនបត្រ ។ សិស្សដែលមានវិញ្ញាបនបត្រ អាចសូមចូលប្រឡងប្រជែងយកកន្លែងសិក្សាក្នុងមធ្យមសិក្សា គឺពុទ្ធិកវិទ្យាល័យព្រះសុកម្រិត ។

សាលាមធ្យមសិក្សា គឺពុទ្ធិកវិទ្យាល័យនេះ មានតែមួយគត់នៅក្រុងភ្នំពេញ ទទួលសមណនិស្សិតក្នុងមួយឆ្នាំបានតែ ១៨០ រូប ។

ឯវិជ្ជាដែលត្រូវសិក្សា គឺ :

១- ភាសាបាលី សំស្ក្រឹត ខ្មែរ អង់គ្លេស នឹងបាកំង ,

២- ប្រវត្តិសាស្ត្រ ,

៣- ភូមិសាស្ត្រ ,

៤- គណិតសាស្ត្រ ,

៥- វិទ្យាសាស្ត្រធម្មជាតិរូបនិយម នឹងគីមី,

៦- លោកនីតិ,

៧- វិជ្ជាខ្ទង់ ៧ : ប្រវត្តិសាស្ត្រ អារ្យធម៌ខ្មែរ ។

ការសិក្សាវិជ្ជាខាងលើនេះ កំណត់កាល ៤ ឆ្នាំ ត្រូវប្រឡងយកសញ្ញាបត្រមធ្យមសិក្សា ហើយអាចនឹងសូមចូលប្រឡងយកតម្លៃនិងសិក្សាក្នុងពុទ្ធិកមហាវិទ្យាល័យតទៅទៀត ។

ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ចាត់ជាឧត្តមសិក្សា មានការសិក្សា ៣ ផ្នែក :

ក- ឧត្តមសិក្សាបឋមភូមិ កំណត់ការសិក្សា ៣ ឆ្នាំ,

ខ- ឧត្តមសិក្សាទុតិយភូមិ កំណត់ការសិក្សា ៤ ឆ្នាំ,

គ- ឧត្តមសិក្សាតតិយភូមិ កំណត់ការសិក្សា ៣ ឆ្នាំ ។

រួមចាំនួនអស់ត្រូវជា ១០ ឆ្នាំ សរុបកាលសិក្សាចាំនួនពីពុទ្ធិកបឋមសិក្សា រហូតដល់ឧត្តមសិក្សាត្រូវជា ១៧ ឆ្នាំ ។

តមក សហជីវិនអធិបតី បានថ្លែងសេចក្តីសរសើរចំពោះបុគ្គលិកដែលខំប្រឹងប្រែងបំពេញមុខការក្នុងពុទ្ធិកសិក្សានេះជាអាទិ៍ គឺ:

១- ព្រះតេជព្រះគុណព្រះពោធិវង្ស ក្រោមការណែនាំនៃសម្តេចព្រះសង្ឃនាយកចាំនួនពីរគណៈ ព្រះអង្គគាន់មុខជាំណែនជាចាងហ្វាងពុទ្ធិកវិទ្យាល័យព្រះសុភមង្គលផង ជាអគ្គាធិការនៃពុទ្ធិកសិក្សាខួរក្បាលក្នុងព្រះរាជអាណាចក្រផង គឺតាំងពីបឋមសិក្សារហូតដល់ឧត្តមសិក្សា ។ ព្រះអង្គបានចាត់ការខាងផ្នែកសិក្សា ឲ្យបានល្អគួរសមចំរើនឡើងជាយ

លំដាប់ គួរឲ្យតេញចិត្តយ៉ាងក្រៃលែង ជាមួយនឹងសហការរបស់ព្រះអង្គគ្រប់ផ្នែក ។

២- លោក ថាច់ សេរ៉ាញ ជាសាស្ត្រាចារ្យ ដែលក្រសួងអប់រំជាតិបានចាត់មកឲ្យធ្វើជាទីប្រឹក្សានៅអគ្គាធិការដ្ឋាននៃពុទ្ធិកសិក្សា បានយកចិត្តទុកដាក់យ៉ាងខ្ជាប់ខ្ជួនក្នុងមុខការដែលត្រូវបំពេញ គួរឲ្យសរសើរយ៉ាងខ្លាំង ។

៣- លោក តែ-ម៉ែងហាច់ ជាសាស្ត្រាចារ្យ ដែលក្រសួងអប់រំជាតិបានចាត់មកឲ្យធ្វើជាអគ្គលេខាធិការនៃពុទ្ធិកមហាវិទ្យាល័យ បានបំពេញមុខការយ៉ាងសកម្ម ជាមួយនឹងសហការ គួរឲ្យសរសើរយ៉ាងក្រៃលែង ។

រីឯពុទ្ធិកមហាវិទ្យាល័យនេះ ដែលកើតមានឡើងដោយព្រះតេជានុភាពនៃសម្តេចព្រះឧបយុវរាជព្រះប្រមុខរដ្ឋ ក្នុងកាលព្រះអង្គគង់លើព្រះរាជបល្ល័ង្កនៅឡើយ ហើយនឹងក្លាយជាកន្លែងនៃការជំរុញកិច្ចសង្គមកស្ត្រីនិយម ។

យើងសូមបញ្ជាក់ថា ក្នុងកាលពីឆ្នាំប្រតេនសញ្ញាប័ត្រដល់សមណនិស្សិត ៦៤ រូបនេះ សម្តេចព្រះប្រមុខរដ្ឋទ្រង់បានព្រះរាជទានបច្ច័យចំនួន ១ លានរៀល សម្រាប់ពុទ្ធិកសិក្សា ។ ក្រៅពីនេះ

ទ្រង់ព្រះកដឋាន ១ ម៉ឺនរៀលទៀត ដើម្បីប្រគេនសមណនិស្សិត ៦៤ រូប យកទៅសម្រេចកិច្ចកឋិនបច្ចុយ ចាំង ៤ តាមពុទ្ធានុញ្ញាត ។

មុននឹងបញ្ចប់ សហជីវិនអធិបតី ក្នុងនាមនៃមជ្ឈដ្ឋានព្រះសង្ឃ សាស្ត្រាចារ្យនឹងបុគ្គលិកចាំងអស់ . នឹងក្នុងនាមផ្ទាល់ ចានសូមជូនជាថ្មីម្តងទៀត នូវសេចក្តីស្វាមីភក្តីនឹងស្នេហាយ៉ាងស្មោះស្ម័គ្រជាទីបំផុត ហើយប្តេជ្ញាថា នឹងដង្ហែតាមព្រះមាគ៌ានៃយោធាយ នៃសម្តេចព្រះបិតាឯករាជ្យជាតិ ឥតឃ្លៀងឃ្លាត រហូតដល់អវសានជីវិត ។

ជាទីបញ្ចប់ សហជីវិនអធិបតី សូមជូនពរដល់ឯកឧត្តម ឯកឧត្តមស្រី ដែលមានឫទ្ធានុភាពដ៏ស័ក្តិសិទ្ធិ សូមជួយអភិបាលរក្សាសម្តេចព្រះមហាក្សត្រិយានី សម្តេចព្រះប្រមុខរដ្ឋ ព្រមចាំងព្រះរាជវង្សានុវង្ស សូមទ្រង់ប្រកបដោយសុខសួស្តីគ្រប់ប្រការ នឹងសូមជួយអភិបាលរក្សាសម្តេចព្រះសង្ឃនាយកចាំងពីរព្រះអង្គ ឯ.ឧ. អស់លោកចាំងឡាយ សូមបានប្រកបដោយពុទ្ធពរចាំង ៤ ប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ អស់កាលជាអង្វែងតទៅ ។

ល្ងាចបំសុន្ទរកថានៃសហជីវិន ចៅ . សេង នេះមក ព្រះតេជព្រះគុណព្រះពោធិវង្ស ហួត-តាត ចានេះហៅព្រះនាមសមណនិស្សិត

មួយអង្គមួង ។ ឲ្យនិមន្តទៅទូលសញ្ជាប័ត្រ ដែលសម្តេចជាអម្ចាស់ទ្រង់សព្វព្រះពជហឫទ័យប្រគេនដាំលាំព្រះហស្តព្រះអង្គ លុះត្រាដល់ត្រប់ចាំង ៦៤ អង្គ ហើយពេលនោះ សម្តេចព្រះប្រមុខវង្ស ស្តេចសព្វព្រះពជ-ហឫទ័យប្រគេនទឹងក្រោសព្រះពជទានគ្រឿងឥស្សរិយយស ដល់ព្រះតេជព្រះគុណព្រះពោធិវង្ស ទឹងសហការរបស់លោកពីរបីខែត ដើម្បីជាគុណូបការជើប្រសើរដែលព្រះតេជព្រះគុណព្រះពោធិវង្ស ទឹងសហការរបស់លោកបានបូជាទឹងការបំរើជាតិ-សាសនាទឹងព្រះពជបល្ល័ង្ក ។

បន្ទាប់ពីការបំពាក់គ្រឿងឥស្សរិយយសនេះមក សម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ បានក្រោសប្រទានទុកឲ្យដល់សមណានិស្សិតដោយព្រះពុទ្ធដីកាដាំលាំ ។

លុះចប់ព្រះទុកឲ្យនៃសម្តេចព្រះសង្ឃនាយកនេះមក សម្តេចព្រះបិតាឯកពជ្យជាតិ ស្តេចបានថ្លែងព្រះសង្កត់ថាមួយយ៉ាងវែង រៀបរាប់អំពីការដែលតាលដូរយើងគោរពព្រះពុទ្ធសាសនាដោយដឿងាក់ថាងាមប្រជាក់ហើយព្រះអង្គបានធ្វើតថ្លែងអំពីនយោបាយក្នុងប្រទេស ក្រៅប្រទេសប្រតេន ព្រះសង្ឃគាំងឡាយ បានយល់ឮសំខ្លួរការសុខទុក្ខនៃតិតតលោកខ្មែត ។

នៅពេលចប់ព្រះសង្ឃថា នៃសម្តេចព្រះអគ្គមហាសាសនូបត្ថម្ភក៍នេះ ហើយ ព្រះសង្ឃដែលមានសម្តេចព្រះសង្ឃនាយកចាត់ឆ័ត្រគណៈជាប្រធាន ចាត់ស្វាធ្យាយន៍ព្រះពុទ្ធមន្តជយន្តោប្រសិទ្ធិពរជ័យ ថ្វាយព្រះសុកមង្គលចំពោះសម្តេចព្រះបិតាជាតិ ។

បន្ទាប់មក សម្តេចព្រះប្រមុខរដ្ឋ ស្តេចចូលប្រទេនព្រះកថ្ឋសន្ទនាអស់រយៈពេលជាច្រើននាទី ជាមួយនឹងសម្តេចព្រះសង្ឃនាយកចាត់ឆ័ត្រគណៈ នឹងព្រះសង្ឃជាឧកញ៉ាគណៈហានានុក្រម ព្រមចាត់ឥស្សរជនថ្នាក់ខាងគ្រហស្ថដែលជាព្រះរាជបរិពារ អំពីកិច្ចការផ្សេង ។ ទើបសម្តេចជាអម្ចាស់ស្តេចចូលថ្វាយបង្គំលាព្រះសង្ឃ លាឥស្សរជនក្លួនចៅយ៉ាងនិវត្តន៍ទៅកាន់ព្រះបរមរាជវាំងវិញ ដោយព្រះសុវត្ថិភាព ។

ពិធីនេះ ចានចប់សព្វគ្រប់នៅវេលាម៉ោង ១១ នឹង ៣០ នាទី ក្រោមបរិយាកាសដ៏សែនរីករាយជាទីបំផុត ។


ភាវនាសនវិយ

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ៣៤ លេខ ៥ ខែ ឧសភា

ព.ស. ២៥០៤ គ.ស. ១៩៦២



ភ័ទ្រសុទ្ធិយោ

ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
–	សទ្ធម្មកថា ព្រះញាណវិរិយៈ ភិន-សាន់ រៀបរៀង	៤៨៣
–	លោកុត្តរចិត្ត (តបប់) អ្នកឧកញ៉ា ខា-សាន អតីតរដ្ឋមន្ត្រី រៀបរៀង	៤៩៤
–	ព្រះអភិធម្មបិដក (គម្ពីរព្រះយមកៈ) (ត) លោកប៉ូ-ប៉ូ ប្រែរៀបរៀង	៥០៩
–	មធុរសវាហិណី(ត)សម្តេចព្រះធម្មលីទ្ធគណ្ឌី-ឯម ប្រែ ព្រះញាណកោសលញ-ឈឺនពិន័ត្យ	៥១៧
–	មហោសថជាតក(ត) លោក អឹម-ភន បម្លងពីសាស្ត្រាស្ងឹកវិតព្រះពុទ្ធវង្ស កឹម-ឆ្លារ ពិនិត្យ	៥២៣
–	ការណាយនៃភាពនៃធនធំនកើតជាថ្មីសារឡើងវិញ(តបប់)កាត្យ លោកញ៉ុង-សឿង និពន្ធ	៥៣៣
ផ្នែកអក្សរសាស្ត្រ		
–	កាសាសាស្ត្រនិងអក្សរសាស្ត្រខ្មែរ លោក ង៉ិក-ជាម រៀបរៀង	៥៥៥
–	ពាក្យខ្មែរប្រែតបរទេស (ត) ដោយគណៈកម្មការជាតិនៃការសិក្សាផ្នែកអក្សរ "ក"	៥៦៦
–	វចនានុក្រមសំស្ក្រឹត-ខ្មែរ (ត) ព្រះមហា ជាំង-ខាត់ រៀបរៀង	៥៦៧
–	រឿងសាមកុក (ត) ឧកញ៉ា ន្នុ-កន ប្រែ	៥៦៨
–	រឿងត្រែងចិន (ត) លោក ភ័យ ប៊ុក ប្រែរៀបរៀង	៥៧៨
–	ប្រកាសប្រឡងប្រជែងទំនៀមទម្លាប់ខ្មែរ	៥៨៣
ផ្នែកកំណត់ទំនឹងប្រវត្តិការណ៍		
–	ពិដ៏បុណ្យវិសាខបូជា នៅមុខព្រះសក្យមុនីចេតិយ លោក ចិន-រ៉ែង រៀបរៀង	៥៧២

34è Année — N° 5 — Mai 1962

KAMBUJASURIYA

Revue mensuelle de culture religieuse et littéraire
publiée par l'Institut-Bouddhique de Phnom-Penh

SOMMAIRE

Partie religieuse

—Saddhammakatha par Vén. VAN-SADUM 483
—Lokuttaracitta (suite et fin) par l'Oknha TEA-SAN. . . . 494
—Prah Abhidhamma pitaka « Kampi prah Yamaka » (suite)
traduit par M. BOU-PO 508
—Madhurasavahini (suite) traduit par Samdech Prah
Dhammalikhita LOUIS-EM, revu et corrigé
par le Vén. NHEAN-CHHŒUN. 517
—Mahosatha Jataka (suite) relevé du manuscrit sur feuilles
de latanier par M. IM-PHON, revu et corrigé
par le Vén. KEM-TO 523
—La fin du monde et sa formation (suite et fin)
par M. NHOUNG-SŒUNG. 533

Partie littéraire

—Le Langage et la littérature Khmèrs par M. DIK-KEAM...555
—Activités de la Commission Culturelle (suite) chapitre « Ka » 566
—Dictionnaire Sanscrit-Khmèr (suite) par Vén. PANG KHAT 567
—Histoire de Sam-Kok (suite) traduite par l'Oknha NOU-KAN 568
—Contes et Légendes de la Chine (suite) traduits
par M. RAY-BUC 578
—Annonce de Concours institués par la Commission des
Mœurs et Coutumes du Cambodge 583

Notes et Chroniques

—Fête du Visakha bochea devant le Prah Sakyamoni
Cheddey par M. THANG-VONG. 592

Prix d'Abonnement annuel (comprenant 12 numéros) : 230 ; 00

ផ្ទៃការសាសនា

ពាក្យឃោតម៉ឺនឲ្យ ធ្វើការអាក្រក់
ជាការណាមក ឲ្យធ្វើល្អទៅ ។
ឲ្យចុំសាត់ចិត្ត កុំឲ្យហ្មងសៅ
នេះឯងលោកហៅ ពុទ្ធសាសនា ។

ប.ព.

សទ្ធម្មកថា

ព្រះញាណវរិយៈ ភ័ន-សាង៉ុ រៀបរៀង

ឥមត្ថុ រតនត្តយស្ស

សូមនមស្សការចំពោះព្រះរតនត្រ័យ គឺព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ។

សទ្ធម្មោ តវុត្តាតញ្ហោ

សុខា សទ្ធម្មទេសនា ។

វេលានេះ សូមតណិនាតាមបទបាទព្រះគាថា ដែលបានតាំងខុកខាងដើមនេះ ដើម្បីផ្សាយទូវែងតួមគតិ នៃព្រះពុទ្ធសាសនា ដែលមានមកក្នុងព្រះត្រៃបិដក ដូចតទៅនេះ៖

បាទគាថា ១ សទ្ធម្មោ តវុត្តាតញ្ហោ សាធុជនគួរគោរពព្រះសទ្ធម្ម

បាទគាថា ២ សុខា សទ្ធម្មទេសនា ការសំដែងព្រះសទ្ធម្ម នាំមកនូវសេចក្តីសុខ ។

ការគោរពព្រះសទ្ធម្ម ឬការសំដែងព្រះសទ្ធម្ម ជាការណ៍យកចិត្ត
ទុកដាក់ក្នុងដែលមានសន្តានសប់ ព្រោះព្រះសទ្ធម្ម ប្រែថា ធម៌សប់
ឬធម៌របស់លោកអ្នកសប់ ។ លោកអ្នកមានកុសល ឈ្មោះវៃកង
ការលះនីវរណធម៌ចំរើន នូវធម៌ដែលគួរលះនីវរណធម៌ដែលគួរចំរើន អាច
រក្សាខ្លួនមិនឲ្យកំរើសធម៌ដ៏កន្ទាំធ្វើអំពើអាក្រក់ មានបញ្ញាវៃជាដើម នេះ
ហៅថាលោកអ្នកសប់ ដោយមាន សីល សមាធិ បញ្ញា ជាធម៌សប់
ក្នុងសន្តាន ។ សប្បុរសពាំងឡាយ មានព្រះពុទ្ធជាដើម មាននាមថា
ជាអ្នកសប់ ដែលហៅជាភាសាបាលីថាសន្តៈ ។ ពួកសន្តៈអ្នកសប់ រមែងមាន
ធម៌សប់ជាទីគោរពជ្រះថ្លា តែមានហឫទ័យធ្ងន់ក្នុងព្រះសទ្ធម្ម សមដោយ
បាលីថា សត្បៃ សទ្ធម្មគរុនោ ព្រះសម្ពុទ្ធគ្រប់អង្គ សុទ្ធតែទ្រង់គោ-
រពក្នុងព្រះសទ្ធម្ម តែមានការគោរពតាំងពីក្នុងការស្តាប់ព្រះសទ្ធម្មជាដើម
រៀ ។ ដូច្នេះ អំពើកាយ វាចា ចិត្ត របស់លោកអ្នកសប់ រមែងមាន
ធម៌សប់ជាទីតាំង ហើយប្រព្រឹត្តទៅដើម្បីសេចក្តីសប់ ដែលជាមូលនៃ
សេចក្តីសុខពិត ។ សមដោយព្រះបាលីថា សន្តោ កាយេន
សំវរេ ធម្មំ ទេសេតិ ព្រះមានព្រះភាគអង្គនោះ ទ្រង់ជា
សន្តៈអ្នកសប់ ទ្រង់សំដែងធម៌ដើម្បីសេចក្តីសប់ ។ ការសំដែងធម៌
ដើម្បីសេចក្តីសប់នេះហើយ ដែលចាត់ទុកជាព្រះសទ្ធម្មទេសនា មកក្នុង

ព្រះជ្ឈាយ៍ថា សុខា សន្តិឆេសជា ការសំដែងព្រះសទ្ធម្ម នាំមកនូវសេចក្តីសុខ ។

សេចក្តីសុខក្នុងខ្លួនខ្ញុំនេះ សំដៅយកនូវកម្ចិតសុខ យ៉ាងបរិសុទ្ធផុតប្រៃក្សាយ កើតឡើងអំពីព្រះសទ្ធម្ម មានព្រះសទ្ធម្មគឺសីលជាដើម ។ តុំមែនខ្លួនភៅដល់សាមិសុខ ដែលមិនបរិសុទ្ធកើតអំពីអសទ្ធម្មមាន រូប សំឡេង ជារបស់មនុស្ស ឬរបស់ទេតាជាដើម ហើយប្រែក្សាយភៅជាទុក្ខវិញឡើយ ។ ដ្បិតសេចក្តីសុខ សោមនស្ស ព្រោះរូប សំឡេង ជាដើមនោះ ព្រះពុទ្ធជាអម្ចាស់ទ្រង់ត្រាស់ថា ជារឹបរំណោមទុក្ខភៅហើយ ដោយសេចក្តីសុខសោមនស្សនោះ តែងតែប្រែក្សាយភៅជាទុក្ខវិញនៅវេលាដែលអារម្មណ៍មានរូបជាដើមនោះវិបត្តិ ព្រោះហេតុមានការចាស់-ស្លាប់ជាដើម ។ ហេតុនេះ ទើបអ្នកប្រាជ្ញតាំងខ្លួយ តុំអាចលះព្រះសទ្ធម្ម ព្រោះអសទ្ធម្មឡើយ ប្រៃសេចក្តីថា លោកតុំអាចប្រព្រឹត្តទុច្ចរិត ព្រោះតែចង់បានលាភ យស សរសើរ សុខ ឬ រូប សំឡេង ក្លិន រស ផ្សព្វនោះ។ ឡើយ ។

ព្រះសទ្ធម្ម បើពោលដោយខ្លឹមាន ៣ ប្រការ គឺ: បរិយត្តិសទ្ធម្ម ១ បដិបត្តិសទ្ធម្ម ១ បដិវេធសទ្ធម្ម ១ ។ ធម្មវិន័យ គឺព្រះត្រៃបិដក ជាសត្ថុសាសន: (ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាអម្ចាស់) ដែលអ្នកប្រាជ្ញលោកបានសង្គាយនារៀបចំទុកមក ប្រកបដោយអត្ថតាំង

៤ ប្រការ មានសុត្តៈ គេយ្យៈ ជាដើម ដែលជាគ្រឿងរៀនសូត្រជាន់ដំបូងសម្រាប់សាងសីល សមាធិ បញ្ញា ហៅថា បរិយត្តិសទ្ធម្ម ។ សីល សមាធិ បញ្ញា ដែលកើតឡើងដោយការប្រតិបត្តិតាមធម្មវិន័យ ហៅថា បដិបត្តិសទ្ធម្ម ។ មគ្គ ផល និព្វាន ដែលកើតមានព្រោះសីល សមាធិ និងបញ្ញា ហៅថា បដិវេធសទ្ធម្ម ។

ព្រះពុទ្ធជាអម្ចាស់ ចាននិព្វានរួចហើយ ទ្រង់ចំរេញពុទ្ធកិច្ចស្ទើរតែគ្មានពេលសម្រាក ។ ក្នុងចំណោម ៤៥ ព្រះវស្សា តាំងពីចាននិព្វាន ទ្រង់មានពុទ្ធកិច្ច គឺប្រកាសព្រះសទ្ធម្មតាំង ៣ ប្រការ នឹងទ្រង់ប្រតិស្ឋានខ្ជាប់ពុទ្ធសាសនមណ្ឌល ដែលប្រដាប់ដោយបរិស័ទ ៤ គឺ ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ។ ក្នុងការប្រកាសព្រះសទ្ធម្ម ទ្រង់ប្រកាសដោយព្រះអង្គឯងផង ទ្រង់គ្រាស់ឲ្យពុទ្ធសាវ័កតាំងច្បាយដួយប្រកាសផង ។ ឧទាហរណ៍ ដូចក្នុងបឋមពោធិកាល ទ្រង់ចាប្រកាសព្រះធម្មចក្ក នឹងព្រះសទ្ធម្មដទៃ ។ ទៀត មានអនត្តលក្ខណសូត្រជាដើម ។ កាលមានព្រះអរហន្តជាពុទ្ធសាវ័កចានចំនួន ៦០ រូបហើយ ទ្រង់តំបញ្ជូនព្រះអរហន្តតាំងនោះ ឲ្យទៅប្រកាសព្រះសទ្ធម្មកន្លែងនីមួយៗ ហើយទ្រង់ហាមមិនឲ្យទៅតាមផ្លូវតែមួយដង ២ រូបឯង ដើម្បីឲ្យព្រះសទ្ធម្មធាប់ផ្សព្វផ្សាយទៅចានច្រើនកន្លែង ។ តាំងព្រះអង្គឯង តំធ្វើពុទ្ធដំណើរតែមួយព្រះអង្គ សំដៅទៅប្រាសដដែលមួយតាន់ខាក់ ឯកាលប្រទេស

ដែរ ។ ក្នុងរយៈផ្លូវតុន្ទដំណើរនេះ ទ្រង់បានបំបួសព្រះភិក្ខុវគ្គិយភទ្ទ-
កុមារ ៣០ អង្គ ដែលបានស្តាប់ព្រះសទ្ធម្មទេសនាបានសម្រេចមគ្គផល
ហើយទ្រង់បញ្ជូនទៅដួចមុន ទើបស្តេចដើរតុន្ទដំណើរតែម្នាក់ឯងព្រះ
អង្គទៀត ។ ហេតុការណ៍ប៉ុណ្ណោះជាដើម ធ្វើឲ្យយើងយល់ឃើញថា ព្រះអង្គ
មានតុន្ទបំណងចង់ណាស់ ក្នុងការផ្សាយព្រះសទ្ធម្មដើម្បីជាប្រយោជន៍
ដើម្បីសេចក្តីសុខ ដើម្បីគុណដល់សត្វសត្វ ដោយព្រះមហាករុណា ។

ព្រះបរិយត្តិសទ្ធម្ម គឺធម្មវិន័យ ដែលមានមកក្នុងព្រះត្រៃបិដកជា
សត្ថុសាសនៈ អាចជាតំណាងព្រះអង្គ តាំងពីទ្រង់គង់ព្រះជន្មទៅ
ខ្លើយ ហេតុនេះហើយ ទ្រង់ត្រាស់ថា "ធម្មោ
ឃើញធម៌ ធម្មោនោះឈ្មោះថាឃើញព្រះអង្គ" ទោះបីតុំបានជួបព្រះ
ភ័ក្ត្រព្រះអង្គក៏ដោយ ។ ឧណាគ្រាន់តែជួបព្រះភ័ក្ត្រព្រះអង្គ តែតុំមាន់
បានឃើញធម៌ ធម្មោនោះតុំអាចឈ្មោះថាបានឃើញព្រះអង្គខ្លើយ ។
លុះទៀបចូលបរិនិព្វានទ្រង់ត្រាស់ ១ ទៀបទៀតថា អំណើះពីព្រះអង្គ
ទៅ ធម្មវិន័យដែលទ្រង់បានសំដែងបានបញ្ញត្តហើយនឹងបាន
ជាសាស្តាតំណាងព្រះអង្គ ដូច្នេះតុន្ទបរិស័ទដែលបានប្រតិបត្តិតាម
ធម្មវិន័យ ឈ្មោះថាបានបូជាព្រះអង្គដោយសក្ការបូជាយ៉ាងប្រសើរបំផុត ។
តួកតុន្ទបរិស័ទដែលបានឃើញព្រះអង្គដោយវិចារណញ្ញាណ តាំងមាន

សេចក្តីស្នេហា កតញ្ញូ កតវេទី ចំពោះព្រះអង្គ ចង់ឲ្យព្រះអង្គទ្រង់គង់ព្រះជន្មនៅជាយូរព្រះមហាករុណាគុណ រមែងនាំគ្នាយកចិត្តទុកជាកំពូលព្រះសទ្ធម្មគោរពក្នុងព្រះសទ្ធម្ម លើកតំកើងនូវព្រះសទ្ធម្មដែលមានមកក្នុងព្រះត្រៃបិដក ដោយការសិក្សា ធំឯការប្រតិបត្តិតាមសីល សមាធិ បញ្ញា, ពោះបើលោកអ្នកចាំនោះអស់ការណីយកិច្ចផ្លាស់ខ្លួនហើយក៏ដោយ ការសន្ទនារឿងរៅបផ្សឹងផ្ងាត់ធម្មវិន័យក្តី រឿនខ្មែញធម្មវិន័យក្តី ផ្សាយធម្មវិន័យក្តី ជាការណីយកិច្ចនៃពុទ្ធសាវ័កចាំនឡាយ តាំងពីព្រះពុទ្ធជាអម្ចាស់ទ្រង់គង់ព្រះជន្មនៅឡើយ ។ ព្រះសារីបុត្តដែលជាតួអង្គអគ្គសាវ័ក ជាន់ក្រាបបង្គំទូលសុំព្រះពុទ្ធានុញ្ញាតប្រជុំសង្ឃធ្វើសង្គាយនាមួយគ្រា ។ ក្នុងការសង្គាយនានោះ អង្គលោកជាអ្នកសំដែងរៀបរៀងធម្មវិន័យក្នុងសង្ឃសន្និបាត នៅទីចំពោះព្រះភ័ក្ត្រនៃព្រះបរមសាស្តា លោកជាន់បញ្ជាក់ត្រង់កន្លែងធម៌ថា នេះជាធម្ម នេះជាវិន័យ នេះជាសត្ថុសាសន៍: លោកដំមានអាយុចាំនឡាយ តម្រូវចាំខុសដូច្នេះបុះ ។ ត្រាព្រះដ៏មានបុណ្យបរិនិព្វានហើយ ពុទ្ធសាវ័កចាំនឡាយ មានព្រះមហាកស្សបៈជាប្រធាន ជាន់ប្រជុំធ្វើសង្គាយនាដែលហៅថាបឋមសង្គាយនា ។ ក្នុងការសង្គាយនានេះ ជាន់លើកព្រះវិន័យមកសង្គាយនាជាមុន ទើបសង្គាយនាព្រះធម៌ តាព្រះសូត្រនិងព្រះ

អភិធម្ម ។ ព្រោះហេតុនោះ សត្ថុសាសនៈដែលភ្ជាប់មានឈ្មោះតែតិ-
ត្តិយ ១ វិន័យ ១ ក៏ជ្រុងជុំវៀនជាបិដកទាំង ៣ គឺ ព្រះវិន័យបិ-
ដក ១ ព្រះសុត្តន្តបិដក ១ ព្រះអភិធម្មបិដក ១ ។
ការសង្គាយនាបិដកទីមួយ ១ ចប់ ដោយយល់ឃើញត្រឹមតែថាជាធម៌
ជាវិន័យ ជាសត្ថុសាសនៈហើយ ក៏នាំគ្នាស្វាធ្យាយឲ្យបានចាំស្ទុះទាំង
អស់ រួចប្រកាសផ្សាយធម្មវិន័យ ជាបរមសព្ទព្រះជន្មរៀងខ្លួន ។

តតិយោនេះមកចេះតែមានការសង្គាយនាជាលំដាប់ គឺទុតិយសង្គាយនា
តតិយសង្គាយនា ចតុត្ថសង្គាយនាជាដើម តាំងពីអរហន្តសម័យ ជាប
ដល់សម័យនេះ ។ ក៏ស្តុតាងជ្រុងជុំកុងប្រវត្តិព្រះសាសនា សង្គាយ-
នានៅជម្ពូទ្វីបមជ្ឈិមប្រទេស (ឥណ្ឌា) ៣គ្រា ។ នៅលង្កាទ្វីប ២ គ្រា
ទីឆ៏នៅឧបទ្វីបសុវណ្ណភូមិយើងនេះច្រើនគ្រា ដូចជានៅប្រទេសភូមា ទីឆ៏
ប្រទេសកម្ពុជាយើងនេះជាដើម ។ ការសង្គាយនាទាំងនេះ សុទ្ធតែជា
របស់ដ្ឋ មានអគ្គីព្រះមហាក្សត្រ័យ ឬប្រធានាធិបតី ជាព្រះសាសនូ-
បត្ថម្ភក៍ ។

ការសង្គាយនាទាំងឡាយ ដែលមានមកហើយ តាំងពីព្រះសត-
វត្សរ៍ទី ១ ជាបដល់ព្រះសតវត្សរ៍ទី ២៥ ដែលខ្ញុំបកន្ទួរទៅនេះ សុទ្ធ
តែមានការផ្ទៀងផ្ទាត់ជាលិព្រះត្រៃបិដក ឲ្យត្រឹមត្រូវតាមបែបបទសង្គា-
យនាដូចគ្នាទាំងអស់ ។

ការសង្គាយនាព្រះត្រៃបិដក របស់រដ្ឋកម្ពុជាយើង ចាប់ផ្តើមធ្វើមកតាំងពីក្នុងរជ្ជកាល នៃព្រះករុណាព្រះបរមនត្ថិយកោដ្ឋ ដោយព្រះសង្ឃជាសន្និតិកាចារ្យច្រើនរូប ដែលហៅថាក្រុមដំបូងព្រះត្រៃបិដក នៅក្រុមភ្នំសាសនបណ្ឌិត្យ ចានប្រដុំធ្វើនឆ្លាក់ព្រះត្រៃបិដកភាសាបាលី រួចប្រែជាសម្រាយភាសាខ្មែរពាល់តែចប់ ។

យើងជាពុទ្ធបរិស័ទ គួរញ៉ាំងចិត្តឲ្យជ្រះថ្លាក្នុងព្រះត្រៃបិដកនេះ គួរមើល គួរអាន គួរពិនិត្យ គួរជាវិធីកជាសម្បត្តិប្រចាំជីវិត ព្រោះជាក្បួនច្បាប់មានសារប្រយោជន៍ខ្ពង់ខ្ពស់បំផុត អាចញ៉ាំងដំណឹងខាងពុទ្ធសាសនា ឲ្យច្បាស់ច្រាកដឡើង ដល់មនុស្សនឹងទេពតា ទាំងអាចញ៉ាំងសារធម៌ គឺសីល សមាធិ បញ្ញា ឲ្យផ្សាយជ្រួតជ្រាបទៅកងសន្តានៃសត្វលោកផង ។

យើងកាល់តែ ដែលបានសៀវភៅព្រះត្រៃបិដកចោះពុម្ព ជាច្បាលីខ្មែរ សម្រាយខ្មែរកាល់ខំតែរបៀបនេះប្រសើរណាស់ ប្រៀបដូចបានប្រទីបប្រាសាទធំ ។ ពីរដួរ តាំងនៅអមផ្លូវទាំងសងខាង ដែលជាផ្លូវដើរទៅគាន់ពីក្បែរក្បាន្ត ខ្នុរក្តូ ខ្នុរកំយ ។

ម្ួយទៀត ការសង្គាយនាត្រះសុត្តន្តក៏ ការដួយខូចត្រូវកងការសង្គាយនាដោយតិចផ្សេង ។ ក្តី ដែលទំនឹកគិតឡើងបាន កំដោយសារមានរយៈពេលវែងសំខាន់ ។ មានដើមដូចតទៅនេះ ៖

១- ព្រះពុទ្ធជាម្ចាស់ មិនដាច់កើតមានក្នុងលោក ព្រោះត្រូវកសាងអភិនីហារអស់កាលយូរអង្វែងណាស់ ទើបបានត្រាស់ជាព្រះពុទ្ធ ។ កាលបើព្រះពុទ្ធមិនដាច់កើតមានហើយ ព្រះសទ្ធម្ម គឺធម្មវិន័យ ជាសត្ថុសាសន៍ក៏មិនដាច់កើតមានដែរ ។ ព្រះសទ្ធម្មចាំងឡាយ មានព្រះបរិយត្តិសទ្ធម្មជាដើម សុទ្ធតែមានព្រះត្រៃបិដកនេះជាប្រកាត ប្រៃសេចក្តីថា យើងគួរតែស្វះស្វែងរកព្រះសទ្ធម្មក្នុងព្រះត្រៃបិដកនេះឯង ។

២- ការសំដែងព្រះសទ្ធម្ម ស្តាប់ព្រះសទ្ធម្ម, រៀនសូត្រព្រះសទ្ធម្ម, ប្រតិបត្តិញ៉ាំងព្រះសទ្ធម្ម ឲ្យកើតមានក្នុងសន្តាន នេះរមែងប្រព្រឹត្តទៅដើម្បីសុខសន្តិភាព ។ ហេតុនេះ ទើបអ្នកប្រាជ្ញចាំងឡាយមានព្រះពុទ្ធជាដើម តែងព្រះទ័យណាស់ក្នុងការផ្សាយព្រះសទ្ធម្ម ដើម្បីប្រយោជន៍ដល់សព្វសត្វ ។

៣- ការសាងបារមី ដើម្បីត្រាស់ជាព្រះពុទ្ធ ឧឡឹកការបំពេញពុទ្ធកិច្ច មានប្រកាសព្រះសទ្ធម្មទេសនាជាដើម ដោយព្រះមហាករុណានៃព្រះពុទ្ធជាអម្ចាស់យើង ធ្វើឲ្យព្រះអង្គលំបាកព្រះកាយហួសប្រមាណមុខគួរសំវែង ការណាចការណិតព្រះទ័យព្រះអង្គណាស់ ។ ហេតុនេះ យើងជាពុទ្ធបរិស័ទ គួរទំប្រតិបត្តិឲ្យសមតាមព្រះពុទ្ធបំណង ។

៤- ព្រះពុទ្ធជាបរមសាស្តាយើង ទ្រង់លះបង់ទ្វេបច្ចួលកាន់ព្រះបរមនិព្វានកន្លងមកជាងពីរភាន់ប្រាំរយឆ្នាំហើយ មានតែព្រះសទ្ធម្ម គឺព្រះ

ព្រៃត្រមិដកជាពុទ្ធវចនៈនេះហើយ ដែលបិតនៅជាតំណាងព្រះអង្គ ។ បើ
យើងជាពុទ្ធបរិស័ទមិនយកចិត្តទុកជាក់ ធ្វើសក្ការៈគោរពប៉ះអានបូជាព្រះ
សទ្ធម្មគឺព្រះត្រៃត្រមិដកជាតំណាងព្រះអង្គ ដោយអាមិសបូជា ខ្ជិលដោយ
បដិបត្តិបូជាទេ តើទៀនណាយកចិត្តទុកជាក់ដំខ្ជួសវិញ ។

៩- ព្រះពុទ្ធសាសនាដែលខ្ជិនរុងរឿងបិតបៀរចំរាលៅបាន ក៏
ដោយសារសម្មាបដិបត្តិនៃពុទ្ធបរិស័ទទាំងអស់គ្នា ដែលមានការរៀន
ខ្នះខ្នែញ្ញាននមើល ខ្លួវព្រះត្រៃត្រមិដកនេះជាមូលហេតុ ។ ចុះបើយើងជា
ពុទ្ធបរិស័ទ មិនយកចិត្តទុកជាក់ក្នុងការរៀននេះហើយ តើពុទ្ធសាសនា
ខ្ជិនសង្ឃឹមលើនរណា ។ យើងតែងបានដឹងថា ព្រះពុទ្ធជាម្ចាស់ទ្រង់
ត្រាស់ថាសាសនាព្រះអង្គខ្ជិនរុងរឿង ដោយសារបរិស័ទដែលជាកូនចៅ
ព្រះអង្គ ទំរៀន ទំប្រតិបត្តិតាម ។ ព្រោះការរៀន ការប្រតិបត្តិនេះ
ហើយជាគ្រឿងប្រកាសគុណព្រះរតនត្រ័យឲ្យប្រាកដ ។

៦- មនុស្សទំកក្នុងលោកសន្និវាសសព្វថ្ងៃនេះ កំពុងអំភាវនាវ
ស្រែករកសន្តិភាព ។ បើអត្ថាសព្រះសទ្ធម្មក្នុងព្រះបិដកទាំង ៣ បាន
ផ្សាយជ្រួតជ្រាបទៅក្នុងពួកមនុស្សនោះសកលលោក យ៉ាងហោចឲ្យបាន
ត្រឹមសីល ៥ ដែលហៅថានិច្ចសីល ការកំតាវនាវរកសន្តិភាពនោះ
មុខជាបានសំរេចផលតាមបំណង ។

ដោយអាស្រ័យយើងជាភ្នួបរិស័ទតាំងអស់គ្នា មានយោបល់ស្រួបគ្នាបែបនេះ ទើបដួលយើងអាចធ្វើសង្គាយនាព្រះសទ្ធម្ម គឺព្រះត្រៃបិដកជាភ្នួវចនៈ ឲ្យបានសម្រេចផលដូចបុរេមក ទីឆ៍ដូចបុរេខ្មែត ។

កាលបើយើងបានសង្គាយនា ទីឆ៍ដួយទុបគម្ពកឆ៍ការនេះ ដោយយើញថា អំពើប្រសើរនេះ ជាការណ៍យកច្ចប្រយោជន៍ដែលជាភ្នួបរិស័ទ កូនចៅព្រះសម្មាសម្ពុទ្ធ គួរតែធ្វើដើម្បីសំដែងសេចក្តីកតញ្ញូកតវេទិចំពោះព្រះអង្គដួចេះ ។ ទោះយើងទីឆ៍បានសម្រេចផលានិសង្សយ៉ាងខ្ពង់ខ្ពស់ កាលទឹកដល់អំពើដែលខ្លួនបានធ្វើហើយនេះគ្រាណា គ្រានោះសេចក្តីសោមនស្សជ្រះថ្លា ទីឆ៍កើតមានដល់យើងមិនតិចម្លើយ ។ ម្ល៉ោះហើយ បុញ្ញាភិសន្ទៈ ស្ទឹងបុណ្យគឺសេចក្តីស្ងប់ ទីឆ៍សេចក្តីសុខសួស្តី រមែងហូរមកកាន់ខ្លួនសន្តាន តាំងយប់តាំងថ្ងៃ តាមដែលយើងទឹកយកអំពើនេះមកជាគាម្មណ៍ ។

សំដែងមកក្នុងព្រះសទ្ធម្ម ធម៌ស្ងប់នាំឲ្យកើតសន្តិភាព ទីឆ៍សន្តិសុខ ដែលសាធុជនគួរគោរព គួរបូជា ដោយអាមិស ទីឆ៍ដោយសេចក្តីប្រតិបត្តិចប់ដោយសង្ខេបតែប៉ុណ្ណេះ ។

អ្នកឧកញ៉ា ជា-សាន អតីតរដ្ឋមន្ត្រីរៀបរៀង

(តមក)

๓ - អប្បណិហិតវិមោក្ខ គឺការរួចផុតស្រឡះចាកកិលេស ដោយគ្មានទីតាំងកិលេស ๑ ។

រីឯវិមោក្ខ ๓ វិញ គឺបញ្ជាក់ថា ចិត្តដែលរួចផុតស្រឡះចាកកិលេសគឺរួចចាកដោយសូន្យកិលេស ๑ ដោយគ្មានត្រឿងសំគាល់កិលេស ๑ ទំនងដោយគ្មានទីតាំងកិលេស ๑ ពោលគឺដោយកិលេសរលត់អស់គ្មានសេសសល់នោះឯង ។ ដោយហេតុនេះ ទើបវិមោក្ខ៣ប្រការ ត្រូវចាត់ទុកជាឧទ្ទិដ្ឋរួបនៃកិរិយារលត់អស់ទៅនៃកិលេស ហើយវិមោក្ខ៣នោះ មានតែព្រះអរហន្តដែលបានសម្រេចមគ្គចិត្ត ๔ ទំនងផលចិត្ត ๔ នោះទេ ដែលអាចធ្វើឲ្យជាក់ច្បាស់ឡើងបានដោយចំរើនអនុបស្សនា ๓ គឺ សុញ្ញតានុបស្សនា ๑ អនិមិត្តានុបស្សនា ๑ ទំនង អប្បណិហិតានុបស្សនា ๑ កិរិយាធ្វើឲ្យជាក់ច្បាស់នូវវិមោក្ខ ๓ ប្រការនេះហើយដែលហៅថា ឯត្ថាឧសច្ឆិតកិរិយា គឺកិរិយាធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានខាងនោះឯង ។

លំដាប់តទៅនេះ ខ្ញុំនឹងធ្វើអត្ថាធិប្បាយអំពីផលចិត្ត ๔ ដួង ដែលកើត

មានឡើងដោយមគ្គចិត្ត ៤ ដួងជាមូលហេតុ ដូចមានសេចក្តីបញ្ជាក់ខាងក្រោមនេះ ។

៩- ផលចិត្ត ៤ ដួង

ចំណែកផលចិត្ត ៤ ដួង ដែលត្រូវជាគូនឹងមគ្គចិត្ត ៤ ដួងនោះគឺ៖

ផលចិត្តទី ១- ឯផលចិត្តទី ១ នោះ គឺសំដៅចំពោះផលចិត្តដែលកើតមានឡើងដោយមគ្គចិត្តទី ១ ជាមូលហេតុនោះឯង ។ ដោយហេតុនេះទើបផលចិត្តទី ១ នេះ ត្រូវចាត់ទុកជាផលចិត្តបានរួចផុតស្រឡះចាកឥដ្ឋាសវៈ ៩ សំយោជនៈ ៣ គឺសក្កាយទិដ្ឋិ ១ វិចិកិច្ឆា ១ និងសីលព្វតបរាមាស ១ ប្រកបដោយវិសុទ្ធិ ៥ មានទិដ្ឋិវិសុទ្ធិជាដើម ហើយត្រូវបានឧទ្ទាត្តិហៅថា សោតាបត្តិផល នោះ ។

ផលចិត្តទី ២- ឯផលចិត្តទី ២ នោះ គឺសំដៅចំពោះផលចិត្តដែលកើតមានឡើងដោយមគ្គចិត្តទី ២ ជាមូលហេតុនោះឯង ។ ដោយហេតុនេះទើបផលចិត្តទី ២ នេះ ត្រូវចាត់ទុកជាផលចិត្តបានញ៉ាំងកាមាសវៈ ឥដ្ឋាសវៈ សំយោជនៈ ២ គឺ កាមរាគៈ និងបដិឃៈ ឲ្យស្ងប់រម្ងាប់ស្រាលស្តើង ហើយត្រូវបានឧទ្ទាត្តិហៅថា សកទាគាមិផល នោះ ។

ផលចិត្តទី ៣ -ឯផលចិត្តទី ៣ នោះ គឺសំដៅចំពោះផលចិត្តដែលកើតមានឡើងដោយមគ្គចិត្តទី ៣ ជាមូលហេតុនោះឯង ។ ដោយហេតុ

ខេះទើបផលចិត្តទី ៣ ត្រូវចាត់ទុកជាផលចិត្តជាន់ទួចផុតស្រឡះចាក កាមាសវៈ ឆ្ងាំ សំយោជនៈ ៦ គឺកាមរាគ ឆ្ងាំបដិឃៈព្រម ទាំងកាមតណ្ហាប្រកបដោយចិត្តវិសុទ្ធិ ហើយត្រូវបានឈ្មោះហៅថា អនាគាមិផលនោះ ។

ផលចិត្តទី ៤- ឯផលចិត្តទី ៤ នោះ គឺសំដៅចំពោះផលចិត្តដែល កើតមានឡើងដោយ មគ្គចិត្តទី ៤ ជាមូលហេតុនោះឯង ។ ដោយហេតុ ខេះ ទើបផលចិត្តទី ៤ នេះ ត្រូវចាត់ទុកជាផលចិត្តជាន់ទួចផុតស្រឡះចាក ភវាសវៈ ឆ្ងាំ អវិជ្ជាសវៈ ហើយឆ្ងាំ សំយោជនៈ ៥ មានរូបរាគ ឆ្ងាំអរូបរាគជាដើម ព្រមទាំងតណ្ហា ២ គឺភវតណ្ហា ឆ្ងាំ វិភវតណ្ហា ប្រកប ដោយវិសុទ្ធិ ២ គឺ បញ្ញាវិសុទ្ធិ ឆ្ងាំ វិមុត្តិវិសុទ្ធិ ហើយត្រូវបាន ឈ្មោះហៅថា អរហត្តផល នោះឯង ។ រួមសេចក្តីពោលយើញថា ផលចិត្ត ៤ ដួងនេះជាន់ទួចផុតស្រឡះចាកអាសវៈ ៤ ឆ្ងាំសំយោជនៈ ១០ ហើយឆ្ងាំតណ្ហា ៣ ប្រកបដោយវិសុទ្ធិ ៧ ប្រការ ត្រូវតាមកំរិតដែល កំណត់ទុកពេញបរិបូណ៌អស់ហើយ ។ បើដូច្នេះ គប្បីពោលសួរថា តើ ផលចិត្ត ៤ ដួងនេះអាចផ្តល់ឱ្យអំរើយបុគ្គលខ្លួនឯងមានប្រយោជន៍អ្វីខ្លះទៅ ? ។

ចំពោះសំនួរនេះ ខ្ញុំសូមឆ្លើយថា ផលចិត្ត ៤ ដួងនេះ កាលបើជាន សម្រេចកើតមានឡើងហើយ រមែងនាំមកនូវឧត្តមសុខ ៤ ប្រការជា ដើម ដូចមានសេចក្តីបញ្ជាក់ខាងក្រោមនេះ ។

១០- សុខ ៤ ប្រការ

ឯសុខ ៤ ប្រការ ដែលកើតមានឡើងដោយផលចិត្ត ៤ ដួងនោះ ត្រូវរៀបជា ២ ប្រភេទដូចតទៅនេះ ៖

សុខ ៤ ប្រការប្រភេទទី ១

បើតាមលំដាប់សុខ ៤ ប្រការ ដែលកើតមានឡើងដោយផលចិត្ត ៤ ដួង បានរួមចាកអាសវៈ ៤ នោះ ដើមសុខ ៤ ប្រការនោះត្រូវចាត់ទុកជាអាសវសុខ ៣ ឧត្តមអនាសវសុខ ១ គឺ ៖

អាសវសុខ ទី ១- ឯសុខចិត្ត ដែលកើតមានឡើងដោយផលចិត្តចិត្ត បានរួមចាកទិដ្ឋាសវៈនោះ ត្រូវចាត់ទុកជាអាសវសុខចិត្ត គឺសុខប្រកបដោយអាសវៈ ៣ គឺ កាមាសវៈ ១ ភវាសវៈ ១ ឧត្តម អវិជ្ជាសវៈ ១ ។

អាសវសុខ ទី ២- ឯសុខចិត្ត ដែលកើតមានឡើងដោយផលចិត្តចិត្ត បានញ៉ាំងកាមាសវៈឲ្យសាបសូន្យស្រឡះស្រឡាំងនោះ ត្រូវចាត់ទុកជាអាសវសុខចិត្ត គឺសុខប្រកបដោយអាសវៈ ៣ ដែរ តែកាមាសវៈបានសាបសូន្យស្រឡះស្រឡាំងហើយនោះ ។

អាសវសុខ ទី ៣- ឯសុខចិត្ត ដែលកើតមានឡើងដោយផលចិត្តចិត្ត បានរួមចាកកាមាសវៈនោះ ត្រូវចាត់ទុកជាអាសវសុខចិត្ត គឺសុខប្រកបដោយអាសវៈ ២ គឺ ភវាសវៈ ១ ឧត្តម អវិជ្ជាសវៈ ១ នោះ ។

អជាសវ៌សុខ។ ឯសុខធី ៤ ដែលកើតមានឡើង ដោយផលចិត្ត
ធី ៤ ជានរួចពីកកកសវ: ឧឹង អវិជ្ជាសវ:នោះ ត្រូវចាត់ទុកជាអនាសវ.
សុខតឺ សុខមិនប្រកបដោយអាសវ: ៤ ដោយប្រការដូច្នេះឯង ។

សុខ ៤ ប្រការប្រភេទទី ២

បើពោលអំពីសុខ ៤ ប្រការ ដែលកើតមានឡើងដោយផលចិត្ត ៤
ដួងនោះជានរួចពីកសំយោជន: ១០ វិញនោះ ទើបសុខ ៤ ប្រការនោះ
ត្រូវចាត់ទុកជាអាមិសសុខ ៣ ឧឹង និរាមិសសុខ ១ ដូចមានសេចក្តី
បញ្ជាក់ខាងក្រោមនេះ ៖

អាមិសសុខធី ១– ឯសុខធី ១ ដែលកើតមានឡើងដោយផល
ចិត្តធី ១ ជានរួចពីកសំយោជន: ៣ មានសក្កាយទិដ្ឋិជាដើមនោះ ត្រូវចាត់
ទុកជាអាមិសសុខធី ១ តឺសុខប្រកបដោយសំយោជន: ៧ មានកាមរាគជា
ដើម ឧឹងតណ្ហា ៣ មានកាមតណ្ហាជាដើមនោះ ។

អាមិសសុខធី ២ – ឯសុខធី ២ ដែលកើតមានឡើងដោយផល
ចិត្តធី ២ ជានញ្ជាំងកាមរាគ ឧឹងបដិឃ: ទ្បើសាបរលាបស្រាលស្តើងនោះ
ត្រូវចាត់ទុកជាអាមិសសុខធី ២ តឺសុខប្រកបដោយ សំយោជន: ៧ ឧឹង
តណ្ហា ៣ដែរ តែសំយោជន: ២ តឺកាមរាគ ឧឹងបដិឃ: ហើយឧឹងកាម-
តណ្ហាជានស្រាលស្តើងហើយ ។

អាមិសសុខធី ៣ – ឯសុខធី ៣ ដែលកើតមានឡើងដោយផល

ចិត្តដែ ៣ ជាន់ចូលចាកតាមកាត ទើបដល់ឃៈនោះ ត្រូវចាត់ទុកជាអាមិសសុខ
ដែ ៣ គឺសុខប្រកបដោយសំយោជនៈ ៥ មានប្រភេទជាដើម ទើងតណ្ហា ២
គឺកវតណ្ហា ទើងវិកវតណ្ហានោះ ។

ឯកមិសសុខ ១- ឯសុខដែ ៤ ដែលកើតមានឡើងដោយផលចិត្ត
ដែ ៤ ជាន់ចូលចាកសំយោជនៈ ៥ មានប្រភេទជាដើមនោះត្រូវចាត់ទុកជានិក.
មិសសុខ គឺសុខមិនប្រកបដោយ អាមិស គោលគឺដោយសំយោជនៈ
ទើងតណ្ហានោះឯង ។

១១- អរិយបុគ្គល ៤ ពួក

ឯអរិយបុគ្គល ៤ ពួកនោះគឺ៖

១- អរិយបុគ្គល ដែលជាន់សម្រេចមគ្គចិត្តដែ ១ ទើងផលចិត្តដែ ១
ហើយទើងអាសវៈសុខដែ ១ នោះត្រូវមានឈ្មោះហៅថា ព្រះសោតាបន្ន
គឺអរិយបុគ្គលដែលជាន់ទៅដល់ដំណាក់ដែ ១ នៃដំណើរឆ្ពោះទៅកាន់បរម.
សុខនោះ ។

២- អរិយបុគ្គល ដែលជាន់សម្រេចមគ្គចិត្តដែ ២ ទើងផលចិត្តដែ ២
ហើយទើងអាសវៈសុខដែ ២ នោះត្រូវជាន់ឈ្មោះហៅថា ព្រះសកទាគាមី
គឺអរិយបុគ្គល ដែលជាន់ទៅដល់ដំណាក់ដែ ២ នៃដំណើរឆ្ពោះទៅកាន់
បរមសុខនោះ ។

៣- អរិយបុគ្គល ដែលជាន់សម្រេចមគ្គចិត្តដែ ៣ ទើងផលចិត្ត

ទី៣ ហើយនឹងអាសវៈសុខទី៣ នោះត្រូវបានតាមប្បញ្ញត្តិហៅថាព្រះអនាគាមីគឺអរិយបុគ្គលដែលបានទៅដល់ដំណាក់ទី៣ នៃដំណើរឆ្ពោះទៅកាន់បរមសុខនោះ ។

៤-អរិយបុគ្គល ដែលបានសម្រេចមគ្គចិត្តទី៤ នឹងផលចិត្តទី៤ ហើយនឹងអនាសវៈសុខនោះ ត្រូវបានតាមប្បញ្ញត្តិហៅថា ព្រះអរហន្ត គឺអរិយបុគ្គល ដែលបានទៅដល់ដំណាក់ទី៤ ទុកជាដំណាក់ចុងក្រោយបំផុតនៃដំណើរឆ្ពោះទៅកាន់បរមសុខហើយ ។

ត្រង់នេះខ្ញុំសូមថ្លែងបញ្ជាក់តាមយោបល់ខ្ញុំថា អរិយបុគ្គល ៤ ពួកនេះ លុះណាតែបានសម្រេចមគ្គចិត្ត ៤ ផលចិត្ត ៤ នឹងសុខ ៤ ប្រការ ដូចមានពណ៌នាខាងលើនេះ ទើបឈ្មោះថាបានគ្រាស់ដឹងមគ្គ ៤ មានសោតាបត្តិមគ្គជាដើម នឹងផល ៤ មានសោតាបត្តិផល ជាដើមនោះឯង ។

១២- បរមសុខ:

ចំពោះបរមសុខនេះមានបញ្ហាមួយចោទឡើងថា : បើសុខដែលកើតមានឡើងដោយផលចិត្ត ៤ ដួង មានតែ ៤ ប្រការ គឺអាសវៈសុខ ៣ នឹងអនាសវៈសុខ ១ ប៉ុណ្ណោះទេ, តើបរមសុខជាសុខកើតមានឡើងដោយចិត្តប្រភេទណាជាពិសេសទៀត ?

រីឯបញ្ហាដែលចោទឡើងនេះ, បើតាមការត្រិះរិះពិចារណាដែលខ្ញុំបានធ្វើនោះខ្ញុំយល់ឃើញថា បរមសុខនោះ គឺគ្រាន់តែជាតាមប្បញ្ញត្តិសម្រាប់

ខុតហៅសុខ ៥ ដែលកើតមានឡើងដោយផលចិត្ត ៤ ជាន់ទាំងនៅ
សល់ក្នុងរវាងមាត្រ ៣ ប្រការ គោលនឹកក្នុងការរួមផុតស្រឡះចាកកិលេសដោយ
សួនឯកិលេស ១ ដោយគ្មានត្រឹមសំតាល់កិលេស ១ នឹងដោយគ្មាន
ទីតាំងកិលេស ១ ខុតជាឯការម្មណ៍នោះឯង ពីព្រោះផលចិត្ត ៤ តាល
បើបានតោងយកវរមាត្រ ៣ ធ្វើជាឯការម្មណ៍ហើយ រមែងជាហេតុធ្វើឲ្យ
អាសវក្កិលេសរលត់អស់ពីសន្តាន ព្រមទាំងជាហេតុធ្វើឲ្យអនាសវសុខ
ដែលជាសុខទី ៤ ប្រែសភាពកើតទៅជាអាសវក្ខយសុខ គឺសុខប្រកប
ដោយអាសវក្ខយវិញជាលំដាប់ ។

គឺអាសវក្ខយសុខនេះហើយដែលត្រូវចាត់ខុតជាសុខទី ៥ ដែលកើត
មាននឡើងបន្ទាប់ពីអនាសវសុខ ហើយត្រូវបាននាមប្បញ្ញត្តិហៅថាបរមសុខ
គឺសុខដ៏ខ្ពង់ខ្ពស់គ្មានសុខណាអាចមកប្រៀបធៀបឲ្យស្មើបាននោះទេឯង ។

ម្យ៉ាងទៀត មានតែព្រះអរហន្ត ដែលបានសម្រេចនូវអាសវក្ខ-
យញ្ញាណហើយបាននឡើងជានេះជាព្រះនិព្វានស្រេចនោះទេ ដែលត្រូវ
បានទទួលសោយនូវបរមសុខ គោលគឺអាសវក្ខយសុខនោះឯង ។

ត្រង់នេះសេចក្តីឲ្យយើញច្បាស់ថា បរមសុខក្តី ឯកន្តបរមសុខក្តី
និព្វានក្តី គឺគ្រាន់តែជានាមប្បញ្ញត្តិសម្រាប់ខុតហៅ អាសវក្ខយសុខតែ
ប៉ុណ្ណោះ ពីព្រោះអាសវក្ខយសុខ គឺសុខប្រកបដោយអាសវក្ខយនោះ
ជាកំពូលលើសុខទាំងឡាយមានអាសវសុខ ៣ ប្រការជាដើម ។ ដោយ

ហេតុនេះហើយបានជាបណ្ឌិតលោកលើកយកតែបរមសុខ ឬឯកន្តសុខ ឬនិព្វាន ដែលជានាមនៃអាសវក្ខយសុខនោះមកថ្លែងប្រាប់បតូ ដើម្បីឲ្យកុំការៈឲ្យសត្វត្រិះរិះពិចារណាពីរកឲ្យឃើញនូវរូប នៃបរមសុខ ឬនិព្វាន ដោយខ្លួនឯងចុះ ។ ចំណែកឯមគ្គចិត្ត ៤ ផលចិត្ត ៤ ក៏មានដំណើរដូចនេះដែរ គឺបណ្ឌិតលោកលើកយកតែមគ្គ ៤ ផល ៤ មកថ្លែងប្រាប់សត្វ ពុំឲ្យសត្វត្រិះរិះពិចារណាពីរកឲ្យឃើញច្បាស់ដោយខ្លួនឯងនូវរូបនៃមគ្គ ៤ ផល ៤ នោះចុះ ។ ម្យ៉ាងវិញទៀត ដោយបរមសុខ ជាសុខប្រកបដោយអាសវក្ខយនោះ ទើបខ្ញុំយល់ឃើញថា តម្រិះតែកញ្ជោកបរមសុខនោះជា ៦ វិភាគឲ្យស្រេចទៅតាមហេតុនីមួយគឺ ៖

- បរមសុខដែលសម្រេចកើតឡើងដោយក្លើនកិលេសរលត់ ត្រូវបាននាមប្បញ្ញត្តិ ហៅថា ឧភាតិសេសនិព្វាន ១ ,

- នីមួយបរមសុខដែលសម្រេចកើតឡើងដោយក្លើនពុក្ខរលត់ ត្រូវបាននាមប្បញ្ញត្តិហៅថា អនុបាទិសេសនិព្វាន ១ ។

រីឯបរមសុខដែលសម្រេចកើតឡើង ដោយក្លើនកិលេសរលត់នោះ ពុកជាបរមសុខក្នុងបច្ចុប្បន្ន ដែលព្រះខីណាស្រពតប្បីបានខន្ធសោយនៅខណៈដែលព្រះខីណាស្រពតអង្គនោះ បានឆ្លងនិព្វានសច្ចកិរិយាឲ្យច្រើនជាច្បាស់ដោយវិមោក្ខ ៣ ប្រការនោះឯង ។ ចំណែកឯបរមសុខដែលសម្រេចកើតឡើងដោយក្លើនពុក្ខរលត់នោះ ពុកជាបរមសុខនៅអនាគត

ដែលត្រះទ័ណាស្រេតតប៉ុន្តែទទួលសោយ ទៅតែលដែលត្រះទ័ណាស្រេតអង្គនោះបានលែងអាយុសង្ខារបួលកាន់ត្រះនិព្វាន ធ្វើដំណើរឆ្ពោះទៅកាន់អាសាទជាតិ គឺជាតិចុងក្រោយបំផុត លែងមានដំណើរវិលកើតវិលស្លាប់ទៀត ដោយប្រការដូច្នេះឯង ។

១៣- សេចក្តីប្រៀបធ្ងឹមរវាងសុខ ៣ ប្រការ :

សរុបសេចក្តីទៅយើញថា លោកុត្តរចិត្ត ៨ដួង គឺមគ្គចិត្ត ៤ ដួង ផលចិត្ត ៤ ដួងនោះ កាលបើបានសម្រេចកើតមានក្នុងខន្ធសន្តានហើយ រមែងតែនាំមកនូវអាសវសុខ ៣ ឥន្ទ្រិយអាសវសុខ ១ ហើយឥន្ទ្រិយមសុខ ១ ពុំមានឡើយ ។ ដើម្បីឲ្យយល់បានដោយងាយនូវសុខមាលភាពនៃសុខ ៥ ប្រការនោះរឿងជាលំដាប់, ខ្ញុំឥន្ទ្រិយលើកយកចេតសិកសុខ គឺសុខខាងផ្លូវចិត្ត ៧ ប្រការមកធ្វើសេចក្តីប្រៀបធ្ងឹមចាប់ពីកាមសុខរឿងទៅទល់ឥន្ទ្រិយមសុខដែលជាកំពូលនៃសុខទាំងឡាយ ដូចមានសេចក្តីអធិប្បាយតទៅនេះ :

១- កាមសុខ គឺសុខដោយការបរិភោគកាមនោះ ត្រូវចាត់ទុកជាសុខប្រកបដោយសំយោជនៈ១០ដែរ ។ ឯកាមសុខជាសុខប្រសើរបេស់ពួកត្រហស្ថមែនហើយ តែកាមសុខនេះមិនប្រសើរដល់នេក្ខម្មសុខទៀត។

២- នេក្ខម្មសុខ គឺសុខដោយការចេញចាកកាមនោះ ត្រូវចាត់ទុកជាសុខប្រកបដោយសំយោជនៈ ១០ ដែរ តែសំយោជនៈ ៣ ខាង

ដើម តែសក្កាយទិដ្ឋិ ១ វិចិកិច្ឆា ១ ទីឆសីលព្វតបរាមាស ១ ជាន់សោបរលោបស្រាលស្តើងហើយ ។ ឯនេក្ខម្មសុខពុំជាសុខប្រសើរបស់ពួកបព្វជិតមែនហើយ តែនេក្ខម្មសុខនេះមិនប្រសើរដល់អាមិសសុខទី ១ ទៀត ។

៣- អាមិសសុខទី ១ គឺសុខប្រកបដោយសំយោជនៈ ៧ មានកាមរាគជាដើម ពុំជាសុខប្រសើរបស់ព្រះសោតាបន្នមែនហើយ តែអាមិសសុខទី ១ នេះ មិនប្រសើរដល់អាមិសសុខទី ២ ទៀត ។

៤- អាមិសសុខទី ២ គឺសុខប្រកបដោយសំយោជនៈ ៧ ដែរ តែកាមរាគ ទីឆដាយៈបានសោបរលោបស្រាលស្តើងហើយ ពុំជាសុខប្រសើរបស់ព្រះសកទាគាមីមែនហើយ តែអាមិសសុខទី ២ មិនប្រសើរដល់អាមិសសុខទី ៣ ទៀត ។

៥- អាមិសសុខទី ៣ គឺសុខប្រកបដោយសំយោជនៈ ៥ មានរូបរាគជាដើម ពុំជាសុខប្រសើរបស់ព្រះអនាគាមីមែនហើយ តែអាមិសសុខទី ៣ នេះ មិនប្រសើរដល់និរាមិសសុខ គឺសុខមិនប្រកបដោយសំយោជនៈ ១០ ទៀត ។

៦- និរាមិសសុខ គឺសុខមិនប្រកបដោយសំយោជនៈ ១០ ពុំជាសុខប្រសើរបស់ព្រះអរហន្តមែនហើយ តែនិរាមិសសុខនោះមិនប្រសើរដល់បរមសុខទៀត ។

៧- បរមសុខ គឺសុខប្រកបដោយអាសវក្ខ័យ ពុកជាសុខប្រសើរបំផុតរបស់ព្រះវិណាស្រេច, គ្មានសុខណាអាចមកប្រៀបផ្ទឹមបានឡើយ ។

សេចក្តីប្រៀបធៀបរវាងសុខ ៧ ប្រការនេះ ទាំងឲ្យសង្កេតយើញថា ខេត្តមួយសុខ គឺជាសុខបានសេរីពិតទៅមែនជាធំធេងអាមិសសុខទី ១ ឬអាសវសុខទី ១ ដែលជាសុខនៃព្រះសោតាបន្នបុគ្គលណាស់ទៅហើយ ។ ត្រង់នេះសេចក្តីឲ្យយើញច្បាស់ថា ពួកបព្វជិត លោកទៅតែញុំាងចិត្តឲ្យ-សាះធំធេងយ៉ាងនេះ ៣ ទាំងដើមឲ្យជាប់អស់តិចតួចសន្តានដោយវិបស្សនា-ការនាទៅ តើលោកមុខតែធំធេងបានសម្រេចនូវអាមិសសុខទី ១ ឬអាសវសុខទី ១ តុំបានឡើយ ។

១៤- បញ្ហាដែលចោទមានទ្បើងដោយសុខ ៥ ប្រការ

សេចក្តីអធិប្បាយអំពីសុខ ៥ ប្រការ ដែលកើតមានឡើងដោយផលចិត្ត ៤ ជួនខ្លះជាហេតុនាំឲ្យមានបញ្ហាមួយចោទឡើងថា ៖

បើសុខ ៥ ប្រការនោះពិតជាខេតសិកសុខគឺសុខទាំងផ្លូវចិត្តប្រសើរមែន តើហេតុដូចម្តេចបានជាពុទ្ធបរិស័ទភាគច្រើន ហាក់ដូចជាពុំសូវអើពើយកចិត្តទុកដាក់ចាប់អារម្មណ៍ទៅកសុខ ៥ ប្រការនោះសោះ ? ។

ឯបញ្ហាដែលចោទឡើងនេះ យើញថាស្តុត្រស្មាញពិបាកទំាងធ្វើយ ដោះស្រាយឲ្យសមហេតុ-ផលណាស់ តែព្រោះម្យ៉ាងទៀតដែលបានដឹងនូវ

អធ្យាស្រ័យនៃអស់លោកអ្នកជាពុទ្ធបរិស័ទផងឬទេ ព្រោះមានហេតុដែលជាប់ពាក់ព័ន្ធនឹងបញ្ហានោះក៏មានច្រើនប្រការផងដែរ ។ បើដូច្នេះ ខ្ញុំសូមដោះស្រាយនូវបញ្ហាខាងលើនេះចំពោះតែហេតុដែលនាំខ្ញុំមិនឲ្យយកចិត្តទុកដាក់អើពើចាប់អារម្មណ៍ទៅរកសុខ ៩ ប្រការនោះវិញ ទើបខ្ញុំអាចដឹងច្បាស់នូវហេតុនោះបាន ។ រីឯហេតុនោះ គឺមកតែពីខ្ញុំពុំដែលបានដឹងនូវសុខ ៩ ប្រការនោះសោះតើឬទើបតែត្រង់រឹះពិចារណាពីរកឃើញនូវសុខ ៩ ប្រការនោះនៅពេលថ្មីៗ នេះ គឺនៅពេលដែលខ្ញុំរៀបរៀងសៀវភៅលោកុត្តរចិត្តនេះឯង ។

តើសេចក្តីអធិប្បាយបញ្ជាក់អំពីសុខ ៩ ប្រការ ដូចមានខាងលើនេះពុំជាត្រឹមត្រូវបានឬទេ, ត្រង់ចំណុចនេះគឺស្រេចតែអស់លោកអ្នកដែលបានអានសៀវភៅលោកុត្តរចិត្តនេះ មេត្តាជួយពិនិត្យនឹងសម្រេចសេចក្តីដោយសុភនិច្ឆ័យចុះ, ក៏ប៉ុន្តែចំណែកខ្លួនខ្ញុំ វិញជឿជាក់ក្នុងចិត្តថា សុខកើតមកតែអំពីចិត្ត, កាលបើចិត្តត្រូវបានជុសខាត់ដំរះបានស្អាតបរិសុទ្ធផូរផង់រួចពីការគ្រឿងសៅហ្មងនឹងគ្រឿងត្រាំអស់ហើយ ចិត្តនោះត្រូវតែផ្តល់ឲ្យនូវសុខ ៩ ប្រការនោះពុំខានឡើយ ។

ដោយហេតុនេះ ខ្ញុំមានជំនឿថា បើពុទ្ធបរិស័ទបានដឹងច្បាស់នូវសុខ ៩ ប្រការ មានបរមសុខជាកំពូលនោះហើយ មុខតែមានពុទ្ធបរិស័ទខ្លះដែលនឿយណាយធុញច្រាន់នឹងកន្ទុកមានជាតិពុក្ខជាដើម យកចិត្តទុក

ជាកំពាប់អារម្មណ៍ឆ្ពោះទៅកេសុរ ៥ ប្រការនោះមិនមានឡើយ ពីព្រោះមានតែសុរ ៥ ប្រការនេះទេដែលអាចកំចាត់បង់នូវកងទុក្ខនោះបានជាតិតក្រោតដ ។ ម្យ៉ាងទៀតខ្ញុំមានសង្ឃឹមយ៉ាងមាំថា បើពុទ្ធបរិស័ទដែលនឿយណាយធុញច្រាន់នឹងកងទុក្ខមានជាតិទុក្ខជាដើមនោះ បានចាប់អារម្មណ៍ទៅកេសុរ ៥ ប្រការនោះហើយ, ពុទ្ធបរិស័ទនោះមុខតែនឹងចំស្មែងរកវត្តប្រតិបត្តិដែលអាចញ៉ាំងសុរ ៥ ប្រការនោះឲ្យសម្រេចកើតឡើងបានមកសិក្សាឲ្យចេះចាំស្ទាត់ ដើម្បីនឹងបានតាំងចិត្តព្យាយាមបំពេញនូវវត្តប្រតិបត្តិតាំងពីឆ្ងាយនោះឲ្យសព្វគ្រប់ រៀងរហូតដរាបលុះត្រាតែបានសម្រេចគោលបំណងជាទីបុងបំផុតមិនមានឡើយ ។

នៅទីនេះខាងក្រោយនេះ ខ្ញុំសូមថ្លែងបញ្ជាក់តាមអត្ថន័យថា វត្តប្រតិបត្តិតាំងពីឆ្ងាយ ណាដែលគ្មានគោលដៅឆ្ពោះទៅរកវិធីដុសខាត់ដំរះចិត្តឲ្យបរិសុទ្ធផូរផង់ គោលគឺការលេះកំលេសទេ, វត្តបដិបត្តិនោះពុកជាសីល-វត្តពុំគប្បីបដិបត្តិតាមឡើយ ពីព្រោះវត្តបដិបត្តិទុសទំនងពុំអាចផ្តល់ឲ្យនូវសុរ ៥ ប្រការ មានបរមសុរជាកំពូលបានសោះឡើយ នេះគឺយោបល់ដែលខ្ញុំយល់ឃើញ, តែស្រេចនូវតែអស់លោកអ្នកជាពុទ្ធបរិស័ទត្រិះពិនិត្យមើលថែមទៀតចុះ ។

សេចក្តីអធិប្បាយអំពីលោកុត្តរចិត្តសន្ទនាចប់ដោយសង្ខេបតែប៉ុណ្ណេះហោង ។

ព្រះអភិធម្មបិដក

គម្ពីរព្រះយមក:

លោក ប៊ុ - ប៊ុ ប្រែរៀបរៀង

(តមជ)

គោចរសម្បជញ្ញោ ឃដ ជាតុយោ សុញ្ញតោ ធម្មវិសេសំ អធិកច្ចំ សមត្តោ ហោតិ តាលវល្លិ-មណ្ឌបាសី មហាជាតត្តេរោ វិយ ច ។ សោ កិរ បឋមំ កកវតោ មហាបជាំ បុច្ឆិស្សាម័តិ ។

ម្យ៉ាងទៀត ព្រះយោគាវចរកំពុងប្រកបដោយគោចរសម្បជញ្ញៈ កាលបើបានតិចារណានុវជ្ជតុំងឲ្យយឲ្យលះឃើញថា ជារបស់សាបសូន្យហើយ ក៏អាចបាននូវធម៌វិសេស ដូចជាព្រះមហានាគត្ថេរដែលគង់នៅក្នុងតាលវល្លិមណ្ឌបមហាវិហារ ។

សោ កិរ មានដំណាលថា ព្រះមហានាគត្ថេរនោះគិតថា អាត្មាខឹងបួជាន្ទរសេចក្តីព្យាយាមចំពោះព្រះមានព្រះភាគជាដំបូង លោកគិតហើយ ក៏ធ្វើសេចក្តីព្យាយាមចំរើនព្រះកម្មដ្ឋាន មិនបានលះបង់ចោលអស់ចំនួន ៧ ថ្ងៃ ។ ខាងក្រោយមក លោកតាំងព្យាយាមចំរើនព្រះកម្មដ្ឋាន ១៦ ឆ្នាំទៀត ទើបបានសម្រេចព្រះអរហត្ត ។

ន កោវិលំ ច មិនមែនមានតែព្រះមហាទានត្ថេ ១ រូបខ្លះទេ បញ្ញាស កិក្ខូ វិយ ព្រះយោគាវចរប្រកបដោយគោចរសម្បជញ្ញៈ ហើយតាំងភ្ញាយាមចំរើនព្រះកម្មដ្ឋានមិនលះបង់ ទាល់តែបានសម្រេចមគ្គផល នៅមានជាច្រើនរូបទៀត ដូចជាកិក្ខុ ៥០ រូប ។

តេ កិរ មានដំណាលថា កិក្ខុទាំង ៥០ រូបនោះ ធ្វើកតិកាវត្ត គឺនិយាយសន្យាគ្នាថា យើងកល់គ្នាបើមិនបានសម្រេចមគ្គផលជាព្រះអរហន្តទេ យើងមិនត្រូវចរចាសន្ទនាគ្នាអំពីរឿងអ្វី ។ ឡើយ ទាល់តែយើងបានសម្រេចអរហត្តផលជាព្រះអរហន្តហើយ ទើបយើងនិយាយគ្នា ។ កិក្ខុទាំង ៥០ រូបនោះ លុះសន្យាគ្នាយ៉ាងនេះហើយ ក៏លចូលទៅកាន់ស្រុកភូមិ ដើម្បីតំកល់ចាវគោចរបិណ្ឌបាតមិនចរចាសំណេះសំណាលគ្នាសោះ ។ ពួកអ្នកស្រុកឃើញកិក្ខុទាំងនោះស្ងៀមស្ងាត់មិននិយាយគ្នាដូរៀងរាល់ថ្ងៃដូច្នោះ ក៏និយាយប្រឹក្សាគ្នាថា ន សល្លបន្តិ ហេតុអ្វីបានជាលោកម្ចាស់ទាំងនោះ មិននិយាយរកគ្នាផង មិននិយាយនឹងយើងរាល់គ្នាផង ប្រហែលជាលោកឈ្លោះប្រកែកគាស់ខែងខ្វែងគំនិតគ្នាទេដឹង គួរតែយើងទៅឯវិហារញ៉ាំងលោកទាំងនោះឲ្យអត់ទោសដល់គ្នាទៅវិញទៅមក ។

សត្ថេ វិហារំ គន្ត្វា មនុស្សទាំងពួងនាំគ្នាទៅកាន់ព្រះវិហារ មិនបានឃើញកិក្ខុទាំងនោះ គង់លើសេនាសនៈជាមួយគ្នា តាំងតែតាំងអង្គ

ឡើងទៅ ប៉ុន្តែ ឃើញចរិវណ, លានព្រះចេតិយ, លានព្រះស្រីមហាពោធិ, ឃើញទឹកប្រែ, ទឹកធានដ៏កល់ទុកនៅជាប្រក្រតី ។

យោ ច ភិក្ខុ បណ្តាមនុស្សអ្នកបានទៅឃើញទីព្រះវិហារក្នុងគ្រានោះ អ្នកដែលមានបញ្ញាចក្ខុ ចេះត្រិះរិះពិចារណាកេរហេតុផលប្រាប់ជនពាល់នោះថា វស្សោ តោ សោ លំនៅរបស់តិក្ខុពាល់អស់ដែលមានសភាពយ៉ាងនេះ មិនមែនជាលំនៅរបស់អ្នកឈ្មោះប្រកែកគ្នាទេ. ព្រោះទីចរិវណ, លានព្រះចេតិយ ទីលានព្រះស្រីមហាពោធិ ស្អាតបាតល្អឥតសម្រាម ពាល់ទឹកប្រើទឹកធានក៏មានពេញពាល់ពេញក្អមឥតខ្វះ សុទ្ធតែក្តៅត្នាំ អំបោសដែលបោសរួចហើយ. ក៏ទុកដាក់រៀបរយតាមទីកន្លែង ។ ហេតុនេះ តិក្ខុពាល់អស់មិនឈ្មោះប្រកែកគ្នាទេ. និយាយគ្នាហើយត្រឡប់ទៅផ្ទះរៀងខ្លួនវិញ ។

ចំណែកតិក្ខុពាល់ ៥០ រូប ទំពាល់ព្យាយាមបំពេញវត្តប្រតិបត្តិមិនលះបង់ចោល ទាល់តែបានសម្រេចព្រះអរហត្តផលត្រមពាល់បដិសម្ភិទាញាណទើបបានចរចាសន្ទនាគ្នាទៅវិញទៅមកតាមធម្មតា ។ តិក្ខុពាល់ ៥០ រូបទំព្យាយាមចំរើនព្រះកម្មដ្ឋានមិនបានលះបង់យ៉ាងនេះ ឈ្មោះថាអ្នកមានគោចរសម្បជញ្ញៈ ។

៤- អធិប្បាយអំពីអសម្មោហសម្បជញ្ញៈ

អសម្មោហសម្បជញ្ញៈនោះ បានដល់តិរិយាដែលតិក្ខុចំរើនកម្មដ្ឋាន

មិនវង្វើនវិលវល់ មិនកាន់ច្រឡំ តិចារណោន្ទូវទ្ធ, ជាតុ, អាយតន:
ទីឯបច្ចុយទ្យាយល់ប្បាស់ថា បក្ខុនោះឯងឈ្មោះថា បក្ខុជាតុ ។ នោះ គឺ
ជាបក្ខុ ។ បក្ខុជាតុនេះជាអនិច្ចំមិនទៀងពាត់ ជាទុក្ខ មិនមែនជាបុរស
ទ្ធន ។ តិក្ខុតប្បីតិចារណោន្ទូវជាតុទាំង ១៨ ប្រការ មានបក្ខុជាតុជាដើម
មានមនោជាតុជាបរិយោសានដោយប្រការដូច្នេះ ឈ្មោះថា អសម្មោហ-
សម្បជញ្ញ: ។

ម្យ៉ាងទៀត តិក្ខុតិចារណោន្ទូវបច្ចុយទាំងបួន គឺចីវរបច្ចុយ, បិណ្ឌ-
បាតបច្ចុយ, សេនាសនបច្ចុយ ទីឯគិលានភេសជ្ជបច្ចុយ កន្លងវេលាខ្លួល
ប្តូវេលាស្វែងរក ទីឯវេលាចរិកោគប្រើប្រាស់ន្ទូវបច្ចុយទាំងបួននោះ ណា
មួយ មិនវង្វើនភ្លាំងភ្លើង មិនកាន់ច្រឡំ យ៉ាងនេះឈ្មោះថា អ្នកមាន
អសម្មោហសម្បជញ្ញ: ។

តត្ត ចីវរោការណោ តាវ បណ្ណាបច្ចុយទាំងបួននោះ សូម
អធិប្បាយអំពីការប្រើប្រាស់ន្ទូវចីវរបច្ចុយជាមុន ។ តិក្ខុស្វែកដណ្តប់ន្ទូវចីវរ
គឺសង្ឃាំ, ចីតរឧទ្ធរសង្ឃាដិ ជាតិចារណោដោយតន្ត្រីណាកបច្ចុវេក្ខណ:ឲ្យ
យើញថា ចីវរំ អនេតនំ ចីវរដែលអាត្មាស្វែកដណ្តប់នេះគ្មានចេត-
នាទេ តាយក៏មិនដឹងន្ទូវចីវរ ។ ក៏មិនដឹងតាយ យថាបច្ចយំ បវត្ត-
មានំ ចីវរនេះ ប្រព្រឹត្តទៅដោយសមគ្គូវដល់បច្ចុយ គ្រាន់តែជាជាតុ
ឯបុគ្គល គឺអាត្មាអ្នកស្វែកដណ្តប់ន្ទូវចីវរនេះក៏ជាជាតុដែរ ។ តិក្ខុតិចា.

រណាដោយជាតុដូច្នេះហើយ ស្មៀតដណ្តប់នូវចិរ ឈ្មោះថា អ្នកមាន
គោចរសម្បជញ្ញៈ ។ កិក្ខុមិនវង្វែង មិនភ្លេចភ្លាំងស្មារតីក្នុង
ការតាំចរណានូវចិរបច្ច័យដោយជាតុនោះ ឈ្មោះថា អ្នកមានអសម្មោហសម្បជញ្ញៈ ។
ការដែលកិក្ខុតាំចរណានូវបិណ្ឌបាត, សេនាសនៈ ខឹងកេសដ្ឋៈឲ្យ
ឃើញថាជាជាតុនោះ មានន័យដូចការតាំចរណានូវចិរបច្ច័យដែរ ។
បណ្តាសម្បជញ្ញៈទាំង ៤ ប្រការ ដូចបានរៀបរាប់មកហើយនោះ
អសម្មោហសម្បជញ្ញៈជាធំជាចម្បងជាងសម្បជញ្ញៈ ៣ ប្រការ គឺសាត្ថក-
សម្បជញ្ញៈ ១ សប្បាយសម្បជញ្ញៈ ១ គោចរសម្បជញ្ញៈ ១ ព្រោះថា
បុគ្គលធ្វើកិច្ចការអ្វីៗបើភ្លេចភ្លាំងស្មារតីវង្វែងការនឹងច្រឡំហើយកិច្ចការនោះ
មុខជាមិនបានសម្រេចប្រយោជន៍ឡើយ ខឹងទាំងកើតទុក្ខទោសដល់ខ្លួន
សូម្បីចំពោះព្រះកម្មដ្ឋាន ក៏មិនបានសម្រេចផលតាមចិត្តប្រាថ្នា ។ ហេតុ
នោះ ទ្រង់ជាលោកពោលថា អសម្មោហសម្បជញ្ញៈជាធំជាងសម្ប-
ជញ្ញៈ ៣ ប្រការខាងដើម ។ បើគ្មានអសម្មោហសម្បជញ្ញៈទេ សម្ប-
ជញ្ញៈ ៣ ខាងដើមក៏មិនអាចកើតឡើងបាន បើទុកជាកើតមានហើយ
ក៏ស្ថិតនៅមិនបាន ខឹងសាបសូន្យទៅវិញជាមិនខាន ។
ព្រះយោគាវចរដែលតាំចរណានូវជាតុ ១៨ ប្រការនោះ គប្បី
តាំងនៅតែងសម្បជញ្ញៈទាំងបួន ដូចពោលមកហើយទើបអាចតាំចរណា
ឲ្យឃើញជាក់ច្បាស់បាន ។ ជាតុ ១៨ ប្រការនោះ បើបុគ្គលគ្មានសម្ប-

ផ្សារហើយ មិនអាចតិចារណាឲ្យឃើញថាជារបស់សាបសូន្យឡើយ ត្រឡប់ជាឃើញថា ចក្ខុជាតុជារបស់ខ្លួន ជារបស់ស្ថិតថេរ ទៀងទាត់ ។

បុគ្គលដែលមានជាតិចាស់ក្បាច្បាតិចារណាជាតុ ១៨ ប្រការនោះហើយ អាចសម្រេចមគ្គផលក្នុងបច្ចុប្បន្នជាតិនេះបាន បើជាតិមិនចាន់ចាស់ក្បាខ្លះ ក៏អាចបានសម្បត្តិសូតិដែរ ។ ហេតុនេះ ជាន់ជាសម្តេចព្រះបរមសាស្តាចារ្យទ្រង់ចាត់ជាតុ ១៨ ប្រការចូលក្នុងគម្ពីរយមកៈនេះ ។

XXX

សច្ចយមកៈ

ចត្តារិ អរិយសច្চានិ ទុក្ខំ អរិយសច្চំ ទុក្ខសមុទយោ អរិយសច្চំ ទុក្ខនិរោធោ អរិយសច្চំ ទុក្ខនិរោធគាមិនីបដិបទា អរិយសច្চន្តិ ទុក្ខំ ទុក្ខសច្চំ ទុក្ខសច្চំ ទុក្ខំ ទុក្ខំ ន ទុក្ខសច្চំ ទុក្ខសច្চំ ន ទុក្ខន្តិ អានិតំ បុច្ឆន្តិ ។

លំដាប់នេះ សូមវិសជ្ជនាក្នុងសច្ចយមកៈតទៅ ដំណើរសេចក្តីថា សច្ចនិទ្ទេស សម្តេចព្រះបរមសាស្តាចារ្យទ្រង់យើញច្បាស់នូវអរិយសច្ចៈទាំង៤ បួនប្រការ ដែលបុគ្គលោ ព្រះអង្គជាបុគ្គលលើសលែងតែមួយអង្គឯងក្នុងត្រៃភព ពុំមានអ្នកណាប្រៀបផ្ទឹមឲ្យត្រឹមស្មើបាន កាលព្រះអង្គសំដែងនូវជាតុយមកៈចប់ហើយ ក្នុងលំដាប់នោះ ព្រះអង្គទ្រង់សំដែង

ន្លូវសច្ចៈយមកៈតៅខៀត ។ ឯសច្ចៈយមកៈនោះ ព្រះពុទ្ធអង្គទ្រង់ទេសនា ដោយចតុក្កៈវារៈសច្ច ត្រាស់ប្តូចជាគូ។ ហើយត្រាស់វិសជ្ជនាជាគូ។ ។

ចត្តារិ អរិយសច្চានិ អរិយសច្ចបួនប្រការនោះគឺ

១- ទុក្ខអរិយសច្ច,

២- ទុក្ខសមុទយអរិយសច្ច,

៣- ទុក្ខនិរោធអរិយសច្ច,

៤- ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ។

ក្នុងទុក្ខអរិយសច្ច មានព្រះពុទ្ធដីកាត្រាស់ទេសនាប្តូចថា ទុក្ខំ អរិយសច្ចំ ទុក្ខនោះឬឈ្មោះថាទុក្ខសច្ច, ទុក្ខសច្ចនោះឬឈ្មោះថាទុក្ខ ឬថាទុក្ខនោះមិនមែនទុក្ខសច្ច, ទុក្ខសច្ចមិនមែនទុក្ខ? ។

ត្រាស់ប្តូចដូច្នេះហើយ ទើបត្រាស់វិសជ្ជនាដោយព្រះអង្គឯងថា ទុក្ខំ ទុក្ខសច្ចំ ទុក្ខនោះឯងឈ្មោះថាទុក្ខសច្ច, ទុក្ខសច្ចនោះឯងឈ្មោះថាទុក្ខ, ទុក្ខនោះនឹងមិនបានឈ្មោះថាទុក្ខសច្ចក៏មិនមែន, ទុក្ខសច្ចនោះនឹងមិនបានឈ្មោះថាទុក្ខក៏មិនមែន, ទុក្ខនោះឈ្មោះថា ទុក្ខសច្ចដោយតិត, ទុក្ខសច្ចនោះឈ្មោះថាទុក្ខតិត ។ អ្នកប្រាជ្ញគប្បីសន្និដ្ឋានចូលចិត្តថា ព្រះពុទ្ធអង្គត្រាស់ទេសនាប្តូចជាគូ។ ត្រាស់វិសជ្ជនាជាគូ។ ក្នុងទុក្ខអរិយសច្ច ដូចម្តេច ព្រះពុទ្ធអង្គត្រាស់ទេសនាប្តូចជាគូ។ ត្រាស់វិសជ្ជនាជាគូ។ ក្នុងទុក្ខសមុទយអរិយសច្ច នឹងទុក្ខនិរោធអរិយសច្ច នឹងទុក្ខនិរោធគាមិនីបដិ-

បាតអរិយសច្ច ដូច្នោះដែរ ។

ទីនេះសង្ឃាតក្នុងទុក្ខអរិយសច្ចជាមុខ; ទុក្ខំ ពាក្យនេះចែកចេញជាពាក្យ អក្សរ គឺទុ ក ខ ំ ទ; ទុ ក ប្រែថាអាក្រក់, ខំ ប្រែថាខេ, ថាគ្មាន, ថាដក; រួមពាក្យនេះទុក្ខំ ប្រែថាអាក្រក់ខេ គឺថាអាក្រក់គ្មានរបស់អ្វីនឹងការពារបាន ។

ន័យមួយទៀត ទុ ប្រែថា កម្រ, ទុក្ខំ ថាបុគ្គលនឹងដឹកបានដោយកម្រ ។ ម្យ៉ាងទៀត ទុក្ខំ ប្រែថា កម្របុគ្គលនឹងដឹកចេញឲ្យផុតពីចក្ខុសន្តានបាន ។ អរិយសច្ចំ ប្រែថា ជារបស់ពិតនៃព្រះអរិយៈ, ព្រោះហេតុព្រះអរិយៈទាំងឡាយ មានសម្តេចព្រះពុទ្ធអង្គជាដើម ជាបុគ្គលតាំងនៅក្នុងទីឆ្ងាយចាកកិលេស រមែងត្រាស់ដឹង, ជារបស់ព្រះអរិយៈនោះ គឺនឹងមិនបានជាទុក្ខ មិនមែនជាទុក្ខតិចណាស់ បើពោលដោយសង្ខេប ទុក្ខនោះមានបួនប្រការ គឺ: ជាតិទុក្ខ ១ ជរាទុក្ខ ១ ព្យាធិទុក្ខ ១ មរណទុក្ខ ១ ។

បើពោលតាមព្រះពុទ្ធដីកាដែលទ្រង់ត្រាស់ទេសនាក្នុងធម្មចក្កប្បវត្តនសូត្រថាមានទុក្ខច្រើនប្រការទៀត គឺអប្បិយសម្បយោគទុក្ខ ១ បិយវិប្បយោគទុក្ខ ១ យម្បិច្ឆលភតិទុក្ខ ១ សង្ខិត្តបញ្ចុប្បាទក្ខន្ធទុក្ខ ១ ផ្សំចូលគ្នាទីនឹងទុក្ខទាំងបួនកងមានជាតិទុក្ខជាដើម ។ ឯជាតិទុក្ខ, ជរាទុក្ខ, ព្យាធិទុក្ខ នឹងមរណទុក្ខនោះលើក

ពុកចុះ ខ្ញុំសំដែងតែក្នុងអប្បិយសម្បយោគទុក្ខជាមុន ។

អប្បិយសម្បយោគទុក្ខ

អប្បិយសម្បយោគទុក្ខនោះ ជាខន្ធ៥ការដែលប្រកបដោយទុក្ខ ព្រោះហេតុនៅក្នុងខ្លួនជាមួយគ្នាខ្ញុំសត្វខ្ញុំសង្ខារមិនជាទីស្រឡាញ់ ។ ការនៅជាមួយខ្ញុំសត្វខ្ញុំសង្ខារមិនជាទីស្រឡាញ់នោះ រមែងនាំមកនូវទុក្ខ គឺថានាំឲ្យកើតទុក្ខដែលខ្ញុំដែប្រែប្រួលបង្ខូចឲ្យបានសុខវិញ្ញាណនោះគ្មានខ្ញុំដចង្អុលតួយ៉ាងឲ្យឃើញជាក់ ។ ក្នុងបច្ចុប្បន្ន ចំពោះបុគ្គលដែលមានបុត្រត្រមាំងមាតាបិតាមានបុត្រធីតាកំជាទីស្រឡាញ់ហើយ ប៉ុន្តែបើបុត្រធីតានោះស្តីថាប្រដៅមិនបាន កំនាំឲ្យកើតទុក្ខមិនបានសុខ ។ ឯបុគ្គលដែលនៅរួមជាមួយសត្វខ្ញុំសង្ខារមិនជាទីស្រឡាញ់នោះ ជាតិត្រៃលែងជាងបុត្រធីតាដែលស្តីថាប្រដៅមិនបាននៅទៀត ចេះតែរងទុក្ខរហូតនៅដល់ខ្ញុំវិនាសស្លាប់បាត់បង់ជីវិតជាទីបំផុត មានរឿងអតីតនិទានដូចក្នុងចិញ្ចឹមនៃឃោសកសេដ្ឋី មានសេចក្តីដំណាលថា ៖

សេដ្ឋីនោះ ដើមដំបូងដើរទៅគាល់ព្រះមហាកស្សបត្រដល់តាក់កណ្តាលផ្លូវបានជួបខ្ញុំឯបុរេហិតសួរថា គោ អាចរិយ បតិត្រលោកអាចារ្យដំចំរែន ! ឥមំ ស្មឹ សំវច្ឆរេ ក្នុងឆ្នាំនេះឫក្សយោមខ្ញុំតិចល្អ ឬអាក្រក់ដូចម្តេច លោកអាចារ្យបានតិចារណាមើលដែរឬទេ ? ។

(នៅមានត)

សម្តែបព្រះធម្មលិខិត ល្ងី-ឯម ប្រែរៀបរៀង

ព្រះញាណកោសល ញាណ-ឈិន ពិនិត្យ

(តមក)

អធិប្បាយថា សម្តេចព្រះសាតអាចព្រះព្រះធ៌ន់ខ្លួនទឹកស្តើងតួចតំាងតួងក្នុង លោកដែលហួរចុះមកប្រដុំមានឧបមាយ៉ាងណា, ព្រះតថាគតជាម្ចាស់នៃខ្ញុំ ព្រះអង្គ អាចព្រះព្រះធ៌ន់ខ្លួនគុណតំាងឡាយតំាងតួងមានឧបមេយ្យយ៉ាងនោះឯង ។ ផែនដីដ៏ធំធេងនេះ អាចព្រះព្រះធ៌ន់ខ្លួសត្វថាកខាចនឹងសត្វឧត្តមថ្លៃថ្លាតំាងអស់តុំរើសមុខមានឧបមាយ៉ាងណា ព្រះតថាគតជាម្ចាស់នៃខ្ញុំ ព្រះអង្គអាចព្រះព្រះធ៌ន់ខ្លួសត្វមានគុណនឹងសត្វឥតគុណតំាងឡាយតុំរើសមុខ មានឧបមេយ្យយ៉ាងនោះឯង, ព្រះតថាគតជាម្ចាស់នៃខ្ញុំ ព្រះអង្គមានកាយវាចាចិត្តស្ងប់រម្ងាប់យ៉ាងនេះ ព្រះអង្គជាវីរបុរសឈ្នះសង្គ្រាមយ៉ាងនេះ ព្រះអង្គមានឥទ្ធានុភាពផ្សេង ។ ព្រះព្រះធ៌ន់ខ្លួកុណគុណយ៉ាងនេះ, បុគ្គលឯណាទីមួយក្នុងលោកនេះ តុំអាចនឹងគោលតាណិនាគុណព្រះមានព្រះភាគអង្គនោះបានឡើយ ។

កាលបើជនតំាងពីនោះ គោលអួតគុណគ្រូរបស់ខ្លួនទីនៃតីគ្នាយ៉ាងនេះហើយ ក៏បណ្តាលកើតឡើងជាជម្លោះឈ្លោះទាស់នៃងយ៉ាងធំ គឺម្នាក់គោលថា នេះរូបរបស់យើងប្រសើរវិសេសជាងគ្រូរបស់អ្នក ។ ម្នាក់

គោលថា ព្រះតថាគតជាម្ចាស់នៃយើង ប្រសើរវិសេសជាងទេវរូបរបស់អ្នក ម្ល៉ោះហើយជនពាំងពីរនាក់ពុំសុខចិត្តនឹងគ្នាទៅវិញទៅមក ហើយនាំគ្នាចូលទៅគាល់ព្រះបរមកូរត្រក្រាបបង្គំទូលតាមដំណើរនោះថា សូមព្រះអង្គទ្រង់វិនិច្ឆ័យតាមយុត្តិធម៌ទៅចាន ។ ព្រះបរមកូរត្រុះទ្រង់ព្រះសណ្តាប់ពាក្យជនពាំងពីរនាក់នោះហើយ ទ្រង់ត្រាស់ថា បើដូច្នោះយើងពាំងឲ្យ ឱនឯងបានដឹងនូវអានុភាពនៃគុណរបស់ទេវតានឹងគុណព្រះសម្មាសម្ពុទ្ធរបស់អ្នកពាំងឲ្យយ៉ាងណា ប្រសើរនឹងមិនប្រសើរ ដោយឥទ្ធិជាហារ្យពាំងឲ្យឥឡូវនេះឯង លុះព្រះអង្គមានព្រះរាជឱង្ការយ៉ាងនេះហើយ ក៏ត្រាស់បង្គាប់សេវកាមាត្យពាំងឲ្យ ឲ្យវាយស្គរជ័យផ្សាយទៅក្នុងនគរពាំងអស់ថា: អនាគតកាលតទៅមុខ ៧ ថ្ងៃទៀត នឹងមានឫទ្ធិជាហារ្យពាំងឲ្យរបស់ព្រះសាស្តាពាំងពីរព្រះអង្គនេះ នឹងកើតប្រាកដដោយពិត ដូច្នេះមហាជនពាំងឲ្យត្រូវបបួលគ្នាចូលមកប្រជុំចាំមើលចុះ ។ រីឯមហាជនពាំងឲ្យដែលនៅកន្លែងទិសផ្សេង ។ ឮនស្តាប់ដំណឹងនោះហើយ ក៏កើតជាកោលាហលគឹកកងជ្រួលជ្រើម ច្រើនកៃក្រេក សឹងចូលមកប្រជុំគ្នាតាមកាលកំណត់នោះហាន ។

កាលនោះ ពួកមនុស្សអ្នកមិច្ឆាទិដ្ឋិបានគិតថា ថ្ងៃនេះពួកយើងនឹងបានឃើញនូវអានុភាពនៃទេវរូបរបស់យើងដោយពិត លុះគិតដូច្នេះហើយ ក៏ធ្វើសក្ការបូជាយ៉ាងធំដល់ឥស្សរទេវរូបនោះឯង ។

ចំណែកឯពួកមនុស្សអ្នកសម្លាប់ដង្កឹកបានគិតថា ថ្ងៃនេះយើងទាំងឡាយនឹងបានឃើញនូវអានុភាពព្រះមានព្រះភាគរបស់យើងដោយពិត លុះគិតយ៉ាងនេះហើយ ក៏នាំគ្នាចូលទៅកាន់ទីប្រតិស្ឋានវាលុកចេតិយ ដែលបញ្ចុះព្រះចុតបិដ្ឋធាតុ (ព្រះនាប់ព្រះចុត) ព្រះមានព្រះភាគ ហើយធ្វើសក្ការបូជាដោយគ្រឿងបូជាទាំងឡាយមានផ្កាកម្រងជាដើម ស្រោចហើយដើរប្រទក្សិណបីដង លើកដៃឡើងប្រណម្យថ្វាយបង្គំ ស្ថិតនៅក្នុងទីនោះឯង ។

លំដាប់នោះ ព្រះទន្ត្រាធិបតីបរមេក្សត្រ ព្រមទាំងតាលពាហនៈនឹងសេវាគាមាត្យជាច្រើនចោមរោមជាបរិវារ ដង្ហែរស្តេចយាងទៅកាន់ទីប្រជុំនោះ ហើយទ្រង់ប្រថាប់នៅក្នុងទីដ៏សមគួរមួយ ។

ចំណែកមនុស្សទាំងឡាយដែលប្រកាន់លទ្ធិផ្សេង ។ បានគិតថា ថ្ងៃនេះ យើងនឹងបានឃើញនូវបាដិហារ្យនៃបុគ្គលមានឫទ្ធិទាំងឡាយនោះដោយពិត លុះគិតយ៉ាងនេះហើយ ក៏បបួលគ្នាគឹកកងចូលទៅកាន់ទីប្រជុំនោះហើយតាក់តែងដងគ្រែគួរដំរែតលើគ្រែធំ អង្គុយប្រជុំចាំមើលក្នុងទីនោះហាង ។

កាលបើមហាជនទាំងឡាយនោះបានប្រជុំគ្នាយ៉ាងនេះស្រេចហើយ ពួកមនុស្សដែលជាសម្លាប់ដង្កឹកធ្វើកិរិយាបូជាយ៉ាងអធិកអធម នូវព្រះសថូបពាលុកចេតិយ ហើយលើកឡើងនូវក្រតុំម្រាមទាំង ១០ នមស្សការសោលថា : បពិត្រព្រះមានព្រះភាគជាម្ចាស់ សូមព្រះអង្គជាទីពឹងចុងវិញ្ញាព្រះ

អគ្គ្គ្គ

សម្តែងចូរដឹងហើយឈរលើផ្ទាំងឈូកមាស បន្ទោញាឱ្យព្រះពាជាសប្បុរសថា អត្តោហាមស្មិ លោកសួរសេដ្ឋោហាមស្មិ ប៉ុណ្ណោះជាដើមគួរជាទីអស្ចារ្យ ប្រសិនបើព្រះជាតុណាមាននៅ សូមព្រះជាតុនោះសម្តែងឱ្យព្រះចូរដឹងហើយជាទីអស្ចារ្យដល់ខ្ញុំព្រះអង្គចាំនឹងឮយ ដោយពាក្យសច្ចនោះឯង ។ កាលព្រះអង្គទ្រង់ទតឃើញឱ្យខេវខ្ចែតចាំនឹងបួនដែលសុទ្ធតែសត្រហ្មមកនិមន្តថ្វាយ លុះឃើញហើយក៏មានព្រះទ័យខឿយណាយចាកវដ្តសង្សារចេញទៅទ្រង់ព្រះកុសកសាងខ្លួនក្លាកំរើយាគួរជាទីអស្ចារ្យ ប្រសិនបើព្រះជាតុណាមាននៅមែន សូមព្រះជាតុនោះសម្តែងឱ្យព្រះចូរដឹងហើយជាទីអស្ចារ្យដល់ខ្ញុំព្រះអង្គចាំនឹងឮយ ដោយពាក្យសច្ចនោះឯង ។ កាលព្រះអង្គទ្រង់សម្តែងព្រះចូរដឹងហើយផ្ទាំញាំនន្ទោបនន្ទកជក្តី ផ្ទាំញាំដ៏នោឡាតិរជិប្រសើរក្តី ផ្ទាំញាំពួកយក្សមានអាឡវយក្សជាដើមក្តី ផ្ទាំញាំពួកព្រហ្មមានតាមហាព្រហ្មជាដើមក្តី ផ្ទាំញាំពួកនិត្តន្តមានសច្ចកនិត្តន្តជាដើមក្តី ផ្ទាំញាំពួកព្រាហ្មណ៍មានកុដទន្តព្រាហ្មណ៍ជាដើមក្តី ដោយឫទ្ធិគួរជាទីអស្ចារ្យប្រសិនបើព្រះជាតុណាមាននៅមែន សូមព្រះជាតុនោះសម្តែងឱ្យព្រះចូរដឹងហើយជាទីអស្ចារ្យដល់ខ្ញុំព្រះអង្គចាំនឹងឮយដោយពាក្យសច្ចនោះឯង ។ លុះមន្ទុស្សចាំនឹងឮយជាសម្ងាត់ដ្ឋិ ចានតោលតាក្សជាបក្ខតាជាដ៏ច្រើនយ៉ាងនេះហើយក៏តោលអាកជនាថា: បតិត្រព្រះជាតុជាម្ចាស់ សូមព្រះអង្គតាំងព្រះទ័យអនុគ្រោះដល់ខ្ញុំព្រះអង្គចាំនឹងឮយ សម្តែងឱ្យព្រះចូរដឹងហើយ

ជាទីអស្ចារ្យដល់មហាជន ដើម្បីបំបែកទំលាយជនមិច្ឆាទិដ្ឋិដែលខាងតែដ្ឋ
ខុសឲ្យប្រែក្រឡាប់ចាន់ឃើញត្រូវវិញក្នុងកាលនេះហាង ។ កាលនោះ
ព្រះចាវបិដ្ឋធាតុចាន់អាស្រ័យនូវពុទ្ធខុភាពផង អាស្រ័យនូវសច្ចកិរិយា-
ខុភាពនៃពុទ្ធបរិស័ទចាំង់ឡាយផង កំចាន់ទំលាយនូវព្រះពាលុកចេតិយ
ឲ្យបែកធ្លាយជាពីរចំណែក ហើយចេញមកខាង់ក្រៅធ្វើចាន់ដ៏ហារ្យហោះ
អណ្តែតឡើង់ទៅស្ថិតនៅឰដ៏អាកាសបញ្ចេញនូវរស្មីចាំង់ច្រាំមួយពណ៌ភ្លឺ-
ច្រាស់ផ្សាយទៅកាន់ទិសនានាជាទីអស្ចារ្យពន់ពេកក្នុងកាលនោះឯង ។
លំដាប់នោះឯង មហាជនចាំង់ឡាយកំមានសេចក្តីសោមនស្សជ្រះថ្លាចាន
លើកឡើង់នូវទង់សំពត់ប្រមាណមួយភាន់បូជា ចាំង់កំសាន្តលែងសាធុ-
ការញ៉ាំង់សំឡេង់ឲ្យលាន់ឮខ្ទាំង់ឲ្យប្រព្រឹត្តទៅតុំដាច់ ធ្វើការយោបូជាយ៉ាំង
ធំក្រៃលែង់ក្នុងកាលនោះឯង ។

ចំណែកឯពួកជនជាមិច្ឆាទិដ្ឋិ លុះចាន់ឃើញនូវព្រះចាវជាហារ្យជា
ទីអស្ចារ្យយ៉ាំង់នេះ កំមានចិត្តស្បើមលះបង់មិច្ឆាទិដ្ឋិដែលខ្ជិនចូលចិត្ត
ខុសប្រែកាន់ខុសជាជ្រះស្រឡះ ហើយចាន់ដល់នូវគុណព្រះរតនត្រ័យដ៏
ខុត្តមជាទីពឹង់ទីលើកប្រព្រឹត្តទៅខាង់មុខ មានសទ្ធាមិនតម្រែក លែង់បូជា
ភប់អាន់ឥស្សរទេវតាអ្នកតាអារក្សទេព្រ័ក្សត្រទៅទៀតឡើយ ។

(នៅមានត)

លោក អ៊ឹម-ភន ចម្លងពីសារ្តាស្ត្រីភាសិត

ព្រះពុទ្ធវង្ស កើម-ឆ្នូរ តំនិត្យ

(តមក)

សេតសុវបណ្ឌិតគិតហើយ ក៏ហើរទៅកន្លែងទន្សាយនោះ ទំាងឮដំមែកឈើសាលព្រឹក្ស ; រំឯព្រះបាទចុលនីថា ម្នាលអាចារ្យ ! ចូរអ្នកថ្លែងទៅមើល ? ! ពរាជគ្រូកេវដ្ដព្រាហ្មណ៍ថា បពិត្រមហារាជ, សូមព្រះអង្គផ្ទៀងព្រះស្រោត្រអម្ចាស់នោះមកឯនេះហោង, តំនិតនេះមានត្រចៀក៤, បពិត្រមហារាជ, ថាបើព្រះអង្គធ្វើតាមពាក្យអញខ្ញុំ អញខ្ញុំនឹងណែនាំតាក់តែងមហារាជឲ្យជាស្តេចប្រសើរលើសលែក ឮដំសកលជម្ពូទ្វីបនេះហោង ។ ព្រះបាទចុលនីស្តាប់ពាក្យពរាជគ្រូដូច្នោះហើយ ហេតុតែព្រះចំណង់ទំាងស្តេចមានព្រះហឫទ័យត្រេកអរសោមនស្សត្រាស់ថា ម្នាលអាចារ្យអើយ ! ពាក្យអាចារ្យសំដែងថ្លែងនោះ អញនឹងធ្វើតាមពាក្យអាចារ្យហោង ។ ពរាជគ្រូថា បពិត្រមហារាជ, យើងខ្ញុំនឹងប្រដុំពលសេនាយោធាមកដុំហើយ យើងខ្ញុំទៅចោមរោមនាគក្ខួចជាដើម ហើយអញខ្ញុំចូលទៅកន្លែងនាគនោះតាមទ្វារក្ខួច ហើយអញខ្ញុំស្រដីនឹងស្តេចនាគនោះថា បពិត្រមហារាជ, អម្ចាស់ចុះចូលជាទ្រព្យសំភប់យើងទំាងពួងហើយ រំឯមហារាជនឹងឋានឥតអង្គីមានឡើយ, ហើយសម្រេចសម្បត្តិមហារាជកំគង់នៅដូចដើម ។

មួយសោត បើមហាក្សត្រាំងនឹងយើងដ៏មានកំឡាំងដ៏រសេះរខេះច្រើនដូច្នោះ កំមហាក្សត្រនឹងចាញ់ខ្មែរតូចតាត់មិនខានឡើយ ថាបើស្តេចនោះតាមដោយពាក្យអញខ្ញុំដូច្នោះហើយ កំអញខ្ញុំនឹងប្រមូលស្តេចនោះប្រពៃហោង, ពោះបើចេមិនតាមដោយពាក្យអញខ្ញុំហើយ កំយើងនឹងច្បាំងឲ្យស្តេចនោះក្សោយជីវិត ហើយយើងយកអស់សេនាពលចេញទៅកាន់ខនរខ្មែរបានហោង, ហើយទៅខនរឯខ្មែរធ្វើតាមដែលនេះ, ហើយយើងយកក្សត្រាំងសុភលដម្ពូជនោះខ្មែរ, យើងធ្វើទុក្ខយកលដូច្នេះស្រេចហើយ យើងនឹងក្រសោដ៏យបានហោង ។ កាលយើងនឹងនឹកស្រាដ៏យបាននោះ យើងឲ្យយកស្តេចមួយរយនឹងមួយយមកជុំគ្នានាខនរយើងនេះ ហើយឲ្យនឹកស្រាដ៏យដាក់ខ្លែវថ្នាំពិសឲ្យដឹងខ្លាន, អ្នកទាំងពួងនោះលុះក្សោយជីវិតហើយ យកភ្នោចនោះចោះក្នុងទឹកហោង យើងធ្វើកដសម្បត្តិអស់កដនានីមួយរយនឹងមួយនេះ ឲ្យលុះក្នុងកណ្តាប់ដៃនៃអម្ចាស់ជាស្តេចប្រសើរថ្លៃក្រៃឲ្យដ៏ដម្ពូនេះ ខ្លួវប្រការដូច្នេះហោង ។ ព្រះចុះចុលទីត្រហ្មុខត្តកដបន្ទូលថា តាប់ហោង អាចារ្យអើយ! អញធ្វើដូចតាក្សអាចារ្យហោង ។ កដត្រូថា បពិត្រមហាកដ, នាហៅតំរែតែត្រូវក្រ ៤ នេះ អ្នកដទៃអង្គឹមានតំរែនេះ មិនអាចដើម្បីនឹងឲ្យអ្នកដទៃដ៏ងឡើយ ហេតុនោះ ព្រះចុះអម្ចាស់ធ្វើកុំឲ្យយូរឡើយ ព្រះចុះអម្ចាស់ចេញទៅនាប់ហោង ។ ព្រះចុះចុលខ្លែត្រហ្មុខត្តកដ ស្តាប់តាក្សាកដត្រូ

នោះហើយមានព្រះហប្ញទ័យត្រេកអរខ្លួលថា តាប់ហោង ។ ឯសេកសុវ-
បណ្ណិតតិទិត្យស្តាប់ស័ព្ទសេចក្តីអ្នកចាំង ២ នោះហើយ កំសយុងកចុះដូច
ទឹងភ្នាត់អំពីមែកលង្វែកសាលត្រីក្ស ហើយលុះសម្រេចតំទៃអ្នកចាំង ២
នោះហើយ សេកកំខម្ចាក់អាចម៍ ១ ដុំមកលើក្បាលអាចារ្យកេវដ្តព្រាហ្មណ៍,
អាចារ្យកេវដ្តព្រាហ្មណ៍ចោសចេញពីក្បាលហើយថា អេះ! សត្វអ្វីដូច្នេះ,
អេះ! ម៉េះហើយសេកខម្ចាក់ខ្លួវអាចម៍ ១ ដុំវិញទៀត ក្នុងមាត់អាចារ្យ
កេវដ្តព្រាហ្មណ៍ដែលឆើយមើលនោះ, វិសប្បន្តោ សីងស្រែក, កិរិ
កិរិ ឥតិ ថា ក្រែក ។ ដូច្នេះ ហើយហើរទៅអំពីមែកសាលត្រីក្ស ហើយ
ព្រះបាទបុលន្ទស្រដីនឹងអាចារ្យកេវដ្តព្រាហ្មណ៍ថា ម្នាលអាចារ្យអើយ!
តែនិតព្រះស្តេចតថា តែអញនឹងព្រះស្តេចឯងជាត្រចៀក ៤, ឥឡូវនេះ
តើតជាត្រចៀក ៦ ហើយ, អដ្ឋកណ្ណោ តើតជាត្រចៀក ៨ វិញ,
អនេកសតកណ្ណោ ជាត្រចៀកច្រើនរយត្រលែងវិញហោង ។
លំដាប់នោះ; សេកហើរទៅដោយផ្លូវទៅកាន់ទីចំណានតរ ហើយស្រែក
ថាដូច្នេះ កណ្ណា ៩ ។ ថា អ្នកចាំងឡាយអើយ! ចូរទៅកាន់លំនៅរៀង
មហាសព្វអ្នកប្រាជ្ញឲ្យឆាប់ ហើយនាំតតិមានសេកសេមមបណ្ឌិតនោះ
ថាមើមកអំពីឯណា ។ ក្តីតប្បីប្រាប់ទៅមហាសព្វនោះឯងហោង; លំដាប់
នោះ, សេកចុះទំឡដ៏ស្មាទៃពោធិសត្វនោះ ថាមើតួបើប្រាប់នាងអមក
ដើម្បីនឹងឲ្យនាងស្តាប់នូវតតិមាននោះ ក៏មកចុះលើចង្កើះ ថាបើចង់ឲ្យ

មហាជនផងស្លាប់ កំពុះលើភូមិដ៏ហោង ។ រឯសេកសុវបណ្ឌិតក៏ចុះមកឰដ៏ស្មោះចាមហោសថអ្នកច្រាជ្ញ ។ ឯពួកមហាជនទាំងឡាយ ឲ្យថយចេញហើយថាដូច្នេះ តប្បីនឹងធ្វើដំណើរអាចរំសេចក្តីកំចាំងដោយសំគាល់នោះហើយ ។ ចាមហោសថអ្នកច្រាជ្ញ យកនូវសេកសុវបណ្ឌិតឡើងលើច្រាសាខ ហើយអ្នកដណ្តើងដូច្នេះថា តាឥ ហៃសេកអើយ! តើជាយល់ឮអ្វី? ។ ក្រៃណានោះ, សេកនិយាយនឹងមហោសថអ្នកច្រាជ្ញដូច្នេះថា បពិត្រអម្ចាស់អើយ! អញខ្ញុំមិនយល់នូវពុទ្ធន័យឰដ៏សំណាក់ស្តេចដទៃក្នុងកំឡុងសកលជម្ពូទ្វីបនោះឡើយ; ប៉ុន្តែកាលនោះ, មានបុរោហិតម្នាក់បម្រះចូលនិព្រហ្មទត្តរាជ ជាព្រាហ្មណ៍ឈ្មោះកេវដ្ដៈ នៅឰដ៏ទត្តរបញ្ចាលនគរមិញ ទាំស្តេចកើតកាន់ទុក្ខនោះ ហើយក៏កាន់យកនូវគំនិតត្រចៀក ៤ ឰដ៏ព្រៃ, អញខ្ញុំសោត ចំនៅឰដ៏លង្វែកមែកសាលព្រឹក្ស អញខ្ញុំបានឧម្ចាក់នូវអាចម៍ ១ ដុំមកក្នុងមាត់អាចារ្យកេវដ្ដព្រាហ្មណ៍ ហើយអញខ្ញុំហើរមកហោង ។ សេកនិយាយស្រាយប្រាប់អស់អាចសេចក្តីតាំងតួនដោយប្រការដូចមកនោះហើយ ក៏យល់ឮទៅដល់ចាមហោសថអ្នកច្រាជ្ញនាគស្យចាមហោសថស្រដីថា រឺតាគ្យនោះតើស្តេចញ៉ាំងឲ្យសេចក្តីប្តូរទេ? សេកថា ទេវ បពិត្រអម្ចាស់អើយ! ស្តេចឲ្យសេចក្តីប្តូរហោង ។ មហោសថឆ្លើយសួរដល់សេកនោះ ឲ្យដេកលើកំពស់ដំខន់ល្មមទុកក្នុងក្រនំមាស, តោងនិយាយប្រាប់តំនិតថា ឯតិ បោសា ដូចអញ

តិតនេះ រីឯអាចារ្យកៅដ្ឋព្រាហ្មណ៍នេះ មិនដឹងនូវសភាពនៃអញ្ញាមកោ-
សជ្ជអ្នកច្រៀង មានច្រៀងយល់សារតើឥតប៉ុន្មាន, ហើយនោងសត្វអ្នក
រាំនឹងតិតថា ឥឡូវនេះ គំនិតស្រដីចាំង ៦ អញ្ញាមិនឲ្យលុះបរិបូណ៌ឡើយ,
ត្រែកូលឲ្យត់ទៅឆ្ងាយអំពីនគរព្រះមហាក្សត្រក្តី ឲ្យលើកចូលមកនៅក្រៅ
ព្រះនគរ, ត្រែកូលមានទ្រព្យសម្បត្តិជាអ្នកមានយសស័ក្តិនៅទាស្រុកហ៊ាន
និតមជនបទនោះ ឲ្យនាំមកណ្តាប់នូវទ្រព្យស្រូវអង្កាជនច្រើន សំរែចពុក
ឲ្យច្រើនក្នុងព្រះនគរនោះហោង ។

ចុលនីព្រហ្មទត្តោបិ ឯស្តេចចុលនីព្រហ្មទត្តជ ឃក
នូវពាក្យអាចារ្យកៅដ្ឋព្រាហ្មណ៍នោះហើយ ស្តេចនោះទៅនឹងសេនា
យោធាជនច្រើនឡាយជាបរិពារកំទៅចោមរោមនគរតែច ១ ។ ឯអាចារ្យ
កៅដ្ឋព្រាហ្មណ៍ក៏ចូលទៅកាន់នគរនោះ ដោយនូវន័យគំនិតដែលថានោះ
ហោង, ហើយច្រាប់ឲ្យជាដំណឹងដល់ស្តេចនោះ ធ្វើឲ្យមកកាន់សំ-
ណាក់អាត្មា ជាមួយនឹងសេនាពីរនឹងចាប់យកនូវស្តេចឯទៀតដូច្នោះ
ក៏នឹងចាប់យកអស់ស្តេចចាំងពួង ដោយនូវល្បិចាប់រឿងទៅហោង ។
ឯកំ ចុលនីព្រហ្មទត្តោ ព្រែះថាចុលនីព្រហ្មទត្តជ ប៉ិត
ដោយនូវពាក្យអាចារ្យកៅដ្ឋព្រាហ្មណ៍ នូវប្រការអម្បាលនោះហើយ
លើកពុកតែស្តេចវិទេហរាជជាសំណល់ ក៏ធ្វើអស់ស្តេចចាំងសកលជម្ពូ-
ទ្វីប ឲ្យបានមកសំណាក់នៃអាត្មាហើយ រីឯសេចក្តីបន្ទុកក្តីរបស់ពោធិ-

សត្វមិញ សឹងប្រើពាក្យមានមកកាន់តែធំសត្វតុំជាច់ដូច្នេះថា ព្រះថ្កល ចុលនីព្រហ្មទត្តភជ គេចាប់ចុងនង្គាច់ឆ្អឹងអម្បាលនោះហើយ កុំបីអម្ចាស់ប្រហែសឡើយ ។ បណ្ឌិតោបិ បពិត្រអើយ ! រីពោធិសត្វអ្នកប្រាជ្ញប្រើពាក្យមានពៅវិញ នាបុរសដែលមកព្រមាននោះដូច្នេះថា ភ្ញូម្នេ រីព្រះស្តេច វសថ ចូរពៅនោះ កុំបីក្រសាលប្រហែសក្លេចស្មារតីឡើយ រីអញនៅនាឋានេះមិនប្រហែសឡើយ ។ ឯព្រះថ្កលចុលនីព្រហ្មទត្តភជ រៀវទុកដំកល់តែសម្បត្តិព្រះថ្កលវិទេហភជ ចេញ ជាសំណាល់ចាន ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ ក៏ខឹងចាប់យកអស់ស្តេចសកលជម្ពូទ្វីបនោះចានងាយក្តាត់ហោង, ស្តេចចុលនីព្រហ្មទត្តភជចន្លូលខឹងអាចារ្យកេវដ្តព្រាហ្មណ៍ដូច្នេះថា អាចរិយ ហៃអាចារ្យអើយ ! យើងខឹងពៅចាប់យកភជសម្បត្តិព្រះថ្កលវិទេហភជ ពៅឮដំមិថិលានតរនោះហោង ។ អាចារ្យកេវដ្តព្រាហ្មណ៍ទូលថា មហារាជ បពិត្រមហារាជអើយ ! រីពៅមហោសថនោះនានតរនោះ យើងតុំអាចដើម្បីនឹងពៅយកភជសម្បត្តិគេនោះចានឡើយ, អាចារ្យកេវដ្តព្រាហ្មណ៍ទូលថា ពៅមហោសថប្រកបនូវព្រះប្រាជ្ញាជាអ្នកឈ្លាសនូវគុណទាយ ខឹងតាយស្រាយនោះឥតងខ្វះឡើយ ។ អាចារ្យកេវដ្តព្រាហ្មណ៍ទូលឃាត់ព្រះថ្កលចុលនីព្រហ្មទត្តភជនូវប្រការអម្បាលនោះហើយ ក៏ថ្លែងសរសើរនូវគុណមហោសថនោះបន្តិចបន្តួច ដូចគ្រាមណ្ឌលព្រះចន្ទ្រាស្រាលដែលមនុស្ស

តតក ទឹងកេជាត់ស្ទើនោះគ្មានឡើយ ហើយចេមហាសថអ្នកជ្រាជ្រៃនេះ
សូម្បីតាត់ចេះខ្លួចបាយកលយល់ឡាយដងហើយនោះហាង, រីយើង
ទាំងមឡាលនេះ នាប៊ីហៅពាជសម្បត្តិមិថិលានតរនោះយើងទឹងទៅយក
តុំជុនឡើយ ហើយស្តេចទាំងសកលជម្ពូទ្វីបនោះ តេនទឹងមើលងាយ
អម្ងាស់ ខ្លួវអញ្ជឹហោង ។ អាចារ្យកេវដ្តព្រាហ្មណ៍ទូលថា នាប៊ី
យើងទឹងសម្ងាប់ស្តេចទាំងនោះខ្លួវប្រការម្តេចអេះ! អាចារ្យកេវដ្តព្រាហ្មណ៍
សំតាលខ្លួចបាយកលមួយថា នាយើងទឹងទៅយកពាជសម្បត្តិឯមិថិលា
នតរ សូម្បីអេស់ស្តេចទាំងអម្បាលនោះ យើងទឹងប់រើផឹកស្រាជ័យ
ជុនហើយ កំសូម្បីទឹងយាត់ស្តេចទាំងនោះថា ឆេវបតិត្រមហាពាជអើយ!
យើងទឹងយកសម្បត្តិស្តេចវិទេហពាជនោះ យើងទឹងតាលធ្វើអ្វីឡើយ រី
ពាជសម្បត្តិស្តេចវិទេហពាជនោះ សឹងជាទ្រព្យសំពប់យើង ហើយ
អញ្ជើញក្រឡាប់មកស្ទេះនៅនេះសិនហោង ។ អាចារ្យកេវដ្តព្រាហ្មណ៍
តឿនអស់ស្តេចទាំងអម្បាលនោះ ដោយខ្លួចបាយកលយល់ហើយ,
ស្តេចទាំងអម្បាលនោះស្តាប់ពាក្យអាចារ្យនោះហើយ ក៏ក្រឡាប់វិលទៅ
ហោង ។ ប៉ុសេដាចបន្ទិកក្តួរបស់ព្រះមហាសថមិញ ប្រើតតិមាន
មកវិញទៀតថា រីស្តេចចុលនីព្រហ្មទត្តពាជ ស្តេចទឹងមកទាមិថិលានតរ ខ្លួវ
ស្តេចមួយយេទឹងមួយដាប៊ីតោរ តែបានអាចារ្យកេវដ្តព្រាហ្មណ៍យាត់
ស្តេច កំស្តេចវិលក្រឡាប់ទៅកាន់ព្រះនតរស្តេចវិញហោង ។ មហា-

សត្ថោបិ តេសំ ឥតោ បដ្ឋាយ ឥស្សរ កិរិយំ ជាឯន្តិ បតិសាសនំ បេសេតិ ។ រីតោធិសត្វប្រែពតិមានតបវិញ ទៅជាសំបុរសមកត្រមានខោះដូច្នេះថា ចាប់ដើមអំពីខេះទៅ ចូរព្រះស្តេងប្រើមកឲ្យបានដឹងនូវអំពើស្តេចខោះហោង ។ រីស្តេចបុលខ្ញុត្តកជស្រដីមួយអន្លើនឹងអាចារ្យកេវដ្តព្រាហ្មណ៍ថា ឥឡូវខេះ យើងនឹងធ្វើម្តេច ? ។ អាចារ្យកេវដ្តព្រាហ្មណ៍ខូលថា យើងចំធីកស្រាជ័យបាន នាបុរសអាមាត្យផងតាំងឡាយ ឲ្យប្រដាប់សំពាប់នូវទ្យានខោះស្រេចហើយ ចូរអណ្តាប់ដំកល់ខុកនូវស្រាបានមួយរយឆ្នាត់ មួយពាន់ឆ្នាត់ ហើយចូរនាំមកនូវបាយដំណើប នូវត្រីសាច់ផងតាំងឡាយជាដើមខោះ មានដំពូកផ្សែង ។ ស្រេចហើយ បង្គាប់ប្រើអាមាត្យ ។ ឮដំណាលខោះរីបុរសទបនិក្ខិត្តនៃពោធិសត្វ ប្រើនាំពតិមានខោះមកកាន់ចៅមហាសថ្កាំដូច្នេះថា មួយនីសោត រីស្តេចបុលខ្ញុត្តកជខោះ ផ្សំថ្នាំពិសនឹងស្រា មានចំណង់ចង់សម្លាប់ស្តេចតាំងឡាយមិនដឹងខ្លួនឡើយ ។ មួយនីសោត, ព្រះមហាសត្វនឹងដឹងពតិមានអំពីសេតសុវបណ្ឌិតតែងទៅសំណាក់បុរសខោះ ហើយមហាសថ្កនឹងចង់ដឹងស្តេចខោះ ថៃណានឹងទៅផឹកស្រាជ័យ, ឆ្កាំដូច្នោះហើយ ប្រើឲ្យនាំពតិមានឲ្យទៅអាមាត្យប្រើមកត្រមានខោះ ។ តេ តថា ករិសុ រីអាមាត្យខោះ ទៅឮដំបានខោះហើយ, ក៏ពោធិសត្វអត់តឹងតិតថា

អ្នកប្រាជ្ញតាំងឡាយមិនគួរធ្វើទ្វារអាត្មានេះឡើយ, មួយទៀតសោត រឹស្តេចតាំងគម្ពាលនេះ កំទើងឲ្យស្ទាប់ដំរីតស្តេចតាំងឡាយនោះ ស្ទាប់ឥតស្ងៀងឡើយ, ព្រោះមហាសត្វអ្នកឲ្យហៅយោធាមួយពាន់ដែលកើតព្រមថ្ងៃមួយទើងតោធិសត្វនោះមកដាំទ្វារពាក្យដូច្នេះថា ម្នាលគ្នាយើងអើយ! រីព្រះចាខុលទីត្រហ្មខត្តកដនោះ ដូចយើងបានឮមក គាត់ថាទើងចង់ភៅកាន់ព្រៃខ្មាន់ហានស្ងាត់ ហើយគាត់ទើងប្រដាប់មានចំណាំបំផឹកស្រាជ័យ មានស្តេចមួយរយទើងមួយជាបរិពារ អ្នកចូលភៅហាននោះ កុំឲ្យស្តេចតាំងឡាយដំទុំគ្នា ចូរប្រដាប់កំពលអាសនាស្តេចតាំងឡាយនោះទីថែ ។ ហោង; រីអាសនាស្តេចចុលទីត្រហ្មខត្តកដនោះនាលថ្វែងហានតណ្ដាល ហើយចូរអ្នកតាំងឡាយដណ្ដើមយកអាសនានោះ អ្នកតាំងឡាយត្រូវស្រែដាថា នេះអាសនាស្តេចយើង នេះអាសនាអម្ចាស់យើង ម្ល៉ោះហើយរីបុរសតាំងឡាយនោះគេថាទើងអ្នកតាំងឡាយដូច្នេះ នេះបុរសអាមាត្យស្តេចឯណាហ៎: គ្នាយើងតាំងឡាយ ចូរថាដូច្នេះ រីយើងនេះជាអាមាត្យនៃព្រះចាខុលទីតេហាកដ អស់តេតាំងនោះគេទើងស្រែដាមួយអន្ទើទើងគ្នាយើងតាំងឡាយគេទើងថាដូច្នេះ រីយើងចាប់យកកដសម្បត្តិស្តេចតាំងឡាយនោះ តែប្រាំពីរថ្ងៃ អធិកទ្វៃ ៧ ខែ, ៧ ថ្ងៃទេ, យើងមើលមកប្រមាណឯស្តេចទីតេហាកដនេះ សូម្បីយើងទើងចាប់តែមួយថ្ងៃហោង; ថាដូច្នោះហើយ ទ្វាចចូទើងព្រះចាខុលទីតេហាកដ

នោះហ៎ះ ! ចូរត្រេះស្តែងទៅក៏ទៅអេះ ឃកអាសនាមួយអន្លើនឹងគ្នាតាំងឡាយហោង ហើយចូរអ្នកតាំងឡាយធ្វើដំណោះឈ្មោះប្រកែកជដែកតាក្យនឹងស្តេចយើងថា រៀវតែស្តេចចុលនិព្រហ្មខត្តជឯងចេញនឹងមានស្តេចដទៃឯណាក្រៃលែងជាងនោះឥតអង្គីមានឡើយ ហើយសូម្បីមាត្រាអាសនានៃស្តេចយើង អ្នកតាំងឡាយមិនឲ្យបានឯងហោង តាឥឡូវនេះ រស្រាលាងនឹងផឹកក្តី ត្រាសាច់នឹងចំណីឆ្កែក្តី យើងកុំឲ្យឆ្ងាយឡើយ ហើយអ្នកតាំងឡាយសន្ទាប់តេទៅតាហ៊ានោះ ចូរគ្នាយើងស្រែកហៅខ្លួសីតូកោលាហលរវៃលរវៃលោះឲ្យច្រើន ហើយយើងកាន់យកខ្លួត្រូវនឹងដំបងផងតាំងឡាយទៀតប្រដាវយន្តតាត់តាំងឡាយ ធ្វើឲ្យខ្លាតខ្លាយត្រាសាច់តាំងឡាយ ចូរកុំឲ្យឆ្ងាយឡើយ ស្បែតាត់ឲ្យធាប់ចូលទៅកណ្តាលដំនុំសេនាយោធាតាំងឡាយ ហើយតែងចូលទៅកន្លែងតស្រែកខ្លួសីតូនោះឲ្យរវៃលរវៃលឡើង ធ្វើហាក់ដូចកលអសុរកំនឹងចាប់អាត្មា ចូរតែងស្រែកយោសនាឡើងថា រីរយើងនេះ ជាអាមាត្យទៅមហោសថអ្នកជ្រាជ្ញ អាចបំតេទៅមិថិលានតេនាយហោង ហើយតែងជាដូច្នេះ កោ ម្នាលអ្នកតាំងឡាយអើយ ! នោះយោជ័នឹងអាចមកចាប់ស្តេចយើងលង់លេងមើលហ៎ះ ។ . . . តុម្ហាកំ អាកតភាវំ ជានា. បេត្វា អាកច្ចថាតិ វត្វា បេសេសិ ។ តេ សាធូតិ តស្ស វចនំ សម្បដិច្ឆិត្វា វដ្ដិត្វា . . . ។

(នៅមានត)

ការរៀបរៀងនៃកតដែនដី

និង

តើតជាថ្នីសារឡើងវិញ

ពាក្យការ

លោក ញ៉ូង.សឿង ធិតន្ត

(តចប់)

ការកកើតឡើងវិញនៃពិភពលោក

តពីនេះទៅយូរអានេក　　គេលមួយមហាមេឃស្រែកធ្ងន់ធ្ងើយ

ផ្គរលាន់ខ្លាំងកើនឥតស្ម័យ　　គគ្រេងរលូងល្ងើយហាក់ស្រណោះ ។

ហាក់ដូចស្រណោកសោកសៅក　　អាសូរដ៏ខ្លាំកសត្វគៀងគោះ

ទីហាន់ប៉ុន្មានដែលឆ្នេះខោះ　　ដោយក្តីអាឡោះស្មោះពេកក្រៃ ។

រួចតាំងបង្អុរភ្លៀងរលើម　　ខ្លួចមជាន់ចុះអចិន្ត្រៃយ

ផ្សើមគ្រប់កន្លែងក្លើងប្រលាយ　　ខ្លួចទៅតាំងដែនគួរអស្ចារ្យ ។

គ្រាប់ភ្លៀងដំបូងដូចគេសាច　　សក្សុសក្ដីស្ងាចតួចល្មិតល្មោះ

ហើយកាន់តែទ្រើសលើសប៉ុន្មាន　　យូរយារជោរជ្រៃប៉ុន្មានឈើពាល ។

ភ្លៀងក្នុងគ្រានេះមិនដូចមុន　　ភ្លៀងខៀងខ្វែគុណដំគ្រកាល

ភ្លៀងនាំបង្កើតចក្រភព្យ　　ភ្លៀងនាំបណ្ដាលស្រស់ស្តួត ។

ភ្លៀងមិនដាច់គ្រាប់ជាប់ជានិច្ច　　ភ្លៀងពាល់តែលិចគ្មានសល់អ្វី

ក្មៀនយូរអង្វែងក្នុងលោកិយ　　ក្មៀនគេញកតបីខែបំផ្លិចស្ងាត់ ។
កាលក្មៀនបង្អុរពោរពេញហើយ　　អ្នកអើយមានខ្សល់បក់ចេញជាត់
តែខ្សល់អស្ចារ្យខ្លាំងក្លាត់　　បក់ពុះពារកាត់កណ្តាលទឹក ។
បក់បៀតជ្រៀតជ្រែកបែកពពុះ　　បក់ប៉ុនគេព្យុះសូរគគឹក
បក់ហើយបក់ខ្យែតខ្យែតពន្លឹក　　បក់ពាល់នៃទឹកឡើងកកវិង ។
បក់ខ្ទាំងប្រជួនជួនយ៉ាំងញាប់　　បក់ថែមសន្ធាប់រំពឹង ។
បក់មិនសម្រាកផ្លាកត្រឹមហ្នឹង　　ខ្សល់នៅតែប្រឹងតឹងចម្អែក ។
ខ្សល់បក់ចំហៀងខ្យែងទៅក្រោម　　ព័ទ្ធខ្មោមដុំវិញគ្រប់ចំណែក
តាំងគ្រដុំទឹកមិនឲ្យបែក　　ខន់ខាប់អន្ទេកទើរលើខ្សល់ ។
ប្រៀបដូចទឹកជក់លើស្នឹកឈូក　　ផ្ទេងផ្ទាំងដូចភ្នូកទៅសល់រំលង
ភរយោភ្ញាំងខ្លួចគ្រប់មណ្ឌល　　ដូចគេតំកល់ជាច់ជាជក ។
រួចហើយខ្សល់បក់ជាល់ជាប់　　រុញច្រានប្រញាប់ការខំតាម
ដើម្បីបង្កើតផែនដីកប　　ទៅតាមសភាពដ៏បុរាណ ។
គ្រានោះព្រហ្មលោកកើតឡើងវិញ　　ពាំងហ៊ានសូត្រមិញតិកើតថ្មាន
តាមដោយខំនឹងដើមជាន　　គ្រប់ជាន់ថ្នាក់ហ៊ានដូចធម្មតា ។
ចំណែកបែកហ៊ានមនុស្សលោកថ្មី　　មិនពាន់មានដាក្រក្រឹក្សា
មានសុទ្ធតែទឹកសន្ធឹកថ្លា　　ល្អក្លាជាក្រណាលខ្លាមសាយ ។

ស្រាប់តែមានខ្យល់ខ្លាំងគ្រឹក(*) បក់បំភ្លេចខ្ចប់ទឹកទាំងមាសឈ្មោយ
ធ្វើទឹកឲ្យទាប់ស្ងួតអន្ទាយ ឲ្យកើតខ្លិះក្អាយមានរសឆ្ងាញ់ ។
ខ្លិះដែនោះឯងអណ្តែតត្រា លើទឹកធម្មតាហាក់ដូចខ្លាញ់
ប្តូរដូចទឹកដោះព្រោះចំពាញ់ ផ្អែមឆ្ងាញ់មិនចាញ់សេដាតិស្ករ ។
មានខ្លិនក្រអូបយ៉ាងឈ្ងុយឈ្ងប់ ព័ណ៌ស្រស់លើសលុបដំបូរ
ជាទឹកឥតមានលាយកកេរ គួរឲ្យត្រេកអរាយចិត្តចង់ ។

កន្លែងនោះឯងថ្ងៃឯសត្វ ដែលកើតរឹបត្តិខ្លាត់ស្ងាប់បង់
ទៅកើតត្រហ្មណោកាំងផ្សាតង្ស អង្វែងយូរលង់មុនឆេះតំប្ល ។
ខ្លះអស់អាយុខ្លះអស់បុណ្យ ពស់ជាបង្កងតែត្រូវស្ងាប់
តំបេះលែងចុះក្រឡាប់ កើតជាលំជាប់កន្លែងលោកិយ ។
ដោយខុបថាតិកកំណើត ស្រាប់តែកកើតធំដឹងក្តី
ហើយមានតន្ទីក្តីស្មើ សិរីប្រាសឆ្ងាំងាំងខ្លួនឯង ។
ជាសត្វមានឫទ្ធិតេជគុណ រុងរឿងថ្កើងថ្កុំសមចិត្តោង
បិតលើអាកាសជាសជាក់ស្តែង ហោះធ្យានខ្លាត់ខ្លែងក្តីត្រោងត្រាយ ។
មានតែបិតជាអាហារ មិនខាន់ត្រូវការបេះឃ្មោងបាយ
ទាំងគ្នាផ្អែកផ្អៅរហោរប្រញាយ កន្ត្រៃស្អែកស្អាយបានតាមចិត្ត ។
ប៉ុន្តែចំណែកត្រឹងប្រជាប់ ភោគាសម្រាប់ស្មៀកចាំងបិទ

---

*- ខ្យល់ផ្សេងមួយលើកទៀត ។

គ្មានខេត្តអ្នកអើយបើតាមពិត ថ្មីបើមានបួនប៊ីបីតសើមេយ ។
ចាំងកេទសង្កើតខឿនច្រាកដ តីគោលកំណត់តត់ចំណែក
ជាប្រុសឬស្រីផ្សេងដោយខ្លួនក កំណតមានថ្ងៃកខែកសញ្ញា ។
គ្រាន់តែមានពាងពិតជាមនុស្ស មិនដឹងស្រីប្រុសទុំសត្រង់ណា
ស្អាតឆេងត្រងិលស្រស់គ្មានគ្រា មិនអាចពាយជាឲ្យត្រូវម៉ក ។
ត្រគាកត្រគះកន្ទឹង - ជើង រលោងរលើងដូចគេបក
សាច់មជ្ឈដ្ឋតស្ងួតតស្រួតស្រក កុញ្ជាកកប្រវែងលើងកំសាន្ត ។
វេលាត្រានោះមានសត្វមួយ មិនស្ងួរចេះត្រួយក្ងេវក្ងាហាន
ខ្លះខ្លោះជាងគេចាំងប៉ុន្មាន ឃើញខ្លិះដើរស្ងាចជាស្ដីនេះ ។
អណ្ដែតដេរដាសក្រាស់លើទឹក តាសគេញាសន្ធឹកច្រើនអីម្ល៉ះ
តិតាំងលូកដៃលែកកេះ កកាយធ្លុះបេះញាក់មាត់ប្លុប
រសជាតិនោះឯងដែលខ្ញុំញៀក្រៃ សរសៃប៉ុន្មានជ្រួតជ្រាបសព្វ
ភ្លក់មើលប៉ុណ្ណោះមិនចាន់ស្កប់ រឡប់រឡប់ចេះតែថែម ។
រីសត្វឯទៀតនឿតគ្រាប់តាម ជញ្ជក់មាត់ញាំមលិទ្ធថ្ងូម ។
តាត្រោះខ្លិះដើមានរសផ្អែម ស្រាប់តែឆ្លើលភ្លែមគ្មានសល់ម្ចាក់ ។
ឆ្ងុះស៊ុតិច ។ មិនអស់ចិត្ត ត្រោះជ្រាតក្ដីល្មោភលោភជំពាក់
មិនកាយខាន់លើសើកក់ ។ លេងលូកដល់ថ្នាក់ប្រឡាក់ដៃ ។
តួតជាតំនូតស៊ុយម ។ ស៊ុនោះមិនល្មមខេត្តកប៉ៃ

ដូចមនុស្សអត់ចាយឃ្មាន់ឃ្មុំរៃថ្ងៃ ពីតវតសំច័យទាល់តែផ្នែត ។
ព្រោះតែបរិភោគរយោគខ្លះដ៏ ស្មៅដែលធ្លាប់ក្លឹកក្រែឡែត
កំស្រាប់តែចាត់ស្មាត់មួយក្បែត បណ្តាលកើតរហតុដ៏ធំតឈឺដ ។
តាំងផ្តើមចល់ខ្លួលជ្រួលជ្រើម ពតាមតើមក័យស្មោស្ងើដ
ពពាក់ពពួនលួនប្រែប្រើដ មិនដឹងជាទៅទិសទាដ៏ណា ។
ធ្លាប់មានពន្ធីក្លឹងដ ចំញាចចំក្លែងដូចតាក
ឥឡូវខ្លាចាត់ពីកាយា ព្រោះតែតណ្ហាលោភលើសលន់ ។
សត្វតាំងពុំទ្នានទានសប្បាយ តើតក្តៅក្រហាយស្តាយពេកពន់
ជំពុំគ្នាព្រួយជួយគិតគន់ បែរបន់ទឹកភពន្ធីថ្ម ។
ត្រាខោះមានភ័ព្វតាប់មង្គល សុរិយមណ្ឌលរឿងរ៉ាវ
ចំបាត់ភ័យសត្វកដ៏លោកិយ ខើបបើកស្មៅក្លឹបស្លាខែដ ។
រីឯពួកសត្វកំពុងព្រួយ ដើបក្បាលរង្គើយអរក្រៃលែដ
បានឃើញពន្ធីក្លឹចំក្លែដ ផ្តើលតេកាត់ខ្លែដឆើយមើលមេយ។
កក្លែដកញ្ជាត់បាត់ក្តីខ្លុក រីកមុខប៉ំប្រមញាញីមត្រេក
លោតហោកក្រេញរៃខ្យៃអែនក សប្បាយចំខ្លែកស្រែកហោហា ។
ខើបតាំងសន្មតនាមពន្ធី មណ្ឌលដែលក្លឹថា "សុរិយា(១)"

១- សន្មតនាមថា "សុរិយៈ" ព្រោះពន្ធីខោះក្នុងពេលដែលរះឡើងអាចបំបាត់នូវភ័យ ព្រួយរបស់សត្វ ហើយញ៉ាំងសុភោគធំសេចក្តីក្សៀវក្សាឲ្យកើតឡើង ។

ក្រោះហេតុញ៉ាំងសត្វព្រួយចិន្តា ឲ្យបានភ្លៀវភ្លាបាត់កិតក័យ ។
កន្លងកាលខោះឯងព្រះអាទិត្យ សំដែងរុងឫទ្ធិពេញមួយថ្ងៃ
ក៏អស្តង្គតរលត់ក្សីយ ទៅតាមសម័យលោកនិយម ។
ឯពួកសត្វនិករាំងខោះឯង គឺឯង្គូនចំបែងវែងបារម្ភ
ងងឹតចូលលុកមុខក្រៀមក្រំ ខាំគ្នាខិតខំអធិដ្ឋាន ។
នេះនុគុណបុណ្យព្រះអង្គអើយ ម្តេចខ្សោយមកខាំឲ្យព្រួយច្រណែ
ម្តងមានពន្លឺម្តងងងឹតខាន ក្សេមក្សាន្តមិនបានហូរហែរសោះ ។
ប្រសិនបើមានពន្លឺពៃ យើងអស់ចង្រៃគ្រួយក្រៀមក្រោះ
មុខជារីករាយសប្បាយស្មោះ រាំដោះកង្វល់ខ្វល់គាននឹង ។
កាលខោះរំងៃចន្ទមណ្ឌល ឆេតឆាយនិមិលហាក់យល់ដឹង
សេចក្តីប៉ុនប៉ងចំណងហ្មឺង ដែលសត្វរំពឹងខន្ធឹងខ្ជាំង ។
ឋភ្លេញាស្មើតិសិរច្ឆេង រះលេចភ្លែតខ្សេងពន្លឺចាំង
ត្រចះត្រចង់ខ្ចង់សម្រាំង ភ្លឺថ្លាំងស្រទន់ពេកពណ្ណភយ ។
ពពួកសត្វសត្វតាំងប៉ុន្មាន កំពុងតឹងតានច្រណែនឮញាណភយ
ស្រាប់តែត្រឡប់ជាប្រែក្លាយ ញាញីមន្ទាក់ឆ្កាយសប្បាយក្រៃ ។
ខាំគ្នាស្មន្តគគក់តាំងតែង ពន្លឺខោះឯងជាជ័ន្ធ(១)ថ្ម

១- កំណាត់នាមថា ...ជន្ធ... ក្រោះពន្លឺខោះហាក់ដូចជាដីតំណ ...ជន្ធ... (បំណែកឬអង្ករស្រែយ) ប្រសិនសត្វទើបរះឡើង ។

ត្រោះរេបំតេញអធ្យាស្រ័យ ពួកសត្វដែលតំយ៉ៃទ្បីដូរស្រាល ។
ពីនេះតទៅជាលំដាប់ កើតឆ្កាយតាន់តាប់ដ៏ត្រកាល
ជាប្រុសផ្សេង ។ គួរត្រកាល ត្រោងត្រាយជាសជាលតេញមេយា ។
ចាប់តាំងពីនោះជាដើមហេតុ បរិច្ឆេទកត្រឹងនឹងពីរ
កើតមានច្រកដងកំណត់ឃ្វា ខៀនតេលវេលាជាដកប ។
រីឯរដូវនឹងខែទាំ មានត្រឿងចំណាំតាមសកាព
កំតែលក្នុងខ្ញុំណាន់រៀងកប ឥតសាបរលាបដល់សត្វថ្ងៃ ។
ចំណែកកតផែនដែនប្រថពី បពិតតីដែស្តីមស្តែ
សំនេរុកជហិមាលីយ កើតកន្លងសម័យជាន់នោះ(១) ឯង ។
តំណាងតំងាតុស្មៅដុះដេរជោស លួតលាស់តេញពាសសត្វកន្លែង
តាំងរៃត្រព្រឹកល្ងាតវែង ប្រដែងដុះដែរជាលំដាប់ ។
ទឹងថ្ងៃងងឹតសត្វតាំងឡាយ លែងត្រាយខ្ទុលខ្ទាយណាយយ៉ឺនយ៉ាប់
បរិភោគខ្ទិះដើទ្បាញ់ចំណាប់ ដែលមានស្រេចស្រាប់សម្រាប់ខ្លួន ។
លុះកាលកន្លងយូរអង្វែង កំឡាំងកំហែងកំម៉ាំមួន
ប៉ុន្តែសម្បុរលែងខ្ចាប់ខ្លួន ខ្លះទៅសមសួនខ្លះស្មៅហ្នង ។
អ្នកមានប្រុលស្អុតតណ្ហាយ មើលឆាយអ្នកអន់ឯទៀតផង
ដៀមដាមចាក់ឆ្នៀលដៀលខឹងង ថាអាប់តេកះហោងសាច់តគ្រើម ។

១- កើតងំណាលគ្នាក្នុងថ្ងៃកំណើតនៃព្រះអាទិត្យនិងព្រះចន្ទ ។

មើលទៅគ្រាតមិនស្អាតស្អំ សម្បុរមិនសមដូចពីដើម
ភាំបៃបកខួរគួរឲ្យខ្ពើម កុំមកជិមទើមនៅស្បែអេញ ។
ព្រោះមើលងាយគ្នាជាបច្ច័យ នាំឲ្យចង្រៃកើតគ្នាខ្ញាញ់
ខ្លះដើរដែលមានរសជាតិធ្ងាញ់ ស្រាប់តែចាលចាញ់រឿងបាត់ ។
នាំគ្នាជំនុំជុំខ្វល់ខ្វាយ មិនសូវសប្បាយស្កាយគេកក្តាត់
ពុំគួរមានអ្វីមកជ្ឈប់កាត់ កំចាត់ចំណីធ្ងាញ់ពីសា ។
គេលនោះស្រាប់តែក្រមរដើ កើតឡើងភ្លេងថ្មីមានទុបមា
ដូចផ្សែតក្បាលពស់ស្រស់ថ្លៃថ្លា មានរសឆ្ងាញ់គេកវៃក្រ ។
ចានជាចំណីសត្វតាំងឡាយ ចែកគ្នាប្រញាយគ្រាន់អាស្រ័យ
ចិញ្ចឹមដរីតរៀងកល់ថ្លៃ តជាបច្ច័យយូរអង្វែង ។
កើតមានកំឡាំងភ្លាំងស្ទាហាប់ រឹងប៉ឹងចំណាប់យ៉ាងខ្លាំងវែង
រឹងសម្បុរកំផ្លាស់ថ្លែង តាំងដៀលគ្នាឯងដូចមុនទៀត ។
លុះក្រមរដើរនាសទៅ តពួកសត្វទៅព្រួយចង្អៀត
ចេះតែគិតតែលៃឈ្លាសទៀត តាំរគ្រោះរកស្មៀតលៀងជីវិត
វេលាគ្រានោះបចាលតៈ(១) ច្រើនពៃក្រណាស់ណាដុះដុំដិត ។
មានរសផ្អែមល្អែមយ៉ាងប្រណិត ជាទីគេញ៉ាំតែសត្វតាំងឡាយ ។
កាលយកវល្ល៍នោះជាគាហារ ស៊ីមានរោគាតុការណ៍ដូចបរិយាយ

១– ឈ្មោះវល្ល៍ស្លាំងមានរសជាតិផ្អែម, មានសណ្ឋានដូចវល្ល៍ត្រកួន ។

ខាងដើមមកហើយដោយច្រួសត្រាយ គឺនាំប្រែក្សាយជាលំនាប់ ។
លុះកាលតមកកំយុវលង់ វិល្ហីនោះមិនតង់អស់កាលកប្ប
សូម្បីសម្បជោសតាន់តាប់ ក៏ប្រែក្រឡាប់តាយសូន្យសោះ ។
សត្វសត្វកើតខ្មុកមុខត្រៀមក្រំ ដែត្រួយជាម្ដងស្ដួយស្រណោះ
ស្មានជានវល្លីឆ្ងាញ់ជាកើរកោះ តែមិនដូច្នោះខុសបំណង ។
គ្រានោះឯងក្លូស្រែវែលលី ព័ណ៌ស្រស់តិសដុះឡើងស្មង
ផ្ទៃជាអង្គរសេមត៌មង ស្អាតស្រេចតែម្ដងមិនជាច់ស្រិត ។
មានទ្វិនក្រអូបយ៉ាងប្រសើរ ឈ្ងុយឈ្ងប់ប្រហើរក្រៃពេកពិត
គឺជាតែគួរចាប់ចិត្ត ដើមដុះដិតស្និទ្ធបិតតាសាល ។
រសត្វតាំងឡាយជានយើញក្លាម ប្រឹងសុះរកមដោយស្រើបស្រាល
ប្រឡេះបេះស្រូវថ្មីត្រកាល ធ្វើជាអាហារយ៉ាងរីករាយ ។
តាមក្នុងតម្ពីរមានសំដែង ថាពេលនោះឯងកើតឆ្នាំងចាយ
សត្វសត្វតាំងអស់មុខស្រស់ស្រាយ ចែកចាយប្រើប្រាស់ត្រប់គ្នីគ្នា ។
គេយកអង្គរដាក់ក្នុងឆ្នាំង រួចតាំងដំកល់លើថ្នាំង
មានភ្លើងឆេះឯងស្ដួងណាស់ណា ក្លៅតិចថ្នាំងនោះឆ្អិនស្រេច ។
គេគ្មានត្រូវការដោយសំឡ ដៃលផ្សំគ្រឿងសូពីត្រីសាច់
ឬម្ហូបឯទៀតមិនចាំបាច់ សម្រេចមានតែជាយនោះឯង ។

ចិត្តអ្នកបរិភោគចង់ដូរប្រៃ(๑) មិនចាំកែរៃត្រួយខ្លះខ្ចៃ
រសជាតិជាយនោះអាចផ្ទាស់ផ្ទៃ ក្លាយភ្លាមទៅឯងតាមចិត្តខឹក ។
ចំណែកផ្ទៃស្រែវិមានជម្ពូ ចោចបេះត្រង់ណាកន្លែងព្រឹក
គេលល្ងាចមានវិញគេញាសខ្លឹក ទ្រុចទ្រុលណែនញឹកដូចប្រក្រតី ។
អស់លោកអ្នកអានជាន់ពិនិត្យ ត្រិះរិះគន់គិតព័ត៌មានុស្សថ្មី
ប្រហែលសង្ឃឹយដែរឬអ្វី បរិភោគចំណីគ្នាខ្លះនោម ។
ស៊ីហើយស៊ីខៀតធ្វើតចម្រុះ ខេះតែបញ្ចុះច្រកចាំងតោម
បើគ្មានទ្វារចេញដេញទៅក្រោម របស់នោះក្រមទៅឯណា ។
រឿងត្រង់ហ្នឹងសឹងជ្រាបស្រាប់ ដូចខ្ញុំសាស័ព្ទខានដើមថា
សត្វមានកំណើតពីព្រហ្ម ដំបូងគឺគ្នាគ្នានូវមគ្គ ។
ឥឡូវខ្ញុំសូមលៃដំរាប ឲ្យលោកអ្នកជ្រាបដោយជាក់លាក់
ទៅតាមហេតុកេរលំដាប់ថ្នាក់ កុំឲ្យវង់វាក់ខាក់សេចក្តី ។
អាហារជាន់នោះខ្ពស់បំផុត ដូចទិព្វបរិសុទ្ធកន្លងលោកិយ
ដំបូងគឺរសជាតិខ្លះដ៏ ដែលកើតជ្មោងថ្មីសម្រាប់សត្វ ។
រហូតមកដល់ថាលភា វិសេសថ្លៃថ្លាឆ្ងាញ់ពេកក្តាត់
កាលលេបចូលភ្លាមរលាយឆាប់ ជ្រួតជ្រាបសូន្យស្ងាត់សត្វសរសៃ ។
គ្មានសៃសស្សល់កាកជាលាមក ខ្ជិនស្អុយគគ្រក់អសោចប្រៃ

๑- មានសេចក្តីប្រែដាក់ដើម ។

លំបាកបត់ដើនរឿងកាលដែ ដូចក្នុងសម័យយើងនេះឡើយ ។
ប៉ុន្តែមកដល់ស្រុកសាលី រីកេទប្រុសស្រីណាអ្នកអើយ
មុនជាកើតមានច្រកដហើយ តម្លើបានធ្វើយយ៉ាងជាក់ស្តែង ។
ព្រោះជាតិអាហារមិនមែនច្រើយ មិនធាប់លាយក្លាមឯង ។
កាលលេបចូលទៅនៅត្រាំត្រែង នាំកើតតឹងតែងរែងរឹតកវ ។
ត្រាំនោះសត្វសត្វច្រើយចិត្តខ្លាំ ព្រោះណែនហួលហាលខ្លួនខ្លះ
តឹងកោះក្នុង ។ ហាក់ដូចស្ពាន បញ្ឈរក្អែកស្ទឹងប្រឹងកិតកើយ ។
ប៉ុន្តែដោយមានកំភ្លាក់ស្មា ពស់ជាតាំងដោតដើយ
តឹងមិនម្នាក់មកជួយលែ រវៃសម្រួលពីរឿងហ្នឹង ។
ពេលនោះអស្ចារ្យការចំឡែក ស្រាប់តែក្លាយបែកបែកជាលិង្គ(១)
មួយភ្លែតលេចលូតស្អីឆ្ងាយឆ្ងើង ទ្រលឹងទឹងតឹងហាក់ដូចចោំល ។
មួយខ្មែតស្រកូកក្រាបនៅគល់ ខនណាមិនយល់កុំដេញដោល
ប្រយ័ត្នខ្ញុំភ័យល្ងាំងតែំចោល គេចបាត់ស្រមោលខានតរឿង ។
កើតក្លាមួយខ្មែតផ្សែងដោយខ្លែក ខុតជាចំណែកបញ្ចេញគ្រឿង
លាមកអួរាប់ខនាប់លឿង កុំឲ្យកកគឿងខ្លែចសុខស្រួល ។

១- ភេទ, លក្ខណៈ ឬ គ្រឿងសំគាល់ជាប្រុស-ស្រី ។ អ្នកដែលធ្លាប់មានភេទជាប្រុសពីដើម ដំណើរកាលមុនកើតជេះក៏ឲ្យ) ពេលនោះបានទទួលភេទជាប្រុសវិញ ឯអ្នកដែលធ្លាប់ជាស្រីពីដើម ក៏មានទំនងដូចគ្នានេះ ។

កាលបានកើតក្នុងពាំងពីរក្នុម　　អ្នកដែលខឹមតាមតំណែនអួល
បត់ដើងតូចធំតាមសម្រួល　　អស់ក្តីចុកហួលស្រួលចម្ងាយ ។
តែបែកប្រុស ។ ធ្លាល់មិនដឹង　　អីក៏ខ្លួនហ្នឹងតិចាកថា
ស្រាប់តែកើតក្នុមមកពីណា　　ឮយំរាងដែបក្រងក់ដំក់ ។
ទើបមើលនាយអាយដោយអឹមអៀម　　មិនស្ងាត់ចាត់ស្ងៀមលបសំឡក់
សំឡឹងតិនស្រីក្នែកមុំក់ ។　　ហាក់មានអ្វីឆក់ប្រពាញចិត្ត ។
រីឯស្រី ។ ដូច្នោះដែរ　　តំតាំងងាកបែរមើលបញ្ជឹត
បញ្ជឿនជឿនវិញដោយស្នេហ៍ស្និទ្ធ　　ឃ្លេ ។ រឹបរឹតលែងឃ្លាតចាយ ។
ខាងណោះងាកទៅខនលគក　　ខាងណោះក្នែកមកត្រតាកសាយ
កតៈកេលកលាលក្នុងតាយ　　បបូរមាត់ស្រាយក្នែកមម ។

ភាព ៩

មេឃខូចមេលើមលាយព្រះតាយផាត់
ឮរំពាត់ភាត់រំពាកបោកសព្ទទី
ឈើតូចធំរលំខ្លះរបាក់រី
ខ្យល់យោយីចិប្តីខ្លាចគ្នាន់ចាំង ។
ផ្លូវគ្រឹកភ្លឹកគគ្រែងរលងខ្លះមេឃ
លាន់អនេកផ្ទេកបន្ទាររញ្ជួយធ្ងាំង
តាំនេះរះនឹកពុទ្ធគុណនាំង

ចាញ់ម៉ាំងម៉ាំងចាំងក្តីប្រាលដាលប្រក់ត់ ។
គួរឲ្យកិតតិតឲ្យកំយៃលៃខ្ចាចដាប់
ឆ្កើលដូចខ័តញាប់រលៀងលំទាំងសត្វ
សូរសៃម្រែកស្រែកគ្រហឹងប្រឹងប្រយ័ត្ន
ខ្លះចោលចាត់ខ្លាត់ភៀតឆ្ងាយផាយបះដើង ។
ខ្លះកេរ្តិ៍កត់រើកដល់ទល់កុដង្គ
នាគរឿងរុងពង់តតាក្អេរធើបខ្លើង
ទឹងធុរេវៀក្រៃតំកេធក្រោធដូចភ្លើង
ក្បាលគ្រមើងដំខ្លើងឫទ្ធិឥតស្ងប់ស្ងៀង ។
ទើបស្តេចនាគងាកងើកគ្រុលសសុលចូល
ជ្រៃកកង់សុលបណ្តុលកោះស្មោះចំភ្នែង
កន្ទុយញាប់ជាប់ប្រកិតតឹតទឹងខែង
ក្បាលប្រខ្មែងរែងប្រឡូកចូកព្រៃស្ងាប់ ។
សូរសន្ធឹកគគឹកញ៉ាខ្ទើរចំខ្លែក
រឹងសន្លែកបែកផ្តាំត្រែងដូចផែ្សងអ័ក្ស
ក៏ខ្លាយសាយសព្រាតភ្លាតខន់ខាប់
នាគស៊ូស្ទាប់យាំប់ដូចម្តេចមិនតេចក ។
ដល់ថ្នាតកោះស្មោះត្រសតិសត្រីស្តេច្រនង់

ហាក់ចង្អន់ចង់ស្រេនស់ឆ្អល់គាត្មា
ញ៉ែរចំប្រជ្រប់ប៉ះយកកាយណាយចិត្តា
ទើបមានតាកក្រឡាប់ធាប់រឹងខ្លី ។

ពាក្យ ៥

គ្រានោះអ្នកមានការស្រើបស្រាល ភ្លើតភ្លើនត្រអាលប្រុសនឹងស្រី
ឥតតិតប្រិតប្រៀនអៀនខ្មាសអ្វី ហោលយោកជាសដ៏កណ្តាលវាល។
ចំណែកអ្នកមានក្តីអៀនខ្មាស ឃើញរឿងផ្តេសផ្តាសអំពើពាល
នៃពួកអ្នកត្រេកជេកគ្រាបគ្រាល ខនលពាសវាល់លគួរឲ្យស្មែន ។
តាំងរវើសដុំដីនឹងដុំថង គ្រវែងចោលខ្នងពួកនោះឯង
ហើយដៀលដោយពាក្យជូរចត់ស្មែន សំដែងនូវការមិនពេញចិត្ត ។
ពួកអ្នកស្រើបស្រាលចាំងប៉ុន្មាន ស្តាប់ពាក្យនោះបានតក់រិតតែត
ឃើញថាតុំគួរគប្បីតែត ទើបរៀបចាំងបិទធ្វើផ្ទះនៅ
មួយចាំងទៀតឯរឿងគ្រឿងស្មៀតពាក់ ខ្លះក្រងប្រមាក់វល្លិ៍ក្រហៅ
ខ្លះភ្ជួសស្ទឹកឈើឬក្រងស្មៅ ប៉ុនឹងព័ទ្ធតំរៀបការកន្លែងខ្មាស ។
គេលនោះរវែលស្រវែសាលី ដែលដុះពេញដីមុខដេរជាស
មិនខាន់ប្រែប្រួលឬវិនាស នៅតែនោរពោសដូចប្រក្រតី ។
ប៉ុន្តែលុះយូរតមកទៀត ពួកមនុស្សខ្ចៅឆ្កៀតចាំងប្រុសស្រី
តាំងគ្នាបេះបួតប្រួតដាក់ល្អី ហើយកំឡាតខ្លីយកទៅពុក ។

ដើម្បីបរិភោគឱ្យបានយូរ ជាការស្រួលដូរខ្ទេចស្រណុក
គ្រាន់មានតែលក្ខុរដែកសំកុក កុំឱ្យត្រួត ។ ពាល់តែថ្នៃ ។
ដោយហេតុភ្លក្សមនុស្សកើតតំនិត ទុបាយរិះគិតចេះសំចៃ
ប្រស្រីវាពុំចិញ្ចឹមមានតម្លៃ ក៏តាយហ៊ានលៃបន្ថែមម្ហូប ។
មានផ្ទៃមិនភ្ញឹកសន្ធឹកស្ពុះ កន្ទែងច៊ីខ្លះដូចគេចង
ប្រមូលជាគុម្ពជាគុម្ពផង ហើយថែមមានល្ងង់កន្ទុំកន្ទុំ ។
មានចាំងអង្កាមតាំណិហ្នង់សៅ ក្តោបតាំងតាស្រៀងសងតង្កុំ
គឺស្រោបអង្កាំដូចគេហ៊ុម ហើយមានខ្លឹពុំចៀតមកាល ។
គេលនោះផ្តើមមានអង្រែត្បាល់ ថែនបុកដំដាល់មិនធ្លុះស្រាល
យូរៗទៅកាន់តែនាំបណ្តាល ឱ្យកើតចិត្តពាលទូចអប្រិយ ។
ទើបតាំងលៃលកក់យកចំណែក ក់សំរែងចាយចែកស្រុកសាលី
ឱ្យស្មើគាគគ្នាចាំងប្រុសស្រី ចៀសក់ងកើតក្តីឈ្លោះពាស់ខែង ។
រួចហើយក៏ចោះត្រាំប្រទល់ កំរែមណ្តូលសព្វកន្លែង
បង្កើតជាស្រែក្រឡាខ្នែង ស្រណុកហួងហែងផ្សែងដោយខ្លែក ។
ពួកអ្នកចាំងនោះក៏ប្រកាន់ ឪពីកំណាន់ខ័ណ្ឌចំណែក
ចៀតមកំរែស្រែគេចែក យើញថាស្រួលឯកប្លែកកង់ចិត្ត ។
ប៉ុន្តែមិនយូរប៉ុន្មានសោះ មានខ្លះឡះឡាះខ្លួចខ្លុំតែ
បានលួចស្រូវគេ ។ តាមកិត ចាប់យកទៅច្រឹតប្រឹងប្រែងដៅ ។

មួយលើកតីរលើកមិនកង់ចាស ទាំឡាជាលក់លក់តែមួយមៅ
អ្នកខ្លះចាប់ចាន់តាត់ផ្លៅ ចិត្តនៅខឹងខ្ញាំងតាំងក៏យូដ ។
អ្នកខ្លះដែលគ្មានកាន់តាត់ កំញើញជាក់ពត់លាត់លោតច្រ
ពាល់តែអ្នកនោះឈឺខ្លួនក្រៃ ឆ្នូយាំងដំណាំស្ទើរជិតស្លាប់ ។
មិនមែនតែរឿងលួចមួយទេ អកុសលកែតទ្វេជាលំជាប់
បច្ចុប្បន្ននេះនោះឈ្មោះអីង៉ អាប់ គ្មានមេស្តីប្រាប់ឡើយស្តាប់ចាន ។
ទើបហៅប្រមូលគ្នាចូលជុំ ជំនុំរើសរកអ្នកក្លាហាន
ដែលមានរូបល្អសមប្រាណ ស័ក្តិខ្ពស់ថ្កើងថ្កានមានប្រាជ្ញា ។
ជាអ្នកឈ្នៀងត្រង់ឆ្លងផង់ពិត មានយោធាន់ទាំងវិសេសថ្នា
ប្រតិភាណយល់ច្បាស់ចាស់ក្បៀវក្បា លើកជាមេបាវបស់ខ្លួន ។
ដើម្បីខ្លួនគ្មានច្រឿនប្រជែង អ្នកដែលល្ងង់ខ្លៅឡើយម៉ាំមួន
ជាកំពេសរណ្តាមម្នាំប្រជួន ដល់អ្នករុកក្លួនឡើងខ្លួប ។
លុះបានពីត្រោះអស់តែលវែង ឥតមានពាស់ខ្វែងក៏យល់ស្រប
ឃើញថារឿងនេះជាវេប សមស្មួនប្រកបតាមបំណង ។
ត្រានោះក៏បានបបួលគ្នា រួសរាន់ម៉ឺម្ចាស់អីង៉កង
តាមក់តក្លួនប្រុសស្រីផង រកអ្នកចំបងធ្វើដាមេ ។
ដល់ទីលំនៅប្តូរសម្លាក់ រូបកាន់សមស័ក្តិឆើតឆាន់គ
ហាក់មានបុណ្យសាន់តិប្តូក កំតាំនិរិះរកប្រាប់ដំណឹង ។

តាមដោយដំណើរដែលខ្ញុំខ្ចប់ធ្វើ មានគោលបំណងរកទីតាំង
អង្វរសូមយកជាតំនឹង បង្ហែកម៉ាំរឹងតវែងឆ្ងាយ ។
បុរសបានស្តាប់យល់យើញល្ម ខ្លួលស្ម័គ្រត្រមដោយស្រស់ស្រាយ
រមែងទុស្សាំងអស់កំរិតកាយ ស្រែកហៅសប្បាយលោតខ្លះដៃ ។
រួចហើយទើបតាំងរៀបអគិសេក សន្មតជាឯកអគិរកែក្រៃ
ឲ្យនៅស្រណុកសុខកល់ថ្ងៃ តែលើកតម្កៃខ្លួកជាមកុដ ។
កាលនោះពាក្យថា "មហាសម្មតៈ"(១) ថ្លៃថ្លាអគ្គដំបូរសុទ្ធ
កំបានកើតឡើងមុនបំផុត ពួកមនុស្សលុំអុតតាំងដំកល់ ។
តាមនេះបុរសបានខ្លួល ស្រុះស្រួលសម្រួលតាមយោបល់
ដែលគេព្រមត្រៀងប្រឹងភ្ញាយខ្លួល តែងតាំងប្រគល់កងជាន់នោះ ។
កាលបានខ្លួលជាស៊ើកុំហើយ មិនទៅកន្តើយខេខោះ
មហាសម្មតកត់ហៅឈ្មោះ អ្នកមានរឿងឈ្លោះកាត់សេចក្តី ។
ផ្សះផ្សាឲ្យបានជាន់ធឹងគ្នា ផុតទោសនិន្ទាពុំគប្បី
អ្នកណាខុសល្មមបន្ទោសស្តី ណាចង់អប្រិយចំបាបធំ ។
តាមដោយដំណើររឿងតែត ។ ត្រឹមត្រូវសុចរិតចិត្តផ្លូវធំ
ឥតមានលំអៀងធ្វើខ្លួនខ្ពង់ តម្រង់តែមនុស្សឲ្យសុខសាន្ត ។
ចំណែកខាងរឿងត្រឿងបាយចឹក ពេលល្ងាចនឹងត្រឹកចាំងប៉ុន្មាន

១- មានន័យថា "អ្នកដែលមហាជនបានសន្មតតាំងឡើង" ។

ឥតមានលំបាកត្រួយរំខាន បុរសនោះបានស្រួលជាខ្លួន ។
ព្រោះតែតែងដួនស្រែរួសាលី ទាំងតៅទាំងល្អីតាមច្រើនតិច
ជាសួយអាករបំពេញកិច្ច គ្មានពុតកលល្បិចក្រឡិចក្រែ ។
ដោយមានខំខន់ចាក់ឧរហតុ ប្រមុខលើខេត្តគឺស្រែស្រែ
បុរសមានយសខ្ពស់ភ្លឺកែ ស្រាប់តែបានតាមមួយខេត្តថ្មី ។
ថា « ខត្តិយៈ(១) » វរៈវង្ស ប្រសើរត្រើសត្រង់ខ្ពង់ពិសី
ពិសេសខត្តមសមល្បាញល្បី មហាជនប្រុសស្រីស្រឡាញ់គ្រប់។
តមកបានតាមក្រោយថង្គស់ ខត្តឆ្នើតស្រស់ដំលើសលប់
គឺនាម « ភជា(២) » កំពូលកត សឹងបានជាមួយយ៉ាងសាខា ។
អស់លោកអ្នកអានបានជ្រាបខេ អ្នក « មេធំ » នេះគឺនរណា
ដែលខ្ញើនជាស្តេចសាច់ភ្លឺថ្លា គ្រប់គ្រងរដ្ឋភ័ព្វប្រមូល ។

១- ជាអធិបតីនៃខេត្តត្រើសចំការ ។ ២- អ្នកគ្រប់គ្រងបណ្តាជនឲ្យបានសេចក្តីរីករាយសប្បាយតាមធម្មតា ។ តាមទាំង ៣ ធំ « មហាសត្ថនៈ , ខត្តិយៈ , ភជា » តាមក្នុងអគ្គញ្ញសូត្រហៅថា « អក្ខរៈ » ជាសេចក្តីថា « ពាក្យសម្រាប់កំណត់ជាកំណើតៈ ឬសម្រាប់បញ្ញត្តហៅ » ។ ពាក្យទាំងនេះ មិនមែនទើបនឹងកើតមានថ្មីក្នុងចម្ងាយប៉ុន្មានេះទេ គឺជាក្បាច់ចាស់មានមកតាំងតាំងពីបុរាណកាល (តាំងតាំងពីក្បាច់មុន ។) លុះដល់មកក្នុងក្បាច់ថ្មីនេះ គឺជាកាលសម្បត្តិ ឬ កាលៈទេសៈ ទាំងណាស់ឲ្យពួកសត្វទាំងឃើញអក្ខរៈដើមនោះយកមកសន្មតកំណត់ជាកំនាមដល់អ្នកដែលត្រូវជានរឡើងជាស្តេចជាដំបូង ។ សព្វថ្ងៃនេះទៅប្រទេសយើងតាមទី ១ ធំមហាសម្មតៈ មិនដែលឃើញប្រើទេ, មានប្រើតែតាមទី ២ ធំ ខត្តិយៈ ឬ ខត្តៈ (ជា) ក្សត្រិយ៍ ឬ ក្សត្រ (ស.) ខ័ណតាមទី ៣ ធំ ភជា តែប៉ុណ្ណោះ ។

មិនមែនមនុស្សផ្តាសាសាសន៍បែត្តិ គឺគោធិសត្វគោត្ត-គោតម
ជាតិដែលព្រះអង្គផ្តន់ទិតទំ ស្ទុះស្ទែងសន្សំសាន់ជាមិ ។
ជាន់នោះទ្រង់យោនយកកំណើត អន្ទោលកកើតក្នុងកប្បថ្មី
នៅក្នុងចំណោមជនប្រុសស្រី ទ្រង់មានសិរីខ្ពស់បណ្តាច់ ។
គេមានសេចក្តីលំបាកចិត្ត ព្រោះកើតរបែរតែមិនចេះស្រេច
ទើបលើកតាំងទ្រង់គង់ជាស្តេច ដើម្បីសម្រេចការក្នុងស្រុក ។
ចាប់តាំងពីនោះដូចថ្ងៃហើយ អ្នកអើយពួកជនដែលកើតក្នុង
ប្រកបការងារនៅជាសុខ ផុតក្តីអកឡើកមុខស្រស់ស្រាយ ។
លុះវណ្ណៈក្សត្រកើតមុនបួច ទើបផ្តួចវណ្ណៈផ្សេងតាំងឡាយ
កើតឡើងបន្តពេញសុសាយ មានជាន់ថ្នាក់ក្តាយជាលំដាប់ ។
ព្រាហ្មណៈវេស្សៈសុទ្ធៈផង (១) ជាពួកជាកងច្រើនតាន់តាប់
មានមុខរបរត្រៃការតាប់ សម្រាប់ពួកក្រុមរៀង ។ ៗ ខ្លួន ។
រីរឿងរលាយកតផែនដី ហើយកើតជាថ្មីវិញម៉ាំមួន
ដែលបានចរិយាយស្រាយតាមក្បួន ប្រកបពាក្យដួនផ្តួនហូរហែ ។
ព្រមទាំងបន្ទែមសែមពាក្យគេចន៍ ឲ្យលាស់លួតលេចមានផ្លាំផ្លែ

១- ព្រាហ្មណៈ: (ព្រាហ្មណ៍ ជាអ្នកបង្ហាត់បង្រៀនវេទមន្ត); វេស្សៈ: ឬវៃស្សៈ: (អ្នកប្រកបការងារផ្សេងៗ មានពាណិជ្ជកម្មជាដើម); សុទ្ធៈ: ឬ សុទ្រៈ: អ្នកស៊ីឈ្នួលសែង ជាកម្មករ) ។

ជាគ្រឿងតំណាងក្តីយល្ហែយល្ហៃ សន្ធតចប់តែប៉ុណ្ណេះហោង ។
ចប្បាប់តិចខេះសូមបញ្ជាក់ ដល់អស់លោកអ្នកចាំពួនផង
អំពីរឿងនេះត្រូវពាក់ពន តាមដោយចំនងដែលគួរយល់ ។
មនុស្សយើងកើតរឿងដំបូងផុត ចិត្តថ្លាបរិសុទ្ធស្អាតនិមិល
អាហារពិពួតើតកើតជួយផ្តល់ ស្រេចស្រាប់តតួរល់តែអស់អ្វី ។
ប៉ុន្តែលុះតល់ដាប់មក តណ្ហាគ្រឿតជ្រកក្នុងចិត្តថ្មី
ធ្វើចិត្តឲ្យល្អក់ខូចអប្រិយ ខួចាំនប្រុសស្រីគ្មានសល់ម្នាក់ ។
នាំឲ្យរបស់ស្រស់ទោះឯង ទៅជាតិនតែងក្លែងអាប់អាក់
ដរាបសាបសូន្យអន្តរធានបាត់ យូរ។ ដល់ថ្នាក់លំបាកខ្លាំង ។
ពាន:ទោស:មោហ:ត្រូត លោភ:ប្រកួតអួតប្រណាំង
នាំឲ្យកេលកលជាលប្រធំាង ក្លាយជាចំបាំងតាប់ចាក់គ្នា ។
សម្រុះសម្រួលលែងតើតសោះ ការញ្ជោលបោលហោះត្រូវបំផ្លាញ
ពុំដឹងជាស្តាប់អ្នកខាងណា ស្រុកយកត្រូវតែរឿងខ្លួន ។
គ្មានឧបាយមួយអាចសម្រេច តាត់ក្តីឲ្យស្រេចល្មមសមសួន
អកុសលចេះតែកើតផ្លួន ។ ឹតែថមជ្រុះជួនជាដរាប ។
លុះកេលវេលាកន្លងយូរ ឥតមានស្រាលជួរគាន់តែជាប
ពាល់តែត្រូវក្តីនិតួលនេះធាប បង្ក្រាបតាត់ក្តីទើបបានចប់ ។
តើបាប់ធម្មជាតត្រូវលាន់លោក ឲ្យជ្រះស្មោគគ្រោគកន្ទក់សព្វ

រួចហើយទើបតាំងសាត្រឡប់ បង្កើតតិតតវិញជាថ្មី ។
ថ្មីនេះយូរទៅ ។ ជាចាស់ ជាបកានតែក្រាស់ភាសតេញដី
ដកបចុះយាំប៉ាប់ស៊ីរី នៃភាសវិញខ្លីខ្លៀតដៀងជាក់ ។
វិលចុះវិលឡើងគ្មានចុងចប់ ត្រឡប់ត្រឡប់ឥតឈប់ឆាក់
នេះឯងហៅថាសំសារចក្រ វិលដូចច្រកក់ត្រឿងយានយន្ត ។
តស្វាប់ទៅកើត ។ ទៅស្វាប់ ច្របល់ផ្សាភ្ជាប់ច្រើនតោកតន់
សូម្បីតុក្កាណមានលើសលន់ ស៊ើរតែគិតគណនាពុំបាន ។
ម្យ៉ាងទៀតរឿងនេះគួរយល់ថា សត្វសង្ខាកអម្បាលម៉ាន
ដែលកកើតឡើងជារូបប្រាណ យើងពុំគួរស្មានថាថេរបាត ។
កុំថាតែសត្វក្នុងលោកិយ មនុស្សទាំងប្រុសស្រីមានដូចតែ
សូម្បីដែនដីធំក្រាស់តិត បតិតរឿងឫទ្ធិយ៉ាងស្តឹមស្តែ ។
សមុទ្រថ្រាលជ្រៅដីទឹកវារ ធំធេងអស្ចារ្យសម្បើមក្រៃ
តនឹងតែមានកាលត្រូវហិនវិហៃ ដោយកើតប្រល័យកន្ត្រាក់ឥតសល់ ។
យើងឃើញតែមនុស្សស្វាប់ភ្លឹកភ្លាប់ សត្វតិរច្ឆានងាប់កំពាប់ឃរលំ
លុះឮដីស្វាប់ស្រាប់តែធ្លាល់ ហាក់ដូចតែអកអល់ខ្លាល់វិន្ធា ។
ត្រោះធ្លាប់សេះទៅតែលើដី តភ្លូជប្រុសស្រីតដូនតា
មិនដែលចាប់ភ្ញីកន្ទឹកស្មានថា ដីត្រូវមរណាស្វាប់ដែរសោះ ។

រឿងហ្នឹងមានតែព្រះជាម្ចាស់ ព្រះអង្គជ្រាបច្បាស់ប្រាកដស្មោះ
ជ្រាបខ្លួនឯងតគ្រប់គ្រាន់គោះ ឥតមានចន្លោះសោះសល់អ្វី ។
ព្រះអង្គបានត្រាស់សំដែងហើយ អ្នកអើយសង្ឃឹកក្នុងលោកិយ
ទោះឥតវិញ្ញាណឬមានក្តី ធំតូចវែងខ្លីសុទ្ធតែស្លាប់ ។
ខ្មុសគ្នាតែត្រង់កំណត់កាល ខ្លះភាក់កណ្តាលខ្លះយូរឆាប់
ចំណែកផែនដីយូរកប់កប្ប តង់ត្រូវខូចអាប់ស្លាប់ដូចគ្នា ។
ធម៌នេះតែងមានសម្រាប់លោក ដូចកេតដឹតជាមតាមធម្មតា
តែមានជាតិហើយត្រូវចាំថា តង់មានមរណាចៀសពុំបាន ។
យោបល់យ៉ាងខ្លីស្តីប៉ុណ្ណោះ បញ្ចប់ឈប់ស្មេះជាអវសាន
បើមានខៅខ្វះខ្វះសល់ខាន សូមលោកអ្នកអានគិតផងចុះ ! ។

ភាសាសាស្ត្រ និង អក្សរសាស្ត្រខ្មែរ

រៀបរៀងដោយ

ឧ.. តាម

អក្សរសាស្ត្រខ្មែរ	ខ្មែរគួរថែថ្នូន
ឲ្យជាទន្លាប់ខ្លួន	ជង់វង់ជង់មំពង់ ។
ព្រោះអក្សរជាតិ	ដោលជាតិប្រាកដ
អក្សរលង់	ជាតិក៏រលាយ ។

ប.ត.

ជំពូកទី ១

យ៉ាងដូចម្តេចដែលគេហៅថាភាសាខ្មែរ ?

តាមវចនានុក្រមខ្មែរ ដែលបោះផ្សាយចេញពីពុទ្ធសាសនបណ្ឌិត្យក្តី តាមអក្ខរានុក្រមខ្មែរក្តី អ្នកនិពន្ធមិនបានអធិប្បាយឲ្យក្បោះក្បាយនូវពាក្យ ថា ភាសា ទេ ។ អ្នកនិពន្ធគ្រាន់តែថា ភាសា គឺសំដី, ពាក្យ តែប៉ុណ្ណោះ ។

ពាក្យថាភាសាមានន័យខ្ពស់ជាងសំឡេងសត្វ ។ ភាសាពុកជាឯកសារបស់មនុស្ស . ពុកជាការសំដែងនូវចិត្តគំនិតរបស់មនុស្សសត្វគ្រប់យ៉ាង ។ ចំណែកមនុស្សយើងមិនមានភាសាទេ ការទាក់ទងគ្នាដោយពាក្យ

ក៏មិនមានដែរ ។ កាលបើមិនមានការទាក់ទងគ្នាដោយពាក្យទេ ការចំ-
រើនតាមផ្លូវអក្សរសាស្ត្រ ក៏មិនមានដែរ ។ សូម្បីតែបុព្វសម័យរបស់ជន
ជាតិខ្មែរយើង សម័យក្រោយយុគថ្មមកហើយ ក៏នៅមិនទាន់មានការ
ទាក់ទងគ្នាបានជាប់ហើយដែរ ។

ភាសាពាក្យពុកថាជាសម្ភារៈសំខាន់ជួយក្នុងការគមនាគមន៍រកចិញ្ចឹមគ្នា ។ ភាសាមានសារប្រយោជន៍ធំបំផុតសំខាន់ត្រង់ពុកនៅក្នុងសា-
រតារ បើសិនជាយើងមិនមានភាសាទេ ប្រហែលជាសារតារនេះមួយ។
សាបសូន្យមិនខាន ។

ឥលូវនេះខ្ញុំសូមលើកយកបញ្ហាថា "តើភាសាមានដើមកំណើតមក
ពីណា ? នរណាទាំងឆ្កឹតឲ្យហៅឈ្មោះវត្ថុមួយ។ មុនគេ ? (ដូចថ្លែ
ស្វាយ នរណាបង្កើតឲ្យហៅឈ្មោះផ្លែឈើនេះថាផ្លែស្វាយ) ហេតុអ្វីបាន
ជាមនុស្សយើងមានភាសាច្រើនម៉្លេះ ?

បញ្ហាទាំងនេះ ដូចជាតិបាកទំនងជាងាស់ស្រាយ ព្រោះថាមិន
ឃើញមានជាប់ភ្ជាប់ថាភាសាមានកំណើតពីត្រឹមណោះត្រឹមណោះតែតាម
ការតិចារណារបស់អ្នកប្រាជ្ញភាសាសាស្ត្រខ្លះយល់ឃើញថា ភាសាមានកំ-
ណើតមកពីសង្គមមនុស្សមួយក្រុម។ ព្រោះថាមនុស្សយើងតែមានសង្គម
ហើយ ត្រូវតែមានការទាក់ទងគ្នា តែមានការទាក់ទងគ្នាហើយ ត្រូវតែ
បង្កើតភាសាសំដីដែលឲ្យងាយចំណាំបានតែថាសម័យដែលសង្គមទំនើមួយ។

បង្កើតជាភាសាហ៊ីយ មិនខាន់មានប្រភពដើមអស្សរនៅឡើយទេ មានត្រឹមតែសំដីគោលចេញមកតិចមាត់ ។ ដល់មកខាងក្រោយមកភាសាមានប្រែកន្ត្រាកដល់ពុកជាត្រឿងកត់ត្រាចំណាំឡើង ។

ចំពោះបញ្ហាទី ២ នេះ ខ្ញុំយល់ឃើញថា បើសង្គមមនុស្សមានភាសាការសន្មតហៅឈ្មោះអ្វីមួយ ។ ក៏ចាប់មានទៅដែរ តែនឹងឲ្យដឹងថា ឈ្មោះមនុស្សណាបង្កើតឲ្យហៅឈ្មោះបែបនេះ បែបនោះមុនគេ ដូចជាតិចាកដែរ ។ តែយើងគួរសន្និដ្ឋានថា ឈ្មោះតែនីមួយ ។ ពិតជាហៅទៅតាមសង្គមមនុស្ស ដែលចាន់យើញហេតុគេទេផលឡើង ។ បើតាមមតខ្ញុំយល់ថាប្រហែលជាគេសន្មតហៅឈ្មោះតាមគេទេ តាមហេតុ តាមផល ដូចយើងហៅ ទន្លេធំ ថ្មី ក្រុងភ្នំពេញ ។ នរណាជាមេនាំហៅភាក្យទាំងពីរនេះមុនគេ ? គឺមនុស្សសង្គមនេះ យល់ឃើញថាទន្លេនេះធំ ឲ្យឈ្មោះថាទន្លេធំ ឯទីក្រុងភ្នំពេញ ដោយដូនពេញមកសង់ខ្លួមនៅកែ្សកុំ គេសន្មតឲ្យឈ្មោះថាកំដូនពេញ តែក្រោយមកឲ្យឈ្មោះថាភ្នំពេញ ចុះនរណានាំហៅភ្នំពេញមុនគេ ? បែបតិចាកគេឈ្មោះមនុស្សហៅមុនគេមិនខាន ។

បើយើងតិចាណាសម័យសង្គមកស្ត្រីធ្វើមានេះ យើងអាចយល់ច្បាស់ថា ពិតជាសង្គមមនុស្សនាំបង្កើតភាក្យឲ្យ ប្រើ ដូចជាទី ក្រុងព្រះសីហនុ ជាដើម ។ ដើម្បីយកព្រះនាមសម្តេចទៅដាក់ឲ្យឈ្មោះទីក្រុងនេះ ត្រូវមានតណៈកម្មការធ្វើចុតហ្វាយថ្វាយទៅសម្តេច ថាសុំព្រះនាមយក

ពៅជាក់ឈ្មោះទីក្រុងនេះ ។ ទាហរណ៍នេះ ក៏អាចសន្និដ្ឋានបានថា គេហៅពៅតាមគេទេហកុដល ។

ឯបញ្ហាទី ៣ យើងមិនចាប់មានសេចក្តីសង្ស័យអ្វីទេ ព្រោះថាឲ្យតែមានសង្គមមនុស្សច្រើន ភាសាក៏ច្រើនដែរ ។ ដោយឡែកសាលភសោកនេះ មានប្រទេសជាច្រើន ដូច្នេះភាសាក៏ច្រើនដែរ សូម្បីតែជាតិដូចគ្នា ទាហរណ៍ដូចចិនមានភាសាច្រើន ដូចលោកអ្នកអានបានជ្រាបខ្លះហើយ ។

ចំពោះន័យរបស់ភាសានេះ តាមមតិលោក (Blancke ថា «Language is the instrument for the expression and communication for human thought . ភាសាជាសម្ភារសំរាប់បញ្ជាក់ប្តូរគំនិតរបស់មនុស្សជាតិ » ។

តែតាមវចនានុក្រម New Webster Dictionary ថា «Any means, vocal or other, of expression or communicating feeling or thought. In the usual sense, language means system of conventionalized signs. ភាសា គឺជាសំឡេង ឬ សេចក្តីបញ្ជាក់ឬការគមនាគមន៍ខ្លួរសេចក្តីសោយអារម្មណ៍ ឬ គំនិតត្រិះរិះ តែតាមធម្មតាវិញ ភាសាគឺជាស្នូរបស់សញ្ញាដែលគេសន្មតឲ្យប្រើ" ។

តាមសម្តីវចនានុក្រមខ្លះទៀតថា " ភាសាគឺជាសំឡេងរបស់មនុស្សដែលអាចស្តាប់បាន ដែលកើតឡើងដោយអណ្តាតនិងសំឡេង

សោតប្បសាទ, កាសាជាប្រធានបស់ភាសា ហើយជារបៀបបបសំកប់ ផ្សំពាក្យឱ្យគេស្តាប់បានខៅក្នុងសង្គមនីមួយ ។ ”

ភាសាសាស្ត្រ និង អក្សរសាស្ត្រ

ពាក្យទាំងពីរនេះ កុំច្រឡំគ្នា មិនមែនមានន័យដូចគ្នាទេ តែថា ពាក្យទាំងពីរនេះ ត្រូវទាក់ទងគ្នា ។

ភាសាសាស្ត្រ គឺជាក្បួនច្បាប់សំកប់សិក្សាខ្លួនពាក្យសំដី ឫសគល់បស់ពាក្យ (Philologie) ។ ការសិក្សាស្រាវជ្រាវរកកំណើតដើមពាក្យ ថាតើពាក្យនេះមានន័យដូចម្តេច យកមកពីភាសាជាតិណា ឬក៏គេប្រើខៅក្នុងសតវត្សរ៍ទីប៉ុន្មានជាដើម ។

អក្សរសាស្ត្រ ការសិក្សាទាងក្បួនច្បាប់អក្សរ (Litterature) ។ ពាក្យទាំងពីរនេះ មានន័យស្មើតែច្រឡំគ្នា ។ ខ្ញុំសូមយកឧទាហរណ៍មួយ ដូចការសិក្សាខ្លួនរឿងខ្ញុំតាវ ។ រឿងខ្ញុំតាវទាំងមូលនេះ ចាត់ទុកថាជា អក្សរសាស្ត្រខ្មែរ ។ ការស្រាវជ្រាវរឿងខ្ញុំតាវមកតន្ទាល់ អធិប្បាយកេឫសគល់ជាដើមហៅថា ភាសាសាស្ត្រ ។

ភាសាសាស្ត្រ ដែលខ្មែរយើងទំយាយរៀនសព្វថ្ងៃមានពីរផ្នែក:

១- ភាសាមនុស្ស

២- ភាសាសត្វ

ភាសាមនុស្ស

ភាសាមនុស្ស ចែកទៅមាន ៣ ផ្នែក :

១- ភាសាសង្ឃ ឬ សាសនាភាសា

២- ភាសាក្សត្រ ឬ រាជស័ព្ទ

៣- ភាសារាស្ត្រ ឬ ភាសាសាមញ្ញ

ខ្មែរយើងចេះភាសាមនុស្សហើយ ត្រូវចេះរៀលរកប្រើពាក្យឲ្យត្រឹមត្រូវទៅតាមហានៈមនុស្សទៅទៀត ។ បើសង្កេតឲ្យមែនខែនទៅយើញថា ភាសាជាតិខ្មែរចាំង ៣ ថ្នាក់នេះ ពុកដូចជាថា ខ្មែរមានភាសាសំរាប់ ៣ ជាតិដែរ ។ ខ្មែរយើងសម្បូរពាក្យច្រើនពាល់តែរកពាក្យប្រើមិនត្រប់គ្រាន់ ។ បានជាខ្ញុំថាដូច្នេះ ព្រោះថាដូចជាពាក្យ ស៊ី មានពាក្យ ២៧ ដែលជាវេរាចនៈនឹងគ្នា នេះហើយដែលខ្ញុំថាសម្បូរ តែរកពាក្យប្រើមិនបាន ព្រោះថាឥទ្ធិពលភាសាបរទេសចូលមកច្រឡែតជ្រែក យើងច្រើនតែយកភាសាគេមកនិយាយលាយឡំ ឬដូនកាលយើងមិនអាចប្រែមកជាភាសាខ្មែរបាន យើងក៏ពុកពាក្យបរទេសប្រើក្នុងភាសាខ្មែរ ។

១- ភាសាសង្ឃ ឬ សាសនាភាសា បុគ្គលតួកនេះ ក៏នៅមានចែកថ្នាក់ទៅទៀតដែរ ។ ទម្រាំយ៉ាយ អាចមានតុំដូចជាទៅតាន់តិក្ខុ-សាមណេរ ដែលមានវិស្សាតិចជាងគេថា "ឆាន់" ឬ "ភ្លឺ" បាន តែសាមណេរ មិនអាចនិយាយថា "ឆាន់" ឬ "ភ្លឺ" ទៅតាន់តិក្ខុទេ ។

ពាក្យខ្លះដែលព្រះសង្ឃសន្ទនាពោលបកប្រែជាតទន្ទឹមបកប្រែជាតគឺ ស្តី, ឆាន់, ភុញ្ជតិ, ខ្ញុំភុញ្ជតិ, ខ្ញុំព្រះភុញ្ជតិ ។ ជួនកាលនិយាយគ្មាយទៅជា ភុញ្ជតិ ។

ពាក្យទៅកន្លងសាសនាខ្មែរ មានពាក្យខ្លះប្រើបានតែចំពោះតែបុគ្គលម្នាក់ ដូចព្រះនាមព្រះពុទ្ធ "តថាគត" ពាក្យនេះប្រើបានតែចំពោះព្រះពុទ្ធទេ គេមិនយកមកប្រើចំពោះបុគ្គលដទៃឡើយ ។

២- ភាសាក្បែត្រ ឬ រាជស័ព្ទ យើងគ្រាប់ហៅមកហើយថា (ពាក្យសំពប់ប្រើទៅក្នុងរាជត្រកូល) រាជស័ព្ទ ។ រាជស័ព្ទ គឺជាពាក្យដោយឡែកដែលគេប្រើបានចំពោះតែត្រកូលក្សត្រ ។

ឧ. សោយ - យាង - ផ្ទំ ជាដើម

បើចង់ជ្រាបឲ្យបានពិស្តារ សូមអានសៀវភៅរាជស័ព្ទដែលបោះពុម្ពផ្សាយពីពុទ្ធសាសនបណ្ឌិត្យ ។

បើពាក្យកស្តែសាមញ្ញប្រើដែរនោះ តែគេយកទៅប្រើជារាជស័ព្ទ គេច្រើនតែយកពាក្យ "ព្រះ" ឬ "រាជ" មកធ្វើជាបុព្វបទ ។

ឧ. ទង គេប្រើជាមួយពាក្យកស្តែដែរ បើយកទៅប្រើជារាជស័ព្ទ ត្រូវដាក់ពាក្យថា "រាជវង" ឬ "ព្រះរាជវង" ឬក៏ "ព្រះទីនាំង" ។

៣- ភាសាវស្តែ ឬ ភាសាសាមញ្ញ ភាសាចំពូកនេះគឺ សំដៅយកភាសាមនុស្សពាំងពីរប្រភេទផ្នែកគ្រហស្ថ :

១- ភេទបុរស

២- ភេទស្រី

មនុស្សម្នាក់ឯណាប្រកភេទនេះ មានចែកថ្នាក់ទៅទៀត តែពេលនេះ ខ្ញុំសុំបរិយាយយ៉ាងសង្ខេបនូវភាសាចំពូកនេះ

ក) ភេទប្រុស មានពាក្យផ្សេង ។ សំរាប់បុគ្គលចំពូកនេះនិយាយ។ ដូចពាក្យថា "ខ្ញុំចាស" ជាដើម ពាក្យនេះសំរាប់តែបុរសទេ មិនអាចយកទៅប្រើជាមួយស្រី ឬ បញ្ជូតគ្នាឡើយ ។

ខ) ភេទស្រី មានពាក្យខ្លះសំរាប់តែមនុស្សចំពូកនេះប្រើ គេមិនយកទៅប្រើលាយឡំជាមួយភេទប្រុស ឬ បញ្ជូតគ្នាឡើយ ។ តែពាក្យថា "ខ្ញុំ" ពុំអាចយកមកនិយាយបានដែរ តែតាមការត្រឹមត្រូវ គួរតែថា "នាងខ្ញុំ"

ភាសាមនុស្សចែកទៅតាមឋានៈ មនុស្សមាន ៣ ថ្នាក់:

១- ថ្នាក់ខ្ពស់ ,

២- ថ្នាក់កណ្តាល ,

៣- ថ្នាក់ទាប ។

ខ្ញុំសូមដូនភាសាដែលមនុស្សម្នាក់ ៣ ក្រុមនិយាយតក់ខន្ធគ្នាយ៉ាងសង្ខេប :

ពាក្យថា "ខ្ញុំចាស, ខ្ញុំព្រះចាស, ខ្ញុំព្រះចាសម្ចាស់ ។

ខ្ញុំចាស - មន្ត្រីសក្តិតូចប្រកាស្ត្រ និយាយទៅកាន់មន្ត្រីសក្តិធំឬកំ-

ភស្តុតាងយោងទៅតាមភស្តុតាងមិនបានទេ ។

ខ្ញុំព្រះទាំង- មន្ត្រីមានយសសក្តិធំ តែមិនមែនជារដ្ឋមន្ត្រី រដ្ឋលេខាធិការ ត្រូវនិយាយទៅកាន់រដ្ឋមន្ត្រី ។ ឯភស្តុតាងនិយាយទៅកាន់មន្ត្រីសក្តិធំ ដែលមិនមែនជារដ្ឋមន្ត្រីថា ខ្ញុំព្រះបាទបាន ។

ខ្ញុំព្រះទាំងម្ចាស់- សំពាក់មន្ត្រីសក្តិតូចឬភស្តុតាងនិយាយទៅកាន់រដ្ឋមន្ត្រី ។

ការសរសេរលិខិតអំពីជាសេក្តីតាមុំទស្តុតាងមុខមន្ត្រី ឬ ជនសាមញ្ញ សូមតាមប្រដុំលិខិតដែល ឯ. ឧ. មហាមន្ត្រី ញ៉ែក - ឯ្ន តែង ។

ឯភាសាសព្ទ ខ្ញុំនឹងអធិប្បាយទៅខាងក្រោយ ។

ភាសាជាគមនាគមន៍

១- វិញ្ញាតិភាសា. ឧបមាថា មនុស្សបរទេសម្នាក់ជាខេសចរមកប្រទេសកម្ពុជា មិនចេះភាសាខ្មែរសោះ ហើយថៃមាំងមិនចេះឮបាច់បកបរនៅប្រទេសកម្ពុជាខ្មែរផង ។ មនុស្សនេះដើរតុក ។ តាមផ្លូវ ដោយមិនបានគិតថានឹងមានគ្រោះថ្នាក់ ដែលបណ្តាលមកពីរថយន្តស្រាប់តែកន្លះតេលជាមួយគ្នានោះ រថយន្តមួយបើកយ៉ាងលឿនសំដៅមកអ្នកដើរ ដើង ហើយចាប់ហ្វាំងនឹត ហើយខ្មែរម្នាក់ស្រែក «ឃ្លៀ» ជាមួយសំ-

ខ្សែឆ្នាំង អ្នកខេសចរអាចយល់ថាខ្លាន ថា "គ្រោះថ្នាក់" ។ សំរែកនេះ
ក៏ចាត់ទុកថាជាភាសាសម្រាប់តែមនុស្សប៉ុណ្ណោះ ។

ម្យ៉ាងទៀត អ្នកធ្វើដំណើរតាមរថយន្ត អ្នកមុខតែយើញមានសញ្ញា
ចរាចរប្រាប់អ្នកបើករថយន្ត ។ បើមិនមានសញ្ញាទាំងនេះទេ អ្នកបើក
បររថយន្ត មុខតែចៀសមិនផុតពីគ្រោះថ្នាក់ឡើយ ។ សញ្ញាទាំងអស់នេះ
មិនមែនសុទ្ធតែជាអក្សរទេ គេច្រើនតែប្រើសញ្ញាជាតំនូស ដូចជាសញ្ញា
ក្មេងព័រទាក់ទាន់ដៃគ្នាជាដើម ។ សញ្ញាក្មេងទាន់ដៃគ្នានេះប្រាប់ថា "ឲ្យ
បន្ថយល្បឿនរថយន្ត ព្រោះជិតសាលារៀន" ។

បើសង្កេតឲ្យយើញវែងឆ្ងាយទៅទៀត នៅតាមមហាវិថីព្រះបាទ
នរោត្តម អ្នកបើករថយន្ត ត្រូវគោរពច្បាប់ចរាចរដែលរាជការប្រើក្មេងជា
សញ្ញា ក្មេងក្រហម ត្រូវ "ឈប់!" ក្មេងលឿង ត្រូវ "ប្រុង!" ក្មេង
ខៀវ ត្រូវ "ទៅ! ដើរ! បើកបរ!" ជាន ។ ឯអ្នកចរាចរវិញ ត្រូវ
ដើរឆ្លងកាត់ផ្លូវនៅកន្លែងតំនូសដែលគួរសកាត់ឆ្លងប៉ុណ្ណោះ ។

ក្មេងទាំងនេះ សញ្ញាទាំងនេះមានអក្សរឬទេ ? គ្មានទេ ប៉ុន្តែចាន
ជាមាន "ឈប់!" មាន "ប្រុង!" មាន "ទៅ!" ជាមកពីក្មេង
មកពីសញ្ញា ប្រាប់ឲ្យប្រតិបត្តិតាម ដូច្នេះយើញថាជាភាសាមួយដែរ ។

សញ្ញានឹងៗមានសំឡេង ដែលមិនមានពាក្យតម្បាញ:បង្ហាញច្រើនបំផុត តែជាសំឡេង-សញ្ញាអន្តរជាតិស្គាល់យល់បាន គេហៅថា "ភាសាតន្ត្រី"។

២- កាយវិការភាសា (Gesture for Words) មនុស្សនៅក្នុងសាកលលោកនេះមានកាយវិការមិនស្មើដូចគ្នាទេ ក្នុងការនិយាយជាក់ខ្លះរវាងមនុស្សទឹងមនុស្ស។ មនុស្សដែលមិនចេះភាសា អាចដោះគាល់ម្ខាងៗដែរ ក្នុងការសំដែងកាយវិការជំនួសភាសា។ យើងពិនិត្យមើលមនុស្សគ្រូ តើគ្នាចេះនិយាយភាសាអ្វីប្លែក? តែមនុស្សគ្រូគាចផ្ទៀងកាយវិការឲ្យគេយល់ថាខ្លួនត្រូវការនេះ ត្រូវការនោះ, តាមកាយវិការបែបគ្នាភាសានេះចាត់ថាជា ភាសាគ្រូ។

(នៅមានត)

ដោយគណៈកម្មការជាតិនៃការស៊ើបអង្កេត ផ្នែកអក្សរ « ក »

(តមក)

Exposé préliminaire		សេចក្តីថ្លែងព្រាងក្ន (ន-ប្ប-) : សេចក្តីថ្លែងដោលៗ ជាដំបូង ។
Exproprier	(v.)	អស្សាមីក្រឹត : ដកកម្មសិទ្ធិ
Expropriation	(n.f.)	អស្សាមីកៈណ៍ : ការដកកម្មសិទ្ធិ
Etranger	(n.m.)	អ្នកបរទេស
Faire exécuter la peine		ធ្វើទោស (ន-ប្ប-)
Famille nombreuse		គ្រួសារច្រើន : គ្រួសារដែលមានសមាជិកច្រើន
Interpréter	(v.)	សំដែង (ន-សិល្ប:)
Interprétation	(n.f.)	ការសំដែង (ន-សិល្ប:)
Livre	(n.m.)	សៀវភៅ
Livre	(n.m.)	ឥន្ទ្ (ន-ប្ប-) : ចំណែកនៃសៀវភៅ,ចំណែកនៃក្រម ។ ឧ ក្រមព្រហ្មទណ្ឌមាន ៥ ឥន្ទ្, ក្រមរដ្ឋប្បវេណីមាន ៣ ឥន្ទ្ ។
De multiples familles		គ្រួសារពហុគុណ: គ្រួសារច្រើនក្រុម ។ ពួកអ្នកទេសជាតិ ផ្តុំគ្នាជាគ្រួសារពហុគុណ ។
National	(n.m.)	អ្នករទេសជាតិ: ពលរដ្ឋរបស់ប្រទេសណាមួយ។ ឧ. កុងស៊ុលតែងការពារផលប្រយោជន៍នៃអ្នកទេសជាតិខ្លួន ។

(នៅមានខត)

វិបុលានុក្រមសំស្ក្រឹត-ខ្មែរ

ព្រះមហា ទាំង . ខាត់ រៀបរៀង

(តមក)

អតិវិសារិន៑ គុ. នែលធ្ងាយ, នែលទូលាយ ។

អតិវិស្តរ ប៉ុ. ពាក្យព្រៃលែង ។

អតិវិស្តីណ៌ គុ. នែលលាតព្រៃលែង, នែលទូលាយព្រៃលែង ។

អតិវិស្តុយ គុ. នែលធូរធ្ងន់ព្រៃលែង, នែលធូរសេងរ៉ូយព្រៃលែង ។

អតិវិស្តឹត គុ. នែលធ្ងន់ព្រៃលែង ។

អតិវិហ្វល គុ. នែលត្រួលប្រចល់ព្រៃលែង ។

អតិវីរ គុ. រឹះព្រៃលែង, នែលក្បៀវក្បាព្រៃលែង ។

អតិវីយ៑ គុ. នែលក្បៀវក្បាព្រៃលែង។–វ័ន្ត, គុ.នែលមានសេចក្តីក្បៀវក្បាព្រៃលែង។

អតិវ្រីហិត គុ. មើលអតិព្ឫហិត ។

អតិវ្រឹត្តិ ឆាគុ. ប្រព្រឹត្តកន្ធងព្រៃលែង ។

អតិវ្រឹត្ត គុ. នែលប្រព្រឹត្តកន្ធងព្រៃលែង ។

អតិវ្រឹត្តិ ស្ត្រី. ការយោប្រព្រឹត្តកន្ធងព្រៃលែង ។

(នៅមានត)

រឿងសាមកុក

កំណែទី ៤៨

ទេសភ្ញាវិបុលភជសេនា ឬ-កាន ប្រែរឿបរឿង

(តមក)

> រឿងសាមកុកខុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃធ្វាសបើបានអាន
> ទំនិងបេះទៅយកលទ្ធំណាន
> ចាំងមានសេន្ធានស្នេហាជាតិ
>
> ——— យ៉ុះ - ភ្នំ ———

ដាវយ៉ើយើញសេចក្តីក្នុងសំបុត្រដូច្នោះ កំដកដង្ហើមធំឈឺដំកងចិត្តខ្លាំងណាស់ ពិសព្រួញកំកំរើកឡើងដួលសន្ធប់ទៅ ។ ខាហានដែលនៅជិតខាង កំកែវទៀងដឹងស្មាតើឡើងវិញ ។ ដាវយ៉ើដឹងខ្លួនថា មុខជាមិនរស់រួចជីវិត កំតាំងសរសេរសំបុត្រខុកមួយច្បាប់ ហើយបង្គាប់នាយទ័ពនាយកងតាំងតួនខុកថា យើងខំធ្វើការតាំងម៉្លេះ ព្រោះតាំងចិត្តគិតទំនងខំទុកបំរុងស៊ុនតួនដោយស្មោះត្រង់ តែគិតទៅមិនដុះក្លាយ ត្រានេះជីវិតយើងនិងនាសអន្តរាយហើយ អ្នកតាំងក្លាយនៅឯក្រោយ កំត្រូវជួយខំទុកបំរុងទៅហ្នាយយើង ឲ្យបានសម្រេចតាមការដែលគិតនោះផងចុះ អ្នកចូលយកសំបុត្រនេះទៅឲ្យស៊ុនតួនថា យើងសូមគំនាប់លាហើយ ។

ជីវិយ៉ាង់តែប៉ុណ្ណេះ តិសត្រូញក៏រត់សព្វសាច់សន្ធប់ជាត់ស្មារតីម្តងទៀត, ទាហានទាំងពីរដងឆ្ងាតើឡើងវិញ, ជីវិយ៉ាន់ក្មាញ់ឈឺក្នងចិត្តណាស់ ក៏ដើរមើលទៅលើអាកាសហើយស្រែកថា "ទេព្តាអង្គណាហ្ន៎! ដែលឲ្យយើងកើតមកហើយម្តេចឲ្យកំឲ្យខ្លះបងកើតមកផងដូច្នេះ", ជីវិយ៉ាស្រែកប្រកាសដូច្នេះជាច្រើនម៉ាត់ ដោយចិត្តខឹងខ្លាំង តិសត្រូញក៏តាំងតែជ្រួតជ្រាបសព្វសព្វាង្គកាយ ក៏ដល់ទូរស័ព្ទអន្តរាយជីវិតក្នុងខណៈនោះ ក្នុងអាយុគម្រប់ ៣៦ ឆ្នាំ ។

បណ្តាពួកនាយកងនាយទ័ព កំលោកត្រឡប់ទាំសពជីវិយ៉ាទៅខុកជាក់តាមបណ្តាសក្តិនាហ្នឹងធំ ។ ឯប៉ះកើតទាំសំបុត្រដែលជីវិយ៉ាសរសេរនោះទៅឲ្យស៊ុនតួន ហើយសាស័ព្ទប្រាប់ស៊ែចក្តីឲ្យស៊ុនតួនត្រាប់ប្រការ ។ ឯស៊ុនតួន កាលបើដឹងថា ជីវិយ៉ាស្លាប់ដូច្នោះ កំយំសោកគាំងឡោះគាល់យ៉ាងតិចមា ហើយយកសំបុត្រនោះមកមើលឃើញសេចក្តីថា "ខ្ញុំបាទជីវិយ៉ាសូមគំនាប់មកដល់លោក ព្រោះលោកមេត្តាតាំងខ្លួនខ្ញុំឲ្យធ្វើមេទ័ពធំ ខឹងប្រជុំប្រឹក្សាការពារជាតាំងពួង នោះព្រះគេជត្រះគុណច្រើនមិនមានទីបំផុត ខ្ញុំបាទក៏តាំងចិត្តធ្វើការដោយចិត្តស្មោះត្រង់ បំងឹងតបស្នងសងគុណលោកឲ្យបាន តែគ្រានេះ ការរបស់លោកតាំងប៉ុន្មានក៏ទៅមិនបានដំណើរ ខ្ញុំមានអកុសលកម្មនាំមកផ្តាច់ឲ្យអស់ជីវិតទៅ ដោយសេចក្តីខ្វល់ខ្វាយក្នុងចិត្ត ទោះបីជីវិតខ្ញុំនឹងស្លាប់ក៏គ្មានគិតស្តាយប៉ុន្មាន តែគិតអាទរព្រោះ

មិនបាននៅជួយធ្វើការលោកតទៅ ព្រោះសព្វថ្ងៃនេះផែនដីក៏នៅមិនទាន់
កបថាបឯទីសាងដើង ចូរឆ្លៀតបានជាធំនៅកន្លែងស្រុកហ្នឹងគោមានចិត្តរីក
រាយណាស់ ឯឡៅតាវែលនៅក្នុងស្រុកគង់ដាវ កំដោយសារស្រុកកាំង
តាំងជួយជាកម្លាំងផងទើបបានសេចក្តីសុខ លោកនឹងបង្ហាញពុកក៏ជួបជា
ចំញឹមភ្លាសាហាវ អំណោះតទៅតន់នឹងមានកម្លាំងពីខាងត្រៀមត្រឡប់ជា
សត្រូវនឹងលោកវិញ ក្នុងស្រុកយើងក៏មិនបានសម្រេចការអ្វីសោះ ព្រោះ
នាហ្នឹងក្នុងស្រុកកាំងតាំងសព្វថ្ងៃនេះ បើសិនឲ្យនឹងមើលក៏ពុំយើញនូវណា
អាចខ្លួលមុខជាវជំនួសខ្ញុំបាន យើញមានតែឡោសុកមួយ មានតម្រេះ
ប្រាជ្ញាម៉ាំមួនសមសួនជាងំ ព្រោះជាមនុស្សខៀងគ្រង់សុចរិត សូមឲ្យ
លោកតាំងចិត្តរាប់អានឡោសុក ហើយតាំងជាមន្ត្រីជំនួសខ្លួនខ្ញុំចុះ បើ
លោកនឹងអនុគ្រោះ ក៏សូមឲ្យធ្វើតាមខ្ញុំគ្រប់ប្រការ ។

ស៊ុនគួនយើញសេចក្តីក្តង់សំបុត្រជូរញ្ចាក៏ថា ជីវយើនេះមានតម្រេះ
ប្រាជ្ញាណាស់ គួរខ្លួលតំណែងជាមហាឧបរាជបាន តែមកមានអាយុខ្លី
គួរតប្បីឲ្យស្លាយតន់ពេកណាស់ រៀលានេះយើងនឹងបាននរណាមកជួយ
រិះគិតធ្វើការតទៅទៀត ដែលជីវយើផ្តាំពុកនោះសោត យើងក៏យល់
ស្រេចដែរ ។ ខណៈនោះ ស៊ុនគួនក៏តាំងឡោសុកជាមាហ្នឹងជំនួស
ជីវយើ ហើយក៏ឲ្យមាហានៅខ្លួលសតជីវយើមកសែនព្រេនតាមតំរៀម
ក្នុងស្រុកធសងគុនតាមបណ្តាសក្តិមាហ្នឹងធំ

ឯខុនបេងនោះ លុះដើរយើលើកខ្នាតៅហើយ កំនាំឡៅតិចុះពី
លើកុំត្រឡប់ទៅស្រុកកេនដើរ លុះវេលាយប់ខុនបេងកំពុងគ្រោះមើលឮក្ស
លើអាកាស ក្រេឡកយើញផ្កាយធ្លាក់ចុះពីលើអាកាសមួយដួង, ខុន-
បេងអស់សំណើចហើយប្រាប់ឡៅតិថា ដើរយើស្លាប់កន្លងថ្ងៃនេះហើយ ។
ខទួលតាហានដែលស្ទើបតាចូលមកដំកបថា ដើរយើស្លាប់ទៅហើយ ។
ឡៅតិកំច្រឹកឮនិងខុនបេងថា យើងនឹងគិតធ្វើដូចម្តេច ? ។ ខុនបេងថា
ដើរយើស្លាប់ទៅហើយ យើញតែឡោសុកមួយនិងបានជាជំនួសដើរយើ,
មួយទៀតខ្ញុំបានមើលឮក្សលើអាកាស យើញផ្កាយទៅប្រជុំគ្នានៅមិស
ខាងកើត ចាំខ្ញុំនឹងទៅសួរសេតដើរយើឯស្រុកគាំងគាំង នឹងបានស្ទើបតេ
អ្នកមានតម្រេះច្រើនជាបញ្ជុះបញ្ជូលមកជួយធ្វើការនឹងលោក ។

ឡៅតិធ្វើយតបទៅខុនបេងវិញថា ដែលលោកនឹងទៅស្រុកគាំង-
គាំងនោះ ខ្លាចក្រែងនាហ្មឹងមុខមន្ត្រីនឹងតាហានធ្វើអន្តរាយដល់លោក ។
ខុនបេងឆ្លើយថា អំបាលដើរយើរស់នៅម្តេចខ្ញុំទៅបានមិនខ្លាច តែឮដើរ-
យើស្លាប់ទៅហើយនឹងត្រូវតែគាតខ្លាចនារណាទៀត ហើយខុនបេងក៏បង្គាប់
ជូឡងឲ្យលើកតាហាន ៩០០ នឹងរៀបចំរុងគ្រឿងភ្លីការទៅជាមួយផង,
លុះចុះទូកទៅដល់កណ្តាលផ្លូវ ឮានដំណឹងអ្នកស្រុកតាមផ្លូវនិយាយថា
ស៊ុនតួន តាំងឡោសុកជានាហ្មឹងធំ ជំនួសដើរយើ, ឯសេតដើរយើ ស៊ុនតួន
ឲ្យនាំទៅទុកឯស្រុកធសងតុន ។ ខុនបេងឮដូច្នោះ ក៏ឲ្យចេវខ្លួកដម្រង់

ទៅស្រុកឆសង្ខគុន ។

ខ្សោសុកដឹងថា ខុនបេងទៅដល់ កំពុះទៅអញ្ជើញឲ្យទៅមកតំនាប់គ្នាតាមចំនៀម ។ ឯពាហានដ៏វាយក្រឡុកឃើញមុខខុនបេង កំរិទ្ធក្តៅខ្លាំងណាស់ តិតនឹងសម្លាប់ខុនបេង តែឃើញជួបឬនឈរកាន់ក្រម៉ាទៅដិតជិតជាប ក៏ញញើតខ្លាចនឹងធ្វើអន្តរាយមិនបាន ។ លុះខុនបេងទៅដល់សាលដ៏វាយហើយ ក៏សែនព្រេនតាមចំនៀម ហើយធ្វើជាយំសោកអាល័យខ្លាំងណាស់ ។ ពួកពាហានដ៏វាយ ឃើញខុនបេងយំសោកដូច្នោះក៏និយាយគ្នាថា ខាងក្រៅឮល្បីតែនិយាយថា ខុនបេងនឹងដ៏វាយជាសត្រូវនឹងគ្នា ឥឡូវខុនបេងមកសែនព្រេនឲ្យដ៏វាយ ហើយយំសោកអាល័យដូច្នេះ ក៏ឃើញថា ខុនបេងនេះ មានចិត្តសុខរិតនឹងដ៏វាយ មិនសមនឹងពាក្យដែលឮល្បីថា សត្រូវនឹងគ្នាសោះ ។ ខ្សោសុកឃើញខុនបេងធ្វើអាការសៅសោកខ្លាំងដូច្នោះ ក៏យំសោកអាណិតជាមួយនឹងខុនបេង ហើយគិតថា ខុនបេងនេះ ចិត្តល្អសុភាពល្អណាស់ គ្មានការអាឃាតព្យាបាទសោះ, ឯដ៏វាយជាមនុស្សមានចិត្តឫស្យាព្យាបាទគេចាលតែស្លាប់ខ្លួន, ខ្សោសុកលុះគិតដូច្នោះហើយ ក៏ឲ្យរៀបតុរលៀងអាហារអញ្ជើញខុនបេងថវិកាគ, លុះរួចហើយ ខុនបេងក៏លាខ្សោសុកទៅវិញ ។

ឯចំនែកឯង ក្រឡុកឃើញខុនបេងក៏ដើរចូលមក ចាប់ជាយអាវខុន-

បេងហើយអស់សំណើចថា អ្នកក្លែងធ្វើកលទុយឲ្យដាំយើញចិត្តខ្លាំតែ
ជាច់ឲ្យលំស្ងាប់ ហើយថែមទាំងមកក្លែងធ្វើជាសែនព្រួន ខ្លួញដើរគាះឲ្យ
អាល័យដាំយើខ្លែត អ្នកធ្វើការចំអកឲ្យកឲ្យើយមើលដាំយើគេដូច្នេះ យើញ
ថាស្រុកកាំងតាំងនេះ គ្មានមនុស្សដើងដល់កលទុយរបស់អ្នកទេឬ ? ។

ខុងបេងតក់ស្លុតក្នុងចិត្ត កំក្រឡេកមើលទៅយើញចាំងថងជាគ្រឿង
សម្ងាញ់ កំសោយសេចក្តីភ័យជាម្ត្ច ទើបអស់សំណើច ហើយដឹក
ដៃចាំងថងចុះទៅអង្គុយក្នុងទូក សន្ធឹងគ្នាដោយសេចក្តីរីករាយយ៉ាងក្រៃ
លែង ហើយខុងបេងកំសាសេរសំបុត្របិទស្រោមចុះត្រាប្រគល់ទុកឲ្យ
ចាំងថងមួយច្បាប់ ហើយផ្តាំពាក្យក្រៅសំបុត្រនោះថាបើស៊ុនគួនមិនបាន
យកអ្នកខុកធ្វើការពេជការេ ឬក៏អ្នកមិនតេញចិត្តដោយប្រការយ៉ាងណា
ក៏ឲ្យអ្នកអញ្ជើញទៅស្រុកកេងជាវិញ ដើម្បីនឹងជួយគ្នាធ្វើការពេជការ
ខ្ញុំកបំផុតផែនដីឲ្យតែបាន ។ ឲ្យតែកំនឹងបានជាង មិនបង់កម្លាំង
ដែលអ្នកបានរៀនចេះដឹងមកជាមួយគ្នា បើអ្នកទៅហើយមិនបានដួចនឹង
ខ្ញុំ កំឲ្យយកសំបុត្រនេះទៅបង្ហាញឲ្យតែចុះ ។ ចាំងថងកំឱ្យលតាក្យថា
ត្រមទៅ ។ ខុងបេងកំលាទៅស្រុកកេងជាវិញ ។

ឯឲ្យសុក កំដូនដំណើរសេតដាំយើទៅដល់ដំបន់ប៊ូគាវ ។ ស៊ុន-
គួនកំឲ្យចាត់ចែងគ្រឿងបរស់ទៅសែនសេតដាំយើ ហើយកំយំសោកចំពោះ
សេតដាំយើយ៉ាងខ្លាំង រួចបង្គាប់ពួកនាយទាហានឲ្យតែងការសេតដាំយើតាម

ឋណ្ណាស័ក្តិឋគ្គះខុកនៅត្រង់ស្រុកកំណើត ហើយយកដីវស៊ុន ដីវអ៊ុន កូនដីវយើងាំងពីរមកចិញ្ចឹមព្យាបាល ។

ថ្ងៃមួយ ព្រឿសុកបានយាយនឹងស៊ុនគួនថា ដែលលោកតាំងខ្លួនខ្ញុំជំនួសដីវយើនោះ ជាគុនធ្ងន់រកទិប៉ផុតគ្នាន តែតម្រេះប្រាជ្ញាវេស់ខ្ញុំតិចណាស់ មិនដឹងដល់ផ្លូវកែការ ខ្ញុំនឹងសុំទៅអញ្ជើញអ្នកមានតម្រេះប្រាជ្ញាម្នាក់ឈ្មោះចាំងឋង មកឲ្យទៅជួយធ្វើការលោក ឈ្មោះនេះនឹងខ្ញុំតិជាកេរ្តិ៍សម្ភាញ់នឹងគ្នាមកតាំដើម ចេះដឹងមើលសក្តណៈឫក្សការ ខាងលើគាកាសនឹងក្រោមផែនដី ដោយតម្រេះប្រាជ្ញាធ្វើវិទ្យាគណាស់ ចានរៀនវិជ្ជាសិល្បសាស្ត្រនេះគ្រូជាមួយនឹងខុងឋង សូមីខុងឋងនឹងដីវយើកំរមែងស្រឡាញ់កប់អាន, តាំដើមចាំងឋងនៅស្រុកសុងយ៉ុង ឥឡូវចូលមកនៅស្រុកយើង ។

ស៊ុនគួនឮព្រឿសុកនិយាយដូច្នោះ កំពេញចិត្តណាស់ថា: យើងបានឮឈ្មោះនេះមកយូរហើយ ចូរអ្នកឲ្យទៅអញ្ជើញចូលមកចុះ ។ ព្រឿសុកក៏ទៅអញ្ជើញចាំងឋងចូលទៅជួបនឹងស៊ុនគួន គំនាប់ហើយស៊ុនគួនក៏សំឡឹងមើលរូបភាពសក្តណៈចាំងឋង ឃើញចិញ្ចើមធំប្រមុះភ្នែង មុខខ្មៅ តុកចង្កាខ្លី រូបរៀបរាងកាលណាស់ ចិត្តមិនសូវត្រេកអរ ស៊ុនគួនក៏សួរថា តម្រេះដែលអ្នកបានរៀនចេះដឹងមកនោះ យកអ្វីជាគោលចាក ? ។ ចាំងឋងថា ដែលនឹងយកជាគោលចាកលើសជាង

ចាំដ៏អស់នោះ ក៏សុទ្ធតែជាការប្រមាណ លុះតែមានការមកដល់ ទើបគិតយើញតទៅ ។

ស៊ុនគួនសួរថា វិជ្ជាសិល្បៈសាស្ត្រដែលអ្នកសង្ឃឹតរៀនមកនោះ ហើយទំនឹតម្រេះដាំយើញប៉ុកគ្នាយ៉ាំងណា ? ។ ចាំដ៏ថដ៏ថា វិជ្ជាសិល្បៈសាស្ត្រដែលខ្ញុំរៀនមក ខុសគ្នាទំនឹតម្រេះដាំយើច្រើនណាស់ ។ ស៊ុនគួនឮដូច្នោះ ហេតុតែចិត្តទៅស្រឡាញ់អាល័យដាំយើច្រើន ក៏ស្តាប់មិនគេញចិត្ត ហើយប្រាប់ចាំដ៏ថដ៏ថា អញ្ជើញអ្នកចេញទៅសិនចុះ បើមានការអាសន្នទៅខាងមុខ សឹមឲ្យអញ្ជើញអ្នកមកជួយរិះគិតការនោះ។ ។ ចាំដ៏ថដ៏ឮដូច្នោះ ក៏ដកដង្ហើមធំ ហើយដើរចេញទៅវិញ ។

ខ្លោសុកយើញចាំដ៏ថដ៏ដើរចេញទៅ ក៏សួរស៊ុនគួនថា ហេតុម្តេចលោកមិនយកចាំដ៏ថដ៏ទុកធ្វើពជការផង ? ។ ស៊ុនគួនថា ខ្ញុំតិនិត្យមើលរូបកាយ មិនសមជាអ្នកមានតម្រេះប្រាជ្ញាសោះ ហើយនិយាយក្រអឺតក្រអោង បើទំនឹយកទុកក៏មិនយើញបានផលការអ្វី ។ ខ្លោសុកថា ត្រាកាលចូនួលើកទ័ពចូកមកច្បាំងនឹងស្រុកយើងតាំងថ្ងៃមុន ចាំដ៏ថដ៏បានទៅជួយដាំយើ ប្រើ១ចាយទៅបញ្ជោតចូនួ បានជាដាំយើដុតទ័ពចូនួស្លាប់ឥហានជាច្រើន ខ្ញុំយើញថា ចាំដ៏ថដ៏មានគុណគាប់ប្រសើណាស់ សូមឲ្យលោកត្រិះរិះគិតមើលសិន ។

ស៊ុនគួនថា ចូនួធ្វើការត្រាខោះ ត្រាះគំនិតចូនួខ្លួនឯង មិនមែនជា

គំនិតជាំនឹងថង់ទៅបញ្ហោតទេ ។ ខ្លាសុកទៅដួលទំនឹងជាំនឹងថង់ហើយថា ខ្ញុំ
ជាន់ដួយខ្នុកបំរុងអ្នកកំសត់ប៉ុណ្ណឹងហើយ ស៊ុនតួនមិនព្រមយកអ្នកទុក
ជាគ្នា ចូរអ្នកវង់ចាំស្តាប់ការបន្តិចទៅខ្លែតចុះ ។ ជាំនឹងថង់ឮខ្លាសុក
និយាយដូច្នោះ ក៏នេងជាក់មុខនឹកតូចចិត្ត មិនជានិយាយតបប្រការម្តង
ទេះតែដកដង្ហើមធំ ។ ខ្លាសុកថា ខ្ញុំឃើញកិរិយាអាការក្នុងខ្លួនអ្នក មុខជា
មិនចង់នៅក្នុងស្រុកតាំងតាំងហើយ អ្នកក៏មានវិជ្ជាសិល្បសាស្ត្រ ប្រកប
ដោយគម្រែះប្រាជ្ញាចូរពិគ្រោះតិចារណាមើលចុះ បើយើញថានឹងទៅ
ទាន់ទីណាជំបន់ណាស្រួល ក៏ចូរទៅនៅតាមអធ្យាស្រ័យអ្នកចុះ ។

ជាំនឹងថង់ឮដូច្នោះក៏ឆ្លើយថា ចិត្តរបស់ខ្ញុំចង់ទៅនៅនឹងបួន ។ ខ្លា-
សុកថា អ្នកមានគម្រែះប្រាជ្ញាក្លាហ៊ានដូចកែវដ៏ល្អពិសេស, បើអ្នកទៅនៅ
នឹងបួនទោះ ជាដួចជាទៅនៅក្នុងទីនឹងនឹត មិនគួរសមទេ សូមអ្នកទៅនៅ
ឯស្រុកកេងដ៏វែ នៅធ្វើការជាមួយខ្លាតាំញ នឹងមានប្រយោជន៍ចំណេញ
ដល់ខ្លួនអ្នក ។ ជាំនឹងថង់ថា សេចក្តីពិតក្នុងចិត្តខ្ញុំ ក៏គិតដូចអ្នកថា តែ
ដែលខ្ញុំថាទៅនៅនឹងបួនទោះ ហាក់នឹងចង់តាំសោធចិត្តអ្នកមើលទេតើ ។
ខ្លាសុកថា បើដូច្នោះសឹមខ្ញុំធ្វើសំបុត្រមួយទៅដល់ខ្លាតាំ ឲ្យអ្នកឡើ
ដួយខ្នុកបំរុងខ្លាតាំ ដើម្បីមិនឲ្យខ្លាតាំនឹងស៊ុនតួនចាំហ្វាយខ្ញុំជាហរិចិត្ត
តាំងសង្ឃាង ដួយរំលាងបំផ្លាញបួនទោះញ ។ ជាំនឹងថង់ថា គំនិតរបស់
អ្នកគិតនោះ ដួចជាគំនិតរបស់ខ្ញុំគិតដែរ សុំឲ្យអ្នកសរសេរសំបុត្រទៅចុះ

ខ្លោសុកកំសរសេរសំបុត្រឲ្យចាំងថង ។ ខ្លួលហើយក៏ទៅស្រុកកេងដើរ
បំផ្លិចផ្លិចចូលទៅជួយខ្លៅតិ ។

រំលោះនោះ ជួនជាខ្ទុះបេងមិនទៅ ចេញទៅដំរេះសេចក្តីរោះខុក
ក្រស្តែងទៃត្រចាំង ៤ ។ នាយក្ងារកំចូលទៅដំកបខ្លៅតិថា ចាំងថង
មកពីស្រុកគាំងតាំង មានការមកកេលោក ។ ខ្លៅតិដឹងចាំងថងមកក
ក៏និយាយថា ខ្ញុំឮល្បីគេនិយាយមកយូរហើយ តែមិនដែលជួបមុខសោះ,
ក៏ឲ្យនាយក្ងារអញ្ជើញចាំងថងចូលមក ។ ខណៈនោះ ចាំងថងក៏មិនបាន
គួរសមគំនាប់តាមប្រក្រតីឡើយ ។ ខ្លៅតិបានតិនិត្យមើលលក្ខណៈសត្វ
គ្រប់ កំយើញអាការៈជាទុចរិកឆិកាយ ក្នុងចិត្តពុំសូវត្រេកអរក៏កាយ ក៏
ក្លែងនិយាយថា អ្នកមកកេយើងពីស្រុកឆ្ងាយយើងក៏មិនទាន់ទាន់មានធុរៈ
អ្វីនឹងត្រូវការ ។

ចាំងថងយើញខ្លៅតិមិនសូវកក់ទាក់ទាប់ទាន កំពោមនស្សក្តួចចិត្ត
មិនយកសំបុត្រឲ្យខ្ទុះបេងនឹងខ្លោសុកបង្ហាញឲ្យខ្លៅតិឡើយ គ្រាន់
តែនិយាយថា ខ្ញុំឮល្បីថា មានឲ្យសំព្រះចៅហៀនតេនេះ រមែងបញ្ជាះ
បញ្ជូលមនុស្សដែលមានតម្រេះច្រើនថា ទឹងសេនាឥហានដែលមាន
ថ្លៃដែរទាំងតួកែណាស់ ខ្ញុំក៏ទស្សាហ៍ស្វះស្វែងមកកេ ។

(នៅមានត)

រឿងព្រះមហាសមុទ្រ

លោក ប៉ាយ-ប៊ុក្ក ប្រែរៀបរៀង

(តមក)

តែដោយមានព្រឹត្តិការណ៍ដូច្នោះ, ព្រះអង្គមិនអាចនឹងធ្វើព្រះរាជសមរសព្រះនាង នឹងព្រះរាជបុត្រស្តេចប្រទេសជិតៗបានឡើយ ។ ទ្រង់ឃើញថា គួរតែធ្វើព្រះរាជសមរសព្រះនាង នឹងព្រះរាជទេសព្រះមហាក្សត្រប្រទេសឆ្ងាយៗវិញបាន, ទ្រង់ចាត់អាមាត្យឲ្យធ្វើព្រះរាជសារតបទៅវិញថា: "បុត្រីយើងតូចក្រមុំហើយ, យើងអាចឲ្យបុត្រីយើងទៅជាទេពីព្រះរាជបុត្រព្រះអង្គបាន យើងនឹងត្រូវជាជន្មនឹងគ្នា, ប្រទេសយើងជាប់ងពីរ នឹងបានជាមិត្តជាមួយគ្នាយ៉ាងជិតស្និទ្ធ សូមស្តេចយាងមកយកបុត្រីខ្ញុំចុះ" ។

រឿងព្រះមហាក្សត្រចង់ធ្វើព្រះរាជសមរសនោះ សូមស្ទើរតែចុំណ្លេះសិន ។ លំដាប់តទៅ សូមតាំងអំពីព្រះអង្គម្ចាស់ដែលទ្រង់រង់ចាំព្រះនាងតែមួយព្រះអង្គនៅទីនោះ មិនឃើញព្រះនាងនិវត្តមកសោះ, ទ្រង់បានតិនិត្យទីកន្លែងដែលទ្រង់ប្រថាប់ គឺដាក់លខ្លាចរហាមនឹងចង លន្លង់លន្លោច មានផ្លូវខ្លាចដាច្រើនតាសតេញ, ឯព្រះអាទិត្យបញ្ចេញខ្លាំងហាយខ្លាំងពន់ពេក, ហើយនៅទីនោះ គ្មានស្មៅ ឬតំណាងតិដុះមួយសរសៃសោះឡើយ ។ ព្រះអង្គម្ចាស់ទ្រង់ស្រែកឃ្លានជាអនេក ទ្រង់

យាងទៅកេរឹក ដើម្បីទំនិះសោយ, តែខ្ញុំនោះគ្មានសោះ ។ ខ្ញុំបានឡើងទៅលើកំពូលភ្នំមួយខ្ពស់ ហើយចុះទៅម្ខាងស្មានថា មានដង្កៀព្រៃកំលោភ ដែលក្រឡេកមើលតាមផ្លូវទៅមានតាណិស្រស់ខៀវខ្ចី . . . . , ប៉ុន្តែ លុះយាងដល់កំពូលលើ ស្រាប់តែអើលផ្ទាតព្រះភ្នែកឃើញសោតចុះមកក្រោម ។ ភ្នំចន្ទោះហូរដូចជាទឹកកកហូរក្នុងទិវាយផ្លូវដូច្នោះ ។ កាលបើព្រះអង្គឆើបឡើង, ខ្ញុំបានឧតទៅឃើញខ្ទមមួយ មានផលាខុផលបរិបូណ៌ត្រប់យ៉ាង ។ ផលាខុផលនោះ មានតាណិក្រហមប្រលែងផ្អែមគួរឲ្យចង់សោយតាន់តែក, ខ្ញុំបានបេះផ្លែប៉ែសមួយសោយ ខ្ញុំយាងទៅផ្ទំក្រោមដើមឈើនោះហើយលក់ទៅ ដល់ខ្ញុំតើនចាកសយនា យកព្រះហត្ថស្ទាបព្រះកំក្រូ ខ្ញុំយល់ថា ព្រះកំក្រូសុទ្ធតែកេម ។ ព្រះអង្គឆ្ងល់តាន់តែក ខ្ញុំព្រះតម្រិះថា: មុនអញដេក អញគ្មានកេមទេ, ម្តេចមកមានកេមដូច្នេះ ? ហើយខ្ញុំយល់ថា "ហេតុដែលមានកេមនេះ ប្រហែលជាមកតាផ្លែប៉ែសនេះទេដឹង ! " ។ ដល់បន្តិចទៅខ្ញុំឃ្លានទៀត, ខ្ញុំមិនហ៊ានសោយផ្លែប៉ែសទេ, ខ្ញុំទំពាយាមត្រចៅកាន់ដើមតាមួយ, ខ្ញុំកំចាប់មែកនោះមកញាបន្ទាបចុះបេះផ្លែតានោះសោយហើយខ្ញុំកំផ្ទំលក់ទៅ ។ ដល់តើនតាក្រឡាព្រះបន្ទំស្រាប់តែមានស្នែងដុះចំព្រះសៀនើងកេមដុះដុំវិញផ្លែងំព្រះនស្ត, មានតុកចង្កាសរែង ។ ខ្ញុំមានព្រះបន្ទូលក្នុងព្រះហឫទ័យថា: "នរូបអញអកក្រកំណាស់ បើព្រះ

នាងយានវិលត្រឡប់មកជ្រោកដដាព្រះនាងវិលស្គាល់អញ ! ព្រះនាង, អស់សេចក្តីស្នេហាមកលើខ្លួនអញ, អញអស់សង្ឃឹមហើយ ចុះជាសំណាងអាក្រក់ណាស់តើ ! កំព្រែនព្រះកន្សែងហូរទឹកព្រះនេត្រស្រោចស្រប់ព្រះកំត្រុង ហើយព្រែនផ្ទួលក់ទៅ. ស្រាប់តែព្រែនព្រះសុបិនឧទ្ទិមិត្ត ឃើញតាបស់ម្នាក់យកដៃមកបបោសអង្អែលព្រះសិរ ហើយក្រាបបង្គំទូលថា: "ព្រះអង្គ, ម្តេចក៏ព្រែនព្រួយព្រះហឫទ័យខ្លាំងម្ល៉េះ ? "

ព្រលឹងនៃព្រះអង្គម្ចាស់ ព្រែនមានព្រះបន្ទូលទៅកាន់តាបស់អំពីព្រឹត្តិការណ៍ដែលមានមកចំពោះព្រះរូបព្រះអង្គ ។ តាបស់ក៏ក្រាបបង្គំទូលថា: "សូមព្រះអង្គកុំព្រួយព្រះហឫទ័យសោះឡើយ សូមព្រែនរើសផ្លែតាឧដ្ឋិតផ្លែប៉ែសដែលមានសភាពក្រៀម ដែលជ្រុះក្រោមក្តួជាតិតាំងនោះ, សូមព្រែនសោយផ្លែឈើតាំងនោះ, ពុកចង្កាឧដ្ឋិតស្នែងដែលជ្រុះនោះឧដ្ឋិតរលត់រលាយជ្រុះជាត់ សូមព្រែនកុំគង់ប្រថាប់នៅទីនេះ, សូមស្តេចយាងឆ្ងាយ, ពីព្រោះព្រះអង្គគង់នៅក្នុងទីឧទ្យានៃអ្នកតាយក្សតាំងពួយ ពេលនេះព្រះអង្គព្រែនកំពុងផ្ទួ, ដល់ព្រែនភ្ញើតចាកព្រះសយនា, ហើយគង់នៅតាមៗគ្នា ឧដ្ឋិតមិនមាន ! " ។

ព្រលឹងនៃព្រះអង្គម្ចាស់ លុះព្រែនព្រះសណ្តាប់ខ្លួរឿងនេះហើយ, មានព្រះហឫទ័យតក់ស្លុតជាខ្លាំង, ព្រែនភ្ញាក់ពីនិទ្រាឡើង, ព្រែនគង់នៅតែមួយព្រះអង្គឯងក្នុងទីនោះ ។ ព្រះចន្ទ្រចាលរស្មីភ្លឺត្រចះត្រចង់

កណ្តាលរមយា , ព្រះភាយនាយផាត់បក់មកយ៉ាងត្រជាក់ ; កលខ្ញុំចាំ
រហាហានក៏គ្មានចំហាយក្តៅខ្ទឹងទួលហុយសោះឡើយ ។ ក្នុងគេលនោះ,
ព្រះអង្គម្ចាស់ ទ្រង់ប្រញាប់ប្រញាល់យាងចេញពីកន្លែងអភមង្គលនោះ
តាមភាក្យដំបូន្មានរបស់តាបស ។ ទ្រង់ឧទានឃើញផ្ទៃបៃសនិងផ្ទៃព័ទ្ធដែល
ជ្រុះកត់កយក្រោមរុក្ខជាតិ ដែលមានសភាពក្រៀមស្វិតហើយ ទ្រង់
សោយទុក្ខផ្ទៃឈើពាំងនោះ ។ ក្នុងមួយរំពេច ពុកចង្កាមិនស្មើនឹងក្រដូរ
ភ្លាក់ចាត់អស់គ្នាទាល់ ។ ព្រះអង្គម្ចាស់ទ្រង់ព្រះតម្រិះមួយស្របក់
រួចទ្រង់កាច់មែកឈើស្ងួត (ស្រល់) ត្រង់ជាល្អិមួយ ហើយទ្រង់ប្រមូល
ផ្ទៃបៃសនិងផ្ទៃព័ទ្ធដែលមានសភាពក្រៀម និងផ្ទៃដែលកំពុងមានទឹកដម
ផ្អែមធ្លាញ់ជាក់ក្នុងល្អីនោះ ។ រួចទ្រង់ចាកចេញពីទន្លាននោះទៅដោយ
ប្រញាប់ប្រញាល់ជាខ្លាំង ។ ទ្រង់មានបំណងចង់និវត្តទៅកាន់មាតុភូមិ
វិញ, តែវង្សនិមន្តជ្រាបផ្លូវសោះ ទ្រង់ចេះតែយាងទៅជាលំដាប់ ។ ទ្រង់
បានធ្វើព្រះដំណើរច្រើនពីរថ្ងៃច្រើនពីរយប់ ទៅកន្លងកលខ្ញុំចាំរហាហាន ,
ទ្រង់មិនបានជួបប្រទះនឹងមនុស្សសត្វអ្វីសោះឡើយ ។ តមកទ្រង់មាន
សេចក្តីស្រេកឃ្លានជាខ្លាំង បានសោយផ្ទៃព័ទ្ធនិងផ្ទៃបៃសក្រៀមនោះ
ទៅ ។ លុះខឿយព្រះកាយតល, ក៏ផ្ទំនៅលើផ្ទៃខ្ញុំចាំលក់ខ្មៅ លុះ
តើនឡើងចាប់បន្តព្រះដំណើរតទៅទៀត បានយាងទៅដល់ថ្នល់ធំមួយ

ផុតពីគ្រោះថ្នាក់នោះ ហើយគង់នៅលើចង្កើមថ្នល់ ដើម្បីសម្រាក
ព្រះកាយ ។

ក្រោយមកបន្តិច មានមនុស្សម្នាក់ដឹកលាមួយដើរមកដល់ទីនោះ ។
ព្រះអង្គម្ចាស់ទ្រង់មានបន្ទូលសួរតាមានផ្សែង ។ ពីអ្នកដឹកលា ។ ក៏ក្រាប
បង្គំទូលថា បើព្រះអង្គចង់ធ្វើព្រះដំណើរទៅកាន់មាតុភូមិ សូមស្តេចយាង
ទៅកាន់ទិសខាងកើត ។ បើមានព្រះរាជបំណងចង់ជួបនឹងព្រះអង្គម្ចាស់
ក្សត្រីសូមស្តេចយាងទៅទិសខាងលិច ។ គ្រានោះ ព្រះអង្គម្ចាស់ទ្រង់មាន
ព្រះតម្រិះថា "អញចង់ឃើញព្រះអង្គម្ចាស់ក្សត្រីនឹងសេះឈើ អញ
មិនត្រូវត្រឡប់ទៅកាន់ព្រៃនិវេសន៍វិញទេ គួរតែធ្វើដំណើរទៅកាន់ទិស
ខាងលិច ដើម្បីឲ្យបានជួបនឹងព្រះអង្គម្ចាស់ក្សត្រីនឹងសេះឈើ" ។

លុះទ្រង់យាងទៅបន្តិច ទ្រង់បានឮសូរសត្វដូចជាដើងសេះរណ្តំ
លើថ្នល់ពីក្រោយព្រះអង្គ លុះទ្រង់ឈ្នៀងព្រះនេត្រទៅ, បានឃើញ
ភួករាយជាមួយក្រុមដំរីសេះតាក់ត្រឿងដែក ហើយស្រែកយ៉ាងខ្លាំង
ព្រមទាំងមានឫកពាដ៏ខៃឆ្វៃឆន ។

(នៅមានត)

ប្រកាសប្រឡងប្រជែងធំៗនៀមទម្លាប់ខ្មែរ

ក្នុងធម្មាសទី ២ ឆ្នាំ ១៩៦២

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅក្នុងសាលនបណ្ឌិត្យ ក្រុងភ្នំពេញ ត្រូវការជ្រើសរើសយកឯកសារធំៗនៀមទម្លាប់ខ្មែរ ដោយបើកការប្រឡងប្រជែង ២ មុខ គឺ :

១- អំពីទឹក

២- អំពីពពិល

វិញ្ញាសាប្រឡងនេះ សម្រេចយកនៅធម្មាសទី ២ គឺតាំងពីខែកក្កដា ដល់ខែធ្នូ ឆ្នាំ ១៩៦២

ដូច្នេះ អស់លោកអ្នកចេះដឹងតាំងពីក្មេង ជាស្ត្រី ឬបុរស ឬជាបព្វជិត ដែលស្ម័គ្រចិត្តប្រឡង សូមសរសេរតែងវិញ្ញាសា ស្តីអំពីទឹក ឬអំពីពពិល តាមគោលបញ្ញាដូចរៀបរាប់ខាងមុខ ឲ្យការណ៍ទៅក្រុមជំនុំទំនៀមទម្លាប់ខ្មែរ យ៉ាងយូរបំផុតត្រឹមថ្ងៃដាច់ខែធ្នូ ឆ្នាំ ១៩៦២ ។

ការប្រឡងប្រជែងនេះ មានរង្វាន់ ៤ ផ្នាក់

- រង្វាន់លេខ ១ ... ៣០០រ០០
- រង្វាន់លេខ ២ ... ៥០០រ០០
- រង្វាន់លេខ ៣ ... ៤០០រ០០
- រង្វាន់លេខ ៤ ... ២០០រ០០

បណ្តាវិញ្ញាសាចំនួន ២ មុខនេះ បើចេកូដនមួយរូបស្ម័គ្រចិត្តធ្វើជាក់ប្រឡងចំនួន ២ មុខហើយបានល្អចំនួន ២ មុខ អាចបានវិញ្ញាប័នចំនួន ២ មុខតែបើត្រូវការជាក់ប្រឡងចំនួន ២ មុខ សូមធ្វើ ១ មុខ ។ ដោយឡែកពីគ្នា គឺសូមសរសេរលើសៀវភៅសរសេរចុះឈ្មោះតាមសេចក្តីខ្វី ឬធុនក្រាស់តាមសេចក្តីរៀង ហើយសូមសរសេរនាម នាមត្រកូលនៅរបស់ខ្លួន ឲ្យច្បាស់លាស់លើក្រដាស ១ សន្លឹកផ្សេងដាក់ក្នុងស្រោមសំបុត្រជាមួយនឹងវិញ្ញាសានោះ ។ រួចយកទៅឲ្យផ្ទាល់ខ្លួនក៏បាន ផ្ញើតាមប៉ុស្តិ៍ទៅក៏បាន យកទៅដូនសាលាឃុំ សាលាស្រុក ឬរៃត្រ សុំឲ្យផ្ញើឲ្យក៏បាន ដោយភា្ជប់នឹងសំបុត្រថា :

ពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ
(ផ្នែកក្រមជំនុំទំនៀមទម្លាប់ខ្មែរ)

គោលបញ្ជានៃការប្រឡងប្រជែង

១- អំពីធីកា

ទីតាំងវត្តចាំបាច់មួយ ដល់វត្តធាតុចាំនួនមានដីវត្ត ចាំនួនដីវត្ត ។

ខ្មែរយើងមានដំណើរ ទឹងចំណែមផ្សេង ច្រើនណាស់ ដែលទាក់ទងដោយ
ទឹក ។ នៅទាំងក្រោមនេះ ក្រុមដំណើរសូមជូនទុកជាការណែនាំខ្លះដល់បេក្ខជន
ដែលចូលចិត្តសរសេរតែងទៅជាក់ប្រឡងប្រជែង ប៉ុន្តែបេក្ខជនអាច
សរសេរការដែលទាក់ទងដោយទឹក ក្រៅអំពីទុកជាការណែនាំទាំងនេះបាន
តាមការដែលអស់លោកចេះដឹង ។

ទឹកសន្សើមធឹងទឹកភ្លៀង.- តាមចំណែមខ្មែរយើង ទឹកទាំងពីរ
យ៉ាងនេះ តើតណ្តើងរបៀបដូចម្តេច ? ភ្លៀងមានប៉ុន្មានយ៉ាង ? អាចំណែត
របស់ភ្លៀងឈ្មោះអ្វីខ្លះ ? ការប្រើប្រាស់ទឹកសន្សើម, ចំណែម ទឹងពាក្យ
ស្មោកផ្សេង ។ ទាក់ទងដោយទឹកសន្សើមទឹងទឹកភ្លៀង ?

ទឹកធឹងព្រះបន្ទូ .- នៅគេលសំពះព្រះវៃ ខ្មែរយើងនៅជនបទ
ក្រៅ ច្រើនតែធ្វើពិធីសម្រក់ទៀនទាយទឹកភ្លៀងក្នុងឆ្នាំទីមួយ ។ ។ កិច្ច
នេះបង្ហាញឲ្យយើញថា ជនជាតិខ្មែរចាប់ចំឲ្យមានការទាក់ទងរវាងព្រះចន្ទ
ទឹងទឹកដែរ ។ តើលោកអ្នកជ្រាបរឿងពាក្យ, ពាក្យសុភាសិត ឬពាក្យ
ស្មោកអ្វី ឬក៏ចំណែមបុរាណអ្វីដែលទិយាយពីព្រះចន្ទទឹងទឹក មានការ
ទាក់ទងគ្នាតាំងពីព្រេងទាយមកទេ ?

ទឹកក្នុងទំនៀមផ្សែង ។- របៀបធ្វើនំនប្រើទឹកប្រសិទ្ធភាព ? ការស្រោចថ្នាំប្រសប់ត្រង់ទឹកនេះនៅពេលធ្វើពិធីផ្សែង ។ ដូចជាការស្រោចទឹក ? ការប្រើទឹកក្នុងមន្តអាគម ?

ទឹកជ្រោះ - ដំខឿ ទំនៀម នឹងការប្រើប្រាស់ទឹកនេះ ។

អ្អូរ- ព្រែក- ស្ទឹង, ទន្លេ, សមុទ្រ, បឹង, ស្រះ :- សូមលោកអ្នកប្រឡងគតិប្បាយអំពីអត្ថន័យនៃពាក្យបទ (ផ្លូវទឹក) ទាំងនេះ ព្រមទាំងសភាពដែលមានផ្នែកគ្នា ។បបមាថា· ម្តេចហៅអ្អូរ ? ម្តេចហៅព្រែក ? ម្តេចហៅស្ទឹង ? ម្តេចហៅទន្លេ ? ពាក្យបទទាំងនេះ មានសភាពខុសគ្នាម្តេចខ្លះ ទើបគេអាចស្គាល់ថានេះជាអ្អូរ នេះជាព្រែក នេះជាស្ទឹង នេះជាទន្លេ . . . បាន ? លោកអ្នកជ្រាបរឿងរ៉ាវអ្វីខ្លះនឹងពាក្យបទដែលលោកអ្នកស្គាល់នោះទេ ? លោកអ្នកស្គាល់ច្បាស់ ទន្លេ បាកយណ៌ ស្រះកន្ទែងទឹកធ្លាក់ រូងថ្ម ជ្រោះ ទឹកច្រាល់ ។ល។ ដែលមនុស្សចូលចិត្តទៅធ្វើជាបូជនីយដ្ឋានក៏ប្រាកដ ? បើស្គាល់សូមអធិប្បាយ ។ នៅបច្ចុប្បន្នកាលនេះ តើគេនៅគោរពទំនៀមផ្សែង ។ ឬទេ ក្នុងការសង់ផ្ទះកសាងភូមិថ្មី ដែលនៅជិតកន្ទែងមានទឹកស្រក់ស្រោច ឬទឹកទន្លេ ស្ទឹង បឹង ។ល។ នៅពេលដែលគេខឹងជីកស្រះ ឬអណ្តូង តើគេធ្វើពិធីនឹងមើលភាពជាដូចម្តេចខ្លះ ? ចុះបើគេត្រូវលើកការចាំង ឬចំនប់ទឹក តើមានទំនៀមធ្វើដូចម្តេចខ្លះ ?

គ្រោះថ្នាក់ដោយផ្លូវទឹក.- បើគេត្រូវការធ្វើដំណើរតាមផ្លូវទឹក តើមានដំនឿអ្វីខ្លះ ? ការប្រតិបត្តិយ៉ាងណាខ្លះដែលទាក់ទងដោយការពន្រ្គោះតាមផ្លូវទឹកនោះ ? បើប្រសិនជាមានមនុស្សលង់ទឹក តើគេត្រូវធ្វើដូចម្តេចដើម្បីជួយឲ្យគេរួចតាំពុក ? បើយើងទៅក្នុងព្រៃហើយទឹកធ្វើឲ្យមានគ្រោះថ្នាក់ តើមានតិចដូចម្តេចខ្លះ ? (ដូចទឹកដែលមានជាតិតុលដោយមានស្មៅក្តាផ្ទៃឈើតុលជ្រុះគ្រាំទៅ បរិភោគមិនបាន) តើមានវិធីអ្វីដើម្បីបន្សាបជាតិតុលឲ្យទឹកនោះទៅជាទឹកបរិភោគបានឬទេ ?

កន្លែងធ្វើអំបិល ឬស្រែអំបិល.- ក្រុមដំទុំគ្មានឯកសារមួយនិយាយអំពីរឿងស្រែអំបិលសោះ ការធ្វើអំបិលមានវិធីបែបយ៉ាងណាខ្លះ ? តើមានចំនៀម ឬគ្រឿងអ្វីខ្លះទាក់ទងដោយការធ្វើអំបិលនេះ ?

ប្រដាប់ប្រើប្រាស់បុរាណដែលប្រើដោយទឹក.- ដូចជារហាត់ទឹក ស្នាច . . . ។ ល ។ សូមអធិប្បាយអំពីវិធីបែបធ្វើ វិធីបែបប្រើ នឹងដំនឿផ្សេង ។ ទាក់ទងដោយវិធីរបស់ទាំងនោះ ។ ក្នុងរឿងនេះលោកអ្នកប្រឡងចង់សរសេរតែងអំពីអ្វីក៏បាន ឲ្យតែជារបស់ប្រើដោយទឹក ពោះជាប្រដាប់ដាក់ទឹក តម្រង់ទឹក ។ ល ។ ក៏បានទាំងអស់ ។

អាទិទេព ឆ្នឹងសត្វអស្ចារ្យទាក់ទងដោយទឹក .- សូមអធិប្បាយអំពីរឿងនាគ ឬសត្វអ្វីដែលខ្មែរយើងតែងនិយាយថាជាអ្នកបណ្តាល

ឲ្យមានភ្លៀង ឬឲ្យមានខ្យល់ ។ សូមអធិប្បាយអំពីពាក្យ អំពីរឿងព្រេងនិងអំពីចំនៀមផង្សែង ? ដែលគេតែងធ្វើនៅគេលមានភ្លៀង ឬមានខ្យល់ ។ ចំណែករឿងកាំនភ្លៀងវិញ ខ្មែរយើងក៏មានដំនៀងដែរ តើហេតុអ្វីដែលបណ្តាលឲ្យកាំនភ្លៀង ?

សត្វដែលរស់នៅក្នុងទឹក.- ការរាប់ឈ្មោះសត្វខ្យងខេ គ្មានសេចក្តីអធិប្បាយ មិនមែនត្រូវចំណង់របស់ក្រុមដំនុំខេ ។ ហេតុនេះក្រុមដំនុំត្រូវការឲ្យលោកអ្នកប្រឡងអធិប្បាយអំពីចំនៀមខម្ងាប់ ដំនៀងចំណាំផង្សែង ។ ពាក់ព័ន្ធដោយសត្វខ្យង ។

លោកអ្នកជ្រាបខេតើរឿងបុរាណដែលមានដំណាលថាសត្វនេះ រស់ជានតែក្នុងទឹក សត្វនោះរស់ជានតែលើគោក សត្វនោះខៀតរស់ជានតាំនក្នុងទឹកតាំនលើគោក មានសត្វខ្លះចេះហែលហើយមុជទឹកតូចផង ? តើអស់លោកអ្នកជ្រាបរឿងព្រេង ចំនៀម ដំនៀង ពាក្យស្មោកផង្សែង ។ ទាំងគ្រប់មាត់ពាក់ព័ន្ធដោយសត្វខ្យងដែរឬទេ ?

ទឹកនៅក្នុងខ្លួនមនុស្ស ធាតុខ្លួនសត្វ.- ទឹកភ្នោះ, ទឹកដោះ, ឈាម, ភ្លើស, ទឹកភ្នែក . . . ទាំងទឹកដទៃទៀត ដូចជាទឹកឃ្មុំ ។ ល ។ ប្រសៃណា ស្តីអំពីការបង្កបង្កើតទឹកនោះនៅក្នុងខ្លួនមនុស្សយើង ទាំងអំពីការប្រើទឹកនោះក្នុងការជាក់ស្តែង, ក្នុងការធម្មតា ព្រមទាំងក្នុងមន្តអាគម ?

ទឹកនៅក្នុងដើមឈើ.- សូមអធិប្បាយអំពីទំនៀម អំពីការស្មោកអំពីជំនឿផ្សេង ។ ទំនងអំពីការប្រើប្រាស់ទឹកនេះក្នុងទុស៥, ក្នុងមន្ត អាគមគោះជាដ៍ក្តៅ ជាអ្វីក្តៅ ។

២-អំពីតន្ត្រី

ក្នុងទំនៀមរបៀបយើង តន្ត្រីលតន្ត្រី ជាមន្ត្រីលមួយធំណាស់ ជាន ជាក្រុមដ៏ខ្ពស់ជាន់ខ្ពស់ជាន សេចក្តីអធិប្បាយឲ្យជានសព្វគ្រប់ ។ ការណ៍ដែលក្រុមដ៏ខ្ពស់ត្រូវការនោះដូចមានជួនជាលំនាំខ្លះតទៅនេះ ៖

១- ដើមកំណើតតន្ត្រី និងការតំណាងរបស់តន្ត្រី.-

២- របាំ និងក្បាច់របាំលើតន្ត្រី.-

បើគ្មានតន្ត្រី តើគេអាចយកអ្វីជាជំនួសជានឬទេ បើគេត្រូវតែធ្វើ ជានមិនជាន ? តន្ត្រីលមានក្បាច់ផ្សេង ។ តើមានទំនៀមទម្លាប់ថាតន្ត្រីលរូបនេះត្រូវប្រើក្នុងពិធីនេះ ក្បាច់នោះត្រូវប្រើក្នុងពិធីនោះឬទេ ? តើតន្ត្រីលមានក្បាច់ដូចម្តេចនៅក្នុងស្រុករបស់លោកអ្នក ? លោកជ្រាបទេ នៅស្រុកនៅឃុំឯទៀតមានខុសគ្នាដូចម្តេចខ្លះ ? បើនៅក្នុងគ្រួសារណាមានតន្ត្រីលតើគេមានទំនៀម ឬត្រូវណាមួយ ចំពោះបុរសនោះឬទេ ?

ទៀនសម្រាប់ប្រើជាមួយតន្ត្រី .- ទៀននោះដូចម្តេច ? ប៉ុណ្ណា ? មានអំបោះប៉ុន្មានសរសៃជាប្រនេះ ? ត្រូវមានទម្ងន់ប៉ុន្មានដង្គីឆ

សម្រាប់ពិធីអ្វី ? ប៉ុន្មានខែទៀតសម្រាប់ពិធីដែរ ?

គេធ្វើពិធីបង្វិលពពិលនៅពេលណា ? ពិធីអ្វីខ្លះដែលគេត្រូវបង្វិលពពិល ? គេធ្វើពិធីនេះនៅគេលណា ? (ដូចក្នុងអាវហាវ៉ាហាមង្គលគេធ្វើនៅគេលថ្ងៃមត្រីកបន្ថែយពិធី) សូមអស់លោកអ្នកប្រឡងអធិប្បាយឲ្យច្បាស់ ប៉ើជាធ្វើជាមួយនឹងពិធីហៅត្រលឹង តើគេធ្វើក្រោយ ឬធ្វើមុន ? ប៉ើនៅគេលចងដែរ តើធ្វើមុនឬក្រោយចងដែរ ? ។ល។

ពិធីបង្វិលពពិលធ្វើដូចម្តេច ? ចំនួនមនុស្សប៉ុន្មានគាត់ដែលត្រូវធ្វើ ទឹងគុណសម្បត្តិមនុស្សដូចម្តេចដែលត្រូវរើសឲ្យធ្វើពិធីនេះ ? ចំនួនពពិលប៉ុន្មានដែលត្រូវប្រើ ? គេហុចពពិលពីម្ខាក់ទៅម្ខាក់ដូចម្តេច ? ខ្នួលដែរណា កាន់ដែរណា ចក់ផ្សែងដែរណា ផាត់ផ្សែងទៅខាងណា ? គេបង្វិលប៉ុន្មានដុំ ? តន្ទុតក្តៅពពិលដូចម្តេច ? គេសួត្រធម៌អ្វីខ្លះនៅពេលនោះ ? ពពិលត្រូវបង្វិលពីខាងណាទៅខាងណា ? មនុស្សរស់គេបង្វិលពីខាងណាទៅខាងណា ? មនុស្សស្លាប់ពីខាងណាទៅណា ?

មនុស្សដែលគេត្រូវធ្វើពិធីបង្វិលពពិលទៀនោះ ត្រូវអង្គុយដូចម្តេច ? អ្នកបង្វិលត្រូវអង្គុយដូចម្តេច ? មានសំណែនអ្វីខ្លះ ? សំណែនពាំងនោះមានរបៀបដូចម្តេចខ្លះ ? ខៅតុកាសដែលគេមិនធ្វើពិធីនេះនៅជុំវិញមនុស្សខ្លះ ពីដូចជានៅគេលបាត់ស៊ីមាជាដើម តើពិធីនេះគេធ្វើដូចជាធ្វើចំពោះមនុស្សដែរឬដូចម្តេច ?

ដើម្បីឲ្យរំលោភសាមានគំស្តុតាង ក្រុមដំនុំសូមឲ្យអស់លោកអ្នកតែងបញ្ជាក់ដើមកំណើតនៃការណ៍ដែលលោកសរសេរតែងនោះ ថាបានដឹងពីអ្នកណា ? ឈ្មោះអ្វី ? ធ្វើការអស៊ីអ្វី ? នៅស្រុកភូមិណា ? តួនសម័យបច្ចុប្បន្ននេះបានដឹងដោយបានឃើញគេ ឬឮបាប់បានធ្វើផ្លាស់ខ្លួន ? បើមានតិចណាដែលគេលែងធ្វើទៀហើយក៏សូមច្រាប់ផង កុំភ្លេច ។

ជាធម្មតាក្រុមដំនុំ បានសង្កេតឃើញអស់លោកអ្នកប្រឡង ច្រើនសរសេរតែងសង្ខេបពេក លេបបាត់ការសំខាន់ ដែលក្រុមដំនុំត្រូវការអស់សូមលោកអ្នកកុំខ្ជាប់ខ្ជួនឲ្យសោះ សូមធ្វើឲ្យអស់សេចក្តី ព្រោះបើការដែលលោកតែងខោះជាការចាំបាច់ ការរឿបាប់ច្បាស់ ។ ធ្វើឲ្យក្រុមដំនុំរកការច្រើនពុំឃើញ ។ ហេតុនេះ សូមអធិប្បាយៗមួយៗ ឲ្យសព្វគ្រប់តាមដែលលោកចេះចាំ ។

ជាពិសេស ក្រុមដំនុំសូមដាបលោកអ្នកស្ម័គ្រចិត្តប្រឡងថា មុនទីឯតែង សូមពិនិត្យមើលពាក្យសូរបស់យើងឲ្យមែនទែន ដើម្បីកុំឲ្យឃ្លាតសេចក្តីគ្នា បើមានការអ្វីដែលអស់លោកនៅឆ្ងល់ សូមសរសេរទៅសួរក្រុមដំនុំ ។ ទីឯធ្វើយប់ក្តីសេចក្តីជូនតាមបំណង ។

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

ពិធីបុណ្យវិសាខបូជា នៅមុខព្រះសក្យមុនីបេតិយ

លោក ជ ង . វង់ រៀបរៀង

ប្រទេសកម្ពុជា ក្រោមការដឹកនាំនៃសម្តេចព្រះប្រមុខរដ្ឋ ជាព្រះអគ្គ-ពុទ្ធសាសនូបត្ថម្ភក៍ ទឹងក្រោមព្រះរាជូបត្ថម្ភនៃព្រះរាជឋល្ងីឆ្ក អស់កាលជាច្រើនសតវត្សមកហើយ ដែលក្នុងរជ្ជកាលនេះ មានសម្តេចព្រះមហា-ក្សត្រិយានីជាអម្ចាស់ដ៏វិសេសលើស្ថានជាទំមិត្តរូប ទ្រង់បានគាន់ព្រះពុទ្ធសា-សនាយ៉ាងខ្លាប់ខ្ជួន ដើម្បីប្រយោជន៍ដល់ការទ្រទ្រង់ជាតិ ឲ្យបានបិត នៅក្នុងសភាពក្សេមក្សាន្តខាងផ្លូវកាយនិងផ្លូវចិត្ត ។

ព្រះសមណៈគោតមបរមគ្រូ ទ្រង់បរិនិព្វានទៅបាន ២៥០៩ ឆ្នាំ ហើយ ប៉ុន្តែសាសនធម៌របស់ព្រះអង្គបានបិតនៅរហូតសព្វថ្ងៃ ។ ព្រោះ ហេតុដូច្នោះ បានជាជាតិខ្មែរ ៩៨ ភាគរយ ក្នុងប្រទេសកម្ពុជាចាំងមួល លុះដល់ថ្ងៃ ១៥ កើតខែវិសាខនៃឆ្នាំទីមួយៗ រមងគុបតែងត្រៀងសក្ការ-បូជាអុជប្រទីបជ្វាលា គ្រប់ផ្ទះគ្រប់វត្តអារាម ធ្វើបុណ្យរំលឹកដល់ថ្ងៃដែល ព្រះបរមគ្រូទ្រង់ប្រសូត ទ្រង់ត្រាស់ដឹង ទឹងទ្រង់បរិនិព្វាន ។

ជាតិសេស នៅកជាទីគួរគេញ ក្រោមព្រះបរមរាជូបត្ថម្ភដ៏ខ្ពង់ខ្ពស់ នៃសម្តេចព្រះមហាក្សត្រិយានី ព្រះមាតាជាតិ ទឹងសម្តេចព្រះប្រមុខរដ្ឋ

ព្រះបិតាជាតិ, ពជរដ្ឋាតិឃ្លាសបានរៀបចំយ៉ាងខ្លះតែទៅតាមធម្មតាវិសាខបូជា នៅព្រះសក្យមុនីចេតិយត្រង់មុខស្ថានីយពជអយស្ម័យយានដែលតែងតែធ្វើជារៀងរាល់ឆ្នាំមក ដោយកិច្ចចាត់ចែងនៃភ្នំក្នុកសមាគមទាំង ៣ កន្លែងការទុបត្ថម្ភរបស់ក្រសួងធម្មការ ។

នៅវេលាម៉ោង ៩ ទីង ៣០ នាទីល្ងាច នៃថ្ងៃ ១៥ កើត ខែវិសាខ ព.ស. ២៥០៥ (១៨-៥-៦២) មានការជួបជុំព្រះសង្ឃចំនួន ៨០ អង្គ ដែលមានសម្តេចព្រះសង្ឃនាយកទាំងពីរគណៈជាប្រធាន ព្រះពជវង្សាខុវង្ស ប្រធាននៃសភាទាំងពីរ សមាជិកពជរដ្ឋាភិបាល សមាជិកនៃសភាទាំងពីរ ប្រធាននៃភ្នំក្នុកសមាគមទាំង ៣ មន្ត្រីត្រួតដំណែងទាំងពាហានទាំងស៊ីវិល លោកស្រី-យុវជនពជសង្គមនិយមខ្មែរ . សិស្សានុសិស្សប្រុសស្រី ព្រមទាំងភ្ញៀវបរទេសជាច្រើន បាននិមន្ត ស្តេចយាង អញ្ជើញមកដើម្បីរួបរួមក្នុងពិធីបុណ្យវិសាខបូជានេះ ។

នៅវេលាម៉ោង ៦ តត់ សម្តេចព្រះប្រមុខរដ្ឋព្រះបិតាជាតិ ជាព្រះពជតំណាងដ៏ខ្ពង់ខ្ពស់នៃសម្តេចព្រះមហាក្សត្រិយានីជាទីគោរព ទីធ្ងន់ជាទីស្នេហាស៊ីដាច់ ដោយមានសមាជិកពជរដ្ឋាភិបាល ទីធ្ងន់ព្រះពជបរិពារផ្លាល់ជាច្រើនអមដង បានស្តេចយាងដល់មុខព្រះសក្យមុនីចេតិយ ដោយបានទទួលការកិច្ចយ៉ាងខ្ពង់ខ្ពស់អំពីក្រុមពាហានក្សត្រព្រះអង្គ កន្លងយោធ-

ពលរទេមរភូមិទូចាំង ៣ ផ្ទៃក ទីឯក្រុមតន្ត្រីព្រះរាជទ្រព្យ ចានបង្ហូរវិបទ
ភ្លេងចរលើលា ទីឯភ្លេងជាតិថ្វាយជាព្រះរាជកិត្តិយសចំពោះព្រះអង្គ ។
បន្ទាប់មក ព្រះអង្គចានស្តេចយាងចូលគាន់ព្រះពន្ធាតាសេសថ្វាយបង្គំព្រះ-
សង្ឃ ដែលមានសម្តេចព្រះសង្ឃនាយករាំងពីរគណៈជាប្រធាន ហើយ
ព្រះអង្គទ្រង់ចានទទួលការក្រាបថ្វាយបង្គំអំពីឥស្សរជនចាំងឡាយ ដែល
រង់ចាំក្រាបថ្វាយបង្គំតាល់នៅទីនោះ ។

តមក មានធ្វើពិធីគោរពទង់ជាតិទីឯទង់ពុទ្ធសាសនា ដោយក្រុម
តន្ត្រីព្រះរាជទ្រព្យ ចានបង្ហូរវិបទភ្លេងនគរាជទីឯបទសរភញ្ញ ព្រមចាំង
មានក្រុមសិស្សប្រុសស្រី ចានច្រៀងនូវបទនគរាជ ទីឯថ្វាយបទសរភញ្ញ
កំដរការគោរពនេះផង ។ បន្ទាប់មក សហជីវិន ចន្ទ-សុន នាយករា-
រិយាល័យក្រសួងធម្មការ ជាតំណាងព្រះរាជរដ្ឋាភិបាល ទីឯពុទ្ធបរិស័ទ
ចាំងអស់ ចានថ្លែងសុន្ទរកថាមួយ សំដែងសេចក្តីគោរពចំពោះព្រះបរម-
សារីរិកធាតុ ក្នុងព្រះសព្វមុនីចេតិយ ដែលមានអត្ថន័យគោរពដ៏ជ្រាលជ្រៅ
ជាអនេតប្បការ ។ ក្រោយពេលចប់សុន្ទរកថា មានធ្វើពិធីនមស្ការ
ជាទម្លាប់ រំលឹកចំពោះព្រះគុណព្រះបរមគ្រូជាអម្ចាស់ ដែលទ្រង់បរិ-
និព្វានកន្លងទៅហើយ ដោយលោក ឈឹម-ស៊ីមង់ សាស្ត្រាចារ្យនៅ
ភូមិវិទ្យាល័យព្រះសុពម្រិត ជាអាចារ្យសូត្រនាំមុខ ។

បន្ទាប់មក សម្តេចព្រះប្រមុខរដ្ឋព្រះបិតាជាតិ ព្រះពជវរង្សាទុវង្ស ខ្ញុំឯកឧត្តម ត្រមាំងតុងបរិស័ទតាំងឡាយ ចូលទៅគាល់ និងអញ្ជើញយៃប្រទក្សិណព្រះសក្យមុនីចេតិយ ៣ ដុំ ដោយមានលោក ឈឹម-ស៊ីមន់ដដែល ជាអ្នកនាំព្រះពជដំណើរ ហើយស្តេចយាងចូលចំពីមុខព្រះចេតិយបូជាខៀនធូបក្តាំ ចំពោះព្រះបរមសារីរិកធាតុក្នុងព្រះសក្យមុនីចេតិយ ដែលក្នុងពេលនោះ ព្រះពជបរិពារតាំងឡាយ ក៏បានបូជាខៀនធូបក្តាំជាបន្តបន្ទាប់គ្នាមកដែរ រួចហើយ សម្តេចព្រះប្រមុខរដ្ឋស្តេចយាងត្រឡប់ចូលកាន់ព្រះតម្រាតាសេសវិញ ។

គ្រានោះ ព្រះសង្ឃ ៨០ អង្គ ដែលមានសម្តេចព្រះសង្ឃនាយកតាំងពីគណៈជាប្រធាន បានសូត្រជ័យមង្គលគាថា ចំរើនសិរីសួស្តីក្នុងពិធីបុណ្យ ។ បន្ទាប់មក មន្ត្រីគ្រប់តំណែង តាហានស៊ីវិល ត្រមាំងតុងបរិស័ទតាំងឡាយ បានតាំគ្នាចូលទៅបូជាខៀនធូបក្តាំ ចំពោះព្រះសក្យមុនីចេតិយ ដើម្បីសាងកុសលតាមសេចក្តីប្រថ្នារៀងខ្លួន ។

វេលាម៉ោង ៦ ទឹង ៤៥ នាទី សម្តេចព្រះប្រមុខរដ្ឋ ដោយមានសមាជិកពជវង្សកិត្តិលទឹងព្រះពជបរិពារផ្សំលំជាច្រើនអមដង បានស្តេចយាងទៅគ្រឹតវិញ ។

កន្លងកត្រីនោះ នៅកន្លែងប្រារព្ធពិធី ពុទ្ធិកសមាគមទាំង ៣ ដែលបិតនៅក្នុងការឧបត្ថម្ភរបស់ក្រសួងធម្មការ បានធ្វើពិសាខបូជា ដោយបានមន្តព្រះសង្ឃសំដែងធម៌ទេសនា ជាទីសណ្ដាប់ធ្នាប់ជាទីគួរដែលប្រកៃព្រមទាំងនិមន្តព្រះសង្ឃសូត្រព្រះពុទ្ធគាថា រហូតដល់ពេលអធ្រាត្រ ។

លុះព្រឹកឡើង ថ្ងៃសៅរ៍ ១ កេះដែលតិសាខ ព.ស. ២៥០៩ ត្រូវនឹងថ្ងៃ ១៨ ឧសភា ១៩៦៦ នៅត្រង់កន្លែងប្រារព្ធពិធី នាព្រះពន្ធាព៌ាសេសមុខព្រះសក្យមុនីចេតិយដដែល ចាប់តាំងពីម៉ោង ៨ ទឹង ៣០ នាទីទៅមានការជួបជុំព្រះសង្ឃ ៨០អង្គ ព្រះពុទ្ធវង្សាធុវង្ស ប្រធានសភាពាំងតាវ សមាជិកព្រះពុទ្ធជាតិចាល សមាជិកសភាពាំងតាវ ប្រធានពុទ្ធិកសមាគមទាំង ៣ រដ្ឋមន្ត្រីក្រសួងធម្មការ មន្ត្រីអភិបាលការគ្រប់តំណែងពាំងតាហាន ពាំងស៊ុីលៀ លោកស្រី ឧត្តមសេនីយ៍ឧត្តមសេនីយ៍ទោ ប្រាំនាក់ បានមន្ត ស្តេចយាង អញ្ជើញមក ដើម្បីរួមរួមជាកិត្តិយស ឧត្តមក្នុងបុណ្យនេះដូចកាលពីល្ងាច ។

នៅវេលាម៉ោង ៨ ទឹង ៤៥ នាទី សម្តេចព្រះប្រមុខរដ្ឋ ជាព្រះពុទ្ធតំណាងដ៏ខ្ពង់ខ្ពស់នៃសម្តេចព្រះមាតាជាតិ ដោយមានព្រះពុទ្ធបរិពារជាន់ខ្ពស់ផ្លាស់ព្រះអង្គជាច្រើនរៀបអមព្រះពុទ្ធដំណើរផង បានស្តេចយាងមកដល់កន្លែងប្រារព្ធពិធី ដោយទ្រង់បានខ្ជួលតាវកិច្ចដ៏ខ្ពង់ខ្ពស់បំផុត

អំពីក្រុមមហានគរក្សព្រះអង្គ ក្រុមទេមរក្សមិនទាន់ ៣ កង ក្រុមក្មេង
កងវរសេនាតួចរក្សព្រះអង្គ នឹងក្រុមជន្ត្រីព្រះរាជទ្រព្យ ដែលបានលើក
ការុណធ្វើវត្ថុទានកិច្ច នឹងបន្ទូលបូជាក្មេងជាតិថ្វាយជាព្រះរាជកិត្តិយសចំពោះ
ព្រះអង្គ ។ រួចហើយ ស្តេចយាងចូលគាន់ព្រះតម្ងាពិសេសថ្វាយបង្គំព្រះ
សង្ឃ ដែលនៅចំពោះព្រះអង្គបានទទួលការក្រាបថ្វាយបង្គំអំពីឥស្សរជន
ទាំងឡាយ ដែលនៅចាំក្រាបថ្វាយបង្គំគាល់ ។

តមក មានធ្វើពិធីសមាទានសីលតាមទំនៀមទម្លាប់ពិធីបុណ្យ ក្នុង
ព្រះពុទ្ធសាសនា ហើយនៅពេលបន្ទាប់ពីនេះ សម្តេចព្រះប្រមុខរដ្ឋ
ព្រមទាំងឥស្សរជន ក៏បានស្តេចយាង អញ្ជើញជាក់ជាត្រព្រះសង្ឃដែល
ជាកិច្ចធ្វើពិធីបុណ្យ ។ ព្រះសង្ឃក៏បានធ្វើកត្តានុមោទនាថ្វាយព្រះរាជ-
កុសលនឹងជូនកុសល ចំពោះពុទ្ធបរិស័ទទាំងឡាយ ដែលមានសទ្ធាជ្រះ
ថ្លាបានស្តេចយាងនឹងអញ្ជើញមកកាន់ពិធីបុណ្យដ៏ខ្ពង់ខ្ពស់នេះ ។

លុះចប់កិច្ចនោះហើយ មានធ្វើពិធីជាក់ខ្លឹងជាតិនឹងខន់សាសនា
ដោយក្រុមជន្ត្រីព្រះរាជទ្រព្យ បានបន្ទូលបូជាក្មេងជាតិនឹងបទសរកញ្ញា
ដែលកន្លងទៅនោះ ក្រុមសិស្សានុសិស្សប្រុសស្រី បានប្រឹងបទទាំង
ពីរនេះ កំដរបទក្មេងកន្លងមកដោយក់ខ្លឹងនេះផង ។

តំណើរបុណ្យវិសាខបូជានៅមុខព្រះសក្យមុនីចេតិយនេះ បានចប់សព្វគ្រប់នៅវេលាម៉ោង ១០ តត់ ហើយសម្តេចព្រះប្រមុខរដ្ឋដោយមានព្រះរាជបរិពារជាដែលតាមជង្ហែផង បានស្តេចយាងនៃវត្តវិញ ដោយមានការធ្វើតាវៃកិច្ចថ្វាយជាព្រះរាជកិត្តិយសដូចកាលស្តេចយាងមក ។

សូមជំរាបថា នៅជុំវិញព្រះសក្យមុនីចេតិយនឹងនៅខាងកើតព្រះគន្ធាតិសេសក្នុងបរិវេណនៃសួនច្បារ មានតុព្ជបរិស័ទប្រុសស្រីក្មេងចាស់ជារាប់រាននាក់ ។ បាននាំយកភាពនិយៈនឹងកោតនិយាហារដ៏ប្រសើរមកជាក់ថ្វាយព្រះសង្ឃ ដែលគណៈកម្មការបុណ្យបានមមន្តមកជារាប់រយអង្គ ដើម្បីទទួលនូវចង្ហាន់បិណ្ឌបាតក្នុងពិធីបុណ្យនេះ ដែលបានប្រព្រឹត្តទៅយ៉ាងសម្បូរសប្បាយ នៃតុព្ជសាសនិកជនទូទៅ ។

ភាវនាសុទ្ធិយា


ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ៣៤ លេខ ៦ ខែ មិថុនា

ព.ស. ២៥០៤ គ.ស. ១៩៦២

- ភ្នំពេញ -



កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ
បេញ្ញារាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	មញ្ជីរឿង	ទំព័រ
– ស្តីអំពីអច្ឆិន្ទិកមគ្គ	អធិប្បាយ អ្នកឧកញ៉ា ខា-សាន អតីតរដ្ឋមន្ត្រី រៀបរៀង	៦០៣
– ព្រះអភិធម្មបិដក (ធម្មីព្រះយមកៈ) (ត)	លោកម៉ូ-ប៊ូ ប្រែរៀបរៀង	៦១៧
– មធុរសវាហិណី(ត)សម្តេចព្រះធម្មលិខិតល្ងី-ឯម	ប្រែរៀបរៀង	៦២៨
– មហោសថជាតក(ត)	លោក អឹម-ភន ចម្លងពីសាស្ត្រាស្ងឹកវត្តព្រះពុទ្ធវង្ស កឹម-ភ្ងុះ តិនិត្យ	៦៣៥
– ប្រវត្តិព្រះពុទ្ធទំនង់សង្គ្រោអសុរ (ភាក្យភាត្យ)	លោក ជិល-ទិត្យ និពន្ធ	៦៥១
ផ្នែកអក្សរសាស្ត្រ		
– ភាសាសាស្ត្រនិងអក្សរសាស្ត្រខ្មែរ (ត)	លោក ង៉ិក-ឆាម រៀបរៀង	៦៦៧
– ភាក្យខ្មែរប្រែតបរទេស (ត)	ដោយគណៈកម្មការជាតិនៃការសិក្សាផ្នែកអក្សរ "ក"	៦៨៥
– វចនានុក្រមសំស្ក្រឹត-ខ្មែរ (ត)	ព្រះមហា ជាំង-ខាត់ រៀបរៀង	៦៨៦
– រឿងសាមកុក (ត)	ឧកញ៉ា ទូ-ភន ប្រែ	៦៨៧
– រឿងព្រេងឥន (ត)	លោក ង៉ិយ ប៊ុក ប្រែរៀបរៀង	៧០៣
– រឿងព្រេង ទាក់ទងដោយភូមិសាស្ត្រខ្មែរ		៧១៥
ផ្នែកតំណាត់ទីឯប្រវត្តិការណ៍		
– ដំណឹងផ្សេង ។ នៃព្រះសូរិយគ្រាមាស		៧១៧

មួយឆ្នាំមាន ១២ លេខ តម្លៃដាវ ២៣០$០០

34è Année — N° 6 — Juin 1962

KAMBUJASURIYA

Revue mensuelle de culture religieuse et littéraire
publiée par l'Institut-Bouddhique de Phnom-Penh

SOMMAIRE

Partie religieuse

—Athangikamgga par Oknha TEA-SAN 603
—Préah Abhidhamma pitaka «Kampir Préah Yamaka» (suite)
par M. BOU-PO 617
—Madhurasavahini (suite) par Samdech Préah Dhammalikhita
LOUIS-EM 628
—Mahosotha Jataka (suite) relevé du manuscrit sur feuilles de la
tanier par M. IM-PHON, revu et corrigé par le Vén. KEM-TO . . . 635
—L'Histoire d'Indra et de la guerre des Asora (en vers)
par M. PHAL-TIT 651

Partie littéraire

—Le Langage et la littérature Khmère (suite) par M. DIK-KEAM . . . 667
—Activité de la Commission Culturelle (suite) chapitre «Ka» . . . 685
—Dictionnaire Sanscrit-Khmer (suite) par Vén. PANG-KHAT . . . 686
—Histoire de Sam-Kok (suite) traduite par Oknha NOU-KAN . . . 687
—Contes et Légendes de la chine (suite) traduits par M. RAY-BUC 703
—Légendes relatives à l'origine géographique Khmère 715

Notes et Chroniques

—Nouvelles du Ministère des Cultes 719

Prix d'Abonnement annuel (comprenant 12 numéros) : 230 ; 00

ពាក្យយោគមិនឲ្យ ធ្វើការអាក្រក់
ជាការលាមក ឲ្យធ្វើល្អទៅ ។
ឲ្យដុំសាត់ចិត្ត កុំឲ្យហ្មងសៅ
នេះឯងលោកហៅ ពុទ្ធសាសនា ។

ប.ព.

វិបារណាកថាស្តីអំពីអដ្ឋង្គិកមគ្គ

អ្នកទុកញ្ញា ធា-សាន អតីតរដ្ឋមន្ត្រីរៀបរៀង

១- អដ្ឋង្គិកមគ្គ គឺអ្វី ?

អដ្ឋង្គិកមគ្គនោះមានអង្គ ៨ គឺ :

១- សម្មាទិដ្ឋិ ការយល់ឃើញត្រូវ ។

ឯការយល់ឃើញត្រូវនេះ សំដៅការយល់ឃើញត្រូវចំពោះអរិយសច្ច ៤ ប្រការ មានទុក្ខសច្ចជាដើម នឹងមគ្គសច្ចជាចំបំផុត ។

២- សម្មាសង្កប្បោ ការត្រិះរិះត្រូវ ។

ឯការត្រិះរិះត្រូវនេះ គឺសំដៅកុសលវិតក្កៈ ៣ មានខន្តិវិតក្កៈ គឺការត្រិះរិះនឹងចេញចាកកាមជាដើម ។

៣- សម្មាកម្មន្តោ ការធ្វើត្រូវ ។

ឯការធ្វើត្រូវនេះ គឺសំដៅវិរតិចេតនាវៀរមិនប្រព្រឹត្តទង្វើកាយទុច្ចរិតជា។

๘- สมฺมาวาจา การเจรจาชอบ ๆ

ได้แก่การเจรจาชอบนี้ คือเว้นจากการพูดเท็จ ๑ พูดส่อเสียด ๑ พูดคำหยาบ ๑ พูดเพ้อเจ้อ ๑ รวมเป็นองค์ ๔ ๆ

๙- สมฺมากมฺมนฺโต การทำการงานชอบ ๆ (ประพฤติชอบทางกาย)

ได้แก่การทำการงานชอบนี้ คือเว้นจากการฆ่าสัตว์ ๑ ลักทรัพย์ ๑ ประพฤติผิดในกาม ๑ รวมเป็นองค์ ๓ ๆ

๑๐- สมฺมาอาชีโว การเลี้ยงชีพชอบ ๆ

ได้แก่การเลี้ยงชีพชอบนี้ คือเว้นจากมิจฉาชีพ ๕ อย่าง ๆ

๑๑- สมฺมาวายาโม การพยายามชอบ ๆ

ได้แก่การพยายามชอบนี้ คือความเพียร ๔ อย่าง ๆ

๑๒- สมฺมาสติ การตั้งสติชอบ ๆ

ได้แก่การตั้งสติชอบนี้ คือสติปัฏฐาน ๔ อย่าง ๆ

๑๓- สมฺมาสมาธิ การตั้งจิตมั่นชอบ ๆ

ได้แก่การตั้งจิตมั่นชอบนี้ คือฌาน ๔ อย่าง ๆ

๒- ก็ธรรมทั้งหลายเหล่านี้ ที่ท่านจัดเข้าในมรรคมีองค์ ๘ ประการ ด้วยเหตุอย่างไร ?

ตอบว่า ธรรมทั้งหลายเหล่านี้ ท่านจัดเข้าในมรรคมีองค์ ๘ ประการ ด้วยเหตุว่า เป็นเครื่องดำเนินไปสู่นิพพาน ๆ

ជាន់សេចក្តីថា យោគាវចរគប្បីចំរើនគុណធម៌ដែលជាគ្លួនៃអង្គនីមួយៗដូច ជាន់តណាទាងលើនេះ ឲ្យសម្រេចកើតមានច្រើនដងឡើងដូចតទៅនេះ:

ដើម្បីនឹងចំរើនអង្គសម្មាទិដ្ឋិឲ្យកើតមានជាក់ច្បាស់ឡើងនោះ យោគាវចរគប្បីលើកខុក្ខ ១២ កង មានជាតិខុក្ខជាដើម មកពិចារណាស្រាវជ្រាវរកហេតុបច្ច័យឲ្យច្បើយៗ រៀងរាបដរាប លុះត្រាតែញាណ គឺការដឹងច្បាស់ ៦ ប្រការកើតឡើងគឺ:

១- ខុក្ខេ ញាណំ ដឹងច្បាស់ខ្លួនកងខុក្ខ គឺដឹងច្បាស់ថាខុក្ខមានព្រោះមានខន្ធ ៥ ជាទីកើត ខន្ធជាទីតាំងសម្រាប់ឲ្យខុក្ខនោះ អាចមានដំណើរប្រព្រឹត្តទៅបាន ព្រមទាំងដឹងច្បាស់ថា ខុក្ខនោះជាបរិញ្ញេយ្យធម៌ តឹធម៌គប្បីកំណត់ខុក្ខក្នុងចិត្តថា ខុក្ខនេះតែងតែបៀតបៀនសត្វ ធ្វើឲ្យកើតមានសេចក្តីឈឺចាប់ សេចក្តីក្តៅក្រហាយគ្រប់បែបយ៉ាង, ឆ្នាំនសត្វណាដែលស្ថិតនៅលើត្រែតត អាចគេចខ្លួនឲ្យរួចផុតចាកខុក្ខនោះបាន សោះឡើយ ។

២- ខុក្ខសមុទយេ ញាណំ ដឹងច្បាស់ខ្លួនហេតុនៃកងខុក្ខ គឺដឹងច្បាស់ថា តណ្ហា ៣ ប្រការ គឺកាមតណ្ហា ១ ភវតណ្ហា ១ ខនឹងវិភវតណ្ហា ១ ជាហេតុនាំឲ្យខន្ធ ៥ កើតឡើងក្នុងភពថ្មីទៀត ព្រមទាំងដឹងច្បាស់ថា តណ្ហា ៣ ប្រការនោះជាបហានតព្វធម៌ តឹធម៌គប្បីលះឲ្យជាច់ស្រឡះចេញ ។

๓- ឧក្ខិត្តិកភេទេញ្ញាណំ ដែលឈ្មោះថាឧក្ខិត្តិកៈ ព្រោះតែដែលឈ្មោះថា តិរិយាវលត់នៃតណ្ហា ๓ ប្រការ ជាហេតុនាំឲ្យខន្ធ ๕ វលត់ជាប់ជាប់ ព្រមទាំងដែលឈ្មោះថា តិរិយាវលត់នៃតណ្ហា ๓ ប្រការជាសច្ចិកាតព្វធម៌ គឺធម៌ដែលប្រាថ្នាឲ្យជាក់ច្បាស់ឡើង ។

๔- ឧក្ខិត្តិកភេទតាមិនបដិបជ្ជាយញ្ញាណំ ដែលឈ្មោះថាឧក្ខិត្តិកៈ ព្រោះតែមិនបដិបទា ដែលអាចញុំាងឧក្ខិត្តិកៈឲ្យវលត់ទៅបាន ព្រោះតែដែលឈ្មោះថា អដ្ឋង្គិកមគ្គ ជាបដិបទាអាចធ្វើឲ្យជាក់ច្បាស់ នូវតិរិយាវលត់នៃតណ្ហា ๓ ប្រការនោះបាន ព្រមទាំងដែលឈ្មោះថា អដ្ឋង្គិកមគ្គនោះជាការពិតព្រះធម៌ គឺធម៌ដែលប្រាថ្នាចំរើនឲ្យសម្រេចកើតមានច្រើនដងឡើង ។

នៅខណៈដែលអង្គសម្មាទិដ្ឋិកើតមានគង់ខន្ធសន្តាន ដូចបានពណ៌នាខាងលើនេះចប់បរិបូណ៌ហើយ, ទើបអង្គសម្មាទិដ្ឋិនោះ ប្រែទៅជាមគ្គង្គខ្លួសក់ជាតិនាំយោគាវចរឲ្យត្រិះរិះតិតយើញនូវកុសលវិតក្កៈ ๓ ប្រការ គឺៈ នេក្ខម្មវិតក្កៈ ត្រិះរិះចេញចាកកាម ๑, អព្យាបាទវិតក្កៈ ត្រិះរិះរឿរមិនព្យាបាទដល់អ្នកដទៃ ๑, នឹងអវិហិង្សាវិតក្កៈ ត្រិះរិះរឿរមិនបៀតបៀនអ្នកដទៃ ๑ ជាដំការចាំបាច់តម្រូវបំពេញឲ្យសម្រេចឡើង ទើបជាហេតុអាចនាំឲ្យចំរើនអង្គឯទៀតគឺ អង្គសម្មាកម្មន្តា, សម្មាវាចា, សម្មាអាជីវៈ, សម្មាវាយាមៈ, សម្មាសតិ និងសម្មាសមាធិ ឲ្យសម្រេចឡើងជាគំរប់ច្រើនដងបាន ។ កាលបើយោគាវចរបានត្រិះរិះតិតយើញត្រូវដូច្នេះហើយ

កំប្តេជ្ញាចិត្តថៅសុំបព្វជ្ជាជាតិក្នុងព្រះពុទ្ធសាសនា ទំព្យាយាមសមាទាន
ខ្លួនចតុប្បាសុំខ្ញុំសិល មានឋានៈមានក្តីសំរើសិលជាដើម ហើយតាំង
វិតិចេតនាវៀរមិនប្រព្រឹត្តខ្លួកាយទុច្ចរិត ៣ , ខ្លួវចីទុច្ចរិត ៤ , ខ្លួ
អនេសន: ៦១ ទីឯខ្លួបាបធម៌ ៤ ជាលំដាប់តទៅ ។

កាលបើអង្គសម្ភាកម្មន្តោ, សម្ភាក់ថា ទីឯសម្ភាគដីរកេ បាន
សម្រេចកើតមានឡើងច្រាកដហើយ យោគាវចរបព្វជិតនោះ តំតាំងចិត្ត
ឡើងសិប់កន្លងការចំរើនកម្មដ្ឋាន ដើម្បីព្យាយាម ៖

១- បំពេញខ្លួបបាន ៤ មានសំវរៈប្បធានជាដើម ជាប្រយោជន៍
ដើម្បីទីឯលះខ្លួវិតក្កិលេស ១៦ មានអកិដ្ឋាវិសមលោភៈជាដើម ដែលជា
កិលេសធ្វើចិត្តឲ្យសៅហ្មង ទីឯដើម្បីបំពេញគុណធម៌ផ្សេង ។ មានឥទ្ធិ-
បាទ ៤ ទីឯពល ៥ ជាដើម ដែលមិនទាន់កើតមានក្នុងខ្លួសន្តានឲ្យ
សម្រេចកើតមានឡើង ប្រយោជន៍ដើម្បីជាកម្លាំងសម្រាប់ទ្រទ្រង់ក្នុងការ
ចំរើនកម្មដ្ឋានផ្សេង ។ តទៅទៀត ។

២- ចំរើនសតិបដ្ឋាន ៤ មានកាយានុបស្សនាសតិបដ្ឋានជាដើម ជា
ប្រយោជន៍ដើម្បីទីឯលះទីវណៈ ៥ មានកាមច្ឆន្ទៈជាដើម ដែលជាសត្រូវ
ទីឯសមាធិចិត្ត ឲ្យវិនាសសាបសូន្យអស់តិខ្លួសន្តាន ។

៣- ចំរើនឈានមានរូបជ្ឈាន ៤ ជាដើម ជាប្រយោជន៍ដើម្បីទីឯលះ
ពាត: ភោស: មោហៈឲ្យអស់តិខ្លួសន្តាន ហើយញុំាងអង្គសម្ភាក់យាមា,

សម្ថៈសតិនេឝសម្ថៈសមាធិឲ្យសម្រេចកើតមានច្រាកដឡើងជាលំដាប់ ។

ដើម្បីនឹងចំរើនឈានឲ្យសម្រេចនូវប្រយោជន៍ចាន់ជាក់ច្បាស់នោះ ទើបអង្គសម្ថៈពុទ្ធ ដែលជាមគ្គុទ្ទេសក៍នោះ ជីកនាំយោគាវចរឲ្យនឹកគិតឃើញត្រូវថា គប្បីចាប់ផ្តើមចំរើនកសិណជាបឋម ឲ្យចានសម្រេចនូវអប្បនាសមាធិជាមុនសិន ព្រោះអប្បនាសមាធិនេះជាមូលដ្ឋានសម្រាប់ឲ្យឈានចិត្ត ៩ មានរូបជ្ឈានចិត្ត ៤ ជាដើមអាចកើតឡើងចានហើយ ពីព្រោះឈានចិត្តទីមួយ ។ សុទ្ធតែសម្បយុត្តដោយអង្គឯកគ្គតាតី អប្បនាសមាធិនោះឯង ។

កាលបើនឹកគិតឃើញដូច្នេះហើយ ទើបយោគាវចរតាំងចិត្តព្យាយាមចំរើនកសិណ, ចំរើនឈាន នឹងចំរើនវិបស្សនាការនារៀងរាបដរាបលុះត្រាតែចានសម្រេចនូវអប្បនាសមាធិ, ឈានចិត្ត ៩ នឹងវិបស្សនាញាណ ១០ សមតាមគោលចំណងសព្វគ្រប់ដោយប្រការដូច្នេះឯង ។

រីឯលទ្ធផលដែលយោគាវចរ ចានចំពេញឲ្យសម្រេចកើតមានឡើងដូចចានរៀបរាប់ខាងលើនេះជាសក្ខីភាព បញ្ជាក់សេចក្តីឲ្យឃើញថា លោកចានចំរើនអដ្ឋង្គិកមគ្គឲ្យសម្រេចឡើងជាក់ច្បាស់ហើយ ។

ចំណែកឯគុណធម៌ដែលយោគាវចរចានចំរើន ឲ្យសម្រេចកើតមានឡើងនោះ បណ្ដិតលោកបែងចែកជា ៣ គំនរ ហៅថាត្រៃខន្ធគឺ លោកយកសុចរិត ១០ នឹងសម្ថាអដ្ឋង្គិកៈធ្វើជាគំនរ ១ ហៅថា សីលខន្ធ, យក

សមាធិចិត្ត ឧទ្ធច្ចកុក្កុច្ចចិត្ត ๕ ធ្វើជាគំនរ ๑ ហៅថា សមាធិខន្ធ, ហើយ
យកវិបស្សនាញាណ ๑๐ ធ្វើជាគំនរ ๑ ទៀត ហៅថា បញ្ញាខន្ធ ។

គឺត្រៃខន្ធនេះហើយ ដែលបណ្ឌិតលោកចាត់ទុកថាជាគ្រឿងសម្រាប់
កំចាត់បង់នូវកិលេស ឲ្យវិនាសសាបសូន្យអស់តិខន្ធសន្តានទៅបាន
ជាតិតម្រាកដនោះ ។

๓- តើត្រៃខន្ធនេះ អាចកំចាត់បង់នូវរាគាទិក្លេសឲ្យវិនាស សាបសូន្យអស់ពីខន្ធសន្តានទៅបានដោយប្រការដូចម្តេចទៅ ?

ចំពោះរឿងនេះ ខ្ញុំសូមបញ្ជាក់ថា ៖

๑ - សីលខន្ធដែលប្រកបដោយសុចរិត ๑๐ មានកាយសុចរិត ๓
ជាដើម ឧទ្ធច្ចកុក្កុច្ចចិត្ត អាចការពារយោគាវចរឲ្យរួចផុតចាកវិតក្កមនោ
តិកិលេសយ៉ាងគ្រោតគ្រាតចាំងឡាយបាន ។

๒- រីឯសមាធិខន្ធ ដែលមានបរិបូណ៌ដោយសមាធិចិត្ត ឧទ្ធច្ចកុក្កុច្ច
ចិត្ត ๕ រមែងញុំាងខន្ធសន្តានឲ្យរួចផុតចាកកាមនោ តិកិលេស តែព្រោះឈានចិត្ត
ដែលសម្បយុត្តដោយអង្គទុបេក្ខា ឧទ្ធច្ចកុក្កុច្ចចិត្ត រមែងតែតាំងនៅជាកណ្តាល
មិនអើតើ គឺមិនសោមនស្សមិនទោមនស្សចំពោះវត្ថារម្មណ៍ ហើយ
ពាំងប្រទាំងមិនឲ្យកន្តរនោ តិកិលេស ចូលមកកើតកន្លងខន្ធសន្តានបាននោះ
ឯង ។

๓- ចំណែកឯបញ្ញាខន្ធ ដែលតោរេតញ្ញាភៅដោយវិបស្សនា-ញ្ញាណ ๑๐ សម្រាប់បន្ទោបង់ខ្លួរមោហៈទំងសក្កាយទិដ្ឋិ ព្រោះវិបស្សនាញ្ញាណ គឺញ្ញាណដែលដឹងច្បាស់ខ្លួរដំណើរនៃសង្ខារធម៌ភៅតាមការណ៍ពិតនោះ ក៏រមែងតែប្រទាំងកាត់ងមិនឲ្យមោហៈទំងសក្កាយទិដ្ឋិចូលមកកើតក្នុងខន្ធសន្តានបាននោះ ដែលជាហេតុធ្វើឲ្យខន្ធសន្តាននោះរងហួតស្ងួតផុតពីកមោហៈសក្កាយទិដ្ឋិ ទំងវិចិកិច្ឆាអស់ភៅបាន ។

លុះណាតែយោគាវចរបានប្រកបដោយញាត្រៃខន្ធនេះ ទើបយោគាវចរអង្គនោះមានសមត្ថភាពអាចលះសំយោជនៈ ๑๐ ជាច់ស្រឡះ ដើម្បីការត្រាស់ដឹងមគ្គផលនិព្វានសមដូចសេចក្តីប្រាថ្នាភៅបាន ។

ភៅទីនេះ ខ្ញុំពុំធ្វើអត្ថាធិប្បាយអំពីការត្រាស់ដឹងមគ្គផលនិព្វានទេ, ខ្ញុំគ្រាន់តែលើកយកគោលធម៌ខ្លះមកបញ្ជាក់ ដើម្បីឲ្យងាយយល់ខ្លួរលក្ខណៈនៃការត្រាស់ដឹងនោះ ដូចមានសេចក្តីតភៅនេះ៖

សំយោជនៈទាំងច្បាយណា ដែលយោគាវចរលះជាច់ស្រឡះអស់ភៅហើយ, សំយោជនៈទាំងច្បាយនោះ ទុកដូចជារួចផុតស្រឡះពីកខន្ធសន្តានអស់ភៅហើយ ។ ម្យ៉ាងទៀតសំយោជនៈទាំងច្បាយណា ដែលរួចផុតស្រឡះពីកខន្ធសន្តានអស់ភៅហើយ សំយោជនៈទាំងច្បាយនោះ ទុកដូចជាបានលះតំខន្ធសន្តាននោះអស់ភៅហើយ ។

បើនិយមតាមទ្រឹស្តីវាងលើនេះ គេអាចសន្និដ្ឋានបានថា កិរិយាលះ

សំយោជន: ១០ ជាចំស្រេចជាសមុដ្ឋានៃការត្រាស់ដឹងខ្លួនមគ្គ ៤ មាន
សោតាបត្តិមគ្គជាដើម, ហើយកិរិយាលះបង់ស្រឡះចាកសំយោជន: ១០ ជា
សមុដ្ឋានៃការត្រាស់ដឹងខ្លួនផល ៤ មានសោតាបត្តិផលជាដើម, ហើយ
កិរិយាលេស់នៃសំយោជន: ១០ ជាសមុដ្ឋានៃការត្រាស់ដឹងខ្លួននិព្វានៈនោះ
ឯង ។

បើអស់លោកជាពុទ្ធបរិស័ទណាចង់ជ្រាប តើមគ្គ ៤ ផល ៤ និង
និព្វានគឺជាអ្វីនោះ ខ្ញុំសូមអញ្ជើញអស់លោកជាពុទ្ធបរិស័ទនោះអានសៀវ-
ភៅ លោកគុន្តកកិសម័យ ដែលខ្ញុំបានទិញនៅហើយបានបោះពុម្ព
ចែកផ្សាយជាធម្មទាននោះទៀត អស់លោកនឹងបានជ្រាបអំពីរឿង
នេះពុំខានឡើយ ។

៤- បើអដ្ឋង្គិកមគ្គជាបដិបត្តិធម៌ សម្រាប់ការត្រាស់ដឹង
មគ្គ ផល និព្វានទេ, តើហេតុដូចម្តេច បានជាបណ្ឌិតលោក-
ចាត់ទុកអដ្ឋង្គិកមគ្គនោះ ជាជាទុក្ខនិរោធគាមិនីបដិបទា គឺបដិ-
បទាអាចញ៉ាំងកងទុក្ខឲ្យរលត់ទៅវិញ ?

បានជាបណ្ឌិតលោកចាត់ទុកអដ្ឋង្គិកមគ្គ ជាជាទុក្ខនិរោធគាមិនីបដិ-
បទាដោយវិញ ព្រោះការត្រាស់ដឹងមគ្គ ផល និព្វានរមែងជាមួល
ហេតុនាំឲ្យបាន ៩ រលត់ជាលំដាប់ពុំខានឡើយ ។ នៅពេលដែលបាន ៩

ត្រូវបានរលត់ហើយ ទុក្ខ ១២ កងដែលមាន ១ខ្ន ៥ នោះជាទឹតាំងនឹងជាទឹកើត ក៏ត្រូវរលត់ព្រមជាមួយគ្នាជាលំដាប់ដែរ ។

អាស្រ័យហេតុនេះ ទើបបណ្ឌិតលោកពោលថាអដ្ឋង្គិកមគ្គជាទុក្ខ. និរោធតាមនិយមដូចមានប្រការដូច្នេះឯង ។

៥- តើការត្រាស់ដឹងមគ្គ ៤ ផល ៤ និងនិព្វាន ជាហេតុអាចញ៉ាំងខន្ធ ៥ ព្រមទាំងទុក្ខ ១២ កង ឱ្យរលត់ទៅបានដោយប្រការដូចម្តេចទៅ ?

ដើម្បីឆ្លើយឃើញ ខ្ញុំសូមរំឭកមកថាខាងដើមថា ការត្រាស់ដឹងនិព្វានដែលនឹងសម្រេចឡើងបាន ក៏ព្រោះកិរិយារលត់នៃកិលេសជាមូលហេតុ, ហើយកិរិយារលត់នៃកិលេសដែលនឹងសម្រេចកើតមានឡើងបាន ក៏ព្រោះការត្រាស់ដឹងមគ្គ ៤ ផល ៤ ជាមូលហេតុ ។

សេចក្តីបញ្ជាក់នេះ ទាំងឱ្យសន្និដ្ឋានបានថា កិរិយារលត់នៃកិលេសនោះហើយ ដែលជាមូលហេតុមិនត្រឹមតែនាំឱ្យការត្រាស់ដឹងនិព្វានសម្រេចឡើងបានប៉ុណ្ណោះទេ, ថែមទាំងនាំឱ្យតណ្ហា, ទិដ្ឋាន និងកម្មរលត់អស់ជាលំដាប់ទៀត ដូចមានសេចក្តីបញ្ជាក់ហេតុផលតទៅនេះ :

- តណ្ហា គឺសេចក្តីប្រាថ្នាខ្លួនអារម្មណ៍ ៦ មានរូបជាដើម ដែលនឹងមានដំណើរប្រព្រឹត្តទៅជាធម្មតាបាន ក៏ព្រោះមានភាពនៃកិលេសគឺ

កតៈ ទោសៈ មោហៈ ជាមូលហេតុ ។ កាលបើកតាទិក្តិលេសជាដើម ហេតុលេត់អស់ទៅហើយ រីឯតណ្ហាដែលជាផលក៏ត្រូវរំសាយលេត់ត្រមជាមួយគ្នាជាលំដាប់ដែរ ។

- ទុច្ចរិត ๔ មានកាមុប្បាទាន គឺសេចក្តីជំពាក់ចិត្តនឹងកាមជាដើម ដែលនឹងមានដំណើរប្រព្រឹត្តទៅជាប្រក្រតីបាន ក៏ព្រោះមានតណ្ហានោះឯងជាមូលហេតុ ។ កាលបើតណ្ហារលេត់អស់ទៅហើយ, រីឯទុច្ចរិត ๔ ដែលជាផល ក៏ត្រូវលេត់ត្រមជាមួយគ្នាជាលំដាប់ដែរ ។

- កម្ម ๒ ប្រការគឺ កុសលកម្ម ๑ នឹងអកុសលកម្ម ๑ ដែលនឹងកើតមានឡើងបាន ក៏ព្រោះទុច្ចរិត ๔ មានកាមុប្បាទានជាដើមនោះឯងជាមូលហេតុ ។ កាលបើទុច្ចរិត ๔ ជាដើមហេតុរលេត់អស់ទៅហើយ, រីឯកម្ម ๒ ប្រការដែលជាផល ក៏ត្រូវលេត់ត្រមជាមួយគ្នាជាលំដាប់ដែរ ។

- ខន្ធ ๕ ដែលនឹងកើតមានឡើងក្នុងភពថ្មីទៀតបាន ក៏ព្រោះមានកម្ម ๒ ប្រការជាមូលហេតុ ។ កាលបើកម្ម ๒ ប្រការរលេត់អស់ហើយ, រីឯខន្ធ ๕ ដែលជាផល ក៏ត្រូវលេត់ត្រមជាមួយគ្នាជាលំដាប់នោះដែរ ។

រីឯខុទ្ទ ๑๒ កងដែលនឹងកើតមានឡើងបាន ក៏ព្រោះមានខន្ធ ๕ នោះជាទីកើត កាលបើខន្ធ ๕ រលេត់អស់ទៅហើយ, ខុទ្ទ ๑๒ កងក៏ត្រូវរលេត់ត្រមជាមួយគ្នាជាលំដាប់ដែរ ។

សរុបសេចក្តីមៅយើញថា កិរិយារលត់នៃភាគចិត្តលេស ជាមួលហេតុអាចនឹងញ៉ាំងខន្ធ ៥ ព្រមទាំងពុទ្ធ ១២ កងឲ្យរលត់ទៅបានពិតមែន តែមិនមែនឲ្យរលត់ក្នុងពេលជាបច្ចុប្បន្ននេះទេ គឺឲ្យរលត់ទៅឯអនាគតនៅពេលដែលអាយុក្តីឈមកដល់ឯណោះ ។

អាស្រ័យហេតុនេះ ទើបនិព្វានដែលសម្រេចកើតមានឡើងដោយកិរិយារលត់នៃកិលេសនោះ តំត្រូវមាន ២ ប្រការដែរគឺ ១ថា ទិសេសនិព្វាន ១ នឹងអនុប្បាទិសេសនិព្វាន ១ ។

ឯ១ថា ទិសេសនិព្វាន គឺនិព្វានដែលសម្រេចកើតមានឡើងដោយកិរិយារលត់នៃកិលេសពុំជាន់និព្វានបច្ចុប្បន្ន, រីឯអនុប្បាទិសេសនិព្វាន គឺនិព្វានដែលសម្រេចកើតមានឡើង ដោយកិរិយារលត់ទាំងកិលេស ទាំងបញ្ចក្ខន្ធនោះពុំជាន់និព្វានទៅអនាគត ។

ត្រង់នេះសេចក្តីឆ្លើយថា កិរិយារលត់នៃកិលេសក្នុងបច្ចុប្បន្ន ជាហេតុនាំឲ្យបញ្ចក្ខន្ធ នឹងកងពុំឲ្យរលត់ទៅអនាគតទៀតពុំមានឡើយ ។

៦- តើបណ្ឌិតលោកយល់ឃើញដូចម្តេច ទើបលោកខំព្យាយាមបំពេញនូវអដ្ឋង្គិកមគ្គ ដើម្បីនឹងធ្វើឲ្យខន្ធ ៥ រលត់លែងឲ្យកើតក្នុងភពថ្មីទៀតយ៉ាងដូច្នេះ?

បើតាមយោបល់ខ្ញុំ ប្រហែលបណ្ឌិតសោកចាត់ពុទ្ធខន្ធ ៥ នោះ ជា

សេចក្តីទុក្ខសោក, សេចក្តីឈឺចាប់ស្តេវក្រហាយខ្វោចផ្សាគ្រប់បែបយ៉ាង, គ្មានសត្វណាដែលស្ថិតនៅលើត្រែតភ អាចនឹងគេចខ្លួនឲ្យរួចផុតពីទុក្ខ ១៦ ពួកនោះបានឡើយ ។ មិនតែប៉ុណ្ណោះ ព័ត្រោះខន្ធ ៥ នោះ ជាអ្នកនាំមកនូវអារម្មណ៍ ៥ មានរូបជាដើម សម្រាប់លួងលោមចិត្ត ធ្វើសត្វឲ្យស្រេ-រឹងជ្រប់នឹងកាមគុណ ៥ រំងឹងក្នុងភ្នាំងស្មាតែ ក្នុងខ្លួនជាប់ស្ថិតនៅវិល-វល់ក្នុងវដ្តសង្សារ រឹងទុក្ខវេទនាកេរ៏ប់ផុតគ្មានសោះឡើយ ។

អាស្រ័យហេតុនេះហើយ ឋានជាបណ្តាំតលោកស្វែងរកទុកជាយដើម្បី នឹងដោះខ្លួនឲ្យរួចផុតស្រឡះចាកខន្ធ ៥ នោះដោយប្រការដូច្នេះឯង ។

លំដាប់តអំពីនេះ ខ្ញុំនឹងធ្វើអត្ថាធិប្បាយបញ្ជាក់អំពីខន្ធ ៥ នឹង ពោសនៃខន្ធ ៥ នោះ ដូចមានសេចក្តីតណ្តៀនេះ ៖

ឯខន្ធ ៥ នោះគឺ ៖

១- រូបក្ខន្ធ គឺគំនរូប.- គំនរូបនេះ មានមហាភូតរូប ៤ គឺ ដី ទឹក ភ្លើង ខ្យល់ នឹងឧបាទាយរូប ២៤ មានបសាទ ៥ អារម្មណ៍ ឋានក្រៅ ៥ ជាដើម ។ល។

២- វេទនាខន្ធ គឺគំនរវេទនា.- គំនរវេទនា មានវេទនា ៥ គឺ សោមនស្ស ទោមនស្ស សុខ ទុក្ខ នឹងឧបេក្ខា ។ ឯវេទនាគឺចិត្តដែល សោយអារម្មណ៍ហើយដឹងថា អារម្មណ៍នោះ ។ ជាសោមនស្ស ឬ ជា ទោមនស្ស ឬ ជាសុខជាទុក្ខ ឬ ជាឧបេក្ខា ។

៣- សញ្ញា ១ ក្នុង គឺគំនរសញ្ញា - គំនរសញ្ញានេះ មានសញ្ញា ៥ គឺ រូបសញ្ញា សទ្ទសញ្ញា គន្ធសញ្ញា រសសញ្ញា ខ័ន្ធផោដ្ឋព្វសញ្ញា ។

ឯសញ្ញាគឺចិត្ត ដែលសំគាល់ជំនឿនូវរូប សម្លេង ក្លិន រស (សម្ផស្ស ប៉ះពាល់ត្រូវដោយអណ្តាត) ខ័ន្ធផោដ្ឋព្វៈ (សម្ផស្សដែលប៉ះពាល់ត្រូវដោយកាយ) ។

៤- សង្ខារក្ខន្ធ គឺគំនរតំនិត.- គំនរតំនិតនេះ មានចេតសិក ៥២ ចែកចេញជាកុសលចេតសិក ២៥ ជាអកុសលចេតសិក ១៤ ខ័ន្ធជាអញ្ញសមានាចេតសិក ១៣ ។ រីឯសង្ខារ គឺចិត្តដែលសន្សំតនា គឺតំនូវការជាកុសលឬជាអកុសល តែងតំកើងយើញនូវតំនិតផ្សេង ។ ហៅថា ចេតសិកនោះឯង ។

៥- វិញ្ញាណក្ខន្ធ គឺគំនរវិញ្ញាណ.- គំនរវិញ្ញាណមាន វិញ្ញាណ ៦ គឺ ចក្ខុវិញ្ញាណ ដឹងតាមភ្នែក សោតវិញ្ញាណ ដឹងតាមត្រចៀក ឃានវិញ្ញាណ ដឹងតាមច្រមុះ ជិវ្ហាវិញ្ញាណ ដឹងតាមអណ្តាត កាយវិញ្ញាណ ដឹងតាមកាយ ខ័ន្ធមនោវិញ្ញាណ ដឹងតាមចិត្ត ។

(នៅមានត)

ព្រះអភិធម្មបិដក

គម្ពីរព្រះយមក:

លោក ម៉ូ . ប៉ុ ប្រែរៀបរៀង

(តមក)

បុរោហិតាចារ្យធ្វើយថា មហាសេដ្ឋិ បពិត្រលោកជាមហាសេដ្ឋី អដ្ឋ ជារកោ ហេតុដូចម្តេចកុំនិយាយចូរលើកខុនកៅចុះ នឹយាយតែហេតុមួយថា ទារកដែលកើតកន្លងថ្ងៃនេះទៅ ធ្វើជាមហាសេដ្ឋី លោកចូរកំណត់ចាំទុកចុះ ។

តទា ករុភក្តា គ្រានោះ ភរិយាចម្រស់សេដ្ឋីនោះមានគតិថាស់ខែដឹងនឹងប្រសូតបុត្រ មហាសេដ្ឋីប្រើអ្នកបំរើឲ្យវិលទៅផ្ទះវិញឲ្យសួរថា ភរិយាប្រសូតបុត្រហើយឬនៅឡើយទេ ។ អ្នកបំរើទៅដល់ផ្ទះសួរតាមពាក្យសេដ្ឋីឮដំណឹងថាភរិយាមិនទាន់ប្រសូតបុត្រ ទើបត្រឡប់មកដំណាលដល់មហាសេដ្ឋី ។ កំពៅគាល់ព្រះមហាសត្វត្រូវហើយវិលមកដល់ផ្ទះវិញហើយប្រើបុរសឲ្យដើរកេម៉ើលទារកដែលកើតកន្លងថ្ងៃនោះ ។ ឯយោសក-ទេវបុត្រច្យុតពីស្ថានសួរចុះមកកើតកន្លងតគិនៃស្ត្រីពេស្យា ។ នោះចិញ្ចឹមតែកូនស្រី ទើបបង្គាប់ឲ្យឡើស្រីនាំយកទារកនោះទៅចោះចោលម៉ងទុកចិញ្ចឹមឡើយ ។ បុរសម្នាក់មកឃើញកើតចិត្តស្រឡាញ់រើសយកទារកនោះ

ទៅចិញ្ចឹមខុសជាកូនធម៌ ។ ចុះសេចក្ដីដឹងថា ពាក្យនោះកើតកូន
ថ្ងៃនោះ ទើបត្រឡប់ទៅដំណាលសេដ្ឋី ។ ឲ្យប្រាក់មួយតាន់តហាបណៈទៅ
ទិញយកពាក្យនោះមកចិញ្ចឹមខុស ។ សេដ្ឋីគិតថា បើកូនរបស់អញ
កើតមកជាស្រីនឹងផ្សំគ្នាឲ្យជាកំរៃរបស់ពាក្យនេះ បើកូនអញជាប្រុស
វិញ អញនឹងសម្លាប់ពាក្យនេះចោលចេញ គិតហើយលាក់ខុសតែកូនចិត្ត
គិតស្រដីឲ្យអ្នកណាដឹងឮផងឡើយ ។

ក្នុងដំណើរនោះមកមិនយូរប៉ុន្មាន កំរៃរបស់សេដ្ឋីប្រសូតកូនមកជា
ប្រុស សេដ្ឋីក៏តាំងចិត្តប្រដូសរក់យពាក្យនោះ ប្រើនាងទាសីឲ្យយកពាក្យ
ទៅចោះចោលក្នុងព្រៃព្នៅច ។ល។ សេដ្ឋីគិតសម្លាប់ពាក្យនេះជាច្រើន
លើកណាស់ សូម្បីកូនប្រុសរបស់ខ្លួនត្រូវស្លាប់ដោយៗបាយកលរបស់
ខ្លួនហើយ ក៏នៅតែមិនឈប់សម្លាប់ពាក្យនោះដែរ ក្នុងទីបំផុតប្រើ
ពាក្យនោះឲ្យទាំសំបុត្រទៅឯស្រុកសួយ ប្រាប់ឲ្យសេដ្ឋីអ្នកទាំសួយនៅ
ស្រុកក្រៅជួយសម្លាប់ពាក្យ ។ ប៉ុន្តែ ផ្ទុយទៅវិញ បែរជាពាក្យនោះ
បានធ្វើតាមសេដ្ឋីកូនជនបទទៅវិញ ។ មហាសេដ្ឋីគិតសម្លាប់ពាក្យមិន
ស្លាប់ កើតទុក្ខក្តួចចិត្តណាស់ ឃើញតាក់ឈាមតិមាត់ពាល់តែស្លាប់ខ្លួន
ឯងទៅ ។ ឯបុគ្គលដែលៈនាំជាមួយសត្វនឹងសង្ឃរមិនជាទីស្រឡាញ់តែង
នាំឲ្យកើតទុក្ខធំដូចជារឿងមហាសេដ្ឋីនេះឯង ។

ការដែលកើតមកជាសត្វដាបុគ្គលហើយ ទៀងតែមានទុក្ខគ្រប់គ្នា ។

បើអ្នកមានធនធានច្រើនប៉ុន្មាន ទុក្ខក៏មានច្រើនប៉ុណ្ណោះដែរ ព្រោះទុក្ខនឹងរក្សាទ្រព្យសម្បត្តិឲ្យតន់ទ្រដ់ទៅកុំឲ្យអន្តរាយ ។ លុះខ្លួនចាស់ជរាហើយ ក៏ជាទុក្ខក្នុងការថែរក្សាខ្លួនមិនឲ្យចាស់ជរា ។ លុះមានព្យាធិជម្ងឺឈឺចាប់មកគ្របសង្កត់ខ្លួនហើយ ទុក្ខក៏តែងតែកើតមានច្រើនឡើងទៀត ។ កាលបើសេចក្តីស្លាប់មកដល់ហើយក៏គ្មានសុខសោះ ព្រោះខ្លាចសេចក្តីស្លាប់ជាទីបំផុត ។

ការនៅជាមួយសត្វនឹងសង្ឃឹមមិនជាទុក្ខស្រឡាញ់ ក៏ជាទុក្ខរហូតដល់បែកគ្នាទៅ កុំថាអ្នកជាខៃ សូម្បីតែប្តីនឹងប្រពន្ធទៅជាមួយគ្នាបានសុខសោះ ព្រោះតែចិត្តស្រឡាញ់ឱណិតមេត្តាគ្នាទៅវិញទៅមក បុះបើចិត្តបែកចេញគ្នា តឹមិនចុកចិត្តគ្នា មិនត្រមត្រៀងគ្នាហើយ ក៏នៅជាមួយគ្នាឥតសុខឡើយ ។

ការត្រេតត្រាសបុគ្គលជាទីស្រឡាញ់ក៏ជាទុក្ខ ។ ចិត្តប្រាថ្នាចង់បានរបស់អ្វីហើយ មិនបានសម្រេចដូចបំណងក៏ជាទុក្ខ ប៉ុន្តែ ចង់បានរបស់ជាខៃ ក្រែតែចង់បានស្រី បើមិនបានកើតទុក្ខយ៉ាងល្មមគ្រាន់អត់ទ្រាំបាន បើចង់បានស្រីហើយមិនបានវិញនោះ កើតទុក្ខធំណាស់ ទាល់តែអត់បាយក្រហាយទឹក ដូចជាព្រះបាទបសេនទិកោសល ព្រះអគ្គមហេសីក៏មានព្រះស្ងួតមានច្រើនណាស់ កាលព្រះអង្គចង់បានស្រីម្នាក់ជាប្រពន្ធរបស់គេនៅស្បែរភ្នែព្រះនគរ តូចនិតសស្តេចយាងប្រទក្សិណព្រះនគរជួនជា

ពោលព្រះនេត្រពៅចំនាងនោះ កំទ្រេនកើតទុក្ខពាល់តែអត់ត្រាំមិនបាន
ឧឡឹកចាប់ស្រេដីថ្លដល់អ្នកឯទៀត ។

ម្យ៉ាងទៀត បញ្ហាពាលក្នុងទុក្ខនោះ សម្តេចព្រះបរមសាស្តាទ្រង់
ត្រាស់ថាជាទុក្ខពិត ។ ឧបាទានក្ខន្ធទាំងប្រាំនេះជាទុក្ខ ។ ទុក្ខមួយ ។ ឧឡឹក
គណនាមិនអស់ទេ ត្រាន់តែជាតិទុក្ខមួយ ហើយចេកចេញទៅទៀតមាន
ច្រើនណាស់ ។ អ្នកប្រាជ្ញតម្រិះសន្និដ្ឋានថា ក្នុងទុក្ខក្ខន្ធសូត្រមានបួនកង
មានជាតិទុក្ខជាដើម មានមរណទុក្ខជាទីបំផុត ។

ក្នុងព្រះធម្មចក្កប្បវត្តនសូត្រមានទុក្ខ ៨ កង មានជាតិទុក្ខជាដើម
មានឧបាទានក្ខន្ធទុក្ខជាបរិយោសាន ។ ក្នុងគម្ពីរអដ្ឋកថាជាដំណែ ។ មាន
គម្ពីរសម្មោហវិនោទនីជាដើម ព្រះអដ្ឋកថាចារ្យសំដែងអនុលោមតាម
ក្រសែព្រះពុទ្ធដីកាជាច្រើនណាស់ ។ អ្នកប្រាជ្ញតម្រិះសន្និដ្ឋានថា ទុក្ខ
ពាលក្បាយមានជាតិទុក្ខជាដើម សម្តេចព្រះបរមទេសនាលប្រទានព្រះ
សទ្ធម្មទេសនាថាជាទុក្ខពិត ពាប់បួលកង់ទុក្ខអរិយសច្ច ។

ក្នុងទុក្ខសមុទយអរិយសច្ច ព្រះពុទ្ធអង្គទ្រង់ត្រាស់ទេសនាដោយធម៌
ជាទីកើតនៃទុក្ខ ជារបស់ពិតនៃព្រះអរិយ ។ ហើយប្រែតាមពាក្យបាលី ស-
មុទយ អក្សរបួនតួនេះចែកចេញជាពីរបទគឺ សំ មួយបទ អក្សរមួយតួ,
ឧទយ មួយបទអក្សរបីតួ ។ សំ ប្រែថា ត្រម, ជាក្នុងទីមួយ, ថា
ល្អ, ថាក្រសែង, ថាប្រជុំជាដើម ។ ឧទយ ប្រែថា ជាទីកើត ។

អរិយៈ ប្រែថា បុគ្គលប្រសើរ ព្រោះថាតាំងនៅឆ្ងាយចាកតិរ៍ថ ។ សព្ទប្រែថា ពិត។ រួមចូលគ្នាទាំងអស់ជា សម្មុឯយអរិយសច្ច ជាន សេចក្តីថា ធម៌ជាទីកើតឡើងត្រាមនៃទុក្ខ, ជាទីកើតឡើងក្នុងទីមួយនៃទុក្ខ, ជាទីកើតឡើងដោយល្អ, ជាទីប្រជុំ, ជាទីកើត ឡើងក្រៃលែងណាស់, ជាទីប្រជុំកើតនៃទុក្ខ ជារបស់បុគ្គលអ្នកប្រសើរឆ្ងាយចាកតិរ៍ថ ។ បុគ្គលអ្នកឆ្ងាយចាកតិរ៍ថនោះ ជានឹងព្រះអរិយៈជាម្ចាស់ទាំងឡាយ មានសម្តេចព្រះភ្នំទ្ធអង្គជាប្រធាន ។

ធម៌ជាទីកើតឡើងត្រាមនៃទុក្ខនោះ សម្តេចព្រះបរមលោកុត្តមាចារ្យ ទ្រង់ត្រាស់ថា ជានឹងតណ្ហា ។ នោះមានបីប្រការ គឺសេចក្តីប្រាថ្នាក្នុងកាមតណ្ហា តាមតណ្ហា ១ សេចក្តីប្រាថ្នាក្នុងរូបតណ្ហា ភវតណ្ហា ១ សេចក្តីប្រាថ្នាក្នុងអរូបតណ្ហា វិភវតណ្ហា ១ ត្រូវជាតណ្ហាបីប្រការ តណ្ហាបីប្រការនេះ បើចាត់ដោយប្រភេទចែកចេញទៅជាមួយរយថែមទ្រាំបីឡើងទៀត រួមជាមួយរយទ្រាំបីប្រការ (១០៨) ។

តស្សតីតិ តណ្ហា ដែលហៅតណ្ហានោះព្រោះអត្ថថាញ៉ាំងចិត្តឲ្យគិតតក់ស្លុតស្ងប់ស្ងាត់មិនជាន គឺចិត្តមិនស្ងប់ ។ តណ្ហាបីប្រការនេះជាតួកធំ ហើយបែកខ្ញែកចេញទៅទៀតជាមួយរយទ្រាំបីប្រការ នេះឯងជាទីកើតឡើងត្រាមនៃកងទុក្ខ ជារបស់ពិតនៃព្រះអរិយៈ ព្រោះថាបើតណ្ហានៅមានដកជណា ទុក្ខក៏នៅមានដកបានោះ ។

កាមតណ្ហា សេចក្តីប្រាថ្នាក្នុងកាមភពនោះ គឺថាប្រាថ្នាក្នុងទីកើតដ៏ប្រកបដោយកាមគុណទាំង៥ប្រាំ គឺមនុស្សនិងសួគ៌ ។ ភវតណ្ហា សេចក្តីប្រាថ្នាក្នុងរូបភពនោះ គឺប្រាថ្នាក្នុងរូបព្រហ្មទាំងពីព្រហ្មបារិសជ្ជាឡើងទៅរហូតដល់ជាន់អកនិដ្ឋ ។ វិភវតណ្ហា សេចក្តីប្រាថ្នាក្នុងអរូបភពនោះ គឺប្រាថ្នាក្នុងរូបព្រហ្មទាំងប្លែនជាន់ នេះ មានអាកាសានញ្ចាយតនព្រហ្មជាដើម ។ សេចក្តីប្រាថ្នាក្នុងភពទាំងបី គឺ កាមភព, រូបភព, អរូបភព នេះឯងជាទីកើតឡើងព្រមនៃកងទុក្ខ មានជាតិទុក្ខជាដើម ។

មានភាសិតមួយថា សេចក្តីប្រាថ្នាក្នុងកាមភពដែលជាទីតាំងមកនូវទុក្ខនោះ ព្រោះថាកាមទាំងឡាយប្រកបដោយទុក្ខ គ្មានសុខសោះ សមតាមព្រះពុទ្ធភាសិតថា កាមតោ ជាយតេ សោ តោ សេចក្តីសោកនឹងកើតមានឡើង រមែងកើតព្រោះកាម, កាមតោ ជាយតេ ភយំ ភ័យនឹងកើតមានឡើង រមែងកើតព្រោះកាម, កាលសេចក្តីសោកនឹងភ័យកើតមានឡើងហើយ ទុក្ខរមែងកើតមានឡើងដែរ ។

ឯសេចក្តីប្រាថ្នាក្នុងកាមភពជាទីកើតនៃកងទុក្ខនេះ ល្មមនឹងឲ្យតិចារណាបានឃើញខ្លះ ។ ចំណែកសេចក្តីប្រាថ្នាក្នុងរូបភពក្តី ក្នុងអរូបភពក្តី សុទ្ធតែជាទីកើតនៃកងទុក្ខទាំងអស់ ក៏ល្មមនឹងតិចារណាឲ្យឃើញបាន នឹងឃើញថាជាទីកើតនៃកងទុក្ខដូចម្តេច ព្រោះឃើញថាមិនបានជាទុក្ខដោយបរិភោគអាហារជាដើម ។ អ្នកប្រាជ្ញតប្បីតិចារណាឲ្យឃើញ

ជាជាតិនាំមកនូវទុក្ខជាំនឹងអស់ ព្រោះហេតុមិនបានផុតពីទុក្ខមានជាតិទុក្ខជាដើម ។ បើបុគ្គលធ្វើការកុសលតិចបានតិចកុសលបានតិចណាន លុះលែងបញ្ចក្ខន្ធហើយ ក៏បានទៅកើតក្នុងរូបាវចរព្រហ្ម ទៅក្នុងរូបាវចរភូមិតាមកំណត់ក្នុងរូបាវចរភូមិនោះ ហើយចំណាយបញ្ចក្ខន្ធក៏រមែងមកកាន់បដិសន្ធិជាតិ លុះមកចាប់បដិសន្ធិជាតិហើយ ក៏ជាហេតុនឹងឲ្យបានទុក្ខមានតណ្ហាកន្ទិកទុក្ខជាដើម ។ ឯបុគ្គលអ្នកធ្វើការកុសល តែអរូបាវចរកុសលនោះតិ្ត កាលមានឈានមិនបានសាបសូន្យអស់ជីវិតន្ទ្រើយហើយទៅកើតក្នុងអរូបាវចរព្រហ្ម សោយសុខតែម្យ៉ាង ឥតទុក្ខ តែថាបើឆ្លងពីអរូបាវចរភូមិណា កំជាហេតុជាបច្ច័យឲ្យមកកាន់ជាតិ គឺបដិសន្ធិកំណើតមានទៅដូចបណា ទុក្ខក៏រមែងជាប់តាមទៅដូចបនោះ មិនបានរួចពីទុក្ខមានជាតិទុក្ខជាដើមទេ ។ ហេតុដូច្នោះ សម្តេចព្រះមានព្រះភាគទ្រង់ត្រាស់ថា សេចក្តីច្រើនក្នុងភពទាំងបី គឺ កាមភព, រូបភព នឹងអរូបភព ជាទីប្រជុំកើតឡើងនៃកងទុក្ខមានជាតិទុក្ខជាដើម ពាក្យថាជាទីកើតឡើងនៃទុក្ខពិត របស់ព្រះអរិយជាម្ចាស់ជាគំរប់តិរ ឈ្មោះថា ទុក្ខសមុទយអរិយសច្ច ត្រាស់ទេសនាក្នុងសច្ចយមក: ក្នុងតម្រាយមកនេះ ។

ទុក្ខនិរោធអរិយសច្ច

ទុក្ខនិរោធ ទុក្ខនិរោធអរិយសច្ច ទុក្ខនិរោធ.

អរិយសច្ចំ ទុក្ខនិរោធោ, ទុក្ខនិរោធោ ន ទុក្ខនិរោធ-
អរិយសច្ចំ, ទុក្ខនិរោធអរិយសច្ចំ ន ទុក្ខនិរោធោតិ ។
អាមន្តា ទុក្ខនិរោធោ ទុក្ខនិរោធអរិយសច្ចន្តិ ។

លំដាប់នេះ នឹងពណ៌នាភាពនៃទុក្ខនិរោធអរិយសច្ច ដែលមានភាព
ទុក្ខយមកៈតទៅ សេចក្តីថា ភគវា សម្តេចព្រះទ្រង់ព្រះភាគអនាវរ-
ណញាណទ្រង់ព្រះនាមថា ព្រះមានព្រះភាគ ព្រោះហេតុជាទីសេពគប់
នៃទេវតានឹងមនុស្សទាំងឡាយ. ដោយអំណាចនាំមកនូវសម្បត្តិបីប្រការ
ដល់បុគ្គលអ្នកសេពគប់ កាលព្រះអង្គត្រាស់ទេសនាទុក្ខសមុទយអរិយ-
សច្ចចប់ចុះហើយ ក៏លំដាប់នោះ ទើបទ្រង់ត្រាស់ ទុក្ខនិរោធអរិយសច្ច
តទៅ មានព្រះពុទ្ធដីកាត្រាស់បុច្ឆាជាដូច្នេះ ហើយត្រាស់វិសជ្ជនាជាដូច្នេះ ។

ព្រះអង្គទ្រង់ត្រាស់បុច្ឆាថា ទុក្ខនិរោធោ ទុក្ខនិរោធអរិយសច្ចំ
ការរលត់នៃទុក្ខនោះឬឈ្មោះថា ទុក្ខនិរោធអរិយសច្ច ទុក្ខនិរោធអរិយ-
សច្ចនោះឬឈ្មោះថារលត់នៃទុក្ខ ឬថាទុក្ខនិរោធនោះម្យ៉ាង ទុក្ខនិរោធ-
អរិយសច្ចនោះម្យ៉ាង, ទុក្ខនិរោធនោះមិនមែនជាទុក្ខនិរោធអរិយសច្ច ទុក្ខ-
និរោធអរិយសច្ចនោះមិនមែនជាទុក្ខនិរោធទេ ឬ មានប្រការដូចម្តេច ?

ព្រះអង្គទ្រង់ត្រាស់វិសជ្ជនាថា អាមន្តា ម៉ែ ! ទុក្ខនិរោធនោះឯង
ឈ្មោះថាទុក្ខនិរោធអរិយសច្ច, ទុក្ខនិរោធអរិយសច្ចនោះឯង ឈ្មោះថា

ខុក្ខនិរោធ, ខុក្ខនិរោធ ខីដ៏ខុក្ខនិរោធអរិយសច្ចនោះដូចគ្នានៃមួយ មិន
មែនផ្សេងគ្នាទេ ។

មានពាក្យអធិប្បាយថា ខុក្ខនិរោធ នោះប្រែថា ធម៌ជាទីរលត់
នៃខុក្ខ ។ ខុក្ខនិរោធអរិយសច្ច នោះប្រែថា ធម៌ជាទីរលត់នៃខុក្ខ
តិតរបស់ព្រះអរិយៈ ឈ្មោះថាជារបស់តិតនៃព្រះអរិយៈនោះ ព្រោះព្រះ
អរិយៈទាំងឡាយមានព្រះសម្មាសម្ពុទ្ធជាដើម រមែងត្រាស់ដឹងធម៌ដែល
ព្រះអរិយៈត្រាស់ដឹង ជាធម៌រលត់ខុក្ខបានតិតនោះមិនមែនដទៃឡើយ
ខ្លើយ បានន័យព្រះនិព្វាន ។ នោះរលត់ខុក្ខបានតិតមិនរឹមរិតប្រែប្រួលទេ ។

និព្វានសត្វនេះ បើប្រែសេចក្តីតាមបាលីថា ចេញាតតណ្ហា ជា
ហេតុស្រោចរួមរឹត ជាហេតុឲ្យសត្វវិលវល់នៅក្នុងវដ្តសង្សារ ។ បើ
តោលដោយបរិយាយមានពីរប្រការគឺ សឧបាទិសេសនិព្វាន ១
អនុបាទិសេសនិព្វាន ១ ។

សឧបាទិសេសនិព្វាននោះ បានន័យព្រះយោគាវចរកុលបុត្រក្នុងព្រះ
ពុទ្ធសាសនានេះ មានសេចក្តីត្បាយាមចំរើនព្រះវិបស្សនា បានសម្រេច
ព្រះអរហត្តផលអស់អាសវកិលេសជាសមុច្ឆេទបហាន ដល់ព្រះនិព្វានគឺ
ចេញាតតណ្ហាលត់បានតែកិលេសនៅមិនទាន់ចូលកាន់ព្រះនិព្វានដូច្នេះ
ឈ្មោះថា សឧបាទិសេសនិព្វាន សមដូចក្រសែព្រះពុទ្ធភាសិតដែលប្រ-
ទានព្រះធម្មទេសនាខុកក្នុងគម្ពីរឥតិវុត្តកៈថា ៨ ឥង ភិក្ខវេ អរហាំ

ហោតិ ទីឃាសវៈ ម្នាលភិក្ខុពាន់ឆ្នាំយ ភិក្ខុកន្ធឆដ្ឋាយនៈ
ជាព្រះខីណាស្រពអស់អាសវៈពាន់ឆ្នាំ គួរដល់សក្ការបូជាវិធី ជានៅ
ចប់ហើយនូវសាសនព្រហ្មចរ្យនឹងមគ្គព្រហ្មចរ្យ មានសោឡសកិច្ចធ្វើ
ស្រេចហើយ មានការៈគឺកិលេសដាក់ចុះហើយ មានប្រយោជន៍នៃខ្លួន
គឺព្រះអរហត្តផលជានដល់ហើយ មានសំយោជនៈដប់ប្រការអស់ហើយ
ផុតដោយបញ្ញាវិមុត្តិនឹងចេតោវិមុត្តិដ៏ល្អប្រពៃ តិដ្ឋន្តេវ នៅមានឥន្ទ្រីយ៍
ពាន់ឆ្នាំតាន់នៅឡើយមិនទាន់រលត់ បច្ចុក្កោតិ សុខទុក្ខំ នៅ
ជានសោយនូវសុខនឹងទុក្ខ ។ អ្នកប្រាជ្ញតម្រាំប្រាប់ថា អាការដែល
អស់ទៅនៃកាមតណ្ហានឹងចេតសៈមោហៈនៃព្រះខីណាស្រពនេះឯង តថាគត
ហៅថា សន្តចិត្តសមាធិ ។

ឯអនុត្តរចិត្តសមាធិនោះ មានព្រះពុទ្ធដីកាត្រាស់ថា ម្នាលភិក្ខុ
ពាន់ឆ្នាំយ ភិក្ខុកន្ធឆដ្ឋាយនៈ ជាព្រះខីណាស្រពគួរដល់សក្ការបូជា
ផុតដោយបញ្ញាវិមុត្តិនឹងចេតោវិមុត្តិដ៏ប្រពៃ រលត់ជីវិតិន្ទ្រីយ៍ចូលកាន់ព្រះ
និព្វានហើយ ដូច្នេះតថាគតហៅថា អនុត្តរចិត្តសមាធិ ។ ព្រះ
និព្វានមានន័យប្រការដូច្នេះ ។

ព្រះអមតមហានិព្វាននោះ បុគ្គលណាមួយមិនទាន់ជានដល់ព្រះ
អរហត្តផលញាណ ដូចជាយើងនេះអស់លោកអ្នកកល់គ្នាសព្វថ្ងៃនេះ

មិនបានឈ្មោះថាព្រះនិព្វានទេ មិនបានឃើញព្រះនិព្វានទេ ។ ឯព្រះនិព្វាននោះ ទំរាំឈើដល់បានចំពោះតែអរិយបុគ្គលតាំបុគ្គលដែលបានសម្រេចព្រះអរហត្តផលមួយភ្លែត សមដោយក្រសែព្រះពុទ្ធដីកាថា

ន ហិ ឯតេហិ គច្ឆេយ្យ អគតំ ទិសំ យានេហិ
យថាត្តនា សុទន្តេន ទន្តោ ទន្តេន គច្ឆតិ ។

សេចក្តីថា បុគ្គលមានខ្លួនខ្លួនទ្រាន់ហើយ អ្នកខ្លួនទ្រាន់ហើយ តើបានសម្រេចព្រះអរហត្តផលហើយ រមែងឈើគាន់ទិសដែលខ្លួនមិនទាប់ទៅឡើយ គឺព្រះនិព្វាន ដោយខ្លួនខ្លួនទ្រាន់ហើយ ដូចម្តេច បុគ្គលតប្បីឈើគាន់ទិសដែលខ្លួនមិនទាប់ទៅហើយ គឺព្រះនិព្វានដោយយានតាំងឡាយនេះដូច្នោះមិនបានទេ ។

ហេតុនោះ សម្តេចព្រះកតក់ច្រើនគ្រាស់ថា ជាវេស់លេត់ខុក្ខបានជាវេស់ព្រះអរិយៈ ។ រមែងគ្រាស់ដឹង ឈ្មោះថា ខុក្ខនិរោធអរិយសច្ច ជាតំរៃបំបែកដឹងសច្ចយមកនេះ ។

(នៅមានត)

សម្តែងព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង

ព្រះញាណកោសល ញាណ-ឈិន ពន្យល់

(តមក)

ឯមនុស្សទាំងឡាយ ដល់នូវគុណព្រះរតនត្រ័យជាទីពឹងទីរលឹកជាមុន ។ លុះធ្វើមរណកាលហើយ សឹងបានទៅកើតឯស្ថានសួគ៌លោកនាយទាំងអស់ បានសោយនូវទិព្វសម្បត្តិទាំង ១០ ប្រការ ដោយផលានិសង្សនៃព្រះត្រ័យសរណគមន៍នោះហោង ។

ព្រោះហេតុដូច្នោះ ទើបព្រះអរហន្តទាំងឡាយ កាលបើបានសម្តែងរឿងនិទាននេះចប់ហើយ លោកពោលនូវបទព្រះគាថាដូច្នេះថា :

ឥទ្ធោបិ ហានេន បិតកាសុ ឃរំ
កាន្តរ្បិន្ទវោ ចាបិ មហាឧកាវោ
តំលោកជាថសុ តថាគតសុ
មហាឧកាវោ ហិ អចិន្តនីយោ ។

អធិប្បាយថា គ្រាន់តែកំណាត់ឈើគឺព្រះចាវនៃព្រះសម្មុខដែលប្រតិស្ឋានក្នុងភពទុកចេតិយ ត្រូវមហាជនអ្នកបានឃើញជាទៀងស្មោះស្ម័គ្របួងសួង តាមហេតុគួរគឿ តទីមានអានុភាពសក្តិសិទ្ធិដល់ម្លេះ, ចំណង់

បើ ព្រះតថាគតជាទីតាំងនៃសត្វក្នុងវត្រគត (កាលព្រឹធ្លាមានទៅ) ទីឆ
មានអាទុកាតធំមិនគប្បីតិតគណនាបាន (យ៉ាងណាទៅ)

សម្តែងរឿងនិទានបុរសអ្នកចូលាព្រះបាទបិដ្ឋជាតុជាតំរេបើ ក្នុងវគ្គ
ទីបី កំចប់ដោយសង្ខេបតែប៉ុណ្ណេះឯង ។

x x x

๔- ឧត្តរសោមណេរវត្ថុកថា

សម្តែងរឿងនិទាន ឧត្តរសោមណេរ តទៅទៀត ដោយពាក្យថា
សោ កិរ បុរិមពុទ្ធេសុ កតាធិការោ ដូច្នេះជាដើម
អធិប្បាយថា មានឧត្តរសោមណេរអ្នកមានអភិនីហារកុសាឆសន្សុំកុសល
ក្នុងសំណាក់ព្រះអតីតសម្ពុទ្ធទាំងឡាយ មកជាច្រើនជាតិណាស់ហើយ,
កាលដែលអនុលោមទៅមកក្នុងសង្សារវដ្ត ហើយបានសន្សុំនូវកុសលកសិ
ដែលជាឧបនិស្សយធម៌យ៉ាងនេះ អាចផ្តាច់បង់សង្សារវដ្តចេញជ្រះស្រ-
ឡះហើយសំរេចព្រះនិព្វានបានដោយតិត ។ លុះដល់មកសាសនាព្រះ
មានព្រះភាគព្រឹធ្លាមសុមេធៈ កំបានឮតមកកើតជាវិជ្ជាធរមួយ
អង្គឯទៅអាស្រ័យក្នុងប្រទេសហិមភាន្ត ។

កាលនោះព្រះសម្ពុសម្ពុទ្ធព្រះអង្គប្រថ្នាយូរទីស្ងាត់ហើយស្តេចគ្នុ-
ដំណើរចេញទៅកាន់ប្រទេសហិមភាន្ត លុះដល់ហើយព្រះអង្គព្រឹធ្លាត់ផ្តត់

ព្រះក្នុងពែនព្រះជាខគន់នៅកន្លែងប្រទេសជាដីរហោឋាន ឥតមានមនុស្ស
ក្រឡើយ ។

កាលនោះវិជ្ជាធរនោះបានហោះចេញមកតាមអាកាសវេហាស៍ បាន
ឃើញព្រះសម្មាសម្ពុទ្ធទ្រង់មានរស្មីពាំង ៦ ពណ៌ ដុំរុងរឿងច្រាល
អស្ចារ្យឆ្ងៃនឆ្ពោះគួរជាទីអស្ចារ្យពន់ពេក ហើយមានចិត្តត្រេកអរជ្រះថ្លាបាន
បួងជាព្រះអង្គដោយយល់កណ្តាការពាំងឡាយជាច្រើនកន្លែងកាលនោះឯង ។

ដោយតេជៈនៃពុទ្ធានុភាព ផ្កានោះបានស្ថិតនៅពីខាងលើព្រះសិរ
នៃព្រះសាស្តាមានអាការដូចជាឆត្រយើកចាំងថ្វាយជាអស្ចារ្យដោយកុសល
ចេតនាដ៏សម្បយុត្តដោយចិត្តសទ្ធារបស់វិជ្ជាធរនោះឯង ។

ឯវិជ្ជាធរនោះសោត លុះដល់កំណត់កាលអស់អាយុក្សីណក្សយជាតែ
ពៅហើយ ក៏បានទៅពើតកន្លែងស្ថានតាវតឹង្សទេវលោកទាយ សោយ
ទិព្វសម្បត្តិជាសុខក្សេមក្សាន្ត អស់កាលជាយូរកន្លែងស្ថានសួគ៌នោះឯង ។
គ្រានតែអន្លើលពៅវិញពៅមកកន្លែងស្ថានសួគ៌ទេវលោក ទីឯស្ថានមនុស្ស-
លោកពាំងឡាយជាច្រើនជាតិ, លុះដល់មកកាលពុទ្ធប្បាទព្រះពុទ្ធជា
ម្ចាស់នៃយើងពាំងឡាយនេះ, ទើបវិជ្ជាធរនោះបានមកពើតជាបុត្តនៃ
ត្រកូលព្រាហ្មណ៍មហាសាលម្នាក់ កន្លែងតរកដត្រឹះ មានឈ្មោះប្រាកដ
ថា ទត្តរកុមារ ។

ឯទត្តរកុមារនោះ ទ្រង់ទ្រន់ខ្លាំរូបឆោមលោមពណ៌ដ៏ទត្តមសមស្មន់គួរ

ជាទីគួរគប់ចំណេះដល់ប្រជុំជន, លុះបានដល់ទូវាភាវជាកុមារដ៏ក្លៀវក្លា, ក៏បានសិក្សារៀនសូត្រចំណេះវិជ្ជា ប៉ែកខាងព្រាហ្មណ៍បានសំរេចចេះចាំស្ទាត់ហើយក៏តើតជាបុគ្គល គឺមនុស្សលោកតប្បីសរសើរសំដៅសីលនឹងមារយាទល្អដោយអំណាចចំណេះវិជ្ជា ដែលចេះដឹងដ៏សមគួរដល់ជាតិដោយភាត ។

កាលនោះ វស្សការព្រាហ្មណ៍ជាមហាមាត្យក្នុងនគរពេជគ្រឹះ បានឃើញទូវបញ្ញាសម្បត្តិនឹងរូបសម្បត្តិរបស់ទត្តកុមារហើយ មានសេចក្តីប្រាថ្នាចង់ឲ្យធ្វើតារបស់ខ្លួនធ្វើជាកំយៅនៃទត្តកុមារនោះ ទាំងបានចាត់មនុស្សទៅឲ្យដំណឹងដល់ព្រាហ្មណ៍ ជាមាតាបិតារបស់ទត្តកុមារនោះផង ដោយសមគួរតាមសេចក្តីប្រាថ្នារបស់ខ្លួន ។

ឯទត្តកុមារកំបានយាត់ទូវដំណឹងនោះ ព្រោះខ្លួនមានអធ្យាស្រ័យចង់រលាស់ចេញចាកកាម កុមារតែងចូលទៅអង្គុយក្នុងសំណាក់នៃព្រះសារីបុត្តត្ថេរ ដើម្បីស្តាប់ធម៌ទេសនាអស់កាលទាំងពួង, លុះបានស្តាប់ធម៌ទេសនាហើយ ក៏មានសទ្ធាកើតឡើងចំពោះខ្លួន ទើបលាមាតាបិតាចេញទៅបួសក្នុងសំណាក់ព្រះសារីបុត្តត្ថេរនោះឯង ។

លុះទត្តកុមារបានបព្វជ្ជាជាសាមណេរហើយ សឹងបរិបូណ៌ដោយវត្តប្រតិបត្តិល្អ ជាបុគ្គលប្រដៅដាយតែងបម្រើព្រះថេរៈដោយសេចក្តីគោរព។ សម័យមួយ ព្រះមហាសារីបុត្តត្ថេរមានអាពាធឈឺចាប់ចុកសៀត

កើតឡើងជាខម្ងួន ។ ឯឧត្តរសាមណេរនោះកាលបើដល់វេលាព្រឹកហើយ
ក៏កាន់យកចាត្រចីវរចេញពីវត្តទៅ ដើម្បីនឹងបិណ្ឌបាតតេសដ្ឋៈប្រគេន
ព្រះសារីបុត្តត្ថេរជាព្រះឧបជ្ឈាយ៍របស់ខ្លួន, ស្រាប់តែដល់ពាក់កណ្តាលផ្លូវ
ក៏ដំកល់ចាត្រចុះទៀបនេះស្រះមួយហើយចុះទៅស្ទឹងពីកមកលុបលាងមុខ។

កាលនោះ មានចោរម្នាក់ពាំដីកំលាយខ្លួរទម្ងន់លួចយកបង្ហិចកែវ
ចំនួន ៧ ប្រការក្នុងសំណាក់ស្តេចហើយរត់ទៅ ។ ពួកមនុស្សអ្នករក្សា គេ
ចាប់ជនហើយកំនាំគ្នាដេញតាមជាប់ប្រកិតខ្លួរចោរនោះ ឯចោរក៏រត់គេច
ចេញអំពីចំណាមទៅតាមទ្វារដែលចំហាយហើស ។ លុះចាប់ដល់ស្រះ
នោះហើយ រាយកបង្ហិចកែវចំនួន ៧ ដាក់ចុះក្នុងចាត្រារបស់ឧត្តរសាមណេរ
ហើយរត់ចាត់ទៅ ។

ចំណែកឯសាមណេរ កាលបើបានលុបមុខរួចហើយ ក៏ត្រឡប់ឡើង
តាស្រះមកវិញដើរចូលទៅរកចាត្ររបស់ខ្លួនក្នុងវេលានោះឯង ។ ស្រាប់
តែរាជបុរសអ្នកដេញតាមចោរក៏ទៅដល់ទីនោះដែរ ហើយបានឃើញបង្ហិច
កែវចំនួន ៧ ប្រការនៅក្នុងចាត្ររបស់ឧត្តរសាមណេរក៏គិតថា សាមណេរ
នេះប្រាកដជាចោរពិត អំពើចោរកម្មគឺសាមណេរនេះធ្វើហើយដោយខ្លួន
ឯងមែន ។ លុះរាជបុរសទាំងឡាយគិតយ៉ាងនេះហើយ ក៏ប្រគល់គ្នាចាប់
សាមណេរនោះចងសេក គីចងឲ្យមានដៃមកខាងក្រោយហើយនាំយក
ទៅប្តឹងចំពោះវិស្សការព្រាហ្មណ៍ក្នុងកាលនោះឯង ។

កាលនោះ វស្សការព្រាហ្មណ៍មានហាន.ជាអ្នកនៃជ្ជយ អាចបង្គាប់បញ្ជាឲ្យកាត់ដៃកាត់ជើងពួកជំបែកស្បាល ប្លន់លាយអាវៃយវៃភ្លូច ដំតាមទោសានុទោសបានឥតមានខ្ចើសខាល់ឡើយ ។

កាលបើវស្សការព្រាហ្មណ៍ឃើញទត្តសោមណោះនោះហើយ ក៏ស្គាល់ជាក់ថា ទត្តសោមណោះនេះ កាលនៅជាកុមារនៅឡើយ តុំបានអើតើខ្លួលស្តាប់តាមភាសារបស់អាត្មា ហើយចេញទៅបួសក្នុងព្រះពុទ្ធសាសនា ការបួសដោយសទ្ធាដូច្នេះ ទុកដូចជាជាប់អន្ទាក់នឹងដកហ្វាតុំរួចឡើយ ។ ដែលវស្សការព្រាហ្មណ៍តិតយ៉ាងនេះ ព្រោះតែសេចក្តីគំនុំគួនចងអាឃាដរបស់ខ្លួនពីមុនយ៉ាងនោះឯង តាត់តុំបានពិចារណាខ្លួអំពើទោសានុទោសនោះឡើយ, ស្រាប់តែបង្គាប់ពួកជបុរសតំាងឡាយថា: អ្នកតំាងឡាយត្រូវយកសាមណេរនេះតំាងរស់ទៅធ្វើទោសឲ្យដេកផ្ងារលើដែកស្រួច "គឺឈើអណ្តាត" ឲ្យស្លាប់ក្នុងដីតែទៅហោង ។ ពួកជបុរសតំាងឡាយបានស្តាប់ហើយ ក៏ចងបណ្តើរទត្តសោមណោះនាំយកទៅឲ្យដេកផ្ងារលើឈើអណ្តាតតាមបង្គាប់មហាមាត្យនោះឯង ។

ចំណែកឯទត្តសោមណោវិញ ឥតអង្គុយលើឈើអណ្តាតនោះហើយ ក៏តុំបានគិតអំពីសេចក្តីខុសរបស់ខ្លួនឡើយ គិតទីតែព្រះសារីបុត្តត្តេរជាព្រះឧបជ្ឈាយ៍ថា: អ្នកណាហ្ន៎! អាចនឹងនាំយកកេសដ្ឋៈមកប្រគេនព្រះឧបជ្ឈាយ៍របស់អាត្មាអញបាន ។

លំដាប់នោះព្រះមហាសាវ័កបុត្តវេរៈ ជាន់ជ្រាបហេតុនោះហើយក៏នាំយកសេចក្តីខ្នុះខ្នែងទាំងប្រាប់ខ្ញុំលួចចំពោះព្រះសម្មាសម្ពុទ្ធជាម្ចាស់ សូមទ្រង់ជ្រាបក្នុងកាលនោះ ។ លុះព្រះមានព្រះភាគជាន់ជ្រាបហើយ ក៏នាំយកសាវកចាំងឡាយជាច្រើន តាមមែព្រះអង្គក៏ជាន់តាមើលជ្រាជ្ញាតាស់ភ្លាដោយដុំវិញ្ញាបស់ទុគ្គរសាមណេរនោះ ជាន់ជ្រាបសព្វគ្រប់ហើយទ្រង់ស្រែតរកព្រះដំណើរយាងទៅដល់ខ័នោះឯង ។

កាលនោះ អ្នកនគរចាំងអស់ជាន់ដឹងថា ព្រះមានព្រះភាគព្រមចាំងព្រះភិក្ខុសង្ឃជាសាវកនិមន្តចេញទៅហើយ ក៏បបួលគ្នាចូលទៅប្រជុំព្រមក្នុងកាលនោះឯង ។

ឯព្រះមានព្រះភាគ ទ្រង់យកព្រះហស្តខាងស្តាំដែលមានព្រះអង្គុលីដ៏ខ្ងន់ល្ងន់ល្ងាស មានបណ្តាញរស្មីផ្សាយចេញអំពីផ្ទៃព្រះហស្ត ចាំងមានតន្ធឺហួរចេញមកតែនតង់ដូចជាវង់កន្ទុយក្អែក ពុំនោះសោតមានតណ្ហាដូចពីកជាតិហិង្គុល ខ្ចីងពីកមាស មកជាក់លើសិរសានៃទុគ្គរសាមណេរ ព្រះអង្គស្ទុបអង្អែលសិរសាចហើយទ្រង់ត្រាស់ថា ម្នាលទុគ្គរសាមណេរ ផលនៃសេចក្តីទុក្ខដែលកើតឡើងដល់អ្នកនាពេលបច្ចុប្បន្ននេះជាផលនៃបាបកម្ម ដែលអ្នកបានធ្វើពីបុព្វជាតិមកហើយនោះ ត្រូវតែអ្នកខំត្រាំអត់សេចក្តីទុក្ខវេទនាដោយកំឡាំងបច្ចវេក្ខណញ្ញាណ តាំងប្រាជ្ញាដែលតិចារណាយើញជាក់ច្បាស់ក្នុងអំពើបាបកម្មនោះឯង ។

(នៅមានត)

លោក ជឹម-ភន ចម្លងពីភាសាស្រ្តាស្ងឹកវែត

ព្រះភ្នំខ្វែង កើម-ភ្ងារ តិនិត្យ

(តមក)

តោធសត្វប្រើទៅថា តែឆ្នងទាំងឡាយ ឲ្យតែដឹងខ្លួនសភាពអាការនាយើងហើយតែឆ្នងមកហោង ។ រីយោងទាំងអម្បាលនោះ ខ្លួលយកខ្លួតាស្យទៅមហាសេដ្ឋអ្នកជ្រាជ្រហើយថា តំរកះ ។ តោក, យោងទាំងនោះសំតះហើយ ក្រាបលាព្រះមហាសត្វ នាំយកខ្លួតតិមានកាលណា យកទៅខ្លួគ្រឿងសាស្ត្រាវុធគេចចេញទៅហោង, កាលនោះ យោងទាំងឡាយទៅនាហានោះ នាំគ្នាចូលទៅកន្លែងឡាន ជាអ្នកប្រដាប់ដូចនន្ទុឡាន យល់ឥសូរសម្បត្តិលោកប្រដាប់សំភាប់ខ្លួកខ្លួរាជអាសនាស្តេចមួយយោនឹងមួយនោះ មានរាជអាសនាស្តេចបុលន៏ជាដើម ដំបូងត្រសាក់នៅទៅខ្លួរស្ងួតច្រត្រតែន៏មាលា ស្យេយោងអម្បាលនោះធ្វើអស់ប្រការទាំងពួង ដូចនិយាយតាព្រះមហាសត្វនោះហោង, យោងទាំងនោះ ករញ្ជោកបង្គន់ជាដំលោះប្រកែកជដែកគ្នា នឹងមហាជនឆ្នងទាំងឡាយ ហើយរត់ឆ្ពោះមកកាន់មិថិលានតរំញ ។ ចំណែកអាមាត្យស្តេចបុលន៏ ក៏រត់ទៅខ្លួលតតិមានស្តេចទាំងឡាយនោះ ។

ចុលនំព្រហ្មទត្តោ ឯវរូបស្ស ជាម មេ វិសយោ
តស្ស អន្តកយោ ភវេតិ តុដ្ឋិ ។ រីព្រះបាទចុលនីព្រហ្ម-
ទត្តកជ ស្តេចឮលំថា ចៅមហោសថនេះ ពាក្យឲ្យអន្តកយខ្លួរស្រា
ផ្សំថ្នាំពិសនៃអញ្ជានេះ នាចីហៅមានសភាគបន្លឺរដូច្នេះហោង ។ ៦
ស្តេចតាំងឮជាយដូចៃឮលំថា រីមហោសថ ពាក្យមិនឲ្យអស់អញផឹកស្រា
ជាយនេះបាននឡើយ ។ រីអស់តពួកពលយោធាសេនាផងតាំងឮជាយ
សឹងទីនឹងថា ឧ ! យើងអើយ ! មិនបានផឹកស្រាជាយ មានដំរៀបប្រសើរ
នេះឡើយ ។ ម្ចាំះហើយព្រះបាទចុលនីព្រហ្មទត្តកជ ស្តេចស្រដី
នឹងស្តេចផងតាំងឮជាយថា ភោ ម្ចាស់អ្នកតាំងឮជាយអើយ ! ចូរគ្នា
យើងតាំងឮជាយទៅមិថិលានគរនាយ យើងនឹងកាត់កយកក្បាលស្តេច
វិទេហរាជនឹងព្រះខាន់ យើងនឹងនៃគនដើងតំនើងនឹងអង្គុយលើ ហើយផឹក
ស្រាជាយបាន, តុម្ចា រីអ្នកចូរឈ្លាប់ធាប់ ។ ខ្លួរសេនាយោធាផង យើង
នឹងទៅហោង, រីស្តេចចុលនីលីលាទៅឋានស្ងាត់ តាប់ចិត្តគិតសំដែង
ច្រាប់ខ្លួរអាចិប្រស្នាការគំនិតនោះ នឹងអាចារ្យកេវដ្តព្រាហ្មណ៍ដូច្នេះថា
មហោសថ តាត់ធ្វើឲ្យអន្តរាយនៃគំនិតយើង មានសភាគបន្លឺរដូច្នេះនេះ
យើងនឹងទៅចាប់ក៏ជាសត្រូវនោះមកហោង, ស្តេចបន្ទូលថា ម្នែអាចារ្យ
អើយ ! ចូរមកយើងនឹងទៅមួយអន្លើជាមួយស្តេចមួយរយនឹងមួយ ខ្លួរតពួក
ពលសេកលយោធាផងតាំងឮជាយ ១៨ អក្ខោតនីជាបរិវារ ។ រីអាចារ្យ

កេវដ្តព្រាហ្មណ៍តើដឹងគិតសភាពនាអត្តាឯងជាអ្នកប្រាជ្ញ កំទើងអាចដើម្បី
ហៅខ្ញុំឈ្នះហើមហោសថអ្នកប្រាជ្ញនោះគ្មានឡើយ ហើយយើងខ្ញុំងឹង
ក្រឡាប់វិលមកកាន់ទន្លេយើងនេះ គួរតែប្តីឲ្យសេដ្ឋចាំងឡាយនោះ
ក្តាន់ហោង ។ លំដាប់នោះ, អាចារ្យកេវដ្តព្រាហ្មណ៍ទូលសេដ្ឋចន្លូ
តាក្សដូច្នេះថា មហារាជ បពិត្រមហារាជអើយ! រីសេដ្ឋចនៃយើងរាជ គេ
មានកំឡាំងនឹងសេដ្ឋចាំងឡាយច្រើន, មហោសថនេះគាត់ចេះគាត់តែងឹ
គ្រប់ប្រការ ឯចម្បាំងនោះមហិមាក្រែតបង្ហូះឡើយ ហើយគាត់មានអា-
ឧកាតនោះច្រើន នាព្រះមហោសថគាត់តែងរក្សាក្រុងមិថិលានគរ ដូច
រាជសីហ៍ចាំរក្សាគូហា យើងពុំអាចដើម្បីនឹងយកដោយខ្លួវប្រការមួយចនឹង
បាន; រីអាចារ្យកេវដ្តព្រាហ្មណ៍ទូលថា រីយើងខ្ញុំឲ្យសេដ្ឋចាំង
ឡាយ, រីដំណើរអ្នកនឹងទៅនាមិថិលានគរនោះមិនគួរក្តាន់ហោង, រីអា-
ចារ្យកេវដ្តព្រាហ្មណ៍ថាដូច្នេះ ។ មួយទៀតរីសេដ្ឋចមានចិត្តរឹងត្អឹង
ដោយជាក្សត្រាធិរាជ ហើយប្រហែលតឹងតែងសូរសេម្លត្តិគាត់, អញ
នឹងធ្វើម្តេច អញនឹងធ្វើសេដ្ឋចនេះឲ្យក្រឡាប់វិលមកបានដោយខ្លួវប្រការ
ដូចម្តេច ? ឯសេដ្ឋចចេញទៅខ្លួវសេដ្ឋចមួយយេនឹងមួយជាបរិពារ មួយ
អន្ទោនឹងតួកសេនាយោធាចាំងឡាយ ១៨ អក្ខោហិនី ។ សូម្បីអាចារ្យ
កេវដ្តព្រាហ្មណ៍ដឹងថាសេដ្ឋចនោះ ពុំអាចដើម្បីនឹងយកតាក្សអត្តាបាន
ឡើយ, អាចារ្យព្រាហ្មណ៍ថា នាប៉ះហៅនឹងទាស់សេដ្ឋចនោះមិនគួរ

ទ្បើយ, អាចារ្យកេវដ្តព្រាហ្មណ៍គិតដូច្នោះហើយ ក៏ចេញទៅមួយអន្ទឹ
ងដ៏ស្ដេចហោង ។ រីឯជាព្រះមហាសត្វចាំងអម្បាលនោះ មកតែ
មួយឯកត្រដាល់ម៉ិចិលានតរ ក៏សំដែងប្រាប់ពាមហោសថខ្លួនកិច្ចដែលអាត្ម
ាបានធ្វើនោះហើយ ។ ឯបុរសទុច្ចរិត្តពោធិសត្វនោះប្រើតតិមាន
មកប្រាប់មុនដូច្នេះថា រីស្ដេចចុលនីព្រហ្មទត្តរាជ នឹងមកចាប់ព្រះ
ចាទរិទេហរាជ, ព្រះចាទចុលនីព្រហ្មទត្តរាជមកនោះ មានស្ដេចមួយ
រយនឹងមួយជាចរិតារមានប្រការដូច្នេះ បណ្ឌិតអើយ ! សូមអង្គាស់កុំបី
ប្រហែសទ្បើយ ឥឡូវនេះ លោកមកដល់ហ៊ានមានឈ្មោះដូច្នេះ ។
លោកនឹងមកដល់ឥឡូវនេះហើយ រីឯបុរសជាទុច្ចរិត្តពោធិសត្វនោះ ប្រើ
តតិមានមកគុំដែលជាប់ទ្បើយ ។

តំ សុត្វា មហាសត្តោ អប្បមត្តកេ អហោសិ ។
ព្រះមហាសត្វអ្នកឮតតិមាននោះហើយ អ្នកឲ្យរណ្ដាប់សំពាប់មិនប្រហែស
ទ្បើយ ។ រីស្ដេចរិទេហរាជ ឮស្ដេចចុលនីព្រហ្មទត្តរាជ មកនឹងចាប់
យកនតរយើងនេះកូវ ឮសព្វនោះដំណាវរឿងទៅដល់ស្ដេចចុលនីព្រហ្ម-
ទត្តរាជ ។ លំដាប់នោះ, ស្ដេចចុលនីព្រហ្មទត្តរាជ ជាអ្នកប្រុងស្ដាប់ក្រែ
ស្ដេចលើកទ័ពគគុកសំរុកមកដល់ចាំងយប់ ស្ដេចឲ្យគាន់ខ្លួរក្ដីងគប់ចន្លុះ
ចាំងឡាយមួយសែន ជាបរិវារពាមភេមដុំអស់ចាំងនតរនោះ ឥតចន្លោះដ៏
លវន្លឹកដល់តិចទ្បើយ ។ លំដាប់នោះ, ស្ដេចចុលនីមកពាមស្ដេច ឲ្យ-

រៀបដំរីជាបន្ទាយ, រៀបសេះជាបន្ទាយ, រៀបរទេះជាបន្ទាយ ជាកំពូលពលជាដំបូងឯណោះហើយ ។ រីមន្ទុស្សធន៌ស្រែកឡើង អ្នកខ្លះរត់ដៃហៅ ខ្លះស្រែកគំរាមហើយបន្តទៅ ។ រីឯខ្លឹព្រះអាទិត្យ ក្តៅគគល់នោះប្រដាប់នោះក្តីអស់ទាំងកំឡាំងមិថិលានតរ ៧ យោជន៍ ក្តីជាតិខ្លីមួយនិមេ្លះហោង ។ រីសត្វទាំងឡាយដ៏រកើប គឺសត្វដំរី សត្វសេះ សត្វរទេះ សត្វគួរឲ្យតន្ត្រីកំលាន់ឮកងរំពងកក្រើកទាំងផែ្ទកក្រោម ។ ឧត្តរោ បណ្ឌិតា ឧស្សោសសទ្ធិំ សុត្វា អជានន្តា រញ្ញោ សន្តិំ កំ តត្ថ មហាភទ្ទ មហាភទ្ទោ ឧស្សាសសទ្ធោ ន ខោ បន ជានាម កិន្នាមេតំ រីមំសិតុំ វដ្តតិ មហាភទ្ទាតិ អាហំសុ ។ រីអ្នកច្រៀងទាំង ៤ ពួកនូវសត្វចេលវៃលៃឡើង មិនដឹងជាសត្វអ្វី ក៏ទៅកាន់សំណាក់ស្តេចទូលថា មហាភទ្ទ បពិត្រមហាភទ្ទអើយ ! បន មួយទៀតសោត ឧ ខោ ដូចអញឮគ្នាតនេះ, រីសត្វចេលវៃលៃឡើងនោះ យើងឮមិនដឹងហៅអ្វីមកលឯងយើង ។ ស្តេចស្តាប់នូវពាក្យអាចារ្យទាំង ៤ ហើយ មានបន្ទូលដូច្នេះថា ឧ ខោ ដូចអញគិតហើយ, រីស្តេចចុលនីសមគាត់មកហើយហោង, ស្តេចបន្ទូលអម្បាលនោះហើយ ស្តេចបើកសីហបញ្ជរតែន៍បវប្រសើរ ខតរមិលមើលដឹងជាស្តេចចុលនីមកដល់ហើយ មានព្រះវិយកតភ្ញាចបន្ទូលថា ន ! ដំរីតេយើនឮឯគ្នាន ឡើយ, ហើយបន្ទូលទៀតថា ឥឡូវនេះ អស់យើងទាំងអម្បាលនេះកំពឹង

លុះក្សីណវិតនោះ នាសែកឯងនហោង. ស្តេចបន្ទុលមួយអន្ទោនឯងអ្នកចាំង
៤ នោះហើយ ស្តេចគង់នៅហោង ។ បន មួយនន័សោត ព្រះមហា-
សត្វ អ្នកដឹងនូវស្តេចចុលនព្រហ្មទត្តកជគាត់មកដល់ហើយ ពោធិសត្វ
អ្នកឥតក្តីកង្វល់ចនូវអំណាចព្រះបាទចុលនោះដល់តំបន្តើយ, ស៊ីហោ
វិយ នទោឋគតាតដូចរាជសីហ៍ចេញពីគុហា អ្នកចាំរក្សាព្យាបាលអស់
ចាំងនគរនោះ, ហើយពោធិសត្វអ្នករំពឹងគិតថា អញនឹងទៅលួងលោម
ស្តេច, ហើយអញឡើងទៅលើកជម្ងឺរ សំតះស្តេច ហើយឋិតនៅ
ឰដ៏ឋានមួយហោង ។ រីស្តេចវិរទេហរាជយល់ព្រះពោធិសត្វហើយ មាន
ជន្លឹមចេញចូលសប្បាយកេះកយមានបន្ទុលថា រីអញនេះ ប៉ើរៀបចង់
ទឹងព្រះមហោសថជាកូនខ្ញែអញហើយ តើនឹងមានអ្នកឯណាជាខ្ញែ នាប៉
ហៅអាចដោះអញចុនអំពីទុក្ខដ៏ពន្ធឹកនេះ. ឯតិ្ត គ្មានឡើយ, ហើយ
ស្តេចបន្ទុលនឹងពោធិសត្វនូវតាថាជាបឋម, ឥមស្មឹ មហាឧទ្ធ្ងៈ-
ជាតកេ មានកូដ៏មហាទេមន្តិជាតកថា ៖

បញ្ញាសោ សត្វសេដ្ឋាយ ព្រហ្មទត្តោ សមាកតោ
សាយ បញ្ញាលិយោ សេដ្ឋា អបុ្បមេយ្យា មហោសធ ។
វិទ្ធិមតី បតិមតី សត្វសង្គាមកោវិទា
ឰហារិនី សន្ទវតី កោវិសង្គប្បពោធនា ។
សោហារិដ្ឋា អលង្ការ ឧដ្ឋិតា ភមកេបិនី

សម្បុយេមា សុសម្ផុន្នា ស្វរេមា សុបតិដ្ឋិតា ។
ឧសេន្ត បណ្ឌិតា អាហុ ភូរិបញ្ញា រហោគតា
មាតា ឯតាទិសី រញ្ញោ បញ្ចាលិយេ បសាសតិ។
អនុជ្ឈន្តេកសតំ ទ្វេ ភ្យា អនុយន្តា យសស្សិនោ
អដ្ឋិន្ទរដ្ឋា ឥធាគតា បញ្ចាលីនំ វសំ គតា ។
យំ វនា តក្កក រញ្ញោ អគាម មយ្ហកាលិនោ
បញ្ចាលមនុយាយន្តំ អគាមា វសិនោ គតា
តាយ សេនាយ មិថិលា តំសន្ទិ បរិវារិតា
ភដ្ឋានី រិនេហានំ សមន្តា បរិខញ្ចតិ ។
ឧទ្ទិ តារកជាតាវ សមន្តា បរិវារិតា
មហោសធ វិជានាហិ កថំ មោក្ខោ ភវិស្សតីតិ។

ម្នៃបាមហោសធអ្នកប្រាជ្ញអើយ! ឥឡូវនេះ ព្រះបាទចុលនីព្រហ្ម-
ទត្តក៏ជាអម្ចាស់នៃអ្នកបញ្ចាលកស្រុក លើកពលពាលចាំងក្រឡា-
មហាប្រឹថពី សឹងតែហ៊ានក្លា សេនាយោធាហានចាំង ១៨ អក្ខោហិនី
សឹងមានកំឡាំងមហិមាក្រៃពេក, រីសេនាយោធានោះសោត គឺតជាអ្នក
ប្រដាប់ខ្នើរទៅខ្លួនគ្រឿងអាវុធមុតថ្លា គឺជាឆន្ទៈណាប់ដោយខ្លួនប្រាជ្ញ
ខ្លាំង, រីសេនាថ្មើរដើរនោះសោត សឹងឈ្លាសខ្លួនការសង្គ្រាមចាំងពួង
មានកំឡាំងឆ្មៃបនាប់ដូចខ្យល់ គោះទឹងស្ទុះទៅឆ្ងាំង ទឹងកំណរប្រាក់

ចាប់ចាន់អាវុធរត់ចូលទៅកណ្តាលសត្រូវ កាត់កយកក្បាលសត្រូវនាំ
ចេញមក កំពុងឲ្យសត្រូវនោះជិនខ្លួន, ពោះនឹងចេញច្បាំងក្តី ចូលច្បាំងក្តី
សឹងដំប្រឿនស្លាត់ប្រយ័ត្ន សឹងស្តាប់ស័ង្ខ ខ្លាំសូរគេរ៉ាំព្រួយស្រដី ស្តាប់
តែស័ព្ទនោះ ជាសំគាល់អស់សេនាចាំងអម្បាលនោះហោង, ហៃហៅ
មហោសថអើយ ! រីគ្រឿងប្រដាប់សេនាផង គឺជាងដែកប្រដាប់ក្រោះ
ក្រាយ ខ្លាំមួកជាត់ជាយសេះសោផង សឹងតែរចនាដោយខ្លាំតន់ចាំង ៧
រុំនរឿងល្អប្រពៃ, ហើយប្រដាប់ខ្មៅខ្លាំខ្លាំជាមាស ខ្លាំជាប្រាក់
គិតជាអ្នកឡើងចង់លើចន្លោលភជរថ, រីសេនាសេះសោត សឹងតែរបៀន
ខ្លាំស្លាត់ប្រយ័ត្នខ្លាំចម្បាំង, ពោះយោធីនឹងស្ទុះឡើងលើខ្នងសេះសោត
សឹងលោតឡើងខាងស្តាំ.ឆ្វេង ពុំជាន់ឈ្នាន់ក៏សឹងបាន ហើយមានប្រាជ្ញ
ចេះសិល្បៈចាំង ១៨ ប្រការ គឺ: សិល្បៈដំរី សិល្បៈសេះជាដើម សឹង
ចេះមន្តមាយាចាំងពួងសត្វគ្រប់ហោង, ហៃហៅមហោសថអើយ ! រីស្តេច
មួយរយនឹងមួយ សឹងមានខ្លាំសេនាយោធាផងច្រើន តែងក្រើនប៉ំរ៉ា
ហែនៃស្តេចចុលន័ត្រហ្មទត្ត បើតាត់នឹងប្រើក្នុងការអ្វី ។ ក្តី អស់ស្តេច
ចាំងនោះបើខុកជាពុំមានចំណង់ក្តី កំលុះខ្លាំអំណាចតាត់ហោង, មួយ
ទៀតសោតស្តេចចុលន័ត្រហ្មទត្តកដ តាត់មានបុត្តីព្រះបាទមីអាទុតាតមហិមា
ប្រកបខ្លាំប្រាជ្ញាឈ្លាសវៃដឹងឥសរហានចម្បាំង ប្រកបខ្លាំកំឡាំងមហិមា
ប្រដាប់អាត្មាតាត់ខ្លាំចក្តីភ័យក្រោះដែកណាជាន់ប្រពៃ, ប្រដាប់ខ្លាំខ្លាំដ៏ធ

ស្លូតប្លឺត្រប្រកិតឆ្នេរ-ស្តាំ លលាំបួលមកពោមរោមម៉ិចលោភជាន់ ប្រកិតខ្លួរត្រឿងអាវុធត្រប់ដៃ កន្ធរចំណោមដំរី ចំណោមរះ ចំណោមរះខ្លះផងស័ត្វតែងជួចជាខ្លឹងភ្លូកប្រើថភ្លីស្រួតមិចលាបប្លីនៃះយើងឡើងបាបជ័យ ខ្លឹងមិនតង់ដីតែរស់រួចអំពីក័យម្តងនេះទេ, ហៃហៅមហាសច្ចៈអើយ ! រីរសេនាយោធាផងគេចោមជុំវិញ សឹងតែមានដៃកាន់ខ្លួតែប់ក្លៀងក្លីប្រសព្វគ្នាក្រៃលែងសែនសល់ ឃល់ភ្លឺនោះត្រាងត្រាយដូចផ្កាយនាកណ្តាលអាកាសតាសតាំងប្រើថពី; ហៃហៅមហាសច្ចបុត្រសំឡាញ់តេញចិត្តអាតុកអើយ ! អ្នកគិតដូចម្តេចកំនំងឲ្យបានរួចអំពីក័យសត្រូវនេះបាន; ហៃហៅមហាសច្ចបុត្រសំឡាញ់អាតុកអើយ ! រីរស្តេចចុលនីនោះ, ក៏រ ដូចយើងបានឮមកថា ឧស បណ្ឌិតា មានអ្នកប្រាជ្ញ ១០ នាក់ ភ្លូវបញ្ញា មានប្រាជ្ញាដូចផែនដី, រីមានាទៃស្តេចបញ្ញាលមានប្រាជ្ញា តែងប្រដៅស្តេចនោះ, ឯកាទសី ជា ១១ នាក់, រីអ្នកប្រាជ្ញទាំងអម្បាលនោះ នោះយោបើហៅអង្គុយនាហានស្ងាត់ គិតតែ៦ថ្ងៃ ៣ថ្ងៃ, នោះទំនងប្រែប្រើថពីនោះក៏សឹងបាននោះហាង, ហៃហៅមហាសច្ចៈអើយ ! ខ្លឹងមានអ្នកដទៃឯណាមួយមានប្រាជ្ញាឃល់ស្មើគ្នា ឯក្រោមដកបដល់អរិចនរក ឯលើដកបដល់អកនិដ្ឋព្រហ្ម នាបើហៅជាអ្នកប្រាជ្ញខ្លឹងណាសខ្លួតលទ្ធបានោះស្មើបានខ្ន, ឯក្តី គ្មានឡើយ, បណ្ឌិតកាកេ ជាម នាបើហៅជាអ្នកប្រាជ្ញ ឃល់ប្រាកដខ្លួប្រាជ្ញាមានសភាពដូច្នេះ ។ ស្តេច

បន្ទូលថា ហេតុនោះហោង យើងនឹងធ្វើឲ្យព្រះបាទដោយប្រការម្តេច? ។

ពោធិសត្វអ្នកស្តាប់ព្រះបន្ទូលព្រះមហាសត្វក្រដូច្នេះហើយ អ្នកគិតថា ស្តេចនេះកំតភ្លើចគ៌យនឹងស្លាប់នោះក្រៃពេក បន មួយទៀតសោត ឯ ខ្លា គឺដោយខ្លួនឯង, រីពេលផងតាំងពីក្មេង តែងជាពាក់នៃអ្នកដ៏មានជម្ងឺ ព្យាធិ សូម្បីតែជាហារត្រកាលពីសោ តែងជាពាក់នៃអ្នកឃ្លាន, រីឯកសោត ជាពាក់នៃអ្នកផង, ឥមសច្ចបិ វញ្ញោ មំ ឋបេត្វា អ-ញ្ញោ បដិសរណំ រីស្តេចវិញ្ញូទេហកជនេះ បើវៀរលែងអញហើយនឹងមានអ្នកឯណាមួយតែងជាពុំខាក់, ឯត្ថ គ្មានឡើយ, ពោធិសត្វថា បើដូច្នោះ អញនឹងលោមស្តេចហោង ។ លំដាប់នោះ, ព្រះមហាសត្វពុំភ្លក់ភ្លើតភ្លើច ពូលព្រះមហាសត្វនូវពាក្យនេះនាឋដូចពាជសីហ៍នៅលើថ្មមនោ-សិលាថា មហារាជ បពិត្រមហារាជអើយ! កុំបីអង្គាស់ខ្លាចឡើយ, ចូរអង្គាស់សោយពាជសម្បត្តិឲ្យស្រណុកហោង ហើយអញខ្ញុំនឹងបណ្តេញអស់សេនាយោធាទាំង ១៨ អក្ខោហិនីនេះ អញខ្ញុំនឹងធ្វើឲ្យព្រាត់នឹងអង្គាស់ឲ្យរួចទៅតែពេលខ្លះ តនិ្តតែសំពត់មួយចង្កេះនេះ ចបមាដួចបុរសកាន់កំណាត់ឈើប្រកួតដ៏ដុំធ្ងន់ស្ងាត់, ឬដួចបុរសមួយកាន់យកស្នាធបង្ហិញក្អែក, អាហ ខើបអ្នកសូត្រ ឯវំ គាថំ ខ្លួតាថា ជាគំរប់ ៤ ដូច្នេះ:

ថានេ នេវ បសារេហិ ភុញ្ជ កាមេ រមស្សុ ច
ហិត្វា បញ្ចាលិយំ សេនំ ត្រុញ្ចនត្តោ បលាយតីតិ ។

ឱ! បពិត្រមហាកដអើយ ! សូមព្រះអង្គ្រាសសណ្តែកទូវព្រះចុង ហើយសោយទូវតាមគុណដោយទូវចំណង់ឲ្យសុខសប្បាយហោង, អញនឹងនិមន្តញ្ញទូវស្តេចចុលនីព្រហ្មទត្តកដ ហើយឲ្យលះបង់ចោលទូវសេនាយោធាបញ្ញាលនតាង់ឆ្ងាយហោង ។

រំលៅមហោសថ អ្នកលាមស្តេចហើយ អ្នកចេញទៅឲ្យទូវដ្ឋស្តេរតេរ៉ ឲ្យមនុស្សតាំងឆ្ងាយលេងល្បែងមហាស្រេត ហើយតោងសត្វអ្នកស្រដីនឹងមនុស្សតាំងឆ្ងាយថា អន្លោ ម្នាលអ្នកតាំងឆ្ងាយអើយ ! កុំបីអ្នកចាម្តេឡើយ, ចូរអ្នកតាំងឆ្ងាយប្រដាប់ចាយទឹក ទូវតោជនាហារនឹងគ្រឿងគន្ធតាងោរ ណ្តាប់ដំកល់ទុក ហើយថ្ងៃនេះលេងមហាស្រេតឲ្យបាន ៧ ថ្ងៃ ។ រីមនុស្សផងទៅមាហានោះ សឹងផឹកស្រាច្រើនដោយឆ្អើលេងគន្ធត, រំលៅតំថ្ងៃផងតាំងឆ្ងាយនោះ ខ្លះប្រឿង ខ្លះកំ ខ្លះស្រែកហោ ខ្លះខះដៃ; សូម្បីល្បែងតាំងឆ្ងាយ កំនឹងចាងប្រាប់អតីតចំណេះនៃអញហោង, តោធិសត្វលោមអ្នកនតាង់ឆ្ងាយថា ឆ្មុម្ចា ចូរព្រះស្តេងមើលមើលអានុភាតនៃអញ, អហំ រែអញឈ្មោះរំលៅមហោសថអ្នកប្រាជ្ញ ខេះតែម្នាក់ បិតនៅតូវ ឮទូវសំតូតាំងឆ្ងាយ មានសំតូរជ្រាំប្រឿងកំជាដើមនៅកងនតរ ។ រីមនុស្សតាំងឆ្ងាយដាក់ទុកដោយឲ្យមើលកលសត្រូវខេះឥតឯគណាចាងខ្លើយ , ហេតុនោះហោង រីសត្រូវនឹងសម្លាប់នាំទៅក៏ឥតបីសម្លាប់ចាងខ្លើយ; ចូរទៅតាមតូវបន្តិច ចូល

ទៅកន្លែងគន្លោះហើយ ឃើញអ្នកផងចាំងឡាយសឹងអង្គុយលេងមហោស្រព ។ សូម្បីឮស័ព្ទជាកោលាហលក្នុងព្រះនគរគន្លោះហើយក៏ព្រះបាទពុលទីបន្ទូលទៅនឹងអាមាត្យ ខ្លួវាក្យដូច្នេះថា អម្ចាស អមច្ចៃហៃទៅអាមាត្យអើយ ! ក៏សេនាយោធាចាំង ១៨ អាក្ខកិនី ឃើញពាមនគរបែកនៅហោង, រីអ្នកក្នុងនគរគន្លោះ ខឹងតតស៊ីយក្តី ខឹងត្រួតអរក្តី, ឯតុំ គ្មានឡើយ; មនុស្សផងចាំងឡាយមានចិត្តត្រួតអរ ខ្លះលះដៃ ខ្លះវាស្រែកហៅ ខ្លះវាស៊ើប ខ្លះវាច្រៀង ខ្លះវាក់; រីមហាសថវាឮធ្លាប់ហៅអំពើអ្វីដូច្នេះ ។

លំដាប់នោះ, រីបុរសជាទុបនិក្ខិតនៃពោធិសត្វ វាស្រដីពាក្យក្លែងខ្លួលស្តេចពុលទីព្រហ្មទត្តជ ខ្លួវាក្យដូច្នេះ ឱទេវ បពិត្រមហារាជអើយ ! យើងខ្ញុំចូលទៅកាន់នគរតាមទ្វារ បន្តិចមើលឃើញអំពើមួយ មហាជនចាំងឡាយអង្គុយលេងមហោស្រព យើងជញ្ជឹងដូច្នេះថា អម្ចាស ម្ចាស់អ្នកចាំងឡាយអើយ ! អស់ស្តេចចាំងសកលជម្ពូទ្វីប មកចោមរោមជាបរិវារនគរអ្នកចាំងឡាយបែកនៅហើយ តើអ្នកចាំងឡាយកុំប្រហែសគេកហ៊ោះហៅអំពើដូច្នេះអ្វី ? រីមនុស្សផងចាំងឡាយនោះ គិតយើងស្រដីដូច្នេះថា រីស្តេចនៃយើង គាស់នៅក្នុងឡើយ ខំខុតខុចចិត្តនូវតែក្តីច្រូងច្រាំមួយ មានច្រើនដ គេថាដូច្នេះ អស់ស្តេចចាំងសកលជម្ពូទ្វីប មកចោមរោមជាបរិវារនគរយើងនេះ ក្លែងប់លេងវិស្សុតមហោស្រព បពិតហ្ន៎នោះហោង,

អដ្ឋ ថៃថ្ងៃនេះ, រីខ្ញុំគចិត្តប្រាថ្នាថៃនេះស្តេចយើងនេះ ខ្ញុំលុះស្រេចបរិបូណ៌, ព្រោះហេតុនោះហាង តោងសូមឲ្យខ្ញុំស្តេរតើ ឲ្យអ្នកផងលេងមហោស្រព, រីខ្ញុំវិតោងសូមឯងសោត តែងដំខ្ញុំដឹកស្រោច្រើនគ្នាលើក្បាលំនាល់ធំ ។ ស្តេចបុលនីប្រហ្មទត្ត ស្តេចស្តាប់តាក្យអាមាត្យនោះហើយ ក៏ទ្រង់ឮាល់ជង្គឹប់ប្រើសេនាយោធាទាំងឡាយថា តោះឡើង ម្នាលគ្នាយើងទាំងឡាយអើយ! អ្នកចូរទៅធាប់ប្រញាប់ចូលទៅចាមរកមនុតនោះឯអាយឯងាយ ខំលាយខ្លួរគួបន្ថាយ បើកខំលាយក្លាងគ្មារ តាស់ចូលទៅឲ្យបានក្នុងនគរនោះ កាត់កយកក្បាលស្តេចវិទេហរាជ អញ្ជាស្តេចណាស់ហ៎: ព្រះស្តេចទាំយកក្បាលមហាជនផងទាំងឡាយ ដឹកនីងរទេះចូលមកឲ្យបានមួយរយេ ដូចគេដឹកឆ្នាំងចុាយ ។ រីយោធាហានទាំងឡាយ ស្តាប់តាក្យស្តេចបន្ទូលដូច្នោះហើយ ជំមានដៃកាន់ទីទៅខ្លួរគ្រឿងអាវុធមានតណាផ្សេង ។ ហើយទៅខៀបភ្លាងគ្មារ, រីបុរសសេនាចាមហោសថអ្នកប្រាជ្ញ ណាប់ខ្លួរគ្រឿងអាវុធទាំងពួង ខ្លួរសាវទំនើចតីដុំថ្ម ថ្មដា ថ្មអាន អំបែងទេះ អំបែងចាន គ្រួសរោន ខ្ញុំនុះចោះខ្ញុំនចោលឥតក្រែងឡើយ, រីសេនាយោធាស្តេចបុលនីឯងឆាំ ឃើងចុះទៅកុងគួនោះ ហើយទៅឡើងអំពីគួនោះ យើងនឹងខំលាយខ្លួរបន្ថាយចាមមហោសថហោង, រីឯសេនាយោធាចាមមហោសថអ្នកប្រាជ្ញនោះមិញ សឹងបិតនៅតាលផ្ទៃកខ្លាងគ្មារបន្ថាយនោះ តំសឹងចាក់ខ្លួរស្នូលកែងដាវសាវកេងូរផង

ប៉ុន្មានដងទៀតសង្ឃឹមថាមានច្រើន ។ រីឯយោធាចៅមហាសេដ្ឋអ្នកជ្រាបដូ អ្នកខ្វះកន្លឹញ ដៃអ្នកខ្វះបង្ហិញដុំដៃចៅកាន់យោធាស្តេចចុលនី ស្រែកដេរថា តុម្ដេ ហៃព្រះស្តែនអើយ! អ្នកមកអំពីលំបាកព្រួយ មិនបានបាយហូបដល់តិច ហើយចូរព្រះស្តែនមកធ្វើត្រាសាច់ ចូរមកផឹកស្រាអ្នកខ្វះប្រាក់បានខ្លួចច្រើនលើកដង់រង់បង្ហិញចៅនោះ, រីអស់អ្នកចាំនអម្បាលនោះ ផឹកធ្លាយាំងរអឹក ហើយដើរចៅដើរមក ចំអើតលើភាគបន្ទាយ ។ រីសេនាយោធាស្តេចចុលនីពុំអាចដើម្បីនឹងធ្វើអ្វីគេដល់តិចក៏ស្រែកដើរចៅកាន់សំណាក់ស្តេចចុលនីថា ខេវ បពិត្រមហាកដអើយ! បើរឿប៉ុន្តែនឹងឱ្យអានុភាពអម្ចាស់ហើយ តើនឹងមានស្តេចដទៃឯណាមួយក៏អាចនឹងចាមចាប់ជាន ។ រីស្តេចចាំនៅអស់ ៤.៥ ថ្ងៃ មិនយល់ឡើយ ក៏គួរតប្បីនឹងចាប់ឱ្យជាន់ចៅកូវ, ស្តេចដណ្តឹងអាចារ្យកេវដ្ដព្រាហ្មណ៍ថា អាចរិយ ហៃអាចារ្យអើយ! ធ្វើដូចម្ដេច? រីយើងនេះ ពុំអាចនឹងចាប់ស្តេចវិទេហកដនោះជាន, សូម្បីនឹងមានអ្នកពួកែណាមួយនឹងអាចដើម្បីចូលចៅចាប់ជាននោះក៏គ្មានឡើយ ។ អាចារ្យកេវដ្ដព្រាហ្មណ៍ទូលស្តេចចុលនីថា បពិត្រមហាកដក្សត្រថ្ងៃច្រើរអើយ! ពោះយោបើដូច្នោះ រីអាថិទុជាយកលមួយណានាបន្ទរនេះ មានទំកន្តែងត្រៅនោះឯងអេះ, ចំណោះនេះ យើងនឹងចាប់ឱ្យជាន់តែនឹងបង្ខំតំពីរនេះហាង, មនុស្សផងទាំងឡាយនៅក្នុងនគរនោះ ក៏នឹងលំបាកដ្បិតឥតទំកផឹករហ័យចេកគ្មារ

ដេញមក ទំនើងយើងចាប់ចាន់ផាយក្តាត់ ទឹងតែតអ៊ូរៀយ ។ ម្ចាំះហើយ
ស្តេចខ្ចួលយកតាកុសអាចារ្យកែវព្រាហ្មណ៍ថា ឯបុយកលនេះជាឯបុយ
ល្អប្រពៃហោង ។ ចាប់ដើមអំពីថ្ងៃនេះទៅ យើងនឹងបង្ហាទឹកចូលមកឯង,
យើងឯណោះចំណោះយើងនេះយល់ល្អក្រៃអេះ ។ ម្ចាំះហើយបុរសជាឧប-
និក្ខិតចៅមហោសថសរសេរសំបុត្រប្រើតតិមានខោះឲ្យទៅបងនាត្រកៀក
គាំបញ្ជូនទៅផ្តាំដូច្នេះថា បើនអ្នកឯណាយល់សំបុត្រនាត្រកៀកគាំនេះ
ឲ្យរើសយកទៅបង្ហាញចៅមហោសថជាដើម ។ អថេ តោ បុរិសោ
តំ ឯស្វា កហេត្វា បណ្ឌិតស្ស ឧស្សេតិ ។ លំដាប់នោះ,
មានបុរសម្នាក់យល់សំបុត្រនោះហើយ នាំទៅបង្ហាញចៅមហោសថអ្នក-
ប្រាជ្ញ ។ រីពោធិសត្វអ្នកដឹងពតិមានខោះជាក់ហើយថា រីអាចារ្យកែវព្រ-
ព្រាហ្មណ៍នោះ មិនដឹងខ្លួសគាតអញជាមហោសថអ្នកប្រាជ្ញនេះទេហ៎:,
ថាដូច្នេះហើយ កំពោធិសត្វអ្នកឲ្យយកនំទៅខ្លួបូស្សីប្រវែងហុកសិបហត្ថ
ហើយអ្នកឲ្យពុះជា ២ អ្នកឲ្យដុះថ្នាំដ៏ចរសុទ្ធល្អហើយ អ្នកឲ្យផ្តាំបំបូល
គ្នាដដែលវិញ ឲ្យបងាកំបោសលាបកកំងលើ, រីពួជកុមុទដែលមហា-
ប្ញសីមានបុប្ផីអាទុភាព ឲ្យនាំមកអំពីព្រៃព្រះហិមពាន្តមានទៅស្រះខោះ ឲ្យ
ដាំទុកនាតកំនេស្រះបុក្ខរណី ឲ្យទុកចុះក្នុងបូស្សីខោះហើយ ឲ្យចាក់
ទឹកបំពេញមាល់មាត់ឯលើហោង ។ រីកុមុទខោះ លួតទៀងតែមួយយកត្រី

ផ្កាផុសឡើងអំពីមាត់ចំពង់នោះ មាត្រហាក់ដូចជារតនវត្ថុហើយកំប៉ិតខៅ ។ លំដាប់នោះ, តោងសត្វអ្នកឡេីយកផ្កាកុម្មុទនោះ ទៅថ្វាយនៃអាគន្តុផ្កាដូច្នេះថា តុម្ហេ ម្ចាលអាគន្តុអើយ ! ចូរឡេីងផ្កានោះទៅស្តេចបុលន្ទីព្រហ្មទត្តជានោះហោង ។ រីបុរសនោះ ធ្វេីជាឆ្ងាយទន. ផ្កាកុម្មុទនោះហើយបោះទៅនិយាយថា អម្ភោ ម្ចាលព្រះស្តេងអាគន្តុតែងចំរេីងតស្ងួនីងស្តេចបុលន្ទ ចូរព្រះស្តេងយកផ្កាកុម្មុទត្សលនេះទៅទ្រេីសស្តេចសៀតត្រចៀកលេង ថាបេីស្តេចឃ្លានទ្រេីងនឹងផ្កាកុម្មុទនោះចុះ ចំពេញនោះកុំទ្រេីសស្ងាប់ ។ មានបុរសមួយតែងចំរេីនៃបុរសជាទុបនិក្ខិត្តទៅមហោសថនោះ រេីសយកផ្កានោះទៅថ្វាយស្តេចទូលថា ឧបជ្ឈាត្រអើយ អញ្ជេីញអម្ចាស់អ្នកឡេីងទៅមេីល ផ្កានេះមានទងវែងសភាពបង្គួរដូច្នោះនោះ យេីងតុំដែលយល់អំពីមុនមក, រីបុរសនោះ កំពុលស្តេចនូវពាក្យលេីកប្រការអម្បាលនោះហើយកូវ, បុរសជាទុបនិក្ខិត្តទៅមហោសថធ្វេីទងផ្កាកុម្មុទប្រវែងហុកសិបហត្ថនោះ បន្ទូនចេញបានទៅជាបែតសិបហត្ថវិញហោង ។

(នៅមានត)

ប្រវត្តិព្រះពុទ្ធ ទំនួ សង្គ្រាមអសុរ

លោក ជ.ល-ធិត នៅភូមិសាស្ត្រឧបល្លាំត្ស

និពន្ធដាក់ជាកម្មវិធីតាមសេចក្តីក្នុងឯកសារសោត្ថិបន

រឿងយដីកា សមន្តប្បាសាទិកាវណ្ណនា

ប្រវត្តិព្រះពុទ្ធ ទេវិភជ
ដែលវិភជអំណាច នៅសូត្រ
ទំនួអសុរយុទ្ធ ដោយយោធា
ក្នុងមិត្រាល់ថ្នា កំណត់ដឹង

រឿងនេះមានចែងថ្លែងក្នុងអត្ថ

គម្ពីរសោត្ត បទដីកា ជារឿងពីកេះចាប់ចំណ្តា
ជួបជាគម្រោយទ្ធសាស្ត្រ ។ តាមរឿងដំណាលពីព្រេងព្រឹទ្ធ
អតីតកន្ទួងយូរលង់ណាស់ ជារឿងនិពន្ធដំនាន់ចាស់

និពន្ធជាគំប្លាស់និយាយថា ៖

កាលដំណាលពីដើមកាល មានចៅមាណពម្នាក់សោភា
គេហៅ មឃៈ កាល់ ១ គ្នា នៅនាស្រុកឈ្មោះអចលគ្រាម ។
គាត់មានភរិយាគ្នាបួននាក់ ខ្លះមានមិត្រភក្តិមិនជាក់នាម
ដែលស្មោះស្ម័គ្រខ្នួនចំនួនសាម. សិបពីរនាក់តាមគម្ពីរថ្លែង ។

គាត់ធ្វើជាចុងជនបទ[1] ដែលស្តេចតំណាត់ប្រទានដែង
ចែកឲ្យជាសួយមួយភាគខ្នែង ដើម្បីចាត់ចែងរក្សាប្រជា ។
មិត្រគាត់ចាំងសាមសិបពីរប្រាណ ក៏ចាត់ចែំណែកគ្រប់គ្នា
តាមស្រុកនោះចាំងអស់គ្នា មូលមិត្រចិត្តាឥតរន្ធំ ។
ឯលោក មឃៈជាប្រធាន នាំមិត្រគ្រប់ប្រាណមកនៅដុំ
ឋានន្តីតថាជាសមាគម ទុបត្តម្ភកសាងប្រយោជន៍ជាតិ ។
ចំណាយកម្ងាំងចាំងជនជាន ជីកនាំសព្ពានឲ្យខ្ជិលឃ្លាត
សាងសាលារៀនយ៉ាងល្អស្អាត សង្ហឹតសាងផ្លូវទៅតេញស្រុក ។
សាងស្រះជាសហាយដែលគ្មានទឹក នាំដឹកដីកព្រែកចែកច្រើនមុខ
សាងកេងសំណាក់ត្រជាក់សុខ សាងស្ពានក្នុងស្រុកចុងភូមិស្តួង ។
នាំគ្នាប្រព្រឹត្តយ៉ាងម៉ឺងចង់ នូវ វត្តបទ[2]ប្រាំពីរផង
ធ្វើបុណ្យសុទ្ធវានពុំមានហ្មង កន្ទុងយូរយោរគាចរន្ទៃយ ។
លុះដល់តំណាត់ផុតជន្ម ក្នុកចាំងអស់គ្នាវិលក្បែយ
ក៏ចានកើតក្នុងសួគ៌លើយ អាស្រ័យបុណ្យទានជាយានទៅ ។
តាមបុណ្យគុណកើតពីការសាង ប្រយោជន៍ត្រប់យ៉ាងឥតហ្មងសៅ
ជួយជនចាំងសាមសិបបីទៅ ឲ្យកើតនិត្យនៅផ្លូវសុខា ។

---

១ ត្រួតត្រាស្រុកចុងភាគខាងមាត់ញាកបែបង្ខុជាស្តេចក្រាញ់ ។ ២ វត្តបទប្រាំពីរប្រការ មានក្នុងជម្ពីរធម្មបទដ្ឋកថាត្រង់សក្តវគ្គ ភាគ ២ ។

កាលនោះព្រះបាទវេបចិត្តិ ស្តេចបំពេញជាម្ចាស់ហានសួគ៌ា
លុះយើញទេវបុត្រតាំងអស់គ្នា តើតនាវិមានឋានព្រះអង្គ ។
ស្តេចមានព្រះទ័យថ្លៃស្មោះសារ អបអរពាក់ពាក់ស្ម័គ្រស្មោះត្រង់
ចាត់ចែងខ្ជួលស្រួលអស់អង្គ ដោយចង់ជាមិត្រស្និទ្ធមេត្រី ។
ចែងចែកសម្បត្តិកន្ទេះលោក គ្រោះយោគយល់ចិត្តមិត្រកើតថ្មី
ដែលមកដុំតាំងសាមសិបបី ចក្រីរៀបចំសមវត្តខ្ពោះ ។
ប្រមូលអស់ចៃបទេពធីតា ដ៏មានកាយថ្លាវត្តមោះ
ទ្រនំតើងឡើងពេញចេញជងគោះ តួដោះក្សិតស្សំដូចគេវែច ។
ជួងក្តែកផ្កែកភ្លឺពន្លឺចាំង ពាក់ក្សាំងតាំងក្សាលរន្ទាលលេច
ចៃមាសពាសដាំអង្កាំពេជ្រ កម្ទេចស្មើរឆ្សើថ្លា ។
ព្រះព័ស្ត្រស្រស់ស្រើបរលើបស្រិល រអិលត្រិលព្រួចកួចចិន្តា
សម្ផស្សស្រោកណាទន់សោភា កេសាវត្តសៅឡៅយ៉ាងស្រស់ ។
ល្អអើយល្អណាស់ល្អះគ្រប់គ្នា ច្រើនវត្តគណនាពាក្យមិនអស់
ពីខ្លួចាមរោមពេញជាកំពូយស ផ្សាយសេតដៅគួរបេត្តី ។
បក្ខាភ្យាធ្មេញស៊ីចស់ណាចស្រួល ខ្ជួលភេញចិត្តមិត្រកើតថ្មី ។
ស្រាយស្រស់ផ្ចោះផ្ចង់សង់សំដី សំដែងមេត្រីស្រីនោមនាយ ។
ពាសពេញរឿណាឆ្គួតពន់ពេក លាតលើកដៃដើងឡើងពន្រាយ
កំបែរបេះមិតពត់កាយ មិត្រថ្មីតាំងឡាយសប្បាយលន់ ។

នានានាដកិត្តិ(๑)ស្រីអប្សរ លើកករចាក់ក្បាច់ពាច់ខន់អង្គ
កៀកកាយលាយកាមតាមខម្រង់ ជន្លង់ពង់តើងឡើងល្ហាសល្ហន់ ។
ជាពួកជាក្រុមជុំអធិក ភ្លុកភ្លឹកគឹកកងគួរគយគន់
ខេពតាកើតថ្មីព្រះទ័យខន់ សប្បាយគេកពន់ភ័ន្តអាត្ម ។
សូរសព្ទសំឡេងបទភ្លេងពិព្ធ រួបរឹបជួនចិត្តមិត្រខេវតា
ពីពេះអើយពីពេះហួសទុបមា គួរត្រីវណ្ណាថ្នាហថ្ងៃទ័យ ។
នៅកន្លែងប្រាសាទស្ថានប្រសើរ ខ្ពស់ខ្ពើរលើតពនតាល័យ
ក្បូរក្បាច់រចនាវាសនាថ្មៃ ល្អហួសវិស័យនៃមនុស្សហាន ។
សុទ្ធសឹងតែមាសតាសាដោយពេជ្រ រំលេចពៃឌូរ្យសូរ្យកាន្ត
មណីរ័ត្នព័ន្ធជុំវិញគ្រប់ហាន ប្រមាណសន្ធឹងធំល្ហឹងល្ហើយ ។
ខេពតាកាប់ច្រើនម៉ឺនចូលចេញ នៅតែមិនពេញប្រាសាទឡើយ
អាកាសត្រជាក់ខ្យល់រំភើយ រហើយស្រួលប្រាណក្សត្តពន់ពេក ។
ខេវប្តុត្តភូចធំសមតាមថ្នាក់ ឃសសក្តិរាប់ម៉ឺនច្រើនអនេក
ខ្លះក្រោកឡើងកំខ្លះទំស្រែក សម្រែកចម្រៀងព្រៀងសប្បាយ ។
ឯស្តេចខេពតាសក្តាធំ លើកផ្តាច់ខុមទិព្វតណ្ហាយ
នាំអស់បរិវារផងតាំងខ្លាយ ចូលថ្វាយចំពោះខេពតាថ្មី ។
ដែលមានមាថា សក្កៈ ឲ្យត្រង់ភារៈអធិបតី

---

๑ ស្តីរបាំ ។

សោយភោជនសម្បត្តិទិព្វស្ដួចស្ដើ គាន់តាប់ផែនដីតាក់តណ្ដាល ។
រួចស្រេចស្ដេចទ្រង់ឲ្យចាត់ដៃឆ តាក់តែងស្រោដ៏យកថ្ងៃត្រកាល
ឲ្យអស់ទេតតាំងចក្រវាឡ ត្រអាលជីកក្រៃបៃបកំសាន្ត ។
ជាសាធុការថ្នាប្រពៃ ប្រសិទ្ធជាតដ៏យកថ្ងៃចំណាន
ដល់មិត្រចំណូលសាមបីប្រាណ ឲ្យបានមង្គលសុខរៀបរៀត ។
ឯពួក សង្ឃ: អ្នកកើតថ្មី តាំងសាមសិបបីមិនភេញចិត្ត
ព្រោះឃើញសម្បត្តិសម្បើមតិត ក្លួចចិត្តចង់បានពាក្យតាំងអស់ ។
កំឲ្យសញ្ញាអាថកំពុំឆ ប្រុងប្រៀបប្រឆាំងដណ្ដើមយស
ធ្វើកលទុបាយយកតាំងអស់ ប្រាថ្នាធំខ្ពស់តាំងសាកល ។
ឯពួកទេតតាជាម្ចាស់ពាក្យ ប្រសេចប្រសាចដើរចេស៎
ចាក់ស្រោហាធីកឥតនឹកខ្វល់ ច្របល់ជ្រួលជ្រើមសម្បើមក្រៃ ។
ខ្លះលើកបើកធ្នូកដែលចុកដប រៀបរបចាក់កងតែវចៃណ
ខ្លះក្រេបមៃបធូខ្លះដើងដៃ ខ្លះលៃបង្ហុកច្រកមិត្រក័ត្តិ ។
ខ្លះជ្រួសហួសគេកដេកសន្ធឹង ទេត្រស្ងឹងរឹងស្លុកមុខញ៉ៅយ៉ាក់
ខ្លះក្រោកងោកជាក់អស់នាងឯក បញ្ចេញសង្ឃាត់ពាក់សាន្ត ។
ខ្លះខៀតប្រមឹកជីកឥតក្រែង ដួលដេកចំខែងលែងដឹងប្រាណ
រងោកងើលជ្រួលប្រមាណ ដេរដាសតាសហានគ្នាឯងស្រស់ៗ
ឯពួកស្រីស្រេីរទេតអប្សរ កំផឹកតែវច្រួលច្របល់

កៀកកែវស្នេហ៍ស្និទ្ធចិត្តវិលវល់ អស់កល់កេរខ្មាសផ្តួសផ្តាសអង្គ ។
ច្រឡូកបូកចំច្រឡំបល់ គ្រប់កាយខ្មាយខ្វល់តាមចំណង់
ប្រឹងប្រឹតតែតែកែទម្រង់ កៀកអង្គតង់អែបនែបតួគាប់ ។
ភួកភ្លើងលេងខ្លួរញ៉ាវពិតព ស្មានឈប់សម្រាកផ្អាកសួរសំឌួ
ក្សេមអើយក្សេមក្សាន្តគ្នានឹកស្ងាប់ ឧកញ្ជាប់ក្រមក្រឹត្យតួរតិតក្រែង ។
ឯភួក សង្ក្រានៈអ្នកកើតច្បី ពាំងសាមសិបបីតំសំដែង
អាការដូចជាប្រឹងផឹកលេង ស្រវឹងវង្វេងគ្រប់ ។ គ្នា ។
លុះឃើញទេវតាដែលខៅមុន ផឹកស៊ុនខន់ខ្លួនផ្ទួនតែស្រា
ដួលជាសញសព៌ាន់នានា លែងដឹងកាយភ្លាស្មារតី ។
ខ្រេតខ្រោតដួលចុះខុសខំនង ដេកគង់គាក់គ្នាលែងដឹងអ្វី
លេចមុខខុកក្រោយមិនតប្បី ស្រីស្រីកំគ្នាខច្រាណអៀនខ្មាស ។
ដេកផ្កាប់ដេកផ្ងាហាមុខក្រោយ ខ្លះដួលបណ្តាយដេកបង្ហុស
ខ្លះដេកយកដៃលៃខ្លួបថ្ងូស ខ្លះច្រាសដើងគងំរំលងក្បាល ។
ខ្លះខៅលើតុសំកុកធ្មឹង ទេបស្រីព្រលឹងប្រឹងត្រអាល
ខេវខន់សព្ទាដោយក្តីភាល ខេនក្បាលជ្រុលជ្រប់ផ្ងប់មុខគ្នា ។
សង្ក្រានៈឃើញព្នាក់អស់ជាម្តង បង្ខំមិត្រភ្លាមតាមសញ្ញា
ឲ្យដួលចំជាប់ចាប់ទេវតា ដែលមានបុញ្ញគុណធំ ។
ម៉ឺងភួកបក្សាក់ជាច្រើននាក់ មានជ្រាក់ស័ក្តិខ្ពស់យសទ្ធម

មិត្តភ្នំសាមប៉ីគ្នានជាមួយ សុះបំពំបួលទ្វូលដើងដៃ ។
កន្ត្រាក់ចាប់ដើងភួកប្រមឹក ដៃលងឹកស្រែងឹងហួសវិស័យ
ត្រែត្រៃត្រាក់ក្បាត់អស់ដៃ ពីសួតាលីយយ៉ាងតំណាច ។
ត្រែវែងចាលកងអន្ធឹងឹង ភ្លាក់ទៅបាតក្តុំសំនេរុកដ(១)
សន្លាំងខ្លួនឯងឥតក្រែងខ្លាច អំណាចតេជះព្រះចេស្តា ។
សុះបួលទ្វូលកួបបួបដើងមិត្រ នាម វេបចិត្តិ មហាកជ
ត្រាក់ត្រាយ៉ាងខ្លាំងកម្លាំងក្លា ភ្លាតចាកហត្ថាភ្លាក់ចុះរឹង ។
ខេតឯកជោគ្រើនកើនម៉ឺនលាន ភ្លាត់ចាកវិមានគ្មានដំណឹង
ជ្រុះទៅបាតក្តុំដុំស្លុកស្តឹង ពាល់តែស្ងាត់ឈឹងពីសួគ៌ ។
នៅសល់ខេតតាណាស្មោះត្រង់ ព្រមអង្គុដ្ឋង់កាយថ្វាយខ្លួ
ស្មគ្រួបួលមូលមិត្រចិត្តរួមគ្នា ទើបរួចអាត្មាពីគ្រោះថ្នាក់ ។
ឯពួកស្រែងឹងសឹងងោកងុយ ជ្រុះចុះបប៉ុយដួចភ្លៀងភ្លាក់
ទៅតរលើគ្នាជាច្រើនខាក់ ឥតភ្លាក់កាយផ្លាប់ផ្ងាប្រាណ ។
ដោយកតូកាតផលកុសលបុណ្យ ពួកខេតតាមុនចាំងប៉ុន្មាន
ត្រាន់តែបែរជ្រុះចុះដល់ហាន វិមានបាតក្តុំផ្ងាត្រាក្បាយ ។
កើតទៅជាតតែងនប្រឹថពី ជាដំរុនរឿនច្បើងសប្បាយ
មានជ្រូងកំភែងវែងក់តន្ទាយ ចម្ងាយមួយម៉ឺនកើនយោជន៍យល់ ។

• ក្តុំព្រះសុមេរុ ។

ផ្ទុសច្រាំងស្អាងស្អាតច្រាសាខច្រូង ដាំស្វាយរូងក្បាច់ប្លុងផល
មានស្រីអប្សរលេងខំមិល មៀងយល់ដូចជាសួគ៌ាល័យ ។
មានដើមច្រខៀង(១)ជៀងជាក់ខ្ពស់ សស្រីបជុះឡើងច្បើងពេកក្រៃ
មណ្ឌារត្នៈពន្លឺភ្លឺដូចថ្ងៃ វិស័យសួគ៌ាឋានគ្មានប្លែកឡើយ ។
លុះពួកទេពតាក្សត្រាក់ច្រាណ មៀងមើលវិមានឋានខោះហើយ
ឃើញអស់ពួកមិត្រដិតបង្កើយ ស្មានតែហ្នឹងហើយឋានច្រក្រតី ។
គិតតែតែកក្បាច់បង្ហាច់កាយ លោតរាំសប្បាយគ្មានគិតអ្វី
ឥតទុក្ខសុខក្សេមដ៏ច្រើនប្រើយ សួស្តីគ្នាខន្ធពន់ពេកក្រៃ ។
នេះគឺដោយផលពីអតីត វិចិត្រកើតឡើងដោយវេរូ
មានកម្មចាំជួយសួយតម្រូវ ខ័ណ្ឌផ្លូវបច្ច័យលៃសាងឲ្យ ។
ឯពួកសត្តៈអកុប្បធម្មា ជាទេវបុត្រកើតជាន់ក្រោយ
ពាយប្លុងស្ងើច្រាណបានពាក្យសោយ គឺដោយតេជៈបុណ្យច្បាមើ ។
ពួកទេពតាចាស់ផ្ទាស់ហាន: ព្រោះតែសត្តៈអកកើតថ្មី
ធ្វើកលទាយយកផែនដី មានជាតសួស្តីដ៏យស្ងិតស្ថេរ ។
លុះចាប់មិត្រខ្លួនផ្លូវចាលក្នុង អន្ទឹងបាតកំព្រះសុមេរុ
អស់ស្រេចតើចស្តេចនាំគ្នាបែរ រៀបគ្នេរតន្ត្រីកអាណាចក្រ ។
បរតេលរយោនជាអធិក គគ្រឹកភ្លឹកផ្ទៀងរហោរប្រពាត់
ច្រទើសលើសកើនច្រើនអនន្តំ្ជ ជាបក្សក្រេរឥន្ទ្រិតខច្រវាល ។

---

១ ដើមចំក្រៃជាលំ ។

ចិត្តដ្ឋចអគ្គីឫទ្ធិក្លា គណនាដំរែច្រើនកើនចំនួន ។

តឿឲ្យជាអ្នកត្រៃតាំងចាត់ នៅចាំសង្កាត់ផ្លូវទីបួន

បើបច្ចាមិត្រចិត្តមាំមួន ចូលដល់ផ្លាំលាំខ្លួនជួនកម្ចាំង ។

ត្រូវបក្សយោកយួយដំតង្ក្រាហាន ប្រុងប្រាណប្រយុទ្ធឈុតប្រទាំង

រៀបចំក្រុមទ័ពចូលទប់ច្បាំង បន្ទុយកម្ចាំងកងរឿណាឆ្ន ។

បន្ទាប់ពីភ្លូកយកក្បួមកខ្មៅ ផុតទ័ចង្រៀតជ្រៀតផ្លូវត្រង់

ចាត់តាំងមហាពលទាំងបួនអង្គ ឲ្យរងើគងំឃ្លាំប្រចាំការ ។

និត្យនៅផ្លូវដើរដង្ហើរទៅចំ លើកុំសិនេះបុរិភាវ(១)

មានកងក្លាហានប្រចាំការ អធិកនុយ្ហាវគន់ពេកក្រៃ ។

កងទ័ពមហាពលអង់អាចណាស់ សុទ្ធសឹងដើងចាស់តបះតេជៃ

មួយភ្លូកមួយភ្លូកមានខន់ជ័យ ជនខ្ពស់លៃជាសញ្ញា ។

លុះតាំងចាំងចាត់សង្កាត់សឹក ផ្លូវគោក ផ្លូវទឹក - អាកាសា

ស្រេចហើយសង្ក្រាប្ញទ្ធិក្លា ឱនភ្លូកខ្មៅគាជាមិត្រភ័ក្តិ ។

តាំងគ្នាចូលកុងកាំងច្រាសាខ ក៏តអាឡដំឡើងថ្កើងបុណ្យស័ក្តិ

មូលម័តិចាត់ការតោរតៀកក័ក្តិ តាំងសាមបីនាក់តាមថ្នាក់ជាន់ ។

ពេលនោះច្រាសាខស្ងាតត្រសុស ប្រជ្រៀតគ្នាផុសច្រើនហ្នឹងតាន់

ខ្លះតាបកបាលខ្លះច្រើនជាន់ ចេញាក់មិនខាន់ហួសគណនា ។

---

១ ភ្លាំងៃលនៅជុំវិញភ្នំព្រះសុមេរុ៍ មានភ្នំឈ្មោះយុគន្ធរជាដើម ។

ខេវពិតតាលុបឈ្មោះចាស់ តាមថ្នាស់ថាវៃត្រត្រឹង្សសួគ៌ា
ឬហៅពិតតាវត្តីសា ដោយតាមខេវតាសាមប៊ីថ្កាណ ។
តាំងនៅលើថ្ងៃនៃមហាភ័ ចំហាំធំខ្ពស់ហួសប្រមាណ
តីភ្នំសិនេរុរាជហាន(១) វិមានកុះកុំដុំច្រើនវៃក្រ ។
ជាខេពនតរល្អត្រកាល ធំរាលដាលឆ្ងាយជាច់អាល័យ
មានទ្វារមួយពាន់ពាំងរាល់ថ្ងៃ វិស័យកំពែងរែងមាំមួន ។
តីកំពែងក្រួងជ្រួងមួយ ។ មាំវតរញ្ជួយព្រួយរត់ពួន
ប្រវែងមួយម៉ឺនយោជន៍ពាំងបួន ចំនួនដប់កោដិយោជន៍ក្រឡា ។
ខាងកន្លែនតរល្អត្រចះ មានស្រះបោក្ខរណីដ៏ក្ដីថ្លា
សួនច្បារផ្កាផុះផុសត្រៀបត្រា ប្ដូចាជម្រុះរីកស្គុសស្គាយ ។
មានរុក្ខជាតិមានធំខ្ពស់ សន្ធឹកខៀវស្រស់ដុះពង្រាយ
ជាជួរជាក្រុមសមធើតធាយ គួរឲ្យសប្បាយដើរកំសាន្ត ។
នៅមជ្ឈមណ្ឌលយល់ត្រកាល ជាទីកណ្ដាលប៊ូរ៉ាំង
ប្រាសាទមួយធំសមប្រមាណ សម្រាប់ក្សត្រក្សាន្តព្រះទ្រង់យស ។
ឈ្មោះថាប្រាសាទវេជយ័ន្ត ប្រកបថ្នាក់ជាន់ពាប់មិនអស់
ជហ្វាប្រាសត្តគ្រប់ទិសទស ធើតធាយសម្រស់ស្រស់ញាញឹម ។
កំពូលកម្ពស់ខ្ពស់ត្រដោច ប្រាំតីរយោជន៍យល់សន្ធឹម
ស្បូវក្បាច់ចនាប៉ាំប៉ង្រឹម រកគួរខ្ចីមឆ្ងឹមតុំបាន ។

(១) ភ្នំព្រះសុមេរុ ។

សុទ្ធសឹងដោយមាសនុកាសផ្ទុក ស្មើចាំងភ្នែកគ្រប់ទីហាន
ត្បូងតេជ្រនៃពូជ្រួសប្រាកាន្ត ដ៏មានតម្លៃក្តីដូចថ្ងៃ ។
ខាងលើក្រោសាខស្អាតត្រចង់ មានដោតដងខ្ចង់ខ្ចុសលៃ
សុទ្ធសឹងមាសតេជ្រល្អភោកក្រៃ វិស័យមនុស្សលោកយោគមិនយល់ ។
មានកដវែមួយឈ្មោះវែជយ័ន្ត ទឹមសេះតីរគាន់មហាឡូល(១)
ក្បូរក្បាច់រចនាថ្លាទិមិល ជាផលថ្កល់ថ្កើងរុងរឿងឫទ្ធិ ។
វែនេះជាយានថ្លានប្រសើរ ហោះហើរដើរបានគ្រប់ហានបវិត
សម្រាប់សក្តិអ្នកមានឫទ្ធិ ធ្វាយដឹតស្តេចគង់ថ្លានយាត្រា ។
មានដំរីមួយសមសោភ័ណ ឈ្មោះឮកវីណសមសោភា
ជាខេតនិម្មិត(២)បំតសួគ៌ា សម្រាប់កជាព្រះទ្រង់យស ។
មានរេងប្រជុំក្រុមខេតតា ឈ្មោះសុធម្មាខួលយាន្តសំ
មានច្បារផ្កាកំភួងគន្ធរស យ៉ាងស្រស់ឈ្មោះចិត្តលតាវ័ន ។
មានស្រះចតុមុខប្បុរាណ ឈ្មោះសុនន្ទាជាតំបន់
ទឹកថ្លាត្រជាក់ស្រស់ពេកគន់ គួរគន់ចុះមុជកែកំសាន្ត ។
ទីក្រុងតាំងមូលតោលដោយឱឡី រស្មីតន្ធីក្តីសត្វហាន
ទុគ្គឆ្ពាំងរឿងល្អថ្កើងថ្លាន ខេវតាប៉ុន្មានក្សេមក្សាន្តសុខ ។

---

๑ មានពាក្យដំណៃប្រែថា ។ ๒ ដែលទេវបុត្រមួយអង្គទិម្មិតខ្លួនជាដំរីសម្រាប់ស្តេចជង់កំសាន្ត ។

ឯមត្រៃតាំងសាមសិបបីនាក់ ស្មោះស្ម័គ្រគ្រប់ប្រាណជាន់ខុក
លើកអង្គសង្ឃៈជាប្រមុខ គ្រប់គ្រងភូមិស្រុកក្នុងស្ងួតា ។
សង្ឃៈពេលនោះឈ្មោះវិចិត្រ ជានាមនិមិត្តប្រើនមហិមា
គឺនាមដែលពួកមនុស្សទេពតា នាំគ្នាហៅថា ព្រះបុន្នកៈ(១) ។
ហៅ តិទិវាធិកូ, បុរិន្ទ័ ខេរិន្ទ, ចាកសាសនា
ខេរកុញ្ជរៈ, រាសរៅ សុរនាថា, ជម្ពារី ។
រិជិរហត្ថ, អមរិន្ទ្រា តន្ទព្ភាជា, សុជម្បតី
អសុកតិកូ, ព្រះកោសីយ ភូតបតី, សុកធិបៈ ។
រិជិរវុធ, មឃវ៉ា ខេរវាជា, សហស្សក្ខៈ
សុរិន្ទ, អសុរសាសនៈ ទសសតរលោចនោ ។
វិត្រកូ, ខេវាន់មិន្ទ អន្ទ្រៈ, មហិន្ទ, សហស្សនេត្តោ
សក្កៈ, តឹសម្បមុខា ជាជាធិបតី(២) ដូច្នេះកំមាន ។
សោយសុខសម្បត្តិសម្បើមបុណ្យ សម្បូណ៌ដោយគុណកុសលាណ
ពួកស្ត្រីអប្សរទេវរាប្រាណ ពេញហានវ៌ាមីរដេរដាស ។
ចាំនឹពួកខេរបុត្រប្បតកើត យោនយកតំណើតខេរកាស
កើតកើនប្រើនខ្ជូបិតដេរដាស ពេញភាសកកកុញ្ជក្នុងស្ងួតា ។
គឺដោយសារគុណនៃសក្កៈ ចាន់ខ្លឹងហាន៖ខេរវាជា

---

១ បុរសជាអធិបតី។ ២ ចាំងពី តិទិវាធិកូ ដល់ បជាធិបោ ៖ នេះ ជាឈ្មោះរបស់សក្កៈចាំងអស់។

មានបុណ្យអស្ចារ្យហួសពាណិនា　　ធំលើសខេត្តផងឯខ្លួន ។

ថ្លៃឯពីខេត្តតាដែលជាម្ចាស់　　កាលផ្ទាស់ហានៈដោយចិត្តស្មោះ

គិតតែតែកែខ្លួនជួនស្រាខ្លួន　　ប្រឹងធ្វើតជ្រៀតជ្រែងលេងសប្បាយ ។

ឥតគួរឥតគិតពិនិត្យហាន　　ពីតតែកំសាន្តគ្មានក្រហាយ

ស្មានថាខ្លួនជាខេត្តនិកាយ　　ទៅសួគាទាយឥតខ្លាយខ្លាត់ ។

មានអាយុវែងសម្បូរស្រស់　　មានវស្សាយយសក្តិសេកក្តាត់

សម្បូណិសម្បើមធ្ងើមសម្បត្តិ　　វិស័យបុណ្យចាត់ជូនសួគា ។

តឹកឆ័ខេវៈលោកយោគសុខសាន្ត　　ឥតខ្វះស្ងួនថៃបយ៉ាងណា

ឯអស្ចារ្យគ្រប់ទីក　　កំសៃនសុទាដូច្នោះឯង ។

ហេតុនេះទើបពួកគេគ្រប់ប្រាណ　　មិនចាន់ដឹងខ្លួនផ្ទួនវង្វេង

ប្រឹងតែស្មានថាទីនោះឯង　　ជាទីកន្លែងសួគាល័យ ។

លុះដល់ជួបត្រូវទាត់ដៀង　　ពេលដើមច្រនៀងទើតត្រៃឈ

បញ្ចេញប្តូចប្តាំងវិស័យ　　រកស្រស់បំប៉ែចល្អឆើតឆាយ ។

ស្រាប់តែពួកគេគេនិត　　តើគិតពិនិត្យដោយក្បាត់កាយ

ថាដើ ! យើងតិតតែសប្បាយ　　គ្មានក្តៅក្រហាយគិតអើពើ ។

ពួកយើងមិនមែនជាខេត្តតា　　ទៅហានសួគាលោកខេត្តតើ

អាដែងគ្នាយើងតិតជាក្តើ　　ឲ្យសក្តៈធ្វើកលបញ្ឆោត ។

តិតវែតជាជីកខ្ចីកស្រែរឹង　　មួយដបហើយប្រឹងវែមមួយចាំត
មួយចាំន់កាន់ដើងរលើងកោដ　　សក្តៈបណ្តោតលោតភ្នាក់ខ្ចឹក ។
ពួកឯងឃើញខេដើមប្រខៀង　　ដុះផ្អៀងរៀងភ្លាផ្ងសខ្ញឹក
ឯណាដើមជាវិច្ចត្តកព្រឹក្ស(๑)　　វែរឹតហើយយើងគ្មានជំងឹកាយ ។
ហានសួតិមានដើមជាវិច្ចត្ត　　ជាខេតសម្បត្តិស្រស់ឆើតឆាយ
ជាទីញ៉ាំងខេតភាពំនង់ឡាយ　　ទៀក្សាខ្ពស់ប្រាយកាយសួស្តី ។
ឥឡូវវែមានឯប្រខៀង　　គ្មានសួរសុំខៀងសៀងសព្វអ្វី
យើ ! ពួកសក្តៈអន្សតិរ្ថីយ　　អប្រិយវៃក្រៃត្រើលមើលងាយធំ ។
ធ្វើយើងឡៃបង់លង់កាយា　　លះភាពខេតភាសក្តិទុត្តម
កើតជាអសុរត្បូលថ្មាតភ្នំ　　ខុក្ខធំនេះរកប្រឿបពុំបាន ។
តើដើមនេះហៅយើងសុភ　　ប្រែថាខេតភាកន់សួតិហាន
ឥឡូវបង់ប្រាជ្ញជាចង្ហាក់ប្រាណ　　មកបានហានមែរប្រទាមា ។
ទៅជាអសុរវុលបពិត　　ព្រោះតែការក្សត់ពួកខេតភា
ដែលយើងសម្បុរសស្មោះចិត្តា　　ពាំងលើកសិមាពាក់កណ្តាល ។

---

๑ ជាវិច្ចត្តកព្រឹក្ស ជំនើមមន្ទាបុស្បង្អុះនៅហានស្ងួត ។

(នៅមានត)

ភាសាសាស្ត្រ និង អក្សរសាស្ត្រខ្មែរ

រៀបរៀងដោយ ឆ. ភាម

(តមក)

អក្សរសាស្ត្រខ្មែរ ខ្មែរធ្លាប់ថែថ្នុង
ឲ្យជានភ្លាប់ខ្លួន ជង់រឹងជង់តម់ ។
ព្រោះអក្សរជាតិ ដោលជាតិជ្រាកជំ
អក្សរលេត់ ជាតិកំរោយ ។

ប.ព

ជំពូកទី ១

មនុស្សសំដែងកាយវិការមិនស្មើគ្នាប៉ុន្មានទេ ទំរាំសូមលើកយក ឧទាហរណ៍ ជនជាតិក្រិក ។ ជនក្រិក ឯកក្បាលសំដែងន័យថា "ចាស! យល់ត្រម! " ដល់ងើបក្បាលថា "អេ! " ។ ទេមរជនត្រីក្បាល ជានន័យថា "អេ! " ។ នៅក្នុងភាពយន្ត បើតេចង់សម្ងាប់មនុស្ស ដោយមិនចាំខ្លួលខ្លួវសេចក្តីអង្វរ មេបញ្ជាត្រូវឲ្យសញ្ញាទៅកូនក្រុម ដោយលើកមេដៃបង្ហិលចុះក្រោម ដោយបង្ហាញន័យថា "សម្ងាប់ទៅ! " ។ ទាំងនេះបានបង្ហាញថា កាយវិការភាសា អក្សរសាស្ត្រគ្មានព្យញ្ជន: ។

មនុស្សក្នុងសាកលលោកនេះ ប្រើកាយវិការជាច្រើនជំនួសភាសា ។ មានកាយវិការខ្លះទៀត គេចាត់ថាជាកាយវិការអន្តរជាតិ ដូចជាកាយវិការរបស់កាយប្ញទ្ធិ ឬអ្នកបើកបរយានជំនិះ ។ កាយវិការភាសានេះ អាចបញ្ជាក់ខ្លួនឯងតិនីងចិត្តគំនិតរបស់មនុស្សបាន ។ ដូចយ៉ាង សំឡេងយ៉ង-សើច-ថ្ងូរ-ក្អួត . . . . . នេះជាកាយវិការភាសាប្រកបដោយសំឡេង ដែលចាត់ថាជាភាសាតម្រាតមន៍អន្តរជាតិស្តាប់យល់បានថា នេះសើច-យំ-កើតពុក្ក ។

កាយវិការមួយទៀត គួរយកមកបញ្ជាក់ "មនុស្សម្នាក់យកដៃបក់ល្វើច ។ មុខសុខ ដែលមិនធ្លាប់ស្គាល់ ឬក៏ស្គាល់ដែរ រួចយកដៃទះដៅទៅក្បែរខ្លួនមនុស្សទៀត "ប្រែជាសេចក្តីថា មនុស្សនេះ បក់ដៃហៅឆ្ងៃមកណេះ ហើយទៀអង្គុយក្បែរខ្លួន" ។ រួចសុខៗដើរមកអង្គុយជិតមនុស្ស តើឆ្លៃឆេះគេនៅសៀវភៅឬទេចុះមើចបានតែក់មកអង្គុយក្បែរមនុស្សថាមកពីឆ្លៃយល់កាយវិការរបស់មនុស្ស ។

៣- តិរិសាសត្វ (Speech of Animal) មិនត្រឹមតែមនុស្សទេ មានកាយវិការជំនួសភាសា សូម្បីតែសត្វក៏មានកាយវិការចំនួសភាសាដែរ សូមសង្កេតមើលមាន់ ។ មាន់ឈ្លាសតែសប្បាយរីករាយចិត្ត ភ្លាមៗមាន់ញីឈឺពងក៏អត តែក្រាបពងហើយវាខ្ពុត គាលណាវាបក់ស្លាបវាសំដែងថ្លែងប់ថា វាគោរពភាគខ្លាច ។ ក្រមើតែវាខ្លាចគ្នាវាប្លែមនុស្ស វាតែង

តែបក់កន្ទុយល្ងិច ។ ហើយរត់ទៅលិចភ្នាក់ ដើម្បីសំដែងថាគោរព ។ ពាក្យនេះចាត់ថាជាភាសាសំគាប់សត្វ ។

សូមសង្កេតពិចារណាឲ្យប្រយោគខ្លះនេះ នៅក្នុងសៀវភៅ (The Gift of Language) ថា ប្រុសគឺជាមនុស្ស ផ្សេងដោយឡែកពីសត្វលោក ដូច្នេះត្រូវបែងចែកយាយតាំងពីកំណើតដោយខ្លួនឯង ។ ឯស្ត្រីវិញ គឺបែងចែកយាយឡើងដោយសារតែអាដាម នៅថ្ងៃដែលអាដាម បានចាត់កំណាត់ឆ្អឹងឆ្អែកសត្វលោក . . . . ។

ភាសាសត្វដែលគេអាចឲ្យយល់ថាបាន ក៏ដោយសារតែ "ចលនា" ដែលចាក់ឥន្ទ្រីយ៍ធម្មជាតិមានដែរ ។ យើងមិនអាចបានដឹងថា តើភាសាដែលកើតឡើងមុនគេនៅកន្លែងណាទេ ព្រោះយើងមិនមានឯកសារ កត់ត្រាចំណាំតាំងពីបុព្វសម័យ ។ មានវិញ្ញាជនជាច្រើនបានយកវៀសំឡេង (banque magnetique) ទៅថតសំឡេងសត្វស្វាធំៗ (Chimpanzés) ហើយយកមកធ្វើជូនវិនិត្តិសាស្ត្រ (Etymologie) ចំពោះសំឡេងនីមួយៗ ។ មានវិញ្ញាជនខ្លះទៀត យកមាំស៊ីនថតសំឡេង ទៅថតសំឡេងសត្វផ្សេងៗ សត្វខ្លះមានសំឡេងថា កាក! គួក! ប៉ូប! ជាដើម ។

តែយើងអាចកត់សំគាល់បានថា ភាសាសត្វស្វាធំ (Ape) មាន

សំឡេងសំនៀងភាន់តែចូលជិតមកសំនៀងសំឡេងភាសាស្ត្រ របស់មនុស្ស ។ លោក រ៉ូប៊ែរ ម. យើក្ស (Robert M. Yerks) បាន សរសរសរសៀវភៅថា (The Great Apes) « ថាសត្វអាចយកទៅបង្ហាត់បង្រៀនឲ្យទៅធ្វើការយវិការភាសាបាន ដូចជាមនុស្សគ្រងថ្ងន់ (The Great Apes that these animals might, however be trained to a gesture language much as deaf mutes employ. »

៤- សញ្ញាភាសា (Signals for Words) ឥឡូវយើងត្រឡប់មកភាសាមនុស្សវិញ ។ តើយើងអាចដឹងថា សញ្ញាភាសាមានប៉ុន្មាន ដែលយើងអាចយល់បានសព្វថ្ងៃនេះ ដែលកើតមកពីភាសានិយាយ ។ មានសំឡេងខ្លះអាចបញ្ជាក់ឲ្យដឹងថា ភ័យ . . . . ប៉ុនប៉ង . . . . ដូច យ៉ាងសញ្ញា « ស្ងប » មនុស្សច្រើនជាតិដឹងថា « ឆ្កែយេតង » ។

អ្នកនៅទីក្រុង ច្រើនតែរេះសញ្ញាភាសា ដែលមិនមានតាស្យ៉ា គ្រឿងសំគាល់ ។ សញ្ញាក្តៅ ក្រហម-ខៀវ-លឿង ចំលើសលើតដែ ដើង ។ល។ សញ្ញាទាំងនេះអាចនាំអ្នកបកប្រែឲ្យរួចផុតសេចក្តីអន្តរាយ ។ នៅសាលារៀន តែគេឮស្ទូរដួង-ស្គរ គេអាចដឹងថា ក្មួនសិស្សសំពក ឈប់ចេញរៀន ឬចូលរៀន ។

សញ្ញាគួសតាមផ្លូវ សំគាល់ឲ្យដឹងថាខ្ពង់ជើងភ្នំ គួសកាត់ផ្លូវ សំគាល់ ឲ្យអ្នកដើរកាត់ ។ បើបានឃើញសញ្ញាមួយគួរឲ្យចាប់អារម្មណ៍ គឺសញ្ញា

នៅក្នុងទម្លុងក្រោមដី (Subway ឬ Métro) នៅទីក្រុងនីវយ៉ក (New York) នៅមហាវិថី ៤២ នៅខាងលើតាមទម្លុងក្រោមដីនេះ មានតួសតណាប្រ-ដេះ ។ តំនួសនេះ មានន័យថា "បើអ្នកចង់ទៅដីរថភ្លើងទៅទិសខាងកើត សូមមកតាមទ្វារ" តែគ្មានសរសេរជាអក្សរទេ តែគ្រាន់តែតួសប្រាប់ ។

សូមពិនិត្យមើលរថយន្តដឹកទំនិញធ្ងន់ ។ ដូចដឹកឈើ ឬដែកជាដើម នៅខាងក្រោយរថយន្ត គេចងកំណាត់សំពត់ក្រហម ។ សំពត់ក្រហមនេះ បានន័យថា "ប្រយ័ត្នគ្រោះថ្នាក់! ទៅឲ្យឆ្ងាយ!"

ឆានីកសិក (អ្នកនៅទីក្រុង) ដល់យើញសញ្ញាច្រើនដូច្នេះ ស្ទើរតែដូចអនារយជន (Primitive) ពួកគ្នាធ្វើ តួយជាដើម ។ ពួកគ្នាធ្វើតួយច្រើនតែកួចចង-លាក់ឈើជាចំណាំ សុនខច្រើនយល់ចិត្តមនុស្សដោយម្រាមដៃ, មនុស្សតូចធំ ច្រើនប្រើដៃ ។

៥- ភាសាត្រាប់ (Imitative Words) គាសាដែលយើងនិយាយគាចយល់បានដោយងាយ ពោះជាសញ្ញាគាសា រូបិក្ខ អរូបិក្ខ ។ ពាក្យដែលគេត្រាប់សំឡេងដូច្នេះហៅថា នាមការកគាសា (Onomatopoetic) ។ តាមការត្រិះរិះមើលទៅតាម ភាសាត្រាប់ នេះទៅ យើញថាប្រជាជាតិដែលមានអារ្យធម៌ខ្ពង់ខ្ពស់ មិនសូវមានគាសាដែលយកលំនាំតាមសំឡេងធម្មជាតិទេ ។ យើងគាចសន្និដ្ឋានបានទៅតាមសេចក្តីនេះបានថា ពួកវែរដូចគ្នាងតួយជាដើម ច្រើនយកគាសាតាមធម្មជាតិ ។

ភាសាខ្មែរយើង កំមានពាក្យដែលត្រាប់យកសំនាំ ឬ ហេតុដែរ ដូចពាក្យថា « ចែកអំពិលអំពែក » ។ ម៉េចបានជាគេនិយាយថាដូច្នេះ ព្រោះថា កាលណាគេទង្គិចក្បាលយ៉ាងខ្លាំងទៅត្រូវអ្វីមួយ មានស្នៀត្រចៀក ។ ខ្លាតក្លែតចេញមក ដូចពន្លឺសត្វអំពិលអំពែក ដូច្នេះគេសន្មតថា « ចែកអំពិលអំពែក » ។

៦- សង្គមភាសាឬគ្រាមភាសា (Community Words)

បើសិនជាយើងសួរខ្មែរគ្នាឯងថា « អ្នកនិយាយភាសាអ្វី ? » ចម្លើយមុខជាមកផ្ទាល់នេះថា « ខ្ញុំនិយាយភាសាខ្មែរ » ។ ចុះម៉េចបានជានិយាយភាសាដូចគ្នា ស្តាប់គ្នាមិនបានខ្លះ ? មកពីនៅត្រង់តែប្រទេស មានភាសាសំរាប់សង្គមឬជនបទ ។ ខ្ញុំសូមលើកយកឧទាហរណ៍មួយមកបង្ហាញ « ក្មេងដែលគេចរៀនមិនទៅសាលារៀន តាមជនបទខ្លះហៅថា « កាន់តាតឈ្លូស, ត្រុក, ខ្ចាយ. . . » ។ មិនមែនតែភាសាយើងទេ ដែលនិយមនិយាយ មិនដូចគ្នា សូម្បីតែប្រទេសឯទៀត ក៏និយាយមិនដូចគ្នាដែរ ដូចសហរដ្ឋអាមេរិក « ក្មេងដែលគេចរៀនគេនិយាយតាមជនបទខ្លះថា Skip bag day out of school, play hooky ឬ hooks Jack. . . ។

សូមសង្កេតមើលក្មេងមួយក្រុមតាមចំនៀមអ្នកស្រុកខ្លះ ឬខ្លួនឯង ខ្ញុំមិនបានយល់ច្បាស់ ។ តែនៅស្រុកយើងខ្ញុំសព្វថ្ងៃនេះ « ក្មេងអង្គុយអាំងភ្លើង

ទៅដូរគេវិញ ។ ក្មេងពីរនាក់ដូនតាក្មេងតេលជាមួយគ្នា ម្នាក់ត្រូវស្ពោះទឹក
v មាត់ឡើងលើ ម្នាក់ស្ពោះទឹកមាត់ចុះក្រោម មានន័យថាមិនឱ្យដំណើរមាត់។
នេះជាភាសាសំកាច់សង្គមក្មេងដែរ ។

បើក្មេងលេងល្បែង ដូចលេងល្បែងដង្កៀះ ក្រមើអូសរេះ ឬផលក្រមើជាដើម តែឈប់លេង ក្មេងថា « ណាឯងតេ ក្រោយ។ លេងទៀត" រួចទើបក្មេងយកដៃធ្វើជាចោសគូថ ។ ការប្រព្រឹត្តិរបស់ក្មេងដូច្នេះ គ្រោះកាយល់ថា បើមិនធ្វើដូច្នេះទេ ខ្លាចដុះកន្ទុយ ។

បើយើងសង្កេតមើលតួកអ្នកសៀមកប និយាយជាមួយខ្មែរក្រោម ស្ទើរតែស្តាប់គ្នាមិនបានប្រហែលតាក់តណ្តាល ។ ខ្ញុំបានជួបខ្មែរសៀម-កបម្នាក់ឈ្មោះ ឈរ-គីលិន និយាយជាមួយខ្មែរក្រោមម្នាក់ឈ្មោះប៉ុល នៅទីក្រុងព្នំស៊ីនគោន សហវាជ្ជអាមេរិក :

គីលិន- ប៉ុល ! ប៉ុល ! រឿនអង់គ្លេសចេះដល់ម៉ាឡាហើយ ?

ប៉ុល ធ្វើភ្នែកឡឹងឡង់ ព្រោះស្តាប់ពាក្យម៉ាឡាមិនយល់ សូម្បីតែខ្ញុំអ្នកនិពន្ធអត្ថបទនេះក៏ស្តាប់មិនយល់ដែរ តាល់តែខ្ញុំបញ្ជាប់ខ្មែរសៀមកប ជាពាក្យកំផ្លែងថា :

មើល៍ ! ប៉ុល ! យល់ពាក្យថាម៉ាឡាឬទេ ?

ប៉ុល - អត់យល់ទេ

មិត្តខ្ញុំសៀមកបថា "ខ្ញុំស្មានថាគេស្លាប់ហ្មង" ខើបខ្មែរសៀមកបតឡស់ថា មាំឡា "ដល់ណាហើយ ឬហ្មងទ្រែនហើយ" ។

លោក ជ.ប. ការ៉ុល (Jonh B. Carroll)និយាយថា "ភាសារបស់សង្គមនីមួយ ។ មិនងាយឲ្យមានឯកភាពត្រឹមត្រូវហ្មងទេ បើសិនណាជាសង្គមមនុស្ស ភ័តធំឡើង ភាសាកាន់តែរវៅរកការឃ្លាតឃ្លាងចន្ទិចដែរ ។ ដូច្នេះនៅក្នុងសង្គមនីមួយ ។ មុខតែមានសំដីលំនាំផ្សេង ។ ពីគ្នា" ។

សង្គមភាសា ចើនិយាយឲ្យច្បាស់ទៅទៀត គេអាចចែកភាសាខ្មែរទៅតាមជនបទ ដូច្នេះយើងត្រូវធ្វើតាមនីជាផែនទីតួសចំណាំច្រាប់ថា ជនបទ ឃុំ - ស្រុក - ខែត្រនេះនិយាយដើនដូច្នេះ មនុស្សនៅក្នុងខែត្រនោះនិយាយដើនដូច្នោះជាដើម ខើបងាយឲ្យអ្នករៀនអាចយល់ហ្មងស្រួល ។

ខ្ញុំសូមអធិប្បាយភាសាតាមសង្គម ឬជនបទខ្លះ ដែលខ្ញុំហ្មងដួចច្រុះតែខ្ញុំសូមអភ័យទោស ចើសិនជាខ្លះខុសខាតដួចម្តេច សូមលោកមេត្តាផ្ទើរសេចក្តីត្រូវទៅខ្ញុំ (សូមអរគុណ)

ពិតមែនតែខ្មែរយើងមានភាសាតែមួយសំរាប់ជាតិ តែលំនាំភាសានិយាយចាត់ទៅតាមសង្គមឬជនបទ ដូចអ្នកខែត្រកំពតនប្រើភាសាថា "ភ្លុត" តាមន័យក្នុងវចនានុក្រម ឬតាមជនបទសង្គមហ្មងន័យថា "ក្រឡាភ្លួច ។ សំរាប់ដាក់កំប៉ោរ" តែអ្នកខែត្រកំពតសំដៅយក "តាន់ធំ" ។

សូមតាំងទស្សនៈមកសាសាខ្មែរដូចតទៅនេះ ៖

ក)- សំដីពាយតាយ

លោកអ្នកភ្ជាប់បានធ្វើដំណើរតាមរថយន្ត ទៅតាមព្រៃកក្តាម ទៅ
ស្ពន់កំពង់ចាម មុខជាឮឈ្មួញពាយតាយនាយថា

លុតហ៊ាំ ! ក្រូចហ៊ាំ ! ឈូកហ៊ាំ !

តទៅវិញលោកអ្នកដឹកថយន្តទៅតាមផ្លូវកំពង់ត្រឿញព្រៃកអ្នកលឿង មុខជា
ឮឈ្មួញពាយតាយនាយថា : មកយើយលុត !

ហើយយើងមកកំពង់ត្រឿញ ឬ តាមដនបទឯទៀត ។ យើងមុខតែឮភាសា
ពាយតាយនាយដូច្នេះទៅវិញ

លុតហ្គី ! លុត ! .ពោតស្ងោរហ្គី ! ពោតស្ងោ !

ខ- សំដីតាមស្រុក ឬ ជនបទ

១- សំដីនិយាយអ្នកខែត្រស្ទឹងត្រែង ក្រចេះ កំពង់ចាម ។ គេ
ច្រើនតែនិយាយបន្ទុះបន្ទាប់តួកខ្មែរនេះថា ខ្លា-លួ-ខ្លាប់-លៀក (ស្វា-ម្ជូ-
ស្វាប់-ស្លៀក) គេនិយាយច្រើនកាត់យកតួអក្សរ ស ចេញ ។ សូម
តាំងទស្សនៈមើលភាសាដនបទនៅឃុំស្តាំ ស្រុកស្ទឹងឃ្មុំកំពង់ចាម ពាក្យថា
"លំប៉ាក" បានន័យថា "ចង្រៃ" សំខៀងភាសានេះដូចជាភាសាខ្មែរ ។

២- ខែត្រតាកែវ សំដីតួកនេះប្លែកពីតួកអ្នកខែត្រក្រចេះ តែស្រ-
ដៀងគ្នាទៅខែត្រព្រៃវែង-ស្វាយរៀងដែរ ។

ពួកខែ្មរខ្រនេះនិយាយស្រដៀងយួន ព្រោះនៅទល់ដែនយួន ដូច ពាក្យដែលមានអក្សរ (ធ-ស) (ចំពោះអក្សរធ-ស មាននិយាយនៅ ក្នុងពួកព្យញ្ជនភាសា)

សូមលើកយកពាក្យខ្លះរបស់អ្នកខែ្មរក្រតាកែវ (ធ-ស-)

ស្ពែ - ឆ្ពះ - - ឆែ្នង

មើលទៅខែ្មរលើមែបច្រឡំពាក្យនេះហើយ សូមជ្រាបចុះថា ស្ពែ> ឆែ្ពះ , ឆ្ពះ>ស្ពះ, ឆែ្នង>ស្ទែ្នង

ម្យ៉ាងទៀតសូមពិនិត្យតារាងខាងក្រោមនេះ ដែលមិនសូវស្រេចគ្នា

ខែ្មរខែ្មរក្រហេះ - ស្ទឹងត្រែង	ខែ្មរខែ្មរក្រតាកែវ
វល់តែ	អាល័យតែ . . . .
ឧ. ម៉េចបានដាយ្យម្ល៉េះ ?	ឧ. ម៉េចបានដាយ្យម្ល៉េះ ?
ឆ្លើយ : ខ្ញុំវល់តែចាំមិត្តខ្ញុំ	ឆ្លើយ : ខ្ញុំអាល័យតែចាំមិត្តខ្ញុំ
. . . . .	. . . . .

តែចំពោះអ្នកខែ្មរក្រហេះ ខ្លឹងខែ្មរខ្លះ ច្រើនតែនិយាយ ចាំងពីរ គឺវល់តែ . . . ខ្លឹងអាល័យតែ . . . ។ តែអ្នកខែ្មរក្រតាកែវ ច្រើនតែនិយាយថា អាល័យតែ . . . ។

៣- ចុះខែ្មរសៀមភូមិ, កំពង់ធំ, កំពង់ឆ្នាំង, ពោធិសាត់, ជាត់-ដំបង និយាយម៉ែកភាសាអ្នកខេត្តខាងលើដូចម្តេច ? ច្រើនណាស់ត្រាន់តែឮ

អ្នកសៀមពេមកភ្លឺ ប៉ាដាក ឬ អ្នកកំភង់ផ្ទាំង ខ្ញែកគ្នាភ្លាមទៅបស្ចឹកត្រ
ចៀកគ្នាកាប់ចាន់ក្រមឲ្យដួយ ។

សំដីអ្នកសៀមវាប

លោកអ្នកនាងដែលឮភាសានេះប្លែក អ្នកសៀមពេចនិយាយដើនៗថា:
" គោរ៉ាចាក្រាំវូលដុប អេងថាកយាអ៊ើយកយ កុំតែបានលោកតិក្ខ
មួយអន្លង្គដួយកាត់ ម្ទេះលំបាកយ៉ាង " ថាតួកអ្នកសៀមពេចនិយាយសៀម
ទៅមិនមែនទេ ថានិយាយបាលីទៅមិនមែនដែរ ចុះម៉េចបានជាគេស្តាប់
ភាសាខ្លះមិនបាន ថាមកតិសង្គមភាសា ឬត្រាមភាសាបស់ពួកនេះដើន
សេចក្តីខាងលើនេះ ប្រែថា " គោរ៉ាផ្តើលចូលព្រៃគុម្ពោត ឯងថាតយ
អ៊ើយតយកុំតែបានលោកតិក្ខមួយអន្លង្គដួយចញ្ចាំម្ទេះលំបាកណាស់ "

សង្គមមនុស្សខ្លះ មានសញ្ញាភាសាប្លែកពីគ្នា (សញ្ញាភាសាខ្ញុំអធិ-
ប្បាយរួចពីខ្ពស់ខាងដើមហើយ) ។ មានអ្នកស្រុកខ្លះដឿងោយប្រើកាយ-
វិការផ្សេង ។ ដើម្បីកំណត់ឲ្យដឹងខ្លួនគោលបំណង គំនិតរបស់ពួកជននោះ
ដូចយ៉ាង " យកដីដាក់លើក្បាល, យកដីដាក់លើពោត (ដែលគេយកធ្វើ
ខ្នុំ) " ដែលឲ្យន័យថា " សូមកុំឲ្យលោះព្រលឹង " ថា " កុំឲ្យពោត
សាច " ជាដើម ។ ខ្ញុំសូមជូនទុកជាឧទាហរណ៍មួយ ដើម្បីតម្រូវគ្នា ជនអា-
មេរិកាំង បើគេចង់មានលាភ ជ័យសួស្តី ក្នុងពេលធ្វើដំណើរ គេត្រូវ
ទោកឬគោះឈើដោយក្រញាត្រមាដៃ អង់គ្លេសថា (Knock on wood)

តទៅវិញយើងនឹងមកពិភាក្សាអំពីរបៀបសង់ប្រយោគរបស់មនុស្សចំពូកខ្លះ ដូចជាការប្រើប្រាស់ប្រយោគដែលគេនិយាយលាយឡំតាមតណ្ហា (ស-ខ្មែរ)

ឧ. ពាក្យ· តសូវ · ណាសូវ · យ៉ាស៊ុំ . . . .

ត្រូវថា ទៅស · នៅស · យកស (ទៅ · នៅ · យក.)

ភាសារបៀបនេះ គប្បីចាត់ទុកថាជាភាសាសម្ងាត់ គឺគេមិនចង់ឲ្យអ្នកដទៃខ្មែរស្តាប់ចុះ ។

ម្យ៉ាងទៀត សូមពិនិត្យភាសាមួយចំពូកទៀត ដែលគេហៅថាភាសាឫសីថ្លែងសារ ។ ភាសានេះទុកដូចជាកំប៉ាំងមួយដែរ ។ ភាសានេះមានន័យនឹងរបៀបដូចខ្លះ ៖

ត្រូវសរសេរឲ្យច្បាស់លាស់ តាមភាសាធម្មតាជាមុនសិន តែត្រូវធ្វើយ៉ាងឲ្យខ្លី។ ឲ្យល្មមកប់ពាក្យចុងឆាយ រួចហើយត្រូវកប់អក្សរបណ្តោយពីដើមទៅចុង ហើយត្រូវដកមួយតួមុន។ យកមកសរសេរទៅតាមបន្ទាត់។ របៀបកប់អក្សរដូច្នេះ ស្រះ ប៉ាំងឈើ, អក្សរ, លេខ កប់មួយតួដែរ តែវិសាខនិយាគេមិនកប់ថាជាមួយតួទេ ។ ពេលផ្ញើសំបុត្រទៅគេ ដើម្បីឲ្យស្រួលដល់អ្នកទទួលផ្ញើចុងឆាយនោះ ត្រូវប្រាប់យ៉ាងខ្លីថា ២.៣.៤ ឬ ៥ តាមដែលយើងកប់ថា "ដក" ដល់ពេលដែលគេកប់អក្សរយកជាពាក្យវិញថា "ស្រង់" ។ ដកស្រង់នេះ មានចំនួនខុសគ្នាក៏មាន ត្រូវគ្នាក៏មាន ។ បើចង់ប្រើរបៀបដកថាស្រង់ ស្រង់ថាដក ចុងឆាយ ។

គ្រាមភាសា ឬសង្គមភាសា នៅមានច្រើនទៀតទៅ តែថាពាក្យទេះច្រើនតែដូចគ្នា ឬក៏ច្រើនតែជាវប្បធម៌ប្រែប្រួលដូចតទៅនេះទៀ:

១- រៀបជាក ៣ ស្រង់ ៣: (តាមវចនានុក្រមខ្មែរភាគ ២)

ល្អក្រៃចិមិយូរត្ថនរ > ចិត្តល្អមិនក្រយូរ

រៀបរាប់ដូច្នេះ ពាក្យ "ចិត្តល្អមិនក្រយូរ" មាន ៨ ពាក្យ ។ គេតាប់ពាក្យដើម :

ចិ ត្ត ល្អ មិ ន ក្រ យូ រ

១ ២ ៣ ៤ ៥ ៦ ៧ ៨

ជាក: ល្អ ក្រ ចិ មិ យូ ត្ត ន រ

៣ ៦ ១ ៤ ២ ១ ៥ ៨

ដល់ជាកមកបានដូច្នេះ ល្អក្រៃចិមិយូរត្ថនរ ត្រូវតម្រូវត្រង់ស្រង់ឃើញជាសេចក្តីដើមវិញ

ស្រង់: ចិ ត្ត ល្អ មិ ន ក្រ យូ រ

១ ២ ៣ ៤ ៥ ៦ ៧ ៨

២- រៀបជាក ២ ស្រង់ ៤ ឬជាក ៤ ស្រង់ ២ :

បេះឆបមើឈ្នះងំ > បេះមិនឈ្នះបង់

មាន ៧ ពាក្យ ។ (នៅមានរៀបច្រើនទៀត)

ក) ពាក្យបង្ខែងដាន ដើម្បីដាក់ឲ្យខ្លះមកហើយដូចជាព្រះ-សង្ឃ ត្រូវគោរពនាំ "ទេសនា" លោកប្រើកូនសិស្សទៅរកទេសនា លោកមានពុទ្ធដីកាថា "សត្វហើរ" ។ រឿងនេះជាហេតុនាំឲ្យក្មេងដែលមិនយល់ន័យពាក្យនេះ ស្មានថាលោកបញ្ជាឲ្យទៅដេញចាប់សត្វមានជីវិតមកំរះហើយទៅដេញក់យសត្វកន្ទុំរុយមួយចានទៅប្រគេនលោក ។ ឧបាសក-សិកា ឃើញត្រូវសំនើកចង់ស៊ុដែរ តែមិនហ៊ានប្រាប់ឲ្យគេសម្លាប់ក៏ថាឲ្យយកទៅលែង តែបើយើងមិនយល់ន័យនេះមុខតែយកទៅលែងនៅបាតបឹងផុត ។ ពាក្យពិតវិញគោះមិនមែន "សត្វកន្ទុំរុយ" មិនមែន "យកទៅចោះចោលទេ" គឺ "សត្វហើរ ជាទេសនា" "លែងថាឲ្យទៅសម្លាប់" ។ ពាក្យទាំងនេះជាពាក្យបង្ខែងដាន ពាក្យរបៀបនេះ នៅមានច្រើនទៀត ។

ខ)- ពាក្យអាស្រ្កាម ឬពាក្យចំអែសចំអាស

ពាក្យអាស្រ្កាម ខ្ញុំមិនចាប់អធិប្បាយទេ ព្រោះថាលោកអ្នកធ្លាប់ឮមកជាញឹកញាយហើយ ។

សង្គមភាសាមានប្លែកៗគ្នា គេមានភាសាតិះសេះច្រើនទៀត ពុកប្រចាំតំបន់ការរបស់គេ ដូចជាភាសាអ្នកបរថ្មញ៉ា-ភាសាចំបាំង-ឬភាសាសំ-ពះអ្នកលែងលែ ។ ល ។ តែលុះកន្លងក្រោយ ។ មកជាច្រើនតំណពូជ

ប្តូរច្រើនសតវត្សមែក កាលដែលឡែមិនទាន់មានអក្សរសោស្តេនៅឡើយ
ភាសាប្រចាំក្រុមមុខការងារនោះ ក៏ចាត់ចែលខ្លះដែរ ។ ម៉ែចចានដា
ភាសាខ្លះចាត់ទៅ មកតែតិភាសានោះ មិនសូវមានសារប្រយោជន៍ បើ
មិនប្រើក៏ចានដែរ ហើយមួយទៀតយូរៗធ្វើម្តង ហើយខ្លះឆាប់ភ្លេចអ្វីតត់
ចំណាំ ម្ខាំះហើយក៏សាបសូន្យទៅ តែចំណែកភាសាដូចជាភាសារបស់
ពួកអ្នកចំប៉ាឆ-ពួកអារក្ស-រះបៀបភាកូន ដែលជាភាសាសំពាប់សាងជីវិត
គេនៅរក្សាទុករហូតមកដល់សព្វថ្ងៃ ។

ភាសាបរបាញ់ តាមមតិរបស់លោក (Edward D. Myers) និ-
យាយអំពីកំណើតរបស់ភាសា (The Origin of Language) ថា ពីដើម
ភាសាបរបាញ់មានត្រប់សង្គម តែគេរៀបៅបាញ់ គេលើកគ្នាទៅ
ប្តូគេទៅបាញ់សត្វទៅតាមវេជ្ជវែលគេត្រូវចេញទៅបាញ់ តែក្រោយ
មកអ្នកខ្លះលួចទៅម្នាក់ឯង ហើយមិនហ៊ានបង្ហើញសំឡេង-សំរែកអ្វីទេ
ខ្លាចគេដឹងឮ ។ បើតាមខ្ញុំពិនិត្យមើលទៅតាមមតិលោកខាងលើនេះ
ឃើញថាប្រហែលជា ២០ ឆ្នាំមុននេះ នៅស្រុកខ្លះ គេលើកគ្នាទៅបាញ់
សត្វមែន ។

ភាសាបរបាញ់ គេត្រូវនិយាយ ឬ ប្រើតាក្យសំដីទៅតាមសំរែក
របស់សត្វ ឬលំនាំរបស់សត្វ ដូចភាបរបាញ់ប្រើសត្តាន់ អ្នកប្រមាញ់ខ្លះ
យកស្នែកឈើមកផ្ទុំធ្វើជាសំឡេងសត្វ ។ អ្នកខាត់លលក ធ្វើត្រាប់សំ-

ខ្សែឆ័លលក គុកគ្រូ ! គុកគ្រូ ! ដើម្បីឲ្យលលកត្រៃមកវាលលកជាក់ ។ ចំណែកអ្នកខាងក្រួចវិញ គេក៏ធ្វើសំឡេងដូចក្រួច ដើម្បីឲ្យត្រួចមកចូលលច់ ។

ភាសាថាក់ជំរឿ យើងពិនិត្យមើលស្រុកខ្មែរខាងក្រៅ មិនថាសម័យមុនទេ សម័យយើងនេះ អ្នកខាងថាក់ជំរឿ គេច្រើនតែប្រើស្នែង ផ្ទុំស្នែងជាបន្ទះ ដើម្បីជាក់ស្តែងឲ្យដំរីខន់ចិត្ត ។

ខាងអ្នកស្ទូចត្រី គេមានភាសាប្លែកខាងក្រៅតែសំរាប់ក្រុមគេដែរ ។ បើលោកអ្នកធ្លាប់ជាអ្នកស្ទូចនៅតាមស្រុកស្រែ លោកអ្នកមុខតែយើញអ្នកស្ទូច "គោះខឹក" ដែលមានន័យថា "ហៅត្រី" ឬផ្លាត់ខឹកនឹងត្រាមដែរហើយគោលថា "មកវើយស៊ីចំណី" អាការៈបែបនេះបង្ហាញឲ្យយើញថា នេះជាភាសារបស់ក្រុមគេនេះដែរ ។

ភាសាខាងល្បែង

ក័ឡាអុំខ្លួនឆ : ពួកអ្នកក័ឡាអុំខ្លួនឆ គេតែងមានពាក្យគេសំរាប់បន្ទរ ឬស្រែកឲ្យមានកំលាំង អ្នកក្បាលស្រែកថា "មួយយើ ! " ហើយអ្នកអុំទាំងអស់គ្នាស្រែកព្រមគ្នាថា "មួយ ! " រួចបន្ទាប់ទៀត គេស្រែកព្រមគ្នាថា "អែយ៉ូសាប់ អែយោមួយ ! "

ក័ឡាអង្គញ់ : នៅក្នុងក័ឡានេះ គេឮពាក្យថា "ម៉ាយ " គឺគេនិយាយចំពោះអង្គញ់ណាដែលចុះត្រូវម្តងហើយ តែចុះត្រូវម្តងទៀត

គេថា " ម៉ាយ " ។ ដក, ណាប់, ប្រគ, ចាក់កន្ទុក, ស្មុគតែជា
ភាសាសំកង់អ្នកលេងអង្គញ់ ។

ក៏ឮឯខៀត ។ ដូចកីឡាក់យកកូនគោល គេស្រែកថា " ចាក់ "
ដើម្បីឱ្យអ្នកម្ខាងប្រុងប្រយ័ត្ន ក្រែងគេក់យកត្រូវដើង ។

ល្បែងចាប់កូនខ្វែង អ្នកលេងឈរនៅចន្លោះ ឬកាន់ចន្លោះចន្លុងគ្នា អ្នក
នៅមុខគេធ្វើជាមេមាន់ អ្នកនៅក្រោយជាកូនមាន់ ហួមានម្នាក់ខៀតធ្វើ
ជាមេខ្វែងចាំឆបកូនមាន់ ។ អ្នកលេងស្រែកថា " ចាប់កូនខ្វែងប្រខ្វែង
កូនមាន់យកមេទៅ មាន់យកមាន់ទៅលាក់ លាក់ឯណា . . . " ។

ល្បែងលាក់កន្ទែង អ្នកលេងអង្គុយជុំគន្លឹះគ្នាជុំវិញ មានម្នាក់កាន់
ក្រមា ឬ កន្ទែងមួយទៀតរត់ក្រឡឹងជុំវិញថា លាក់កន្ទែង ឆ្នាំកែង
អូសលោង . . . ហើយគេដាក់មួយកន្ទែងទៅក្រោយខ្នងអ្នកអង្គុយម្នាក់
ដល់អ្នកនោះដើរមកកន្ទុងដែលគេទុកកន្ទែងនោះវិញ អ្នកអង្គុយមិនដឹង
ខ្លួនគេត្រូវក់យមួយកន្ទែង ។ បើសិនជាអ្នកអង្គុយឃើញកន្ទែងទៅ
ក្រោយខ្នងត្រូវយកកន្ទែងហើយដេញដុំវិញខាងក្រោយអ្នកអង្គុយ ហើយ
ស្រែកថា លាក់កន្ទែង . . . . " ។

ឯល្បែងអុក គេថា " អុក " ជាន់ឮថាគេប្រុងស៊ុំស្ដេចហើយ ។

យើងឃើញហើយថា សង្គមមួយ ។ មានភាសាប្រចាំក្រុម ។ ឥឡូវ
មើលកូនក្មេងលេងល្បែងក្តី ក្មេង ។ ច្រើនតែជ្រើសរើសឆ្លាក់ថា « ជ្រាំ
យ៉ាស៊ុង » បើអ្នកណាចាញ់គេត្រូវចាំទី បើឈ្នះគេត្រូវធ្វើ ឬ ផ្តើម
លេងមុនគេ ដូចជាបោះឡូជាដើម ។ បើមិនថារបៀបនេះទេ គឺគេ
ថា " ត្រាយត្រក ត្រាយត្រែងចាក់កាអេងណាំខ្វែកចាក់កាឆ្វែក ដួយាំ
ជីកាជាហិច " ។ របៀបនេះ បើអ្នកណានៅសល់ក្រោយគេត្រូវចាំទី។

៣- ភាសាសំរាប់អារក្ស ឬ អាគមភាសា (Magic Words)

ក)- ភាសាប្រើក្នុងអារក្ស បើហៅថា ព្រហ្មញ្ញភាសាក៏សឹងតែ
ចាន ។ ភាសាអារក្សស្ទើរតែមានមនុស្សតិចណាស់ ដែលចេះភាសា ។
ចម្ងាយនៃដែលមិនសូវឮអារក្សអ្នកគា ស្ទើរតែមិនដឹងន័យភាសានេះអស់
ទៅហើយ ។

(នៅមានត)

(តមក)

Paragraphe	(n.f.)	កថាខណ្ឌ (ព.ប្ប) : ចំណែកនៃផ្នែក ។
Partie	(n.f.)	ភាគ (ព.ប្ប.)
Peine	(n.f.)	ទោស (ព.ប្ប.)
Prescription de l'action		អាជ្ញាយុកាលនៃបណ្តឹង (ព.ប្ប.)
Prescription de l'acquisition		អាជ្ញាយុកាលនៃលទ្ធកម្ម (ព.ប្ប.)
Prescription de la peine		អាជ្ញាយុកាលនៃទោស (ព.ប្ប.) : ធ. ការដុតរលត់សិទ្ធិធ្វើទោស ដោយហេតុថា កាលបរិច្ឆេទនៃការដាក់ទោស ឃ្លាតឆ្ងាយអំពីកាលបរិច្ឆេទនៃការទទួលទោស យូរអង្វែងពេក ។ ខ. អាជ្ញាយុកាលនៃទោសខ្រិនមានកំណត់ ២០ ឆ្នាំ ។
Prononcer la peine		ធ្វើទោស
Purger la peine		រងទោស
Régnicole	(n. & adj.)	ខ្នើរស៊ី
Réprimer une infraction		ទប់ក្រោះបទល្មើសមួយ ។
Répression	(n.f.)	ទប់ក្រោះ
Répressif	(adj.)	ទប់ក្រោះ

(នៅមានត)

វិបដានុក្រមសំស្ក្រឹត-ខ្មែរ

ព្រះមហា ទាំង . ខាត់ រៀបរៀង

(តមក)

អតិរិទ្ធ គុ. ដែលចំរើនក្រៃលែង, ធំ, ប្រសើរ ។

អតិរិទ្ធិ ស្ត្រី. សេចក្តីចំរើនក្រៃលែង ។

អតិរិប្ត ឆគុ. ក្តៀងក្រៃលែង ។

អតិរិប្តិ ស្ត្រី. ការយាក្តៀងក្រៃលែង ។

អតិរេគវន្ត គុ. ដែលមានសន្ទុះក្រៃលែង, ដែលមានល្បឿន ។

អតិរេទនា ស្ត្រី. វេទនាក្រៃលែង

អតិរេបបុំមន្ត គុ. ដែលញាប់ញ័រក្រៃលែង ។

អតិរេបក្សណ្យ នប៉ុ. ការនៃការគិតចារណាយើញច្បាស់ក្រៃលែង,ការគិតសោធន៍ ។

អតិរេភស គុ. ដែលត្បះត្បាប់ក្រៃលែង,ដែលដិលត្បាប់ក្រៃលែង ។

អតិរេមណ្យ នប៉ុ. ភាវៈនៃ (នៃខន្ធ) មានភាពស្មើគ្នាទៅគ្រាសហើយក្រៃលែង, ភាពមិនស្មើគ្នា ។

អតិរៀបិត គុ. ដែលឈឺចាប់ក្រៃលែង ។

(នៅមានត)

កំណែទី ៤៨

ទកញ៉ាវិបុលភជនសេនា ឧ-ត្រ ជ ប្រៃរឿបរឿង

(តមក)

> រឿងសាអាកុកទុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃធ្វើសបើបានអាន
> ទំនិះទៅយកលក្ខណាន
> ពាំងមានសន្តានស្នេហាជាតិ
>
> ——ឃ្លះ-ឆ្លុន——

ខ្ញុំតាំថា ស្រុកកេងដីវាខេះ កំសូម្បីកបតាបហើយ បើនិយាយអ្នកខ្សែទៅផងក៏មិនសមគួរ ឃើញនៅទំនេរតែស្រុកឡយគឿងទាងទំសបូតា គឿងទត្តរបម្ងាយផ្លូវតើខេះទៅប្រហែល ១.៣០០ សិន (៥២ គ.ម.) មិនទាន់មានទៅហ្វាយស្រុកថ្មី អញ្ជើញអ្នកទៅស្រដីកជាការធ្វើជាទៅហ្វាយស្រុក ទៃត្រនោះសិនចុះ, បើថ្ងៃក្រោយមានទីដទៃក្រៅពីនោះគួរសមសឹមខ្ញុំឡើងស់ចេញពីទីនោះ ។ ជាំងឥឆងកំតិតកងចិត្តថាខ្ញុំតាខេះមើលងាយហើយមិនពប់អានអញ្ជើសោះបើអញ្ជើទៅសន្ធានាឡើយើញសតិបញ្ញាសោតខ្ញុំឆងបេងកំមិនទៅទៀត ត្រូវតែប្រថុយខ្លួលទៅចុះ តិតដូច្នោះហើយក៏លាខ្ញុំតាទៅ ។

លុះទៅដល់ស្រុកឡុយអៀនភាលណា ចុំនឹងថនក៏ចេះតែផឹកស្រាស៊ីដេក ក្រោកពីដំណេកផឹកស្រាមិននិយាយការរាជការសោះ, បណ្តាក្រស្តេកនឹស្រុកនោះពាស់អស្សាស្រ័យ ក៏ចូលមកស្រដីផ្តិនផ្តល់ដល់ខ្លៅតាថា ចុំនឹងថនចេះតែផឹកស្រាស្រវឹង គ្មានប្រើនិយាយការដោះសុខទុក្ខបណ្តាក្រស្តេ តាមសណ្តាប់ធ្នាប់អ្នកធំសោះ ។ ខ្លៅតាឮដូច្នោះខឹងណាស់ ក៏និយាយថា ចុំនឹងថនោះជាមនុស្សមិនល្អនាំឲ្យយើងខូចការ កំពុតប្រើខ្ញុំវហ៊ុយជាអាជ្ញាកណ្តាល ទៅមើលចុំនឹងថនឯស្រុកឡុយអៀន ដើម្បីឃើញមិនយកចិត្តទុកជាក់នឹងធ្វើការតែប្លែកជាងដូចពាក្យក្រស្តេមកប្តឹងមែន ត្រូវឲ្យបញ្ជូនខ្លួនមក តែតាហ៊ីយក៏ត្រឡប់មានស្មារតីថា ខ្ញុំវហ៊ុយធ្វើការអ៊ីរមែនប្រឡែសបើសណាស់ ក៏ឲ្យស៊ុនខៀនទៅអមជាមួយផង ដើម្បីនឹងជាន់ជួយមើលការខុសត្រូវ ។

ខ្ញុំវហ៊ុយ, ស៊ុនខៀន នឹងគាហានក៏នាំគ្នាទៅដល់ស្រុកឡុយអៀន ឃើញតែគួកគាហាននឹងក្រស្តេនាំគ្នាចេញមកទទួលក្រៅស្រុក មិនបានឃើញចុំនឹងថនចៅហ្វាយស្រុកចេញមកគួរសមតាមធម្មតា ខ្ញុំវហ៊ុយសួរថា ចៅហ្វាយស្រុកទៅណា ហ៊ានជាមិនចេញមកទទួលយើង ។ ក្រស្តេតាំងអស់ឆ្លើយថា លោកចៅហ្វាយស្រុកផឹកស្រាស្រវឹងដេកលក់ទៅហើយ ។ ខ្ញុំវហ៊ុយឮដូច្នោះកំខឹងណាស់ ចង្អាប់គាហានឲ្យទៅចាប់ខ្លួនចុំនឹងថនមាំមក ។ ស៊ុនខៀនក៏ហាមឃាត់ខ្ញុំវហ៊ុយថា កុំអាលខឹងប្រញាតម៉ាស.

ដាំយកតេ ត្រូវយើងចូលទៅតដន្ត្រីក យកខ្ទះមកសាកសួរឲ្យដឹងការណ៍
ឲ្យស.ត្រូវសិន បើតិតក្រែងដូចគាស្បែកស្ត្រីទៅជួនសារខ្លួនមែន ស៊ីមកធ្វើ
តាមចោស ។ ខៀវហ៊ុយឮដូច្នោះក៏យល់ឃើញត្រូវ ទើបនាំគ្នាចូល
ទៅសាលាកណ្តាល ហើយឲ្យបំរើចូលទៅហៅខ្ទះចាំងថងចេញមក ។
បំរើចូលទៅឃើញចាំងថងកំភុងស្រវឹងស្រា កំត្រាចេញមកអង្គុយ ។
ខៀវហ៊ុយឃើញចាំងថងស្រវឹងដូច្នោះទើងណាស់ទិយាយថា ចងខ្ញុំ
យល់ឃើញថា អ្នកដាមខ្សត្តិយជាឲ្យមកធ្វើចៅហ្វាយស្រុក ហេតុ
ម្តេចអ្នកមកអង្គុយសំកុកផឹកតែស្រា លះចងំការពេជការមុខងារបេស់ខ្លួន
សួរឲ្យសោះ ។ ចាំងថងឮដូច្នោះក៏អស់សំណើចហើយថា អ្នកមកនិយាយ
ថា យើងលះបងំការពេជការមុខងារកេងវៃត្រនោះ តើលះបងំដូចម្តេច? ។

ខៀវហ៊ុយថា អ្នកមករក្សាសេចក្តីសុខទុក្ខក្រុកក្នុងស្រុកនេះជាង
១០០ថ្ងៃហើយ ចេះតែផឹកស្រាមិនបានគាត់សេចក្តីតាមការបណ្តឹងដែល
ក្រុកប្តឹង ពាលតែប្រជាក្រុកចូលទៅសារខ្លួន ។ ចាំងថងថា ស្រុក
នេះតួចណាស់ ក្រអ៊ូនឹងគាត់សេចក្តីប៉ុណ្ណេះ អញ្ជើញអង្គុយចាំខ្ញុំមួយស្រែ-
បក់ចុះ ខ្ញុំនឹងដុះគាត់សេចក្តីដែលក្រុកប្តឹងនោះឲ្យអ្នកស្តាប់ ចាំងថងក៏ឲ្យ
យកការបណ្តឹងចាំងពីរចាំងមកធ្វើយ ហើយឲ្យហៅតួក្តីចាំងសងខាងមក
អង្គុយរៀងគ្នាពេញចាំងសាលា ហើយឲ្យស្មៀនសូត្រសារការបណ្តឹង
ទីងចម្ងាយទៅវិញទៅមកចប់ចុះ ត្រចៀកចាំងថងនោះក៏ធ្ងៀងស្តាប់ ដៃក៏

ចាប់ពីតសរសេរកត់ត្រា មាត់ពីភាក្សាកាត់សេចក្តីវែរហ៍សពំនរៃដពំនមាត់
ស្ងាត់ពំនស្តាប់ចំណាប់ពំនស្មារតីរៃពំនច្រូជាព្រមគ្នា តែមួយស្រមៃក៏
កាត់អស់សេចក្តីពំនប៉ុន្មានគ្មានពស់អច្បាស្រ័យនៃគូក្តីណាមួយ ត្រូវសេ-
ចក្តីតាមច្បាប់ត្រង់មាត្រា សារក្រមដែលពិភាក្សាក៏សរសេរបួចជាស្រេច ។
អស់អាណាប្រជាទុកស្រួតពំនល្អាយ កំនាំគ្នាកោតសរសើតម្រេះច្រូជា
អំនកនំទួ៧ ។ ចុំនឆនក៏និយាយនំនខៀវហ៊ុយថា ខ្ញុំលះបនំមុខការ
នោះសោត តើមុខការអ្វី ? សូមថាមកខៀតចុះ ។ ខៀវហ៊ុយថាសេចក្តី
ពំនអច្បាលនេះក៏អស់លើនពៅហើយ ។ ចុំនឆនថា បើសេចក្តីតែ
ត្រឹមប៉ុណ្ណេះខំនំនជាអ្វី ខ្ញុំនំនិយាយមិនចានឬ ? តែមិនសច្បាយចំតួចាន
ជាមិនរៀលំនំនជំរះកាត់សេចក្តី ពោះបីភាគជការខានបួនំនំសុំនតួនក្តី ក៏មិន
ដួចជាខ្ញុំចាប់សរសេរអក្សរលើចានដៃប៉ុណ្ណោះ បើលាដៃមើលកាលណា
ក៏នំនឃើញច្បាស់កាលនោះពំនអស់ ។ ខៀវហ៊ុយឮដូច្នោះ ក៏តក់ស្លុត
ក្នុនចិតួនិយាយនំនចុំនឆនថា ខ្លៅពីនំនខ្ញុំពុំចានដឹនំនសោះខ្លើយថា អ្នក
មានតម្រេះច្រូជាជល់ប៉ុណ្ណោះ តិតថាអ្នកលះបនំការភជការសោះ ចាន
ជាប្រើខ្ញុំមកពិនិត្យមើល ដើម្បីនំនចានជួយដាស់តឿនកុំឲ្យថ្លង់ភ្លោយ
ឥឡូវខ្ញុំមកឃើញច្បាស់នំនំនក្អែកហើយ នំនវិលខៀវដំរបខ្លៅតឲ្យច្រាប
កិច្ចការវិញ ។ ចុំនឆនក៏យកសំបុត្រខ្លោសុកឲ្យមកជល់ខ្លៅតីនោះឲ្យ
ស៊ុនខៀនបើកមើលឲ្យខៀវហ៊ុយស្តាប់ ។

ខៀវហ៊ុយឮសេចក្តីសំបុត្រនោះសព្វគ្រប់ ក៏សួរចាំឆ័ថឆ័ថា កាលដែលអ្នកមកជួបនឹងខ្លៅតាំងនោះ ហេតុអ្វីក៏មិនឲ្យសំបុត្រនេះទៅខ្លៅតាមើល ។ ចាំឆ័ថឆ័ថា កាលជួបគ្នាតាំងបួនោះ ខ្លៅតាក៏មិនបានដឹងថា ខ្លួនខ្ញុំជួចម្តេចសោះ បើនឹងចង្ហាញសំបុត្រនោះឲ្យមើល ក៏ហាក់ដូចខ្ញុំក្លែងសុំសំបុត្រគេមកថង្ហតខ្លួនឯង ពុកឲ្យអ្នកដទៃសរសើរដំនួសាញាវិសេសជាង រួចសឹមបង្ហាញសំបុត្រនេះជាកស្តតាង ។ ខៀវហ៊ុយក៏និយាយនឹងស៊ុនខៀនថា បើកុំតែអ្នកយាត់យាំងក៏ងក៏ងក្ងិតដូបួននឹងមិនជ្រុលខួចការទៅទេឬ ? ថាតែប៉ុណ្ណោះហើយ ខៀវហ៊ុយនឹងស៊ុនខៀន ក៏លាចាំឆ័ថឆ័ទៅស្រុកកេងជាវិញ លុះទៅដល់កំពង់ណានោះសេចក្តីឲ្យខ្លៅតាស្តាប់ត្រប់ប្រការហើយហុចសំបុត្រឲ្យខ្លៅតាមើលដែលមានសេចក្តីថា :

" ចាំឆ័ថឆ័នេះ បានរៀនសូត្រចេះដឹងវិជ្ជាសិល្បសាស្ត្រច្រើនណាស់ជាមនុស្សមានតម្រេះប្រាជ្ញាគួរតាំងជាទីប្រឹក្សាលោកបាន បើនឹងក្រឡេកមើលខ្លួនប្រាណ កំឃើញថា រូបកាយខាងក្រៅមិនសមជាអ្នកមានតម្រេះប្រាជ្ញាសោះ ខ្ញុំមានសេចក្តីស្តាយស្រណោះចាំឆ័ថឆ័ណាស់ ខ្លាចក្រែងស្នែងស្នុះទៅទៅនឹងអ្នកដទៃទៀត ទើបខ្ញុំទំនៀតសរសេរសំបុត្រឲ្យចាំឆ័ថឆ័តាន់មកជួបនឹងលោកសិន " ។

ខ្លៅតាបានឃើញសំបុត្រដូច្នោះ ក៏ទៅគិតត្រិះរិះសន្ធិះសង្ឃឹយខ្លួលតាហានបួលទៅថ្វែងសេចក្តីថា ពុំដឹងបងត្រឡប់មកវិញហើយ ។ ខ្លៅតា

ក៏ចេញទៅខួលចូលមក ហើយទុំនបេន៏សួរថា ចុំនឹងថនឹងបានមកនៅ
ឥនឹលោក តើគេបានសេចក្តីសុខសប្បាយទេឬ ? ។ ខ្ញុំតបវិញថ្លែងឆ្លើយ
ថា ចុំនឹងថនឹងបានមកជួបឥនឹនខ្ញុំ ។ កំតាំនឹងទៅធ្វើចៅហ្វាយស្រុកឡងអៀង
ចេះតែលះបង់ការងារមិនបានត្រួតត្រានិយាយឡែកស្តួបានសេចក្តីសុខចិត្ត
គិតតែផឹកស្រាត្រីកល្ងង់ជាមិនខ្លួ ហើយជេកឆ្មេចមិនធ្វើការអ្វីសោះ ។
ទុំនបេន៏ឮដូច្នោះ កំអស់សំណើចហើយថា ចុំនឹងថនេះជាមនុស្សបានរៀនវិជ្ជាចេះដឹងមានតម្រេះប្រាជ្ញាច្រើនណាស់ ចំពោះតែនឹនខ្ញុំតុំមែនដូចគ្នាទេ តេចេះជានឹខ្ញុំ ១០ ភាគទៅទៀត ខ្ញុំបានសរសេរសំបុត្រឆ្លើតុកដូនលោកមួយច្បាប់ផង ចុំនឹងថនដូនមកលោកឃើញឬទេ ។ ខ្ញុំតបឆ្លើយ
ថា ថ្ងៃនេះ បានឃើញតែសំបុត្រខ្មៅសុកឆ្លើមក ឯសំបុត្រចេស់លោក
មិនបានឃើញទៅឡើយ ។

ទុំនបេន៏ថា លោកតាំនឹចុំនឹងថនឹទៅធ្វើចៅហ្វាយស្រុកឡងអៀង
ដែលជាស្រុកតូចនោះ ប្រហែលជាខាស់ចិត្ត បានជាកែ្លងលះបង់មុខការ
ងារកេជការ ផឹតតែស្រាស៊ីដែកដូច្នេះ ។ ខ្ញុំតិចថា បើទៀហ៊ុយមិនមក
ច្រាប់ កំនឹនឹងបួចអសារមនុស្សមានប្រាជ្ញាម្នាក់ទៅសោះ ហើយទុំនបេន
ក៏ប្រើទៀហ៊ុយឲ្យទៅអញ្ជើញចុំនឹងថនមក ។ ទៀហ៊ុយកំទៅអញ្ជើញចុំនឹង
ឯស្រុកឡងអៀងមកដល់ស្រុកកេនដែរ ។ ខ្ញុំតិច ទុំនបេន៏ កំនាំគ្នា
ចេញទៅខួលចុំនឹងថនដល់ក្រៅទ្វារស្រុកគំនាប់គ្នាតាមទំនៀម ហើយ

ខ្លៅតាកំនិយាយថានឹងចាំនឹងចនថា ខ្ញុំជាមនុស្សគ្មានស្រាលហើស ទើបមិនបានស្គាល់ឮស់ថា អ្នកមានតម្រេះច្រើនឮ ចាត់ប្រើអ្នកឱ្យទៅធ្វើការស្រែកតូចនោះ ខ្ញុំសុំសារគាតខ្លួនខ្លុស ឱ្យអ្នកអនុគ្រោះលើកទោសម្តងចុះ លុះនិយាយហើយក៏នាំគ្នាទៅអង្គុយលើគេហដ្ឋាន ។ ចាំនឹងក៏យកសំបុត្រខ្លឹងបងឱ្យភ្ញាក់ទៅខ្លៅតា ។ ខ្លួលយកមកមើលឃើញសេចក្តីថា ៖

“ ហនសូដែលជាឈ្មោះចាំនឹងនោះ បើបានមកដល់វេលាណាសូមឱ្យខ្លៅតាខ្លួលក្បាលុកចុះ ព្រោះនឹងបានជួយធ្វើការ ” ។

ខ្លៅតាឃើញសំបុត្រដូច្នោះ ក៏មានចិត្តសោមនស្សត្រេកអរណាស់ថា ៖ “ ខ្ញុំក្មេងសួនឮសោះ ទើបតែនឹងលឺកនឹកឃើញតាកុសុមាតេកជាជាអាចារ្យបានឱយាយខ្លុកនឹងខ្ញុំថា ហុកឮឯងនោះគឺ ខ្លឹងបង ហនសូគឺចាំនឹង ចាំន ២ នាក់នេះ បើបានតែឈ្មោះណាមួយ ក៏នឹងជួយច្រាមច្រាច់សត្រូវផែនដីបាន គ្រានេះ កំបានមកច្រមគ្នាចាំងតែនាក់ហើយ គួរតែខំខ្លុកបំរុងផែនដីព្រះចៅហៀនតេ ឱ្យបានរុងរឿងតទៅ ទើបតាំនចាំនចាំងជាខ្លឹប្រឹក្សាជាមួយគ្នានឹងខ្លួនបង ឱ្យជួយចំប្រឹងបង្ក្រាត់សេនាពាហនឱ្យចំណានស្អាត់កងក្បួនតាជ័យសង្គ្រាម ព្រមទាំងកិច្ចការពារគ្រប់ដំណាក់ក្នុងស្រុកខេស កំជាសិទ្ធិដល់ខ្លួនបងនឹងចាំនឹងចាត់ចែងត្រួតត្រាទាំងអស់ ។

ពួកអ្នកស៊ើបការ កំនាំយកតតិមានៅឡដំណាំនចូនួ ឯស្រុកហ៊ូតោ
ថា ខ្លាតិចាន១ងំបេងនំនចាំងថងមកជាតិប្រឹក្សា ប្រើប្រាជ្ញបញ្ជុះបញ្ចូល
សេនាតហានំនប្រមូលឲ្យចានស្បៀងអាហារ នូវគ្រឿងសាស្ត្រាវុធជា
ច្រើនណាស់ មុខជាំនរួមតំនតាំជាស្រេឡះៅតាងស៊ុនគួន ហើយ
លើកតំតមកដោយអាការគុំគួននំនធ្វើអន្តរាយលោកជាប្រាកដ ។ ចូនួព្ធ
ដូច្នោះ កំឲ្យប្រមូលតិប្រឹក្សានំនសេនាតហានមកប្រជុំពិគ្រោះ ដើម្បីនំន
លើកតំតៅតាងំសនាកូណ ។

ស៊ុនហ៊ីវកំដំរាបចូនួថា ខ្ញុំចានយល់ថា ដាវយើតើចនំនស្ងាប់ មិនតាន់
មានមេកងំតំនំនតិប្រឹក្សាទេ គួរនំនលើកតំតៅវាយយកស្រុកកាំងតាំង
តនំនំនចានដោយស្រួយ រួចសឹមលើកៅវាយយកស្រុកកេនដាវៀត ។
ចូនួថា យើងនំនលើកតំតៅ ផ្លូវតីឆ្ងាយខ្លាចក្រែងមាំថេងដំនំនលើកមក
វាយយកស្រុកហ៊ូតោ កាលក្រោយដែលយើងលើកតំត ៨ សែន ៣ ម៉ឺន
ៅវាយយកស្រុកកាំងតាំង គ្រានោះ ចានក្លាតេនិយាយថា មាំថេងចៅ-
ហ្វាយស្រុកសែលៀង ប្រុងនំនលើកតំតមកវាយយកស្រុកហ៊ូតោ បើ
ដូច្នោះវេលានេះ យើងត្រូវប្រុងប្រយ័ត្នចាត់ចែងឲ្យនៅរក្សាស្រុកជាមាំ-
មួននើបចាន ។

ស៊ុនហ៊ីវថា ខ្ញុំចានយល់យើញថា បើចាម្តុខាតដូច្នោះត្រូវតែ
បរណ្តែតឲ្យមានក្រេតម្រាស់ក្រេរចៅហ្នឹងតេរាជសំមាំថេង លោកជា

អ្នកខ្លួលព្រះតម្រាស់ តាំងមាំថេងឲ្យរៀនខ្លាំងខ្លាយខាហានធំ ទីឆ
ឲ្យប្រាប់ប្រាមអាណាខែត្រខាងខំសេកស្ងួណ គឺចាំងយកស្រុកស៊ុនគួន
តែត្រូវហៅយកទ្វួនមកគិតកងការសឹង កាលណាមាំថេងមកដល់ហើយ
យើងត្រូវចាប់សម្លាប់ចេញ រួចសឹមលើកទ័ពទៅកាយយកស្រុកតាំងតាំង
ជាខាងក្រោយ ម៉ើគិតដូច្នេះហើយ ទើបអស់កិច្ចឆ្ងុះ ។ ចូនឆ្លើយដូច្នោះកំ
យល់ឃើញត្រូវ ទើបឲ្យសរសេរសំបុត្រព្រះតម្រាស់ព្រះចៅហៀនតេ ដូច
ពាក្យស៊ុនហ៊ីវ៉ាថា ហើយប្រើព្រះពលជំរើកាន់ទៅឲ្យមាំថេង ។

មាំថេងខ្លួលព្រះតម្រាស់ហើយ កំឲ្យហៅមាំឈៀវ, មាំហ៊ុវ មាំធៀត
ជាកូន ទីឆមាំតាយជាកូយមកប្រឹក្សាថា ពីដើមតាំងស៊ុនខ្លួលព្រះតម្រាស់
ព្រះចៅហៀនតេទៅរៃគិតគ្នាទីឆឡៅតី ដើម្បីទីឆកំចាត់ចូនួចេញ តាំងស៊ុន
ធ្វើការនោះមិនកំចាំង ចូនួកំចាប់ខ្លួនតាំងស៊ុនសម្លាប់ចេញ យើងនឹងឡៅ-
តីកំដោះខ្លួនតែរួចទៅ យើងមកនៅស្រុកសៃលៀងនេះក៏ជាខ័កំចាំង ហើយ
ឮនឮដំណឹងថា ឡៅតីទៅកាយយកស្រុកគេងដាវ យើងក៏គិតចង់ទៅគេ
ដើម្បីទីឆជួយខំនុកបំរុងឡៅតី ឥឡូវចូនួឲ្យមានសំបុត្រព្រះតម្រាស់ព្រះ-
ចៅហៀនតេឲ្យមកហៅយើង ។ ទីឆគិតប្រការម្តេច ? ។

មាំឈៀវទ្វើយថា ចូនួកាន់ព្រះតម្រាស់ព្រះចៅហៀនតេឲ្យហៅ
ត្រូវតែទៅកុំខាន ម៉ើពុំបានចូលទៅដូចរឹងទីឆគង់ទីឆមានខាស តែបើ
ទៅដល់ស្រុកក្រុងហើយ ត្រូវតាំងចិត្តមើលការឲ្យស្រួលសិន ម៉ើឃើញ

ល្មមនឹងធ្វើការបាន កំត្រូវធ្វើតាមព្រះតម្រាស់ព្រះចៅហៀនតេ ត្រាដែលព្រះអង្គទ្រង់ព្រះអក្សរដោយលោហិតនោះ, មាំតាយជាកូយធ្វើយថា ចូរឲ្យជាមនុស្សចេះរិះគិតល្អិតល្អៀតណាស់ ម្ចាចក្រែងឲ្យហៅទៅដល់ហើយនឹងធ្វើអន្តរាយដល់យើងខ្ញុំឬទេដឹង? ។ មាំឈៀវថា ខ្ញុំសុំលើកតាហានទៅជាមុន នឹងលុកយកស្រុកហ៊ូគោតែម្តង ដើម្បីនឹងជួយគ្រប់គ្រងដែនដីនៃព្រះចៅហៀនតេ ដូចគំនិតចិត្តដែលគិតខុកនោះ ។

មាំថេងថា ចៅកុំគាលគិតវែរឡើយ យើងនឹងខុកចៅខ្លួវហ៊ានសុីយជាសម្ងាញ់យើង ឲ្យនៅរក្សាស្រុកសែសៀងចុះ ខ្លួនយើងនឹងមាំហ៊ុវ មាំ-ឆៀត មាំតាយ នឹងលើកតាហានទៅស្រុកហ៊ូគោ បើព្រះតម្រាស់ឲ្យហៅពិតក្តី មិនពិតក្តី វានឹងធ្វើអន្តរាយ យើងប្រកាន់ម្តេចកំតាមការ តែយើងមានសេចក្តីបារម្ភក្រែងបាននៅរក្សាស្រុកឯតាយ ទើបមាំថេងចែងតាហានទាំងឡាយឲ្យទៅរក្សាស្រុកខ្លះ យកតាហាន ៥ ពាន់លើកចេញ-ទៅ ឲ្យមាំហ៊ុវ មាំឆៀតជានាយទ័ពមុខមាំតាយជានាយទ័ពក្រោយ លើកទៅដល់ជិតស្រុកហ៊ូគោ ប្រហែល ២០០ សិន (៨ គ.ម.) កំចុះទ័ពឈប់នៅទីនោះ ។

លុះចូនថ្ងៃដើនដំណើន កំបង្គាប់អ៊ុយកុយឲ្យចេញទៅជួបនឹងមាំថេង ក្រោះមាំថេងលើកតាហានមកច្រើន បើនឹងចូលទៅកំឲ្យចូលតែខ្លួន មាំថេងនឹងតាហានមានឧបសគ្គ ។ ដើម្បីនឹងចូលទៅក្រាបបង្គំគាលព្រះចៅ

ហៀនតេ ឯបណ្តាកូនភាហានដែលហ៊ានមកតតិះម្ខាយនឿយហាត់ បើខ្លះ
ខាតដោយស្បៀងអាហារកំត្រូវឲ្យនៅត្រឡមការខាងក្រៅចុះ លុះខ្ញុំស្លេក
ខាងយកស្បៀងអាហារទៅឲ្យ ។ អ៊ុយកុយឧបាសកក៏ចូលទៅហើយ កំចេញ
ទៅជួបនឹងមាំថេង គំនាប់គ្នាហើយ កំនាំគ្នាធ្វើកស្រោនឹងបរិភោគអាហារ
ឯអ៊ុយកុយ កាលធ្វើកស្រោស្រេចកំនិយាយថា បិតាខ្ញុំឈ្មោះអ៊ុយអ៊ួន
ឧបាសកនៃក្នុងកាលគ្រា លំឈុយ កុយគឺលើកទ័ពមកធ្វើអន្តរាយដល់ទី
ក្រុងកជកំនក្រុងចៅហៀនតេ គ្រានេះចិត្តខ្ញុំក៏តុំមានទឹងនឹងតុំគួរអ្វីសោះ គ្រា
នេះ កំមកជួបប្រទះនឹងអាសត្រូវចំពោះកជសម្បត្តិខៀត ។

មាំថេងសួរថា ខរណាជាសត្រូវចំពោះកជសម្បត្តិនោះ ? ។ អ៊ុយ
កុយទ្វើយថា គឺចូនូនោះឯងជាសត្រូវចំពោះកជសម្បត្តិ អ្នកមិនដឹងទេឬ?
បានជាធ្វើមកសួរខ្ញុំ ។ មាំថេងគិតមនុស្សកនឹងចិត្តថា អ៊ុយកុយជាពួកចូនូ
ខ្លាចក្រែងប្រើមកបញ្ឆោតយកការ កំធ្វើជាតក់ស្លុតរន្ធត់ញាប់ញ័រអេះអាំង
ខ្លួន ហើយថាអ្នកកុំចោទជូចុះ ចិត្តចូនូនេះមិនមែនដូច្នោះទេ បើដឹង
ដល់ចូនូហើយ យើងកំត្រូវនាំគ្នាស្លាប់អស់រលីងតែការ ។ អ៊ុយកុយកំ
ស្រែកគំហកឲ្យមាំថេងថា អ្នកក្លែចហើយឬ ? កាលព្រះចៅហៀនតេ
ទ្រង់ព្រះអក្សរចេញមកដោយព្រះលោហិត គ្រានោះ យើងជាខ្ញុំព្រះអង្គ
ក្រោកដ មិនមែនជាខ្ញុំអាស្រ័ចូនូនោះទេ អ្នកកុំមនុស្សសង្ស័យអ្វីនឹងខ្ញុំ
ឡើយ ការគំនេះហើយ ខ្ញុំក៏ត្រូវដួយគិតអ្នក មាំថេងស្លាប់មាត់អ៊ុយ

កុយចរចាចំពោះនឹងមាត់ដូចគ្នា ក៏យល់ថា មិនមែនល្បួងបញ្ឆោត ក៏ជ្រាបក៏ចុះការអាចក៏ចាំងតាំងពីដើមពោះឡើងកុយស្គាប់ត្រចាប់ប្រការ ។

អ៊ុយកុយឮដូច្នោះក៏ជ្រាបថា ឯបួនដែលឲ្យហៅអ្នកចូលទៅតាល់នោះ មិនមែនពិតត្រង់ទេ បើអ្នកចូលទៅវេលាណា គេនឹងចាប់សម្លាប់វេលានោះ ចូរអ្នករិះគិតប្រយ័ត្នខ្លួនឲ្យមាំមួន ។ មាំថេងថា តំនិតបួនោះគឺតិតដូចម្តេចខ្លះ អ្នកទៅកន្លែងស្រុកនេះជាមួយ តង់ទឹងដឹងមិនខាន សូមឲ្យអ្នកជួយគិតចុះខ្ញុំនឹងធ្វើតាម ។ អ៊ុយកុយថា ដែលបួនឲ្យហៅអ្នកចូលទៅតាល់ព្រះចៅហៀនតេនោះ អ្នកត្រូវធ្វើយាទៅវិញថា ទើបមកពីស្រុកឆ្ងាយកំពុងទឿយហត់ណាស់សូមឲ្យបង្អង់ឈប់សិន ព្រឹកនេះ បួនឲ្យយកស្បៀងមកឲ្យ ហានអ្នក មុខជាបួនឲ្យចេញមកមើលកលការខ្លួនឯង បួនចេញមកហើយ ឲ្យអ្នករិះគិតចាប់ខ្លួនវាសម្លាប់ឲ្យបាន ។

មាំថេងឮដូច្នោះ ក៏គេញាចិត្តណាស់ថា ការខាងក្នុងស្រុកឲ្យអ្នកជួយគិតកែវិញចុះ ឯការខាងក្រៅនោះខ្ញុំនឹងរិះគិតខ្លួនឯង និយាយគ្នាហើយអ៊ុយកុយក៏លាមាំថេងទៅជ្រាប់បួនថា មាំថេង ទើបឲ្យមកពីស្រុកឆ្ងាយកំពុងទឿយហត់ណាស់ ដែលឲ្យបួលមកគាល់នោះសុំឲ្យលោកបង្អង់សិន ជ្រាប់ហើយអ៊ុយកុយក៏លាបួនទៅផ្ទះ ខំត្រិះរិះដែលនឹងគិតធ្វើអន្តរាយបួន ក៏ខ្វាចមិនសម្រេចដូចជ្រាប់ថា តាំងតែគិតសាចុះសាឡើងយូរណាស់ ទុក្ខក៏ស្ទុះទៅកន្លែងដើមទ្រូង ដូចអន្ទង់ស៊ីតន៏កន្ទុក ។

ឯកវិយោធំយើញអ៊ុយកុយរសាប់រសល់មិនសប្បាយ ក៏ចូលទៅលួងលោមសួរដល់ ៦.៣ ដង អ៊ុយកុយក៏មិនប្រាប់ថាប្រការម្តេច ។ ឯនាងលីស៊ុនអៀង ជាកវិយោបន្ទាប់ ជាប់មានប្រុសសហាយឈ្មោះបៀវតេក ជាប្អូនប្រពន្ធធំ ។ បៀវតេកនោះចង់បាននាងលីស៊ុនអៀងជាប្រពន្ធ ក៏ខំអត់ធន់ទីនឹងកេកំហុសអ៊ុយកុយយូរណាស់មកហើយ មិនសមនឹងសេចក្តីប្រាថ្នា ។

កាលអ៊ុយកុយមិនសប្បាយចិត្តនោះ នាងលីស៊ុនអៀងក្រឡេកឃើញមុខប្តីដូចជាគេមនស្សខឹងក្តា កំនាំយកហេតុនោះទៅប្រាប់បៀវតេកជាសហាយថា អ៊ុយកុយប្តីខ្ញុំទៅធ្វើកជាតិនឹងបួនត្រឡប់មកផ្ទះថ្ងៃនេះ ឃើញកំរិយាដូចជាខឹង ហើយចេះតែរសាប់រសល់មិនសប្បាយ មិនដឹងជាហេតុដូចម្តេច ។ បៀវតេកថា បងបានឮថា អ៊ុយកុយចេញទៅជួបនឹងមាំថេង ហើយត្រឡប់មកវិញមិនសប្បាយតែម្តង មុខជាមានរឿងអ្វីប្លែកបានជាដូច្នេះ ប្អូនឯងចូលទៅលួងលួនលោមសួរឲ្យដឹងការចុះ នោះនាងលីស៊ុនអៀងក៏ចូលទៅ ។

លុះដល់គេលយប់ អ៊ុយកុយក៏ចូលទៅអាស្រ័យដំណេកជាមួយនាងលីស៊ុនអៀង ។ កំធ្វើប្រតិបត្តិតាមប្រក្រតី ហើយធ្វើធុញនិយាយលួងលោមសួរអ៊ុយកុយថា ខ្ញៀតជាភ្នំជ្រះកដាវឱ្យព្រះចៅហៀនតេតាំងចិត្តធ្វើកជាតិខ្ញុំទុកបំរុងផែនដីដោយសុចរិត ខានបួនជាមនុស្សខុសចរិត

អាក្រក់ ខ្ញុំឯងធ្វើការអ្វីក៏គ្មានត្រង់ខ្ញុំឯងដែរដោះ ឯខ្ញុំឯងលោកក៏ជាមនុស្ស
មានតម្រេះច្រើនថ្ងាដែរ ហេតុអ្វីក៏មកនៅជាមួយចួតួដែលជាសត្រូវខ្ញុំឯងក៏ដ.
សម្លាប់ខ្ញុំឯងដែរ ។

អ៊ុយកុយផឹកស្រាស្រវឹងខ្លាំង មិនតាំងចិត្តខ្ញុំឯងតាត្រៃឲ្យឃើញខុស
ត្រូវធ្ងន់ស្រាល បណ្តាលឲ្យរន្ធត់ដោយមាតុគ្រាម លុះតាមកលមាយា.
ស្រីក៏ស្រែដាច្រាប់ថា ខ្ញុំឯងជាស្រី ស្រាលសេចក្តីណាស់ បងជាប្រុសទើប
ដឹងច្បាស់ថា ចួតួជាសត្រូវរាជសម្បត្តិ បងក៏គិតខ្ញុំឯងធ្វើប្រឆូសក៏យចួតួជា
យូរមកហើយ តែម្ចាចមិនសម្រេចសេចក្តីច្រើនថ្ងា ខាងលីស៊ុនអៀងក៏ធ្វើ
ជាអង្វរសួរថា តំនិតលោកខ្ញុំឯងគិតការនោះដូចម្តេច ទើបអាចសម្លាប់ចួតួ
បាន អាណិតច្រាប់ខ្ញុំឲ្យដឹងជាខ្ញុំឯងចុះ ខ្ញុំជាស្រីពោះប៉ាមិនស្គាល់ខុសត្រូវ
ក៏គង់ជួយពន្យល់ប្រុសបានខ្លះទៅដែរ ។ អ៊ុយកុយឃើញថា ខាងលី.
ស៊ុនអៀងចេះតែសួរកើតឡើងថា ការណ៍នេះខ្ញុំឯងមិនដឹងម៉ាថេង បានគិតគ្នា
ជាស្រេចហើយ ។ កំពុងនិងរឿងកំពុង ដែលគិតខ្ញុំឯងម៉ាថេងនោះ ឲ្យខាង
លីស៊ុនអៀងនោះស្តាប់គ្រប់ប្រការ, លុះអ៊ុយកុយឱនមុខដោយស្រវឹងស្រា
ដេកលក់ ខាងលីស៊ុនអៀងក៏លបបើកទ្វារចេញទៅច្រាប់បៀវតេក តាម
រឿងដែលអ៊ុយកុយនិយាយនោះ ឲ្យបៀវតេកស្តាប់ ។ បៀវតេកក៏ប្រ.
ញាប់ទៅច្រាប់ឲ្យចួតួដឹងពាក់ព័ន្ធណាស់ ។ ចួតួក៏ឲ្យយុំខ្ញុំឯង
បៀវតេកខុកក្នុងបន្ទប់មួយ ហើយឲ្យចំរើលើកគ្នាទៅចាប់ខ្ញុំឯងអ៊ុយកុយខ្ញុំឯង

ការយោបល់ត្រៅដាក់គុកតាំងអស់ ។

គ្រានោះ បូធ្លូក៏ឲ្យហៅបូហាន ទៅជួ ស៊ីវ្ឈុង ហៃហ៊ូអៀនមកឱ្យបែប
ប្រាប់ឥតមាន ដែលចៀវតេកជ្ជីនឲ្យការណ៍ឥអ៊ុយកុយនោះឲ្យស្តាប់គ្រប់
ប្រការ ហើយបង្គាប់ថា ត្រីកនេះឲ្យអ្នកកាល់គ្នាតែងខ្លួនឲ្យដូចយើង យក
ខន់ក្រហមរបស់យើងហៃមុខទៅ ហើយឲ្យទៅជួជាបែកស្តាំ ឲ្យហៃហ៊ូ-
អៀនជាបែកឆ្វេង បូហានជាកងហ្មុង ស៊ីវ្ឈុងជាកងជួន លើកចេញទៅ
តាំងផ្លែស្នាមខ័ពក្រៅក្រុង ឲ្យធ្វើអាការចើដូចជាខឹងលើកចេញទៅ ។
ម៉ាថេងមិនទាន់ដឹងខ្លួន ក៏សំគាល់ថា យើងលើកចេញទៅ កំខឹងលើក
ទ័ពចូលមកតាមសញ្ញាគ្នាខឹងអ៊ុយកុយ អ្នកត្រូវអុជផ្ទាំជាសញ្ញាឡើង
ហើយឲ្យបាហានចុញ្ចូនពីក្នុងម៉ាថេង ហើយចាប់ខ្លួនឲ្យបាន ។ បូហាន
ខឹងបាហានទាំងពួង ក៏លើកចេញទៅតាំងតាមបង្គាប់គ្រប់ទីកន្លែង ។

ម៉ាថេង លុះព្រឹកឡើងក៏ចាត់ចែងបាហាន លើកចេញចាកបន្ទាយចូល
ទៅជិតស្រុកហ៊ូគោ ឃើញបាហានចេញមកមានខន់ក្រហមដោតត្រៀម-
ត្រាក៏មានអំណរក្នុងចិត្តណាស់ សំគាល់ថា ល្បាស់ជាបូធ្លូលើកទ័ពមក
ដូចពាក្យអ៊ុយកុយខិយាយ ម៉ាថេងក៏បរសេះលើកបាហានដម្រង់ចូលទៅ
លុះទៅជល់ដិតក៏ឮសូរសំឡេងផ្ទាំ ហើយឃើញបាហានពួកខន់ក្រហម
លើកធ្លាក់ឡើងចុះ ព្រួញធ្លាក់ចម្រុះមកត្រង់ ឃើញចូរហង់បំផាយសេះ

ត្រង់ចូលមក ម៉ាថេងភ័យណាស់ចរសេះត្រឡប់រត់ ខ្លួលទៅជួស៊ីឡឹង
ហៅហ៊ូអឿនលើកទាហានចេញមកចាមរកមព័ទ្ធជុំវិញខ្លួន ម៉ាថេងនឹងម៉ា
ហ៊ីវ ម៉ាឆៀតក៏ពាក់ចំលាយចេញទៅបាន ខ្លួលត្រញ្ជក្ខបាញ់ទៅត្រូវ
ចាំងញ ខាយសេះ រលះភ្លាត់ពីលើសេះ ឯម៉ាឆៀតនោះក៏អស់អាយុស្លាប់
មួយរំពេច ទាហានក៏ស្ទុះស្រែចូលទៅចាមព័ទ្ធចាប់ខ្លួនម៉ាថេងនឹងម៉ាហ៊ីវ
ចងបាន ហើយនាំខ្លួនចូលទៅជូនចួន ។ ក៏ឲ្យយកខ្លួនអ៊ុយកុយចេញមក
សួរតាមការណាឲ្យឆ្លើយតបលស់ដំគ្នានឹងម៉ាថេងនោះ អ៊ុយកុយក៏ឆ្លើយបដិ
សេធមិនឲ្លួលហើយថា ខ្លួនខ្ញុំបានឧនឹងបានតបតគ្នានឹងម៉ាថេងប៉ងប្រថ្នា
ប្រជ្រួសរាំយមហាឧបរាជក៏ពេ ហើយនិយាយតទៅនឹងម៉ាថេងថា អ្នកកុំ
ភ័យបារម្ភអ្វីឡើយ ព្រោះខ្លួនយើងមិនមានសេចក្តីទុក្ខព័ន្ធអ្វីសោះ ។ណ:
នោះ ចូរឲ្យនាំយកខ្លួនបៀវតេតចេញមកសួរតាមការណាចំរាះមុខអ៊ុយ-
កុយ បៀវតេតក៏និយាយនឹងតាក្សដដែល ។ ចួរឆ្លើសួរអ៊ុយកុយនឹងម៉ា-
ថេងតទៅ អ៊ុយកុយម៉ាថេងក៏តាលស់ដំនឹងបៀវតេតគ្រប់ប្រការ ។

(នៅមានត)

លោក ប៉ាយ-ម៊ុត ប្រែរៀបរៀង

(តមក)

នៅចំកណ្តាលភូមិតាសេះនេះ មានពាជវេមួយខ្ទមដោយសេះជួនប្រដាប់ដោយក្បាច់ចនាដ៏មានតណិដូចមាសក្តីក្រហមប្រាលផ្លេ ហើយមានគ្រានើដ៏បង្ហូរចនោដោយកញ្ចក់ ។ ព្រះអង្គម្ចាស់ទ្រង់កៀសព្រះអង្គឡាយ ដើម្បីទៀពាជវេនេះបរដោយសេរតែមថ្នល់ធំនោះ ។ លុះពាជវេនោះមកដល់, ស្រាប់តែមានបុរសម្នាក់ចេញពីពួកជវែ មកក្រាបបង្គំទូលសួរព្រះអង្គម្ចាស់ថា: « តើអ្នកឯងលក់អ្វី? បុរសនេះមិនស្គាល់ថាព្រះអង្គជាព្រះរាជបុត្រព្រះមហាក្សត្រទេ ។

– ព្រះអង្គម្ចាស់ទ្រង់មានព្រះបន្ទូលតបថា: ខ្ញុំគ្មានលក់អ្វីទេ ! ។

– បុរសក៏សួរតទៅទៀតថា: « តើអ្វីនៅក្នុងកន្ត្រកនោះ? មិនគឺផ្លែចំសប្តផ្លែថ្មាំមប្ត ? ព្រះអង្គម្ចាស់យើងទ្រង់ធ្វើព្រះរាជដំណើរមកតាំងពីព្រឹកទល់ល្ងាច ទ្រង់មានបំណងចង់សោយដែរ ចូរលក់ផ្លែនោះមកឲ្យយើងខ្ញុះ ! » ។

ព្រះអង្គម្ចាស់ទ្រង់មានព្រះបន្ទូលតបថា: « ផ្លែឈើនេះសម្រាប់តែយើងប៉ុណ្ណោះ, យើងមិនអាចលក់បានទេ ! ដូចអ្នកឯងជ្រាបស្រាប់

ហើយ នៅទីនេះគ្មានស្មៅមួយចង្កឹះសោះ បើខ្ញុំឃ្វាន តើខ្ញុំមានអ្វីបំ-
ផ្តាត់ការស្រេកឃ្វានបាន ! " ។

ចំណែកព្រះអង្គម្ចាស់ដែលគង់នៅលើកជវែ កំឱ្យយកប្រាក់ ១ ក-
ហាបណៈទៅទិញផ្លែឈើនោះ ។

ព្រះអង្គម្ចាស់ទ្រង់មានព្រះបន្ទូលសួរបុរសថា :

" តើអ្នកឯងនៅណា ? "

បុរសក្រាបបង្គំទូលព្រះអង្គម្ចាស់ថា :

" ព្រះអង្គម្ចាស់ឈើងទ្រង់យាងទៅគាន់សំណាក់ព្រះអង្គម្ចាស់ក្សត្រី
ដែលទ្រង់ត្រូវបញ្ជាប់ពាក្យ ។

ឯព្រះអង្គម្ចាស់មានព្រះបន្ទូលដូច្នោះ កំទ្រង់បានយកផ្លែឈើប្រទាន
ទៅបុរសនោះ ។

ព្រះអង្គម្ចាស់ដែលគង់លើកជវែ ទ្រង់សោយផ្លែតាន់ឆីផ្លែបែស
ស្រស់នោះទៅ ។ ដោយកជវែនោះចេះតែបរ ។ ទៅ, ស្រាប់តែព្រះអង្គ
ម្ចាស់បានបញ្ចេញព្រះសូរសៀងយ៉ាងខ្លាំង ដោយកំយាតក់ស្ញូតឥតឧបមា
ដោយទ្រង់ឧតព្រះរូបព្រះអង្គទៅឃើញជារូបអមនុស្សមានព្រះកំភ្លុក មាន
តុកចង្កាហើយព្រះសិរមានស្នែងតិរដុំតិរលើថែមទៀត ។ ព្រះពល-
បរិវារដែលជង្ហែព្រះអង្គម្ចាស់ កំឈប់ទៅកណ្តាលផ្លូវទាំងអ្នកលក់ផ្លែ
ឈើ ។ ចន្លួចទៀតព្រះអង្គម្ចាស់ដែលលក់ផ្លែឈើ, ទ្រង់យាងមកដល់

ទីនេះ ។ ពួកវេជ្ជមន្ត្រីតំឡើងនឹងផ្ទៃមិនឲ្យទ្រង់ស្តេចយាងបាន ។

ពួកវេជ្ជមន្ត្រីក្រាបបង្គំទូលថា: ‘‘តើផ្ទៃឈើដែលទ្រង់បានលក់ថ្វាយព្រះអង្គម្ចាស់យើង យកភ្លើងមក» ។

ព្រះអង្គម្ចាស់ទ្រង់មានព្រះបន្ទូលតបទៅវិញថា: ‘‘ផ្ទៃឈើនេះគឺ ខ្ញុំបេះពីដើមក់តែង ។ » ។

ពួកវេជ្ជមន្ត្រីក៏ក្រាបបង្គំទូលថា: ‘‘សូមទ្រង់ទតនៅ! ក្រោយដែលព្រះអង្គម្ចាស់ទូលព្រះបង្គំសោយផ្ទៃឈើទ្រង់ ។ មេត្តាទតមើលចុះ ម្តេចក៏លើព្រះភក្ត្រព្រះអង្គមានដុះកេមវែង ។ ហើយទៅលើព្រះសិរមានស្នែងដូច្នេះ! » ។

ព្រះអង្គម្ចាស់លុះយាងទៅកាន់កដវេទហើយ ក៏ទ្រង់ទតទៅឃើញមនុស្សម្នាក់អង្គុយក្នុងកដវេទមានសភាពប្លែកអស្ចារ្យ. ទ្រង់មានព្រះហឫទ័យសប្បាយឥតបមា » ។

ព្រះអង្គម្ចាស់ទ្រង់មានបន្ទូលតបទៅវិញថា: ‘‘ខ្ញុំបានសោយផ្ទៃឈើនោះវែរ, ម្តេចក៏ខ្ញុំគ្មានកេម, គ្មានស្នែង! » ។

ពួកវេជ្ជមន្ត្រី ក៏មិនអាចនឹងធ្វើយតបតទឹងទ្រង់បានឡើយ ។

ក្រោយដែលព្រះអង្គម្ចាស់ទ្រង់ព្រះតម្រិះ ទ្រង់ក៏បានឈ្វេងយល់មួយរំពេចហើយទ្រង់មានបន្ទូលថា:

‘‘តើព្រះអង្គម្ចាស់អ្នកឯងសោយផ្ទៃឈើនោះហើយទ្រង់ផ្ទុប? » ។

ពួករដ្ឋមន្ត្រីក៏ក្រាបបង្គំទូលតបថា: "ព្រះ!" ។

ព្រះអង្គម្ចាស់ព្រះតបវិញថា: "ឥឡូវនេះខ្ញុំឥតមានសង្ស័យទេ! អ្នកឯងជាជនបរទេស, អ្នកឯងមិនដឹងច្បាប់ទៀមទាត់ក្នុងប្រទេសនេះ ដែលគេហាមមិនឲ្យដេក ក្រោយដែលបានបរិភោគម្ហូបអាហារហើយ ។ ចេះតែដេកមុនជាមានភេមនឹងស្មានហើយ" ។

ពួករដ្ឋមន្ត្រីមើលមុខគ្នាទៅវិញមកហើយថា: "តើយើងធ្វើយ៉ាងណា! ការណ៍នេះគឺមកពីការស្រេកឃ្លានហួសប្រមាណ នឹងការឆ្អែតឆ្អន់នៃព្រះអង្គម្ចាស់យើង តើព្រះអង្គម្ចាស់យើងទៅធ្វើព្រះកាយសមរសជាមួយព្រះអង្គម្ចាស់ក្សត្រីដូចម្តេចកើត បើព្រះរូបព្រះអង្គអាក្រក់ដូច្នេះ!" ។

មានរដ្ឋមន្ត្រីម្នាក់ទៀតថា: "បើយ៉ាងនេះត្រូវតែយើងវិលទៅកាន់ព្រះកាជានីវិញ" ។

តែព្រះអង្គម្ចាស់ព្រះមិនយល់ព្រមតាម ហើយព្រះមានព្រះបន្ទូលថា: "យើងរងាំចាំព្រះអង្គម្ចាស់ក្សត្រីជាច្រើនឆ្នាំមកហើយ យើងមិនអាចនឹងដកឃ្លាថយ មានធ្វើសមរសនឹងព្រះនាងនោះសោះឡើយ" ។

ដល់អវសាន មានរដ្ឋមន្ត្រីម្នាក់ទៀត ដែលស្ថិតនៅជិតព្រះអង្គបានស្នើសុំប្រើឧបាយកលមួយថា: "យើងត្រូវកេងយុំប៉ុនសម្ងាត់ មានសភាពស្អាតស្អំប្រកបដោយសោភណភាព ដែលយើងខ្ញុំតជាព្រះអង្គម្ចាស់យើង

សុខ្ខសាធ ហើយយើងនាំឲ្យចូលទៅក្នុងព្រះបរមរាជវាំងថ្វាយបង្គំព្រះបិតាក្មេក, តាំងដំណែងព្រះអង្គម្ចាស់ក្សត្រី ។ លុះដល់ព្រះនាងយាងទៅកាន់ព្រះទីនោ ព្រះបិតាក្មេកវិញ ព្រះនាងទទឹងត្រង់ទូលព្រះអង្គម្ចាស់ជាព្រះស្វាមីពុំមាន" ។

ចំណែកលុះនេះបានទទួលយល់ព្រមភ្លាមពួកវេជ្ជមន្ត្រីនាំងឲ្យាយ ពួកវេជ្ជមន្ត្រីនាំងឲ្យាយ ក៏ទំព្យាយាមស្វែងរកយុវបុរសម្នាក់ មានរូបឆោមលោមតិណស្រស់ប្រិមប្រិយ ។ ក្រោយដែលបានតាំងឲ្យបុរសកំណើរដែលស្ថិតនៅទីនោះ វេជ្ជមន្ត្រីនាំងឲ្យាយក៏យល់ថា : "អ្នកលក់ផ្លែឈើនេះជាយុវបុរសមានរូបកាយប្រកបដោយលំអគ្រប់យ៉ាង ក៏មូលមតិគ្នាឲ្យអ្នកលក់ផ្លែឈើនោះ ឡើងជិះលើកជវថង់ទូលព្រះអង្គម្ចាស់ខ្លួន ។ ប៉ុន្តែអ្នកលក់ផ្លែឈើធ្វើឫកពាដូចជាមិនត្រូវធ្វើសហការជាមួយនោះ ក៏មានវាចាថា ខ្ញុំប្រញាប់ណាស់ ខ្ញុំមិនអាចបំពេញបេសកកម្មនោះបានឡើយ ។

ពួកវេជ្ជមន្ត្រីក៏បានទទួចអង្វរអ្នកលក់ផ្លែឈើ ឲ្យទទួលធ្វើមុខដំណែងនោះជូនព្រះអង្គម្ចាស់ ។ ទីឆ្ងៃប្រមាណប្រាំកហាបណៈ ។

អ្នកលក់ផ្លែឈើតបថា : "ប្រាំកហាបណៈ ! មិនសមទឹងទៅកាន់មុខដំណែងនោះបានទេ" ។

ពួកវេជ្ជមន្ត្រីក៏តបមកវិញថា សូមដូន ៧ កហាបណៈចុះ ។

អ្នកលក់ផ្លែឈើ(១) កំយល់ច្រមៃហើយខឿនទៅអង្គុយនៅលើកជវែ។
ឯព្រះអង្គម្ចាស់ដែលមានតុកមានតុកចង្កាខ្លីនឹងស្មែន កំតង់លើពាជ័មួយចូលទៅគាន់កជាន់ទោះដែរ ។ អ្នកលក់ផ្លែឈើគេតុបតែងឲ្យដួតក្បាលខ្លែងកន្ទែនធំមានសៀបំពង់មុខដិត ។ ពួករដ្ឋមន្ត្រីបានគិតគ្នាថា លុះទៅដល់ព្រះបរមកជវ័ងត្រូវឲ្យព្រះអង្គម្ចាស់យើង ស្តេកលាក់ពួនខ្លួនទៅបន្ទប់មួយ ហើយកុំឲ្យអ្នកណាឃើញសោះឡើយ ។ ការប្រយ័ត្ននេះរួចហើយ កជវែកំធ្វើដំណើរតទៅទៀត ។

លុះបុរសលក់ផ្លែឈើមកដល់កជាន់, ព្រះមហាក្សត្រនគរនោះទ្រង់បានយាងទៅទទួលនៅខ្ទាន់ទ្វារធំយ៉ាន់ទល្លាំក ។ ទ្រង់បានទតទៅឃើញព្រះសុទិសាមានរូបឆោមល្អស្រស់ជាអនេកកប្បការ ហើយមានព្រះដំនូនច្រើនផង, ទ្រង់មានព្រះកជហឫទ័យខ្លាចក្រែងព្រះសុទិសាទ្រង់បានជ្រាបនូវព្រឹត្តិការណ៍នៃព្រះអង្គម្ចាស់ក្សត្រ, ទ្រង់ក៏ប្រញាប់ប្រញាល់ចាត់ឲ្យរៀបចំព្រះតិជសមរសក្នុងរវាង ៤ ថ្ងៃ ៤ យប់យ៉ាងអធិកអធ័ម ។

ពួកចាស់ទុំត្រូវជម្រៀងនៅខាងត្រៀកព្រះបរមកជវ័ង ។ ពួកក្មេងអាចចូលមកជម្រៀងនៅក្នុងព្រះបរមកជវ័ង ដើម្បីខ្ចីកំជរព្រះអង្គម្ចាស់ខ្លែងព្រះខាន់ជាន ។ តិជខ្លែងកិច្ចការកំសាន្តសប្បាយត្រូវលែលះបង់ពញ្ញាដោយ

១- ប៊ុះសលក់ផ្លែឈើនេះជាព្រះអង្គម្ចាស់នៃរៈ តែពួកឯកន្ត្រីទាំងឡាយបែនបានដឹងស្គាល់ទេ ជានជាខ្ញុំសូមពណិនាជាពាក្យសាមញ្ញ. ដ៏ជានប្រើភាសាឯ ។

ស្តាប់ស្តាត់ត្រមាំងំប្រយ័ត្នប្រយែងដែរ ។ ព្រែងដំណឹងអាក្រក់ពីព្រះមាងលេចឡូរភ្លាយៗ ។

ពីរីសមរសេកខ្នងមក ៣ ថ្ងៃ, ព្រះនាងមិនដែលបានឧតៅកាន់ព្រះអង្គម្ចាស់ដល់ម្តងសោះឡើយ ។ ទ្រង់ព្រះកន្សែងសោយសោកនឹកលើកដល់ព្រះអង្គម្ចាស់ ដែលទ្រង់ស្នេហាគេពាក្រះហឫទ័យ លុះដល់ថ្ងៃទី ៤ ព្រះមហាក្សត្រទ្រង់ព្រួយព្រះកដហឫទ័យជាខ្លាំង កំមានព្រះកដបញ្ជាឲ្យយាយអកម្ចាក់ជាទីគុកព្រះកដហឫទ័យទៅដកបព្រះនាងថា : ព្រះអង្គម្ចាស់ទ្រង់មានព្រះហឫទ័យស្នេហាចំពោះព្រះនាងជាខ្លាំង ។

នៅពេលលៀងព្រះក្រយាស្ងោយមួយនៅសាយណ្ហសម័យ, ព្រះអង្គម្ចាស់ទ្រង់គង់នៅដឹតព្រះអង្គម្ចាស់ក្សត្រី ទ្រង់ធ្វើតទាសក្នុងពេលដែលពួកសមន្តពាជជាំងឡាយមិនបានអើពើនឹងទ្រង់ ទ្រង់ឱបដាក់ព្រះកាណៀព្រះនាងថា : ទ្រង់បានលៃត្រឡប់មកវិញហើយ ព្រះនាងទ្រង់បានជ្រាបច្បាស់នូវព្រះសូរសៀងនៃព្រះអង្គម្ចាស់ហើយ, ទ្រង់បើកវិស្សាចាំងព្រះភ័ក្ត្រ ហើយទ្រង់បានក្រឡេកទៅឃើញច្បាស់ដូចជាទ្រង់សុបិនទិម្មិតដូច្នោះ ។

ព្រះអង្គម្ចាស់ក្សត្រីទ្រង់ជូតព្រះភ័ក្ត្រ ដែលងាប់ដង់ដោយទឹកព្រះនេត្រ ; ទ្រង់មានព្រះហន្ទុលធ្វើយតបហើយទ្រង់ព្រះសំរួល ; ទ្រង់បានជាមួយព្រះអង្គម្ចាស់ជាច្រើនដង ។ ព្រះអង្គម្ចាស់ទ្រង់មានព្រះហន្ទុល

ចំពោះព្រះទាន់ថា : យើងនឹងតតែដើរណើរទៅគេលទានស្អែក សូម
ព្រះទាន់សុំសេះឈ្មោតព្រះវរបិតា ហើយបើព្រះវរបិតាពុំព្រមព្រះពរទាន
ទេ សូមព្រះទាន់ក្រាបបង្គំទូលថា ព្រះទាន់មិនត្រមៅជាមួយទូល
បង្គំទេ បើពុកជាព្រះវរបិតាកំញើញតតែមយ៉ាងណា កុំឲ្យព្រះទាន់ទ្រង់
ភ័យតក់ស្លុតឲ្យសោះ ត្រូវទ្រង់ខ្ចប់សុំព្រះវរបិតាឲ្យសេះឈ្មោះទៅ
តាលវែតបាន ។

ចំណែកខាងព្រះមហាក្សត្រវិញ ព្រះអង្គទ្រង់បានចាត់ឲ្យយាយអភ័
ម្ភាក់ឃ្លាំមើលព្រះអង្គម្ចាស់តាំងពីព្រះអង្គ ។ យាយអភ័ភ័ល្បត
ទៅវិញបានក្រាបបង្គំទូលមហាក្សត្រថា : "ព្រះអង្គម្ចាស់តាំងពីព្រមត្រៀង
គ្នាដោយសុខចិត្ត ទ្រង់បានកំប្រៀតតាំងពីព្រះអង្គយាងសប្បាយរីករាយ។
ព្រះមហាក្សត្រទ្រង់មានព្រះពរជាហួសខ្លាំងសោមនស្សពន់ពេក ដោយទ្រង់
បានដំណឹងល្អនេះ ។

ព្រឹកឡើងមានបុគ្គលជាក្បែរកំពង់យសបានមកជំរាបថា នៅមុខទ្វារ
ព្រះបរមរាជវាំងដើម្បីនឹងក្រាបបង្គំព្រះអង្គម្ចាស់ក្សត្រ ។ ព្រះអង្គម្ចាស់
ខ័ណ្ឌព្រះបរិតាបានជំរាបព្រះអង្គម្ចាស់ក្សត្រនៅតីនោះដែរ តែព្រះទាន
មិនឃើញយាងទៅ ។ ព្រះទាន់បានតាមការសេះឈ្មោ តាព្រះវរបិតា;
ទ្រង់បានយកព្រះហស្តតាំងពីទឹបព្រះភ្លុកនៃព្រះវរបិតា តាមការដោយ
សោកសង្រៀងជាខ្លាំង ។ ព្រះរាជាទ្រង់ព្រះតិរោធជាខ្លាំងទ្រង់ត្រាស់

បង្គាប់ឱ្យហៅនាយតេជ្ជយោធមក តែព្រះនាងទ្រង់ឥតមានតក់ស្លុតអ្វីសោះឡើយ ។

ព្រះនាងទ្រង់ក្រាបបង្គំទូលព្រះវរបិតាថា: "សូមបិតាសម្លាប់កូនចុះ, បើបិតាទ្រង់មិនព្រមឱ្យសេះឈើមកកូន" ។

ព្រះរាជាទ្រង់ព្រះតម្រិះពេជជាខ្លាំង តែបើទុកជាយ៉ាងណាក៏ជាយ៉ា ក៏ព្រះនាងទ្រង់គ្មានត្រឹត្រូវអ្វីសោះឡើយ ទ្រង់មិនលះបង់ព្រះបំណងតាមការយកសេះឈើនោះទេ ។

ពួកឥស្សរជន ដែលរង់ចាំព្រះនាងនៅខ្វាងទ្វារព្រះបរមរាជវាំង ក៏នឹកឆ្ងល់ថាហេតុដូចម្តេចក៏បាត់ព្រះនាង មិនឃើញយាងមក ! ។ ពួកនេះក៏ចូលទៅក្នុងព្រះបរមរាជវាំង ដើម្បីនឹងសួរហេតុនោះឱ្យច្បាស់លាស់។

ព្រះមហាក្សត្រទ្រង់មានព្រះរាជបន្ទូលថា: "កូនខ្ញុំក៏បង់យកសេះឈើទៅជាមួយនឹងក់ ! " ។

ពួកឥស្សរជនក៏ក្រាបបង្គំទូលតបថា:

"សូមទ្រង់ព្រះមេត្តាប្រោស · សូមព្រះអង្គទ្រង់ព្រះរាជានុញ្ញាតឱ្យព្រះនាងយកសេះឈើជាលែ្បងក្មេងទៅជាមួយព្រះនាងផងចុះ" ។

លុះទ្រង់ព្រះសណ្តាប់ដូច្នោះ ព្រះមហាក្សត្រក៏ប្រគល់សេះឈើឱ្យព្រះនាងភ្លាមមួយរំពេច ។

ព្រះអង្គម្ចាស់ ខឹង ព្រះនាងក៏ទ្រង់គង់លើកជវាធ្វើព្រះដំណើរចេញ

ទៅដោយមានព្រះបរិពារជាច្រើនតាន់នាក់ចាមរកមទៅជាមួយផង ។

ព្រះដំណើរនោះមានសភាពឆ្ងាយជាច់ស្រយាល ។ ព្រះអង្គម្ចាស់ទីឥន្ទ្រព្រះនាងមានមនុស្សថែរក្សាអមព្រះអង្គជានិច្ច ជាន់ជាគ្មានឧកាសទីឥន្ទ្រនេចព្រះអង្គចេញតាមទីនោះសោះ ។ ព្រះអង្គតាំងពីរស្តេចយាងដំរៀតទៅដល់ប្រទេសព្រះមហាក្សត្រនៃព្រះអង្គម្ចាស់ដែលមានស្នេង ទ្រង់មានព្រះហឫទ័យត្រួយជាមួយជាខ្លាំង ទ្រង់មានព្រះបន្ទូលទៅកាន់ព្រះនាងថា: "បើយើងតាំងពីនាក់ទៅដល់មុខព្រះបរមរាជវាំងនៃព្រះករុណាប្រទេសនោះ សូមព្រះនាងក្រាបបង្គំទូលព្រះមហាក្សត្រថា សូមទ្រង់យកថាសប្រាំពីរសុទ្ធតែពេញទៅដោយមាស ។ មាសនោះ, ព្រះនាងនឹងជាចុះទៅលើមហាជន ។ បើព្រះមហាក្សត្រទ្រង់មិនព្រមស្រាស់ថង្គាប់ឲ្យយកថាសតាំងប្រាំពីរនោះទេ ព្រះនាងមិនត្រូវចុះពីរាជវរាជឡើយ ។

លុះព្រះអង្គម្ចាស់តាំងពីរយាងទៅដល់មុខព្រះបរមរាជវាំង ព្រះនាងទ្រង់ទឹកឃើញបណ្តាំព្រះស្វាមី ទ្រង់ធ្វើតាមបណ្តាំនោះយ៉ាងម៉ឺងម៉ាត់ ។ មហាជនតាំងប្រុសស្រី ក្មេង ចាស់រត់ទៅដណ្តើមមាស ដែលព្រះនាងទ្រង់ចាចលើផែនប្រថពី ។ ក្នុងគេលនោះ ព្រះអង្គម្ចាស់ទ្រង់ពាក្យព្រះហស្តព្រះនាងហើយទ្រង់តន់លើសេះឈើ ទ្រង់មួលក្បូនសោ សេះឈើនោះហោះទៅលើអាកាស ។ ព្រះដំណើរនៃព្រះអង្គម្ចាស់តាំងពីព្រះអង្គគឹងទៅដល់ភពឆាន់ដោយស្ទុះគ្គិតគាត ។

តាំងតាំងព្រះអង្គម្ចាស់ស្តេចយាងចុះតាំងជាន់ ព្រះវេបិតាព្រះអង្គទ្រង់ត្រាស់ប្រាប់តាន់តេកផ្ទំភ្ញុំជាន់ហោះ មានត្រះពាសនាថ្លែងថា "ការចុះតាំងព្រះនុសេនេះ ចុះតួហេតុមកតាំងជាន់ឈើនោះឯង ព្រោះហេតុថ្ងៃនេះ ត្រូវជាន់ឈើនេះខ្លួនខ្លួនឯងមកប្រហារដើរតែងនឹង" កំត្រាស់បង្គាប់ឲ្យយកជាន់ឈើ ទៅចោះដែកគោលក្លាប់ត្រង់កន្លែងដែលចូលទៅកាន់ស្ថានអស់រយៈវេលា ៣ ថ្ងៃ ៣ យប់ហើយ ។ ប៉ុន្តែគង់តែលនោះ ខ្លួលព្រះអង្គម្ចាស់ស្តេចនិវត្តមកកាន់ពាសនានិវត្តិញ្ញ លុះយាងមកដល់ទ្រង់ទឹកដល់ជាន់ឈើភ្លាម ទ្រង់មានព្រះបន្ទូលទៅកាន់ព្រះវេបិតា: "បិតា, សេះឈើនេះមានប្រយោជន៍សំខាន់ណាស់! បើគ្មានសេះឈើនេះទេ កូនមិនអាចធ្វើដំណើរដោយស្រួលបាន កូនមិនអាចនឹងបានព្រះនាងធ្វើជាមហេសីត្រមាំងមិនអាចវិលត្រឡប់មកកាន់ព្រះពាសនិវេសន៍បានឡើយ" បិតា! សូមព្រះអង្គទ្រង់ត្រាស់បង្គាប់ឲ្យហៅជាន់ឈើ ដែលធ្វើសេះឈើនោះមកសូមឲ្យបិតា ព្រះពាសនានឹងវង្វាន់ដ៏ប្រសើរ ។

លុះទ្រង់ព្រះសណ្តាប់ដូច្នេះហើយ ព្រះមហាសត្វទ្រង់ខ្មាស់អៀនតន់តេក កំប្រាប់ព្រះនុសេថា ព្រះអង្គបានយកជាន់នោះទៅចោះដែកគោលចំតាំមុខស្ថានហើយ ។ តមកបានត្រាស់បង្គាប់អាមាត្យឲ្យទៅម៉ើលជាន់ឈើនោះ ។ ឯជាន់ឈើទៅសាកពាសនានដ៏វែងនោះឡើយ ។ គេបាន

ឆាំជាន់ឈើនោះយកមកថ្វាយព្រះអង្គម្ចាស់ ។ ក៏បានចាត់គ្រូគេឲ្យយាំដំ-
នាញមកត្បាច់លបួសនោះឲ្យជាសះស្បើយ ។ ព្រះមហាក្សត្រទ្រង់បាន
ធ្វើព្រះរាជអំណោយជូនវត្តដ៏មួយគេក្បាលៅដោយមាស ដើម្បីទំនងឲ្យជាន
ឈើនេះត្បាយមធ្លើសេះឈើនេះឲ្យវិសេសវិសាលឡើងតទៅអនាគត ។

បន្ទាប់មក មានការជម្លៀង ហើយប្រគំតូរ្យតន្ត្រីតគ្រឹកតគ្រែងជា
ឧឡារឹក ដើម្បីជាព្រះកិត្តិយសចំពោះព្រះរាជសមរស រៀងព្រះអង្គម្ចាស់
ទំនងព្រះនាង ។

ថ្ងៃក្រោយមក ព្រះអង្គម្ចាស់តាំងពីព្រះអង្គ ក៏បានឡើងគ្រងរាជ-
សម្បត្តិជាដំណតពីព្រះវរបិតារហូតមក ។

ចប់រឿងសេះឈើ

(នៅមានត)

រឿងព្រៃដ៏ទាក់ទងដោយភូមិសាស្ត្រខ្មែរ
ផ្សាយរបៀបពីក្រុមជំនុំទំនៀមទម្លាប់

ទំនៀមទម្លាប់	នៃទេមរជាតិ
ខ្មែរឲ្យឮឃ្មាត	សិក្សាពេញទី ។
ព្រោះទេមរជាតិ	ជាជាតិសោភ័
ក្នុងទ្វីបអាស៊ី	ពាំងពីព្រៃងនាយ ។

ច.ព

រឿងក្តុំសុតណាកាលី

នៅខែត្រក្រចេះ

បើយើងធ្វើដំណើរចេញពីក្រុងភ្នំពេញទៅ តាមផ្លូវខេត្តដ៏ ដោយ ឡានម្ភកថ្មាំល ដល់ទៅភ្នំដីក្រាល ហើយបត់ទៅចូលផែផ្សារក្រូចឆ្មារ ស្រុកក្រូចឆ្មារ ជាទីរួមខែត្រកំពង់ចាម ក្រឡេកចេលក្នុងទៅទិសឦសាន ក្នុងទីរួមខែត្រក្រចេះ ស្រុកធ្លុង ត្រើយខាងដើង ត្រង់ឃុំចម្បក់ យើងនឹងឃើញភ្នំមួយខ្ពស់ខុង . នៅកែរឆ្នេរខេត្តនោះ ឈ្មោះ "ភ្នំសុតណាកាលី" ជាភ្នំសក្តិសិទ្ធិ ។ ប្រវត្តិនៃភ្នំនោះ មានរឿងដំណាលដូចតទៅនេះ ៖

កាលតាំត្រែងនាយ មានក្រតើ ១ ឈ្មោះ "សុតណាកាលី" ខ្លួនធំមហិមា មានប្ញទ្ធានុភាពក្លៀកណាស់ ឥតក្រតើណា

ប្រឡងបូជ្ឈដ្ឋានបាន អាស្រ័យនៅអន្ទង់មួយឈ្មោះអន្ទង់សាលិ ដែលសព្វថ្ងៃហៅភូមិអន្ទង់សាលិ នៅកន្លែងស្រុកស្ទឹងត្រង់ ទឹរមៃខេត្រកំពង់ចាម ខាងក្រោមភ្នំសុតណាគាលិចម្ងាយប្រហែល ៦០ គីឡូម៉ែត្រ ។

កន្លងសម័យជាមួយគ្នានោះ នៅឃុំមហាលាភ ស្រុកកោះសុទិន កន្លងទឹរមៃខេត្រកំពង់ចាម មានក្រតើ ១ ឈ្មោះ "ទានុវ៉ែ" នៅអាស្រ័យកន្លងទឹកខេត្ន ត្រង់ទីកំពង់វត្តមហាលាភ ជាក្រតើរបស់លោកសង្ឃចិញ្ចឹម បើលោកនិមន្តទៅចំណូលបាត ក្រតើនោះតែងបញ្ជូនចម្ងាលោកទៅ ដល់លោកនិមន្តត្រឡប់មកវិញ ក្រតើនោះកំបានចម្ងាមកតាមដំណើរនោះ ។

ក្រតើនោះ មានខ្លួនធំណាស់ ក្បាលប្រវែង ៧ ហត្ថ ចេះតំណែងខ្លួនជាមនុស្សបាន ។ កាលដែលតំណែងខ្លួនជាមនុស្ស បានឮពាក្យមនុស្សនិយាយគ្នាថា "ក្រតើឈ្មោះទានុវ៉ែនេះ ធំម្ល៉ឹងណ្ណឹងក្រតើឈ្មោះសុតណាគាលី នៅអន្ទង់សាលិធំជាងនេះទៅទៀត" ។

ទានុវ៉ែបានឮពាក្យមនុស្សដូច្នោះ កំនិម្មិតខ្លួនជាក្រតើដូចដែលហែលទឹកសំដៅទៅរកក្រតើសុតណាគាលី ដោយប្រាថ្នាទំនប្រឡងប្ងូគ្នា ទៅតាមផ្លូវមានចម្ងាយច្រើនរយគីឡូម៉ែត្រ, លុះចេញទៅដល់មាត់តាមផ្លាំយម្រេច ប្រទះនឹងយាយចាស់ភាស់កំពុងចែវទូកឆ្លងខ្ទេ ទានុវ៉ែកំតិតថា "បើខ្លួនទៅជាក្រតើខ្លាំងស៊ុះដាំយសារតាយាយនេះពុំបានទេ ព្រោះតាត់ខ្លាច, បើដូច្នេះ តួរកញ្ចឹមម្ល៉ឹតខ្លួនជារលាកនេន

ទើបសុំដោយសារខ្លីនតាត់ភ្នែន ។ តែកន្លះបាត់ហើយ ក៏និយាយទៅប្តីថា លោកនេង សុំដោយសារដៃមួយតាខ្លីនយ៉ាយភ្នែនដូចម្តេចណាន ។ ខាងនៃលោកនេង មិនបានឮតែបែកនៃខ្លួកទេ ខាងបង្អាប់ថា ។ ស្អីមតាទៅអង្គុយកាន់ដើងបែរទាំងក្បាលខ្លួកដាក់ខ្លួនឲ្យនៃងចុះ ។ ថាដូច្នោះហើយខាងនៃលោកនេង ក៏ចំបែរខ្លួកលឿនបន្តិចម្តង ។ ឃ្លាតៅតែតែលឿនឡើង ។ ដោយអំណាចខាងនៃនិម្មិតយកកន្ទុយដួយកាយទឹកផ្សំផង, ចំនួន ៤ មៅងទើបដល់កន្លែងក្រតើសុតណាកាលនោះ, ខាងនៃលោកនេងបានសួរទៅតាយាយថា ។ ឡើងត្រើយខាងណាតា ! ? ។ តាយាយប្រាប់ទៅវិញថា ។ ឡើងត្រើយខាងស្តាំនេះបានហើយ ។ លុះចូលខ្លួកទៅដល់កំពង់ ខាងនៃលោកនេង ដួយអួសខ្លួកតាយាយឲ្យផុតពីទឹក ។ តាថា ។ ដាក់ខ្លួកត្រង់ហ្នឹងបានហើយ ។ ខាងនៃលោកនេងថា ។ ពុំបានទេតា ! ។, ថាហើយក៏អួសខ្លួកនោះទៅដាក់ដល់ចិញ្ចើមមាត់ជ្រាំង បងក្រែកដោយប្រាក់ក្លាច់ខ្មៅបង្គោល ព្រោះខាងនៃតែតថា ។ ទៅតេលប្រឡងហ្នឹងគ្នានោះ លេកខ្លីកភ្នាំងណាស់ តោរដល់ចិញ្ចើមជ្រាំង បើប្រហែសមិនបងខ្លួកឲ្យជាប់មុខជាខ្លីនអណ្តែតខ្លួកនោះបាត់ ។, ចូរហើយក៏ប្រែខ្លួនជាក្រតើ លោតចុះទៅកន្លែងទឹក ហែលសំដៅទៅកក្រតើសុតណាកាលី បានដួចគ្នាហើយក៏ប្រកាំគ្នាដោយហ្មុងយ៉ាងឥស្លាម្ប បញ្ជាខ្លួនផុតពីទឹក ផ្តើលអស់មនុស្សមកមើលត្រៀបត្រា លេកខ្លីកចេកហួសបងចិញ្ចើមជ្រាំង ។ លុះប្រកាំគ្នាយូរទៅ ក្រតើខាងនៃ

មានជួញដាំ ទាំក្រូវគោះក្រគើសុតណិកាលី ។ កំឡុងគោះស្ងាប់មួយ រំពេច ក្លាយកើតជាកង្កែមួយហៅថា "កង្កែសុតណិកាលី" តាមតាមក្រគើ គោះ ដកចេញកដល់សព្វថ្ងៃនេះ ។

(ភ្លាំនេះ ពួកលោកចិនទិញណាស់ បើអ្នកណាចង់រៀនមន្តវិជ្ជាខ្មៅទិញគោះ កំពុងអង្គុយ ស្ងាត្បាយ មានពួកភូតបិសាច មកល្បងធ្វើជាដុំមាសប៉ុនខ្លួនខ្ញុំ ឬស្រីក្រមុំមកតិតមែប ស្មាទាំងសងខាង, បើអ្នករៀនវិជ្ជាគោះភ្លាត់ចំណាប់ បង់ជាខូចស់អស់គោះ ម្យ៉ាងពួកគោះ វាយប៉ះជាក់កស្ងាប់ពុំខាន) ។

កាលមានដំយជំនះហើយ ក្រគើនាគនៃរគោះ កំត្រឡប់ទៅទីលំនៅវិញ ។ លុះនៅយូរបន្តិចទៅ ក្រគើគោះកំពុងតែបញ្ចេះលោកនេន ធ្វើនឹក ស្រាប់តែប្រទះនឹងក្រគើជាបច្ចាមិត្តដដែរទៀតមកបៀតបៀន, នាគនៃរគំតិតថា "ឥឡូវនេះ នឹងទុកលោកនេននៅកន្លែងណា?" ។ រកកន្លែងនឹងទុកគ្មាន នាគនៃរគំលេបលោកនេនចូលទៅក្នុងគោះខ្លួន ហើយគំប្រយុទ្ធនឹងក្រគើជាបច្ចាមិត្ត ។ ក្រគើបច្ចាមិត្តចាញ់ក្រគើ នាគនៃរគេចខ្លួនរត់ចាកទៅ ។

លុះរួចគំប្រយុទ្ធនេះហើយ នាគនៃរគំញុះលោកនេនចេញ ពីគោះតាមមាត់ខ្លួនមកវិញ ឃើញលោកនេននោះសុគត នាគនៃរ គំកើតសេចក្តីសោកស្តាយក្រៃពេក ។

នៅគាសដែលតួគមហាជន កំពុងធ្វើបុណ្យឈាបនកិច្ចលោក សព្វលោកនេននោះ, ក្រគើនាគនៃរគំកំរឡើងទៅដេកលើក្តក់ភ្លើងដែល កំពុងឆេះពេញអំណាច ។ តេជោ ជាតុកំឆេះក្រគើនាគនៃរបង់ដាវគទៅ ។

តាមមានដូច្នេះ ។ របស់ក្រសួងធម្មការ

ការតាំងមន្ត្រីសង្ឃ

តាមព្រះរាជក្រឹត្យលេខ ១៤ ន.ស. ចុះថ្ងៃ ២៩ មីនា ១៩៦១ សម្តេចព្រះនរោត្តម-សីហនុ ឧបយុវរាជ ព្រះប្រមុខរដ្ឋ ទ្រង់សព្វព្រះរាជ-ហឫទ័យតាំងព្រះគ្រូវាដីរបស្សាញ្ញាមុនី ង្ហ-យ៉ែន ជន្មាយុ ៤៣ ឆ្នាំ, វស្សា ២០ ជាឋានានុក្រម នៅវត្តចតុមវតី ក្រុងកំពត ជាទីពាជាគណៈសម្រាប់ចតុគាមនគោរម្យជារាជា « ព្រះនេតមោលី » ជាដំណួសព្រះខេតមោលី ង្ហត-ម៉ាន់ ដែលខ្ចួលអនិច្ចធម្ម ។

ចានតាំងលោកគ្រូ ញ៉ែប-ដៅ ជន្មាយុ ៥១ ឆ្នាំ, វស្សា ៣១ នៅវត្តអន្ទង្ស៊ី ឃុំមៀន ជាព្រះគ្រូវាដីរបស់ អនុគណស្រុកព្រៃឈរ ខេត្តកំពង់ចាម ។

ចានតាំងលោកគ្រូ ច្រាក់-ជន ជន្មាយុ ៥០ ឆ្នាំ, វស្សា ២៨ នៅវត្តជោតនារាម ជាព្រះគ្រូសង្ឃវាមុនី អនុគណស្រុកកំពង់សៀម ខេត្តកំពង់ចាម ។

ចានតាំងលោកគ្រូ ឌេប្រ-លោង ជន្មាយុ ៦៣ ឆ្នាំ, វស្សា ៤៣ នៅវត្តតាំរែកំណាកាម ឃុំតាំងយ៉ាប ជាព្រះគ្រូមន្ត្រីលទ្ធិភូលោកង្ស៊ី មេគណខេត្តតាកែវ ។

ចាន់តាំងលោកគ្រូ សិង្ហ ញាន-ស្នង ជន្មាយុ ៤៩ ឆ្នាំ, វស្សា ២៨ ជាព្រះគ្រូវិសុទ្ធសីលធម្ម មេគណខេត្តកោះកុង ។

ចាន់តាំងលោកគ្រូ ភារ-ង៉ា ជន្មាយុ ៥៣ ឆ្នាំ, វស្សា ៣៦ ជាព្រះគ្រូចៅអធិការវត្តសុគ្គា អនុគណស្រុកកោះកុង ។

ចាន់តាំងលោកគ្រូ សាំង ហួយ ជន្មាយុ ៤៤ ឆ្នាំ, វស្សា ២២ នៅវត្តអរញ្ញាភម លំដាប់ជាព្រះគ្រូធម្មញ្ញាណាចារ មេគណខេត្តតនគីរី ។

ចាន់តាំងលោកគ្រូ ឃេន-សេន ជន្មាយុ ២៥ ឆ្នាំ, វស្សា ៥ នៅវត្តអរញ្ញាភម លំដាប់ជាព្រះចុងត្រាត់ព្រហ្មវិហារមេធី សម្រាប់មេគណខេត្តតនគីរី ។

ចាន់តាំងលោកគ្រូ ចាំង-ចោត ជន្មាយុ ២៦ ឆ្នាំ, វស្សា ៦ នៅវត្តតនងឹ្ក បវរវ ជាព្រះវិន័យធរ សម្រាប់មេគណខេត្តតនគីរី ។

ចាន់តាំងលោកគ្រូ ក្លេន-ចាំង ជន្មាយុ ២៣ ឆ្នាំ, វស្សា ២ នៅវត្តអរញ្ញាភម លំដាប់ជាព្រះសមុហ៍ សម្រាប់មេគណខេត្តតនគីរី ។

ចាន់តាំងលោកគ្រូ ដិ-ស៊ី ជន្មាយុ ២២ ឆ្នាំ, វស្សា ២ នៅវត្តអរញ្ញាភម លំដាប់ជាលេខាធិការ សម្រាប់មេគណខេត្តតនគីរី ។